# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ



សម្ដេចព្រះសង្ឃរាជ ជួន ណាត

ឆ្នាំទី ៤៨ លេខ ១ ខែ មករា - កុម្ភៈ - មីនា

ព.ស ២៥៣៧ គ.ស ១៩៩៤

ភ្នំពេញ

*លោកអ្នកអាន ជាទីមេត្រី,*

ទស្សនាវដ្ដី មានជំនឿមុតមាំថា លោកអ្នកអានមុខជាទទួលស្វាគមន៍ ហើយអានទស្សនាវដ្ដី " *កម្ពុជសុរិយា* " លេខដំបូងនេះ តាំងពីទំព័រដើម រហូតដល់ទំព័របញ្ចប់ ។

លោកអ្នកប្រាកដជាផ្ដោតអារម្មណ៍ត្រិះរិះលើ " កំណាព្យប្រស្នា " របស់ កវី វណ្ណ ស៊ុនហេង, អ្នកតំណាងរាស្ត្រមណ្ឌលព្រៃវែង ។ គួរកត់សំគាល់ជាពតិមានថា ឯកឧត្តម វណ្ណ ស៊ុនហេង នឹងបន្តចុះផ្សាយកំណាព្យប្រស្នាផ្សេងៗទៀត នៅក្នុង "កម្ពុជសុរិយា" រៀងរាល់លេខ ហើយលោកត្រៀមថវិកាផ្ទាល់ខ្លួនចំនួន ២០០.០០០ រៀល សម្រាប់ជូនជ័យលាភីទាំងអស់ ដែលឆ្លើយត្រូវក្នុងលេខនីមួយៗ ចាប់ពីពេលនេះ តទៅ ។ អ្នកអានទាំងឡាយណា ដែលមានបំណងចូលរួមឆ្លើយប្រស្នា ត្រូវផ្ញើចម្លើយទៅ " ពុទ្ធសាសនបណ្ឌិត្យ " ផ្នែកទស្សនាវដ្ដីកម្ពុជសុរិយា ។ គណៈកម្មការមេប្រយោគមួយ នឹងត្រូវបានរៀបចំឡើងដើម្បីពិនិត្យចម្លើយ ហើយនឹងចុះផ្សាយលទ្ធផលនៃចម្លើយចំពោះ " កំណាព្យប្រស្នា " លេខនេះ នៅក្នុងទស្សនាវដ្ដី " កម្ពុជ-សុរិយា " លេខបន្ទាប់ ។ ចម្លើយរបស់លោកអ្នកអានទាំងអស់ ដែលបានទៅដល់ពុទ្ធសាសនបណ្ឌិត្យ នឹងត្រូវបានគណៈកម្មាការមេប្រយោគពិនិត្យ និងរៀបចំចំណាត់ថ្នាក់រង្វាន់ជាទឹកប្រាក់ នឹងប្រគល់ជូនជ័យលាភីណាដែលឆ្លើយត្រូវ ពីលេខ ១ ដល់លេខ ៣ ។

អាស្រ័យហេតុនេះ លោកអ្នកអានទាំងឡាយ ដែលបានចូលរួមឆ្លើយកំណាព្យប្រស្នានេះ សូមប្រញាប់សរសេរផ្ញើទៅពុទ្ធសាសនបណ្ឌិត្យនៃក្រសួងធម្មការ និងសាសនា ដែលមានទីស្នាក់ការនៅវត្តឧណ្ណាលោម ក្រុងភ្នំពេញ ។

កម្ពុជសុរិយា



# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ

ចេញរាល់ត្រីមាស ពី ពុទ្ធសាសនបណ្ឌិត្យ


ចាត់ចែងបោះពុម្ពផ្សាយដោយគណៈកម្មការមួយ មាន ៖

ទីប្រឹក្សា : **ហៀន ចណ្ណារត្ន**

នាយកការផ្សាយ : **ឈន អៀម**

និពន្ធនាយក : **យី ធន់**

និពន្ធនាយករង : **ឱម ខែម**

គណៈកម្មការនិពន្ធ

ព្រះធម្មលិខិត **លាស់ ឡាយ**, ព្រះមហាព្រហ្មមុនី **ហេង លាងហោ**,
លោក **ម៉ែន ឫទ្ធាច**, លោក **អាំ ឆន**,

ごあいさつ

この本は、世界宗教者平和会議日本委員会と曹洞宗国際ボランティア会との共同プロジェクトとして印刷されました。

この本が、日本の宗教者とカンボジアの人々との友情のきずなとなり、カンボジアの宗教と文化の発展に貢献できれば幸いです。

## ACKNOWLEDGEMENT

The Kampuja Surya Magazine is specially printed as a cooperative project of the Japanese Committee of the World Conference on Religion and Peace (WCRP) and Japan Sotoshu Relief Committee (JSRC).

We pray that this magazine would contribute to the Friendship with Cambodian people and their religious and cultural preservation.

## និវេទនកថា

ទស្សនាវដ្ដីកម្ពុជសុរិយានេះ ត្រូវបានបោះពុម្ពឡើងជាពិសេស ទុកដូចជាគម្រោងការងារ របស់គណៈកម្មាធិការជប៉ុននៃក្រុមប្រឹក្សាពិភពលោកស្ដីពីសាសនា និងសន្តិភាព (WCRP) ហើយនិងគណៈកម្មាធិការជំនួយសូតូស៊ូជប៉ុន (JSRC) ។

យើងខ្ញុំអធិដ្ឋាន សូមឱ្យទស្សនាវដ្ដីនេះ បានជាវិភាគទានរក្សាមិត្តភាពជាមួយប្រជាជនកម្ពុជា និងថែរក្សាសម្បត្តិសាសនានិងវប្បធម៌របស់ប្រជាជនកម្ពុជា ។

# សូមថ្វាយព្រះពរ

ក្នុងឱកាសចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំចរ ឆស័ក ព.ស ២៥៣៨ ទូលព្រះបង្គំទាំងឡាយ ជាមន្ត្រីរាជការនៃក្រសួងធម្មការ និងសាសនា ព្រមទាំងគណៈកម្មការនិពន្ធទស្សនាវដ្ដីកម្ពុជសុរិយា សូមថ្វាយព្រះពរ បវរមហាប្រសើរ ចំពោះព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្ដម សីហនុវរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ព្រះបិតានៃអក្សរសាស្ត្រជាតិ និងសម្ដេចព្រះមហេសី **នរោត្ដម មុនិនាថ សីហនុ** សូមព្រះអង្គមានព្រះសុខុមាលភាពល្អបរិបូណ៌ និងព្រះជន្មាយុយឺនយូរ ដើម្បីគង់ជាម្លប់ដ៏ត្រជាក់ សម្រាប់កូនចៅព្រះអង្គ ដរាបរៀងទៅ កុំបីឃ្លៀងឃ្លាតឡើយ !



# មាតិកាអត្ថបទ


I. *អត្ថបទរដ្ឋបាល :*

- និវេទនកថា ស្តីពីការបោះពុម្ពឡើងវិញ ទស្សនាវដ្តីកម្ពុជសុរិយា ______ ១
- សេចក្តីសំរេចរបស់គណៈរដ្ឋមន្ត្រី ស្តីពីការអនុញ្ញាតអោយ បោះពុម្ពឡើងវិញ ទស្សនាវដ្តីកម្ពុជសុរិយា ______ ៣
- សេចក្តីសំរេចរបស់ក្រសួងធម្មការនិងសាសនា ស្តីពីការតែងតាំង គណៈកម្មការទស្សនាវដ្តីកម្ពុជសុរិយា ______ ៤

II. *អក្សរសិល្ប៍ពុទ្ធសាសនា :*

- ព្រះធម៌របស់ព្រះពុទ្ធ ______ ៥
- សិគាលោវាទសូត្រ ______ ២១
- សង្គាយនា ______ ២៩

III. *អក្សរសាស្ត្រទូទៅ និងអក្សរសិល្ប៍ខ្មែរ :*

- ពាក្យសម្បថរបស់មន្ត្រីរាជការក្នុងរាជ្យព្រះបាទសូរ្យវ៌្ម័នទី១ ______ ៣៥
- អ្នកនិពន្ធល្បីៗ ______ ៤២
- ទិដ្ឋភាពខ្លះនៃអក្សរសិល្ប៍ខ្មែរ ______ ៦១
- ល្បើកនគរវត្តរបស់អ្នកប៉ាង ______ ៧៤
- ពាក្យទំនីមទំនៀមខ្មែរ ______ ៨៦
- បុណ្យចូលឆ្នាំខ្មែរ ______ ៩២
- កំណាព្យ : - ពន្លឺកម្ពុជសុរិយា ______ ១០២

- សុភាសិត ________ ១០៣
- ស្តាយកេរចាស់ ________ ១០៤
- កវី អ៊ូ ចុង ________ ១០៦

IV. *កំណត់ និងប្រវត្តិការណ៍ ៖*
- ដើម្បីលើកកំពស់កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ពុទ្ធសាសនា ________ ១០៧
- សេចក្តីអំពាវនាវចំពោះជនរួមជាតិកម្ពុជា ________ ១២០
- កំណាព្យប្រស្នា ________ ១២៣



សម្តេចព្រះសង្ឃរាជ **ជួន ណាត** (ជោតញ្ញាណោ) បានទ្រង់ប្រសូត នៅថ្ងៃអង្គារ ១១ រោច ខែផល្គុណ ឆ្នាំវក (១១. ៣.១៨៨៣) នៅភូមិកំរៀង សង្កាត់រកាកោះ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ, បិតានាម **ជួន** មាតានាម **យក់** ។

ព្រះអង្គទ្រង់ព្រះផ្នួសពីខែឧសភា ១៨៩៧ នៅវត្តពោធិព្រឹក្ស ហៅវត្តពោធិល្វៀ សង្កាត់ រលាំងកែន ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។ សម្តេចទ្រង់ចេះអក្សរ និងភាសាសៀម លាវ បារាំង អង់គ្លេស និងយៀកណាម ។

សម្តេចព្រះសង្ឃរាជ ជួន ណាត (ជោតញ្ញាណោ) ជាអ្នកប្រាជ្ញជាតិមួយអង្គ ទាំងខាងពុទ្ធសាសនា ទាំងខាងអក្សរសាស្ត្រ ដែលបានទទួលព្រះឋានៈជាបណ្ឌិតអក្សរសាស្ត្រ ជាព្រះអគ្គនិពន្ធអក្សរសាស្ត្រខ្មែរ ជាអភិធជមហារដ្ឋគុរុនៃសហរាជភូមា ជាព្រះអគ្គមហាបណ្ឌិត្យនៃសហភាពភូមា ។

ព្រះអង្គទ្រង់សោយព្រះទិវង្គត នៅថ្ងៃទី២៥ កញ្ញា ១៩៦៩ វេលាម៉ោង ២០ និង ២០ នាទី ក្នុងព្រះជន្មវស្សា ៨៦ ឆ្នាំ ។

ព្រះអង្គបានបន្សល់ទុកជាមតិកនូវស្នាព្រះហស្តជាច្រើនដែលពោរពេញដោយឱវាទដ៏មានខ្លឹមសារ សម្រាប់ការប្រតិបត្តិ និងការចេះដឹង ទុកដូចជាប្រទីបបំភ្លឺផ្លូវរបស់យើងគ្រប់ពេលវេលា ។

# និវេទនកថា

នៅដើមឆ្នាំ១៩៩៤ នេះ ទស្សនាវដ្ដី " **កម្ពុជសុរិយា** " ត្រូវបានរស់រាន ចេញមុខបន្តបេសកកម្ម ផ្សព្វផ្សាយចំណេះដឹងផ្នែកសាសនា អក្សរសាស្ត្រ វប្បធម៌ បំរើសាធារណជន ទាំងព្រះសង្ឃ ទាំងគ្រហស្ថ ជាថ្មីឡើងវិញ ក្រោយពេលបានបាត់ឈ្មោះ បាត់សំឡេង អស់ជិតពីរទសវត្ស កន្លងទៅ ។

ជាជំហានដំបូងនេះ ទស្សនាវដ្ដីកម្ពុជសុរិយា នឹងត្រូវចេញផ្សាយប្រចាំត្រីមាស ហើយបើមានលទ្ធភាពក្នុងពេលខាងមុខ នឹងចេញផ្សាយប្រចាំខែវិញ ។ លទ្ធភាពរបស់ទស្សនាវដ្ដីកម្ពុជសុរិយា ពឹងផ្អែកយ៉ាងសំខាន់ លើភាពរីកចំរើន រឹងមាំ របស់ពុទ្ធសាសនបណ្ឌិត្យ ដែលជាមាតាបង្កើតទស្សនាវដ្ដីនេះឡើង ។ ប៉ុន្តែ មាតាបង្កើតពោលគឺ ពុទ្ធសាសនបណ្ឌិត្យ ឥឡូវនេះ កំពុងតែឋិតក្នុងស្ថានភាពពិបាក និង ខ្វះខាតយ៉ាងធំធេងណាស់ដែរ, មិនចាំបាច់និយាយដល់ការពិបាកខាងហិរញ្ញវត្ថុ ខ្វះឯកសារ គម្ពីរដីកា ក្បួនច្បាប់ ខ្វះមន្ត្រីមានសមត្ថភាពបំពេញការងារស្រាវជ្រាវ ជាដើមនោះទេ សូម្បីតែអគារជាទីតាំងធ្វើការងារ, ទីតាំងបណ្ណាល័យ ជារបស់ផងខ្លួន ក៏គ្មានដែរ ។

សព្វថ្ងៃ ពុទ្ធសាសនបណ្ឌិត្យ ឋិតក្នុងវត្តឧណ្ណាលោម ដោយយកអតីតសាលាឆាន់របស់វត្ត ធ្វើជាទីកន្លែងធ្វើការបណ្ដោះអាសន្ន ។ គំរោងចង់ពង្រីកសកម្មភាពការងារ របស់ពុទ្ធសាសនបណ្ឌិត្យអោយបានគ្រប់ផ្នែក ដើម្បីលើកស្ទួយស្ថាប័នអោយ

សក្តិសមជាវិជ្ជាស្ថានមួយ របស់ប្រទេសកម្ពុជា មានមុខងារសិក្សា ស្រាវជ្រាវសាសនា វប្បធម៌ អក្សរសាស្ត្រ ប្រពៃណី ទំនៀមទម្លាប់ជាតិនោះ ក៏ត្រូវជួបឧបសគ្គដែរ បណ្តាលមកពីខ្វះអគារ ខ្វះទីតាំង ដែលអាចអោយដំណើរការងារប្រព្រឹត្តទៅ ដោយនឹងនចិត្ត ប្រកបដោយឯករាជភាព ក្នុងអារម្មណ៍ ។

ទោះបីជាមាតាបង្កើតរបស់ខ្លួន ឋិតក្នុងស្ថានភាពពិបាក និងក្នុងទលិទ្ទភាពដូចបានពណ៌នាខាងលើនេះក្តី ក៏ទស្សនាវដ្តីកម្ពុជសុរិយា នៅតែប្តេជ្ញាចិត្តមោះមុត ពុះពារជំនះរាល់ឧបសគ្គ ដើម្បីពង្រឹង និង ពង្រីកសមត្ថភាពរបស់ខ្លួន សំដៅបន្តបេសកកម្មរបស់បុព្វបុរសជាតិយើង ដែលបានបន្សល់ទុកនូវគតិបណ្ឌិត និង ឧត្តមគតិ ដ៏ល្អប្រសើរ ដើម្បីរួមចំណែកស្តារ និង អភិវឌ្ឍន៍សង្គមជាតិយើងជាថ្មី ទាំងផ្នែកសីលធម៌ ទាំងផ្នែកបញ្ញាស្មារតី និងទាំងផ្នែកជីវភាពសម្ភារៈ ។

គឺនៅក្នុងន័យនេះហើយ ដែលទស្សនាវដ្តីកម្ពុជសុរិយា ត្រូវបានបង្កើតឡើង ទោះបីលទ្ធភាពរបស់ខ្លួនតិច, ប៉ុន្តែបានទទួលការឧបត្ថម្ភដ៏សប្បុរស និងស្មោះស ពីអង្គការជំនួយសូត្តស៊ូជប៉ុន ( JSRC ) និងពីក្រុមប្រឹក្សាពិភពលោក ស្តីពីសាសនា និងសន្តិភាព ( WCRP ) នាជំហានដំបូងនេះ ដើម្បីបំរើសាធារណជន ទាំងព្រះសង្ឃ ទាំងគ្រហស្ថ ក្នុងវិស័យបញ្ញា និងស្មារតី ។

សូមព្រះធម៌ ផ្សព្វផ្សាយសុខសន្តិភាព ជានិរន្តរ៍ មកលើព្រះរាជាណាចក្រកម្ពុជា !

**ឈន អៀម**

នាយកការផ្សាយ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្ដីការនាយករដ្ឋមន្ត្រី

លេខ ៦១៧សជណ.ផក

ភ្នំពេញ, ថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ១៩៩៣

សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការនាយករដ្ឋមន្ត្រី

**ជំរាបមក**

លោករដ្ឋមន្ត្រីក្រសួងធម្មការ និង កិច្ចការសាសនា

**កម្មវត្ថុ** : សំណើសុំគោលការណ៍អនុញ្ញាតបោះពុម្ពផ្សាយទស្សនាវដ្ដី « កម្ពុជា សុរិយា » ។

**យោង** : លិខិតរបស់ក្រសួងធម្មការ និង កិច្ចសាសនា លេខ ៥៦៧.៩៣ កធ.ស ចុះថ្ងៃទី១៥ ខែ កញ្ញា ឆ្នាំ ១៩៩៣ ។

- ចំណារឯកឧត្ដមសហនាយករដ្ឋមន្ត្រី ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ១៩៩៣ ។

តបតាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំសូមជំរាបឯកឧត្ដមថា : រាជរដ្ឋាភិបាលកម្ពុជា បានសំរេចឯកភាពជាគោលការណ៍អោយបោះពុម្ពផ្សាយទស្សនាវដ្ដី កម្ពុជាសុរិយា តាមសំណើរបស់ក្រសួងហើយ ។ ប៉ុន្តែទស្សនាវដ្ដីនេះរកចំណេញខាតដោយខ្លួនឯង បន្ទាប់ពីបានទទួលឧបត្ថម្ភ ពីអង្គការជំនួយ សូតូស៊ូជប៉ុន ( J S R C ) នូវថវិកាដើម្បីបោះពុម្ពក្នុង ឆ្នាំ ១៩៩៤ នេះតទៅ ។

អាស្រ័យហេតុនេះ សូមឯកឧត្ដមជ្រាប និង ទទួលចាត់ចែងអនុវត្តតាមការគួរ ។

ជ. សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការនាយករដ្ឋមន្ត្រី

សហអនុរដ្ឋមន្ត្រី

ស៊ុំ ម៉ានិត ទូច ភានុន

ចម្លងជូន

- ក្រសួងឃោសនាការ

« ដើម្បីជ្រាបជាពត៌មាន »

- កាលប្បវត្តិ - ឯកសារ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធម្មការ និង សាសនា

លេខ : 101/94 កធស.ពប

ភ្នំពេញ, ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៣

# សេចក្តីសំរេច

## ស្តីពីគណៈកម្មការទស្សនាវដ្តីកម្ពុជសុរិយា

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

- បានឃើញព្រះរាជក្រឹត្យព្រះបាទសម្តេចព្រះនរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ស្តីពីការតែងតាំងគណៈរដ្ឋមន្រ្តី ចុះថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣,
- បានឃើញលិខិត លេខ ៤១៧ សជណ.ផក របស់ទីស្តីការនាយករដ្ឋមន្រ្តី ចុះថ្ងៃទី ០៥-១០-៩៣· ស្តីពីការអនុញ្ញាត អោយចេញផ្សាយទស្សនាវដ្តីកម្ពុជសុរិយា,
- បានឃើញសេចក្តីសំរេច ស្តីពីខ្លឹមសារ និង រូបភាពរបស់ទស្សនាវដ្តីកម្ពុជសុរិយា,
- អនុលោមតាមការចាំបាច់របស់ក្រសួង,

## សំរេច

ប្រការ ១ : ក) តែងតាំងឯកឧត្តម ឈន អៀម អោយទទួលជានាយកការផ្សាយនៃទស្សនាវដ្តីកម្ពុជសុរិយា,

ខ) តែងតាំងលោក យី ធន់ ជានិពន្ធនាយកនៃទស្សនាវដ្តីកម្ពុជសុរិយា,

គ) តែងតាំងលោក ឱម ខែម ជានិពន្ធនាយករង នៃទស្សនាវដ្តីកម្ពុជសុរិយា,

ឃ) តែងតាំងព្រះតេជព្រះគុណ ព្រះធម្មលិខិត លាស់ ឡាយ, ព្រះមហាព្រហ្មមុនី ហេង លាងហោ , លោក ម៉ែន ប្រាង និង លោក អាំ ឆន ជាសមាជិកគណៈកម្មការនិពន្ធរបស់ទស្សនាវដ្តីកម្ពុជសុរិយា ។

ប្រការ ២ : ឯកឧត្តម ព្រះតេជព្រះគុណ និង អស់លោកដែលមានចែងក្នុងប្រការ ១ ចំណុច ក. ខ. គ. ត្រូវបំពេញភារកិច្ចថ្មីនេះ បន្ថែមលើភារកិច្ចដែលមានមកហើយ ។

ប្រការ ៣ : លោកនាយកខុទ្ទកាល័យ លោកនាយកពុទ្ធសាសនបណ្ឌិត្យ លោកនាយករដ្ឋបាល និងឯកឧត្តម អស់លោក ដែលមានចែងក្នុងប្រការ ១ ត្រូវអនុវត្តតាមសេចក្តីសំរេចនេះ ចាប់ពីពេលចុះហត្ថលេខា នេះ តទៅ ។

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

ហៀន-វណ្ណារិទ្ធ

ចម្លងជូន :
- ក្រសួងឃោសនាការ " ដើម្បីជ្រាប ជាពត៌មាន "
- គ្រប់នាយកដ្ឋាន " ដើម្បីជ្រាប"
- ដូចក្នុងប្រការ ១ " ដើម្បីអនុវត្ត "
- ដូចក្នុងប្រការ ៣ " ដើម្បីចុះការ"
- ឯកសារ - កាលប្បវត្តិ

# ព្រះធម៌របស់ព្រះពុទ្ធ

ដោយភិក្ខុ (Jagdish Kasyapa)

បកប្រែដោយ **ឈិន អៀម**

នមោ តស្ស ភគវតោ
អរហតោ សម្មាសម្ពុទ្ធស្ស ។

## ជំពូកទីមួយ
## មុនព្រះពុទ្ធកើតមាន

ស្ថានភាពទស្សនវិជ្ជា និងសីលធម៌វិជ្ជារបស់ប្រទេសឥណ្ឌា មុនការកើតមានព្រះពុទ្ធ បានធ្លាក់ក្នុងភាពច្របូកច្របល់ ។

### I. ជំនឿឆ្វេងរបស់ពួកព្រាហ្មណ៍

ពួកព្រាហ្មណ៍បានដឹកនាំប្រជាជនអោយបំពេញពលីកម្មគ្រប់បែបយ៉ាង ដែលគេអោយឈ្មោះថា យជ្ញ ឬ យញ្ញ ។ នៅក្នុងពលីកម្ម គឺការបូជាយញ្ញនេះ គេបានសម្លាប់ពពែ សេះ បសុសត្វ និងសត្វឯទៀតៗ ជាចំនួនច្រើន ដើម្បីថ្វាយពលីការដល់ទេវៈផ្សេងៗ តាមគម្ពីរវេទ, សូម្បីមនុស្ស ក៏ជួនកាលត្រូវគេសម្លាប់ ហើយបោះទៅក្នុងភ្លើងដ៏ពិសិដ្ឋដែរ ។

ពួកអ្នកដែលបានបំពេញពិធីបូជាយញ្ញនោះៗ ត្រូវបានពួកអ្នកបួសបោកប្រាស ទាំងឡាយ បញ្ចុះបញ្ចូលអោយជឿថា ទេវៈ និងបិសាចផ្សេងៗ គាប់ព្រះទ័យពេញអធ្យាស្រ័យ ហើយផ្តល់មកឱ្យនូវពរសព្ទសាធុការ តាមរយៈតង្វាយទាំងនោះ ។ ដោយសេចក្តីរីករាយយ៉ាងនេះ, ទេវៈទាំងឡាយនោះ បានបាចសាចមកលើអ្នកធ្វើពិធីបូជាយញ្ញ នូវសេចក្តីចំរុងចំរើននៅក្នុងលោកនេះ ហើយនាំគេទាំងនោះទៅកាន់ស្ថានសួគ៌ ក្រោយពេលគេស្លាប់ទៅ ។

ដំបូង មហាជនល្ងង់ខ្លៅ បានជឿក្នុងការគោរពប្រតិបត្តិជំនឿឆ្វេង និងងងឹតងងល់ទាំងនោះ ហើយការប្រតិបត្តិទាំងនោះ ត្រូវបានមនុស្សគ្រប់រូបប្រព្រឹត្តកាន់តាម ចាប់ពីមនុស្សក្រីក្របំផុត រហូតដល់ស្តេច ។ ពិធីបូជាយញ្ញ ត្រូវបានក្លាយទៅជាពិធីធម្មតា នៅក្នុងប្រទេសឥណ្ឌា ហើយឈាមសត្វ មនុស្ស ត្រូវបានហូរយ៉ាងច្រើនរៀងរាល់ថ្ងៃ ក្នុងនាមសាសនា ។

ប៉ុន្តែ បន្តិចម្តងៗ មនុស្សទាំងឡាយចាប់ផ្តើមសង្ស័យអំពីតម្លៃនៃពិធីបូជាយញ្ញទាំងនោះ, ពីព្រោះ គេបានសន្និដ្ឋានឃើញថា គេពុំបានឃើញមានសភាពប្លែកសោះនៅក្នុងវឌ្ឍនភាពរបស់ប្រជាជន ។ មនុស្សបានងើបឡើងប្រឆាំង ហើយបោះបង់ចោលអាជ្ញារបស់ពួកព្រាហ្មណ៍ ហើយនាំគ្នាសាកល្បងកសាងទស្សនវិជ្ជា និងសីលធម៌របស់ខ្លួន លើខ្សែបន្ទាត់មួយឯករាជ ។

## II. សម្ភារនិយមរបស់ពួកចរិកៈ (Carvakas)

ក្នុងចំណោមមនុស្សទាំងនោះ, មានមុនគេគឺ ពួកចរិកៈ ដែលមិនជឿថាមានជីវិតមួយទៀត ក្រោយពេលស្លាប់, ទោះជានៅស្ថានសួគ៌, នៅស្ថាននរក ឬនៅក្នុងកំណើតថ្មី ។ ពួកគេគឺ ជាអ្នកសម្ភារនិយមដាច់ខាត ។ ចំពោះពួកគេ, មនុស្សកើតតែមួយដង ហើយស្លាប់តែមួយដង ដូចជាអ្វីៗទាំងអស់ ដែលយើងឃើញក្នុង

លោកនេះ ។

ក្រឡ ត្រូវបានស្ទូនផលិតឡើងនៅពេលណាមួយ, នៅពេលនោះ ក្រឡ មានអត្ថិភាពបែបណាមួយ ហើយនៅទីបំផុតត្រូវបែក ហើយបាត់រូបរាងទៅក្នុងពេលជាមួយគ្នា ។ ក្រឡដដែលនោះ មិនមានអត្ថិភាពជាថ្មីវិញឡើយ ។ យ៉ាងដូចម្ដេចមិញ, មនុស្សម្នាក់កើតឡើងនៅត្រង់ចំណុចពេលណាមួយ, រស់នៅអស់មួយរយៈពេល ហើយបន្ទាប់មក ក៏ស្លាប់ និងបាត់ខ្លួនជារៀងរហូតទៅ ។ មនុស្សដដែលនោះ មិនត្រឡប់រស់រានជាថ្មីវិញឡើយ ។ បុណ្យកុសលដ៏ខ្ពស់ៗ របស់យើង ឬអំពើអកុសលរបស់យើង ក៏ត្រូវបានបញ្ចប់ជាមួយមរណភាពរបស់យើងដែរ ពីព្រោះបន្ទាប់មក យើងក៏ឈប់មានអត្ថិភាពទៀតហើយ ។

ទស្សនាទានស្ដីពីអត្ថិភាពនេះ បាននាំដោយឯកឯងទៅកាន់ឧត្ដមគតិកាមសុខនិយម (Idéal hédoniste) ៖ ស៊ី ផឹក និងរស់នៅសប្បាយ ។ កាលបើវាគ្មានអ្វីសោះ បន្ទាប់ពីជីវិតនេះទៅទេ តើព្រោះហេតុអ្វី គេត្រូវមានសប្បុរសធម៌ ឬគេត្រូវបំពេញកុសលកម្ម នាំអោយអាក់ខានដល់សេចក្ដីសប្បាយរីករាយផ្ទាល់ខ្លួនគេធ្វើអ្វី ។ ហេតុនេះ វាគ្មានសីលធម៌អ្វីទេ ។ ចាប់យកសេចក្ដីសប្បាយអោយបានច្រើនបំផុត តាមតែអាចធ្វើទៅបាន នោះគឺជាដំណោះស្រាយ ដ៏ប្រសើរ ។

ទស្សនវិទូ ដ៏ស្រេកឃ្លានសេចក្ដីសប្បាយទាំងនោះ បានជះឥទ្ធិពលយ៉ាងធំធេងទៅលើសាវ័កដ៏ល្ងិតល្ងង់របស់គេ ហើយមានមនុស្សជាច្រើនក្រុម បានរស់នៅដោយប្រព្រឹត្តយ៉ាងចំហនូវបាបកម្មគ្រប់បែបយ៉ាង ។ ពួកគេបាននាំសីលធម៌សង្គម មកដល់ចំណុចមួយយ៉ាងទាប ទាល់តែជីវភាពមនុស្ស និងសន្តិសុខ ត្រូវបានគំរាមកំហែង ។

នេះគឺជា *អច្ចន្តធម៌* មួយ (Cela était l' un des extrêmes) ។

## III. តបះនិយម :

ចំណុចទីពីរ, គេឃើញមានអច្ឆេរ្តធមិមួយទៀតគឺ ពួកទស្សនវិទូតបះនិយម ហៅថា *តិត្ថីយ* ។ ពួកគេបានយល់អំពីគ្រោះថ្នាក់នៃការស្វែងរកសេចក្តីសប្បាយ ទុកជាបន្ទាត់នៃការប្រព្រឹត្ត ហើយគេបានសាកល្បងបង្កើតឧត្តមគតិ សីលធមិ ដ៏ប្រសើរមួយ ។

ផ្ទុយពីពួក *ចវិកៈ* ដែលមិនជឿថាមានជីវិតអនាគត, ពួកនេះបានជឿថា មានអាត្មន ដ៏រីករាយ និងអចិន្ត្រៃយ៍មួយ ដែលកើតហើយកើតទៀត នៅក្នុងរូបកាយខុសៗពីគ្នា ឬជឿថា ព្រលឹង ឬ អាត្មនអន្ទោលពីរូបកាយមនុស្ស ទៅក្នុងរូបកាយសត្វនៃប្រភេទមួយ ផ្សេងទៀត ។ " អាត្មាដ៏ពិត " របស់យើង មាននៅក្នុងព្រលឹង ឬអាត្មននេះ ។ រូបកាយរបស់យើង, អង្គវិញ្ញាណរបស់យើង ឋិតនៅក្រៅពីយើង ពីព្រោះ វាពុំមែនជាព្រលឹង ឬ អាត្មនទេ ។ ព្រលឹងកើតហើយកើតទៀត ហើយព្រោះហេតុនេះ ត្រូវរងវេទនា ពីព្រោះព្រលឹងនេះ ឋិតក្រោមការគ្របដណ្តប់នៃរូបកាយ និង អង្គវិញ្ញាណរបស់យើង នាំយើងទៅរកបំណងអាក្រក់ក្នុងលោក ហើយធ្វើអោយយើងប្រព្រឹត្តបាបកម្មដ៏ច្រើន ហើយព្រោះតែយ៉ាងនេះ យើងក្លាយទៅជាមនុស្សមានទោស និង ត្រូវរងទុក្ខវេទនា ។

តាមពួកគេ សុភមង្គលដ៏ពិត គឺឋិតក្នុងការកំទេចអោយសូន្យនូវរូប និងវិញ្ញាណ ដែលឋិតនៅក្រៅពីព្រលឹងរបស់យើង ដែលព្រលឹងខ្លួនឯងនេះ គឺជាសុភមង្គលពីកំណើត ។ ដោយហេតុនេះ ពួកគេនោះ ប្រឌិតបង្កើតឡើងនូវមធ្យោបាយផ្សេងៗ សំរាប់ធ្វើអោយវិញ្ញាណរបស់គេស្រងាប់ទៅ ហើយអសកម្ម ។

ពួកគេ បានបង្អត់អាហារអស់ពេលជាច្រើនថ្ងៃ ឬ រស់នៅដោយបរិភោគតែស្មៅ និង សំបកឈើ, ដើម្បីរំលត់ភ្លើងតណ្ហានៅក្នុងឈាមរបស់ពួកគេ ។ បើយើងរស់នៅក្នុងសង្គម ហើយបើយើងនិយាយទៅកាន់មនុស្សដទៃទៀត យើង

អាចនិយាយពាក្យកុហក ព្រោះហេតុនោះហើយ ទើបពួកគេបិតនៅស្ងៀម មិននិយាយស្ដីអស់ពេលរាប់ឆ្នាំ ឬក៏ អស់មួយជីវិតរបស់គេតែម្ដង ។ ពួកគេគ្របដណ្ដប់កាយដោយសម្លៀកបំពាក់គ្រោតគ្រាតបំផុត ហើយចាក់បន្លាលើរូបកាយ ដើម្បីយកឈ្នះលើផស្សារម្មណ៍ ។ ដោយប្រការនេះ, គេបានអនុវត្តវិធីធ្វើទារុណកម្មមកលើខ្លួនគេ តាមមធ្យោបាយផ្សេងៗ ដើម្បីបន្សាត់បង់រូបកាយ ហើយទទួលយកនូវធម្មជាតិរីករាយនៃអាត្មន ។

នេះគឺជា *អច្ចន្តភាព* មួយទៀត របស់បណ្ដាទស្សនវិទូ, ដែលមិនសមហេតុផល អន់ជាងអច្ចន្តភាពរបស់ពួក *ចរិកៈ* ប៉ុន្មានដែរ ។

ទស្សនវិជ្ជាទាំងពីរប្រភេទនេះ បានបង្វិលចក្រនៃសង្គម ឬមួយឆ្ពោះទៅរកអសីលធម៌ ឬមួយឆ្ពោះទៅរកការប្រតិបត្តិឥតន័យ ។

# ជំពូកទីពីរ

## ព្រះអង្គម្ចាស់សិទ្ធថ៌ (សិទ្ធត្ថ)

## អំពីប្រសូត

កាលពីពេលជាង៥០០ឆ្នាំ មុនការប្រសូតនៃព្រះគ្រីស្ដ, មានព្រះរាជាមួយអង្គព្រះនាមសុទ្ធោទនៈ ទ្រង់គ្រងរាជសម្បត្តិលើព្រះរាជាណាចក្រ នៃពួកសាក្យៈដែលតាំងនៅលើជាយដែននៃប្រទេសនេប៉ាល់ ។ ព្រះក្សត្រិយានី ព្រះនាមមហាមាយាទេវី គឺជាក្សត្រីប្រកបដោយគុណធម៌ ហើយបំពេញតែអំពើជាកុសល ។ ពេលមួយនោះ ព្រះក្សត្រីជាមួយព្រះរាជបរិពារ បានយាងទៅក្រសាលឧទ្យានលុម្ពិនី ។ នៅក្នុងឧទ្យាននោះ, ក្រោមម្លប់សាលព្រឹក្ស, ព្រះនាងបានប្រសូតព្រះរាជបុត្រមួយ

អង្គដ៏ល្អផូរផង់ ។ ព្រះក្សត្រីមហាមាយា ទ្រង់យាងត្រឡប់ចូលក្នុងរាជធានីកបិល-វត្ថុវិញ ហើយពិធីបុណ្យដ៏ធំ ក៏ត្រូវបានរៀបចំឡើង ដើម្បីអបអរសាទរទទួលព្រះកំណើតនៃរជ្ជទាយាទរបស់ព្រះរាជា ។

## ទំនាយរបស់មហាឫសី អសីតៈ

ពេលដែលមហាឫសីអសីតៈ បានឮគេប្រកាសអំពីការប្រសូតនៃរាជ-បុត្រ, លោកក៏ធ្វើដំណើរយ៉ាងប្រញាប់ ទៅកាន់ព្រះរាជដំណាក់ ហើយសុំមើលព្រះរាជបុត្រ ។ ព្រះរាជាទ្រង់នាំយកព្រះរាជឱរសចេញមកផ្ទាល់ព្រះអង្គឯង ហើយតាបសក៏លំឱនកាយគោរពយ៉ាងជ្រាលជ្រៅ នៅចំពោះមុខព្រះរាជឱរស ។ តាបសបានគន់គូរមើលសញ្ញានក្ខត្តឫក្ស ហើយក៏ប្រកាសថា ព្រះរាជឱរសនឹងបានត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធ ហើយបង្ហាញដល់ពិភពលោក នូវផ្លូវរំដោះផុតទុក្ខវេទនា នៃផែនដីនេះ ។

ព្រះក្សត្រីមហាមាយា ទ្រង់បានសោយព្រះពិរាល័យ ក្រោយការប្រសូតរាជបុត្របានមួយសប្តាហ៍ ។

ប៉ុន្តែ ព្រះរាជាទ្រង់មានទុក្ខយ៉ាងក្រៀមក្រំនៅក្នុងព្រះហឫទ័យ ក្នុងឋានៈព្រះអង្គជាព្រះបិតា ដោយទ្រង់បានជ្រាបថា បុត្ររបស់ព្រះអង្គ ត្រូវបោះបង់គ្រហា-វាស ហើយក្លាយទៅជាសមណៈមួយអង្គ ។ ព្រះអង្គទ្រង់ហ៊ុំព័ទ្ធព្រះរាជបុត្រ ដោយប្រណីតភាពដ៏ប្រសើរបំផុត របស់រាជវាំង ។ ប្រាសាទ និងឧទ្យានដ៏ឆើតរុងរឿង ត្រូវបានដាក់អោយប្រើប្រាស់សំរាប់ជាព្រះរាជដំណាក់ ដែលមានតែយុវនារីល្អៗប៉ុណ្ណោះ ត្រូវបានអនុញ្ញាតអោយចូល ហើយគាល់បំរើព្រះអង្គម្ចាស់ ។

ព្រះរាជគ្រូដែលមានចំណេះវិជ្ជាជ្រៅជ្រះ ត្រូវបានប្រគល់ភារកិច្ចអោយបង្រៀនព្រះអង្គម្ចាស់ ។ ដោយមានទេពកោសល្យ និងបញ្ញា ញាណដ៏អស្ចារ្យ ព្រះ

អង្គម្ចាស់សិទ្ធថ បានឈាត់ហ្វឹកហ្វឺនយ៉ាងសុក្រឹតក្នុងគ្រប់មុខវិជ្ជា និង សិល្បៈទាំងអស់, លើសព្រះរាជគ្រូ ដែលជាអ្នកមកបង្រៀនព្រះអង្គ ទៅទៀត ។

លុះដល់ព្រះអង្គម្ចាស់មានព្រះជន្មាយុជិតគម្រប់ ១៩ វស្សា, ព្រះរាជាទ្រង់បានរៀបអាពាហ៍ពិពាហ៍ព្រះអង្គម្ចាស់ ជាមួយព្រះអង្គម្ចាស់ក្សត្រី យ សោ ធ រា ។ សភាពការណ៍នេះ បានធ្វើអោយព្រះរាជាស្ងប់ហឫទ័យ, ពីព្រោះ ព្រះអង្គទ្រង់ព្រះតម្រិះថា ព្រះអង្គម្ចាស់ នឹងមិនក្លាយជាសមណៈបានឡើយ, ដោយហេតុថា ព្រះអង្គម្ចាស់ ត្រូវបានជាប់ជំពាក់ក្នុងលោកនេះ ដោយចំណងអាពាហ៍ពិពាហ៍ហើយ ។

## ព្រះសិទ្ធថជួបមនុស្សជរា, មនុស្សព្យាធិ និង មនុស្សស្លាប់

ថ្ងៃមួយ, ព្រះអង្គម្ចាស់ទ្រង់មានព្រះរាជបំណងចេញទៅក្នុងទីក្រុង ដើម្បីទតមើលជីវភាពប្រជាជន ។ ព្រះរាជរថទាំងឡាយ ត្រូវបានគេបញ្ជាអោយតុបតែងយ៉ាងល្អ ហើយឆន្នៈ ជានាយសារថីនៃព្រះរាជរថ ក៏បានដឹកនាំព្រះអង្គម្ចាស់ចេញទៅ។

មិនទាន់ទាំងបានយាងទៅឆ្ងាយពីក្លោងទ្វារទីក្រុងប៉ុន្មានផង, ស្រាប់តែព្រះអង្គបានទតឃើញមនុស្សចាស់ម្នាក់ ដែលគ្រាំគ្រាបំផុត នៅលើចិញ្ចើមផ្លូវ ។ មនុស្សនោះ មានខ្នងកោងដោយវ័យជរា, សក់ក្បាលសសំពោង ភ្នែកងងឹតមើលអ្វីមិនឃើញ រាងកាយស្គមកំព្រឹង ពិការ ញ័រទទ្រើក មានដៃកាន់ឈើច្រត់ទប់ខ្លួន ។

- ព្រះអង្គម្ចាស់ឆ្ងល់ជាខ្លាំង ក៏ទ្រង់សួរថាៈ អ្នកណាហ្នឹង? តើគេកើតអ្វី?

- ឆន្នៈ បានក្រាបបង្គំទូលថា : នេះគឺជាមនុស្សជរា គាត់ធ្លាក់ទៅជាមនុស្សទន់ខ្សោយណាស់ ។ អវយវៈរបស់គាត់ឥឡូវនេះ រេចរឹលដោយវ័យហើយ

គាត់នឹងស្លាប់បន្តិចទៀតនេះ ។

- ព្រះអង្គម្ចាស់ទ្រង់សួរតបថាៈ តើអាត្មាអញនឹងទៅជាមនុស្សចាស់ម្នាក់ ហើយនឹងត្រូវស្លាប់ ដូចគាត់ដែរឬ ?

- ឆន្នៈ ឆ្លើយតបថា ៖ ក្រាបបង្គំទូល មែនហើយ មនុស្សគ្រប់រូបដែល កើតមកហើយ ពិតជាត្រូវក្លាយទៅជាចាស់ ហើយឆ្ពោះទៅរកមរណភាព ។ មរណ-ភាព មិនដែលលោះលែងអ្នកណាម្នាក់ឡើយ, ទាំងអ្នកក្រ ទាំងព្រះរាជា ។

នេះជាហេតុការណ៍គ្រប់គ្រាន់ ដែលធ្វើអោយព្រះអង្គម្ចាស់ ទ្រង់បាន យល់នូវតថភាពនៃលោកនេះ ។ ព្រះអង្គម្ចាស់ទ្រង់ព្រះតម្រិះថា ៖ " គឺជាពួកឆ្កួត, ពួក អ្នកដែលខំរត់តាមសេចក្ដីស្រើបស្រាលនៃលោកនេះ នៅពេលដែលពួកគេយល់ ច្បាស់ថា សេចក្ដីស្រើបស្រាលទាំងនេះ គ្រាន់តែជាសភាវៈបណ្ដោះអាសន្ន ។ ទ្រព្យ សម្បត្តិ រាជអំណាច, មហាប្រាសាទ, ស្ត្រីល្អៗ ពោរពេញដោយស្នេហា គឺគ្រាន់ តែជាការសំញ៉ែងអោយឃើញមួយខណៈ, ជាស្រមោល ដែលនៅក្នុងនេះ មនុស្ស វង្វេងអិលវល់ដូចកូនក្មេងឥតដឹងក្ដី ហើយដល់ស្រមោលនោះកន្លងផុតទៅ ក៏បន្សល់ ទុកមនុស្សនោះ នៅខំយំស្រែក ហើយសោកសៅ " ។ មនុស្សទាំងឡាយ ខំរត់ តាមចាប់យកសេចក្ដីស្រើបស្រាលដោយងងឹតងងល់, ប៉ុន្តែ នៅទីបំផុតនៃការរត់ នេះ ក៏ធ្លាក់ចូលក្នុងជ្រោះជ្រៅ ដែលមនុស្សទាំងនោះ ទទួលរងនូវសេចក្ដីព្រួយ កង្វល់រាប់ ពាន់ជំពូក ។ អ្វីៗទាំងអស់ គឺជាអនិច្ចំ ( ឬបណ្ដោះអាសន្ន ) និង ទុក្ខំ ( ឬ សេចក្ដីឈឺចាប់ ) ។

ព្រះរាជាទ្រង់មានហឫទ័យកង្វល់ណាស់ កាលបើព្រះអង្គទ្រង់បានជ្រាប អំពីរឿងនេះ ។ ព្រះអង្គបានចេញបញ្ជាថា នៅពេលអនាគត ត្រូវតែប្រកាន់យកការ ប្រុងប្រយ័ត្នគ្រប់បែបយ៉ាង ដើម្បីកុំអោយព្រះអង្គម្ចាស់អាចទតឃើញរូបភាពបែប ហ្នឹងទៀត ដែលនឹងដាស់មនោគតិ និងការស្អប់ខ្ពើមរបស់ព្រះអង្គ ។ ទោះបីមាន

ការថែទាំ និង ការប្រុងប្រយ័ត្នរបស់រាជបរិពារតឹងរ៉ឹងដូចម្តេចក្តី, ព្រះអង្គម្ចាស់នៅក្នុងព្រះរាជដំណើរកំសាន្តផ្សេងទៀត ទ្រង់បានជួបជនព្យាធិម្នាក់ ជនមរណៈម្នាក់ ហើយព្រះអង្គក៏បង្កើតបាននូវសកលភាព ( ពោលគឺ ការយល់ដឹងបានគ្រប់ជ្រុងជ្រោយ ) អំពីទុក្ខៈយ៉ាងរឹងមាំជាងពេលណាៗ ទាំងអស់ ។

ព្រះបាទសុទ្ធោទនៈ ទ្រង់ព្រួយហឫទ័យខ្លាំងណាស់ ដោយហេតុព្រះអង្គម្ចាស់បានទតឃើញសញ្ញាទាំងអស់នោះ ដែលនឹងបង្វែរព្រះអង្គពីលោកនេះឆ្ពោះទៅរកជីវភាពជាសមណៈ រស់នៅម្នាក់ឯង ។

## ព្រះសិទ្ធថជួបបព្វជិតមួយអង្គ ដែលគ្មានទីលំនៅជាប់លាប់

រយៈពេល ៤ ខែក្រោយមក ព្រះអង្គម្ចាស់សិទ្ធថ មានព្រះរាជបំណងចង់ចេញទៅខាងក្រៅទៀត ដូចពីមុន ។ ទោះបីព្រះរាជាបារម្ភចំពោះការចេញដំណើរទៅខាងក្រៅទាំងនោះក្តី, ព្រះអង្គក៏នៅតែទ្រង់ប្រទានសេចក្តីអនុញ្ញាតជាលើកទី ៤ ដោយសេចក្តីទើសទាល់, ពីព្រោះព្រះអង្គមិនចង់អោយមានទំនាស់ចំពោះបុត្ររបស់ព្រះអង្គ ដោយប្រការណាមួយឡើយ ។

គេបានប្រុងប្រយ័ត្នកាន់តែតឹងរ៉ឹង ដើម្បីកុំអោយព្រះអង្គម្ចាស់ទតឃើញអ្វីដែលអាក្រក់នោះ ។

លើកនេះ, ព្រះអង្គម្ចាស់ទ្រង់បានជួបបព្វជិតមួយអង្គ ដែលស្លៀកដណ្តប់សំពត់ពណ៌លឿង, កាន់បាត្រសុំទាននៅដៃ ប្រកបដោយទិដ្ឋភាពស្ងប់ស្ងៀមយ៉ាងសុក្រឹត ។ ព្រះអង្គម្ចាស់ពុំធ្លាប់ដែលឃើញទឹកមុខស្រស់បស់ និងគួរអោយស្រឡាញ់ដូចនេះពីមុនសោះ ។ ព្រះអង្គក៏ឈប់ ហើយមានបន្ទូលសួរ ដោយចង់ដឹងថា :

- ម្នាលឆន្នៈ, មនុស្សនោះជាអ្វី ? ខ្ញុំសព្វព្រះទ័យចង់ស្គាល់គេណាស់ ។

រាជរថ ក៏ឈប់ស្ងៀម ។ បព្វជិតនោះ ក៏ចូលមកជិតព្រះអង្គម្ចាស់ ។ ដោយមានឋាមពល និងសេចក្ដីថ្លៃថ្នូរ ដ៏ចម្លែក លោកបានបន្លឺវាចាថា :

- ព្រះអង្គម្ចាស់, អាត្មាភាពជាបព្វជិត, ជាបុគ្គលម្នាក់ឯង ។ ដោយឃើញលោកនេះ ពោរពេញដោយសេចក្ដីទុក្ខ, អាត្មាភាពបានចាកចោលលោកនេះ ហើយខិតខំស្វែងរកសច្ចធម៌ និងសេចក្ដីសុខក្សេមក្សាន្ត ។

លុះបានពោលពាក្យនេះហើយ លោកក៏និមន្តចេញបាត់ទៅ ។

ព្រះសិទ្ធថ ទ្រង់យល់ហេតុការណ៍ដ៏ពិតប្រាកដ ដែលធ្វើអោយព្រះអង្គទទួលនូវសុខារម្មណ៍ ពួដ៏ផ្ដេក្នុង ។

## ក្រុមស្ត្រីរបាំ

ជាទម្លាប់, នៅពេលល្ងាច ក្រុមស្ត្រីរបាំតែងមករាំថ្វាយព្រះអង្គម្ចាស់កំសាន្ត ។ ស្ត្រីរបាំទាំងនោះ ប្រគំភ្លេងគ្រប់បែប, ច្រៀងបទស្រទន់ ពិរោះៗ និងរាំរបាំដ៏ល្អៗ ។ ព្រះអង្គម្ចាស់សិទ្ធថ ទ្រង់ព្រះសណ្ដាប់ និងទតស្ត្រីទាំងនោះ, ប៉ុន្តែព្រះអង្គគ្មានពេលណាមួយងាកចេញពីព្រះតម្រិះ ដែលព្រះអង្គបានជាប់ជំពាក់ព្រះទ័យនៅល្ងាចនោះទេ ។ ព្រះអង្គបានផ្ទង់ព្រះទ័យមកក្នុងព្រះកាយព្រះអង្គឯង ។ ព្រះអង្គបានផ្ទំនៅលើទែនសយនា ។ ស្ត្រីទាំងឡាយ ក៏បញ្ឈប់ភ្លេង ចំរៀង និងរបាំរបស់គេ ហើយក៏នាំគ្នាអង្គុយសំរាក ។ យប់កាន់តែជ្រៅ ឯស្ត្រីរបាំទាំងនោះ ក៏ទម្រេតកាយ ហើយក៏ចាប់ផ្ដើមដេកលក់ ។

នៅពេលកណ្ដាលអធ្រាត្រ ព្រះអង្គម្ចាស់ទ្រង់តើនឡើង ។ ចង្កៀងទាំងឡាយ នៅឆេះភ្លឺនៅឡើយ, ព្រះអង្គទ្រង់បើកព្រះនេត្រទតមើលជុំវិញព្រះអង្គ ។

តើព្រះអង្គទតឃើញអ្វី ? ស្ត្រីរបាំទាំងឡាយ ដេកលក់ច្រងេងច្រងាង ហាក់បីដូចជាសាកសព ។ ស្ត្រីរបាំខ្លះ មានភ្នែកបើក, ខ្លះទៀត មានភ្នែកបិទពាក់កណ្តាល ហើយពិបាកមើលណាស់ ។ ទឹកមាត់ហូរចេញពីមាត់ស្ត្រីខ្លះ, ច្រមុះស្រមុកឮសូរងឺល សំពត់ស្លៀកដណ្តប់ របូត លាត់ សើយ, ស្ត្រីខ្លះទៀត សង្កៀតធ្មេញ, ខ្លះទៀត មមើមមាយ និយាយងុំៗ ពួកគេទាំងអស់ បង្ហាញអោយឃើញនូវទិដ្ឋភាពដ៏អាណោចអធម ។ ចំពោះទស្សនៈព្រះសិទ្ធថ ទ្រង់ទតឃើញដូចជាទីស្មសាន ។

## មហាបរិច្ចាគ

ព្រះអង្គម្ចាស់សិទ្ធថ ទ្រង់តើនឡើង ហើយក៏ទ្រង់យាងចេញទៅ ។ ព្រះអង្គទ្រង់យាងចេញដោយស្ងាត់ស្ងៀម ទៅដាស់នាយសារថីឆន្នៈ ហើយមានបន្ទូលថា :

- ចូរអ្នករៀបចំអាជានេយ្យរបស់ខ្ញុំភ្លាម, ខ្ញុំនឹងយាងទៅឥឡូវនេះ ។

ភ្លាមនោះ ឆន្នៈ ក៏ដើរតម្រង់ទៅកាន់ក្រោលសេះ ហើយដាក់ និងចងកែបលើខ្នងសេះឈ្មោះ *កន្ថកៈ* យ៉ាងប្រញាប់ ហើយនាំសេះនោះមកភ្លាម ។

ព្រះអង្គម្ចាស់ ទ្រង់ឡើងគង់លើខ្នងសេះ ហើយទ្រង់យាងចេញដោយស្ងាត់ស្ងៀមអំពីទីក្រុង ។ អស់ពេលមួយរាត្រី, ព្រះអង្គបានបំផាយអាជានេយ្យយាងទៅយ៉ាងសៃនឆ្ងាយ ។ ព្រះអង្គបានយាងឆ្លងស្ទឹងអនោមា, បានបោះបង់ចោលគ្រឿងអលង្ការ, ព្រះខ័ន អម្ពរភស្ត្រាររបស់ព្រះអង្គ, ទ្រង់បានកាត់ព្រះកេសាដ៏វែងរបស់ព្រះអង្គ, ទ្រង់ស្លៀកដណ្តប់សំពត់ស្បង់ ហើយកាន់បាត្រ រួចចូលទៅក្នុងព្រៃជ្រៅ ស្វែងរកសច្ចធម៌ និងភាពសុខក្សេមក្សាន្ត ។

## ស្នួមដ៏អាថិកំបាំងម្នាក់នៅក្នុងវិថីនានានៃក្រុងរាជគ្រឹះ

ព្រះអង្គទ្រង់បានគង់នៅអស់ពេលមួយសប្តាហ៍ក្នុងដង្ហំព្រៃស្វាយ ( លុម្ព-វ័ន ) នៃអនុបិយៈ ជិតស្ទឹងអនោមា ។ ព្រះអង្គទ្រង់សោយសុខារម្មណ៍ដ៏ពេញលេញដោយព្រះអង្គមានសេរីភាព ហើយពុំមានចំណងនៃលោក ដើម្បីរារាំងផ្លូវព្រះអង្គឡើយ ។ បន្ទាប់មក ព្រះអង្គបានយាងចូលក្រុងរាជគ្រឹះ, ជារាជធានីនៃព្រះរាជា-ណាចក្រ ដ៏ខ្លាំងពូកែនៃរដ្ឋមគធៈ, ដែលមានព្រះរាជាពិម្ពិសារគ្រងរាជ្យ ។

នៅពេលព្រះសិទ្ធថ យាងទៅតាមវិថីនានានៃក្រុងរាជគ្រឹះ, ទោះបីព្រះអង្គស្លៀកដណ្តប់សំពត់ ដ៏ក្រខ្សត់នៃអ្នកដើរចច្រប់ក្តី, ក៏ទឹកព្រះភក្ត្រប្រកបដោយសិរីវិលាស ហើយនិងដំណើរយាងយាសរបស់ព្រះអង្គ បានទាក់ទាញចិត្តមនុស្សម្នាអោយរត់មកពីទីឆ្ងាយជិត ចោមរោមមើលព្រះអង្គ ។ ការរំជើបរំជួល បានកើតមានពេញទីក្រុងទាំងមូល ៖ អ្នកប្រាជ្ញដ៏អស្ចារ្យមួយរូប ទើបឃើញមកដល់ !

## តង្វាយរបស់ព្រះបាទពិម្ពិសារ

ព្រះបាទពិម្ពិសារ ទ្រង់ព្រះសណ្តាប់គេនិយាយអំពីការឃើញនេះ ទ្រង់ក៏មានព្រះទ័យចង់ស្គាល់ ថាតើអ្នកប្រាជ្ញនោះ ជាអ្នកណា ហើយតើលោកមានគំរោងនឹងធ្វើអ្វី ។ ព្រះអង្គក៏ទ្រង់យាងចេញតែមួយអង្គឯង ដើម្បីឃើញស្នួមដ៏អាថិកំបាំង ហើយទ្រង់ក៏ជាប់អារម្មណ៍នឹងបុគ្គលិកលក្ខណៈ របស់ស្នួមនោះដែរ ។

លុះទ្រង់បានស្គាល់ជាតិកំណើតដ៏ខ្ពស់ និងចំណង់ដ៏ឧត្តុង្គឧត្តមរបស់ព្រះសិទ្ធថហើយ, ព្រះបាទពិម្ពិសារទ្រង់ស្ងប់ស្ងែងយ៉ាងខ្លាំង រហូតដល់ព្រះអង្គស្ម័គ្រព្រះទ័យរំលែកព្រះរាជអាណាចក្រថ្វាយព្រះសិទ្ធថ ។ ព្រះបាទពិម្ពិសារ ទូលសុំដោយសេចក្តីស្រឡាញ់ចំពោះព្រះសិទ្ធថ អោយព្រមលះបង់គំរោងការរបស់ព្រះអង្គ

ហើយស្ងមគង់នៅជាមួយព្រះអង្គវិញក្នុងប្រណីតភាព និងភាពសម្បូរ រុងរឿង ។ ប៉ុន្តែ គ្មានការប៉ុនប៉ងណាមួយនៃលោកនេះ អាចបង្វែរព្រះសិទ្ធថ អំពីការស្វែងរករបស់ព្រះអង្គបានឡើយ ។ ព្រះសិទ្ធថ ទ្រង់បានបដិសេធតង្វាយរបស់ព្រះរាជាដោយវាចាដ៏ទន់ភ្លន់, ប៉ុន្តែប្រកបទៅដោយឆន្ទៈមោះមុត ឥតកែប្រែបាន ។

នាពេលនោះ ព្រះសិទ្ធថ បានសាកល្បងចូលទៅសិក្សា ជាមួយគ្រូអាចារ្យផ្សេង១ ប៉ុន្តែ មិនអាចបំពេញព្រះរាជបំណងបាន ដោយការប្រៀនប្រដៅរបស់គ្រូអាចារ្យណាមួយឡើយ ។

## ព្រះសិទ្ធថសាកល្បងតបះនិយម

នៅជិតឧរុវេលៈ ព្រះសិទ្ធថ ទ្រង់បានជួបតាបសទាំងប្រាំរូប ។ តាបសទាំងនោះ បានសុំអោយព្រះអង្គហ្វឹកហាត់តបះជាមួយគេ ។ ព្រះសិទ្ធថ បានចាប់ផ្ដើមនៅពេលនោះ អនុវត្តទុក្ករកម្មយ៉ាងតឹងរឹងបំផុត ៖ ដោយទ្រង់តមអាហាររាប់ខែ, ដុតកម្ដៅព្រះកាយរបស់ព្រះអង្គក្នុងកំដៅព្រះអាទិត្យនារដូវក្ដៅ និងឋិតនៅក្នុងទឹកកកនៅពេលយប់ត្រជាក់នៃហេមន្តរដូវ ។ ព្រះអង្គក្លាយទៅជាស្គាំងស្គម ហើយរូបកាយសល់តែជាគ្រោងឆ្អឹង ។ ដោយសារភាពទន់ខ្សោយនេះ ព្រះកេសារបស់ព្រះអង្គក៏ចាប់ជ្រុះ, ស្បែក សាច់ជ្រួញជ្រីវ ដូចជាស្បែកសាច់មនុស្សចាស់ ។ ថ្ងៃមួយព្រះអង្គបានសាកល្បងយាងដើរ ទ្រង់ក៏ដួលសន្លប់បាត់វិញ្ញាណ ហើយពេលនោះ ព្រះអង្គ មិនទាន់បានស្វែងរកឃើញអ្វីនៅឡើយ ។

ខណៈនោះ ព្រះអង្គបានយល់ច្បាស់ថា *តបកម្ម* ពុំមែនជាផ្លូវត្រូវទេ ហើយព្រះអង្គ ត្រូវតែរក្សាព្រះកាយពលអោយមានសុខភាពបរិបូណ៌ ប្រសិនបើព្រះអង្គចង់អោយអ្វី១បានសំរេច ។ ព្រះអង្គចាប់សោយអាហារ ហើយព្រះកាយពល

ក៏កើនឡើងវិញជាលំដាប់ ។ ពេលនោះ តាបសទាំង ៥ រូប ដែលអនុវត្តតបកម្មជាមួយព្រះអង្គ មិនយល់ស្របតាមព្រះអង្គ ហើយក៏នាំគ្នាចាកចោលព្រះអង្គទៅ ។

## ការត្រាស់ដឹង

ព្រះសិទ្ធថ គង់នៅតែឯកឯង តាំងសមាធិយ៉ាងជ្រាលជ្រៅ ។ ថ្ងៃមួយព្រះអង្គទ្រង់គង់ក្រោមម្លប់ពោធិព្រឹក្ស ជិតស្ទឹងនេរញ្ជរា ( ស្ទឹងផាល្គុ បច្ចុប្បន្ន ) ដោយមានការសំរេចព្រះទ័យយ៉ាងមុតមាំថា ព្រះអង្គនឹងមិនក្រោកចេញពីទីនេះឡើយ ដរាបណាព្រះអង្គមិនបានរកឃើញមាគ៌ារំដោះទុក្ខទេ ។ ព្រះអង្គគង់នៅអស់ពេលមួយសប្តាហ៍ លង់ស្លុងក្នុងសមាធិដ៏ជ្រាលជ្រៅ ។ ថ្ងៃទីប្រាំពីរ ព្រះអង្គបានរកឃើញដំណោះស្រាយ, ព្រះអង្គត្រូវបានត្រាស់ដឹង, ព្រះអង្គជ្រាបច្បាស់ថា ព្រះអង្គជាព្រះពុទ្ធមួយអង្គ ជាសព្វញ្ញុពុទ្ធ ។

ព្រះអង្គបានរកឃើញថា *អវិជ្ជា* គឺជាឫសគល់នៃបាបធម៌ទាំងអស់ ហើយតាមការបំបាត់អវិជ្ជានេះប៉ុណ្ណោះ គេអាចរំដោះខ្លួនផុតពី *សំសារៈ* ។ ព្រះអង្គបានស្រាវរកខ្សែសង្វាក់ពិភពទាំងឡាយនៃទុក្ខទាំងនោះ ទៅតាមស្មារតីនៃវិទ្យាសាស្ត្រសុទ្ធសាធ ជា ១២ ចង្កោម ឬ ១២ ហេតុ ដែលមានឈ្មោះថានិទានទាំង ១២ ។ នេះហើយ ដែលព្រះពុទ្ធទ្រង់អោយឈ្មោះថា បដិច្ចសមុប្បាទ នោះ ។

## ជំពូកទីបី

## អំពីព្រះពុទ្ធ

### I. បដិច្ចសមុប្បាទធម៌ :

ពាក្យថា " បដិច្ចសមុប្បាទ (១) " មានន័យដោយត្រង់ថា " ហេតុទាំងឡាយ ដែលមានតាំងតែពីដើមកំណើតមក" ន័យនេះ អាចនិយាយបានទៀតថា : " ដោយសារបច្ច័យនេះ, នោះកើតមានឡើង" ឬថា " នេះកើតមាន, ព្រោះនោះ

(១) តាមន័យក្នុងវចនានុក្រមសម្តេចព្រះសង្ឃរាជ ជួន ណាត (ជោតញ្ញាណោ) ថា បដិច្ច-

បានកើតមាន ។

## ធម្មជាតិត្រូវបានគ្រប់គ្រងដោយក្រឹត្យក្រម នេះរបស់បដិច្ចសមុប្បាទ

យ៉ាងណាមិញ, ដោយសារមានពពកនៅក្នុងអាកាស ទើបមានភ្លៀងធ្លាក់ចុះ ។ ដោយមានភ្លៀងធ្លាក់ចុះ ទើបផ្លូវក្លាយទៅជារអិល ។ ដោយផ្លូវរអិល, ទើបមានមនុស្សដើរទៅដួល ។ មនុស្សរអិលដួលនោះ បានត្រូវរបួស ។

យើងមើលឃើញភ្លៀងបង្អុរចុះ ព្រោះតែមានពពកនៅក្នុងអាកាស, ផ្លូវក្លាយទៅជារអិល ព្រោះតែមានភ្លៀងបង្អុរចុះ, មនុស្សនោះដួល ក៏ព្រោះតែផ្លូវរអិល, របួសរបស់គាត់កើតមាន ដោយសារតែតែការដួល ។

ដូច្នេះ ប្រសិនបើមិនមានពពកនៅក្នុងអាកាសទេ នោះក៏ពុំអាចមានភ្លៀងធ្លាក់, នៅពេលនោះ ផ្លូវក៏មិនរអិល, ហេតុនេះ មនុស្សក៏មិនអាចដួល ហើយមនុស្ស ក៏មិនអាចរងរបួសដែរ ។

## តើក្រឹត្យក្រមនោះ ប្រព្រឹត្តទៅយ៉ាងដូចម្តេច ?

នៅក្នុងខ្សែសង្វាក់នេះ យើងឃើញថា ឧប្បត្តិហេតុមួយកើតឡើង អាស្រ័យដោយឧប្បត្តិហេតុដែលបានកើតមានមុននេះ ហើយបណ្តាលឱ្យឧប្បត្តិហេតុថ្មីកើតមានបន្តបន្ទាប់ ។ អ្វីៗទាំងអស់ នៅក្នុងលោកយើងនេះ អាចត្រូវបានគេ

---

សមុប្បាទ គឺធម៌ ឬសភាវៈដែលកើតមានឡើងដោយសារបច្ច័យ គឺគ្រឿងអាស្រ័យទាក់ទងគាៗគ្នា ដូចជា សង្ខារកើតមានឡើង ព្រោះមានអវិជ្ជាជាបច្ច័យ, វិញ្ញាណកើតមានឡើង ព្រោះមានសង្ខារជាបច្ច័យ ឬថា អវិជ្ជាជាបច្ច័យនាំអោយកើតសង្ខារ, សង្ខារជាបច្ច័យនាំអោយកើតវិញ្ញាណ . ល . ។

អាចត្រូវបានគេពន្យល់តាមខ្សែសង្វាក់មួយនៃហេតុ និងផលដូចនេះ ។ គ្មានអ្វីកើតមានឡើង ដោយមិនអាស្រ័យអ្វីមួយ ដែលបានកើតមានពីមុនទេ ហើយគ្មានអ្វីមួយដែលមានដើមហេតុ អាចត្រូវបានគេយល់ថា មិនបណ្តាលអោយមានអ្វីមួយទៀតបន្តវេននោះទេ ។ ដូច្នេះ អភិក្រមចេះតែបន្តគ្មានទីបំផុត ។ អ្វីៗទាំងអស់ អាចត្រូវបានសាត្រឡប់ទៅដល់អ្វី ដែល បណ្តាលអោយមានដើមហេតុ, ហើយអ្វីៗទាំងអស់អាចត្រូវបានតាមដានរហូតដល់អ្វី ដែលកើតមានបន្ទាប់នោះ ហើយដែលកើតមានឡើងអាស្រ័យដោយអ្វីៗ ដែលមានមុនបន្ទាប់នោះ ។

## តើវិទ្យាសាស្ត្រ ធ្វើដូចម្តេចដែរ ?

វិទ្យាសាស្ត្រដោយឡែក គ្រាន់តែតាមដាន ឬលំអាននៃព្រឹត្តិការណ៍មួយ ដោយពិពណ៌នារៀបរាប់ឡើងវិញ នូវបាតុភូតទាំងឡាយជាបញ្ជាស ឬ បណ្តោយ ដែលព្រឹត្តិការណ៍នោះចងភ្ជាប់ទៅនឹងបាតុភូតទាំងនោះ ។

យ៉ាងណាមិញ, ភូតគាមសាស្ត្របានប្រាប់យើងថា ៖ ការដុះដាលដ៏ល្អនៃដើមឈើមួយដើមគឺ អាស្រ័យលើការដាក់ជីដ៏សមស្រប ហើយជីសមស្រប គឺ អា-ស្រ័យដោយបតិដ្ឋាភាគ (Constituants) នោះៗ តាមលំដាប់លំដោយ ។ រូបវិទ្យាប្រាប់យើងអោយដឹងថា ចលនារបស់ម៉ាស៊ីន ពឹងផ្អែកលើអានុភាពនៃចំហាយ ឯចំហាយពឹងផ្អែកលើទឹក និងភ្លើង ។

( នៅមានត )

# សិគាលោវាទសូត្រ

សិគាលោវាទសូត្រនេះ មានទម្រង់ជារបៀបសន្ទនារវាងព្រះពុទ្ធ និង យុវជនសិគាលៈ ឬ ជារបៀបបុច្ឆា-វិសជ្ជនា យ៉ាងពីរោះ, អ្នកម្ខាងលើកឡើងនូវសំនួរ ម្ខាងទៀតឆ្លើយនូវបញ្ហាកម្ម ។

## ផ្ទៃរឿង

ដូចដែលខ្ញុំបានប្រាប់មកហើយ យ៉ាងនេះ :-

ថ្ងៃមួយនោះ ព្រះសម្ពុទ្ធបរមគ្រូ ទ្រង់កំពុងគង់ប្រថាប់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ក្បែរក្រុងរាជគ្រឹះ ។

ពេលនោះ យុវជនមួយរូប ឈ្មោះសិគាលៈ ជាបុត្រនៃគ្រួសារមួយ តែងភ្ញាក់ពីព្រលឹម ហើយចេញដើរទៅក្នុងក្រុងរាជគ្រឹះ ដោយមានសក់ និង សំលៀកបំពាក់ទទឹកជោគ លើកដៃទាំងពីរប្រណម្យឡើងថ្វាយបង្គំទិសទាំង ៦ គឺ ទិសខាងកើត ខាងត្បូង ខាងលិច ខាងជើង ខាងក្រោម និង ខាងលើ ។

នៅព្រឹកថ្ងៃនោះ ព្រះបរមគ្រូទ្រង់យាងទៅបិណ្ឌបាតក្នុងក្រុងរាជគ្រឹះ ។ ព្រះអង្គបានទតឃើញសិគាលៈ កំពុងថ្វាយបង្គំទិសដូច្នេះ ទ្រង់បានមានព្រះតម្រាស់សួរថា :

- ម្នាលយុវជន, ហេតុអ្វីបានជាអ្នកក្រោកពីព្រលឹម ហើយធ្វើដំណើរចេញមកក្រុងរាជគ្រឹះ មានសក់ និង សំលៀកបំពាក់ទទឹកជោគ ហើយថ្វាយបង្គំទិសដូច្នេះ ?

- បពិតព្រះអង្គដ៏ចំរើន ឪពុកខ្ញុំព្រះអង្គ មុនពេលគាត់អនិច្ចកម្ម បាន

និយាយប្រាប់ខ្ញុំព្រះអង្គថា ៖ ម្នាលកូនប្រុស ឯងគប្បីថ្វាយបង្គំទិសទាំង ៦ ។ ដោយគោរពតាមបណ្ដាំឪពុកខ្ញុំព្រះអង្គនោះ ទើបខ្ញុំព្រះអង្គក្រោកពីព្រលឹមចេញមកកាន់ក្រុងរាជគ្រឹះ ថ្វាយបង្គំទិសទាំងឡាយ ។

- ម្នាលយុវជន, ក្នុងសាសនាតថាគត គេមិនថ្វាយបង្គំទិសទាំង ៦ បែបនេះទេ ។

- បពិត្រព្រះអង្គដ៏ចំរើន ក្នុងសាសនាព្រះអង្គនេះ តើគេថ្វាយបង្គំទិសទាំង ៦ ដូម្ដេចវិញ ? សូមព្រះអង្គមេត្ដាសម្ដែងប្រាប់ខ្ញុំព្រះអង្គផង ។

- បើដូច្នេះ យុវជន អ្នកចូរប្រុងស្ដាប់អោយមែនទែន តថាគតនឹងសម្ដែងប្រាប់ ៖ ម្នាលយុវជន ! សាវ័កតថាគត បានវៀរចាកមិច្ឆាជីវៈ ៤ យ៉ាង អស់មួយជីវិត មិនធ្វើនូវអំពើបាប ដែលកើតមកអំពីអគតិ ៤ យ៉ាង អស់មួយជីវិត មិនប្រព្រឹត្ដអបាយមុខ ៦ យ៉ាង ដែលនាំអោយហិនហោចអស់ទ្រព្យសម្បត្ដិ អស់មួយជីវិត ។ សាវ័កតថាគត ដែលបានលះបង់នូវអំពើអាក្រក់ ១៤ យ៉ាងនេះ ឈ្មោះថាជាអ្នកគោរពនូវទិសទាំង ៦ ។

ក) ដូម្ដេចហៅថា មិច្ឆាជីវៈ ? - ការមិនសម្លាប់, ការមិនលួច, ការមិនប្រព្រឹត្ដខុសក្នុងកាម គឺខុសនឹងគន្លងធមិលើបុត្រ ភរិយាអ្នកដទៃ, និងការមិនពោលពាក្យកុហក ។

ខ) ដូម្ដេចហៅថា ធ្វើអំពើបាប បណ្ដាលមកពីអគតិ ៤ យ៉ាង ? គឺអំពើបាបដែលកើតមកពីការស្រឡាញ់រាប់អាន (ឆន្ទាគតិ), ការខឹងក្រោធ ស្អប់ (ទោសាគតិ) ការល្ងង់ខ្លៅ (មោហាគតិ) និងការភ័យខ្លាច (ភយាគតិ) ។

គ) ដូម្ដេចខ្លះហៅថា អបាយមុខ ៦ យ៉ាង ?

ការប្រព្រឹត្ដល្បែងស្រាជានិច្ច, ការដើរលេងតាមទីច្រកល្ហកខុសពេលវេលា, ការប្រព្រឹត្ដល្បែងស្រី, ការប្រព្រឹត្ដល្បែងភ្នាល់គ្នា, ការសេពគប់មិត្ដអាក្រក់

និងការខ្ជិលច្រអូស ។

* ការប្រព្រឹត្តល្បែងស្រា រមែងមានទោស ៦ យ៉ាង ៖ ហិនហោចទ្រព្យសម្បត្តិដែលមានហើយ, បង្កើតការឈ្លោះវិវាទ, នាំអោយមានកើតរោគបានដោយងាយ, ខូចចរិយាសណ្ដាប់ធ្នាប់, មិនមានការអៀន ខ្មាសក្នុងការលែងខ្លួន និងនាំអោយខ្សោយប្រាជ្ញា ។

* ការដើរលេងខុសពេលវេលា នាំអោយមានទោស ៦ យ៉ាង ៖ នាំអោយមានអសន្តិសុខដល់ខ្លួន, ដល់បុត្រ-ភរិយា, ដល់ទ្រព្យសម្បត្តិ, នាំអោយគេសង្ស័យថាជាមនុស្សប្រព្រឹត្តចោរកម្ម ជាដើម, ការចោទប្រកាន់ខុសបែបបទ អាចធ្លាក់មកលើខ្លួន, ហើយនឹងមានគ្រោះថ្នាក់ដទៃទៀត ជាច្រើនដែលត្រូវជួបប្រទះ ។

* ការប្រព្រឹត្តល្បែងស្រី មានទោស ៦ យ៉ាង ៖ នាំអោយគិតតែដើររករោងរាំ, រោងចម្រៀង, រោងតន្ត្រី, រោងល្ខោន, រោងល្បែងឆាបឆ្បោះ, និងរោងល្បែងស្គរ តែយុំ ។

* ការប្រព្រឹត្តល្បែងភ្នាល់ មានទោស ៦ យ៉ាង ៖ អ្នកឈ្នះតែងព្រួយបារម្ភចំពោះគំនុំចិត្តអ្នកចាញ់, អ្នកចាញ់នឹងស្ដាយទ្រព្យរបស់ខ្លួនដែលចាញ់ទៅនោះ, ទ្រព្យសម្បត្តិដែលធ្លាប់មានមកហើយនោះ នឹងវិនាសបាត់បង់ទៅវិញ, ពាក្យសំដីគ្មានតម្លៃនៅក្នុងតុលាការ, ត្រូវមិត្តភ័ក្តិ និងអ្នករាជការមើលងាយមើលថោក, មិនមាននរណាម្នាក់ចង់ទាក់ទងអោយកូនចៅមានគូស្រករជាមួយព្រោះគេនិយាយថា មនុស្សល្បែង មិនអាចចិញ្ចឹមភរិយាខ្លួនបានឡើយ ។

* ការគប់បាបមិត្ត មានទោស ៦ យ៉ាង ៖ អាចក្លាយទៅជាអ្នកល្បែង, អ្នកលេងស្រី, អ្នកប្រមឹក, អ្នកឆបោក, អ្នកលួចប្លន់, ជាមនុស្សមានមិត្តភក្ដិច្រើនតែជាមនុស្សកំណាច ។

* មនុស្សទម្លាប់ខ្លួនអោយខ្ជិលច្រអូស មានទោស ៦ យ៉ាង ៖ មនុស្ស នោះតែងនិយាយថា ៖ ត្រជាក់ពេកធ្វើការមិនកើត, ក្តៅពេក, ព្រឹកពេក, យប់ពេក, ឃ្លានពេក, ឆ្អែតពេក, ធ្វើការមិនកើត ។ ម្ល៉ោះហើយ កិច្ចការដែលត្រូវធ្វើប៉ុន្មាន ឥតបានធ្វើទាំងអស់ ។ ទ្រព្យសម្បត្តិថ្មីៗ គ្មានចូល ហើយទ្រព្យសម្បត្តិដែលបានរក មកហើយ ត្រូវចាយវាយអស់ ។

* មិត្តមិនគួរសេពគប់ ៤ ពួក ៖

ក. មិត្តល្មោភប្រាក់កាស ៖ ចាយបន្តិចបន្តួច តែសម្លឹងយកប្រយោជន៍ ច្រើន, ធ្វើការអ្វីដោយសារសេចក្តីខ្លាច និងគិតតែពីប្រយោជន៍ផ្ទាល់ខ្លួន ។

ខ. មិត្តបានតែមាត់ ៖ ដល់ពេលមានកិច្ចការពឹងពាក់ម្តងម្កាល ដោះដៃ ថាយ៉ាងនេះ យ៉ាងនោះ ។

គ. មិត្តចាក់បណ្តោយ ៖ យល់ស្របទាំងអស់ក្នុងការធ្វើការអាក្រក់ ហើយប្រឆាំងជានិច្ចក្នុងការធ្វើត្រូវ សរសើរយើងតែនឹងមុខ និយាយដើមប្រាប់អ្នក ដទៃពីក្រោយខ្នង ។

ឃ. មិត្តជួយបំផ្លាញ ៖ តាំងខ្លួនជាមិត្តរបស់យើង ពេលណាយើងមាន លុយផឹកស៊ី ពេលយើងដើរលេងខុសពេលតាមច្រកល្ហក ពេលយើងទៅមើលកុន ល្ខោន ឬទៅដើរលេងស្រី ឬក៏ក្នុងពេលដែលយើងកំពុងប្រព្រឹត្តល្បែងភ្នាល់ ។

* មិត្តគួរគប់រកមាន ៤ ពួក ៖

ក. មិត្តឧបត្ថម្ភ ៖ ជួយថែទាំយើង ក្នុងពេលដែលយើងគ្មានអ្នកថែទាំ, ជួយថែរក្សាសម្បត្តិយើង ក្នុងពេលយើងមិននៅ, ជាពំនឹងរបស់យើង ក្នុងពេល ដែលយើងមានភ័យ និងជួយរំលែកការងារដ៏លំបាកៗ បើយើងត្រូវការពឹងពាក់ ។

ខ. មិត្តរួមសុខទុក្ខ ៖ ប្រាប់យើងនូវរឿងអាថ៌កំបាំងរបស់ខ្លួនគេ, បិទបាំងនូវអាថ៌កំបាំងរបស់យើង មិនបោះបង់យើង នៅពេលមានការលំបាក ហ៊ាន

លះបង់សូម្បីជីវិតរបស់ខ្លួន ចំពោះជីវិតរបស់យើង ។

គ. មិត្តមគ្គុទ្ទេសក៍ : ហាមឃាត់យើងមិនអោយធ្វើអំពើខុស, រួបរួមជាមួយនឹងយើងក្នុងអំពើត្រូវ, ប្រាប់យើងនូវរឿងរ៉ាវដែលយើងមិនដែលធ្លាប់បានឮ, បង្ហាញយើងនូវផ្លូវទៅរកសេចក្តីសុខ ។

ឃ. សមានមិត្ត : មិនត្រេកអរចំពោះគ្រោះថ្នាក់របស់យើង, រីករាយចំពោះការចំរុងចំរើនរបស់យើង, ហាមឃាត់នរណាមួយដែលនិយាយអាក្រក់អំពីយើង, សរសើរបុគ្គលណាដែលនិយាយល្អពីយើង ។

ម្នាលយុវជន, មាតាបិតា ទុកជាទិសខាងកើត, គ្រូបង្រៀន ជាទិសខាងត្បូង, ភរិយានិងបុត្រធីតា ជាទិសខាងលិច, មិត្តសំឡាញ់ ជាទិសខាងជើង, អ្នកបំរើនិងកម្មករ ជាទិសខាងក្រោម, គ្រូឧបជ្ឈាយ៍និងព្រាហ្មណ៍ជាទិសខាងលើ ។

* កូនគប្បីសង្គ្រោះមាតាបិតា ដោយន័យ ៥ យ៉ាង :

- ត្រូវតែទំនុកបំរុងលោកវិញ ព្រោះលោកបានទំនុកបំរុងខ្លួនពីមុនមក,
- ត្រូវតែជួយធ្វើការ សំរាលភារៈរបស់លោក,
- ត្រូវតែរក្សាទុកនូវវង្សត្រកូល និងប្រពៃណីរបស់គ្រួសារ,
- ត្រូវតែធ្វើខ្លួនអោយសមគួរ ល្មមជាអ្នកទទួលនូវកេរមរតក,
- ធ្វើបុណ្យទានឧទ្ទិសកុសលជូនលោក ។

* ក្នុងន័យដូចគ្នា, មាតាបិតាគប្បីសង្គ្រោះបុត្រធីតា ដោយន័យ ៥ យ៉ាង

- ហាមឃាត់កូនមិនអោយធ្វើអំពើអាក្រក់,
- ណែនាំកូនអោយធ្វើតែអំពើល្អ,
- អប់រំកូនអោយមានការងារមុខរបរសមរម្យ,
- រៀបចំអាពាហ៍ពិពាហ៍អោយកូន, និង
- ប្រគល់កេរមរតក តាមការគួរ ។

* សិស្សត្រូវឧបដ្ឋម្ភគ្រូ ដោយន័យ ៥ យ៉ាង ៖

- ដោយការក្រោកទទួល,
- ធ្វើគារវកិច្ច,
- ចាំបំរើគ្រូ,
- យកចិត្តទុកដាក់ក្នុងការរៀនសូត្រ,
- ចាត់ចែងទឹកក្តៅ ទឹកត្រជាក់ តក់ច្របាច់ ។

* គ្រូគប្បីសង្គ្រោះសិស្ស ដោយន័យ ៥ យ៉ាង ៖

- ប្រៀនប្រដៅសិស្សដោយល្អ,
- បង្រៀនសិស្សដោយល្អ,
- បង្រៀនសិស្សគ្រប់មុខវិជ្ជាដែលខ្លួនចេះ,
- ប្រកាសគុណសម្បត្តិរបស់សិស្សក្នុងកណ្តាលទីប្រជុំ,
- រក្សាការពារសិស្សគ្រប់មធ្យោបាយទាំងអស់ ។

* ស្វាមីគប្បីសង្គ្រោះភរិយា ដោយន័យ ៥ យ៉ាង ៖

- ស្រឡាញ់រាប់អានដ៏ស្មោះ,
- ពោលពាក្យទន់ភ្លន់ មិនមើលងាយមើលថោក,
- មិនក្បត់ចិត្ត ប្រគល់តំណែងជាស្រីមេផ្ទះពេញលក្ខណៈ,
- ផ្តល់គ្រឿងអលង្ការផ្សេងៗ តាមការគួរ ។

* ភរិយា គប្បីសង្គ្រោះស្វាមី ដោយន័យ ៥ យ៉ាង ៖

- ចាត់ចែងធ្វើការគ្រប់យ៉ាងដោយថ្លិតថ្លង់,
- រាប់អានញាតិខាងស្វាមី និងញាតិខាងខ្លួនដោយស្មោះស្មើ,
- ថែរក្សាទ្រព្យសម្បត្តិដែលស្វាមីរក មកទុកអោយគង់វង្ស,
- មិនក្បត់ចិត្តនឹងស្វាមី,

- ប៉ិនប្រសប់ និងប្រឹងប្រែងជានិច្ចធ្វើការគ្រប់យ៉ាងរបស់ខ្លួន ។

* នាយចៅហ្វាយ គប្បីសង្គ្រោះកម្មករ ដោយន័យ ៥ យ៉ាង :

- តម្រូវអោយធ្វើការងារតាមសមគួរដល់កម្លាំង,
- ផ្តល់អាហារ និងតម្លៃឈ្នួល តាមគួរ,
- ជួយព្យាបាល ក្នុងគ្រាមានជំងឺ,
- ចែករំលែកនូវវត្ថុចម្លែកៗ,
- អនុញ្ញាតច្បាប់សំរាក តាមការគួរ ។

* កម្មករ គប្បីសង្គ្រោះចៅហ្វាយនាយ ដោយន័យ ៥ យ៉ាង :

- ក្រោកពីដេកមុននាយចៅហ្វាយ,
- ប្រកបការងារមុនចៅហ្វាយនាយ,
- រីករាយទទួលតែវត្ថុអ្វីដែលអោយដល់ខ្លួន,
- ធ្វើការរបស់ខ្លួនដោយយកចិត្តទុកដាក់,
- និយាយសរសើរកិត្តិគុណ របស់នាយចៅហ្វាយក្នុងទីទាំងពួង ។

សិគាលោវាទសូត្រនេះ មាននៅក្នុងគម្ពីរទីឃនិកាយ ជាសូត្រខ្លីៗ តែងាយយល់ ជាសូត្រស្តីអំពីការរស់នៅដ៏ប្រសើរនៅក្នុងសង្គមមនុស្ស ។ សូត្រនេះមានអត្ថន័យ និងគុណប្រសើរវិសេស សំរាប់មនុស្សទូទៅ ហើយអាចយកមកអនុវត្តបានគ្រប់កាលៈទេសៈទាំងអស់ ។ ប្រពៃណី និងការរស់នៅរបស់មនុស្សតែងប្រែប្រួលពីសតវត្សមួយ ទៅសតវត្សមួយ តែគោលធមិសំខាន់ៗ នៃចរិយាត្រូវនិងខុស ពុំប្រែប្រួលឡើយ ។ ឱវាទដ៏ប្រសើរនេះ នៅតែមានសេចក្តីពិតរស់រវើកគ្រប់ពេលវេលាទាំងអស់ ចំពោះមនុស្សទូទៅ ។ សិគាលោវាទសូត្រនេះទាក់ទងនឹងសង្គមមនុស្សទាំងស្រុង ។

ព្រះឱវាទរបស់ព្រះអង្គក្នុងសូត្រនេះ ងាយស្តាប់ ងាយយល់ ហើយមាន

ភាពពិតឥតល្អៀងផង ពីទិដ្ឋភាពគ្រប់យ៉ាង នៃជីវិតប្រចាំថ្ងៃរបស់មនុស្សទូទៅ ។ ត្រង់នេះ បញ្ជាក់អោយឃើញថាព្រះពុទ្ធ ព្រះអង្គស្គាល់ច្បាស់នូវជីវិតរបស់មនុស្ស, ជាអ្នកប្រាកដនិយម មានព្រះទ័យពោរពេញដោយមេត្តា និងករុណា ជាកល្យាណ-មិត្តរបស់មនុស្សទាំងអស់ ។

បញ្ហាគ្រប់យ៉ាងនៃមនុស្សលោក អាចរលុបរលាយសាបសូន្យទៅបាន ប្រសិនបើពិភពលោកសិក្សាក្នុងសូត្រនេះ ហើយប្រតិបត្តិតាមដោយម៉ត់ចត់ ។ សិគាលោវាទសូត្រនេះ ជាធមិសំរាប់ដោះស្រាយបញ្ហាសង្គម បញ្ហាសេដ្ឋកិច្ច និងបញ្ហាសីលធមិ ។ សិគាលោវាទសូត្រនេះ ប្រសើរដាច់គេក្នុងចំណោមវណ្ណកម្មផ្សេងៗ ខាងសាសនា ក្នុងពិភពលោក ។ សូត្រនេះ គ្មានលាយឡំនឹងទិដ្ឋិ (ជំនឿផ្សេងៗ) ឬ បរមត្ថវិជ្ជាអាថិកំបាំងឡើយ ព្រោះឱវាទក្នុងសូត្រនេះ មានន័យភ្លឺច្បាស់លាស់បំផុត ប្រៀបដូចជា ដុំត្បូងដែលគេបានច្នៃហើយយ៉ាងបរិសុទ្ធ ។ សូត្រនេះ ជាពុទ្ធវចនៈផ្ទាល់ដែលព្រះអង្គបានសំដែងប្រាប់ដល់មនុស្ស ក្នុងពិភពលោកទាំងមូល ។

ប្រមូលរៀបរៀងដោយ

**ម៉ែន ប្រាជ្ញ**

**អាំ ឆន**

ពិនិត្យ និងកែសំរួលដោយ

**ឱម ខែម**

# សង្គាយនា

សង្គាយនា គឺការប្រជុំផ្ទៀងផ្ទាត់ធម៌វិន័យ ជាពាក្យប្រៀនប្រដៅរបស់ព្រះសម្ពុទ្ធ អោយបានត្រឹមត្រូវតាមបែបដើម ។ ការធ្វើសង្គាយនាធម៌វិន័យ គឺដើម្បីបំបាត់ចោលនូវការចម្រូងចម្រាស់ចំពោះធម៌វិន័យ ក្នុងផ្ទៃពុទ្ធសាសនា, ដើម្បីបំបាត់ចោលនូវការចូលចិត្តខុស ការយល់ឃើញខុស និង ការប្រតិបត្តិខុសពីធម៌វិន័យ សំដៅពង្រឹងពុទ្ធសាសនាអោយបានស្ថិតស្ថេរ គង់វង្ស រុងរឿងយូរអង្វែង ។

## សង្គាយនា ទី១

មូលហេតុដែលនាំអោយមានសង្គាយនាទី១ នោះ គឺប្រារព្ធរៀបចំឡើងដើម្បីជម្រះពាក្យតិះដៀលរបស់សុភទ្ទវុឌ្ឍបព្វជិត ចំពោះអង្គព្រះសម្ពុទ្ធ ដែលទើបតែបរិនិព្វានកន្លងទៅបានត្រឹមតែ ៧ ថ្ងៃប៉ុណ្ណោះ និងដើម្បីប្រារព្ធចំពោះព្រះមហាឧបការគុណរបស់ព្រះសម្ពុទ្ធ ។

មានសេចក្តីដំណាលថា ព្រះមហាកស្សប ជាព្រឹទ្ធសាវ័កដែលមានព្រះជន្មនិងព្រះវស្សាច្រើនជាងពុទ្ធសាវ័កទាំងអស់ ហើយជាឯតទគ្គៈ (ជើងឯក) ខាងវិបស្សនាធុរៈនោះ បាននាំសិស្ស ៥០០ អង្គរបស់លោក ទៅកាន់ក្រុងកុសិនារាដើម្បីថ្វាយបង្គំគាល់ព្រះបរមសាស្តា ។ លុះដល់ពាក់កណ្តាលផ្លូវ ក៏សំរាកឆាន់ពេលថ្ងៃត្រង់ ក្រោមដើមឈើមួយដើមធំ ក្បែរផ្លូវ ។ វេលានោះ ស្រាប់តែមានអាជីវកម្នាក់ដើរចូលមក ។ ព្រះមហាកស្សប ក៏សាកសួរដំណឹងសុខទុក្ខរបស់ព្រះសម្ពុទ្ធចំពោះអាជីវកនោះ ។ អាជីវក ក៏ឆ្លើយថា ព្រះសមណគោតមទ្រង់ចូលបរិនិព្វាន

កន្លងទៅ ៧ ថ្ងៃហើយ ។ គ្រានោះ ពួកភិក្ខុជាសិស្សរបស់ព្រះមហាកស្សប មានការខ្សឹកខ្សួល សោកស្តាយអង្គព្រះសម្ពុទ្ធយ៉ាងក្រៃលែង ។ រំពេចនោះ ស្រាប់តែសិស្សមួយអង្គ ក្នុងចំណោមសិស្ស ៥០០ អង្គ បានសំដែងឡើងនូវការអបអរសាទរ របស់ខ្លួន ចំពោះការចូលបរិនិព្វានរបស់អង្គព្រះសម្ពុទ្ធទៅវិញ ដោយពោលថា «ព្រះសម្ពុទ្ធតែងបៀតបៀនពួកយើង, តែងហាមប្រាមពួកយើង, ពួកយើងធ្វើអ្វី ក៏ខុសដែរ .ល.។ ឥឡូវ ពួកយើងបានធូរស្រាលហើយចាប់ពីពេលនេះទៅ ព្រោះលែងមានអ្នកណាហាមប្រាម រារាំងពួកយើងទៀតហើយ ពួកយើងចង់ធ្វើអ្វី ស្រេចតែចិត្តចង់... » ។ ព្រះមហាកស្សប ឮដូច្នេះ ក៏នឹកសង្វេគថា " ឱ ព្រះសម្ពុទ្ធ ! ព្រះអង្គមានមហាគុណដ៏ធ្ងន់ឥតអ្វីប្រៀបបាន ព្រះអង្គចូលបរិនិព្វាន មិនទាន់ទាំងបានប៉ុន្មានថ្ងៃផង ស្រាប់តែមានបាបជន ពោលពាក្យប្រមាថ តិះដៀលព្រះអង្គ យ៉ាងនេះ ! » ។

ដោយមូលហេតុបែបនេះហើយ ទើបព្រះមហាកស្សប មានបំណងនឹងរៀបចំអោយមានជាសង្គាយនាទី ១ នោះឡើង ។ ក្នុងការធ្វើសង្គាយនានេះ ព្រះមហាកស្សប បានជ្រើសរើសយកតែព្រះអរហន្ត ខីណាស្រព ដែលទ្រទ្រង់នូវបដិសម្ភិទា និងអភិញ្ញា ៦ ( គឺអ្នកដែលចេះចាំ យល់ច្បាស់នូវព្រះធម៌វិន័យ ) ហើយដែលបានទទួលឯតទគ្គៈ ( ជើងឯក ) អំពីសំណាក់ព្រះសម្ពុទ្ធផង ។ ការជ្រើសរើសបែបនេះ បានតែ ៤៩៩ អង្គប៉ុណ្ណោះ ប៉ុន្តែពេលជិតសង្គាយនា ទើបលោកបញ្ចូលព្រះមហាអានន្ទមួយអង្គទៀត បង្គ្រប់ជា ៥០០ អង្គ ព្រោះមហាអានន្ទ ទើបតែបានសំរេចមគ្គផលជាន់ខ្ពស់ ជាព្រះអរហន្ត ខីណាស្រព នៅព្រឹកដែលសង្គាយនានោះចាប់ដំណើរការ ។ សង្គាយនានោះ លោកហៅថា " បញ្ចសតិកសង្គាយនា " ក៏បានព្រោះមានការកសង្ឃ ( ព្រះសង្ឃដែលបានចូលរួមក្នុងសង្គាយនានោះ ) ចំនួន ៥០០

អង្គ ឬហៅថា « ថេរិកសង្គាយនា » ក៏បាន ព្រោះមានការកសង្ឃ សុទ្ធតែជាព្រះអរហន្ត ខីណាស្រព បដិសម្ភិទា និងអភិញ្ញា ។

សង្គាយនាទី១ នោះ បានចាប់ផ្ដើមនៅថ្ងៃ ១ រោច ខែស្រាពណ៍ ឆ្នាំម្សាញ់ ពុទ្ធសករាជ កន្លងទៅបាន ៣ ខែ, ប្រព្រឹត្តទៅអស់ពេលចំនួន ៧ ខែ ទើបចប់ ធ្វើនៅសត្តបណ្ណគុហា ភ្នំវេភារៈ ជិតក្រុងរាជគ្រឹះ ដោយមានព្រះមហាក្សត្រ អជាតសត្រូវ ជាពុទ្ធសាសនូបត្ថម្ភក៍ ។ សង្គាយនានោះ មានព្រះមហាកស្សប ជាប្រធាន ហើយជាអ្នកចោទសួរព្រះធម៌វិន័យ ។ ដំបូង លោកចោទសួរវិនយប្បញ្ហាទៅនឹងព្រះឧបាលី អោយដោះស្រាយ ។ បន្ទាប់មក លោកចោទសួរសុត្តន្តប្បញ្ហា និងអភិធម្មប្បញ្ហា ទៅនឹងព្រះមហាអានន្ទ អោយដោះស្រាយ ។ ឯការកសង្ឃ ចំនួន ៤៩៧ អង្គទៀត ជាអ្នកពិនិត្យផ្ទៀងផ្ទាត់ ថាតើការសួរ និងការឆ្លើយនេះ ត្រឹមត្រូវតាមព្រះពុទ្ធវចនៈ ឬទេ ? ពេលចប់បញ្ហានីមួយៗ ការកសង្ឃ បានបញ្ចេញមតិថា «ត្រឹមត្រូវតាមព្រះពុទ្ធវចនៈ ពិតប្រាកដហើយ » ។

## សង្ខេបព្រះត្រៃបិដក

វិន័យបិដក មាន ២ វិភង្គ : ភិក្ខុវិភង្គ និង ភិក្ខុនីវិភង្គ ។ វិភង្គទាំងពីរនេះ ហៅថា ឧភតោវិភង្គ ។

*១ . ភិក្ខុវិភង្គ មាន ៨ កណ្ឌ និងមាន ២២៧ សិក្ខាបទ :*

- បារាជិកកណ្ឌ មាន ៤ សិក្ខាបទ,
- តេរសកណ្ឌ មាន ១៣ សិក្ខាបទ,
- អនិយតកណ្ឌ មាន ២ សិក្ខាបទ,
- និស្សគ្គិយកណ្ឌ មាន ៣០ សិក្ខាបទ,

- បាចិត្តិយកណ្ឌ មាន ៩២ សិក្ខាបទ,
- បាដិទេសនីយកណ្ឌ មាន ៤ សិក្ខាបទ,
- សេក្ខិយកណ្ឌ មាន ៧៥ សិក្ខាបទ,
- អធិករណសមថកណ្ឌ មាន ៧ សិក្ខាបទ ។

*២ . ភិក្ខុនីវិភង្គ មាន ៧ កណ្ឌ និងមាន ៣៣១ សិក្ខាបទ :*

- បារាជិកកណ្ឌ មាន ៨ សិក្ខាបទ,
- សង្ឃាទិសេសកណ្ឌ មាន ១៧ សិក្ខាបទ,
- និស្សគ្គិយកណ្ឌ មាន ៣០ សិក្ខាបទ,
- បាចិត្តិយកណ្ឌ មាន ១៦៦ សិក្ខាបទ,
- បាដិទេសនីយកណ្ឌ មាន ៧ សិក្ខាបទ,
- សេក្ខិយកណ្ឌ មាន ៧៥ សិក្ខាបទ,
- អធិករណសមថកណ្ឌ មាន ៧ សិក្ខាបទ ។

* *ព្រះវិន័យបិដក មាន ៥ គម្ពីរ :*

១. គម្ពីរ អាទិកម្ម,

២. គម្ពីរ បាចិត្តិយៈ,

៣. គម្ពីរ មហាវគ្គ,

៤. គម្ពីរ ចុល្លវគ្គ

៥. គម្ពីរ បរិវារ ។

ដើម្បីងាយចាំគម្ពីរទាំង ៥ នេះ គេសរសេរជាអក្សរកាត់ថា " អា.បា.ម.ចុ.ប. " ។ ចែកជាសៀវភៅមាន ១៣ ក្បាល, ចែកជាធម្មក្ខន្ធ មាន ២១.០០០ ធម្មក្ខន្ធ ។

* *ព្រះសុត្តន្តបិដក មាន ៥ គម្ពីរ :*

១ . គម្ពីរ ទីឃនិកាយ,

២ . គម្ពីរ មជ្ឈិមនិកាយ,

៣ . គម្ពីរ សំយុត្តនិកាយ,

៤ . គម្ពីរ អង្គុត្តរនិកាយ,

៥ . គម្ពីរ ខុទ្ទកនិកាយ ។

ដើម្បីងាយចាំ គម្ពីរទាំង ៥ នេះ ត្រូវបានគេសរសេរជាអក្សរកាត់ថា " ទី.ម.សំ.អំ.ខុ." ។ ចែកជាសៀវភៅ មាន ៦៤ ក្បាល, ចែកជាធម្មក្ខន្ធ មាន ២១.000 ធម្មក្ខន្ធ ។

* *ព្រះអភិធម្មបិដក មាន ៧ គម្ពីរ :*

១ . គម្ពីរ សង្គណី,

២ . គម្ពីរ វិភង្គ,

៣ . គម្ពីរ ធាតុកថា,

៤ . គម្ពីរ បុគ្គលបញ្ញត្តិ,

៥. គម្ពីរ កថាវត្ថុ,

៦. គម្ពីរ យមកៈ,

៧. គម្ពីរ បដ្ឋាន ។

គម្ពីរទាំង ៧ នេះ គេសរសេរជាអក្សរកាត់អោយងាយចាំថា " សំ.វិ. ធា.បុ.ក.យ.ប. ។ ចែកជាសៀវភៅ មាន ៣៣ ក្បាល, ចែកជាធម្មក្ខន្ធ មាន ៤២.000 ធម្មក្ខន្ធ ។

សរុបធម៌វិន័យក្នុងព្រះត្រៃបិដក មាន ៨៤.000 ព្រះធម្មក្ខន្ធ ។

បឋមសង្គាយនានោះ ជាព្រឹត្តិការណ៍សំខាន់ ដែលជាជំហានដំបូងបង្អស់ក្នុងការផ្ទៀងផ្ទាត់ តម្រែតម្រង់ធម៌វិន័យ ក្នុងផ្ទៃព្រះពុទ្ធសាសនា អោយបានត្រឹមត្រូវ តាមព្រះពុទ្ធឱវាទរបស់ព្រះសម្ពុទ្ធ ដែលព្រះអង្គបានខិតខំទេសនាអប់រំពុទ្ធបរិស័ទ ក្នុងរយៈពេល ៤៥ ព្រះវស្សា ។ ដូច្នេះហើយបានជា អ្នកកាន់ព្រះពុទ្ធសាសនា នៅពេលដែលមានពិធីបុណ្យសំខាន់ៗ គេតែងរៀបចំអោយមានការទេសន៍សង្គាយនានេះឡើង ។ ការទេសន៍បឋមសង្គាយនានេះ បានក្លាយទៅជាប្រពៃណីដ៏សំខាន់មួយ របស់ប្រជាជនកម្ពុជា តាំងពីអតីតកាល រហូតមកដល់បច្ចុប្បន្នកាល ។

*( នៅមានតទៅទៀត )*

រៀបរៀងដោយ
ម៉ែន ប្រាជ្ញ * អាំ ឆន

> *« គួរគប្បីឱ្យមួយរយ តែមិនគួរធ្វើឱ្យកើតវិវាទមួយទេ នេះជាមតិអ្នកប្រាជ្ញ, សូម្បីមិនមានមូលហេតុអ្វីជាមាំមួន ហើយក៏ធ្វើវិវាទដែរ នេះជាលក្ខណៈមនុស្សល្ងង់ទេ » ។*
>
> ហិតោបទេស



K. 192. Palais royal, gopura E.

# ពាក្យសម្បថ
## របស់
## មន្ត្រីរាជការក្នុងរាជ្យព្រះបាទសូរ្យវរ្ម័ន ទី១

*Le serment des fonctionnaires de*

*SURYAVARMAN 1er*

*933 çaka (XIº siècle)*

គេបានរកឃើញអត្ថបទនៃពាក្យសម្បថ របស់តម្រួតភាគ (ស្រុក) ថ្នាក់ឯក-ទោ-ត្រី-ចត្វា នៅក្នុងសិលាចារឹក ដែលបានចារលើមេទ្វារនៃគោបុរៈខាងកើត បរិវេណខាងក្នុងនៃព្រះបរមរាជវាំងគឺ ក្លោងទ្វារដែលនាំចូលទៅរកប្រាសាទភិមានអាកាស ។ នៅគោបុរៈខាងកើតនេះ គេឃើញមានសិលាចារឹកចំនួន ៨ ផ្ទាំង ដែលមានអត្ថបទចំនួន ១១ បន្ទាត់ ខាងដើមជាពាក្យសម្បថ រួចអត្ថបទបន្ទាប់ ជាបញ្ជីរាយនាមមន្ត្រី និងឈ្មោះស្រុក ដែលមន្ត្រីទាំងនោះគ្រប់គ្រង ។ ទោះបីមន្ត្រីទាំងឡាយនោះ ធ្វើពាក្យសម្បថតាមថ្នាក់គឺ ថ្នាក់ឯកដោយឡែក ថ្នាក់ទោដោយឡែក... ក៏ដោយ ក៏អត្ថបទនៃពាក្យសម្បថ មានទម្រង់ និងខ្លឹមសារដូចគ្នាបេះបិទ ។

សិលាចារឹកទាំងនោះ សរសេរជាភាសាខ្មែរបុរាណ ដោយមានចុះកាលបរិច្ឆេទ ឆ្នាំ ៩៣៣ គ.ក (មហាសករាជ) ។ អត្ថបទសិលាចារឹកទាំង ៨ ផ្ទាំង ដែលរកឃើញនៅគោបុរៈខាងកើត នៃបរិវេណកំផែងព្រះរាជវាំងនោះ មានភាពទ្រុឌទ្រោមរេចរឹល និងរលុបបាត់ជាច្រើនអន្លើ មិនអាចប្រមូលផ្តុំអោយបានជាអត្ថបទពេញ

លេញបានឡើយ ។ តែជាភ័ព្វសំណាងល្អ ក្រោយមក គេបានរកឃើញសិលាចារឹក ដូចគ្នានេះ ១ ផ្ទាំងទៀត ដែលមានឃ្លាខ្លះនៅល្អ អាចយកទៅបំពេញចំណែកខ្វះ ចន្លោះនៃអត្ថបទសិលាចារឹកទាំង ៨ ខាងដើម ។ លោក អាយម៉ូនីញេ និងលោក ហ្ស៊ សឺដែស បានផ្គុំសិលាចារឹកទាំង ៩ ផ្ទាំងនោះ ហើយចងក្រងអត្ថបទដើម បានទាំងស្រុងឡើងវិញ ។

នៅខាងក្រោមពាក្យសម្បថ គេឃើញមានបញ្ជីរាយនាមមន្ត្រីរាជការ ថ្នាក់ទី១ ទី២ ទី៣ និងទី ៤ ។ លោក អាយម៉ូនីញេ បានសរសេរថា ឈ្មោះដែលមាន ក្នុងអត្ថបទខាងក្រោយពាក្យសម្បថទាំងនោះ ជានាមរបស់ចៅហ្វាយខេត្ត (ចៅ-ហ្វាយភូមិភាគ) ដែលតាមការប៉ាន់ស្មានរបស់គាត់ ថាមានរហូតដល់ ៤០០ នាក់ ។ គាត់បានសន្និដ្ឋានថា នៅជំនាន់នោះ ប្រទេសកម្ពុជាយើងអាចមានខេត្តតូចៗ ឬភូមិ-ភាគចំនួន ៤០០ ដែរ ។

ប៉ុន្តែ លោក ហ្ស៊ សឺដែស ដែលបានសិក្សាសិលាចារឹកដដែលនេះ នៅពេលក្រោយមក បានកត់សំគាល់ថា គាត់បានរាប់ឈ្មោះមន្ត្រីទាំងនោះទៅ ឃើញថាចំនួនសរុបទាំងអស់ គិតទាំងផ្នែករលុបផងនោះ មានប្រហែលតែ ២០០ នាក់ ប៉ុណ្ណោះ ។

សិលាចារឹកទាំង ៨ ផ្ទាំងនេះ សរសេរជាអក្សរខ្មែរបុរាណរាងមូល ហើយច្បាស់ មានបន្ទាត់ត្រង់ស្មើល្អណាស់ និងមានទំហំប៉ុនៗគ្នា ដែលលោកអាយម៉ូនីញេ សន្និដ្ឋានថា ទំនងជាសរសេរដោយដៃអ្នកចារតែម្នាក់គត់ ។

ខាងក្រោយនេះគឺ អត្ថបទពាក្យសម្បថទាំងស្រុង ដែលយើងសរសេរឡើងវិញ តាមលំនាំខ្មែរបុរាណ ដោយប្រើអក្សរខ្មែរទំនើប និងអត្ថបទបកប្រែ ជាភាសាខ្មែរបច្ចុប្បន្ន ។

## អត្ថបទពាក្យសម្បថ ដែលសរសេរតាមលំនាំខ្មែរបុរាណ

៩៣៣ ឝកនវមី កេត៌ ភទ្របទ អាទិត្យវារ ០ នេះគឺ រោះហ វទ្ធប្រតិជ្ញា ០ យេង៑ អំបាល្ល នេះហនា ភាគ តម្រ្វាច៑ ឯក ( ទោ ត្រីណិ ចត្វារិ ) ស្យង្គ ឝបថ វេលា កាត្តៃ ថ្វាយ៑ អាយុះ នុ ក្ឫតជ្ញភក្តិយេង៑ តឝុទ្ធ ត ធ្វលី វ្រះបាទកម្រតេង៑ កំត្វន៑ អញ៑ត្រី ស្វយ៌្យវម៌្មទេវ តសកល ស្វេយ៑ វ្រះធម៌្មរាជ្យនុ ៩២៤ ឝក វ្នេក្ត តវ្រះ វ្លេង៑ វ្រះ រត្ន នុ វ្រាហ្មណាចាយ៌្យ ០ យេង៑ វ្វ៑ បង្គំ ត កម្រតេង៑ ផ្ដេ ករោតទៃតិលេយ៑ វ៑ខ្មាង្ស វ្វ៑ សំនុ ខ្មាង្វ វ្វ៑ ថ្ងេ ទ្រោហ ប្រការ ផោង៑ ០ នៅអំបាល្ល អំវេ ផល ក្ឫតជ្ញភក្តិ ត ធ្វលី វ្រះបាទ កម្រតេង៑ កំត្វន៑ អញ៑ ត្រី ស្វយ៌្យវម៌្មទេវ នោះគិបិ យេង៑ឧទ្យោគ ថ្ងេ ០ ទហ មាន៑ចំបាង្វ យេង៑ឧទ្យោគ ឆ្យាង៑ នុ សវ៌្វាត្មណា វ៑ស្វត្ត អាយុះ ហេតុ ភក្តិ វ្វ៑ រត៑ លេង៑ ចំបាង្វ ០ ទហ អ្សត៑ ចំបាង្វ បិយេង៑ ស្លាប៑ នុ ស្វយំវ្យាធិ មុហ្ន៑ លេង៑ ផល្លអ្នក៑ ត ស្វាមិភក្តិ មាន្តយេង្វ ០ ទហ អាយុះ យេង៑ អាច៑ ទន្ត វ្រះរាជកាយ៌្យ វេលា ល្វោះ ត កាល នៅ ប្រការ លេហ យេង៑ ស្លាប៑ ហេតុ ភក្តិយ គិបិ យេង៑ ថ្ងេ ០ ទហ មាន៑ វ្រះរាជកាយ៌្យ នា កម្រតេង៑ កំត្វន៑ អញ៑ បន្ទ្វល្បិប្រេ យេង៑ ទៅនា ត ឆ្វាយ៑ បិ មាន៑ វត្តិមាន ត ៗ ស្វេង៑ បិ ត្យង៑ វស្តុ ត វ្យក្ត ថ្ងេរោះហ វទ្ធប្រតិជ្ញា ទិទៃវ០ ទហ យេង្គ អំបាល្ល នេះហ មាន្ត នុ វ្វ៑ ថ្ងេ រោះហ វទ្ធប្រតិជ្ញា នេះហ រីយ កម្រតេង៑ផ្ដេ ករោត ស្វេយ៑ វ្រះ ធម៌្មរាជ្យ ចំន្យរ ស្វំ លេង៑ ឧយ៑ រាជភយ ត យេង៑ វ្វ៑ ម្វាយ៑ប្រការ ០ ទហ យេង៑មាន្ត កបត បិ វ្វ៑ ផ្ដត៑ រោះហ ប្រតិជ្ញា តរោះហ នេះហ លេង៑ យេង៑ ជាត ទ្វាត្រីឝនរក តរាប៑ វ្រះ ចន្ទ្រាទិត្យ មាន៑ លេយ៑ ០ ទហ យេង៑ ថ្ងេ រោះហ វទ្ធប្រតិជ្ញា

នេះហា ពគុទ្ធ លេង៑ កម្រតេង៑ ផ្ដែករាំ ប្រេ បរិបាលន ឞ្រះ បុន្យ ស្រុក ទេឝ យេង៑ លេង៑ សំប្វរណ អ្នៅ ត កុលេ យេង៑ ហេតុ យេង៑ ស្វាមីភក្តិ ត ធូលិ ឞ្រះ បាទ កម្រតេង៑ កំត្វន៑ អញ ឝ្រីសូយ៌្យវម្មទេវ ត សកល ស្វេយ ឞ្រះធម្មរាជ្យ នុ ៩២៤ ឝក ០ រិយ ផល អ្នក្ត ស្វាមីភក្តិ លេង៑ មាន្ត យេង្វ អំរិ ឰហលោក ទៅល្វោះហ បរលោក ០

## អត្ថបទប្រែជាភាសាខ្មែរទំនើប

មហាសករាជ ៩៣៣, ប្រាំបួនកើត ខែភទ្របទ ថ្ងៃអាទិត្យ ។ នេះគឺពាក្យសច្ចាប្រណិធាន (របស់ទូលព្រះបង្គំទាំងអស់គ្នា ) ។ (ទូលបង្គំ) យើង (ខ្ញុំ) ទាំងអស់គ្នា ជាតម្រួតរបស់ភាគ (តំបន់) ថ្នាក់ឯក ( ទោ - ត្រី - ចត្វា ) នៅពេលស្បថ (ទូលបង្គំ) យើង (ខ្ញុំ) សូមសច្ចាកាត់ដៃ ថ្វាយអាយុ និងថ្វាយនូវកតញ្ញូភក្តីភាពដ៏បរិសុទ្ធ ផូរផង់ ចំពោះព្រះករុណាព្រះបាទសម្ដេច *ឝ្រីសូយ៌្យវម្មទេវៈ* (សូរ្យវរ្ម័នទី១) ដែលបានសោយរាជ្យជាសកល នៅឆ្នាំ ៩២៤ នៃមហាសករាជ នៅចំពោះមុខព្រះភ្លើង, ព្រះរតនៈ និងព្រាហ្មណាចារ្យទាំងឡាយ ។ (ទូលបង្គំ) យើង (ខ្ញុំ) មិនបង្គំ (គោរព)គម្ដែងផ្ទៃក្រោមដទៃឯទៀត (ក្រៅពីព្រះអង្គ) ឡើយ ពុំ(ធ្វើជា)ខ្មាំង និងពុំចំណុះខ្មាំង (ចូលដៃ សមគំនិតជាមួយខ្មាំងសត្រូវ) ពុំធ្វើប្រការអ្វីដែលអាចនឹងនាំមកនូវសេចក្ដីវិនាស (ចំពោះព្រះអង្គ) ឡើយ ។ រាល់អំពើផងទាំងឡាយ

ដែលជាផលនៃស្វាមីភក្តិភាពរបស់(ទូលបង្គំ) យើង (ខ្ញុំ) ចំពោះព្រះករុណាព្រះបាទ *ត្រីសូរ្យវង្សទេវៈ* (ទូលបង្គំ) យើង (ខ្ញុំ) នឹងខិតខំប្រឹងប្រែងធ្វើអោយបាន សម្រេច ។ ទោះបីមានចម្បាំង (ទូលបង្គំ) យើង(ខ្ញុំ) ប្តេជ្ញាច្បាំងដោយស្មោះអស់ ពីចិត្ត ដោយឥតស្តាយអាយុជីវិតឡើយ ។ ដោយស្វាមីភក្តីភាព (ចំពោះព្រះរាជា) (ទូលបង្គំ) យើង (ខ្ញុំ) មិនរត់ចោលចម្បាំងឡើយ ។ ទោះគ្មានចម្បាំង ប្រសិនបើ (ទូលបង្គំ) យើង (ខ្ញុំ) ស្លាប់ដោយសារជំងឺបៀតបៀន គឺថា សូមអោយ (ទូលព្រះ បង្គំ) យើង (ខ្ញុំ) ទាំងអស់គ្នា បានទទួលនូវផល (រង្វាន់) ជាអ្នកមានកតញ្ញូ ភក្តី ចំពោះ អម្ចាស់របស់ខ្លួន ។ ប្រសិនបើអាយុជីវិតរបស់(ទូលបង្គំ) យើង (ខ្ញុំ) អាចទាន់ព្រះ រាជការ (អាចបំរើការងាររាជការ)តទៅ រហូតដល់ពេលស្លាប់ (ក្នុងមុខងារ) (ទូល បង្គំ) យើង (ខ្ញុំ) នឹងបំរើកិច្ចការនោះ ដោយហេតុថា (ទូលបង្គំ) យើង (ខ្ញុំ) មាន ស្វាមីភ័ក្តិ (ចំពោះព្រះរាជា) ។ ប្រសិនបើមានព្រះរាជការ ដែលព្រះមហាក្សត្រ (ទ្រង់ត្រាស់)បន្ទូលប្រើ (ទូលបង្គំ) យើង (ខ្ញុំ) ទៅទីឆ្ងាយ ដោយសារមានព្រឹត្តិ-ការណ៍ ដែលព្រះរាជាបានឮគេនិយាយនោះ (ទូលបង្គំ) យើង (ខ្ញុំ) នឹងរកវិធីស្វែង យល់រឿងនោះអោយបានល្អិតល្អន់ និងប្តេជ្ញាធ្វើតាមពាក្យសច្ចាប្រណិធានរបស់ខ្លួន អោយបានខ្ជាប់ខ្ជួន រៀង១ខ្លួន ។ ប្រសិនបើក្នុងចំណោម (ទូលបង្គំ) យើង (ខ្ញុំ) ទាំងអស់គ្នានោះ មានអ្នកមិនធ្វើតាមពាក្យសច្ចាប្រណិធាននេះ ចំពោះព្រះមហា-ក្សត្រ ដែលសោយរាជ្យដ៏យូរលង់ ក្រោយៗទៀត (ទូលបង្គំ) យើង (ខ្ញុំ) សូមព្រះ អង្គដាក់ព្រះរាជទោសទណ្ឌគ្រប់ប្រការចុះ ។ ប្រសិនបើ (ទូលបង្គំ) យើង (ខ្ញុំ) មាន ល្បិចកលមិនគោរពខ្ជាប់ខ្ជួននូវពាក្យសម្បថនេះ សូមអោយ(ទូលបង្គំ) យើង (ខ្ញុំ) ធ្លាក់ទៅកើតក្នុងឋាននរកទាំង ៣២ ជាន់ អស់កាលដ៏យូរ ដរាបណានៅមានព្រះ អាទិត្យ និងព្រះចន្ទ ។ ប្រសិនបើ(ទូលបង្គំ) យើង(ខ្ញុំ) ទាំងអស់គ្នា បំពេញបានល្អ បរិសុទ្ធ តាមពាក្យសច្ចាប្រណិធាននេះ សូមព្រះគម្តែងផ្ទៃក្រោម ទ្រង់ព្រះមេត្តា

ព្រះរាជទាន(ប្រើ) អោយ(ទូលបង្គំ) យើង (ខ្ញុំ) បានថែទាំនូវការ ស្ថាបនាជាកុសល របស់ស្រុកទេសយើង និងផ្តល់នូវភាពស្ថិតស្ថេរ សម្បូរ រុងរឿងនៃវង្សត្រកូលរបស់ (ទូលបង្គំ) យើង (ខ្ញុំ) ដោយហេតុថា (ទូលបង្គំ) យើង (ខ្ញុំ) មានកតញ្ញូ ភក្តីចំពោះ ល្អងធូលីព្រះបាទ (គម្តែងផ្តែក្រោម) សម្តេចព្រះ *ស្សិវម្មិទេវៈ* ដែលព្រះអង្គទ្រង់ បានសោយរាជ្យជាសកល នៅឆ្នាំ ៩២៤ នៃមហាសករាជ ។ សូមអោយផល (រង្វាន់) នៃអ្នកមានសាមីភក្តិចំពោះព្រះរាជា ជាអម្ចាស់របស់ខ្លួន កើតមានដល់ (ទូលបង្គំ) យើង (ខ្ញុំ) ចាប់ពីលោកនេះ រហូតដល់បរលោក ។

**យី ធន់**

**សេចក្តីបញ្ជាក់របស់អ្នកបកប្រែ** :

សេចក្តីប្រែជាភាសាខ្មែរទំនើបនេះ ជាការសម្រួលតាមអត្ថបទជាភាសាខ្មែរបុរាណផង និងតាមអត្ថបទប្រែរបស់លោក ហ្សឺ.សឺដែស ផង ។ ការបន្ថែមពាក្យខ្លះ ធ្វើអោយឃ្លាខ្លះឃ្លាតឆ្ងាយពីអត្ថបទបុរាណ ប៉ុន្តែយើងខិតខំថែរក្សាន័យរបស់ឃ្លាអោយនៅដដែល ដោយគ្រាន់តែសម្រួលអោយអ្នកអានយល់បានដោយងាយប៉ុណ្ណោះ ។

# អ្នកនិពន្ធខ្មែរដែលមានឈ្មោះល្បី

លីធាម តេង
ប្រមូលចងក្រង
ព.ស ២៥១៦ គ.ស ១៩៧២

## អ្នកនិពន្ធសម័យអង្គរ

*បណ្ឌិត សិវ សោម* (សិលាចារឹកប្រាសាទកណ្ដាលដើម) សម័យរាជ្យព្រះបាទឥន្ទ្រវរ្ម័ន រវាង គ.ស ៨៧៧ - ៨៨៩,

*បណ្ឌិត យតិអមរភាវៈ* ( សិលាចារឹកភ្នំបាយង្គ ) សម័យរាជ្យព្រះបាទយសោវរ្ម័ន រវាងគ.ស ៨៨៩-៩០៨,

*បណ្ឌិត ទិវាករ* ( សិលាចារឹកប្រាសាទកំពីស ) សម័យរាជ្យព្រះបាទរាជេន្ទ្រវរ្ម័ន រវាងគ.ស ៩៤៤ - ៩៦៨,

*បណ្ឌិត កវិន្រ្ទ* ( សិលាចារឹកប្រាសាទខ្នារ ) សម័យរាជ្យព្រះបាទសូរ្យវរ្ម័ន រវាង គ .ស ១០០២ - ១០៤៩,

*បណ្ឌិត ភូបន្រ្ទ* ( សិលាចារឹកប្រាសាទទរ ) សម័យរាជ្យព្រះបាទជ័យវរ្ម័នទី៧ រវាង គ.ស ១០៨០ - ១១០៩,

*ព្រះនាង ឥន្ទ្រទេវី* ( សិលាចារឹកភិមានអាកាស ) មហេសីព្រះបាទជ័យវរ្ម័នទី៧ រវាង
គ.ស ១០៩០ - ១១០៩,

## អ្នកនិពន្ធសម័យក្រោយអង្គរ
*( លង្វែក និង ឧត្តុង្គ )*

*បណ្ឌិត ជ័យនន្ទ* - ស្នាដៃសិលាចារឹកអង្គរវត្ត ( ពាក្យកាព្យ សរសេរពីកាលខាងចុង
សតវត្សទី ១៦ ),

*អ្នកប៉ាង* - ល្បើកអង្គរវត្ត ( ពាក្យកាព្យ សរសេរពីគ.ស ១៤៩៨ ),

*ព្រះរាជសម្ភារ* - កាព្យនិរាស-ច្បាប់ព្រះរាជសម្ភារ- (សរសេរពី គ.ស ១៦៣៤),

*ឧកញ៉ាកោសាធិបតីកៅ* - រឿងក្រុងសុភមិត្រ ( សរសេរ គ.ស ១៧៩៨ ),

*ឧកញ៉ាព្រះឃ្លាំងនង* - ច្បាប់សុភាសិត ( ១៧៩០ ),
- លោកនេយ្យជាតក ( ១៧៩៤ ),
- រឿងបុញ្ញ សារសិរសា ( ១៧៩៨ ),
- រឿងភោគកុលកុមារ ( ១៨០៤ ),
- រឿងវរនេត្រវរនុជ ( ១៨០៦ ),

*ព្រះបាទអង្គឌួង* - រឿងកាកី ( ១៨១៣ ),
- ច្បាប់ស្រីព្រះអង្គឌួង ( ១៨...),

*ព្រះបទុមបារមីពេជ្រ* - របាក្សត្រស្រុកខ្មែរ ( ១៨១៨ ),

*ឧកញ៉ាសោទសខែក* - ល្បើកជេតពន ( ១៨១៥ ),

*បណ្ឌិត សំអាត* - រឿងនាងមុជលិន ឬ ព្រះចន្ទគោរព ( ១៨៣៣ ),

*ឧកញ៉ា ចក្រីកែវ* - រឿងដាវរឿង ( ១៨៤១ ),

*ព្រះអរិយគាមុនី ហ៊ីង* – រឿងព្រះជិនវង្ស (១៨៥៦),
*ព្រះធម្មបញ្ញា ម៉ែន* . រឿងពេជតា ( ១៨៥៧ ),
*ឧកញ៉ាធិបតី យ៉ែម* . រឿងនាងវិមានចន្ទ( ១៨៥៨ ),
*ឧកញ៉ាអនុជិតស្រី* . ល្បើកស្រីវិជ័យ ( ១៨៥៨ ),
*ឧកញ៉ាសុន្ទរវោហារមុក* . រឿងទេវន្ទ ( ១៨៥៩ ),

## អ្នកនិពន្ធសម័យអាណាព្យាបាលបារាំង

*ព្រះធម្មបញ្ញា អ៊ុក* : . រឿងមរណមាតា ( ១៨៧៧ ),
*បវរភក្តិព្រហ្ម* : . រឿងពោធិវង្ស ( ១៨៨១ ),
*យុនសុន្ទពិនិត្យ* : . រឿងចៅមាស ( ១៨៨៧ ),
*ឧកញ៉ាវង្សាធិបតីអ៊ុក* : . រឿងសង្ខសិល្បជ័យ ( ១៨៨២ ),
*ម៉ឺនភក្តីអក្សរតន់* : . រឿងសព្វសិទ្ធ (១៨៩៩ ),
*លោក យស ងិន* : . រឿងចៅស្រទបចេក ( ១៩ ...... ),
*វិសេស ដួង* : . ល្បើកអក ល្បើកសារិកា ( ........ ),

## ព្រះបទុមត្ថេរ សោម
(១៨៥២ . ១៩៣២)

### ជីវប្រវត្តិ :

. កវី *សោម* កើតពីឆ្នាំ ១៨៥២ នៅឃុំអំព្រៅ ស្រុកស៊ីធរកណ្ដាល ខេត្តព្រៃវែង ។

- បិតានាម *ងួន* មាតានាម *យិន* ជាកសិករ ។
- អាយុ ១៥ ឆ្នាំ បានរៀនអក្សរ លេខនព្វន្តនៅក្នុងស្រុកកំណើត ហើយបានបួសជាសាមណេរពីរវស្សា ក៏សឹកមកជួយធ្វើការរកស៊ីឪពុកម្តាយវិញ ។
- អាយុ ២១ឆ្នាំ បានឧបសម្បទា ជាភិក្ខុ ក្នុងសំណាក់ឧបជ្ឈាយ៍នាមរស់ មាននាមបញ្ញាត្តិជាបទុមត្ថេរ និងបានបន្តការសិក្សានៅក្រុងភ្នំពេញ អស់ច្រើនឆ្នាំ ហើយវិលទៅធ្វើជាចៅអធិការ នៅវត្តកំព្រេវិញ ។
- មាននិស្ស័យស្លូតបូត ចូលចិត្តអានសាស្ត្រា គម្ពីរ ស្តាប់ចំរៀងចាប៉ី រហូតចេះតែងកាព្យដ៏ប៉ិនប្រសប់ ។
- លោកសុគត នៅ គ.ស ១៩៣២ ក្នុងកំណត់ជន្មាយុ ៨០ ឆ្នាំ ។

## ស្នាដៃ :

- រឿងទុំទាវ ( សរសេរពី ព.ស ២៤៥៨ គ ស ១៩១៦ ),
- រឿងសព្វសិទ្ធិ ( មិនមែនសព្វសិទ្ធិ របស់ម៉ឺនភក្តីអក្សរតន់ទេ ),

*អត្ថបទដកស្រង់ :*

.... កាលនោះនាងនោជាភិល្បៀង- នាងទាវបានឆ្ងៀងចរយាត្រា
កាន់ក្អមថ្មីតថ្មមទឹកប្រាថ្នា ចូលទៅស្តាប់ការណ៍ដឹងសេចក្តី ។
ឈរទ្រឹងរឹងខ្លួនពួនចាំស្តាប់ ពិរោះហាក់ផ្កាប់មុខដល់ដី
ស្រងាកស្រងោចស្រងល់ស្រី នៅនឹកបេតីមិនស្តីសោះ ។
ចាំទៅដល់ផ្ទះប្រាប់ទាវគ្រប់ ទាវនៅក្នុងម្លប់សមស្រណោះ

នាងជាម្ដាយទាវមានរបស់ កូនស្រស់រូបស្រេចដាច់ស្រីផង ។
នៅទីកក្នុងចិត្តគិតស្រេចស្រាប់ ដងទឹកងូតឆាប់ដើរផ្សៀងផ្អង
ដល់ផ្ទះនោះឡើងទៅជាម្តង សាសងរ៉ាយរ៉ាប់ប្រាប់ទៅថា ។
ទាវអើយទាវស្រីសេចក្តីនេះ នេនមួយនោះចេះមើលសាស្ត្រា
ពិរោះស្រួយស្រាប់ស័ព្ទភាសា ដូចសត្វសារិកាពិសាចេក ។

*(រឿងទុំទាវ)*

## ឧកញ៉ាសុត្តន្តប្រីជា ឥន្ទ
( ១៨៥៩ . ១៩២៤ )

## ជីវប្រវត្តិ ៖

- កវី *ឥន្ទ* កើតនៅឆ្នាំ ១៨៥៩ នៅរការកោង ស្រុកមុខកំពូល ខេត្តកណ្ដាល ។
- មាតានាម *ម៉ុំ* បិតានាម *បញ្ញង់កែ* ជាកសិករ និងជាអាចារ្យវត្ត,
- អាយុ ១០ ឆ្នាំ ទៅនៅវត្ត ហើយបួសជាសាមណេរ បានរៀនប្រែគម្ពីរបាលី,
- អាយុ ២០ ឆ្នាំ ចេញទៅបន្តវិជ្ជានៅប្រទេសសៀម អស់ ៧ ឆ្នាំ,
- អាយុ ៣៧ ឆ្នាំ បានលាចាកផ្នួស មានគ្រួសារនៅបាត់ដំបង,
- អាយុ ៥៥ ឆ្នាំ បានចូលមកធ្វើការនៅពុទ្ធសាសនបណ្ឌិត្យ ខាងតែងវចនានុក្រម និងផ្ទៀងផ្ទាត់គម្ពីរ ដីកា ។
- អាយុ ៦៥ ឆ្នាំ បានលារាជការឈប់ត្រឡប់ទៅបាត់ដំបងវិញ ហើយទទួលអនិច្ចកម្មនៅ គ.ស ១៩២៤ ។

## ស្នាដៃ :

- គតិលោក ( បោះពុម្ពដោយពុទ្ធសាសនបណ្ឌិត្យ ),
- និរាសនគរវត្ត ពាក្យកាព្យ ( បោះពុម្ពដោយពុទ្ធសាសនបណ្ឌិត្យ ),
- រឿងអំបែងចាន ( ជាសាស្ត្រាស្លឹករឹត ),
- បឋមសម្ពោធិ ( ជាក្រាំង ),
- លោកនីតិបករណ៍ ( ពាក្យកាព្យ ),
- សុភាសិតច្បាប់ស្រី( បោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ ),
- ក្បួនមេកាព្យ,

និង ស្នាដៃដទៃច្រើនទៀត បូករួមមាន ៤៤ មុខ ។

*អត្ថបទដកស្រង់ :*

...គយគន់ឋានស្ពានថ្មតប្រជិត មានក្ការថ្មដាសជិតប្រកិតគោក
ទោះដីរីបរជាន់ក៏គ្មានយោគ ឥឡូវជ្រោកស្រុតខ្លះតែដើរបាន ។
បង្កាន់ដៃឆ្វេរបវាសុក្រី ដប់សិរសីដូចស្មិតជិតជុំប្រាណ
បើកពពាឡើងពពាក់បាក់បាវបាន សម្តែងប្រាណប្រញូរបជាមួយគ្នា ។
មើលនាគរាជអង់អាចអំណាចស្វែង ខ្លួនក៏វែងក្បាលក៏វក់តាមទ្វារា
លូនលើស្ពានមានជើងកល់គង្គា កន្ទុយបែកញែកគ្នាតាមផ្លាផ្លូវ ។
ឱរូបវាសុក្រីឥតក្រែងគ្រុឌ តាំងសម្តែងឫទ្ធិរុទ្ធតសត្រូវ
ប្រសិនគ្រុឌមកយល់យ៉ាងពុំនៅ គង់ស្ទុះទៅជ្រកក្នុងកសិណនេះ ។
នាគអើយនាគបាសាណបុរាណសាង ពីដើមយ៉ាងល្អឯកដូចម្តេចអេះ
ឥឡូវនាគងាកធ្លាក់បាក់របេះ ឃើញតែរាងយ៉ាងនេះអស់លំអ ។

*( និរាសនគរវត្ត )*

# ភិរម្យ ង៉ុយ ឬ ក្រមង៉ុយ

( ១៨៦៥ - ១៩៣៦ )

## ជីវប្រវត្តិ :

- កើតពី គ.ស ១៨៦៥ នៅឃុំកំបូល ស្រុកភ្នំពេញ ។
- បិតានាម *អ៊ុក* ធ្វើជាមេឃុំ ងារជាចៅពញាធម្មធារា ។
- ចូលរៀននៅវត្តអង្គបឹងចក ក្នុងឃុំកំណើត ហើយបួសជាសមណេរ ចាប់រៀនប្រែគម្ពីរបាលី ។
- អាយុ ២១ ឆ្នាំ បួសជាភិក្ខុ ស្វែងរៀនប្រែបិដកជាច្រើនវត្ត ហើយរៀនវិបស្សនាកម្មដ្ឋានទៀត ។
- សឹកពីបួសហើយ ធ្វើជាកសិករធម្មតា និងទទួលការអញ្ជើញពីអ្នកស្រុកអោយទៅទេសនា ដូចជាសង្ឃដែរ ។
- ចេះច្រៀងពិរោះ ប្រកបសាដៀវ កំប្លែងផង ទូន្មានផង ដាស់តឿនកូនខ្មែរអ្នកស្រុកខ្មែរផង ។
- បានច្រៀងអោយពួកស្រាវជ្រាវបារាំងស្ដាប់ពេញចិត្ត ចម្លងយកមកបោះពុម្ពបាន ៥ ច្បាប់ ហើយនាំទៅលេងឯស្រុកសៀម ។
- ទទួលអនិច្ចកម្ម ក្នុងខែមិគសិរ គ.ស ១៩៣៦ អាយុបាន ៧១ ឆ្នាំ ។

## ស្នាដៃ :

- ច្បាប់ល្បើកថ្មី ( បោះពុម្ពផ្សាយពីពុទ្ធសាសនបណ្ឌិត្យ )
- សេចក្ដីរំលឹកដាស់តឿន ( បោះពុម្ពផ្សាយពីពុទ្ធសាសនបណ្ឌិត្យ )
- ច្បាប់កេរកាលថ្មី ( បោះពុម្ពផ្សាយពីពុទ្ធសាសនបណ្ឌិត្យ )

- ច្បាប់ទូន្មានជនប្រុស-ស្រី ( បោះពុម្ពផ្សាយពីពុទ្ធសាសនបណ្ឌិត្យ )

*ដកស្រង់អត្ថបទ :*

....កុំឆ្មើងអាងបុណ្យ ស្រដីស្រទន់
ពោលពាក្យពិរោះ ខ្លួនអ្នកនឹងថ្កើង
នឹងឡើងសក្តិយស កុំឆ្មៀតនាំឈ្លោះ
ញុះញង់អ្នកធំ ។
កុំស្អប់អ្នកតូច បើឃើញគ្នាខូច
គួរគិតប្រមុម ទោសគ្នាតិចតួច
ផ្តួចផ្តើមជាធំ ផ្សែងពួតជាដុំ
ផ្តុំឆេះជាភ្លើង ។
កុំភ្លើនភ្លេចខ្លួន ចេះសាសន៍ចិនយួន
កុំភ្លេចខ្មែរយើង កុំធ្វើក្រអើត
កុំពើតកុំពើង កុំពាក់ស្បែកជើង
ចូលវត្តលោកសង្ឃ ។

*( ច្បាប់ល្បើកថ្មី )*

## លោក នូ . កន

( ១៨៧៤-១៩៤៧ )

## ជីវប្រវត្តិ :

- លោក *នូ-កន* កើតពី គ.ស ១៨៧៤ នៅអង្គតាសោម ស្រុកត្រាំកក់

ខេត្តតាកែវ ។

- មាតានាម *នូ* បិតា នាម *អ៊ុក* ជាកសិករ,
- អាយុ ៩ ឆ្នាំ បានទៅនៅរៀនវត្តឆ្នោត,
- អាយុ ១៤ ឆ្នាំ បួសជាសាមណេរបាន ១ វស្សា,
- អាយុ ១៧ ឆ្នាំ ចូលធ្វើជាស្មៀនចៅហ្វាយខេត្តទ្រាំង,
- ១៨៩១ បានចូលធ្វើការក្នុងក្រុមអាលក្ខណ៍ ក្នុងវាំង ៤ ឆ្នាំ ហើយនៅធ្វើការក្នុងក្រុមសុរិយោដី, រួចឃ្លាំងប្រាក់,
- ១៩០២ ប្រឡងជាប់លេខ ១ ជាឡៃត្រេ រាជការបារាំងបានចាត់អោយទៅបន្តវិជ្ជាខាងច្បាប់នៅក្រុងប៉ារីស លុះត្រឡប់វិញ បានធ្វើចៅហ្វាយខេត្តកំពង់សៀម ចាងហ្វាងសាលាលុឃុនសាលាឧទ្ធរណ៍ រួចជាភូឈួយសេនាបតី ក្រសួងក្សេត្រាធិការ,
- ១៩៤៥ ជាប់ឆ្នោតជាតំណាងរាស្ត្រ មណ្ឌលកោះសូទិន,
- ទទួលអនិច្ចកម្មនៅ គ.ស ១៩៤៧ នៅលំនៅឋានក្រុងកំពង់ចាម ។

## ស្នាដៃ :

- រឿងសាមកុក រឿងប្រែ
- រឿងពិម្ពានិព្វាន ពាក្យកាព្យ
- រឿងទាវឯក ពាក្យកាព្យ
- រឿងតុងឈិន ប្រលោមលោកពាក្យរាយ
- រឿងសមុទ្ទជេដ្ឋា ប្រលោមលោកពាក្យរាយ
- រឿងមហាសុបស្សីតាបស មិនទាន់បោះពុម្ព
- រឿងឥណាវ មិនទាន់បោះពុម្ព

*ដកស្រង់ស្នាដៃ :*

...ស្រីប្រុសខ្លះក្រាស់កាមប្រលោក គិតតែស្នេគ្រជាក់ដល់វល់ចិន្តា
នឹកឃើញរឿងក្នុងខ្លួនមានសង្សារ ពីកាលណានិរាសប្រាសទីទៃ ។
ខ្លះក៏ប្រាសទាំងរស់ខ្លះប្រាសស្លាប់ លុះមកស្តាប់ស័ព្ទសត្រកើតរីងរៃ
នឹកដល់ដើមកំសត់មិត្តម្ចូលមៃ ឆ្អែតហាឫទ័យន័យនឹកស្រក់ទឹកនេត្រ ។
ខ្លះអាល័យអាឡោះស្រណោះផ្សេង ដោយសំឡេងអន្លង់ពីងសម្តេច
ដូចជាដើមក្នុងព្រៃឆ្ងាយទូរេត ពេលវិសុយេតសាយណ្ហទន់ត្រជាក់ ។
ខ្លះពោះម៉ាយស្តាយមិត្តគិតខ្មោចនាង ឯមេម៉ាយស្តាយរាងរូបខ្មោចអ្នក
តារអាណោចខ្មោចយាយវាយមាយភ្ញាក់ យាយញញាក់នឹកខ្មោចដល់ខ្មោចតា ។

*(រឿងទាវឯក )*

លោក **បាន - តេង**

( ១៨៨២ - ១៩៥០ )

## ជីវប្រវត្តិ :

- លោក បាន តេង កើតពីខែមិគសិរ ឆ្នាំមមែ ព.ស ២៤២៥ ត្រូវនឹងគ.ស ១៨៨២ នៅសង្កាត់លេខ ៤ ក្រុងភ្នំពេញ ។

- មាតានាម ត្រយ៉ង់ បិតានាម បាន ធ្វើមន្ត្រីនៅក្នុងវាំង,

- ពីកុមារ បានចូលរៀននៅសាលាបឋមសិក្សា បារាំង - ខ្មែរ,

- អាយុ ១៤ ឆ្នាំ បានបួសជាសាមណេរ ក្នុងសំណាក់សម្តេចមង្គលអៀម វត្តបទុមវតី បានមួយវស្សា,

- បន្តការសិក្សាភាសាបារាំងក្នុងសាលា និងរៀនភាសាសៀមថែមទៀតផង,

- គ.ស ១៩១៩ ចូលធ្វើការក្នុងឃ្លាំងប្រាក់ រួចជាស្មៀនក្នុងវាំង,

- គ.ស ១៩២១ ចូលធ្វើគ្រូផ្លាស់ទៅកោះកុង ៥ ឆ្នាំ ទើបវិលមកភ្នំពេញវិញ,

- បានរៀនក្បួនកាព្យពីលោកសុត្តន្តប្រីជា ឥន្ទ ព្រះធម្មរក្ខិត ប៉ាត នៅវត្តសុគន្ធមានបុណ្យ ឧត្តុង្គ,

- ទទួលមរណភាព នៅថ្ងៃ ២៨ កក្កដា ១៩៥០ ។

## ស្នាដៃ :

- សប្បុរិសធម៌ ៧ ប្រការ ( ផ្សាយពីពុទ្ធសាសនបណ្ឌិត្យ ),
- ឱវាទនារី ពាក្យកាព្យ ( ផ្សាយក្នុងប្រក្រតិទិន ឆ្នាំ ១៩៤៦ ),
- លោកធម្មត្តចរិយា,
- រឿងនាងស្រីហង្សានដាក់,
- អត្ថបទមេស្ងួត្រ និង រឿងប្រែខ្លីៗ ច្រើនណាស់,
- រឿងឆទ្ទន្តជាតក ពិម្ពាពិលាប និង ទិព្វសង្វារ មិនទាន់បោះពុម្ព ។

## អត្ថបទដកស្រង់

.... ក្រមុំតូចដូចបទុមក្រពុំពក
ប៉ិចពន្លកពីអន្លង់វារីសាយ
ស្រទាប់ត្រៀងលឿងបំព្រងលំអងខ្ចាយ
ជាតម្រាយអោយភមរាប្រាថ្នាប៉ង ។
គ្រេបជញ្ជក់បុប្ផជាតិជួញស្រទាប់
លុះជញ្ជក់ស្កប់ស្កល់ចិត្តចោលជាម្តង

ចូលមកភ្លក់ជាតិមួយភ្លែតអោយសៅហ្មង
ប្រុសបំណងបែបប៉ុណ្ណឹងចូរដឹងទាន់ ។

ថាបើមានប្រុសណាមួយចង់មកស្និទ្ធ
ត្រូវមើលចិត្តគេអោយជាក់កុំបីភាន់
ឯកម្លោះនេះក្រឡេចល្បិចច្រើនជាន់
មិនចេះទ្រាន់ស្ករកន្ទ្រីសស្នមស្នេហា ។

( ឱវាទនារី )

## អ្នកស្រី សិទ្ធ

( ១៨៨១ - ១៩៦៣ )

## ជីវប្រវត្តិ :

- កើតថ្ងៃពុធ ខែមិគសិរ ឆ្នាំមមី ព.ស ២៤២៤ ត្រូវនឹងឆ្នាំ១៨៨១ គ.ស នៅសង្កាត់លេខ ៤ ក្រុងភ្នំពេញ ។

- ជាកូនពៅនៃលោក ពិពិនសិរី ចាងហ្វាង សូ អ្នកស្រី ឆ្លង,

- បានរៀនអក្សរខ្មែរ អក្សរសៀម ក្នុងសំណាក់ឪពុក និងអ្នកជិតខាង,

- ចេះបើកក្រាំង បើកបទ ក្នុងក្រុមរបាំព្រះរាជទ្រព្យយ៉ាងប៉ិនប្រសប់,

- មានស្វាមីជាមន្ត្រីខាងតុលាការ និង មានបុត្រីមួយនាក់,

- ប៉ិនប្រសប់តែងកាព្យបានភ្លាមៗ ដូចជា បានឆ្លងឆ្លើយក្នុងការបើកបទសកវាទីប្រកួតជាមួយក្រុមវាំង ជាដើម,

- បានធ្វើជានាយិកា នៃក្រុមបើកក្រាំងមហោរី,

- នៅពេលអាយុចំណាស់ បានទៅនៅវត្តបទុម កាន់សីល ១០ បម្រើសង្ឃ និង បានសាងកុដិទុកបូជាសង្ឃ,

. ជន្មាយុ ៨២ ឆ្នាំ បានទទួលមរណភាពនៅថ្ងៃ ៥ កញ្ញា ១៩៦៣ ។

## ស្នាដៃ :

. រឿង ពិម្ពាពិលាប ( បោះពុម្ពឆ្នាំ ១៩៤២ ),
. រឿង គូសាង ឬ មិត្តមិនទ្រុស្តមិត្ត ( បោះពុម្ពឆ្នាំ ១៩៥២ ),
. រឿង ចិត្តសត្យា ( បោះពុម្ពឆ្នាំ ១៩៥៣ ),
. បែបបទសកវាទី ( ភាគខ្លះ បោះពុម្ពពីឆ្នាំ ១៩៣២ )

## អត្ថបទដកស្រង់:

.... ថ្វីបើស្រីខឹងប្រឹងស្រែកជេរ មិនទេមិនទើងខឹងសោះឡើយ
ប្ដីនាងត្រូវសរស្លាប់ទៅហើយ កែវអើយគឺកម្មនាំសរទៅ ។
ចិត្តបងគ្មានប៉ងនឹងប្រមាថ តែព្រួញវាផ្លាតខ្ទាតទៅត្រូវ
បងបាញ់សត្វសោះចុះឥឡូវ ស្រីពៅនៅថ្វីព្រៃព្រឹក្សា ។
យំសោករកប្ដីអាល័យរស់ គឺមោះនឹងបានប្រាណស្នេហា
នេះទៅជាខ្មោចខ្ទិចអសារ សោកាធ្វើថ្វីស្រីតាមបង ។

..........................................................................

ធើយស្ដេចអបលក្ខណ៍ចិត្តយ័ក្ខយង់ កុំមករារង់ប្រឹងរិះរេ
លួងចិត្តអញឥតអំពើទេ ប្ដីគេគេនៅមួយមូលគ្នា ។
មកកេងចង់បានប្រពន្ធគេ ទទេតាមចិត្តឥតរួញរា
បាញ់ប្ដីគេស្លាប់ត្រឡប់ជា ក្លែងថាបាញ់សត្វផ្លាតទៅត្រូវ
ស្លាប់ប្ដីរំពៃចង់ប្រពន្ធ មិនស្គាល់ទោសធ្ងន់ពន់ពេកក្រូវ
ទេវតាបរាមុខឥឡូវ ស្លាប់ទៅនៅនានរកនាយ ។

( ស្រង់ពីពិម្ពាពិលាប )

# លោក រីម គិន

( ១៩១១ - ១៩៥៩ )

## ជីវប្រវត្តិ :

- កើតពី គ.ស ១៩១១ នៅសង្កាត់លេខ ៤ ក្រុងភ្នំពេញ,

- មាតានាម រសា បិតានាម គឹម ធ្វើនាយត្រួតការសាធារណការ,

- ចូលរៀនដំបូងនៅវត្តស្វាយដង្គំ ចេះអក្សរ មើលសាស្ត្រាបានសព្វគ្រប់ ទើបទៅចូលរៀននៅសាលា ឌូដារត៍ដឺឡាគ្រេ,

- ១៩២៩ ចូលអនុវិទ្យាល័យស៊ីសុវត្ថិ អស់ពេល ៤ ឆ្នាំ,

- ១៩៣៣ បានចូលរៀនវិជ្ជាគរុកោសល្យ ចេញធ្វើគ្រូជាដំបូងផ្លាស់ទៅខេត្តបាត់ដំបង,

- ១៩៣៥ បានផ្លាស់មកភ្នំពេញវិញ ជាអនុរក្សនៅវិទ្យាល័យស៊ីសុវត្ថិ,

- ១៩៤៧ ជាសាស្ត្រាចារ្យភាសាខ្មែរ នៅសាលាគរុវិជ្ជា,

- ១៩៥៥ - ៥៦ ជាប់ឆ្នោតជាប្រធានសមាគមអ្នកនិពន្ធខ្មែរ,

- បានសរសេររឿងប្រលោមលោក សៀវភៅសិក្សា, កំណាព្យ និងរឿងខ្លីៗ បោះពុម្ពហើយខ្លះ ពុំទាន់បោះខ្លះ រួមទាំងអស់មាន ៣៤ ឈ្មោះ,

- ទទួលអនិច្ចកម្ម នៅថ្ងៃ ២៧ មករា ១៩៥៩ ដោយរោគរលាកខួរ ។

## ស្នាដៃ :

ស្នាដៃសំខាន់ៗ គឺ :

- រឿង សូផាត ( បោះពុម្ពពីឆ្នាំ ១៩៣៨ ),
- ចិត្តចងចាំ ( បោះពុម្ពឆ្នាំ ១៩៤៨ ),
- ស្ត្រីកំព្រា ( បោះពុម្ពឆ្នាំ ១៩៥១ ),
- មើលព្រះចន្ទ្រា ( បោះពុម្ពឆ្នាំ ១៩៥២ ),

- នាងសមាភារី ( បោះពុម្ពឆ្នាំ ១៩៥២ ),
- ពលវង្សា ( បោះពុម្ពឆ្នាំ ១៩៥៣ ),
- នាងរតននារី ( ពាក្យកាព្យ ១៩៥៤ ),
- ឈាមរកឈាម ( ពាក្យកាព្យ ១៩៥៥ ),
- រៀនមើលពន្យល់ ( . ពាក្យកាព្យ ១៩៥៧ ),

*អត្ថបទដកស្រង់ :*

... ស្ងួផាត ប្រដាប់ដោយខោអាវចាស់តែមួយសម្រាប់ ប្រញិប ប្រញាប់ទាញសំបុត្រមួយពីហោប៉ៅដាក់ទៅលើតុ ស្ទុះសីម១ ចុះមកដី ដើរចេញទៅក្រៅរបងភ្លាម ។ អ្នកក្រឡេកមើលទៅផ្ទះ លើកដៃសំពះ « ឱ គុណបុណ្យព្រះម្ចាស់ថ្លៃ ខ្ញុំបួងសួងសូមលោកជួយទ្រទ្រង់វង្សាលោកអធិបតីសេនា ដែលប្រកបដោយចិត្តវិសេសល្អ » ។

ទឹកភ្នែកជោរចេញពេញមុខមួយរំពេច ។

ស្ងួផាត ឈានជើងដើរ ក្តុកក្តួងចិត្ត អាឡោះអាល័យ មិនចេះអស់មិនចេះហើយ ពីវង្សត្រកូលលោកអធិបតីសេនា ។ អ្នកនឹកឃើញថា លោកនាម៉ឺនធំ មានគុណនឹងអ្នកស្មើឪពុកបង្កើត ។ ណារិន ជាមិត្តរកគ្មាននៅក្នុងលោក ។ ម៉ានយ៉ាន ជាធីតាដែលតែងតែរាប់អានអ្នកដោយស្មោះត្រង់ ។

ការខុស គឺខ្លួនអ្នកដែលក្បត់ចិត្តត្រង់របស់នាង ។

( រឿង ស្ងួផាត )

## លោក **ហេង យ៉ាន់**

( ១៩២១ - ១៩៦៧ )

*ជីវប្រវត្តិ :*

- កើតនៅថ្ងៃ ២៦ មករា១៩២១ នៅសង្កាត់លេខ ៣ ក្រុងភ្នំពេញ,

- មាតានាម ទេស - ទីម បិតានាម សៅ - ហេង ជាមន្ត្រីក្នុងវាំង,

- អាយុ ៧ ឆ្នាំ ចូលរៀននៅសាលាប្រាំងស្វា រួចចូលវិទ្យាល័យស៊ីសុវត្ថិ នៅ គ.ស ១៩៣៥,

- ឆ្នាំ ១៩៤៤ ធ្វើជាលេខាធិការបច្ចេកទេស ហើយប្រឡងជាប់ជាសីក្រេទែរវេស៊ីដង្គ និងជាប់ចូលរៀនសាលារដ្ឋបាល,

- ១៩៤៤ ជាប់សញ្ញាបត្រសាលារដ្ឋបាល ទៅធ្វើបាឡាត់ស្រុកបាកានខេត្តពោធិសាត់,

- ១៩៤៦ ចូលមកធ្វើការនៅក្រសួងហិរញ្ញវត្ថុ ជានាយការិយាល័យនាយក្រុម ហើយជានាយកការិយាល័យ ដោយបានផ្លាស់ប្ដូរក្របខ័ណ្ឌពីមន្ត្រីរដ្ឋបាល មកខាងក្រសួងហិរញ្ញវត្ថុវិញ ។ ក្នុងមុខក្រសួងនេះ លោកបានទទួលភារកិច្ចទៅបំពេញបេសកកម្ម ឯបរទេសជាញឹកញាប់,

- បានសិក្សាខ្មែរហ្មត់ចត់ ក្នុងសំណាក់ព្រះគ្រូសំសត្ថា ជួន - ណាត, ព្រះគ្រូសិរីជ្ញា ហួត - តាត, ព្រះអាចារ្យ ប៉ែន - សុខ ជាដើម,

- ទោះបីជាប់កិច្ចការច្រើនក្ដី លោកនៅតែខិតខំឆ្លៀតសរសេរ ខំអានខំស្រាវជ្រាវ ចងក្រង រៀបរៀងជាសៀវភៅសិក្សាខ្លះ ប្រលោមលោកខ្លះ,

- ទទួលអនិច្ចកម្មនៅថ្ងៃទី ២៨ ឧសភា ១៩៦៧ អាយុបាន ៤៦ ឆ្នាំ ។

## ស្នាដៃ :

- រឿង កំពូលកំសត់ ( បោះពុម្ពផ្សាយក្នុងកម្ពុជសុរិយា ១៩៤៤ ),
- រឿង កំពូលស្នេហា ( បោះពុម្ពផ្សាយក្នុងកម្ពុជសុរិយា ១៩៤៦ ),
- អក្សរសាស្ត្រខ្មែរ ជាគោលប្រវត្តិ ( បោះពុម្ព ១៩៥៦ ),
- ប្រជុំរឿងល្បើក ពាក្យកាព្យ ( បោះពុម្ព ១៩៥០ ),
- អំពីការវែងនៃវដ្ដសង្សារ ( បោះពុម្ព ១៩៥៧ ),

- អត្ថបទខ្លីៗ ច្រើនទៀតចុះផ្សាយក្នុងទស្សនាវដ្ដីមិត្តសាលាបាលី ។

*អត្ថបទដកស្រង់ :*

... ក្នុងខណៈនោះ ឮស្វរជើងមនុស្សរត់ពីក្រោយខ្នងមក សោភ័ក្រ្តក៏ងាកភ្លាម ឃើញក្មេងកាន់ក្រដាសពណ៌ខៀវ សណ្ឋានបួនជ្រុង ហុចអោយពីចម្ងាយមក ។ សោភក្រ្ត ស្ទុះពីកៅអី ទទួលបានសំបុត្រកាន់នៅដៃ ហើយវិលត្រឡប់មកអង្គុយកន្លែងដដែលវិញ លើកសំបុត្រឡើងដាក់លើដើមទ្រូង ដោយសេចក្ដីគោរព តក់ស្លុត រន្ធត់ចិត្ត អរផង ភ័យផង ញ័រដៃ ហែកសំបុត្រស្ទើរមិនចង់កើត ។

ខណៈដែលសោភ័ក្រ្តអានសំបុត្រចប់ ចិញ្ចើមក៏ត្របាញ់ចូលគ្នាឡើងជាទ្រនុងត្រង់លើខ្នង់ច្រមុះ ។ មើលបានពាក់កណ្ដាល ក៏សំឡឹងមើលទៅឆ្ងាយយ៉ាងស្រងូតស្រងាត់ យូរបន្តិចបានលើកសំបុត្រឡើងអាន តទៅទៀត មុខក្រញូវសន្សឹមៗ រីកបន្តិចម្ដងៗឡើងវិញ ចុងបំផុត បបូរមាត់ញញឹមយ៉ាងស្រស់ ។

( រឿង កំពូលស្នេហា )

## លោក **រឹម - ស៊ុំងា**

( ១៩២២ - ១៩៧១ )

## ជីវប្រវត្តិ :

- កើតនៅថ្ងៃ ២៣ មេសា ១៩២២ នៅឃុំផ្សារក្រោម ស្រុកបាកាន ខេត្តពោធិសាត់ ។

- មាតានាម សេង - លិញ បិតានាម ម៉ៅ - រ៉ែហិល ជាមន្ត្រីក្នុងរាជការអាណាព្យាបាល " សីក្រេទែរ រ៉េស៊ីដង្គ " ,

- អាយុ ៧ ឆ្នាំ ចូលរៀននៅកំពង់ស្ពឺ រួចនៅកំពង់ចាម,
- អាយុ ១២ ឆ្នាំ បិតាទទួលអនិច្ចកម្មទៅ មករៀននៅភ្នំពេញ,
- ១៩៤០ ចូលរៀនសាលាច្បាប់ ចេញទៅធ្វើជាមន្ត្រីក្នុងតុលាការ,
- ១៩៤៣ ធ្វើក្រឡាបញ្ជី នៅសាលាដំបូងកំពង់ធំ,
- ១៩៤៥ ធ្វើសុភាចារបុរស នៅសាលាដំបូងសៀមរាប ក៏បានរៀបអាពាហ៍ពិពាហ៍ នៅសៀមរាប ។
- ១៩៤៧ ជាចៅក្រម នៅសាលាឧទ្ធរណ៍ រួចផ្លាស់ទៅកំពង់ចាម មកភ្នំពេញវិញ នឹងទៅសិក្សានៅប្រទេសបារាំងមួយឆ្នាំ,
- ១៩៦២ ជាប់ឆ្នោតជាតំណាងរាស្ត្រ មណ្ឌលជីក្រែង ខេត្តសៀមរាប,
- បានធ្វើជាប្រធានសមាគមអ្នកនិពន្ធខ្មែរ ពីឆ្នាំ ១៩៥៧ ដល់ ១៩៦៤,
- ជាសាស្ត្រាចារ្យមហាវិទ្យាល័យច្បាប់ អស់ពេលច្រើនឆ្នាំ,
- ទទួលអនិច្ចកម្ម នៅថ្ងៃទី ៤ កញ្ញា ១៩៧១ ។

## ស្នាដៃ :

- រឿង ចិត្តឪពុក (បោះពុម្ពផ្សាយ ឆ្នាំ ១៩៥៩),
- រឿង ចោរបិទមុខ ( បោះពុម្ពផ្សាយ ឆ្នាំ ១៩៥១ ),
- រឿង ចោរលួចប្រាក់ ( បោះពុម្ពផ្សាយ ឆ្នាំ ១៩៥៣ ),
- រឿង ចោរភ្នំត្បែង ( បោះពុម្ពផ្សាយ ឆ្នាំ ១៩៥៥ ),
- ពន្យល់ច្បាប់សំរាប់ប្រជារាស្ត្រ ( បោះពុម្ពផ្សាយឆ្នាំ ១៩៦០ ),
- វចនានុក្រមច្បាប់ ( បោះពុម្ពផ្សាយ ឆ្នាំ ១៩៦៨ ),

## ដកស្រង់ស្នាដៃ:

... អច្ឆរិយ៍ មិននិយាយអ្វីច្រើនទេ ចាប់ដៃនាងបារមិត្រេរត់ឡើងឡានហ្ស៊ីបរបស់លោកតេជកុល អង្គុយទន្ទឹមគ្នា បរចេញពីទីនោះ សំដៅទៅផ្ទល់

ភ្លាមទៅ ។ បាត់ប្រហែលកន្លះម៉ោង ទើបឃើញយុវជនទាំងពីរនេះត្រឡប់មកវិញដោយទឹកមុខញញឹមរីករាយ ហើយស្រែកពីនាយឡើងថា ៖ អ្នកម្ដាយរៀបចំទៅ លោកធានាថានាំយកក្រុមប៉ូលីសជាតិមកទទួលយើងហើយ ។

តាំងពីថ្ងៃនោះមក បណ្ដាជនក្នុងប្រទេសកម្ពុជាទាំងមូល មានសោមនស្សតែរាល់រូប ចំណែកឈ្មួញជួញដូរ បានរកស៊ីក្នុងសេរីភាព ដោយសារស្នាដៃពួកកងទ័ពនៃនាងចរណៃ ដែលរាជការខ្មែរបានយកមកទំនុកបំរុង ហើយឱ្យបង្ក្រាបអស្ដិសុខឱ្យបានស្ងាត់ឥតឆាប់ ។

( រឿង ចោរបិទមុខ )

| | | |
|---|---|---|
| កើតជាអង្គ | ពង្សជាមនុស្ស | ប្រុសឬស្រី |
| មានសំដី | ថ្វីគំនិត | គិតគ្រប់ប្រាណ |
| ត្រូវប្រឹងរៀន | រៀនអោយចេះ | ចេះចំណាន |
| ទើបជាតិបាន | ឋានខ្ពង់ខ្ពស់ | យសថ្កុំថ្កើង ។ |

# ផ្ទុះភាពខ្លះនៃអក្សរសិល្ប៍ខ្មែរ

អក្សរសិល្ប៍ខ្មែរ មានប្រភពកំណើតជាមួយនឹងមនុស្សខ្មែរ និងមានការទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងសភាពការណ៍ប្រវត្តិសាស្ត្ររបស់ប្រទេសជាតិ ព្រមទាំងទទួលឥទ្ធិពលយ៉ាងខ្លាំងពីសាសនាធំពីរគឺ ព្រហ្មញ្ញសាសនា និងពុទ្ធសាសនា ។ ព្រោះហេតុនោះហើយបានជា អក្សរសិល្ប៍ខ្មែរមានការវិវឌ្ឍន៍រីកចំរើន និងប្រែប្រួល ទៅតាមសម័យកាលនៃប្រវត្តិរបស់សង្គមខ្មែរ ។

គេបានរកឃើញស្នាដៃអក្សរសិល្ប៍ខ្មែរ ដែលនៅមានសេសសល់ តាំងពីសម័យមុនអង្គរ ។ ពេលនោះ គេនិយមប្រើភាសាសំស្ក្រឹត ជាភាសាអ្នក អក្សរ-សាស្ត្រ និងជាភាសាពិសិដ្ឋ ។ ការនិយមប្រើភាសាសំស្ក្រឹត ជាភាសាពិសិដ្ឋនេះ មានបន្តរហូតដល់សម័យអង្គរ ។ អ្នកប្រាជ្ញខាងបុរាណវិទ្យា បានរកឃើញសិលាចារឹកជាភាសាខ្មែរ និង ភាសាសំស្ក្រឹត ជិត២.០០០ ផ្ទាំង ដែលគេបានចារទុកតាមប្រាសាទនានា នៅលើទឹកដីដ៏ធំទូលាយរបស់អាណាចក្រខ្មែរបុរាណ ។ សិលាចារឹកជាភាសាសំស្ក្រឹត ដែលមានចំណាស់ជាងគេ គឺ សិលាចារឹក វ៉ូកាញ បច្ចុប្បន្ននៅក្នុងតំបន់ញ៉ាត្រាង ប្រទេសវៀតណាម ដែលមានអាយុតាំងពីសតវត្សទី ៣ គ.ស ។ រីឯសិលាចារឹកជាភាសាខ្មែរ ដែលយើងរកឃើញ នៅត្រង់តំបន់អង្គរបុរី ខេត្តតាកែវ មានចុះកាលបរិច្ឆេទ ៥៣៣ នៃមហាសករាជ គឺត្រូវនឹងឆ្នាំ ៦១១ គ.ស ។ តែទោះបីអក្សរសិល្ប៍ខ្មែរមានចំណាស់ដ៏យូរលង់រាប់ពាន់ឆ្នាំ និងមានចំនួនមិនតិចជាងចំនួនប្រាសាទបុរាណក៏ដោយ ក៏អក្សរសិល្ប៍ខ្មែរមិនសូវល្បីរន្ទឺទៅខាងក្រៅ ដូចដែលគេតែងស្គាល់ និងកោតសរសើរចំពោះស្នាដៃសិល្បៈខ្មែរឡើយ ។ អត្ថបទ និងខ្លឹម

សារនៃអក្សរសិល្ប៍ ទោះបីគេមើលមិនឃើញសំបើមដូចជាប្រាសាទអង្គរវត្ត ក៏ដោយ ក៏មានសារសំខាន់យ៉ាងខ្លាំង ជួយអោយអ្នកប្រាជ្ញ អ្នកសិក្សាស្រាវជ្រាវ រកឃើញពន្លឺខ្លះ ក្នុងការស្វែងយល់អំពីប្រវត្តិសាស្ត្រ អំពីវប្បធម៌ និងអរិយធម៌ របស់មនុស្សខ្មែរជំនាន់មុន ។

ដូចយើងបានបញ្ជាក់ខាងលើស្រាប់មកហើយថា អក្សរសាស្ត្រខ្មែរ ពុំមែនមានតែធាតុរបស់ខ្លួនមួយដាច់ដោយឡែក កកើតឡើងតែឯងទេ ប៉ុន្តែវាមានទំនាក់ទំនងជាច្រើនជាមួយនឹងអក្សរសាស្ត្រ និងភាសាឯទៀតដែលហូរចូលមកពីខាងក្រៅ ដូចជាភាសាសំស្ក្រឹត បាលី និងភាសានៃប្រទេសជិតខាង ភូមិផងរបងជាមួយ មានភាសាថៃ ចិន ជាដើម ។ នៅក្នុងការវិវឌ្ឍន៍ និងសាកល្បងរាប់ពាន់ឆ្នាំ អក្សរសាស្ត្រមួយនេះ បានប្រែប្រួលទៅរកសុក្រឹតភាព និងបង្កើតបានអត្តភាពមួយដោយឡែករបស់ខ្លួន ដោយប្រើប្រាស់ពាក្យពេចន៍របស់ខ្លួនផង និងពាក្យដែលខ្ចីពីភាសាសំស្ក្រឹត បាលី និងភាសាដទៃឯទៀតផង ទៅតាមក្បួនខ្នាតនៃភាសាខ្មែរ ទៅតាមទេពកោសល្យ ច្នៃប្រឌិតនៃអ្នកប្រាជ្ញ កវី និពន្ធខ្មែរ ដែលមានតាំងពីបុរាណ ដ៏យូរលង់មក ។ ហើយក្បួនខ្នាត ដែលខ្មែរមានតាំងពីបុរាណមកនោះហើយ គឺជាមូលដ្ឋានគ្រឹះ យ៉ាងរឹងនៃការវិវឌ្ឍន៍រីកចំរើននៃអក្សរសាស្ត្រ និង អក្សរសិល្ប៍ជាតិ ក៏ដូចជាមូលដ្ឋាននៃការវិវឌ្ឍន៍រីកចំរើនរបស់វប្បធម៌ និង សង្គមខ្មែរដែរ ។

ប៉ុន្តែ ពេលវេលាដែលបានកន្លងទៅរាប់សតវត្ស និងមហន្តរាយដោយសារសង្គ្រាមជាញឹកញយ បានធ្វើអោយបាត់បង់ក្បួនខ្នាត និងកេរមរតកខាងអក្សរសាស្ត្ររបស់យើងយ៉ាងច្រើនមិនដឹងជាអស់ប៉ុន្មានទេ តែទោះបីយ៉ាងណា ក៏យើងឃើញមានសេសសល់ស្នាដៃយ៉ាងច្រើន ដែលយើងរក្សាបានរហូតដល់សព្វថ្ងៃ ។ អក្សរសិល្ប៍ខ្មែរ មានលក្ខណៈទូទៅ ប្រហែលៗគ្នា ក្នុងសម័យកាលមួយៗ ប៉ុន្តែមានសំនួន

វោហារ និងគោលគំនិត ប្លែកៗគ្នា ពីសម័យមួយទៅសម័យមួយ ដែលធ្វើអោយសម័យនិមួយៗ មានលក្ខណៈផ្ទាល់របស់ខ្លួន ។

ប្រជាលពរដ្ឋខ្មែរ ជាអ្នកបង្កើតអក្សរសិល្ប៍ផ្ទាល់របស់ខ្លួន ប្រកបទៅដោយគតិបណ្ឌិតតាមរយៈសំនួនវោហារនៃភាសាខ្មែរ ។ អក្សរសិល្ប៍នេះ បានឆ្លុះបញ្ចាំងអោយឃើញថា នៅក្នុងអក្សរសិល្ប៍ខ្មែរ ពុំមែនមានតែធាតុវប្បធម៌របស់ជាតិខ្លួនផ្ទាល់ទេ ប៉ុន្តែគេឃើញមានចរន្តនៃអរិយធម៌ វប្បធម៌ក្រៅហូរចូលមកលាយឡំជាច្រើន ។ ប៉ុន្តែ ប្រការគួរចាប់អារម្មណ៍នោះ គឺអ្វីដែលខ្មែរទទួលយក លុះតែអ្វីនោះ វាស្របនឹងចិត្តគំនិតរបស់ខ្លួន ហើយដែលខ្លួនអាចសម្របសម្រួល ទៅតាមលក្ខណៈក្បួនខ្នាតរបស់ខ្លួន រហូតដល់អ្វីៗទាំងអស់នោះ បានក្លាយទៅជាមានលក្ខណៈមួយទៀត ខុសប្លែកពីរូបភាពដើមទាំងស្រុង ហើយប្រែក្លាយទៅជាស្នាដៃ ដែលមានលក្ខណៈពិសេសរបស់ខ្មែរ ។ ព្រោះហេតុនេះហើយបានជា ពាក្យសំស្ក្រឹត បាលីបានរលាយទាំងរូប ទាំងសូរទៅក្នុងសំនៀងនៃភាសាខ្មែរ រហូតដល់គេស្ទើរតែមិនបានដឹងថា ពាក្យនេះមានប្រភពចេញពីភាសា ដែលគេនាំចូលមកពីប្រទេសឥណ្ឌាទៀតផង ។ ស្នាដៃអក្សរសិល្ប៍ដ៏ល្បីល្បាញរបស់ឥណ្ឌា គឺរឿងរាមាយណៈ បានប្រែរូបរាង និងខ្លឹមសារទៅជារឿងមួយទៀត ដែលខ្មែរហៅថា " រឿងរាមកេរ្តិ៍ " ។ តាមការសិក្សាស្នាដៃរបស់ខ្មែរ គេឃើញថា ទោះបីគេបានរក្សាទុកឈ្មោះតួអង្គ ទីកន្លែងអោយនៅស្របដៀងនឹងឈ្មោះដើម ក៏ប៉ុន្តែ ខ្លឹមសាររបស់វាមានលក្ខណៈខុសគ្នាស្រឡះពីរឿងរាមាយណៈរបស់ឥណ្ឌា ។ អត្ថបទនៃរឿងរាមកេរ្តិ៍ បានបង្ហាញអោយឃើញថា ពុំមែនជាអត្ថបទបកប្រែចេញពីអត្ថបទរបស់ឥណ្ឌាទេ ប៉ុន្តែជាស្នាដៃមួយ ដែលមានអត្ថរូប និងអត្ថន័យផ្ទុយពីរឿងរាមាយណៈ ។

គេបានដឹងថា នៅក្នុងសង្គមខ្មែរបុរាណ មានស្រទាប់វណ្ណៈក្នុងសង្គមដែរ តែមិនឃើញមានការប្រកាន់វណ្ណៈ និង បែងចែកវណ្ណៈ ហើយគ្មានការការពារវណ្ណៈ

ការពារមនោគមវិជ្ជារបស់វណ្ណៈ ដូចពួកព្រាហ្មណ៍ការពារមនោគមវិជ្ជារបស់ខ្លួន នៅប្រទេសឥណ្ឌាទេ ។

ក្នុងរឿងរាមាយណៈ គេបានធ្វើអោយព្រះរាមចុះពីស្ថានទេវលោក មកស្ថានមនុស្សលោក រួចវិលត្រឡប់ទៅស្ថានទេវលោកវិញ ប៉ុន្តែ ចំពោះព្រះរាម នៅក្នុងរឿងរាមកេរ្តិ៍វិញ គឺជាទេវៈដែលគេធ្វើអោយក្លាយមកជាវីរជន ជាមនុស្សធម្មតា ដើម្បីរស់នៅក្នុងស្ថានមនុស្សដែលជាប់ជំពាក់ទៅដោយទំនាស់ និងមនោសញ្ចេតនា ដូចមនុស្សធម្មតា ។ ស្នាដៃរឿងរាមកេរ្តិ៍ខ្មែរ បង្ហាញនូវទំនាស់រវាងសាសនាព្រាហ្មណ៍ និងសាសនាព្រះពុទ្ធនៅសម័យអង្គរ ហើយរឿងរាមកេរ្តិ៍ គាំទ្រទស្សនៈរបស់ពុទ្ធសាសនា ប្រឆាំងនឹងទស្សនៈសាសនាព្រាហ្មណ៍ ។

ចំពោះអក្សរសិល្ប៍ ដែលទទួលឥទ្ធិពលពីពុទ្ធសាសនាវិញ គេឃើញថាមិនមានការផ្លាស់ប្តូរទាំងស្រុង ដូចក្នុងរឿងរាមកេរ្តិ៍ទេ ។ ប៉ុន្តែ ការដែលគេទទួលយករូបភាព និង ខ្លឹមសារនៃរឿងជាតកខ្លះនោះ ក៏ព្រោះតែអត្ថរូប និងអត្ថន័យនៃរឿងទាំងនោះ វាសមស្របទៅនឹងលក្ខណៈសោភ័ណ និងមនោគមវិជ្ជាខ្មែរ ។

នៅក្នុងការផ្លាស់ប្តូរទម្រង់រូបភាព និងខ្លឹមសារ ពីរូបភាពដើមអោយមកជាខ្មែរ ទោះជាក្នុងភាសាក្តី ក្នុងសិល្បៈក្តី ឬ អក្សរសិល្ប៍ក្តី ខ្មែរតែងរក្សាគោលគំនិតពីរសំខាន់គឺ ប្រាកដនិយម និង សមហេតុសមផលនិយម ។ គឺដោយផ្អែកលើទស្សនៈទាំងពីរខាងលើនេះហើយបានជា អ្នកនិពន្ធរឿងរាមកេរ្តិ៍ បានធ្វើអោយព្រះរាមក្លាយមកជាមនុស្ស ។

ពិតមែនហើយ នៅក្នុងអក្សរសិល្ប៍ខ្មែរ គេឃើញមានតួអង្គដែលមិនមែនមនុស្សមិនតិចទេ ដូចជាតួអង្គទេព្តា . យក្ស . ខ្មោច . សត្វ ឬដើមឈើ... . ល . ដែលគេនិយមហៅថា តួអង្គអស្ចារ្យ ។ ប៉ុន្តែ អត្ថបទទាំងនោះ បានឆ្លុះបញ្ចាំងតាម

រយៈការវិភាគអក្សរសិល្ប៍អោយឃើញនូវលក្ខណៈប្រាកដនិយម លក្ខណៈមនុស្ស និយម ឬ លក្ខណៈសង្គមនៃតួអង្គអច្ឆរិយៈទាំងនោះ ។

ជាទូទៅ នៅក្នុងអក្សរសិល្ប៍ខ្មែរ គេមិនសូវនិយមអ្វីដែលជាជំនឿមិនសមហេតុទៅលើអាទិទេព ឬ តួអង្គដែលមានលក្ខណៈអស្ចារ្យហួសនិស្ស័យនឹងជឿបាននោះទេ ។ ផ្ដើមចេញពីគំនិតនោះ ទើបអ្នកនិពន្ធខ្មែរ ធ្វើអោយអាទិទេពទាំងអស់ ក្លាយជាមនុស្ស ទាំងរូបរាងកាយ ទាំងសកម្មភាព ទាំងចិត្តគំនិត ទាំងមនោ - សញ្ចេតនា ។ ព្រោះពោធិសត្វក្នុងរឿងខ្មែររស់នៅ និងប្រព្រឹត្តអំពើផ្សេងៗ ដូចមនុស្សធម្មតា ធ្វើការផ្សងព្រេង ស្វែងរកចំណេះវិជ្ជា ជាប់ជំពាក់នឹងសេចក្ដីស្នេហាពិសេស នៅក្នុងរឿងបញ្ញាសជាតក ឬរឿង៥០ជាតិរបស់ព្រះពុទ្ធ តួអង្គពោធិសត្វ មិនសូវមានសកម្មភាពក្នុងការស្វែងរកនិព្វានទេ ។ នៅក្នុងរឿងទសជាតក តួអង្គពោធិ-សត្វ ធ្វើសកម្មភាពមានលក្ខណៈអស្ចារ្យផង និងលក្ខណៈមនុស្សផង ។ ដូច្នេះ បានជាខ្មែរនិយមរាប់អានជាតកទាំងនោះ ទៅតាមលក្ខណៈរបស់តួអង្គនោះឯង ។ គេនិយមរឿងមហាវេស្សន្តរជាតកជាងគេ មកពីតួអង្គព្រះវេស្សន្តរ មានលក្ខណៈមនុស្សច្រើនជាងតួអង្គពោធិសត្វឯទៀត ។ នៅក្នុងការស្វែងរកសម្មាសម្ពោធិញ្ញាណ ព្រះវេស្សន្តរបានបំពេញទានបារមី ទាំងពាហិរទាន ទាំងអជ្ឈត្តិកទាន តែចុងបំផុត ព្រះអង្គទ្រង់យាងត្រឡប់មកសោយរាជ្យវិញដដែល ពោលគឺ មិនអាចចៀសផុតពីការបង្ខំរបស់សង្គម ពីភារកិច្ចក្នុងគ្រួសារ និង មិនអាចកាត់ផ្ដាច់មនោសញ្ចេតនា ក្នុងឋានៈជាមនុស្សបានឡើយ ។

ដូច្នេះ យើងឃើញថា ខ្មែរបានធ្វើអោយអាទិទេព និងភាពអស្ចារ្យ ដែលមាននៅក្នុងគម្ពីររបស់ឥណ្ឌា ក្លាយទៅជាមានលក្ខណៈមនុស្ស លក្ខណៈប្រាកដនិយម សមហេតុផល ល្មមអាចជឿបាន ធ្វើតាមបាន ប្រព្រឹត្តតាមបាន នៅក្នុងអក្សរសិល្ប៍ខ្មែរ ។ នៅក្នុងគំនិតប្រាកដនិយមរបស់ខ្មែរ គេមិនគ្រាន់តែធ្វើអោយអាទិទេពក្លាយ

មកជាមនុស្សទេ ឬ ធ្វើអោយអច្ឆរិយៈក្លាយជាតថៈទេ ប៉ុន្តែគេប្រើលក្ខណៈប្រាកដនិយម ធ្វើជាមធ្យោបាយនៃសកម្មភាពតែម្តង ។ ប្រសិទ្ធភាពនៃសកម្មភាព មិនផ្សារភ្ជាប់ទៅនឹងបរមត្ថវិជ្ជាទេ ប៉ុន្តែទៅនឹងការអនុវត្តជាក់ស្តែង ដែលឈរលើមូលដ្ឋាននៃពុទ្ធិ គឺការចេះដឹងពិតប្រាកដ និងដោយប្រុងប្រយ័ត្នរបស់សភាវៈ និង ផលប្រយោជន៍ ។

ព្រោះហេតុនេះបានជា យើងឃើញនៅក្នុងកម្រងច្បាប់ផ្សេងៗ មានកំណាព្យ ឧបទេស ពោរពេញទៅដោយគតិបណ្ឌិតប្រជាប្រិយខ្មែរ ។ ច្បាប់ទាំងឡាយនោះ សំដៅអប់រំទូន្មានតាមភាសាមួយ ប្រកបដោយរូបារម្មណ៍ យ៉ាងពិរោះចំពោះមនុស្សគ្រប់ស្រទាប់សង្គម ចាប់តាំងពីអ្នកដឹកនាំផែនដី មានព្រះមហាក្សត្រជាដើម រហូតដល់មន្ត្រី ព្រះសង្ឃ អ្នកមាន អ្នកក្រ ឈ្មួញ អ្នកបំរើ ក្មេង ចាស់ទាំងស្រី ទាំងប្រុស ។ វត្ថុបំណងរបស់ច្បាប់ទាំងនោះគឺ ចង់អោយសមាជិកទាំងអស់ក្នុងសង្គមខ្មែរ ស្គាល់ក្បួនច្បាប់ក្នុងការរស់នៅ ប្រព្រឹត្តខ្លួនអោយបានល្អ ក្នុងសង្គម និងមានសុភមង្គល ។ ប៉ុន្តែ ដើម្បីរស់បានសុខ ប្រាសចាកភយន្តរាយ គេត្រូវតែប្រុងប្រយ័ត្ន ត្រូវតែរិះគិតពិចារណា តាមលក្ខណៈប្រាកដនិយមនៃស្ថានការណ៍ ដែលប្រែប្រួល និងឱកាសដែលនាំទៅដល់គោលបំណងដែលខ្លួនចង់បាន ។

នៅក្នុងរឿងព្រេងនិទានខ្មែរ យើងឃើញតួអង្គនីមួយៗ ទោះជាសត្វក្តី ឬជាមនុស្សក្តី សុទ្ធតែប្រើប្រាស់បញ្ញាស្មារតី និងពេលវេលាដែលខ្លួនមាន សំរាប់ជាមធ្យោបាយក្នុងការរំដោះខ្លួន និង ជួយអ្នកដទៃអោយរួចពីគ្រោះថ្នាក់ តួយ៉ាងដូចជាក្នុងរឿងសុភាទន្សាយ ជាដើម ។ ទន្សាយ បានប្រើកលល្បិចបោកបញ្ឆោតអ្នកខ្លាំង ដើម្បីជួយអ្នកខ្សោយ ហើយជួនកាលរហូតដល់ភូតកុហកផង ។ ប៉ុន្តែ ដោយពិតទៅនេះជាសីលធម៌មួយនៅក្នុងការអនុវត្តជាក់ស្តែង ស្របទៅតាមស្ថានភាព ពេលវេលា

ទីកន្លែងជាក់ស្តែង ដើម្បីដោះស្រាយបញ្ហាមួយឱ្យមានប្រយោជន៍ជាក់ស្តែងដែរ ។ ហើយសីលធម៌ជាអ្នកស្លូតបូត ជាអ្នកស្រឡាញ់សច្ចះ យុត្តិធម៌នេះ មាននៅក្នុងផ្នត់ចិត្តគំនិតខ្មែរ តាំងពីរាប់ពាន់ឆ្នាំកន្លងមក រហូតដល់ជួនកាល ក៏ទទួលរងគ្រោះ ដោយសារការជឿការទុកចិត្ត ការស្រឡាញ់រាប់អាន និងការសន្តោសប្រណី និង ព្រហ្ម-វិហារធម៌ ក៏មាន ។

ដោយសារខ្មែរមិនមានជំនឿទៅលើអ្វីដែលហួសហេតុ គេក៏មិនសូវឃើញមានរឿងសោកនាដកម្មដែរ ផ្ទុយទៅវិញ គេច្រើនឃើញរឿងកំប្លែង សប្បាយប្រកបដោយ សុ ទិ ដ្ឋិ និ យ ម ចំអកតាមបែបប្រាកដនិយម ប្រកបដោយមនោ-សញ្ចេតនា អាណិតអាសូរ ។ គេមិនចូលចិត្តអោយតួអង្គប្រាសព្រាត់គ្នា កាប់សម្លាប់គ្នាឥតប្រយោជន៍ទេ គេច្រើនបញ្ចប់រឿង ដោយអោយតួអង្គជួបជុំគ្នា ។ គឺដោយហេតុនេះហើយបានជា ខ្មែរនិយមរឿងជាតក ។ នៅក្នុងរឿងល្ខោនខ្មែរក្តី រឿងប្រលោមលោកក្តី គេគ្រាន់តែអោយតួអង្គកំសត់ តែមិនអោយស្លាប់ទេ បានជានៅពេលគេទាល់ច្រកម្តងៗ អ្នកនិពន្ធងាកទៅរកម្លាំងក្រៅខ្លួន មានជំនួយរបស់ទេវៈឬអច្ឆរិយៈ មកជួយសំរាលស្ថានភាពរបស់រឿង កុំអោយធ្លាក់ដល់សោកនាដកម្ម ។ ការរឹតបន្តឹងស្ថានការណ៍នៅក្នុងរឿង គឺដើម្បីបន្ធូរវិញ ព្រោះខ្មែរចូលចិត្តសើចផង យំផង ។ ពេលជួបគ្នាក៏យំ ពេលបែកគ្នាក៏យំ ។ ការធ្វើអោយយំ អោយសើចនេះមិនមែនជាលក្ខណៈសោភ័ណរបស់អក្សរសិល្ប៍ខ្មែរទេ តែនេះគ្រាន់តែបង្ហាញនូវលក្ខណៈចិត្តសាស្ត្រ តែប៉ុណ្ណោះ ។

ប៉ុន្តែ រឿងទុំទាវមានលក្ខណៈពិសេស ដោយសារលក្ខណៈសោកនាដកម្មរបស់វា ។ អ្នកសិក្សារឿងនេះភាគច្រើន វាយតំលៃថា ជារឿងសោកនាដកម្មគួរអោយភ័យខ្លាច ហើយពិបាកនឹងទទួលយកបានផង ។ ទុំទាវ ជាស្នាដៃឯក នៃអក្សរសិល្ប៍ខ្មែរសុទ្ធសាធ ប្រៀបបានទៅនឹងរឿងរ៉ូមេអូ និង ស៊ុយលីយែតរបស់

អង់គ្លេស ។ តួអង្គមានកំហុសក្នុងការស្រឡាញ់គ្នា ដោយឥតបានគិតពីអ្វីទាំងអស់ ហើយនាំគ្នាស្វែងរកភាពដាច់ខាតមួយ នៅក្នុងសង្គមមួយ ដែលមិនអាចរកលក្ខណៈដាច់ខាតនេះបាន ដូច្នេះ មានតែនៅក្នុងពិភពមរណៈទេ ទើបអាចរកឃើញនូវភាពដាច់ខាតនោះ ។ ដោយសារលក្ខណៈជ្រុលហួសហេតុខ្លះ នៅក្នុងសកម្មភាពទំនាក់ទំនងរវាងយុវជនទាំងពីរ ប្រៀបទៅនឹងច្បាប់សីលធម៌ ទំនៀមទម្លាប់របស់ខ្មែរ បានជាមហាជនគេមិនសូវគាំទ្រ ចំពោះមរណៈរបស់តួអង្គ ប៉ុន្តែ គេក៏មិនបានគាំទ្រចំពោះច្បាប់របស់ខ្មែរជំនាន់នោះ ព្រមទាំងសង្គម និងអ្នកកាន់អំណាចនៅសម័យនោះដែរ។ ហេតុដូច្នេះហើយបានជាតួអង្គទុំទាវ ទោះបីបានជាតួអង្គឈានមុខក្នុងចំណោមតួអង្គទាំងឡាយមែន ប៉ុន្តែមិនបានទទួលស្គាល់ជាតួអង្គគំរូឡើយ ។ ទាំងនេះ មកពីទស្សនៈប្រាកដនិយមដែរ គឺថា ស្នេហាមិនមែនដើម្បីស្លាប់ទេ ការស្វែងរកសុក្រិតភាពមិនមែនសំរាប់ប្រើនៅពេលអនាគត ដែលមិនទាន់មកដល់ទេ ។ អ្វីៗ ត្រូវតែប្រព្រឹត្តទៅនៅលើលោកយើងនេះ ទោះបីជាអំពើកុសល ឬ អកុសល ក៏ដោយ ។ គេឃើញមានទស្សនៈកម្មផល ពិសេស ក្នុងរឿងជាតកខ្មែរ នៅក្នុងអក្សរសិល្ប៍ខ្មែរ ក៏ដូចជាក្នុងអក្សរសិល្ប៍នៃបណ្តាប្រទេស ដែលទទួលឥទ្ធិពល ពុ ទ្ធ សា ស នា នៅអាស៊ីអាគ្នេយ៍ ។ គេជឿថា ភ័ព្វវាសនារបស់មនុស្សម្នាក់ៗ ជាផលនៃអំពើរបស់ខ្លួនពីជាតិមុន ។ ប៉ុន្តែ នៅក្នុងការអនុវត្តជាក់ស្តែង សកម្មភាពរបស់មនុស្សម្នាក់ៗ វាទាក់ទងទៅនឹងបរិយាកាសសង្គមបច្ចុប្បន្ន ។ ផ្នត់ចិត្តគំនិតខ្មែរ គឺជួយស្រោចស្រង់ គាំទ្រអ្នកណាដែលធ្វើអំពើល្អ ដូច្នេះ គេមិនអោយតួអង្គល្អនោះស្លាប់ដោយងាយៗ ទេ ។ គេចង់ឱ្យរឿងទាំងឡាយ បញ្ចប់ដោយសប្បាយរីករាយ ជួបជុំគ្នា មូលត្រកូលគ្នា ។ ក៏ប៉ុន្តែ នៅក្នុងច្បាប់សីលធម៌ខ្មែរ គេក៏មិនបានអប់រំអោយមនុស្សទាំងអស់ មានសុទិដ្ឋិនិយមជ្រុលហួសហេតុដែរ ។ គេបានបង្ហាញអំពីភាពស្មុគស្មាញនៃជីវិត ដែលពោរពេញទៅដោយបញ្ហាពិបាកដោះស្រាយ ។ ដូច្នេះ ម្នាក់ៗត្រូវតែប្រុង

ប្រយ័ត្ន ចៀសវាងការបណ្តោយខ្លួនទៅតាមព្រេងវាសនា ព្រោះសង្គមនីមួយៗ មានច្បាប់ ទម្លាប់ដោយឡែករបស់សង្គមនោះ ។

ដូច្នេះហើយបានជា គេឃើញមានការគាបសង្កត់ ការរំលោភបំពាន និងទំនាស់មិនអស់មិនហើយ នៅក្នុងរឿងព្រេងខ្មែរ ។ ជួនកាលរឿងតូចតាច ក៏ក្លាយជាធំ រហូតដល់ព្រះមហាក្សត្រ ទើបអាចកាត់សេចក្តីបាន ។ ដើម្បីរកយុត្តិធម៌អោយអ្នកក្សត់ខ្សោយ នៅក្នុងអក្សរសិល្ប៍ខ្មែរ គេនិយមយកសត្វទន្សាយ ដែលជាសត្វស្លូត ទន់ខ្សោយ អោយធ្វើជាតំណាងតុលាការ ។ ទន្សាយ គ្មានអំណាច គ្មានកម្លាំងកាយយកមកប្រើ ដើម្បីតទល់នឹងអ្នកខ្លាំង ក្នុងការដោះស្រាយបញ្ហាទេ គឺប្រើតែកម្លាំងបញ្ញាមួយប៉ុណ្ណោះ ។ មានជួនកាល ទន្សាយ ក៏ទទួលផលកំរៃពីគូក្តី ទាំងសងខាងដែរ តែនេះគ្រាន់តែជាការបង្ហាញអោយឃើញនូវផលអាក្រក់ នៃរឿងក្តីដែលទាំងអ្នកឈ្នះ ទាំងអ្នកចាញ់ សុទ្ធតែខាតបង់ទាំងអស់គ្នា និងជាការចំអកអោយអង្គការតុលាការនៅក្នុងជំនាន់មុនៗ នោះផង ។ រឿងរ៉ាវទាំងនេះ សុទ្ធតែបង្ហាញអោយឃើញនូវការណ៍ពិត ដែលកើតមាននៅក្នុងសង្គមខ្មែរពីបុរាណ ។ ការបង្ហាញភាពប្រាកដនិយមមួយទៀតគឺ គេបញ្ចូលឥទ្ធិពល និង គុណធម៌របស់ពោធិសត្វ ទៅក្នុងតួអង្គរបស់មហាក្សត្រ ។ មហាក្សត្រខ្មែរ ដែលតាំងពីបុរាណមក ប្រកបដោយទសពិធរាជធម៌ ព្រះអង្គជាតំណាងគតិយុត្តិធម៌ ព្រះអង្គតែងតែរកយុត្តិធម៌ ជូនប្រជារាស្ត្រ របស់ព្រះអង្គ ។ ព្រះអង្គជាតុលាការកំពូលរបស់ប្រជារាស្ត្រ ។

ម្យ៉ាងទៀត អត្ថបទអក្សរសិល្ប៍ខ្មែរ បង្ហាញនូវលក្ខណៈសមហេតុច្រើនជាងការបង្ហាញពីភាពអស្ចារ្យ ប៉ុន្តែបើមានខ្លះនោះ ជាឥទ្ធិពលដែលទទួលពីខាងក្រៅជាពិសេស នៅក្នុងប្រភេទសាស្ត្រាល្បែង ។ ជួនកាល គេឃើញថា សាច់រឿងវែងអន្លាយ ដែលបង្ហាញនូវសកម្មភាពដដែលៗ មានតួអង្គអស្ចារ្យ និង សកម្មភាព

អស្ចារ្យច្រើន ។ នេះទំនងជាសេរីភាពក្នុងការច្នៃប្រឌិត ពិសេសខាងអត្ថរូប ក្នុងការបង្ហាញរឿងអោយបានវែង ដោយមិនបានគិតដល់សិល្បៈនៃការនិទានរឿង (វណ្ណនាវិធិ) ឡើយ ។

នៅក្នុងស្នាដៃរបស់អ្នកនិពន្ធខ្មែរ គេសង្កេតឃើញលក្ខណៈច្បាស់លាស់ សមហេតុផល និងសុខដុមភាព ដែលជាលក្ខណៈសមហេតុផលរបស់ខ្មែរ ដូចដែលគេឃើញមាននៅក្នុងសំណង់ស្ថាបត្យកម្មបុរាណដូច្នេះដែរ ។ អត្ថបទនៅក្នុងរឿងរាមកេរ្តិ៍ ជាតួយ៉ាងបញ្ជាក់ក្នុងលក្ខណៈខាងលើ ពាក្យពេចន៍មួយម៉ាត់ៗ សុទ្ធតែមានន័យ ហើយចាំបាច់របស់ឃ្លា និង របស់រឿងទាំងមូល ។ បានសេចក្តីថា គ្មានពាក្យណាមួយដែលគេប្រើ គ្រាន់តែបំពេញឃ្លាហើយឥតមានមុខងារនោះទេ ក៏ដូចជា ដុំថ្មដែលគេយកមកសង់ប្រាសាទអង្គរវត្ត ដែលថ្មមួយដុំៗ សុទ្ធតែមានប្រយោជន៍ មានសារសំខាន់ ដូច្នេះដែរ ។

តាមពិត នៅក្នុងស្នាដៃអក្សរសិល្ប៍ខ្មែរ ក៏មានសកម្មភាពជាអច្ឆរិយៈអស្ចារ្យខ្លះដែរ តែនោះគ្រាន់តែជាវិធីសាស្ត្រខាងអក្សរសិល្ប៍ និង ខាងសោភ័ណវិជ្ជាប៉ុណ្ណោះ គឺមិនមែនបង្ហាញភាពអស្ចារ្យ ដើម្បីអោយឃើញអច្ឆរិយភាពនោះទេតែ គ្រាន់តែធ្វើអោយមានការរំភើបនៅក្នុងតថៈ មួយតែប៉ុណ្ណោះ ។ តាមអ្នកសិក្សាអក្សរសិល្ប៍ខ្មែរ គេយល់ថា លក្ខណៈសមហេតុផល បានធ្វើអោយអច្ឆរិយៈខិតទៅជិតតថៈនៅក្នុងអត្ថរូប ក៏ដូចជាក្នុងអត្ថន័យនៃអក្សរសិល្ប៍ខ្មែរ ។

បើយើងនិយាយអំពីស្នាដៃអក្សរសិល្ប៍នៅសតវត្សទី ២០ នេះវិញ ក៏ឃើញថា លក្ខណៈប្រាកដនិយម រិះគន់ និងស្ថាបនា ដែលមានពីបុរាណមក បានរស់ស្ថិតស្ថេររហូតមក នាំអោយបង្កើតបានជាស្នាដៃប្រជាប្រិយ៍ មានលក្ខណៈជាតិនិយម នៅពេលដែលប្រទេសខ្មែរ ស្ថិតនៅក្រោមការសង្កត់សង្កិនរបស់ពួកអាណានិគម ។ ដោយឃើញភាពល្ងង់ខ្លៅ ភាពស្ពឹកស្រពន់ ខ្ជិលច្រអូសរបស់រាស្ត្រ

ខ្មែរនៅតំបន់ខ្លះ និងឃើញការកេងប្រវ័ញ្ចជិះជាន់របស់ជនបរទេស មកលើប្រជា-រាស្ត្រខ្មែរ អ្នកព្រះភិរម្យភាសា **អ៊ូ** ហៅ **ឧ៊ុយ** ដែលជាកវីស្នេហាជាតិម្នាក់ បានដើរច្រៀងពីការឈឺចាប់នៃបេះដូងរបស់គាត់ រំលឹកដាស់តឿនសតិអារម្មណ៍ខ្មែរ អោយភ្ញាក់រលឹក បំផុសស្មារតីស្នេហាជាតិ ពីភូមិមួយទៅភូមិមួយ ពីវត្តមួយទៅវត្តមួយ ពីស្រុកមួយទៅស្រុកមួយ ។ គាត់ច្រៀងពីទុក្ខវិក្ប ពីភាពក្រខ្សត់របស់ប្រជារាស្ត្រ ពីទម្ងន់នៃពន្ធដារ ដែលអ្នករដ្ឋការអាណានិគមជរិតយកពីប្រជារាស្ត្រ ។ គាត់យំ ដោយឃើញខ្មែរល្ងង់ មានជំនឿអកុសល បណ្តោយអោយគេបោកប្រាស់ កេងប្រវ័ញ្ចបានតាមចិត្ត ។ គាត់ឈឺចាប់នឹងឃើញអ្នកកាន់ពុទ្ធសាសនា ទាស់ទែងគ្នាពីរឿងធម៌អាថ៌ ។ ដូច្នេះហើយបានជា គាត់ក្រើនរំលឹកជនរួមជាតិរបស់គាត់ អោយចេះរួបរួមសាមគ្គីគ្នា បណ្តុះស្មារតីស្នេហាជាតិ ភ្ញាក់រលឹកស្រឡាញ់ពលកម្ម ខិតខំរកស៊ី សន្សំសំចៃតាមគំរូចាស់បុរាណ ពិសេសគឺបង្រួបបង្រួមជាតិ ប្រមូលកម្លាំង ដើម្បីទប់ទល់នឹងការលំបាកក្នុងជីវភាពរស់នៅ និងទប់ទល់នឹងការលោភលន់របស់ជនបរទេស ។ រហូតមកដល់សព្វថ្ងៃ ខ្មែរគ្រប់រូបនៅតែចាំដោយអន្លើ នូវពាក្យពេចន៍នៃកំណាព្យ ដ៏ពិរោះរបស់គាត់ ។

ប៉ុន្តែ នៅសម័យអាណានិគម គំនិតស្នេហាជាតិ តម្លៃនៃលក្ខណៈប្រាកដនិយម និងសមហេតុផលរបស់អក្សរសិល្ប៍ខ្មែរ បានសំងំស្ងៀមនៅតែក្នុងសាស្ត្រាស្លឹករឹត រហូតរាប់សិបឆ្នាំ ព្រោះក្នុងពេលនោះ ពួកអាណានិគមនិយម បានយកភាសាបរទេសជំនួសភាសាខ្មែរ ហើយលើសពីនេះទៀត គេបាននាំចូលអក្សរសិល្ប៍របស់គេមកបង្រៀនកូនខ្មែរទៅវិញ ។

គឺនៅពេលនោះហើយ ដែលកើតមានអ្នកនិពន្ធសម័យថ្មី ជាអ្នកបង្កើតស្នាដៃ ប្រលោមលោក តាមបែបលោកខាងលិច ។ អ្នកបកប្រែ អ្នកធ្វើអនុកម្ម

ក៏មានច្រើន ។ ឥទ្ធិពលនៃអក្សរសិល្ប៍ខ្មែរ ដែលធ្លាប់តែល្បីល្បាញពីមុនៗមក ក៏ធ្លាក់ចុះបន្តិចម្តងៗ តាមរយៈការតែងនិពន្ធ ដែលបានទទួលការអប់រំបែបទំនើប ។ គេឃើញថាស្នាដៃរបស់គេ គ្មានអ្វីក្រៅពីរឿងស្នេហាធម្មតា ប្រកបដោយតណ្ហា កាម-គុណ និង អំពើឃោរឃៅ កាប់ចាក់ វាយតប់ សម្លាប់គ្នាតែប៉ុណ្ណោះ ។

ពីមុន យើងឃើញថា អ្នកនិពន្ធ អ្នកកវី គេបង្កើតថ្មីតាមលក្ខណៈសោភ័ណ និងសិល្បវិធីអក្សរសាស្ត្រ ដោយធ្វើស្នាដៃបរទេសអោយមកជាខ្មែរ ឬក៏គេបង្កើតថ្មីដោយច្នៃប្រឌិតថ្មីរបស់ខ្លួនគេ ដែលមានលក្ខណៈជាតិ និងប្រជាប្រិយ៍ ។ ប៉ុន្តែ នៅសម័យអាណានិគម គេច្រើនឃើញមានការបកប្រែ និងការចម្លងតាមទាំងដុលទៅវិញ ។

នៅសម័យដែលប្រទេសខ្មែរ បានទទួលឯករាជ្យពេញបរិបូណ៌ឡើងវិញ ដោយសារស្នាព្រះហស្តនៃព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុវរ្ម័ន ព្រះបិតាអក្សរសាស្ត្រជាតិ និងក្រោមព្រះរាជូបត្ថម្ភរបស់ព្រះអង្គ សមាគមអ្នកនិពន្ធខ្មែរ ក៏ត្រូវបានបង្កើតឡើងដើម្បីជួយបណ្តុះបណ្តាលអ្នកនិពន្ធក្មេងៗ និងមានសាលាឧត្តមសិក្សា មានបណ្ណាល័យជាច្រើន បានបើកទ្វារទទួលអ្នកអាន - អ្នកស្រាវជ្រាវពេលនោះ យើងឃើញថា អក្សរសិល្ប៍ខ្មែរ បានរីកចំរើនឡើងវិញមួយកំរិតគួរអោយស្ងើចសរសើរ ។

ប៉ុន្តែ នៅសម័យឆ្នាំ ១៩៧០ គឺពេលដែលប្រទេសកម្ពុជាចាប់មានសង្គ្រាម ហើយជាពិសេស ចាប់ពីឆ្នាំ ១៩៧៥ រហូតដល់ឆ្នាំ ១៩៧៩ អក្សរសិល្ប៍ខ្មែរបានទទួលការវិនាសអន្តរាយស្ទើរតែទាំងស្រុង ។ អ្នកនិពន្ធ អ្នកកវីភាគច្រើន ត្រូវស្លាប់ សាលា-រៀន វត្តអារាម បណ្ណាល័យ ត្រូវរុះរើ បំផ្លិចបំផ្លាញ ។ ស្នាដៃជាសៀវភៅជាគម្ពីរ ជាក្រាំង សាស្ត្រា ដែលជាមរតកវប្បធម៌ មានតម្លៃមិនអាចកាត់ថ្លៃបាន ត្រូវដុតបំផ្លាញអស់ ស្ទើរគ្មានសល់ ។

នៅក្រោយថ្ងៃ ៧ មករា ១៩៧៩ អ្នករស់ពីស្លាប់ ដែលយល់ពីតម្លៃអក្សរ-សាស្ត្រជាតិ បានប្រមូលបំណែកស្នាដៃ ដែលមានសល់រាត់រាយគ្រប់ទីកន្លែង មករក្សាទុកនៅបណ្ណាល័យជាតិ ។ ក្រៅពីនេះ យើងបានខិតខំបណ្ដុះបណ្ដាលអ្នកនិពន្ធថ្មីបានជាច្រើនលើក ដើម្បីបន្តវេនបង្កើនស្នាដៃអក្សរសិល្ប៍ តទៅទៀត ។

ស្នាដៃបង្កើតថ្មីដែលយើងទទួលបាន មិនទាន់មានគុណភាព និងលក្ខណៈល្អ ស្របតាមទ្រឹស្ដីនៃអក្សរសិល្ប៍ខ្មែរ ដូចអធិប្បាយខាងដើមនៅឡើយ ប៉ុន្តែ នេះជាពន្លកនៃការរស់ឡើងវិញនៃវិស័យអក្សរសិល្ប៍ខ្មែរ គួរជាទីសង្ឃឹមទៅអនាគត ។ នៅក្នុងរយៈពេលជាង ១០ ឆ្នាំ កន្លងនៅនេះ យើងឃើញថាមានអ្នកនិពន្ធ អ្នកកវីជំនាន់ថ្មី បានខិតខំប្រឹងប្រែងបង្កើតស្នាដៃ យ៉ាងច្រើន សន្ធឹកសន្ធាប់ ដែលយើងបានសរិតសំរាំង និងបោះពុម្ពផ្សាយបានរាប់សិបរឿង ។ ហើយរឿងដែល គេនិយមអានជាងគេនោះគឺ រឿងវិលរកទ្រនំ និង មេឃបាត់ដួងចន្ទ របស់អ្នកនិពន្ធ ទី ជីហួត ។

យើងមានជំនឿជឿជាក់ថា ក្រោយពេលដែលប្រទេសកម្ពុជា ទទួលបានសន្តិភាពមកវិញ ចលនាតែងនិពន្ធ នឹងកាន់តែមានសន្ទុះខ្លាំងក្លា ឯស្នាដៃអក្សរ-សិល្ប៍ថ្មី ក៏នឹងកើតមានជាបន្តបន្ទាប់ ធ្វើអោយអក្សរសិល្ប៍ខ្មែរ ឈានទៅដល់កំរិតខ្ពស់ ដូចដែលវិស័យនេះធ្លាប់មាននៅក្នុងសម័យបុរាណ ដូច្នេះដែរ ។

ស្រាវជ្រាវ និង រៀបរៀង

ដោយ

**ឃី ធន់**

# ល្បើកអង្គរវត្ត

*សំនាំមុខ*

អត្ថបទល្បើកអង្គរវត្ត ដែលចម្លងមកនេះ មានប្រយោជន៍ដល់អ្នកនិរុត្តិសាស្ត្រខ្មែរ ដែលមានបំណងស្រាវជ្រាវរកលក្ខណៈភាសាខ្មែរ ក្នុងប្រវត្តិសាស្ត្រ ។ តើភាសាខ្មែរ ក្នុងអត្ថបទនិវត្តនេះ បានផ្លាស់ប្តូរដូចម្តេចខ្លះ ? ។

យើងរក្សាទុកសំនេរ តាមអត្ថបទលោក E. Aymonier ទាំងស្រុង ទោះបីអត្ថបទនេះ មានមកពីយូរយារហើយក្តី

"... លើកតៀត្រិតតាមទុំនង
ដំណើរពីមុនបោង
អ្នកប្រាជ្ញលោកឲ្យលើកមកស្រាប់ ..."

.........................................

ល្បើកនេះបូរាណរាជយូរលុង
តែងតពីក្នុងនគរវាត់ ...."

ក៏អ្នកចម្លងបានរក្សាទុកសំនេរ កំណត់សូរសំឡេងភាសាខ្មែរ តាំងពី គ.ស.១៨៧៨ នេះដែរ ព្រោះជាកាលបរិច្ឆេទចុងក្រោយបង្អស់ នៃការចម្លងបោះពុម្ពរបស់ Textes Khmers នេះ ។

ដើម្បីបកស្រាយសំនេរ ក្នុងអត្ថបទបែបនេះ

១ . កំណត់សំនេរពាក្យដូចសព្វថ្ងៃ ត្រូវទុកថាមានសូរសំឡេងដូចសព្វថ្ងៃនេះដែរ ។

២ . ស្វរសំឡេងដែលស្គាល់នេះ ជាផ្លូវនាំឱ្យរកស្វរសំឡេងរបស់សំនេរជំនាន់ "អ្នកប៉ង" ( គ.ស . ១៦០៩ ) ឬក្នុង គ.ស. ១៨៧៨ បានខ្លះ ដោយអាងលើចាប់ចុងចួននៃក្បួនកាព្យ ។

៣ . ស្វរសំឡេងរបស់ចុងចួន ដែលទើបរកឃើញនេះ មានប្រយោជន៍សំរាប់ស្រាយស្វរសំឡេងពាក្យក្លាយមកពីភាសាបរទេសថែមទៀត ។ វិធីកម្លាយពាក្យបរទេស គឺជាវិធីខ្មែរនិយមសំរួលស្វរសំឡេងពាក្យបរទេស តាមស្វរសំឡេងពាក្យខ្មែរ ។ វិធីទាំងនេះគឺ

- ល្បុបស្វរខ្លះ មានស្វរស្រះ ស្វរព្យញ្ជនៈ ឬស្វរព្យាង្គរបស់ពាក្យ
- គំនស្វរស្រះទី ១ របស់ពាក្យពីរព្យាង្គ
- បន្លាស់ស្រះ ឬព្យញ្ជនៈ ឬព្យាង្គ
- ប្តូរស្ទរស្រះទី ១ របស់ពាក្យពីរព្យាង្គ

៤ . សំអាងលើឯកសារផ្សេងៗ ក្នុងពេលដំណាលគ្នា ក៏ជាមធ្យោបាយសំរាប់ស្រាវជ្រាវរកស្វរសំឡេងពាក្យខ្មែរ ក្នុងសំនេរជាន់ដើមបានដែរ មានវចនានុក្រមពីរភាសា ជាដើម ។

ភ្នំពេញ, ចុះថ្ងៃទី ៣១ ធ្នូ គ.ស. ១៩៧១

**ឃួន សុខម្ភ**
សាស្ត្រាចារ្យឧត្តមសិក្សា

# ល្បើកអក្ខរវត្ត

កំណត់ឯកសារ

១. វចនានុក្រមខ្មែរ ពុទ្ធសាសនបណ្ឌិត្យ គ.ស. ១៩៦៨

២.ល្បើកអង្គរ " បែបចាស់ " . សម្តេចព្រះសុគន្ធ -ENLO de Paris

៣.រឿងសំរាំង . ក្រសួងសិក្សាធិការ . ភ្នំពេញ គ.ស. ១៩៥៤

៤. Textes Khmer - E. Aymonier - Saigon 1878 pp. 267-297 (Institut Bouddique de Phnom Penh code Nº g-2)

៥. Revue de l'INP Nº 2 - 1959

៦. មេរៀនអក្សរសាស្ត្រ លោក លាង ហ៊ាបអាន សមាគមអ្នកនិពន្ធខ្មែរ គ.ស.១៩៦៦ . ៦៧

៧. ឯកសារមហាបុរសខ្មែរ លោក អេង សុត ភ្នំពេញ គ.ស.១៩៦៩

៨. សាស្ត្រាស្លឹករឹតរបាក្សត្រស្រុកខ្មែរ បទមបារមីពេជ ពុទ្ធសាសន-បណ្ឌិត្យ លេខ ១៩១៣

៩. បញ្ជាក់សករាជ . លោក ភួង នួន . ភ្នំពេញ គ.ស. ១៩៥៧

១០. អក្សរសាស្ត្រខ្មែរ . សាស្ត្រាចារ្យ ១ ក្រុម . បណ្ណាគារភ្នំពេញ គ.ស ១៩៥៦

១១. អក្សរសាស្ត្រខ្មែរ . លោក លី ធាមតេង . ភ្នំពេញ គ.ស.១៩៦០

១២. និរាសអង្គរ . សុត្តន្តប្រីជាឥន្ទ . ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ គ.ស ១៩៦៩

១៣. កំណើតអង្គរវត្ត . លោកម៉ា ប៉ូ . បណ្ណាគារភ្នំពេញ គ.ស. ១៩៦៩

១៤. ស្រាវជ្រាវរកអ្នកនិពន្ធខ្មែរ . មជ្ឈមណ្ឌលរកឯកសារ និងស្រាវជ្រាវ ផ្នែកអក្សរសាស្ត្រវប្បធម៌ អរិយធម៌ខ្មែរ នៃមហាវិទ្យាល័យអក្សរ សាស្ត្រ និងមនុស្សសាស្ត្រ . ភ្នំពេញ គ.ស. ១៩៧១ ទំព័រ ១៧ . ២២

## *លំនាំដើម*

អត្ថបទ "ល្បើកអង្គរវត្ត" ឬ "សាត្រាព្រះកេតុមាលា" ឃើញមានផ្សាយសព្វថ្ងៃ ក្នុងឯកសារបី គឺ :

១ . ឯកសារល្បើកអង្គរបែបចាស់ ជាស្នាដៃសម្ដេចសុគន្ធ មាន នៅឯ Institut National de Langues et Civilisations Orientales នាក្រុងប៉ារីស ។

*សេចក្ដីខាងដើមអត្ថបទ មានដូចនេះ :*

១. នេះនិងពារនិា សសើរដ្ឋមហា ឥន្ទ្រីប្រសព្រះនគរ មុនមានខ្សត្រា
ថិរាជបវរ ទ្រង់ព្រះនាមករ ទេវង្សឥស្ចរ ។

២. ស្ដេចមានបរមី មានបុន្យរិទ្ធី សោយ្យរាជដោយ្យធមិ គង់នៅរគោកធ្លក
ឯងជាសម្គាល់ គ្រប់គ្រងរាស្តការ ខ្សែមខ្សានសាប្យ ។

៣. មានអគ្គមេស្មី ១ឈ្មោះនាងស្រី ទេវតីឆោមឆាយ្យ ប្រសើរដ្ឋលើសលែង
ព្រះស្នំសំម្នាយ ខ្សត្រីពន្រ្យា ឥតឯផ្ទឹមដល់ ។

៤. មហាខ្សត្រត្រកូល ជាតិជាឥស្សរ កុំពូលមន្តល់ កបនៅរសេណា
យោទ្ធារេព័ល ទូរទ្ទាំសុកល់ ជុំពូរប្រិបហោង ។

៥. ស្តេចមានស័ម្ភារ កបន្ទូវបរិពារ មាឞប្រាកកែវកង មានរត្នពាជី
ដំរីរយានផង ច្រើនក្រៃកន្លង ធំធាមុះហិម្មា ។
៦. ស្តេចមានរាជបុត្រ ពិសេសពិសុទ្ធិ ពីសីសោភា ទ្រង់ព្រះនាមា
ព្រះកែតមាលា ប្រសើរឧត្តមថ្លៃថ្លា ថ្លៃងថ្លីងពុំបាន ។
៧. ព្រះរាជកុមារ មានបុន្យត្រកាល ឥតឯប្រមាណ ក៏ក្រេីកអំពើក
ទ្វារទាវ៍សព្វស្ថាន ហេតុមានបរមី ពីមុនក្រាលក្រៃ ។
៨. អស់ស្តេចទាំឞ្សាប្យ ម្ស្យរំម្ស្យផ្ស្យ សឹងមូលមកនៃ ថ្វាតថ្វាយបង្គំ
ប្រណំសព្វថ្ងៃ បរិបូណ៌ថ្កើងក្រៃ ប្រាស់មាឞផងនៃ ។
៩. អណែាកដេរដាស់ ដង្វាឞ្សស្វយផង ដេឞ្យពារ៍ដេឞ្យទេស ពីសែសពេក្យហោង
គងគាល់ឥតឆ្កង សព្វថ្ងៃប្រកតី ។
១០. ព្រះវរបីតា នៅវព្រះមាតា ខ្យព្រោបិប្តី ស្រលេញស្នេស្មិត
បុត្ររត្នភ្វាប្រី ហារទៃឥតបី ឆ្អងឆ្អែតលើឞ្យណា ។
១១. កាន្នោះព្រះឥន្ទ្រ ទិព្វទេព្វនរិន្ទ បរំមទេព្វា សោឞ្យសុខស័ម្បាព្រ
ស្នឹតត្រៃត្រីង្យា លើឞ្យលែងទេវតា ឃ្វគាទិព្វស្ថាន ។
១២. សម្តេចឥន្ទ្រា ទ្រង់ព្រះករុណា ហាំទ្យេស្មោះស្មាន ស្តេចយកព្រះកេត
មាលាទោវឋាន ត្រៃត្រឹងសួគិស្ឋាន ជាបុត្រស្វួនភ្វា ។
១៣.ព្រះឥន្ទ្រស្រលេញ បាក់ដូចកើតចេញ ពីព្រះឱទរា ទាំងទិព្វទេពី
ស្រីសុជាតា ស្រលេញស្វួនភ្វា ជាបុត្រថ្លាថ្លៃ ។
១៤. វិត្យទេវតា មកគាល់ឥន្ទ្រា ប្រកតីសព្វថ្ងៃ ធុំក្លិនព្រះកេត
មាលាបុត្រថ្លៃ ជាមនុស្សវិសៃ លើងទៅស្វួគា ។
១៥. ទេវតាវំជួល ហាំទៃខ្សិកខ្សួល ឈឺព្រះកេសា ទេវតាផងចូល
ទូលព្រះឥន្ទ្រា ដេឞ្យច្បាប់ស្វួគា ពុំដែលកើតមាន ។

១៦. នោះទេិព្វព្រះឥន្រ្ទ សម្តេចអរិន្ទ បន្ទូលរឹងថ្កាន ថាហៃ្យទេព្វិហ្បើ
ហេតុបុន្យ័បូ្វរាណ អញឯងទេព្វិបាន នាំឡើងមកហោង ។
១៧. កាល្មោះសោតណា ព្រះកេតមាលា យល់ភិមានផង យល់ពេជយន្ត
ប្រសាទឯងហោង ប្រសើរ្ឋកន្លង លើ្យលើភិមាន ។ ...."

២. រឿងសំរាំងដែលជាកម្រងអត្ថបទសិក្សា សំរាប់ថ្នាក់បំពេញវិជ្ជា ក៏បានស្រង់ល្បើកនគរវត្តនេះមកបង្ហាញនៅទំព័រ ៩០-១០០ ហើយដែលមានសេចក្តីខាងដើម :

១. យើងខ្ញុំស្រណោះសល់ ឮ្បិតពុំយល់ព្រះសាស្តា
យល់តែព្រះបដិមា ស្ថិតលើអាស្នាព្រះអង្គ ។
២. ទើបខ្ញុំត្រេកអរណាស់ ឱនសំពះបង្គំផ្គង់
ព្រះរូបប្រសើរទ្រង់ ប្រោសសត្វផងឯក្រោយណា ។ ...."

៣. ក្នុង Textes Khmers លោក E.Aymonier បានចម្លងរឿងល្បើកនគរវត្តចុះនៅទំព័រ ២៦៧ - ២៩៧ ហើយបកប្រែជាភាសាបារាំង ចុះនៅទំព័រ ៦៨ - ៨៤ ។

## អ្នកនិពន្ធ

អ្នកនិពន្ធល្បើកអង្គរវត្តមានឈ្មោះថា " អ្នកប៉ង " តាមអារម្ភកថារបស់លោកខាងដើមថា

"... ខ្ញុំមអង្គអំបូ្វរ ពូជពង្សត្រកូល ជាតិវង្សា នាមនៃអ្នកប៉ង
គាត់សាងសត្រា ល្បើកអង្គរជា ច្បាប់ទៅមុខហោង ..."

សេចក្តីនេះត្រូវលោក E.Aymonier បកស្រាយឈ្មោះអ្នកនិពន្ធថា:

" ... Pour les personnes qui s'occupent de l' archéologie de ce pays, j' ai terminé par le chant de l' Edification d'Angkor Vat, autrement appelé Satra de Préah Kêt Méaléa. Puissent-elles n' y pas trouver une déception! Il me semble que ce poème témoigne, chez son auteur Pâng, plutôt une lecture assidue du Réam-Kér qu'une entente scritable du monument sacré. Son style même, fortement frappé et d'une énergique concision peut indiquer une certaine Antiquité mais il montre surtout que le poète s'est assimilé jusqu'aux expressions de la version khmère de la Grande Epopée indienne ... "

ប៉ុន្តែ លោក ញ៉ុក ថែម [១] ព្រមទាំងសាស្ត្រាចារ្យមួយក្រុម [២] បានបកស្រាយឈ្មោះអ្នកនិពន្ធថា ជា " អ្នកប៉ាង " ទេវិញ ដោយអាង " ប៉ាង " ប្រើចាប់ចុងចួន និងពាក្យ "សាង " តាមក្បួនកាព្យបទកាកគតិ ។

តាមសេចក្តីក្នុងវគ្គកាព្យខាងលើនេះ អ្នកនិពន្ធជាមនុស្សមានពូជពង្សមិនមែនជាទាសៈទេហើយតាមឯកសារ"ស្រាវជ្រាវរកអ្នកនិពន្ធខ្មែរ" លោក ពេជ ប៊ុននិល បានស្មានថា "អ្នកប៉ង " នេះ ជាឧបាសកជើងវត្តទ្រាល ជំនាន់ព្រះបទុមបារមីស៊ិន ជាចៅអធិការ ក្នុងខេត្តបារាយណ៍ ដោយយោលទៅលើពតិមានក្នុងឯកសារ មហាបុរសខ្មែរ និង ទៅលើន័យនៃពាក្យ " អ្នក " និងទៅលើសំដីអ្នកនិពន្ធថា :

---

១. Revue de L'INP No 2 Mai 1959 p.24

២. អក្សរសាស្ត្រខ្មែរ - ប្រជុំសាស្ត្រាចារ្យ - បណ្ណាគារភ្នំពេញ គ.ស.១៩៥៦ - ទំព័រ ៤២

...ទើបខ្ញុំមត្រេកសាធ្លា
ឱនសិរសាបង្គំមផ្ទង
ព្រះរូបប្រសិទ្ធទ្រង
ប្រោសសត្វផងឯក្រោយណារ ..."

ដែលសឱ្យឃើញថា" អ្នកប៉ង" នេះ ជាអ្នកកាន់សាសនាព្រះពុទ្ធមួយរូបដែរ ។

## កាលបរិច្ឆេទ

អ្នកប៉ង បានសាងស្នាដៃនេះពីឆ្នាំ

| | | |
|---|---|---|
| " ... សារសប្តសេដ្ឋោ | ឆ្នាំមវកន័ខ្សត្រ | តិលកាលា ..." |
| ឯកបញ្ចទោ | វិវច្ឆនំ | |
| សសោត្តមំ | សាធុការំ | |

ដែលលោក ញ៉ុក ថែម បកស្រាយ "ឯកបញ្ចទោសសោត្តមំ" ជាមហាសករាជ ១ . ៥ . ២ . ០ ក្នុងឆ្នាំវក ហើយដែលត្រូវនឹង គ.ស (១៥២០+៧៨) ១៥៩៨ ។

ការបកស្រាយនេះ ពុំទាន់ជាក់លាក់ទេ ព្រោះបើផ្ទៀងផ្ទាត់ និងបញ្ជាក់សករាជរបស់លោក ភ្លង នួន ដែលឆ្លើយត្រូវឆ្នាំវកគឺ

គ.ស ១៥៧២ ត្រូវនឹងឆ្នាំវក ចត្វាស័ក

- ១៥៨៤ - - ឆ -
- ១៥៩៦ - - អដ្ឋ -
- ១៦០៨ - - សម្រិទ្ធិ -

បណ្ដាឆ្នាំទាំងបួននេះ មានតែគ.ស ពីរខាងក្រោយនេះទេ ដែលអាចទាក់ទងនឹង ម.ស នោះបានគឺៈ .គ.ស ១៥៩៦ ត្រូវនឹង ម.ស ១៥១៨ "ឯកបញ្ចឯកអដ្ឋ"

. គ.ស ១៦០៨ ត្រូវនឹង ម.ស ១៥៣០ " ឯកបញ្ចត្រីសម្រឹទ្ធិ" ឬ "ឯកបញ្ចតិសម្រឹទ្ធិ" ។ បើ "សសោត្តមំ" ត្រូវជា "សូន្យ" តាមលោក ញ៉ុក ថែម នោះយើងអាចជំនួស "សម្រឹទ្ធិ" និង "សសោត្តមំ" បានដែរគឺ "ឯកបញ្ចតិ សសោត្តមំ" ។

*បញ្ហានេះ អាចស្រាយបានដូចតទៅ :*

"ឯកបញ្ចតិសសោត្តមំ" ជាកម្រងពាក្យប្រាប់មហាសករាជមែន ព្រោះមានលំនាំជារបៀបបង្ហាញមហាសករាជក្នុងអក្សរសិល្ប៍ខ្មែរស្រាប់ ដូចមានក្នុង :

- រឿងខ្យងស័ង្ខ របស់ឧញ៉ាសុភាធិបតីអ៊ុក : "ឯកឆបញ្ចេក" ត្រូវជា : ១ . ៦ . ១ . ៥

- រឿងក្រុងសុភមិត្រ របស់ឧកញ៉ា កោសាធិបតីកៅ : "សករាជជួបជួនឯកស័ប្តទោសូន" ត្រូវជា : ១៧២០

- រឿងកាកី របស់ព្រះអង្គឌួង : មហាសករាជ ឯកស័ប្តត្រីស័ប្ត" ត្រូវជា : ម.ស ១៧៣៧ ។

ដូចនេះ មហាសករាជ ដែលអាចឆ្លើយត្រូវនឹងឆ្នាំរក មានតែ

"ឯកបញ្ចតិសសោត្តមំ" គឺ ម.ស ១៥៣០

តាមការបកស្រាយរបស់លោក ញ៉ុក ថែម ដែលគិត " សសោត្តមំ " ថា"០" ។

ប៉ុន្តែ បើ "សសោត្តមំ" ត្រូវបកស្រាយជា "ស័កសោត្តមំ" វិញនោះ កម្រងពាក្យ "សោត្តមំ" គឺជាការផ្សំ "ស + ឧត្តមំ" ដែលមានន័យថា យ៉ាងខ្ពស់បំផុតមួយ" ។ ដូចនេះ "ឯកបញ្ចតិសសោត្តមំ" ត្រូវបកស្រាយថា " ក្នុងមហា

សករាជ ១៥៣០ យ៉ាងខ្ពស់បំផុត" ទើបសម ពោលគឺ ម.ស ១៥៣១ ដែលត្រូវនឹង គ.ស.១៦០៩ ដែលថិតនៅក្នុងរង្វង់ឆ្នាំវកផង និងឆ្នាំរកាផង ព្រោះឆ្នាំរកា ចាប់កំណើតតាំងពី គ.ស ១៦០៩




ប៉ុន្តែ ដើម្បីឱ្យចួននឹង " សេដ្ឋោ " អ្នកនិពន្ធត្រូវដូរ " តិ " ឱ្យទៅជា "តោ" ដូចអ្នកចម្លងក្រោយកែជា " ទោ " ។

រួមមក ល្បើកអង្គរវត្តរបស់អ្នកប៉ង ត្រូវសាងឡើងពី ម.ស. ១៥៣១ ដែលត្រូវនឹង គ.ស. ១៦០៩ ដើម្បីដំណាលអំពីបុព្វហេតុនៃការកសាងអង្គរវត្ត ។ ដើមហេតុ គឺព្រះកេតុមាលា ដែលព្រះឥន្ទ្រជាព្រះវរបិតាបូរាណ បានមកនាំព្រះអង្គយកទៅស្ថានត្រៃត្រឹង្ស តែពួកទេពនិករពុំអាចទ្រាំនឹងក្លិនមនុស្សលោកបាន ក៏សុំឱ្យព្រះឥន្ទ្រនាំព្រះរាជកុមារ ចុះមកស្ថានក្រោមវិញ ។ ព្រះកេតុមាលា នឹករអាលោះអាល័យប្រាសាទល្អៗនៅស្ថានលើ ដូចជាពេជសន្ទរ័តន៍ជាដើម ។ អាស្រ័យហេតុនេះ ព្រះឥន្ទ្រ ក៏ប្រើព្រះពិស្ណុការឱ្យមកកសាងប្រាសាទទាំងនោះថ្វាយព្រះរាជបុត្រ នៅស្ថានមនុស្ស ។ ហើយអ្នកនិពន្ធបាននាំអ្នកអានឱ្យដើរមើលប្រាសាទគ្រប់ថ្នាក់ តាមថែវរបៀងផ្សេងៗ បង្ហាញពីក្បូរក្បាច់និងផ្ទាំងចម្លាក់ ផ្សេងៗយ៉ាងរស់រវើក ដូចជាសេចក្ដីរាយការណ៍របស់ហនុមានពីកោះលង្កាដូច្នោះដែរ ។

# អត្ថបទល្បើកអង្គរវត្ត

១. សារសប្ដសេដ្ឋោ ឯកបញ្ចទោ សសោតុមំ ឆ្នាំមវកន័ខ្សត្រ
វិវឌ្ឍនំ សាធុការំ តិលកាលោ ។

២. ខ្ញុំមអង្គអំបូរ ពូជពុង្សត្រកូល ជាតិវង្សា នាមនៃអ្នកប៉ង
គាត់សាងសត្រា ល្បើកអង្គរជា ច្បាប់ទៅមុខហោង ។

៣. មានចិត្រសាទ្ធា អាចចាសត្រា តៀតានគន្លង គាថាបាឡី
ពិត្យពីព្រេងហោង មែនដូច្នេះហោង ពុំឃ្លាតល្បើណារ ។

៤. អង្គអញខ្ញុំមសូម សំណាងសំណូម បានបបូណ៌ប្រា. កដ្ឋដូចខ្ញុំមគិត
ក្នុងចិត្រប្រាថ្នារ កុំឱ្យមានឃ្លារ ឃ្លាតដល់តិចល្បើ ។

៥. តែងជាបទព្រហ្មគិត លើកតៀគិតតាមទំនង
ដំណើរពីមុនហោង អ្នកប្រាជ្ញលោក្យលើកមកស្រាប់ ។

៦. ខ្ញុំមនៅសូមពន្ទ្យ ប្រកបកាយជាតិចំណាប់
ចំណងចងជាសប្ដ ជាត្រកាលពេត្យក្ដាត់ណារ ។

៧. អង្គអញសូមកុំណើត កប់កាលកើត១នៅនា
ស្ថានសួរត្រៃត្រើង្សារ ពិតពុំឃ្លាឃ្លាត់ល្បើហោង ។

៨. ខ្ញុំមសូមកំណើតគាប់ ជាសំរាប់ព្រះអង្គហោង
ព្រះសីអាកន្លង លែងទេព្ដនៅសួរនាថ្យ ។

៩. កាលព្រះចាកចយុត ស្រេវបស្រាប់ស្រុតសោះសព្វសា្យ
ចាប់ព្រះប្រឌិសុន្និឆ្ឆ្យ បបូរបានត្រាសហើ្យហោង ។

១០. ខ្ញុំមសូមកុំឱ្យឃ្លាត់ យោនយកជាតិថ្ងៃម្សផង

ព្រះអង្គនោះឯងហោង សូមបានដូចប៉ងប្រាថ្នា ។

១១. ខ្ញុំមសូមបានរៀនធម្ម៌ ចប់អសអាត្រៃភេទផង

សូមចិត្រល្អរកន្លង ជាសំឡាញ់និងញាតិផោរ ។

១២. ខ្ញុំមសូមមានសំមឡឹង សូរសប្ទផ្សឹងក្រាំងក្រាឱរ

រង្វាប់ចិត្រនិតនោរ អសអ្នកផងទុព្វពុំបាន ។

១៣. ខ្ញុំមសូមមានប្រាជ្ញា កាត់សាទ្ធាពន្ធ៌ប្រមាណ

ខ្ញុំមសូមបានឱ្យទាន អសទាំងស្មឹមយាចក់ផង ។

១៤. សំណូមនេះឯណា ខ្ញុំមប្រថ្នាស្រាប់ហើ្យហោង

សូមបានដូចបំណង ន្ទៃ្យអញខ្ញុំមសូមប្រថ្នា ។

១៥.ត្រៃភប្ត៌សាសុច្ចរិត្ត វិរិតហារទៃ្យា

ឱនអង្គអរសាធ្ធា ក្រុញក្រាប់ក្រោមព្រះលាក្សលក្ខណ៍ ។

១៦.ទោះទាំងគ្វូរលិ្យថ្កើង លុតលើកលើងស្មោះដោមដាក់

សិរសាដាក់ជៀងជាក់ ថ្ង្យវន្ទាឱនលំអុត ។

១៧.ស្មោះស្មានពីចិត្រចង់ បង្គំមត្រង់ព្រះសាម្ពុទ្ធ

ស្ដែងស្ដេចជាមកុដ្ឋ ត្រៃភប្ត៌ភារផងទាំងប្ល្យ ។

១៨. ព្រះអង្គគីភេត្រា មាលមាសមារត្នរៀងរាុ្យ

រាក្សីភ្លើហត្រោងព្រាយ ចិញ្ចែងចាំងទាំងសុកលំ ។

# ពាក្យទំនឹមទំនៀមខ្មែរ និងពាក្យស្លោក

១. កកក៏បាយ មេម៉ាយក៏ស្រី កន្ទុយបារីក៏ថ្នាំ

២. កាត់ទឹកមិនដាច់ កាត់សាច់វាឈឺ

៣. កាប់បំពង់ រង់ទឹកភ្លៀង

៤. ការប៉ុនភ្នំមិនគិត ទៅគិតឯស្គរកំបែកមាត់

៥. កោក១ សឹកតែមាត់ត្រដោក ឆ្អែតតែពោះក្របី

៦. កោរមិនដាក់ទឹក

៧. កុំខ្ញើកតាមខ្យល់ កុំខ្វល់តាមរលក

៨. កុំគួមុនគិត

៩. កុំឈ្លោះនឹងស្រី កុំក្តីនឹងគ្នាឯង

១០. កុំដេកផ្សងព្រេង កុំវង្វេងខុសផ្លូវ

១១. កុំដាំស្រូវ នៅផ្លូវដំរី

១២. កុំទុកចិត្តមេឃ កុំទុកចិត្តផ្កាយ
កុំទុកចិត្តប្រពន្ធ ថាគ្មានសហាយ
កុំទុកចិត្តម្តាយ ថាគ្មានបំណុល

១៣. កុំទុំមុនស្រគាល

១៤. កុំផ្អុកតាមទូកថ្ងៃ

១៥. កុំពត់ស្រឡៅ កុំប្រដៅស្រីខូច

១៦. កុំពូតផ្សេងជាដុំ កុំយកភ្នំទ្រាប់អង្គុយ
១៧. កុំវាមុខដឹង កុំទទឹងមុខសឹក
១៨. កុំពាក់មុខយក្ខ កុំពាក់ស្បែកខ្លា
១៩. កុំយកស្រឡៅធ្វើខ្នួច កុំសម្រួចឈើពុក
២០. កំភ្លាញស្លាប់ព្រោះមាត់ ខ្មែរស្លាប់ព្រោះអាចម៍
២១. ក្តៅថ្ងៃ មិនស្មើក្តៅចិត្ត
២២. ក្តៅស៊ីរាក់ ត្រជាក់ស៊ីជ្រៅ
២៣. ក្រពើវង្វេងបឹង
២៤. ក្រមុំដណ្តឹងម្តាយ មេម៉ាយដណ្តឹងចិត្ត
២៥. ក្រអឺក្រចុះ កុំអោយតែក្រគំនិត
២៦. ខឹងខុស ខឹងខូច ខឹងខាត
២៧. ខឹងគោ វាយរទេះ
២៨. ខឹងអោយរត់ ខ្សត់អោយរក
២៩. ខ្ពស់កប់ពពក ចុះមកជ្រកអាចម៍ជន្លេន
៣០. ខ្មោចស្រុកអោយដៃ ទើបខ្មោចព្រៃវាបានធ្វើ
៣១. ខ្លាមិនខ្លាច ទៅខ្លាចអាមច៍ខ្លា
៣២. ខ្លួនរស់ របស់រកបាន
៣៣. គោដំបៅខ្នង ក្អែកហើររំលង រំសាយកន្ទុយ
៣៤. គ្នាច្រើនអន្សមខ្មោច គ្នាដូចស្រមោចអន្សមឆៅ
៣៥. គ្រូកាច សិស្សខូច
៣៦. គ្រូទាយ ម្តាយថា
៣៧. ឃើញដីរីជុះ កុំជុះតាមដំរី

៣៨. ឃ្លាតកាយ ណាយចិត្ត

៣៩. ឃ្លានឆ្ងាញ់ ស្រឡាញ់ល្អ

៤០. ងប់នឹងល្បែង តែងវិនាស

៤១. ងើយវាស្ពក ឱនវាដាក់គ្រាប់

៤២. ចង់មានអោយដួញអង្ករ ចង់ក្រអោយដួញឡាន

៤៣. ចាក់អង្ករ យកអង្កាម

៤៤. ចានមួយរាវ លែងអីរណ្តំគ្នា

៤៥. ចាប់ក្តាមដាក់ចង្អេរ

៤៦. ចាប់នេះ ចាប់នោះ មិនឆ្ពោះត្រង់ណា

៤៧. ចូលព្រៃទាន់ព្រឹក ចង់សឹក(១) ទាន់នៅក្មេង

៤៨. ចូលស្ទឹងតាមបត់ ចូលស្រុកតាមប្រទេស

៤៩. ចំណីឆ្ងាញ់ កុំទុកស្អែក

៥០. ចេះដប់ មិនស្មើប្រសប់មួយ

៥១. ចេះពីរៀន បានពីរក

៥២. ចេះឯងអោយក្រែងចេះគេ

៥៣. ឆ្កែខាំ កុំខាំឆ្កែវិញ

៥៤. ឆ្កែព្រុស មិនដែលខាំ

៥៥. ឆ្នាំងណា គ្របនឹង

៥៦. ឆ្មាមិននៅ កណ្តុរឡើងរាជ្យ

៥៧. ឆ្អិនក្បាលស៊ីក្បាល ឆ្អិនកន្ទុយស៊ីកន្ទុយ

(១) លាចាកផ្នួស

៥៨. ជាងទងស៊ីរងកំបែក ជាងដែកស៊ីហែកនឹងដៃ

៥៩ . ជាងមិនកើត បន្ទោសដែក

៦០. ជិះក្របី ចម្លងភក់

៦១. ឈោមស្រែក ស្បែកហោ

៦២. ឈើកោងវល្លិព័ទ្ធ មនុស្សខ្ជាត់ភ្លាត់កុំយកខ្លួនបៀត

៦៣. ឈើពុក កុំដាក់គូទលើ

៦៤. ដល់ត្រើយ សើយគូទ

៦៥. ដាំជើងក្រាន មិនប្រមាណឆ្នាំង

៦៦. ដឹងដប់ ប្រសប់ឈើមួយ

៦៧. ដៃភ្លើង ជើងមាន់

៦៨. ដីរជល់គ្នា ងាប់ស្មោចិញ្ចៀន

៦៩. ដីរសារស្លាប់ យកចង្អេរបាំង

៧០. តក់ៗ ពេញបំពង់

៧១. ត្រីងៀត ឆ្អៀតពង

៧២. ត្រីមួយត្រក ស្អុយមួយ ស្អុយទាំងអស់

៧៣. ថោកអ្វីនឹងដៃ ថ្លៃអ្វីនឹងមាត់

៧៤. ទន្លេដប់ មិនស្កប់សមុទ្រមួយ

៧៥ . ទម្លាក់វាទៅ ទើបផ្ទៅវាមក

៧៦. ទូកទៅ កំពង់នៅ

៧៧. ធ្នូបង់បាញ់ ធមិបង់ទន្ទេញ ស្ត្រីបង់ភស្តា

៧៨. ធ្វើគុណ ១០០ សំពៅ ទោស ១ ចូលទៅរលាយគុណអស់

៧៩. ធ្វើស្រែទាន់ក្តៅដី ចង់ស្រីទាន់ក្តៅចិត្ត

៨០. ធ្វើស្រែនឹងទឹក ធ្វើសឹកនឹងបាយ

៨១. ធ្វើស្រែអោយមើលស្មៅ
ទុកដាក់កូនចៅ អោយមើលផៅសន្តាន

៨២. ធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់

៨៣. ធ្វើគុណ បានទោស

៨៤. នៅផ្ទះម្តាយទីទៃ ទៅព្រៃម្តាយជាមួយ

៨៥. បាតដៃ ខ្នងដៃ

៨៦. បុណ្យក៏ធ្វើ ឈើក៏កាប់

៨៧. ប្ញញមាត់ បត់ដុំដៃ

៨៨. ប្រហែសបាត់ ប្រយ័ត្នគង់

៨៩. ប្រញាប់ពេក ដេកផ្លូវ

៩០ . ប្រាក់ក៏បង់ ផង់ក៏ដាច

៩១. ផ្លែឈើជ្រុះ មិនដែលឆ្ងាយពីគល់

៩២. ពាក្យម្តាយ ទំនាយគ្រូ ( គ្រូទាយ ម្តាយថា )

៩៣. ពេលឈឺ យកដីរបន់ ពេលស្រន់ យកពងមាន់ទៅថ្វាយ

៩៤. ភូតនៅហោរ ចោរនៅជាង

៩៥. មនុស្សនឹងប្រាក់ យក្ខនឹងសាច់

៩៦. មានដំបៅ ទើបរុយវារោម

៩៧. មានមាស ខ្វះក្រដាសខ្ចប់

៩៨. មាសល្បងអគ្គី ទុក្ខវេទនាល្បងមនុស្ស

៩៩. មីះៗ កេះឆ្មាំងបាយផ្ទះ

១០០. ម្ទេះៗ យកជ័រព្នោមកត្បៀតឃ្លៀក

១០១. យកពងមាន់ទៅផ្ញើនឹងក្អែក

១០២. យប់មើលនឹងដៃ ថ្ងៃមើលនឹងភ្នែក

១០៣. រកអុស ប្រទះឈើងាប់

១០៤. រស់តែមាត់ ត្រគាកស្លាប់ស្ងួត

១០៥. រឹងដែកពត់បាន រឹងថានពត់បាក់

១០៦. លួចគេធ្លាប់ដៃ ដេកថ្ងៃធ្លាប់ភ្នែក

១០៧. លឿន លៃមិនទាន់

១០៨. លេងក្មេង អាប់យស លេងពស់ៗខាំ

១០៩. សូវស្ងួច កុំអោយដាច់

១១០. សូវស្លាប់ជា កុំអោយស្លាប់មេ

សូវលិចទូកកណ្តាលទន្លេ កុំអោយភ្លើងឆេះផ្ទះ

១១១. ស្រឡាញ់ខ្លួន អោយស្ងួនចំណី

១១២. ស្រឡាញ់កុំទៅញ៉ើក បើរលីកសីមទៅម្តងៗ

១១៣. ស្លៀកស្បង់មិនកោរសក់ ឆ្លុះកញ្ចក់ធ្មេចនេត្រា

១១៤. ស្លាប់ដូចពស់ រស់ដូចកង្កែប

១១៥. ហុតទឹក សម្លឹងកាក

១១៦. អង្គុយលើចង្អេរ លើកខ្លួនឯង

១១៧. អន្ទង់វែង ផ្អាំងវែង

១១៨. អាវៀចធ្វើកង់ អាត្រង់ធ្វើទូក

ស្រាវជ្រាវដោយ

**យី ធន់ * ឱម ខែម**

# បុណ្យចូលឆ្នាំខ្មែរ

គ្រប់ប្រជាជាតិក្នុងលោក សុទ្ធតែមានការចូលឆ្នាំរបស់ខ្លួន គ្រាន់តែប្លែកគ្នាត្រង់ការកំណត់ពេលចូល និងពិធីធ្វើខុសគ្នាប៉ុណ្ណោះ ។ ឯប្រជាជនខ្មែរ ក៏មានការចូលឆ្នាំប្រពៃណីរបស់ខ្លួន តាំងពីបុរាណកាលមកដែរ ។

## I. ពេលវេលាចូលឆ្នាំខ្មែរ

កាលដើមឡើយ ខ្មែរយើងប្រារព្ធធ្វើបុណ្យចូលឆ្នាំ ក្នុងខែមិគសិរ ព្រោះគេកំណត់យកខែនេះ ជាខែដើមឆ្នាំ ។ នាសម័យព្រេងនាយ ឆ្នាំនីមួយៗ ចែកជា ៣ រដូវ តាមចន្ទគតិ គឺ *ហេមន្តរដូវ គិម្ហរដូវ និង វស្សានរដូវ* ។ បុរាណាចារ្យលោកគិតថា *ហេមន្តរដូវ* ជារដូវត្រជាក់ ត្រូវចាត់ទុកជារដូវដើមឆ្នាំ ប្រៀបបាននឹងពេលព្រឹក ដែលផុតពីរាត្រី គឺជាដើមថ្ងៃ ។ *គិម្ហរដូវ* ជារដូវក្តៅ ត្រូវចាត់ទុកជាកណ្តាលឆ្នាំ ប្រៀបដូចជាពេលថ្ងៃត្រង់ ។ *វស្សានរដូវ* ជារដូវដែលមេឃមីរ ងងឹតមានភ្លៀងផ្គរ ត្រូវចាត់ទុកជាចុងឆ្នាំ ប្រៀបបាននឹងពេលព្រលប់ ។

ចំណេរកាលក្រោយមក, គ្រាដែលបុព្វបុរសខ្មែរយើង អនុលោមប្រើចុល្លសករាជជាសំខាន់នោះ (មិនដឹងជាប្រើនៅក្នុងរជ្ជកាលនៃព្រះរាជាអង្គណាទេ) ទើបការចូលឆ្នាំថ្មី មានការប្រែប្រួល ហើយកំណត់យកខែចេត្រ ជាខែដើមឆ្នាំវិញ ។ ឯថ្ងៃចូលឆ្នាំខ្មែរ តែងប្រព្រឹត្តទៅ មិនមុនថ្ងៃ ៤ កើត ខែចេត្រ និងមិនក្រោយថ្ងៃ ៤ កើត ខែពិសាខ ព្រោះបុព្វបុរសយើងយល់ឃើញថា នៅខែមិគសិរនេះ ប្រជា-កសិករខ្មែរយើង រវល់មមាញឹកក្នុងរបរកសិកម្ម មានស្រែចំការ ជាដើម ទើបលោកលើកកំណត់ពេលចូលឆ្នាំ មកធ្វើនៅក្នុងខែចេត្រវិញ ដោយហេតុថា ខែចេត្រ

កិច្ចការច្រូតកាត់ បោកបែន បានចប់សព្វគ្រប់ ហើយប្រជាពលរដ្ឋខ្មែរយើងទំនេរ មានឱកាសធ្វើបុណ្យទាន កំសាន្ត សប្បាយ តាមប្រាថ្នា ។ ការកំណត់នេះ ក៏ជាប់ ជាប្រពៃណី រហូតមកដល់សព្វថ្ងៃ ។

## II. ទិដ្ឋភាពបុណ្យចូលឆ្នាំខ្មែរ

បុណ្យចូលឆ្នាំខ្មែរ ជាព្រឹត្តិការណ៍យ៉ាងធំមួយក្នុងទឹកចិត្ត និងជីវភាពខ្មែរ។ មុនពេលចូលឆ្នាំថ្មីមកដល់ គេនាំគ្នារៀបចំ តុបតែងផ្ទះសម្បែង សំអាតទីធ្លា វត្ត អារាម ផ្លូវថ្នល់ ចេតិយ រមណីយដ្ឋាន សង់រានទេវតា បុកអង្ករ រកឧស ដងទឹក ត្រៀមសំលៀកបំពាក់ថ្មីៗ . ល . អោយហើយស្រេច ។ ពេលចូលឆ្នាំ ជាពេល ជម្រះឧបទ្រពចង្រៃនៃឆ្នាំចាស់អោយជ្រះស្រឡះ ដើម្បីទទួលឆ្នាំថ្មី ទេវតាថ្មី ក្នុងក្តី សោមនស្ស ក្សេមក្សាន្ត និងសុភមង្គល ។

ឆ្នាំថ្មីមកដល់, ស្គរស្គរ រគាំង សំឡេងធមិពរជ័យ លាន់ឮរន្ថឺអឹងកង ចេញ ពីវត្តអារាម ។ ភ្លើងទៀនធេះព្រោងព្រាត ផ្សែងធូបហុយចេញពីគ្រប់រានទេវតា តាម ដងផ្លូវ មុខផ្ទះសម្បែង វត្តអារាម ។ ចាស់ទុំ ក្រមុំ កម្លោះ ក្មេងក្មាង តូចធំ ប្រដាប់ ដោយសំលៀកបំពាក់ស្អាតៗ ចេញមកទទួលទេវតាឆ្នាំថ្មី ។ ម្នាក់ៗ មានទឹកមុខរីករាយ ស្រស់ស្រាយ រំភើបក្រៃលែង ។ ក្រមុំ កម្លោះ និងក្មេងៗ សប្បាយក្អាកក្អាយជាងគេ ព្រោះជាឱកាសដ៏ពិសេសបំផុត សំរាប់ពួកគេចូលឆ្នាំ កំសាន្តល្បែងប្រជាប្រិយ ជា មួយគ្នា ដោយគ្មានចាស់ទុំណា ខាឃាំង រាំងឃាត់អ្វីឡើយ ។

ពេលព្រលប់, គេនាំគ្នាទៅស្តាប់ធមិអាថិក្នុងវត្ត ។ អ្នកខ្លះដែលមិនបាន ទៅស្តាប់លោកឯវត្ត ក៏ប្រមូលផ្តុំគ្នាលេងល្បែងប្រជាប្រិយផ្សេងៗ តាមចំណង់ ។ គេនាំគ្នាលេងល្បែងចាប់កូនខ្លែង, លាក់កន្សែង, ក្រុងមាន់, ទាញព្រ័ត្រ, ច្រៀង

ប្រេបកែ ស្តេចចង់, ឈូង, អង្គញ់, រាំវង់ . ល . យ៉ាងសប្បាយរីករាយ ។ គេនាំគ្នាយកចង្ហាន់ទៅប្រគេនព្រះសង្ឃ បង្សុកូលឧទ្ទិសកុសលជូនដល់បុព្វការីជន ញាតិសន្តាន ដែលបានចែកស្ថានទៅកាន់បរលោកហើយ ។ គេនាំគ្នាជញ្ជូនដីចំរើនទីវត្ត ពូនភ្នំខ្សាច់ រែកទឹកស្រង់ព្រះ ស្រង់ព្រះសង្ឃ និងចាស់ព្រឹទ្ធាចារ្យ ។ ពេលត្រឡប់ទៅភូមិវិញ គេអញ្ជើញមាតាបិតា ជីដូនជីតា ចាស់ទុំ មកផ្លូតទឹក ជូនសំលៀកបំពាក់ថ្មី នំ ចំណី ដើម្បីជាកិច្ចតបស្នងសងគុណ ចំពោះបុព្វការីជនរបស់គេ ។ តាមគ្រប់វត្តអារាម គេសង្កេតឃើញចាស់ទុំ ក្រមុំ កម្លោះ ក្មេងក្មាង ប្រមូលផ្តុំជួបជុំគ្នាក្រោមម្លប់ឈើធំៗ ក្រសាលលេងល្បែងប្រជាប្រិយផ្សេងៗ តាមចំណង់ចំណូលចិត្ត ។ គេនាំគ្នាទៅទស្សនាកំសាន្តប្រាសាទបុរាណ រមណីយដ្ឋាន គោរពបូជាវត្ថុសក្តិសិទ្ធិ ភ្ជាប់បរិយាកាសរីករាយនេះ ទៅនឹងបរិយាកាស នាសម័យព្រេងនាយ ដ៏រុងរឿង ។ នៅតាមខេត្ត តំបន់ខ្លះ ពេលចូលឆ្នាំម្តងៗ គេមិនមែនសប្បាយតែក្នុងរយៈពេលបីថ្ងៃប៉ុណ្ណោះទេ, គេចាប់ផ្តើមលេងសប្បាយរបៀបនេះ មុន និងក្រោយប៉ុន្មានថ្ងៃចូលឆ្នាំ ទៀតផង ។ គេនាំគ្នាធ្វើបុណ្យអោយអស់ចិត្ត សប្បាយអោយអស់ចិត្ត ដើម្បីអបអរសាទរចំពោះជីវិតថ្មីរបស់គេ ដែលបានហែលឆ្លងកាត់ឧបសគ្គ ទទួលជោគជ័យក្នុងរយៈពេលឆ្នាំចាស់កន្លងទៅ និងដើម្បីត្រៀមចាំបំពេញភារកិច្ចថ្មី ត្រៀមចាំរដូវដកស្ទូង ត្រៀមចាំទឹកភ្លៀងដែលនឹងបង្អុរចុះ នាដើមវស្សានរដូវនៃឆ្នាំថ្មី ដ៏ខ្លីខាងមុខ ។

## III. ជំនឿ និង ពិធីផ្សេងៗ (១)

*១. ទេវតាឆ្នាំថ្មី :* ក្នុងសង្ក្រាន្តសូត្រ និទានថា ក្នុងដើមភទ្ទកប្បនេះ មានបុរសម្នាក់ឈ្មោះ *ធម្មបាល* ជាអ្នកប្រាជ្ញចេះចប់ត្រៃវេទ ព្រមទាំងចេះភាសាសត្វ

(១) ស្រង់សង្ខេបពីព្រះរាជពិធីទ្វាទសមាស ភាគ ១

បក្សីផង ។ ធម្មបាល តែងសម្តែងមង្គលដល់មនុស្សផងទាំងពួង ។ លុះកបិលមហា-ព្រហ្ម ( សម័យកាលនោះ គេគោរពបូជាមហាព្រហ្ម និងកបិលមហាព្រហ្ម ) ជ្រាបថា ធម្មបាលកុមារ ជាអ្នកប្រាជ្ញ ក៏មកសួរប្រស្នា ៣ខ ហើយសន្យាថា ប្រសិនបើធម្មបាល ដោះស្រាយប្រស្នានេះរួច កបិលមហាព្រហ្ម នឹងកាត់ក្បាលខ្លួនបូជាធម្មបាល តែបើ ធម្មបាលដោះមិនរួចទេ ត្រូវកាត់ក្បាលបូជាមហាព្រហ្មវិញ ។ ធម្មបាល សុំបង្អង់ ៧ថ្ងៃសិន ដើម្បីគិតប្រស្នា ប៉ុន្តែ ៦ថ្ងៃកន្លងផុតទៅហើយ នៅតែគិតមិនឃើញសោះ ធម្មបាល ក៏ភៀសខ្លួនទៅពួននៅក្រោមដើមត្នោតមួយគូ ដែលជាលំនៅសំបុកនៃ សត្វឥន្ទ្រី ។ ជាភ័ព្វសំណាងល្អ យប់នោះ ធម្មបាលក៏បានឮឥន្ទ្រីញី-ឈ្មោល និយាយ គ្នាថា :

- ញី : ព្រឹកនេះ យើងបានអាហារពីណាស៊ី ?
- ឈ្មោល : យើងនឹងបានស៊ីសាច់ធម្មបាល ដែលត្រូវកបិលមហាព្រហ្ម សម្លាប់ ព្រោះដោះប្រស្នាមិនរួច ។
- ញី : ប្រស្នានោះ ដូចម្តេច ?
- ឈ្មោល : . (ខ១) វេលាព្រឹក សិរី ស្ថិតនៅទីណា ? ត្រូវឆ្លើយថា នៅមុខ, ហេតុនោះ មនុស្សទាំងឡាយ ត្រូវយកទឹក លាងមុខ ។
  - . (ខ២) ថ្ងៃត្រង់ សិរី ស្ថិតនៅទីណា ? ត្រូវឆ្លើយថា នៅទ្រូង, ហេតុនោះ មនុស្សទាំងឡាយ ទើបយកទឹក លាងទ្រូង ។
  - . (ខ៣) វេលាល្ងាច សិរី ស្ថិតនៅទីណា ? ត្រូវឆ្លើយថា នៅជើង, ហេតុនោះ មនុស្សទាំងឡាយ ទើបយកទឹក

លាងជើង ។

ពាក្យពេចន៍ទាំងប៉ុន្មានរបស់ឥន្ទ្រី ក៏បានជាពន្លឺមកបំភ្លឺដោះស្រាយប្រស្នាកបិលមហាព្រហ្មរួច ជៀសផុតពីក្តីមរណៈ ។ កបិលមហាព្រហ្ម សុខចិត្តចាញ់ព្រមកាត់ក្បាលបូជាធម្មបាល ។ មុននឹងកាត់ក្បាល កបិលមហាព្រហ្ម ហៅទេពធីតា ៧ អង្គ ដែលជាបុត្រីរបស់ខ្លួន អោយយកពានមកទ្រក្បាល (ព្រោះបើដាក់ក្បាលនោះលើផែនដី នឹងកើតជាភ្លើងឆេះលោកធាតុ, បើបោះទៅលើអាកាស នឹងរាំងភ្លៀង, បើចោលទៅក្នុងសមុទ្រ ទឹកនឹងរីងស្ងួតអស់) រួចហើយ ក៏កាត់ក្បាលអោយទៅនាង *ទុង្សា* ជាកូនច្បង ។ នាងទុង្សា ហែក្បាលកបិលមហាព្រហ្ម ប្រទក្សិណភ្នំព្រះសុមេរុ អស់ ៦០ នាទី ទើបអញ្ជើញក្បាលនោះទៅប្រតិស្ឋានទុកក្នុងមណ្ឌប ភ្នំកៃលាស ។ លុះដល់គម្រប់មួយឆ្នាំសង្ក្រាន្ត ទើបនាងទេធីតាទាំង ៧ អង្គ ផ្លាស់វេនគ្នា មកដង្ហែក្បាលកបិលមហាព្រហ្ម ប្រទក្សិណភ្នំព្រះសុមេរុ ជារៀងរាល់ឆ្នាំ ។ បុត្រីទាំង ៧ អង្គនោះគឺ :

១. បើសង្ក្រាន្តចំថ្ងៃអាទិត្យ ត្រូវវេននាង *ទុង្សា*,

២. បើសង្ក្រាន្តចំថ្ងៃចន្ទ ត្រូវវេននាង *គោរាគៈ*,

៣. បើសង្ក្រាន្តចំថ្ងៃអង្គារ ត្រូវវេននាង *រាក្សសា*,

៤. បើសង្ក្រាន្តចំថ្ងៃពុធ ត្រូវវេននាង *មណ្ឌា*,

៥. បើសង្ក្រាន្តចំថ្ងៃព្រហស្បតិ៍ ត្រូវវេននាង *កិរិណី*,

៦. បើសង្ក្រាន្តចំថ្ងៃសុក្រ ត្រូវវេននាង *កិមិរា*,

៧. បើសង្ក្រាន្តចំថ្ងៃសៅរ៍ ត្រូវវេននាង *មហោទរា* ។

ដោយមាននិទានបែបនេះហើយ ទើបខ្មែរយើងមានជំនឿ ហើយបានរៀបចំជាពិធីបូជាទេវតា ដែលត្រូវវេនដង្ហែក្បាលកបិលមហាព្រហ្ម និងត្រូវអភិបាលពិភពលោក រៀងរាល់ឆ្នាំថ្មីចូលមកដល់ ពុំដែលអាក់ខានឡើយ ។

*២ . ពិធីស្រង់ព្រះ :* មហាសំការសូត្រ ដែលមានមកក្នុងគម្ពីរសុត្តជាតក ជាមគធភាសា បាននិទានថា ថ្ងៃសង្ក្រាន្តឆ្នាំថ្មីជិតចូលមកដល់ ព្រះបាទបសេនទិ-កោសល បានរៀបចំជាបារាំយ៉ាងស្អាតនៅឆ្នេរស្ទឹងមួយ ហើយក៏និមន្តព្រះពុទ្ធ និងព្រះសង្ឃស្រង់ទឹក រួចសមាទានសីល ប្រគេនភត្តាហារចំពោះព្រះពុទ្ធ ព្រមទាំងភិក្ខុ-សង្ឃ នៅទីនោះ ។ គម្ពីរនេះដដែល បញ្ជាក់ទៀតថា អ្នកដែលបានស្រង់ទឹកព្រះសង្ឃ មាតាបិតា គ្រូ ឧបជ្ឈាយ៍ មានអានិសង្សច្រើនណាស់ ។ អនាគតជាតិ នឹងបានទៅកើតក្នុងទេវលោក បានជាស្ដេចចក្រពត្តិ មានបុណ្យបារមីច្រើន មានរូបល្អ មានទ្រព្យសម្បត្តិច្រើន មានសេចក្ដីសុខគ្រប់យ៉ាង .ល. ។

គម្ពីរបញ្ញាសជាតក ត្រង់ជាតកទី ៣១ បានបញ្ជាក់អំពីអានិសង្ស នៃការស្រង់ទឹកព្រះសង្ឃ ដូចមហាសំការសូត្រដែរ គ្រាន់តែខុសគ្នាត្រង់មិនបានបញ្ជាក់ថាក្នុងឱកាសចូលឆ្នាំនោះប៉ុណ្ណោះ ។ លោកលើកឧទាហរណ៍ ដូចជា ព្រះបាទបុប្ផរាជដែលបាននិមន្តព្រះឧសភត្ថេរ ក្នុងសាសនាព្រះពុទ្ធសរណង្ករ អោយស្រង់ទឹក ។ លុះអនាគតជាតិទៅ បានទៅកើតក្នុងទេវលោក មានបុណ្យបារមីច្រើន ហើយទីបំផុតបានទៅជាស្ដេចចក្រពត្តិ ក្នុងជម្ពូទ្វីបនេះ ។

នៅក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី ៧ ពេលចូលឆ្នាំម្ដងៗ គេតែងធ្វើពិធីមួយ ដោយនិមន្តព្រះពុទ្ធរូបមានមហិទ្ធិឫទ្ធិ ២៥ អង្គ ដែលជាតំណាងអាណាខេត្តទាំងឡាយក្នុងព្រះរាជាណាចក្រ មកធ្វើពិធីស្រង់ទឹកនៅប្រាសាទជ័យស្រី (ប្រាសាទព្រះខ័ន) រួចគេដង្ហែព្រះពុទ្ធរូបទាំងនោះ ជាក្បួនយ៉ាងមហោឡារិក មុននឹងយកទៅតំកល់នៅកន្លែងដើមវិញ ។

ដោយមានជំនឿលើនិទាន និងទំនៀមរបស់ដូនតាយើង ដូចខាងលើនេះហើយ បានជាមានទម្លប់ជាប់ជាប្រពៃណីរហូតមកដល់សព្វថ្ងៃនេះ ។ តែដល់ពេលចូលឆ្នាំម្ដងៗ គេតែងធ្វើពិធីស្រង់ទឹកព្រះពុទ្ធរូប-ព្រះសង្ឃ - មាតាបិតា - ជីដូនជីតា

បុព្វការី នៅតាមវត្តអារាម និងតាមភូមិ ស្រុក ។

៣. ពិធីជូនភ្នំខ្សាច់ ៖ មហាសំការសូត្របានបញ្ជាក់ថា ៖ ពេលសង្ក្រាន្តឆ្នាំថ្មីជិតមកដល់ ព្រះបាទបសេនទិកោសល បានទូលសួរព្រះពុទ្ធថា ក្រោយព្រះអង្គបរិនិព្វានទៅ បើដល់រដូវសង្ក្រាន្តចូលឆ្នាំថ្មីម្តងៗ តើខ្ញុំព្រះអង្គគួរបំពេញកុសលអ្វីខ្លះ ? ព្រះពុទ្ធត្រាស់ថា « គួរសាងវាលុកចេតិយ នៅឆ្នេរស្ទឹង ទន្លេ ហើយនាំយកគ្រឿងសក្ការៈ ទៀនធូប គ្រឿងក្រអូប ផ្កា ជាដើម មកបូជាចុះ » ។ ព្រះអង្គបានបញ្ជាក់អំពីអានិសង្សនៃការសាងវាលុកចេតិយនោះ ថាមានអានិសង្សច្រើនវិសេសណាស់ ដូចគ្នានឹងស្រង់ទឹកព្រះសង្ឃដែរ ។

គម្ពីរអានិសង្សវាលុកចេតិយ ជាសាស្ត្រាស្លឹករឹតភាសាខ្មែរ មានតែមួយខ្សែ ហើយមានបីនិទាន ៖

*- និទានទី ១ ៖* ដំណាលពីបារិកពោធិសត្វ និងពួកពាណិជ ដែលបានជូនភ្នំខ្សាច់ឧទ្ទិសជាតំណាងចូឡាមណីចេតិយ ដែលតំកល់ព្រះចង្កូមកែវរបស់ព្រះពុទ្ធពីបុរាណ ប្រតិស្ឋនៅស្ថានត្រៃត្រិង្សទេវលោកនោះ ។ លុះអនាគតជាតិទៅ បានទៅកើតក្នុងសុគតិភព កើតជាស្តេចចក្រពត្តិ ជាច្រើនជាតិ ហើយទីបំផុត បានត្រាស់ជាព្រះពុទ្ធយើងនេះ ។

*- និទានទី ២ ៖* ដំណាលពីនាយនេសាទម្នាក់ (ឈ្មោះមិនប្រាដក) ដែលជាអ្នកសម្លាប់សត្វជាអាហារ តាំងពីតូចមក ។ ថ្ងៃមួយ អ្នកនេសាទនេះ បានប្រគេនបាយមួយពំនូតដល់ភិក្ខុមួយអង្គ ។ ពេលដែលគាត់ស្លាប់ទៅ យមរាជបានយកទៅវាយសួរចម្លើយ ហើយចាប់បោះទៅក្នុងរណ្តៅភ្លើងនរក តែមិនឆេះ បែរជាខ្ទាតចេញមកវិញ ។ នាយយមបាល ក៏វាយសួរម្តងទៀត ។ ទទួលពេលនោះ នាយនេសាទក្រឡេកឃើញអណ្តាតភ្លើងនរក មានសម្បុរដូចចីវរលោក ក៏នឹកដល់ទានរបស់ខ្លួន

ហើយជំរាបយមបាល តាមដំណើររឿងធ្វើមាន ។ ពួកយមបាល ក៏អនុញ្ញាតអោយបុរសនោះ ទៅកើតក្នុងទេវលោកចំនួន ៧ ថ្ងៃ ហើយសឹមត្រឡប់មកស្ថាននរកវិញ ។ ទេវបុត្រនេះ ឈ្មោះថា « *អន្ទំលោកង្សិនី* (១)» មានប្រពន្ធសំណប់ចិត្តឈ្មោះនាង សុវណ្ណឱរ៉ៃ ។ គាត់បាននិយាយរឿងរ៉ាវរបស់គាត់ ដែលធ្លាក់ទៅនរកនោះប្រាប់ភរិយា ដោយសព្វគ្រប់ ។ នាងសុវណ្ណឱរ៉ៃ ក៏អោយស្វាមីខ្លួនសាងវាលុក-ចេតិយ ហើយឆ្លងអោយស្រេចក្នុងថ្ងៃទី ៧ ។ លុះដល់ថ្ងៃទី ៨ យមរាជ ក៏តាមមកហៅ អន្ទំលោកង្សិនី ទៅស្ថាននរកវិញ ។ នាងប្រពន្ធ ក៏ចេញមកនិយាយតបថា " យើងមិនបើកទ្វារអោយស្វាមីយើងទៅទេ ព្រោះស្វាមីយើង បានសាងវាលុក-ចេតិយ និងធ្វើ ពិធីឆ្លងរួចហើយ, បើនៅតែត្រូវការយកប្ដីយើងទៅធ្វើទោសនោះចូរអ្នករាប់គ្រាប់ខ្សាច់នេះអោយអស់សិន " ។ យមរាជ ក៏ចាប់ផ្ដើមរាប់គ្រាប់ខ្សាច់ពេញមួយព្រឹកថ្ងៃត្រង់ មិនចេះអស់សោះ ។ យមរាជ ក៏ទាល់តម្រិះ ហើយត្រឡប់ទៅស្ថាននរកវិញ ។

. *និទានទី ៣ :* ដំណាលពីចៅកម្ជិលខ្សាច់ ថា " មានក្មេងម្នាក់ ចេះតែពូនខ្សាច់ នៅទីផ្នូកខ្សាច់មុខផ្ទះ ហើយដេកនៀលលេងរាល់ៗថ្ងៃ ប្រឡាក់ប្រឡូសទៅដោយខ្សាច់ មើលមិនយល់, គេក៏នាំគ្នាហៅថា ចៅកម្ជិលខ្សាច់ តមក ។ ថ្ងៃមួយព្រះឥន្ទទតឃើញយ៉ាងនេះ ក៏អោយនាងទេពធីតាម្នាក់ ចុះមកធ្វើជាប្រពន្ធ ។ ក្រោយមក ព្រះរាជាទ្រង់ចូលទីវង្គត ហើយគ្មានអ្នកណាស្នងរាជ្យ ពួកមន្ត្រី ក៏ធ្វើបុស្បុកផ្សងរកអ្នកមានបុណ្យបារមី ។ បុស្បុក ក៏ទៅត្រូវលើចៅកម្ជិលខ្សាច់ ។ គេក៏នាំគ្នាអញ្ជើញចៅកម្ជិលខ្សាច់នោះ ទៅអោយសោយរាជ្យជាសុខ តទៅ " ។

ដោយមាននិទានបែបនេះហើយបានជា ខ្មែរយើងមានជំនឿជាប់តរៀងរហូតមកដល់បច្ចុប្បន្ន ប៉ុន្តែភ្នំខ្សាច់នេះ គេមិនមែនធ្វើតែក្នុងឱកាសចូលឆ្នាំប៉ុណ្ណោះ

(១) អានថា អាន់ណាំង លោកាំង សិណី

ទេ សូម្បីនៅក្នុងពិធីបុណ្យផ្សេងៗ ក៏គេនិយមធ្វើដែរ ព្រោះជឿថាជាការរំដោះកម្ម ពៀរវេរាដែលធ្វើអាក្រក់ កន្លងមក ។

*សេចក្តីសន្និដ្ឋាន :*

កាលបរិច្ឆេទ នៃការចូលឆ្នាំប្រពៃណីរបស់ប្រជាជាតិនានាក្នុងលោក តែងមានការប្រែប្រួលជាធម្មតា មិនថាឡើយតែពេលវេលាចូលឆ្នាំ របស់ប្រជាជនកម្ពុជាទេ ។ ពិធីនានាក្នុងឱកាសចូលឆ្នាំខ្មែរនោះ ក៏មានប្រការខ្លះមិនសមរម្យ រកកល់ទៅជារឿងភូតភរ គួរអោយពិបាកជឿកើត សំរាប់មនុស្សមានវិចារណញ្ញាណ ។ ប៉ុន្តែរឿងខ្លះ ក៏ជាប្រភពនៃការដឹកនាំមនុស្សអោយចេះសាមគ្គីគ្នា ស្រឡាញ់ រាប់អានគ្នា បំផុសលើកទឹកចិត្តមនុស្សអោយខិតខំបំពេញកុសលកម្ម លើកស្ទួយសង្គមជាតិ ឆ្ពោះទៅកាន់ភាពរឹងមាំ រីកចំរើនដែរ ។

កាលពីព្រេងនាយ ពិធីទាំងឡាយក្នុងឱកាសចូលឆ្នាំខ្មែរ សុទ្ធសឹងមានប្រភពភ្ជាប់មកពីលទ្ធិព្រាហ្មណ៍ ប៉ុន្តែចាប់ពីពេលដែលប្រជារាស្ត្រ ទទួលយកពុទ្ធ-សាសនា មកគោរពប្រតិបត្តិជំនួសសាសនាព្រាហ្មណ៍ ពិធីខាងដើមមួយចំនួន ក៏បានសម្របសម្រួលខ្លួនទៅតាមពិធីរបស់ពុទ្ធសាសនា ហើយក្រោយមក ក៏រលាយសាច់ឈាមផ្សិតចូលគ្នាគ្រប់អន្លើ ស្ទើរមើលពុំយល់ ហើយប្រការមួយចំនួនទៀត ដែលប្រាសចាកហេតុផលខ្លាំងពេក ក៏រលាយរសាយបាត់ធាតុពីបុណ្យចូលឆ្នាំប្រពៃណីខ្មែរក៏មាន ។

ទោះបីយ៉ាងណាក៏ដោយ បុណ្យចូលឆ្នាំនេះ ពិតជាកថាខ័ណ្ឌមួយសំខាន់ចាំបាច់បំផុត ក្នុងទំព័រជីវិតមនុស្សគ្រប់រូប គ្រប់ជាតិសាសន៍ ក៏ដូចជាខ្មែរគ្រប់រូបដែរ

សំរាប់ត្រួតពិនិត្យ វាយតំលៃសរុបលទ្ធផលការងារ បេសកកម្ម បទពិសោធន៍ដែលខ្លួនបានអនុវត្តកន្លងមកក្នុងរយៈពេលមួយឆ្នាំ ហើយប្រមើលមើលទៅក្រោយ ដកស្រង់យកចំណុចល្អៗ បន្តអនុវត្តអោយប្រាកដ និង ជោជ័យជាងទៀត នាឆ្នាំថ្មី ដ៏ក្បៀមក្សាន្ត ។

រៀបរៀងសង្ខេប ដោយ
ម៉ែន ប្រាង * អាំ ធន

# ពន្លឺកម្ពុជសុរិយា

* រស្មីសុរិយាដែលថាថ្លាថ្លៃ ភ្លឺបានតែថ្ងៃពេលយប់ងងឹត
កម្ពុជសុរិយាក្រៃណាមានឫទ្ធិ យប់ថ្ងៃឆ្ងាយជិតតែងតែភ្លឺថ្លា ។
* ច្រើនឆ្នាំកប់បាត់រសាត់កេរ្តិ៍ឈ្មោះ តែព្រលឹងរស់ជិតជាប់ខេមរា
ពេលនេះវិលវិញកាន់ពេញហាត្ថា កម្ពុជសុរិយាជាមិត្តឧត្តម ។
* ខ្ញុំសូមឱនកាយគោរពវន្ទា កម្មស្សសទ្ធាវិជ្ជាសន្សំ
ពុះពារឧបសគ្គស្មគ្រ្គមឧបត្ថម្ភ ថៃមិត្តឧត្តមលុះគ្រាអវសាន ។
* គ្រាន់ជាពំនឹងដល់ជនអន្ធការ អាចឥតប្រាជ្ញាអោយភ្លឺថ្លាបាន
ឆ្លងចតុរាបាយឈានដល់ត្រើយត្រាន ជាទ្រព្យចំណានចាយមិនចេះអស់ ។
* ក្រោមម្លប់ស្វេត្រឆត្រអង្គមហាក្សត្រា កម្ពុជសុរិយាប្ដេជ្ញាចិត្តស្មោះ
បំរើប្រជាពុំរាថយសោះ អោយខ្មែររំដោះពីគ្រោះអវិជ្ជា ។
* វិជ្ជាជាទ្រព្យប្រសើរថ្លាថ្លៃ ជាត្រីវិស័យបង្ហាញមាគ៌ា
អាណាចក្រពុទ្ធចក្រពឹងពាក់គ្រប់គ្រា អ្នកមានវិជ្ជាជាពេជ្ររចនា ។
* អាចជួយសាងជាតិឃ្លាតពីចោកទាប ឈានឡើងទៅភាពរុងរឿងថ្លៃថ្លា
ហេតុនេះខ្ញុំសូមស្មគ្រ្គមស្ដាបនា កម្ពុជសុរិយាស្ថិតស្ថេរអមតះ ៕

**ចណ្ណ ស៊ិនហេង**

# សុភាសិត

ជាតិខ្លឹមចន្ទទោះស្វិត ក្រៀមក្រញង់
មិនលះបង់ក្លិនក្លែប សុគន្ធា
ជាតិដីរីទោះចូល សឹកយុទ្ធនា
មិនលះបង់លេលា ល្បាយល្អងក្រាយ ។
ជាតិអំពៅទោះនៅ ក្នុងយន្តឃ្នាប
មិនលះបង់សភាព ជាតិផ្អែមសាយ
ជាតិបណ្ឌិតទោះមាន ទុក្ខក្នុងកាយ
មិនជិនណាយលះបង់ ព្រះធម៌ថ្លៃ ។
ពូជទាមិនដែលដេក លើទ្រនំ
ពូជសត្វរស់ព្រៃភ្នំ មិននៅស្រុកអាយ
ពូជបណ្ឌិតមិនស្ម័គ្រ ទុក្ខក្នុងកាយ
ពូជសត្វកុកមិនណាយ បោះបង់បឹង ។

ហៀន ចន្ទរ័ត្ន

* * *

# ស្តាយកេរចាស់

ស្តាយកេរបុរាណលោកខំសាង ទុកជាតំណាងវប្បធម៌ខ្មែរ
ឥឡូវរេចរឹលទៅហែៗ ព្រោះតែស្រុកទេសកើតចម្បាំង ។
កេរខ្លះវិនាសដោយធម្មជាតិ ដោយធាតុអាកាសប្រែប្រួលខ្លាំង
កេរខ្លះវិនាសព្រោះចោរខ្លាំង វាតាំងជីកគាស់កាយរំលើង ។
ស្តាយជនចិត្តចោរសោគំនិត ត្លុចគិតតែលួចតាមទំនើង
បាត់ជាតិបាត់សាសន៍ធ្វើមិនដឹង តេប្រឹងតែលួចលក់យកប្រាក់ ។
ស្តាយកេរដូនតាការខ្វះថែ យូរឆ្នាំយូរខែក្តៅត្រជាក់
នៅដោយកន្លែងគ្មានធ្មើថ្នាក់ ធូលីហុយដាក់គណ្ឌុរកាត់ ។
ស្តាយបាត់គតិប្រជាប្រិយ៍ ទំនៀមប្រពៃមានច្រើនក្តាត់
រស់រវៀងតំណាតតាមមាត់ ចាស់គាត់ចេះចាំតាមសំនួន ។
ឥឡូវចាស់ស្លាប់បាត់ស្ទើរអស់ យកទាំងរបស់ប្រចាំខ្លួន
ចំណេះចំណាំគ្មានក្នុងក្បួន ចាស់ចាំដោយខ្លួនមិនបានចារ ។
ស្តាយភ្លេចចំរៀងសៀងពិរោះ ស្តាយព្រោះរបាំល្បែងប្រជា
ក្មេងក្រោយមិនស្គាល់ទាល់ប្រាជ្ញា យកល្បែងពលោមកជំនួស ។
ស្តាយព្រៃព្រឹក្សាលតាវល្លិ ឈើល្អបុរាណបានដាក់ឈ្មោះ
ប្រភេទផ្សេងៗ គ្មានចន្លោះ ស្តាយបាត់ដើមអស់សល់តែនាម ។
ស្តាយឈើស្តាយព្រៃចាស់លោកដាំ ទុកជាដំណាំក្នុងអារាម
កាលមានចាស់នៅចាស់លោកហាម ពេលអត់ចាស់ភ្លាមក្មេងបានដៃ។
ស្តាយមិនបានដាំចាំតែកាប់ ស្តាយចាប់ច្រើនជាងចិញ្ចឹមត្រី
ទឹកសាបសមុទ្រមិនយូរថ្ងៃ គង់ក្ស័យផុតពូជមិនសល់ដាន ។

ឯត្បូងរតនៈមានតម្លៃ ក៏គង់មានថ្ងៃអន្តរធាន
ព្រៃក្លាយជាវាលរហោស្ថាន គួរខ្មែរគិតអានគ្រប់អាត្មា ។
អស់ព្រៃអស់សត្វបាត់ទាំងទឹក ខ្វះហូបល្ងាចព្រឹកខ្វះមច្ឆា
ព្រៃទន្លេស្ទឹងបឹងជលសា ប្រែជាវីងស្រកខកខានខែង ។
ស្តាយទ្រព្យវប្បធម៌ចាស់កសាង ទុកជាភស្តុតាងអោយជាក់ស្តែង
ជាគោលចារឹកប្រាប់ក្មេងៗ អោយស្គាល់កន្លែងដំណែលចាស់ ។
ឥឡូវបាត់អង្គបង់ទួលតាំង បាត់ប្រាង្គព្រះធាតុមានចំណាស់
ប្រាសាទតូចធំធានីចាស់ សល់ខ្លះខូចខ្លះខ្វះរមណីយ៍ ។
ស្តាយកេរ្តិ៍កាលណោះខ្ពស់ជាងមេឃ ឥឡូវចុនពេកទាបស្មើដី
ខ្មែរអើយគួរខ្មាសសាសន៍ដទៃ ហេតុអីមិនស្តាយកេរដូនតា ។
ស្តាយនៅក្នុងចិត្តដិតកង្វល់ ចម្ងល់ជាទុក្ខក្នុងឱរា
ស្តាយប្រាណប្រែចាស់ក្រាស់វស្សា រស់មិនបានការដូចបុរាណ ។
ស្តាយធ្វើមិនបានដូចបំណង ចិត្តប៉ងចង់ធ្វើធ្វើមិនបាន
ស្តាយកើតមកហើយរស់រំខាន រស់រួចតែប្រាណគ្មានកំណើត ។
នេះចាស់ស្តាយចាស់របស់ចាស់ ស្តាយណាស់ការកេរចាស់បង្កើត
ការក្មេងធ្វើតាមមិនសូវកើត ការនើតបាត់នោមក្នុងគ្រានេះ ។

**យី ធន់**

***

# ស្រណោះសំដី .... កវី អ៊ុំ ចុខ

" ខ្មាសគេប្រទេសលង្កា ឥណ្ឌា ភូមា គេមកមើលយើង ។
គួរយើងនាំគ្នាក្រោកឡើង តំកើងជាតិយើងអោយថ្កើងដូចគេ ។
ខិរិះ ខំរក ខំរេ អោយល្អដូចគេប្រទេសនានា ។
មួយទៀតយើងជាតិខេមរា ត្រូវខំសិក្សាទាំងក្មេងទាំងចាស់ ។
កុំដើរឡេឡូឡេសឡាស់ ត្រូវខំអោយណាស់ទាំងប្រុសទាំងស្រី ។
ស្រុកខ្មែរដែលមានរស្មី ខ្មែរមានសេរីអាស្រ័យខ្មែរដឹង ។
កុំថ្នូរចង់ធ្វូរខ្លាចតឹង លុះតែខ្មែរប្រឹងទើបខ្មែរសប្បាយ ។
ឯករាជ្យខ្មែរមិនរលាយ ជាតិខ្មែរមិនងាយជាតិណាត្រូតបាន ។
បើខ្មែរព្រមប្រឹងគ្រប់ប្រាណ ខ្មែរនឹងមានបានសម្បូរសម្បត្តិ ។
បើជាតិខ្មែររឹងម៉ឹងម៉ាត់ សុខសាន្តពេកក្កាត់ព្រោះកាត់ខ្ជិលចោល ។
សព្វថ្ងៃខ្មែរនៅតែលតោល ព្រោះនៅកំរោលមិនទាន់លុបជ្រុង ។
ដូចខ្សែមិនទាន់ចូលផ្លុង មិនចុះសំរុងមិនសាមគ្គីគ្នា ។
មិនទាន់ពេញជាអ្នកជា គួរយើងគ្រប់គ្នាកែគំនិតថ្មី ។
ចំណែកអស់លោកមន្ត្រី គួរចែកសេរីភាពរាស្ត្រខ្លះផង ។
កុំបីឆ្មើងឆ្មៃកន្លង នាំគ្នាសៅហ្មងរាស្ត្រក្តៅចិត្តស្អប់ " ។

( ច្បាប់ដំបូន្មានបព្វជិត គ្រហស្ថ )

ដកស្រង់ចេញពីទស្សនាវដ្តី មហាវិទ្យាល័យអក្សរសាស្ត្រ មនុស្សសាស្ត្រ
ឆ្នាំទី ៣ លេខ ១៥ ខែមករា ១៩៧៣

# កិច្ចប្រជុំការងារ ដើម្បីលើកកំពស់កិត្តិយស និង សេចក្តីថ្លៃថ្នូររបស់ពុទ្ធសាសនា

នាពាក់កណ្តាលឆ្នាំ ១៩៩៣ ក្រសួងធម្មការ និងសាសនា បាននិមន្ត មន្ត្រីសង្ឃជាន់ខ្ពស់ទាំងពីរគណៈ និងមន្ត្រីរាជការក្រោមឱវាទក្រសួងធម្មការ ពីគ្រប់ខេត្ត-ក្រុង មកជួបប្រជុំគ្នា ដើម្បីជម្រាបអំពីដំណើរប្រព្រឹត្តិទៅនៃក្រសួង ធម្មការនិងសាសនាផង និងពិគ្រោះពិភាក្សាគ្នាអំពីពុទ្ធសាសនា និងការប្រតិបត្តិ នាពេលបច្ចុប្បន្នផង ។

ក្នុងជំហានដំបូងនៃការជួបប្រជុំគ្នានេះ អង្គប្រជុំទាំងមូល បានផ្តោត ការយកចិត្តទុកដាក់ខ្ពស់ដល់ការពង្រឹងពង្រីកពុទ្ធសាសនាឡើងវិញ មានការ ណែនាំប្រតិបត្តិធម៌ និងវិន័យសាសនាអោយល្អសុក្រឹត ដោយចេញសារាចរ សេចក្តីណែនាំស្តីពីការបួស, ការត្រាច់ទៅកាន់ទីគោចរ-អគោចរ, ការហាម ឃាត់ចំពោះការរៃអង្គាស, សេចក្តីអំពាវនាវសុំអោយព្រះសង្ឃជួយប្រមូល និង រក្សាទុកនូវសម្បត្តិសាសនា និងសម្បត្តិវប្បធម៌ អោយគង់វង្ស ជាដើម ។

គណៈកម្មការទស្សនាវដ្តី " កម្ពុជសុរិយា " បានចុះផ្សាយអត្ថបទ ខាងលើនេះ សំរាប់អ្នកអានរបស់យើង ដោយយល់ថា អត្ថបទនេះ នឹងជួយ ផ្តល់មតិទាក់ទងគ្នាជិតស្និទ្ធចំពោះពុទ្ធសាសនា និងការប្រតិបត្តិ នាពេលបច្ចុប្បន្ន ដើម្បីធ្វើអោយពុទ្ធសាសនា រក្សាបានតម្លៃសីលធម៌ និងតួនាទីរបស់ខ្លួនក្នុង សង្គម ក្នុងភាពបរិសុទ្ធត្រឹមត្រូវ ម៉ត់ចត់តាមពុទ្ធប្បញ្ញត្តិ និងពុទ្ធានុញ្ញាត ព្រម ទាំងរក្សាបាននូវជំនឿរបស់ប្រជារាស្ត្រចំពោះពុទ្ធសាសនា និងរក្សាបាននូវ ឋានៈជាសាសនារបស់រដ្ឋ តរៀងទៅ ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធម្មការ និង កិច្ចការសាសនា

លេខ : ០៣.៩៣ / កធស

ភ្នំពេញ, ថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ១៩៩៣

## សារាចរ

ស្តីអំពីទីអគោចរ ( ទីដែលមិនគួរទៅ ) និងការ
ឃោសនារៃអង្គាសបច្ច័យនៅតាមទីកន្លែងសាធារណៈ

- អនុលោមតាមស្មារតីនៃសេចក្តីព្រមព្រៀង របស់អនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃលើកទី១ ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃ ១៥ មីនា ១៩៩២ និងអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃលើកទី២ កាលពីថ្ងៃ ៦ មីនា ១៩៩៣,

- ដោយបានសង្កេតឃើញថា មានបព្វជិតរូបខ្លះ បាននិមន្តទៅកាន់ទីដែលជាអគោចរដ្ឋាន ពុំគួរគប្បីនឹងត្រាច់ចរទៅមក និងម្យ៉ាងទៀត មានព្រះសង្ឃខ្លះ អាចារ្យវត្តខ្លះ និងពុទ្ធបរិស័ទខ្លះ បាននាំគ្នាដង្ហែក្បួនធ្វើការឃោសនា ដោយប្រើឧគ្ឃោសនស័ព្ទរៃអង្គាសបច្ច័យ នៅតាមដងផ្លូវនៅក្នុងរាជធានី ទីក្រុង និងទីប្រជុំជន ធ្វើឱ្យប៉ះពាល់ដល់ពុទ្ធប្បញ្ញត្តិ និងពុទ្ធានុញ្ញាត ព្រមទាំងប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណសង្គម និងដល់កិត្តិយស សេចក្តីថ្លៃថ្នូររបស់ព្រះពុទ្ធសាសនា,

- ដើម្បីបង្កើនជំនឿ សេចក្តីទុកចិត្ត និងសេចក្តីគោរពជ្រះថ្លារបស់ប្រជារាស្ត្រ ចំពោះពុទ្ធសាសនា និងលើកតម្កើងកិត្តិយសព្រះពុទ្ធសាសនាអោយសមឋានៈជាសាសនារបស់រដ្ឋ ,

រដ្ឋមន្ត្រីក្រសួងធម្មការ និងកិច្ចការសាសនា សូមពិតពុទ្ធដីកាព្រះមេគណ គ្រប់ខេត្ត ក្រុង, ព្រះអនុគណគ្រប់ស្រុក ខ័ណ្ឌ ព្រះចៅអធិការគ្រប់វត្ត និងជំរាបមកលោកនាយកមន្ទីរធម្មការ និង កិច្ចការសាសនា គ្រប់ខេត្ត-ក្រុង សូមព្រះមេត្តាជួយ និងជួយ ៖

១- ណែនាំភិក្ខុ-សាមណេរ នៅក្រោមឱវាទ កុំអោយនិមន្តទៅបិណ្ឌបាត ឬត្រាច់ចរទៅមកកាន់ទីដែលបព្វជិតមិនគួរគប្បីនិមន្តទៅ មានអគោចរដ្ឋាន ៦ យ៉ាង ជាអាទិ៍គឺ លំនៅឋានរបស់ស្រីពេស្យា, ផ្ទះលក់សុរា ជាកន្លែងមិនគួរត្រាច់ចរទៅ ព្រមទាំងទីកន្លែងផ្សេងៗទៀត ដូចជាទីប្រជុំជនដែលមានមនុស្សប្រុស-ស្រីទៅមកឈូឆរ ពពាក់ពពូន ណែនណាន់តាន់តាប់ ដូចយ៉ាង ៖

- ទីផ្សារ រានលក់គ្រឿងបរិភោគ-ឧបភោគ, រានលក់សាច់-ត្រី-បន្លែបង្ការ,
- ហាងលក់ទំនិញផ្សេងៗ,
- សណ្ឋាគារ-ភោជនីយដ្ឋាន,
- តាមក្រសួង-មន្ទីររបស់រដ្ឋ . ល .

ព្រោះការនិមន្តត្រាច់ចរទៅកាន់កន្លែងទាំងប៉ុន្មានខាងលើនេះ នាំអោយពុទ្ធបរិស័ទអ្នកមានសេចក្តីជ្រះថ្លាគោរពចំពោះព្រះពុទ្ធសាសនា កើតមន្ទិលសង្ស័យរង្កៀសចិត្ត ឬនាំអោយអ្នកដែលមិនទាន់មានសេចក្តីជ្រះថ្លា រិះគន់តិះដៀលបាន ។ ហេតុនេះ ទីកន្លែងខាងលើនេះ មិនអនុញ្ញាតអោយបព្វជិតត្រាច់ចរទៅកាន់ឡើយ វៀរលែងតែមានការចាំបាច់ ដែលឃើញថាជាការខានមិនបាន ឬ ដោយមានការអារាធនានិមន្ត ទើបអាចនិមន្តទៅបាន មួយដងមួយកាល ។

២- ណែនាំភិក្ខុ-សាមណេរ ដែលនិមន្តចេញពីទីអាវាសវត្ត ត្រូវអោយ ៖

ក- យកជាប់ជាមួយនូវឆាយា ឬសង្ឃដីកា ជានិច្ច,

ខ- ឃ្លុំចីពរឱ្យបានរៀបរយ មានបរិមណ្ឌលសមរម្យជាអ្នកបួស ចៀស

វាងការស្ពាយ ឬ យួរសំពីងសំពោង និង ការប្រើវ៉ែនតាពណ៌ខ្មៅ ដែលមិនជាការ ជាការចាំបាច់ ។

៣. ណែនាំភិក្ខុ - សាមណេរ កុំអោយប្រើប្រាស់ឧបករណ៍ ឬសម្ភារៈមិនចាំបាច់ សម្រាប់ព្រះសង្ឃ ដូចជា : ម៉ាស៊ីនថតរូប, ម៉ាស៊ីនថតវីដេអូ, វិទ្យុ, ម៉ាស៊ីនថតសំឡេង, យួរកាពាប ជាដើម ។

៤. ណែនាំ និងហាមប្រាមដាច់ខាត ចំពោះភិក្ខុ-សាមណេរ អាចារ្យវត្ត កុំអោយធ្វើការរៃអង្គាសគ្រប់រូបភាព ដោយស្ពាក់ចរាចរតាមផ្លូវសាធារណៈ ឬដោយយកព្រះពុទ្ធបដិមាចងក្រៀកដាក់លើរទេះរុញសហែជាក្រុម ឬជាក្បួន មានឧគ្ឃោសនស័ព្ទ ភ្លេង របាំ ទីងមោង តគ្រឹកគគ្រេងនៅតាមទីក្រុង-ទីប្រជុំជន និងតាមដងផ្លូវសាធារណៈ តទៅទៀត ។

ទទួលបានសារាចរនេះ សូមព្រះតេជព្រះគុណមេគណ អនុគណ ចៅ-អធិការ លោកអាចារ្យវត្ត និងលោកនាយកមន្ទីរធម្មការខេត្ត-ក្រុង ផ្សព្វផ្សាយ និងណែនាំអោយអនុវត្តតាមភារកិច្ចរបស់ព្រះតេជព្រះគុណគ្រប់ព្រះអង្គ និងរបស់លោកនាយកមន្ទីរធម្មការខេត្ត-ក្រុង រៀងៗខ្លួន ។

បានឃើញ និងយល់ព្រម

វត្តឧណ្ណាលោម, ថ្ងៃទី ៩ ខែកញ្ញា ១៩៩៣

សម្តេចព្រះមហាសុមេធាធិបតី

ព្រះសង្ឃរាជគណៈមហានិកាយ នៃកម្ពុជា,

ព្រះហស្តលេខា និងត្រា

**ទេព វង្ស**

រដ្ឋមន្ត្រីក្រសួងធម្មការនិងកិច្ចការសាសនា

ហត្ថលេខា និងត្រា

**ឈឹម សៀកឡេង**

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងធម្មការ និង សាសនា**

លេខ : ០៣_៩៣ / កធស

ថ្ងៃទី ៩ ខែកញ្ញា ឆ្នាំ ១៩៩៣

## សារាចរ

### ស្តីពីការបួសក្នុងពុទ្ធសាសនា

- ដោយអនុលោមតាមស្មារតី នៃអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃ លើកទី២ កាលពីថ្ងៃទី៦ ខែមីនា ឆ្នាំ១៩៩៣ ពាក់ព័ន្ធនឹងការប្រឹងប្រែងធ្វើឱ្យការគោរពប្រតិបត្តិពុទ្ធសាសនា កាន់តែមានសុក្រឹតភាពតាមពុទ្ធប្បញ្ញត្តិ និងពុទ្ធានុញ្ញាត,
- ដោយបានកត់សម្គាល់ឃើញបាតុភាពខុសឆ្គង កាន់តែរីកដាលក្នុងការបួស បណ្តាលឱ្យប៉ះពាល់ដល់ការសាងផ្នួសត្រឹមត្រូវតាមពុទ្ធប្បញ្ញត្តិ និងពុទ្ធានុញ្ញាត,
- ក្នុងស្មារតីថែរក្សាប្រពៃណីដ៏ល្អនៃការបួសក្នុងពុទ្ធសាសនា ហើយបំបាត់ឱ្យអស់នូវភាពខុសឆ្គង បណ្តាលមកពីការមិនយល់ ឬការបំពានលើការបួស,

រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា សូមពិតពុទ្ធដីកាព្រះអង្គមេគណអនុគណ ចៅអធិការគ្រប់ខេត្ត_ក្រុង_ស្រុក_ឃុំ_សង្កាត់ និងសូមជំរាបលោកនាយកមន្ទីរធម្មការគ្រប់ខេត្ត_ក្រុង និងការិយាល័យធម្មការគ្រប់ស្រុក_សង្កាត់ទូទាំងប្រទេសថា: ការបួសក្នុងព្រះពុទ្ធសាសនា គឺជាបញ្ញត្តិកម្ម ពោលគឺ ការបួសត្រូវប្រព្រឹត្តទៅឱ្យបានត្រឹមត្រូវតាមក្រឹត្យក្រមនៃពុទ្ធប្បញ្ញត្តិ និង ពុទ្ធានុញ្ញាត ។ តាម

ន័យនេះ កុលបុត្រដែលពុំមែនជាអភព្វបុគ្គល ហើយមានបំណងចង់បួស ដោយមានវ័យសមស្របផងនោះ អាចចូលមកសុំសាងផ្នួសក្នុងពុទ្ធសាសនាបាន ប៉ុន្តែបន្ថែមពីលើនេះ ដើម្បីធានាលក្ខណៈត្រឹមត្រូវតាមច្បាប់រដ្ឋ កុលបុត្រអ្នកប្រាថ្នាសាងផ្នួស ត្រូវបំពេញលក្ខខ័ណ្ឌ ដូចខាងក្រោមនេះ :

- ត្រូវមានប្រវត្តិរូបច្បាស់លាស់ ដែលត្រូវបានមន្ត្រីថ្នាក់ឃុំ - សង្កាត់ ដែលខ្លួនស្នាក់នៅ បញ្ជាក់ថាត្រឹមត្រូវ,
- ត្រូវចេះចាំច្បាស់លាស់នូវវិធីសុំផ្នួស និងបច្ចវេក្ខណវិធី៤យ៉ាងជាមុន,
- ត្រូវមានបដិញ្ញាណ ចេញឱ្យដោយមន្ត្រីថ្នាក់ឃុំ-សង្កាត់ ដែលខ្លួនរស់នៅ ក្រោយពេលបានដេញដោយផ្ទាល់មាត់ ត្រួតពិនិត្យមើលការយល់ដឹង ចេះចាំវិធីសុំផ្នួស "បព្វជ្ជាវិធី និងបច្ចវេក្ខណវិធី ៤ យ៉ាង" រួចមកហើយ ។

ជាមួយនេះ ក្រសួងធម្មការ និងកិច្ចការសាសនា សូមគួសបញ្ជាក់ប្រគេនជ្រាប និងជូនជ្រាបថា ការបួសមុខភ្លើង ឬការបួសលាបំណន់ ដែលជាការនិយមជាប់ជាប្រពៃណីរបស់ប្រទេសយើង គឺជាការបួសដោយចេតនាកម្ម ។ ផ្នួសបែបនេះ មិនត្រូវឱ្យបំពេញលក្ខខ័ណ្ឌ ដូចបានកំណត់ខាងលើនេះទេ ។ ដោយហេតុនេះ ឧបជ្ឈាយ៍ពុំចាំបាច់ចេញឆាយាទទួលស្គាល់បព្វជិតភាពឱ្យកុលបុត្រនោះទេ ។

កុលបុត្រដែលទទួលបួសមុខភ្លើង អាចតាំងនៅក្នុងផ្នួសបានយ៉ាងយូរ ២៤ ម៉ោង ។ កុលបុត្រដែលទទួលផ្នួសលាបំណន់ អាចឋិតនៅក្នុងផ្នួសបានយ៉ាងយូរចំនួន ៧ ថ្ងៃ ។ ហាមឃាត់ដាច់ខាត មិនឱ្យកុលបុត្រទទួលផ្នួសដោយចេតនាកម្មទាំងពីរបែបខាងលើ បន្តយកភេទជាបព្វជិតលើសពេលខាងលើនេះបានឡើយ ។

ភ្ជាប់ទៅនឹងការបួសនេះដែរ ភិក្ខុដែលមានវស្សាយ៉ាងតិច ត្រឹម១០

ហើយចេះធម៌វិន័យល្មមដល់ឋានៈជាឧបជ្ឈាយ៍ ទើបធ្វើជាឧបជ្ឈាយ៍បាន ។

សារាចរ សេចក្តីណែនាំ ឬបទបញ្ញត្តិទាំងឡាយពីមុនស្តីពីការបួស ដែលផ្ទុយពីសារាចរស្តីពីការបួសក្នុងពុទ្ធសាសនានេះ ត្រូវទុកជានិរាករណ៍ ។

សារាចរស្តីពីការបួសក្នុងពុទ្ធសាសនានេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

បានឃើញ និងយល់ព្រម

វត្តឧណ្ណាលោម, ថ្ងៃទី ៩ ខែកញ្ញា ឆ្នាំ១៩៩៣

សម្តេចព្រះសុមេធាធិបតី

ព្រះសង្ឃរាជគណៈមហានិកាយនៃកម្ពុជា,

ព្រះហស្តលេខា និងត្រា

**ទេព - វង្ស**

រដ្ឋមន្ត្រីក្រសួងធម្មការ និងកិច្ចការសាសនា,

ហត្ថលេខា និង ត្រា

**ឈឹម សៀកឡេង**

# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធម្មការ និង កិច្ចការសាសនា
លេខ ០៣ . ៩៣/កធស

ភ្នំពេញ, ថ្ងៃទី ៩ ខែកញ្ញា ឆ្នាំ ១៩៩៣

រដ្ឋមន្ត្រីក្រសួងធម្មការ និងកិច្ចការសាសនា
សូមពិតពុទ្ធដីកា

ព្រះតេជព្រះគុណមេគណ អនុគណ និងចៅអធិការគ្រប់វត្ត ក្នុងទូទាំងប្រទេស

**កម្មវត្ថុ** : ការប្រមូល និងថែរក្សាទុកនូវវត្ថុបុរាណ ដែលជាបេតិកភ័ណ្ឌជាតិ ខាងវប្បធម៌ សិល្បៈ និងសាសនា ។

**យោង** : សេចក្ដីសំរេចចិត្តរបស់អនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃលើកទី១ ថ្ងៃទី ១៦-០៣-១៩៩២ ។

ដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំព្រះករុណា ខ្ញុំ មានកិត្តិយស សូមពិតពុទ្ធដីកាព្រះអង្គមេគណ អនុគណ និងចៅអធិការគ្រប់វត្ត គ្រប់ព្រះអង្គថា តាំងពីបុរាណកាលរៀងមក វត្តអារាមរបស់យើង ក្រៅពីជាទីសក្ការៈដែលប្រជារាស្ត្រខ្មែរគោរពបូជា, ក៏ជាឃ្លាំងបេតិកភ័ណ្ឌវប្បធម៌ និងសិល្បៈជាតិ ជាសារមន្ទីរ ជាបណ្ណាល័យដែលរក្សាទុកនូវវត្ថុបុរាណ និងស្នាដៃអក្សរសាស្ត្រខ្មែរ និងអក្សរសិល្ប៍សាសនា មានគម្ពីរ ដីកា សាស្ត្រា ក្រាំង និងក្បួនខ្នាតផ្សេងៗ ដែលជាព្រលឹងរបស់ជាតិផងដែរ ។

ឯកសារដ៏មានតម្លៃមិនអាចកាត់ថ្លៃទាំងនោះ ត្រូវបានបំផ្លិចបំផ្លាញអោយវិនាសស្ទើរតែទាំងអស់ ក្នុងអំឡុងពីឆ្នាំ ១៩៧០ ដល់ ១៩៧៨ ។ មកដល់បច្ចុប្បន្ននេះ ទោះបីវត្តអារាមស្ទើរតែទាំងអស់ ត្រូវបានជួសជុល សាងសង់ឡើងវិញថ្មីក៏ដោយ ក៏បេតិកភ័ណ្ឌខាងសិល្បៈ វប្បធម៌ និងសាសនា ដែលបាត់បង់ទៅនោះមិនអាចទាន់ប្រមូលផ្តុំ ចងក្រងឡើងវិញបានឡើយ ហើយប្រការដែលគួរឱ្យព្រួយបារម្ភជាងគេនោះ គឺការបាត់បង់ឯកសាររបស់ពុទ្ធសាសនា ដែលជាការបាត់បង់មួយមិនអាចជួសជុលវិញបាន ។

អាស្រ័យហេតុនេះ ខ្ញុំព្រះករុណា ខ្ញុំ សូមព្រះតេជព្រះគុណគ្រប់ព្រះអង្គមេត្តាជួយប្រមែប្រមូល និងរក្សាទុកនូវឯកសារ និងស្នាដៃបូរាណ ដែលមានលក្ខណៈសិល្បៈ ដូចជា បំណាក់បាក់បែកនៃសំណង់ កុដិ ព្រះវិហារ ដែលមានក្បាច់ ចម្លាក់ ឬមានលំអដោយគំនូរវិចិត្រកម្ម ព្រមទាំងវត្ថុបូរាណដែលគេប្រើប្រាស់ក្នុងពិធីសាសនា នៅក្នុងវត្តអារាម ដូចជា ផ្តិល-ពាន-គោក-តុ-ទូ-ថាស និងបដិមាដែលសាងអំពីឈើ-ស្ពាន់-ថ្ម និងឯកសារ ក្បួនខ្នាត មានគម្ពីរ ដីកា សាស្ត្រា ក្រាំង ដែលមាននៅតាមទីវត្ត និងកន្លែងផ្សេងទៀត ដែលអាចបិណ្ឌបាតប្រមូលបាន ដើម្បីរក្សាទុកជាកេរដំណែលរបស់ជាតិ តាមលំអានដែលបុព្វបុរសយើងធ្លាប់បានធ្វើពីបូរាណកាលរៀងមក ។

ក្នុងករណីដែលជួបការលំបាកដោយប្រការណាមួយនោះ សូមព្រះតេជព្រះគុណ មេត្តាផ្តល់ដំណឹងទៅក្រសួង ដើម្បីក្រសួងរិះរកវិធានការជួយសំរួលដោះស្រាយ ។

រដ្ឋមន្ត្រីក្រសួងធម្មការ និង កិច្ចការសាសនា

ហត្ថលេខា និង ត្រា

**ឈឹម សៀកឡេង**

## ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងធម្មការ និង កិច្ចការសាសនា**

លេខ ០៣-៩៣/កធស

# សេចក្ដីអំពាវនាវ

សុំខ្ចីសៀវភៅ ឯកសារ សាស្ត្រា គម្ពីរ
ដែលបោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ

ពុទ្ធសាសនបណ្ឌិត្យ ជាស្ថាប័នមួយរបស់ក្រសួងធម្មការ និងកិច្ចការសាសនា មានភារកិច្ចស្រាវជ្រាវ ចងក្រង ប្រមូលផ្ដុំ រក្សាទុក និងបោះពុម្ពផ្សាយនូវឯកសារ សៀវភៅ គម្ពីរ ដីកាទាំងឡាយ សំដៅពង្រីកចំណេះដឹងរបស់ប្រជារាស្ត្រទូទាំងប្រទេស ទាំងផ្នែកផ្លូវលោក ទាំងផ្នែកផ្លូវសាសនា និងជាពិសេសផ្នែកវប្បធម៌ អក្សរសាស្ត្រ សិល្បៈ ទំនៀមទម្លាប់ ប្រពៃណីជាតិ ។

គួរគប្បីរំលឹកឡើងវិញថា ពុទ្ធសាសនបណ្ឌិត្យកើតឡើងនៅក្នុងឆ្នាំ ១៩៣០ ដែលដំបូងឡើងគឺ នៅក្នុងឆ្នាំ ១៩២១ ជាបណ្ណាល័យជាតិ រួចក្រោយមកប្ដូរឈ្មោះជាព្រះរាជបណ្ណាល័យកម្ពុជា តាមព្រះរាជប្រកាសលេខ ០២ ចុះថ្ងៃទី១៥ មករា ឆ្នាំ១៩២៥ ។ ចាប់តាំងពីពេលនោះ មកដល់ឆ្នាំ១៩៧០ ពុទ្ធសាសនបណ្ឌិត្យបានប្រមូលផ្ដុំឯកសារ ចងក្រង និងបោះពុម្ពផ្សាយសៀវភៅ ស្ដីអំពីសិល្បៈ វប្បធម៌ អក្សរសាស្ត្រ ទំនៀមទម្លាប់ ព្រមទាំងក្បួនក្បាច់ គម្ពីរ ដីកាខាងពុទ្ធសាសនា

ជាភាសាខ្មែរ និង ភាសាបរទេសជាច្រើនម៉ឺនក្បាល ហើយបានក្លាយជាវិជ្ជាស្ថានរបស់ជាតិ ដែលមានពនាមល្បីល្បាញ ដោយសារសៀវភៅ-ឯកសារដែលខ្លួនមានយ៉ាងសម្បូរបែប ។

ប៉ុន្តែ ក្នុងរយៈពេលជាង ២០ ឆ្នាំកន្លងទៅ ប្រទេសកម្ពុជា ត្រូវទទួលរងមហន្តរាយដោយសង្គ្រាម ពុទ្ធសាសនបណ្ឌិត្យរបស់យើង ត្រូវបានបំផ្លាញទាំងស្រុង ក្នុងអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ។ សៀវភៅ ក្បួនច្បាប់ គម្ពីរ ដីកា ដែលមាននៅក្នុងបណ្ណាល័យទាំងអស់ ត្រូវបានគេរើកកាយ និងកំទេចចោលគ្មានសល់ ។ ចំណែកឯអ្នកប្រាជ្ញ កវី-បណ្ឌិតខ្មែរ ទាំងព្រះសង្ឃ ទាំងគ្រហស្ថស្ទើរតែទាំងអស់ ក៏ត្រូវគេធ្វើគត និងសម្លាប់ដែរ ។ ការបាត់បង់សៀវភៅ ឯកសារ គម្ពីរ ដីកា ជាពិសេស ឯកសារដែលបានចងក្រង ហើយមិនទាន់បានបោះពុម្ព និងអ្នកប្រាជ្ញ បណ្ឌិតខាងលើនេះ ជាការបាត់បង់ខាងបញ្ញាស្មារតី និងខាងព្រលឹងជាតិមួយផ្នែក ដែលនិងមិនងាយរកឃើញវិញបានទេ ។

បច្ចុប្បន្ននេះ ពុទ្ធសាសនបណ្ឌិត្យនៃប្រទេសកម្ពុជាយើង បានចាប់បដិសន្ធិឡើងវិញ ហើយកំពុងបោះជំហានទៅមុខជាបណ្តើរៗហើយ ប៉ុន្តែកំពុងជួបប្រទះការលំបាកជាច្រើន ដូចជា ៖

- ការប្រមូលឯកសារ ដែលសេសសល់ពីការបំផ្លិចបំផ្លាញ បានយ៉ាងតិចតួចស្តួចស្តើងបំផុត ។

- កង្វះខាតខាងសម្ភារៈ ថវិកា សំរាប់ចំណាយលើការបោះពុម្ព និងការកសាង រៀបចំបណ្ណាល័យ និងអគារអោយបានសមរម្យឡើងវិញ ។

- កង្វះអ្នកមានសមត្ថភាពគ្រប់ជំនាញ . ល . ។

តែទោះបីយ៉ាងណា ក៏ពុទ្ធសាសនបណ្ឌិត្យ បានខិតខំពុះពារគ្រប់ឧបសគ្គ ដោយបានទទួលការឧបត្ថម្ភពីក្រសួងធម្មការ និង កិច្ចការសាសនា និងពីអង្គការ

មនុស្សធម៌ខ្លះផង ដើម្បីបោះពុម្ពផ្សាយឡើងវិញនូវសៀវភៅខ្លះ ដែលចាំបាច់ចំពោះមុខ សំរាប់បំរើពុទ្ធិកសិក្សា និង ការប្រតិបត្តិក្នុងពុទ្ធសាសនា និង សំរាប់បំរើការស្រាវជ្រាវខាងវប្បធម៌ អក្សរសាស្ត្រ ប្រពៃណីជាតិខ្លះផង ។

ក្នុងចំណោមភារកិច្ចចម្បងៗរបស់ពុទ្ធសាសនបណ្ឌិត្យ ទន្ទឹមនឹងការបោះពុម្ពផ្សាយឡើងវិញ មានការបន្តស្រាវជ្រាវរកឯកសារ សៀវភៅ គម្ពីរចាស់ៗ ដែលបោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យពីមុនមក ដូចជា ៖

- សាស្ត្រា ក្បួនច្បាប់ គម្ពីរ ដីកា អដ្ឋកថា ខាងពុទ្ធសាសនា និងសៀវ-ភៅស្តីអំពីសិល្បៈ វប្បធម៌ អក្សរសាស្ត្រ និងវិជ្ជាដទៃទៀតរបស់ជាតិ ព្រមទាំងសំណៅដើមនៃឯកសារស្រាវជ្រាវអំពីប្រពៃណី ទំនៀមទម្លាប់ខ្មែរ ដែលមិនទាន់បានបោះពុម្ពផ្សាយជាភាសាខ្មែរក្តី ដើម្បីយកមកធ្វើការបោះពុម្ពផ្សាយទាំងអស់ឡើងវិញ ។

ប៉ុន្តែ ការបោះពុម្ពផ្សាយឡើងវិញ នឹងអាចធ្វើទៅបានឆាប់ អាស្រ័យទៅលើការប្រមូលឯកសារទាំងឡាយនោះ បានសព្វគ្រប់ដែរ ។

ហេតុនេះ ដើម្បីជួយជំរុញការកសាងពុទ្ធសាសនបណ្ឌិត្យឡើងវិញអោយបានសម្រេចតាមគោលបំណង និងសំណូមពររបស់សាធារណជន ពិសេសសំណូមពរចំពោះមុខខាងសៀវភៅ ឯកសារ សម្រាប់ប្រើក្នុងពុទ្ធិកសិក្សា និងការសិក្សាទូទៅ ក្រសួងធម្មការ និងកិច្ចការសាសនា សូមធ្វើការអំពាវនាវចំពោះ ៖

- ឯកឧត្តម អស់លោក លោកស្រី,
- ព្រះតេជព្រះគុណមេគណ អនុគណ ចៅអធិការវត្ត, ព្រមទាំង
- ពុទ្ធបរិស័ទទាំងអស់ក្នុងទូទាំងប្រទេស ដែលមានសៀវភៅ ឯកសារ គម្ពីរ ដីកា និងស្នាដៃអក្សរសាស្ត្រ សិល្បៈ ព្រមទាំងសៀវភៅទាក់ទងនឹងវិជ្ជាផ្សេងៗទៀត ដូចបានរៀបរាប់ខាងលើ ដែលជាស្នាដៃបោះពុម្ពផ្សាយដោយពុទ្ធ-

សាសនបណ្ឌិត្យពីអតីតកាលក្តី សាស្ត្រាស្លឹករឹត ក្បួនតម្រា និងឯកសារផ្សេងៗទៀតដែលមិនទាន់បោះពុម្ពក្តី សូមព្រះម្រត្តា សូមមេត្តាអនុញ្ញាតអោយពុទ្ធ-សាសនបណ្ឌិត្យបានខ្ចីចម្លង ឬ ផ្តល់ពត៌មានអំពីឈ្មោះសៀវភៅ ឯកសារនោះ ឬធ្វើអំណោយដល់ពុទ្ធសាសនបណ្ឌិត្យ នូវសៀវភៅ ឯកសារណា ដែលឯកឧត្តម អស់លោក លោកស្រី ព្រះតេជព្រះគុណមានសទ្ធាជ្រះថ្លា ដើម្បីតម្កល់ទុកជាសម្បត្តិរបស់ជាតិ តទៅ ។

ក្រសួងធម្មការ និងកិច្ចការសាសនា នឹងចារឹកនាមរបស់ព្រះតេជព្រះ-គុណ ឯកឧត្តម អស់លោក លោកស្រី និងឈ្មោះសៀវភៅ ឯកសារទាំងនោះទុកក្នុងក្រាំងមាសរបស់ក្រសួង ទុកអោយកុលបុត្រ កុលធីតាខ្មែរជំនាន់ក្រោយបានស្តាប់ បានដឹង បានរៀនសូត្រតាម ។

ក្នុងនាមក្រសួងធម្មការ និងកិច្ចការសាសនា ខ្ញុំព្រះករុណា ខ្ញុំ សូមសម្តែងនូវក្តីសង្ឃឹម ប្រកបដោយជំនឿជឿជាក់យ៉ាងមាំទៅលើសន្តានចិត្ត ដ៏សប្បុរស និងសទ្ធាជ្រះថ្លារបស់ព្រះតេជព្រះគុណគ្រប់ព្រះអង្គ របស់ឯកឧត្តម អស់លោក លោកស្រីគ្រប់រូប ក្នុងការជួយឧបត្ថម្ភគាំទ្រនឹងសេចក្តីអំពាវនាវនេះ ។

ភ្នំពេញ, ថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ ១៩៩៣

រដ្ឋមន្ត្រីក្រសួងធម្មការ និង កិច្ចការសាសនា

ហត្ថលេខា និង ត្រា

**ឈឹម សៀកឡេង**

# សេចក្ដីអំពាវនាវ
# ចំពោះជនរួមជាតិកម្ពុជា

ព្រះរាជាណាចក្រកម្ពុជា ត្រូវបានបាត់បង់ស្ទើរអស់រលីងសត្វព្រៃ និងជម្រករបស់វា ក្នុងរយៈកាលជាងពីរទសវត្សនៃសង្គ្រាមអូសបន្លាយរហូតដល់សព្វថ្ងៃនេះ ។ ជារៀងរាល់ថ្ងៃ សត្វព្រៃដ៏ល្អៗ ប្រកបដោយសោភណភាព និងសមធមិនោះ ត្រូវបានបំផ្លាញឥតឈប់ឈរ ។

ឈ្មួញរកស៊ីជួញប្រែសត្វព្រៃ និងប្រជាជនមួយចំនួនតូច ទាក់សត្វព្រៃ បាញ់សត្វ បំពុលសត្វ ដោយប្រើប្រាស់មធ្យោបាយដែលគេធ្វើបាននោះ មានភាពអនាធិបតេយ្យគួរអោយចាប់អារម្មណ៍ ។ ជនប្រដាប់អាវុធ និង មធ្យោបាយសម្លាប់សត្វព្រៃដោយខ្វះមេត្តាធម៌ និងពុំបានយល់ពីសារសំខាន់ និងផលប្រយោជន៍ដែលជាធម្មជាតិផ្ដល់អោយ សំរាបវិស័យទេសចរណ៍ ដែលជាផ្នែកមួយនៃសេដ្ឋកិច្ចជាតិនោះ គួរតែឈប់ប្រព្រឹត្តអំពើនេះតទៅទៀត ដើម្បីទុកអោយសត្វទាំងនោះបន្តពូជអោយបានច្រើនឡើងៗ ។

គោព្រៃ Bos sauveli



ខ្ទិង Bos gaurus



ប្រើស Rusa unicolor



សូមបងប្អូនទាំងអស់ រួមសហការគ្នាជាមួយរដ្ឋាភិបាល ដើម្បីបំបាត់នូវអំពើល្មើសច្បាប់ក្នុងការគំរាមកំហែងដល់សត្វព្រៃ ។

ដូចបងប្អូនបានជ្រាបស្រាប់ហើយថា សត្វព្រៃមានច្រើនប្រភេទ គឺមានសត្វចិញ្ចឹមកូនដោយទឹកដោះ សត្វវារ សត្វល្មូន និងបក្សាបក្សីខ្លះរស់នៅក្នុងព្រៃ ដីគោក ខ្លះទៀតរស់នៅក្នុងព្រៃលិចទឹក ទាំងនេះហៅថាជីវសាស្ត្រចំរុះ ដែលបងប្អូនទាំងអស់គ្នា មានកាតព្វកិច្ចការពារអោយបានគង់វង្ស ដោយធានាសុវត្ថិភាព ដល់ពពួកសត្វទាំងនេះផង ។ បើសត្វទាំងនេះវិនាសអស់ទៅ កូនចៅជំនាន់ក្រោយ ត្រូវស្តីបន្ទោសយើង ។

កាលពីជំនាន់ដើម យើងឃើញសត្វទន្សោង គោព្រៃ ដំរី ខ្លា ប្រើស រមាំង ក្ដាន់ ឈ្លូស ពស់ថ្លាន់ ពស់វែក អណ្តើក កន្ធាយ ក្រៀល ទុង ក្រសារ កុក ... គ្រប់ប្រភេទ ដើរហើរទាំងហ្វូងៗ គួរអោយគយគន់ ។ ប៉ុន្តែ



ក្រៀល Grus antigone



កុក Egretta intermedia



សារិកាកែវ
Acridotheres javanicus



លលក
Streptopelia chinensis

ឥឡូវនេះ ពពួកសត្វទាំងអស់នោះបានផុតពូជ ខ្លះទៀតនៅសល់តិចតួចបំផុត និងទទួលនូវគ្រោះថ្នាក់ឈានទៅរកការបាត់បង់ទាំងស្រុង ។ យើងពុំបានរៀបរាប់អោយបានអស់ទេ អំពីសារសំខាន់ នៃសត្វ ព្រៃទាំងនោះ ។ ជាឧទាហរណ៍ : ដំរី បានជួយបងប្អូនព្រៃភ្នំក្រំថ្មជាយានជំនិះ ជាមធ្យោបាយអូសទាញដោយពុំបណ្តាលអោយខូចខាតដំណុះឈើឡើយ ។ រីឯពស់ថ្លាន់ ខ្លែង ស្ទាំងចាប់កណ្តុរ ហើយបក្សាបក្សីចាប់សត្វល្អិតជាអាហារ មិនអោយបំផ្លាញដំណាំស្រូវ ។

ដូចនេះ ប្រភេទសត្វព្រៃទាំងនោះ មានប្រយោជន៍ដល់សេដ្ឋកិច្ចជាតិដែលមិនអាចកាត់ថ្លៃបានឡើយ ។

សូមបងប្អូនឈ្នួញគ្រប់ជាតិសាសន៍ឈប់ទិញសត្វព្រៃ ហើយយើងប្តេជ្ញាការពារវាអោយមានសុវត្ថិភាព និងការរីកចំរើន ។

សូមអរគុណ

# កំណាព្យប្រស្នា

កម្ពុជសុរិយា សូមជូនប្រស្នា ជាការកំសាន្ត កបដោយកលកិច្ច
ល្បោយល្បិចដើមដាន លោកអ្នករាប់អាន ឆ្លើយបានទាំងអស់ ។
ផ្ញើទៅរួសរាន់ ត្រូវបានរង្វាន់ ខានខៅខំដោះ ខុសត្រូវឧកខាន
បានជាអម្រស់ ពុំសាបសូន្យសោះ កម្ពុជសុរិយា ។
តទៅសូមស្ដាប់ ខ្ញុំផ្ដើមរ៉ាយរ៉ាប់ ពាក្យពេចន៍ប្រស្នា មិនវែងមិនខ្លី
ស្ដីតាមប្រាជ្ញា បង្កប់ខ្លឹមសារ មានអាថិកំបាំង ។
បងប្អូនពីរនាក់ កើតមកមានជាក់ ហាក់កម្មពៀរខ្លាំង បងប្អូនមែនពិត
តែចិត្តប្រឆាំង ប្រកាន់ទីតាំង រស់នៅទីទៃ ។
បងនៅក្នុងស្រុក ប្រកបដោយសុខ ឥតមោះគ្រោះភ័យ ប្អូននៅស្រយាល
កណ្ដាលទ្រូងព្រៃ មិនមានមោះមៃ សឹងបានសុខជា ។
ប្រស្នាបញ្ជាក់ បងប្អូនពីរនាក់ មានមាឌប៉ុនគ្នា ជារៀងរាល់ឆ្នាំ
កម្មតាមផ្ដន្ទា តម្រូវជួបគ្នា ម្ដងជាកំណត់ ។
រាល់ពេលជួបនោះ កើតរឿងរ៉ាវឈ្លោះ វាយគ្នាប្រាកដ ពកមុខជាំមាត់
ពុំមាននឿយហត់ ដល់ថ្ងៃសន្មត បែកគ្នាទីទៃ ។
សូមអស់លោកអ្នក ឆ្លើយឆ្លងតាមវគ្គ ស្រាយបញ្ជាក់ន័យ បងប្អូនពីរនាក់
មួយស្រុកមួយព្រៃ រស់នៅទីទៃ តើវាជាអ្វី ?
មួយឆ្នាំជួបម្ដង ជួបពេលណាផង ពេលវែងឬខ្លី ? ឆ្លើយជាពាក្យកាព្យ
ជាសម្រាយក្ដី រំលងខែបី(១) បានដឹងចម្លើយ ។

(១) មួយត្រីមាស

**ខណ្ឌ ស៊ុនហេង**

# សេចក្ដីកែតម្រូវ

មុននឹងអាន សូមកែតម្រូវពាក្យខុស ដូចខាងក្រោម ៖

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| បរម្យគ្រូ | បរមគ្រូ | ២១ | ១៤ |
| មិច្ឆាជីវះ | វៀរចាកមិច្ឆាជីវះ | ២១ | ១៥ |
| តាឡទី | តាមទី | ២១ | ២២ |
| ការសៃព | ការសេព | ២១ | ២៣ |
| បពិត | បពិត្រ | ២១ | ២០ |
| មិន | មិត្ត | ២៥ | ៦ |
| មិនជាការជាការ | មិនជាការ | ១១០ | ២ |
| ដេញដោយ | ដេញដោល | ១១២ | ៩ |
| ជក្រ | ជម្រក | ១២០ | ៦ |

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ




ឆ្នាំទី ៤៨ លេខ ២ ខែ មេសា - ឧសភា - មិថុនា

ព.ស ២៥៣៧ គ.ស ១៩៩៤

ភ្នំពេញ



# កម្ពុជសុរិយា

## ទស្សនាវដ្ដី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ

### ចេញរាល់ត្រីមាស ពី ពុទ្ធសាសនបណ្ឌិត្យ

ចាត់ចែងបោះពុម្ពផ្សាយដោយគណៈកម្មការមួយ មាន :

ទីប្រឹក្សា : **ហៀន ចណ្ឌារត្ន**

នាយកការផ្សាយ : **ឈន អៀម**

និពន្ធនាយក : **យី ធន់**

និពន្ធនាយករង : **ឱម ខែម**

គណៈកម្មការនិពន្ធ

ព្រះធម្មលិខិត **លាស់ ឡាយ**, ព្រះមហាព្រហ្មមុនី **ហេង លាងហោ**,

លោក **ម៉ែន ប្រាង**, លោក **អាំ ឆន**,

ごあいさつ

この本は、世界宗教者平和会議日本委員会と曹洞宗国際ボランティア会との共同プロジェクトとして印刷されました。

この本が、日本の宗教者とカンボジアの人々との友情のきずなとなり、カンボジアの宗教と文化の発展に貢献できれば幸いです。

ACKNOWLEDGEMENT

The Kampuja Surya Magazine is specially printed as a cooperative project of the Japanese Committee of the World Conference on Religion and Peace (WCRP) and Japan Sotoshu Relief Committee (JSRC).

We pray that this magazine would contribute to the Friendship with Cambodian people and their religious and cultural preservation.

និវេទនកថា

ទស្សនាវដ្ដីកម្ពុជសុរិយានេះ ត្រូវបានបោះពុម្ពឡើងជាពិសេស ទុកដូចជាគម្រោងការងារ របស់គណៈកម្មាធិការជប៉ុននៃក្រុមប្រឹក្សាពិភពលោកស្ដីពីសាសនានិងសន្តិភាព (WCRP) ហើយនិងគណៈកម្មាធិការជំនួយសូតូស៊ូជប៉ុន (JSRC) ។

យើងខ្ញុំអធិដ្ឋាន សូមឱ្យទស្សនាវដ្ដីនេះ បានជាវិភាគទានរក្សាមិត្តភាពជាមួយប្រជាជនកម្ពុជា និងថែរក្សាសម្បត្តិសាសនានិងវប្បធម៌របស់ប្រជាជនកម្ពុជា ។

# មាតិកាអត្ថបទ

I. *អត្ថបទរដ្ឋបាល :*

- សារព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុ វរ្ម័ន ចំពោះសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ នាយករដ្ឋមន្ត្រីទី១ និងសម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីទី២ ........................ ១
- សារព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុ វរ្ម័ន ចំពោះឯកឧត្តម ឈន អៀមអនុរដ្ឋលេខាធិការក្រសួង ធម្មការ និងសាសនា ........................ ២
- សេចក្តីអំពាវនាវរបស់ពុទ្ធសាសនបណ្ឌិត្យ ........................ ៣
- សេចក្តីសំរេចចិត្តរបស់អនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃ លើកទី៣ . ១៩៩៤ ........................ ៤

II. *អក្សរសិល្ប៍ពុទ្ធសាសនា*

- ព្រះធម៌របស់ព្រះពុទ្ធ (ត) ........................ ៨
- រឿងកាឡិយក្ខិនី ........................ ៣៨
- បុណ្យភ្ជុំបិណ្ឌ ........................ ៤៥
- អំពីពុទ្ធិកសមាគមពិភពលោក (ព.ស.ព) ........................ ៥៦
- សង្គាយនាទី២ ........................ ៦៥

III. *អក្សរសាស្ត្រទូទៅ និងអក្សរសិល្ប៍ខ្មែរ*

- ល្បើកនគរវត្ត (ត) ........................ ៦៩

- គម្ពីរស្លឹករឹត ........................................ ៩៤
- អំពីអ្នកតា ........................................ ១០៣
- ចេះដប់មិនស្មើប្រសប់មួយ ........................................ ១០៩
- មាន់ស្រុក និង មាន់ព្រៃ ........................................ ១១៣
- សេចក្តីជូនដំណឹងស្តីពីការប្រកាសលទ្ធផល
នៃចម្លើយ " កំណាព្យប្រស្នា" ........................................ ១១៧
- ចម្លើយកំណាព្យប្រស្នា ........................................ ១១៩
- ឆ្លើយកំណាព្យប្រស្នា (រង្វាន់លេខ១) ........................................ ១២០
- ឆ្លើយកំណាព្យប្រស្នា (រង្វាន់លេខ២) ........................................ ១២២
- * កំណាព្យប្រស្នា ........................................ ១២៥

IV. *កំណត់ និងប្រវត្តិការណ៍* :
- សេចក្តីប្រកាសពតិមាន ........................................ ១២៦

ព្រះករុណាព្រះបាទសម្តេច
ព្រះនរោត្តម សីហនុ វរ្ម័ន
ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

ជូនចំពោះ សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ
នាយករដ្ឋមន្ត្រីទី ១ និង
សម្តេច ហ៊ុន សែន
នាយករដ្ឋមន្ត្រីទី ២ នៃ
រាជរដ្ឋាភិបាលជាតិកម្ពុជា

សម្តេចទាំងពីរ ជាទីស្រឡាញ់ដ៏ជ្រាលជ្រៅបំផុត

ខ្ញុំសូមផ្ញើមកជូនសម្តេចទាំងពីរ នូវសំណុំលិខិតរបស់ឯកឧត្តម ឈន អៀម អនុរដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា ចុះថ្ងៃទី ៥ ខែឧសភា ឆ្នាំ១៩៩៤ ស្តីអំពីការសុំដីធ្លីសំរាប់កសាងអាគារធំមួយ នៃពុទ្ធសាសនបណ្ឌិតកម្ពុជាយើង ដែលអង្គការ រីស្សូកូស៊ីកៃ (Reissho Kosei-Kai) នឹងជួយ ឧបត្ថម្ភផ្តល់ថវិកាចំនួន ២៥០.០០០ $US ទៅ ៣០០.០០០ $US ដើម្បីការសាងសង់នោះ ។

ខ្ញុំសូមថ្លែង នូវអំណរគុណដ៏ជ្រាលជ្រៅ និងកក់ក្តៅបំផុតទុកជាមុន ជូនសម្តេចទាំងពីរ និងរាជរដ្ឋាភិបាលកម្ពុជា ចំពោះការយកហឫទ័យទុកដាក់ជ្រោមជ្រែង ជួយដោះស្រាយដោយសេចក្តីអនុគ្រោះបំផុត នូវសំណូមពរខាងលើ ។

សូមសម្តេចទាំងពីរទទួល នូវសេចក្តីរាប់អានដ៏ខ្ពង់ខ្ពស់ និងស្រឡាញ់ដ៏ជ្រាលជ្រៅ និងកក់ក្តៅបំផុត អំពីខ្ញុំ ។

នរោត្តម សីហនុ

ព្រះរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែឧសភា ឆ្នាំ១៩៩៤

**ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ វរ្ម័ន**
**ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា**

ជូនចំពោះ ឯកឧត្តម ឈន អៀម
អនុរដ្ឋលេខាធិការក្រសួងធម្មការ
និងកិច្ចការសាសនា

ឯកឧត្តម ជាទីរាប់អានដ៏ជ្រាលជ្រៅ

ខ្ញុំ និងសម្តេចព្រះមហេសី បានទទួលរួចហើយ នូវអំណោយជាសៀវភៅ "កម្ពុជសុរិយា" ចំនួនពីរក្បាល ដែលឯកឧត្តមបានផ្ញើមកជូនខ្ញុំ និងសម្តេចព្រះមហេសី នៅប្រាសាទខេមរិន្ទ តាមរយៈខុទ្ទកាល័យរបស់ខ្ញុំ ។

ខ្ញុំ និងសម្តេចព្រះមហេសីសូមថ្លែង នូវអំណរគុណដ៏ជ្រាលជ្រៅជាអតិបរមា និងសេចក្តីសរសើរយ៉ាងស្មោះអស់ពីដួងហឫទ័យ ជូនឯកឧត្តម និងសហការី សហការិនីក្នុងក្រសួងធម្មការ និងកិច្ចការសាសនា ចំពោះកាយវិការដ៏វិសេសវិសាល ប្រកបដោយសមានចិត្តដ៏ឧត្តុង្គឧត្តម ថ្លៃថ្លាខាងលើ ។

សូមឯកឧត្តម និងសហការី សហការិនីទទួល នូវសេចក្តីស្រឡាញ់រាប់អានដ៏ជ្រាលជ្រៅ និងកក់ក្តៅអំពី ខ្ញុំ និងសម្តេចព្រះមហេសី ។

នរោត្តម សីហនុ

ព្រះរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែឧសភា ឆ្នាំ១៩៩៤

# សេចក្តីអំពាវនាវ
## របស់
# ពុទ្ធសាសនបណ្ឌិត្យ

ពុទ្ធសាសនបណ្ឌិត្យ មានសេចក្តីរីករាយណាស់ នឹងជំរាបអស់លោកអ្នកអានទូទាំងប្រទេសបានជ្រាបថា : *ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ* ត្រូវបានរៀបចំបង្កើតឡើងវិញហើយ ។ សព្វថ្ងៃនេះ កំពុងដំណើរការសកម្មភាពស្តារឡើងវិញនូវប្រពៃណី ទំនៀមទម្លាប់ខ្មែរយើង ដោយប្រមូលអត្ថបទផ្សេងៗដែលមានពីមុនមក និងសិក្សាស្រាវជ្រាវឯកសារថ្មីៗទៀតទាក់ទងនឹងប្រពៃណី ទំនៀមទម្លាប់ វប្បធម៌ ជំនឿ ព្រឹត្តិការណ៍ ឬទីឋានប្រវត្តិសាស្ត្រ ដែលមាននៅក្នុងទូទាំងប្រទេស ។

អាស្រ័យហេតុនេះ ពុទ្ធសាសនបណ្ឌិត្យ សូមអំពាវនាវចំពោះអស់លោកអ្នកអាន ទាំងព្រះសង្ឃ ទាំងគ្រហស្ថទាំងអស់ ព្រមទាំងឯកឧត្តម អស់លោកមន្ត្រីរាជការឯទៀតៗ ដែលជាប់ចិត្តនឹងប្រពៃណី ទំនៀមទម្លាប់ខ្មែរ មេត្តាជួយស្រាវជ្រាវ សរសេរចងក្រងជាអត្ថបទ ហើយសូមផ្ញើទៅក្រុមជំនុំទំនៀមទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ ដើម្បីពិនិត្យនិងបោះពុម្ពផ្សាយ រក្សាទុកជាឯកសារសំរាប់កូនចៅខ្មែរជំនាន់ក្រោយសិក្សាស្រាវជ្រាវ អំពីសង្គមខ្មែរ និងជាតិខ្មែរយើងតទៅទៀត ។

ពុទ្ធសាសនបណ្ឌិត្យ សង្ឃឹម និងរង់ចាំជានិច្ច ។

ពុទ្ធសាសនបណ្ឌិត្យ

# សេចក្ដីសំរេចចិត្ត

## របស់អនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃ លើកទី ៣

ថ្ងៃទី ៦ . ៧ . ៨ . ៩ ខែឧសភា ឆ្នាំ ១៩៩៤

អនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃលើកទី៣ ដោយមានសម្ដេចព្រះសង្ឃរាជ និងមន្ត្រីសង្ឃទាំងពីរគណៈចូលរួម ត្រូវបានប្រារព្ធឡើងយ៉ាងមហោឡារិក នៅវេលាព្រឹកថ្ងៃទី៦ ខែឧសភា ១៩៩៤ នាសាលចតុមុខ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់នៃព្រះករុណាព្រះបាទសម្ដេចព្រះនរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងសម្ដេចព្រះមហេសី នរោត្តម មុនីនាថ សីហនុ ។ ចាប់ពីពេលរសៀល នៃថ្ងៃទី៦ និងថ្ងៃទី៧ ទី៨ ទី៩ ខែឧសភា អនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃលើកទី៣ ខាងគណៈមហានិកាយ ត្រូវបានបើកប្រជុំពេញអង្គ នៅក្នុងវត្តឧណ្ណាលោម ក្រុងភ្នំពេញ ក្រោមព្រះអធិបតីភាពសម្ដេចព្រះមហាសុមេធាធិបតី ទេព វង្ស ព្រះសង្ឃរាជគណៈមហានិកាយ ដោយមានមន្ត្រីសង្ឃពីគ្រប់ខេត្ត ក្រុង ចូលរួមចំនួន ៩៩ អង្គ និងមន្ត្រីធម្មការខេត្ត ក្រុង ចំនួន ២១ រូប ព្រមទាំងចៅក្រសួង និងមន្ត្រីក្រសួងធម្មការមួយចំនួន ក៏បានចូលរួមផងដែរ ។

អនុសំវច្ឆរមហាសន្និបាត បានសំដែងស្វាគមន៍អបអរសាទរ និងសំដែងកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅ ចំពោះព្រះករុណាព្រះបាទសម្ដេចព្រះនរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៍ និងសម្ដេចព្រះមហេសី នរោត្តម មុនីនាថ សីហនុ ដែលបានស្ដេចយាងចូលរួមជាព្រះអធិតីភាព

ដ៏ខ្ពង់ខ្ពស់ ហើយទ្រង់បានថ្លែងព្រះសង្កថា ប្រកបដោយខ្លឹមសារជ្រាលជ្រៅ ស្តីពីបច្ចុប្បន្នភាពនយោបាយនៃព្រះរាជាណាចក្រកម្ពុជា ដែលកំពុងប្រឈមមុខដាក់គ្នាខាងយោធា រវាងខ្មែរនឹងខ្មែរ ដែលតម្រូវអោយព្រះអង្គទ្រង់ព្រះតម្រិះរកវិធីបមន្តថ្មីដើម្បីបង្រួបបង្រួមជាតិ និងផ្សះផ្សាជាតិអោយបានឆាប់ ដើម្បីកសាងព្រះរាជាណាចក្រកម្ពុជា ឆ្ពោះទៅរកសន្តិភាព វឌ្ឍនភាព និងសុភមង្គល ក្រោមម្លប់ព្រះពុទ្ធសាសនា ។

អនុសំវច្ឆរមហាសន្និបាត បានស្តាប់ដោយយកចិត្តទុកដាក់សុន្ទរកថាស្វាគមន៍ របស់ឯកឧត្តមរដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា ស្តីពីការវិវត្តន៍នៃពុទ្ធសាសនា និងសកម្មភាព ព្រមទាំងគំរោងការងាររបស់ក្រសួងធម្មការ និងសាសនា ។

អនុសំវច្ឆរមហាសន្និបាត បានស្តាប់ដោយយកចិត្តទុកដាក់ព្រះរាជមតិសម្តេចព្រះមហាសុមេធាធិបតី ព្រះសង្ឃរាជ ណែនាំមហាសន្និបាត លើវិស័យធម្មការ និងសាសនា វិស័យពុទ្ធិកសិក្សា និងពុទ្ធសាសនបណ្ឌិត្យ ដែលពាក់ពន្ធ័ជានិច្ច ដល់ក្រសួងព្រះសង្ឃរាជ, ក្រសួងធម្មការ និងសាសនា និងការប្រព្រឹត្តទៅនៃព្រះពុទ្ធសាសនា ។

អនុសំវច្ឆរមហាសន្និបាត បានស្តាប់ដោយយកចិត្តទុកដាក់ខ្លឹមសារមួយចំនួន របស់ឯកឧត្តម ឈន អៀម អនុរដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា ស្តីពីតួនាទីរបស់វត្តអារាមក្នុងការរក្សា ការពារ និងកសាងបរិដ្ឋាន ការលើកកិត្យានុភាព និងឥទ្ធិពលរបស់ភិក្ខុសង្ឃ ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍន៍សង្គម រួមចំណែកផ្សព្វផ្សាយអហឹង្សា ដើម្បីបង្រួបបង្រួម និងផ្សះផ្សារជាតិ ។

អនុសំវច្ឆរមហាសន្និបាត បានសំដែងស្វាគមន៍ដោយសោមនស្ស រីករាយបំផុត ចំពោះរដ្ឋសភាជាតិដែលបានលើកស្ទួយព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋ

ហើយផ្តល់សេរីភាពគ្រប់យ៉ាងដល់ព្រះសង្ឃ និងពុទ្ធបរិស័ទ អោយធ្វើសកម្មភាពសាសនា ស្របតាមជំនឿ និងប្រពៃណីរបស់ជាតិ ។

អនុសំវច្ឆរមហាសន្និបាត បានធ្វើការពិភាក្សាប្តូរយោបល់ស្តីពីចំណុចរីកចំរើន និងចំណុចខ្វះខាត ជុំវិញការប្រតិបត្តិធម៌វិន័យ និងការរៀនសូត្រព្រះបរិយត្តិធម៌ នៅតាមខេត្ត-ក្រុងនីមួយៗ ។

ក្នុងស្មារតីឯកភាពខ្ពស់ មន្ត្រីសង្ឃជាសមាជិកទាំងអស់នៃអនុសំវច្ឆរមហាសន្និបាតលើកទី៣ បានអនុម័តជាឯកច្ឆន្ទ នូវសេចក្តីសំរេចចិត្តមួយចំនួនដូចតទៅនេះ ៖

១. មន្ត្រីសង្ឃគ្រប់ថ្នាក់ ត្រូវយកចិត្តទុកដាក់ដោះស្រាយ និងបំបាត់រាល់បាតុភាពអសកម្ម ដែលជះឥទ្ធិពលមិនល្អដល់ពុទ្ធសាសនា ដូចជាការបន្លំបួស ហើយពោលអួតគុណវិសេស បង្កភាពវឹកវរ និងមន្ទិលសង្ស័យក្នុងជួរសាសនា និងប្រជារាស្ត្រ, ការជ្រកក្រោមរូបភាពក្លែងក្លាយផ្សេងៗ ។

២. រាល់បាតុភាពវង្វេងរង្គាសមិនសមហេតុផល, ការបង្កអោយមានអធិករណ៍ ក្នុងជួរ សាសនា, ការប្រព្រឹត្តឃ្លៀងឃ្លាតអភិសមាចារ និងកិច្ចវត្តផ្សេងៗ, ការត្រាច់ចរដោយបំពានទៅកាន់ទីតាំងអគោចរ និងភាពអលជ្ជីនៃបព្វជិត ត្រូវតែខិតខំលុបបំបាត់នៅគ្រប់ទីកន្លែងទូទាំងព្រះរាជាណាចក្រកម្ពុជា ។

៣. ខិតខំប្រើប្រាស់អោយអស់លទ្ធភាព និងមធ្យោបាយដែលមាន ដើម្បីបន្តជំរុញសាលាពុទ្ធិកបឋមសិក្សា និងសាលាធម្មវិន័យ ដែលជាគ្រឹះមូលដ្ឋាននៃការពង្រឹងពង្រីកពុទ្ធិកមធ្យមសិក្សា និងពុទ្ធិកឧត្តមសិក្សា ដែលជាប្រភពនៃភាពឋិតថេររបស់ពុទ្ធសាសនា ក៏ដូចជាប្រភពនៃការរីកចំរើនខាងបញ្ញាញាណជាតិ ដែរ ។

៤. មន្ត្រីសង្ឃគ្រប់ថ្នាក់ ត្រូវបង្កើនការិតគ្រប់គ្រងវត្តអារាម, គរុភណ្ឌ និង

ភិក្ខុសាមណេរ ដើម្បីធានាបានសេចក្ដីថ្លៃថ្នូរផ្ទាល់ខ្លួន និងរួមចំណែកលើកស្ទួយកិត្យានុភាព និងឥទ្ធិពលនៃពុទ្ធសាសនា ។

*វត្តឧណ្ណាលោម ថ្ងៃទី ៩ ខែឧសភា ឆ្នាំ១៩៩៤*

សម្ដេចព្រះមហាសុមេធាធិបតី

ព្រះសង្ឃរាជ គណៈមហានិកាយ

**ទេព វង្ស (សុមេធាវង្សោ)**

បានឃើញ និងឯកភាព

រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា

**ហៀង បណ្ណរក្ខ**

# ព្រះធម៌របស់ព្រះពុទ្ធ

ដោយភិក្ខុ (Jagdish Kasyapa)

បកប្រែដោយ **ឈេន អៀម**

## I. បដិច្ចសមុប្បាទធម៌ (ត)

### ចរន្តនៃហេតុភាព

ចូរយើងលើកយកតែឧទាហរណ៍តូចមួយក្នុងលោកយើងនេះមកពិនិត្យ ហើយតាមដានជាបញ្ច្រាស ឬជាបណ្តោយតាមរបៀបដូចគ្នា ។ធម្មជាតិ ត្រូវបានគ្រប់គ្រងដោយក្រឹត្យក្រមរបស់បដិច្ចសមុប្បាទ : អាស្រ័យដោយមាននេះ, ទើបនោះមានឡើង ។ ក្នុងអភិក្រមនេះ ពុំមានការផ្អាក ឬដាច់ទេ ។ ខ្សែ ឬឈុតនៃព្រឹត្តិការណ៍ទាំងឡាយ ចេះតែហូរតៗគ្នាជាប់មិនដាច់ គឺព្រឹត្តិការណ៍មួយផ្តល់កំណើតអោយព្រឹត្តិការណ៍មួយទៀត ។ បីដូចជា រលកទឹកមួយ បង្កើតអោយមានរលកទឹកមួយទៀត ហើយរលកទឹកក្រោយនេះ បង្កើតអោយមានរលកទឹកថ្មីទៀត, ដោយប្រការយ៉ាងនេះ*ចរន្តនៃហេតុភាពរមែងប្រព្រឹត្តទៅ* ។

### អំពីបញ្ហានៃបឋមហេតុ

ប៉ុន្តែ វាអាចកើតមានការជំទាស់មួយ ស្តីពីអ្វីដែលជា*បឋម*ហេតុ ឬថាតើដល់ទៅចំណុចណា ទើបអភិក្រមនៃហេតុភាព ត្រូវចប់ ?

តាមពិត វិទ្យាសាស្ត្រមិនរវល់ស្រាវជ្រាវរកអោយឃើញបឋមហេតុ ឬ

ផលចុងក្រោយនោះឡើយ ។ ពុទ្ធិ ឬវិជ្ជារបស់យើងកើនឡើងតាម សមាមាត្រនៃការប៉ិនប្រសប់ និងការព្យាយាមរបស់យើងក្នុងការស្រាវជ្រាវ ។ កាលណាយើងខ្វះពុទ្ធិខាងវិទ្យាសាស្ត្រ យើងច្រើនតែធ្លាក់ទៅក្នុងជំនឿ ផ្ដេសផ្ដាស ( La superstition ) ។ បឋមមនុស្ស ពេលឃើញអច្ឆរិយហេតុនៃធម្មជាតិ ក៏មានចិត្តចូចចង់ដឹង ចង់ពន្យល់អំពីអច្ឆរិយហេតុនេះ ។ គេពុំអាចបកស្រាយអច្ឆរិយហេតុនោះៗតាមវិទ្យាសាស្ត្របាន ពោលគឺ តាមក្រឹត្យក្រមនៃដើម កំណើតអន្តរានិស្សរៈ ( La loi de l'origine interdépendante ) ។ គេក៏បានសាកល្បងពន្យល់បាតុភូតទាំងនោះ តាមរយៈភ្នាក់ងារប្រឌិតឡើង ឬ" អធិមនុស្ស" ទេវៈ ឬអាទិទេព ។ ប៉ុន្តែយើងបានឃើញច្បាស់ថា ជំនឿតាមការបកស្រាយផ្ដេសផ្ដាសនេះ គឺជាសត្រូវដល់ការជឿនលឿននៃវិទ្យាសាស្ត្រ ។ មនុស្សបុព្វកាលបានជឿថា ខ្យល់បក់កើតមានពីព្រោះអាទិទេពខ្យល់ ( ទេពវាយុ ) ចេញដំណើរ ដង្ហែក្បួនអាពាហ៍ពិពាហ៍ ។ ប្រសិនបើវិទ្យាសាស្ត្រទទួលយកគំនិតនេះ ហើយមិនបានខិតខំពន្យល់ទៅតាមក្រឹត្យក្រមអន្តរានិស្សរៈទេ, យើងក៏ពុំអាចដឹងបានថា ចលនាខ្យល់កើតចេញមកពីភាពផ្សេងគ្នានៃសម្ពាធបរិយាកាសបានទេ ។

ការពន្យល់តាមរយៈទេវៈ ឬតាមបែបអប្បិយជំនឿ រាំងស្ទាក់គ្រប់ការសិក្សាស្រាវជ្រាវសម័យកាលក្រោយ មិនអាចអោយទៅមុខបាន ។ យើងពុំអាចសួរថាតើអ្នកណាបង្កើតអាទិទេព ឬថា ដោយអាស្រ័យអ្វី ទើបអាទិទេពឧប្បត្តិកឡើងទេ ។ នេះជាការទាល់ច្រកមួយ នៅក្នុងការឈានទៅមុខនៃពុទ្ធិ ។

*ក្រឹត្យក្រមបដិច្ចសមុប្បាទ មិនស្វែងរកអោយឃើញបឋមហេតុនេះទេ ពីព្រោះគ្រាន់តែគំនិតអំពី " បឋមហេតុ " គឺមានន័យថា បញ្ឈប់ទាំងស្រុងនូវការរីកចំរើននៃពុទ្ធិទៅហើយ ។*

## ក្រឹត្យក្រមបដិច្ចសមុប្បាទ មិនមែនជាក្រឹត្យក្រមហេតុភាពអារីស្តូតទេ

មនុស្សខ្លះ យល់ក្រឹត្យក្រមបដិច្ចសមុប្បាទ ដោយភាន់ច្រឡំ ។ តាមពិតក្រិត្យក្រមនេះ ពុំមែនជាក្រិត្យក្រមហេតុភាព ដូចតក្កវិញ្ញូនៅមជ្ឈិមសម័យ ដែលដឹកនាំដោយលោកអារីស្តូតបានយល់នោះទេ ។ លោកអារីស្តូត បានចាត់ទុក ហេតុ និង ផល ថាជាព្រឹត្តិការណ៍ពីរផ្សេងគ្នា, ព្រឹត្តិការណ៍មួយបង្កើតអោយមានព្រឹត្តិការណ៍មួយទៀត ។

បើពិនិត្យអោយម៉ត់ចត់ទៅ ការអះអាងនេះ ហាក់ដូចជាពុំអាចការពារបាន ។ តាមបដិច្ចសមុប្បាទ ព្រឹត្តិការណ៍ពីរ ពុំអាចចាត់ទុកថាផ្សេងពីគ្នាស្រឡះពីមួយទៅមួយបានទេ ពីព្រោះ ព្រឹត្តិការណ៍ទាំងនោះ ជាប់គ្នាជាខ្សែសង្វាក់ក្នុងអភិក្រមជាមួយគ្នា ដែលគ្មានការកាត់ផ្តាច់ ។ *នៅក្នុងលោកនេះ គ្មានព្រឹត្តិការណ៍ណាមួយ ដែលជាព្រឹត្តិការណ៍ឯកោតែឯងឡើយ ។ ហេតុមួយ មិនអាចត្រូវបានចាត់ទុកថាមានអត្ថិភាពដោយខ្លួនឯងនោះទេ ។*

## មិនមែនជាហេតុភាពទេ ប៉ុន្តែជាដើមកំណើតអន្តរានិស្សរៈ(ដើមកំណើតចំណុះគ្នាទៅវិញទៅមក) ដែលជាវោហារស័ព្ទវិទ្យាសាស្ត្រ

តក្កវិទូយុគកណ្តាល បានអះអាងថា ដីឥដ្ឋគឺជាហេតុនៃសិល្បៈស្មូនឆ្នាំង (la poterie) ។ មែនហើយ ដីឥដ្ឋគឺជាហេតុនៃសិល្បៈស្មូនឆ្នាំងយ៉ាងពិតប្រាកដ, ប៉ុន្តែ ដីឥដ្ឋខ្លួនឯង មិនទាន់គ្រប់គ្រាន់សម្រាប់ផលិតកម្មនៃកុម្ភការភណ្ឌបានទេ ។ ប្រសិនបើគ្មានទឹកគ្មានកម្លាំងដែលប៉ិនប្រសប់, គ្មានស្មូនឆ្នាំង គ្មានចិត្តចង់របស់ស្មូន

ឆ្នាំងក្នុងការធ្វើ ឆ្នាំងទេ, នោះឆ្នាំងក៏មិនអាចនឹងផលិតបានដែរ ។ ល័ក្ខខ័ណ្ឌទាំងអស់នេះ គឺជាល័ក្ខខ័ណ្ឌចាំបាច់សម្រាប់ការផលិតឆ្នាំង ។ ប្រសិនបើក្នុងបណ្តាល័ក្ខខ័ណ្ឌទាំងនោះ មានខ្វះល័ក្ខខ័ណ្ឌណាមួយ, នោះឆ្នាំងមិនអាចត្រូវបានគេផលិតបានឡើយ ។ ក្នុងលក្ខណៈនេះ តើយើងអាងអ្វី ទើបហ៊ាននិយាយថា *ដីឥដ្ឋគឺជា*ហេតុនៃការធ្វើឆ្នាំង ? វាជាការបំពានមួយរបស់យើង ដែលគ្រាន់តែជ្រើសយកវត្ថុមួយក្នុងបណ្តាវត្ថុឯទៀតជាច្រើន ហើយហៅវត្ថុដែលជ្រើសនោះថាជាហេតុ ។ ដូច្នេះ វាជាការពុំត្រឹមត្រូវទេ ដែលនិយាយថា ដីឥដ្ឋជាហេតុនៃការផលិតឆ្នាំង ។ *បែបបទដែលសមស្របសម្រាប់និយាយ ចំពោះប្រការនេះ គឺឆ្នាំងត្រូវបានផលិតដោយចំណុះ ឬអាស្រ័យ ដីឥដ្ឋ* ។ ដូច្នេះ ការពន្យល់ប្រកបដោយវិទ្យាសាស្ត្រ និងប្រកបដោយវិចារណញ្ញាណ បំផុតអាចប្រព្រឹត្តទៅបានតែតាមក្រឹត្យក្រម នៃបដិច្ចសមុប្បាទ ប៉ុណ្ណោះ ។

## ការអនុវត្តក្រឹត្យក្រមនេះចំពោះការពន្យល់អំពីអកុសល

ព្រះពុទ្ធ ទ្រង់បានពិចារណាអំពីហេតុផលនៃមរណៈ និងទុក្ខៈ ។ ខុសប្លែកពីពួកមនុស្សដែលនិយមអប្បិយជំនឿនៅក្នុងសម័យកាលរបស់ព្រះអង្គ ព្រះពុទ្ធពុំបានជឿថា ទុគ្គតភាព ( Les misères ) កើតមកអំពីកំហឹងរបស់ទេវៈ ឬទេវធីតាផ្សេងៗ ទេ ។ នៅក្នុងការស្រាវជ្រាវរបស់ព្រះអង្គ វាមានទិសមួយជាវិទ្យាសាស្ត្រ ។ ព្រះអង្គបានសាកល្បងតាមដានទុក្ខវេទនារបស់មនុស្ស ដោយស្រាវ ឬសួរតាមកម្រងតៗគ្នា នៃបដិច្ចសមុប្បាទ ។

តើមរណៈ ជរា ... បណ្តាលមកពីអ្វី ? ទុក្ខកើតមានអាស្រ័យដោយអ្វី ? តើបាតុភូតអ្វីខ្លះ កើតមានមុនបន្ទាប់នៃទុក្ខៈ ជរា មរណៈ នោះ ?

*១. ព្រះអង្គ ទ្រង់បានយល់ថា វាទាំងអស់នេះ ( ទុក្ខៈ ជរា មរណៈ ) ចំណុះក្នុង ការកើត* ពីព្រោះ ទុក្ខៈ ជរា មរណៈ កើតឡើងក្រោយការកើតរបស់មនុស្ស ។ ដូច្នេះ វាទាំងអស់នោះ អាស្រ័យដោយការកើត គឺជាតិនោះឯង ។

## តើការកើត(ជាតិ) គឺអាស្រ័យដោយអ្វី ?

*២. ការកើត អាស្រ័យដោយភព ពោលគឺការមានអត្ថិភាព ។* គ្មានអ្វីកើតចេញមកពីទទេ ( Rien ne vient de rien ) នោះទេ ។ វត្ថុមួយត្រូវបានកើតចេញមកពីវត្ថុមួយទៀត ។ ដូច្នេះ កំណើតមិនអាចមានទេ ប្រសិនបើគ្មានអត្ថិភាពពីមុនសម្រាប់តួអង្គមនុស្ស ឬបុគ្គលភាពមនុស្ស ។ បុគ្គលភាពនេះ ពុំមែនកើតចេញពីទទេនោះទេ ។ អត្ថិភាពពីមុន ទោះជាមានធម្មជាតិជាអ្វីក៏ដោយ ក៏ត្រូវបានគេចាត់ទុកថាមាន ដែលគួរអោយជឿបានយ៉ាងពិតប្រាកដ ។

បុគ្គលភាព ជាមនុស្សម្នាក់ គ្មានមានអ្វីក្រៅពីមហិច្ឆតាផ្ទាល់ខ្លួន, ជោគជ័យ, បរាជ័យ, សេចក្តីសង្ឃឹម, សេចក្តីខកចិត្ត, និងអ្វីៗដទៃទៀតរបស់មនុស្សនោះទេ ។ ទាំងអស់នេះ មិនចាប់ផ្តើមជាមួយកំណើតរបស់យើងតែឯងនោះទេ ពីព្រោះ ការចាប់ផ្តើមណាមួយបណ្តែអោយឃើញជានិច្ច នូវអត្ថិភាពអ្វីមួយពីមុនមក ។ ជីវិតបច្ចុប្បន្នខ្លួនឯង មិនមែនជាចរន្តមួយថ្មីទេ, ជីវិតនេះ គឺជាការបន្តនៃជីវិតមួយដែលមានពីមុននេះ ។

## តើភពអាស្រ័យដោយអ្វី ឬមានអ្វីជាបច្ច័យ ?

*៣. ភពចំណុះក្នុងការជំពាក់ចិត្ត ពោលគឺភពមានឧបាទានជាបច្ច័យ ។* ជីវិតរបស់យើង គឺជាខ្សែសង្វាក់នៃការជំពាក់ចិត្តជាប្រចាំដើម្បីបានអ្វីមួយ ដែលយើងខំស្វែងរក ហើយខំសម្របខ្លួនយើងតម្រូវទៅនឹងរបៀបរបបនៃលោក ។ ស៊ី

ផឹក ធ្វើដំណើរពីកន្លែងមួយ ទៅកន្លែងមួយទៀត អំពើតូចតាចបំផុតដែលយើងបាន ធ្វើ គឺសុទ្ធតែនាំអោយមានការតម្រូវដ៏ចាំបាច់នេះ ។ យើងមិនអាចគិតប្រឌិតឡើងនូវមនុស្សណាម្នាក់ ដែលពុំមានការជំពាក់ចិត្ត ទោះបីជាការជំពាក់ចិត្តនោះតិចតួចយ៉ាងណាក៏ដោយនោះបានទេ ។ ដូច្នេះ គឺដោយសារការជំពាក់ចិត្តរបស់យើងក្នុងការប្រឹងប្រែងរបស់យើង ដើម្បីបំពេញចំណង់នោះហើយ ដែលភព ឬអត្ថិភាព របស់យើងត្រូវចំណុះ " ពោលគឺ ភពកើតមាន ដោយមានឧបាទានជាបច្ច័យ " ។

## តើឧបាទានចំណុះអ្វី ?
## ( តើការជំពាក់ចិត្ត មានអ្វីជាបច្ច័យ )

*៤. ការជំពាក់ចិត្ត ចំណុះក្រោមចំណង់គឺតណ្ហា ។* ប្រសិនបើគ្មានចំណង់ នោះក៏គេពុំមានការជំពាក់ចិត្តដែរ ។ មនុស្សម្នាក់ មានចំណង់ដើម្បីក្លាយទៅជាអ្នកច្បាំងដណ្ដើមយកទឹកដីនៃប្រទេសមួយ ពេលនោះ គេមានចិត្តជាប់ជំពាក់ក្នុងរឿងនេះ គេខិតខំប្រយុទ្ធដើម្បីក្លាយទៅជាអ្នកឈ្នះ ។ ដូច្នេះ ការជំពាក់ចិត្តចំណុះក្រោមចំណង់ គឺបានសេចក្ដីថា ការជំពាក់ចិត្តនេះមានចំណង់ គឺតណ្ហា ជាបច្ច័យ ។

## តើតណ្ហាចំណុះអ្វី ?
## ( ចំណង់ មានអ្វីជាបច្ច័យ )

*៥. ចំណង់ចំណុះវេទនា គឺការដឹងដោយវិញ្ញាណ ។* គឺនៅពេលដែលយើងមានវេទនារីករាយហ្នឹងឯង ទើបយើងមានចំណង់ដើម្បីក្រេបយកសេចក្ដីសប្បាយ ។ វត្ថុមួយដ៏ស្រទន់ ដែលស្ទាប ឬពាល់ត្រូវ ឬវត្ថុមួយមើលឃើញល្អធ្វើអោយកើតចំណង់ ។ ដូច្នេះ ចំណង់ចំណុះវេទនា ឬការដឹងដោយវិញ្ញាណ (តណ្ហា

មានវេទនា ជាបច្ច័យ ) ។

## តើវេទនាចំណុះអ្វី ?

## ( វេទនា មានអ្វីជាបច្ច័យ )

*៦. វេទនាចំណុះផស្សៈ ពោលគឺការប៉ះពាល់ ។* កាលណាវិញ្ញាណរបស់យើងបានប៉ះពាល់ជាមួយវត្ថុខាងក្រៅ នៅពេលនោះហើយដែលយើងមានវេទនា ។ ដូច្នេះ វេទនាចំណុះផស្សៈ គឺការប៉ះពាល់ កាន់ ស្ទាប នោះឯង ។

## តើផស្សៈចំណុះអ្វី ?

## ( តើផស្សៈ មានអ្វីជាបច្ច័យ )

*៧. ផស្សៈ ចំណុះអង្គវិញ្ញាណទាំង ៦ ( សឡាយតនៈ ) និងកម្មវត្ថុទាំងឡាយរបស់វា ។* ប្រសិនបើយើងគ្មានភ្នែក និងគ្មានទស្សនីយភាពសម្រាប់សម្លឹងមើល តើយើងអាចមានផស្សារម្មណ៍ដូចម្តេចកើត ។ ដូច្នេះ ផស្សៈចំណុះអង្គវិញ្ញាណទាំងប្រាំមួយ និងកម្មវត្ថុរបស់វា រៀង១ខ្លួន ។

## តើអង្គវិញ្ញាណទាំង ៦ ចំណុះអ្វី ?

## ( តើសឡាយតនៈ មានអ្វីជាបច្ច័យ ? )

*៨. វាចំណុះនាម និងរូប (le nom et la forme) ។* អាយតនៈទាំង ៦ អាចជានាម ឬអាចជារូប ។ វត្ថុទាំងអស់ដែលអាចដឹងដោយវិញ្ញាណបាន គឺអាចជា នាម អាចជារូប ។ ដូច្នេះ អង្គវិញ្ញាណទាំងប្រាំមួយ គឺសឡាយតនៈចំណុះនាមនិងរូប។

## តើនាម និងរូបចំណុះអ្វី ?

*៩. នាមនិងរូបចំណុះវិញ្ញាណ ពោលគឺ ធម្មជាតិដឹងច្បាស់នូវអារម្មណ៍ ។* នាមមួយ ពុំមានន័យទេ និងទទេស្អាត ប្រសិនបើយើងគ្មានវិញ្ញាណអំពីកម្មវត្ថុរបស់នាមនោះទេ ។ ឈ្មោះ ( នាម ) មួយរបស់មនុស្សពុំមានន័យអ្វីសោះសម្រាប់យើង ប្រសិនបើយើងពុំបានដឹងថាគេជាអ្នកណា គេជាអ្វី ហើយនិងលក្ខណៈពិសេសដទៃទៀតរបស់គេ ។ ដូចគ្នាដែរ រូប ( une forme ) មួយក៏ពុំមានហេតុផលអ្វីដែរ ប្រសិនបើយើងពុំមានវិញ្ញាណ គឺដឹងច្បាស់អំពីកម្មវត្ថុរបស់រូបនោះទេ ។ រូបភាពផ្លែឈើមួយ ដែលយើងពុំដែលបានភ្លក់រសជាតិសោះ ទាំងពុំដែលបានធ្លាប់ឃើញពីមុនផង ពុំបង្ហាញអ្វីដល់យើងទេ ។ ដូច្នេះ នាម និងរូបចំណុះវិញ្ញាណ ។

## តើវិញ្ញាណចំណុះអ្វី ?

*១០. វិញ្ញាណចំណុះសង្ខារ ពោលគឺគ្រឿងប្រកប ឬការចាប់អារម្មណ៍ពីមុន ។* ខ្ញុំបានដឹងច្បាស់ថា ធ្លាប់មានលោក " ក " ជាមិត្តភ័ក្តិ ។ តើនេះ មានន័យយ៉ាងណា ? គឺបានន័យថា ខ្ញុំបានទទួលការផ្តិតអារម្មណ៍ផ្សេងៗពីលោក " ក " ៈ គាត់អញ្ជើញមកពីស្រុកជប៉ុន, គាត់ជាមនុស្សម្នាក់នៅវ័យក្មេង ឫកពារបសា, គាត់ជាប់ជិពាក់ចិត្តក្នុងការស្រាវជ្រាវសិល្បៈបុរាណខ្មែរ . ល . ។

ប្រសិនបើ ខ្ញុំលុបចោលម្តងមួយៗ នូវការផ្តិតជាប់អារម្មណ៍ទាំងនោះ ខ្ញុំនឹងពុំអាចមានការដឹងច្បាស់អំពីលោក " ក " ឡើយ ។ ដូច្នេះ វិញ្ញាណរួមមានឃុតមួយនៃការផ្តិតអារម្មណ៍ គឺសង្ខារ ហើយវាចំណុះការផ្តិតអារម្មណ៍ទាំងនោះ ។

# តើសង្ខារចំណេះអ្វី ?

*១១. សង្ខារចំណេះអវិជ្ជា* ។ អវិជ្ជា រួមមានការគិតពិចារណាថា វត្ថុឋិតថេរជាអចិន្ត្រៃយ៍ ហើយឥតប្រែប្រួល ។ តាមទស្សនៈអស្សិរូប (du vrai point de vue métaphysique) គ្មានអ្វីឋិតថេរដដែល (Semblable) ក្នុងខណៈពីរបន្តបន្ទាប់គ្នាទេ ។ អ្វីៗទាំងអស់ប្រព្រឹត្តទៅតាមអភិក្រមមួយជាប់លាប់ផ្ទាល់របស់វា ។

ការផ្ដិតអារម្មណ៍ទាំងអស់ ដែលខ្ញុំទទួលបានពីលោក " ក ", ខ្ញុំរួមបញ្ចូលការផ្ដិតអារម្មណ៍នោះជាមួយលោក " ក " ។ ប៉ុន្តែការពិត លោក " ក " ពុំមែនជាមនុស្សដដែល ដែលបានឃើញពីថ្ងៃមុនទេ ។ តើខ្ញុំមានសិទ្ធិអ្វីភ្ជាប់ការផ្ដិតអារម្មណ៍នោះជាមួយលោក " ក " ? *អំពើភ្ជាប់ការផ្ដិតអារម្មណ៍នេះ ចំណេះអវិជ្ជាជ្រាលជ្រៅរបស់យើង ពីព្រោះគ្មានអ្វីឋិតថេរជាអចិន្ត្រៃយ៍ឥតប្រែប្រួលទេ។*

អ្វីៗទាំងអស់ក្នុងលោកនេះ ឋិតក្នុងល័ក្ខខ័ណ្ឌបណ្ដោះអាសន្ន ។ អ្នកដែលមើលឃើញបញ្ហានេះ, គឺអ្នកដែលមានគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់បំផុត, អ្នកនោះមិនអាចចាត់ទុកវត្ថុមួយឋិតថេរ ដូចគ្នានឹងអ្វីដែលវត្ថុនោះមានក្នុងខណៈពីមុនទេ ។ ដូច្នេះគេមិនត្រូវធ្លាក់ក្នុងអវិជ្ជារហូតដល់រួមបញ្ចូលការផ្ដិតអារម្មណ៍ ( សង្ខារ ) យ៉ាងនេះឡើយ ។

ប្រសិនបើ គ្មានសង្ខារទាំងឡាយទេ, នោះក៏ពុំមានវិញ្ញាណដែរ ។ ប្រសិនបើ គ្មានវិញ្ញាណ នោះក៏គ្មាននាម និងរូបដែរ ។ ប្រសិនបើ គ្មាននាម និងរូប នោះក៏គ្មានអាយតនៈទាំងប្រាំមួយ ។ បើគ្មានអាយតនៈទាំងប្រាំមួយ (six bases) នោះក៏គ្មានផស្សៈ ។ បើគ្មានផស្សៈ នោះក៏គ្មានវេទនា (sensation) ។ បើគ្មានវេទនា នោះក៏គ្មានតណ្ហា (désir) ។ បើគ្មានតណ្ហា នោះក៏គ្មានឧបាទាន គឺការជាប់ជំពាក់ចិត្ត (Attachement) ។ បើគ្មានការជំពាក់ចិត្ត នោះក៏គ្មានភព គឺអត្ថិភាពក្នុងជីវិត

មនុស្ស ។ បើគ្មានភព នោះក៏គ្មានកំណើត ( ជាតិ ) ។ បើគ្មានកំណើតនោះ ក៏គ្មានមរណៈ ជរា ទុក្ខៈ ដែរ ។

ដោយប្រការដូចនេះហើយ ដែលព្រះបរមគ្រូទ្រង់ឃើញភាពបន្តរួមបញ្ចូលគ្នា ( Les séries assoeiées ) របស់បដិច្ចសមុប្បាទនៅក្រោមម្លប់ពោធិព្រឹក្ស នៅពុទ្ធគយា ។ នេះគឺជាការត្រាស់ដឹងដ៏សំខាន់ ដែលបានកើតឡើងក្នុងព្រះបញ្ញាញាណព្រះពុទ្ធ ។

ព្រះពុទ្ធ ទ្រង់ក្រោកឡើង ប្រកបដោយព្រះទ័យរីករាយដ៏សុក្រឹត ព្រះអង្គមានព្រះពុទ្ធដីកាថា :

*អនេកជាតិ សំសារំ សន្ធាវិស្សំ អនិព្វិសំ*
*គហការំ គវេសន្តោ ទុក្ខា ជាតិ បុនប្បុនំ ។*
*គហការក ទិដ្ឋោសិ បុន គេហំ ន កាហសិ*
*សព្វា តេ ផាសុកា ភគ្គា គហកូដំ វិសំខតំ ។*
*វិសង្ខារគតំ ចិត្តំ តណ្ហានំ ខយមជ្ឈគា ។*

*អនិច្ចា វត សំខារា ឧប្បាទវយធម្មិនោ*
*ឧបជ្ជិត្វា និរុជ្ឈន្តិ តេសំ វូបសមោ សុខោ ។*

" អស់ជាតិជាអនេកហើយ តថាគតបានស្វែងរកដោយឥតស្រាកស្រាន្តនូវ " ជាងសង់ផ្ទះ ( តណ្ហា ) " ទ្រាំទ្រនូវទុក្ខវេទនាផ្ទួនៗគ្នា ។

" ម្នាលជាងសង់ផ្ទះ អ្នកឯងត្រូវបានរកឃើញហើយ ។ អ្នកមិនអាចសង់ផ្ទះជាថ្មីទៀតទេ ។ រនូត រត ធ្នឹម ទាំងអស់ត្រូវកាច់បំបាក់ហើយ ។ ដំបូលរបស់អ្នកត្រូវបានបំបាក់ហើយ ។ ចិត្ត ( l'esprit ) ឥឡូវនេះ ត្រូវរំដោះផុតពីសង្ខារ ។ តណ្ហា ( ចំណង់ ) បានបាត់ទាំងស្រុងហើយ " ។

" សង្ខារទាំងអស់ គឺជាអនិច្ចតាធម៌ ( បណ្ដោះអាសន្ន ) ។ វាកើតឡើង រួចរលត់ទៅវិញ ។ ការរំលត់ជាទីបំផុតនៃសង្ខារទាំងនោះ គឺជាសុភមង្គល ដ៏ខ្ពស់បំផុត " ។

ដូច្នេះ ត្រូវយើងមើលអោយឃើញនូវអនិច្ចតាធម៌នៃលោក ហើយត្រូវពិចារណាលើអនិច្ចតាធម៌នេះ ។ នេះគឺជាគតិបណ្ឌិតដ៏ខ្ពស់បំផុត ។

## II. បឋមទេសនា

### ឆ្ពោះទៅកាន់ក្រុងបេណារ៉េស ( ពារាណសី )

ព្រះពុទ្ធបានឈ្វេងយល់ថា ព្រះធម៌ដែលព្រះអង្គទ្រង់បានត្រាស់ដឹងហើយ មានកំរិត ខ្ពស់ណាស់ ហើយជ្រាលជ្រៅណាស់ ដែលមនុស្សធម្មតាជាប់ជំពាក់ក្នុងការប្រកាន់ស្អិត ( les attachements ) នៃលោកពុំអាចយល់បាន ។ ប៉ុន្តែព្រះអង្គបានយល់ថា តាបសទាំង ៥រូប ដែលបានប្រព្រឹត្តតបធម៌ជាមួយព្រះអង្គនៅឧរុវេល អាចយល់ ព្រះធម៌នោះបាន ពីព្រោះតាបសទាំងនោះ មានភាពស្មោះត្រង់ ហើយមានប្រាជ្ញាវាងវៃក្នុងការស្វែងរកព្រះធម៌ ។ ព្រះបរមគ្រូបានសំរេចព្រះទ័យយាងទៅប្រទានពាក្យប្រៀនប្រដៅរបស់ព្រះអង្គ ចំពោះតាបសទាំង ៥រូប ជាមុនគេ ។ តាបសទាំងនោះ នៅពេលនោះបានរស់នៅឥសីបតនៈ ( សារនាថបច្ចុប្បន្ន ) ជិតក្រុងប៉េណារ៉េស ។ ព្រះអង្គបានទ្រង់យាងឆ្ពោះទៅតាម ទិសនោះ ។

### ការជួបជាមួយឧបកៈ

នៅពេលដែលព្រះពុទ្ធជាម្ចាស់ទ្រង់កំពុងយាងពីរដ្ឋគយា ទៅកាន់ក្រុងកាសី ដែលនៅទីនោះ ព្រះអង្គត្រូវសំដែង*ធម៌ទេសនាជាលើកទី ១*, ព្រះអង្គបាន

ជួបឧបកៈ ដែលជាអ្នកបួសគោចរ ( moine errant ) នៃនិកាយមួយផ្សេង ។ ឧបកៈ ពេលដែលបានជួបព្រះភ័ក្ត្រដ៏ភ្លឺចិញ្ចែញនៃព្រះពុទ្ធហើយ ក៏ពោលពាក្យចំពោះព្រះពុទ្ធថា :

- ណែមិត្ត, អ្នកអញ្ជើញទៅណា ?

ព្រះបរមគ្រូ បានឆ្លើយតបថា

" ធម្មចក្កំ បវត្តេតុំ គច្ឆាមិ កាសីនំ បុរំ " *" តថាគត ទៅកាន់ក្រុង កាសី ដើម្បីញ៉ាំងធម្មចក្កអោយប្រព្រឹត្តទៅ "* ។ ដោយប្រការយ៉ាងនេះឯង ទើបព្រះធម្មទេសនាដំបូងរបស់ព្រះអង្គនៅ ឥសិបតនៈ ( កាសី ) ត្រូវបានគេអោយឈ្មោះថា ធម្មចក្កប្បវត្តសូត្រ ឬថាការទេសនា ស្តីពីការញ៉ាំងចលនា នៃចក្ររបស់ធម៌អោយប្រព្រឹត្តទៅ ។

ព្រះធម៌ទេសនានោះរបស់ព្រះពុទ្ធ ត្រូវបានចាត់ទុកថា ជាព្រះធម៌ទី ១ មានសារៈ និងអត្ថៈជ្រាលជ្រៅនៃគម្ពីរព្រះត្រៃបិដក, ពីព្រោះព្រះធម៌នោះបានរៀបរាប់ស្ទើរតែគ្រប់ទិដ្ឋភាពនៃព្រះធម៌តាមបែបបទដ៏ច្បាស់លាស់ និងម៉ត់ចត់ ។

ព្រះធម៌ទេសនានោះ មានឈ្មោះប្រកបដោយអត្ថន័យជ្រាលជ្រៅណាស់, ពាក្យបាលី "ចក្កបវត្តនៈ" ញ៉ាំងចក្រអោយវិលទៅ" មានន័យមួយទៀតថា បដិវត្តន៍នៃចក្រ " ( la révolution de la roue ) ។ ព្រះពុទ្ធបានផ្តល់នូវទស្សនាទានថ្មីមួយអោយសាសនា ។ ព្រះធម៌ទេសនានោះ បានកំណត់នូវសម័យកាលមួយក្នុងប្រវត្តិសាស្ត្រនៃគំនិតខាងសាសនា ។

## នៅក្រុងប៉េណារ៉េសជាមួយតាបសទាំងប្រាំ

នៅពេលសមណៈទាំងប្រាំរូបមើលឃើញព្រះពុទ្ធនិមន្តមកពីចម្ងាយ, សមណៈទាំងនោះបានព្រមព្រៀងគ្នាថា :

"ឃើញទេ, ព្រះសិទ្ធត្ថ ដែលបានលះបង់ទុក្ករកម្មទាំងអស់ ហើយត្រឡប់ទៅជាសោយអាហារ និងស្លៀកពាក់ដូចគ្រហស្ថ កំពុងនិមន្តសំដៅមករកយើងហើយ ។ យើងមិនត្រូវទទួលលោកដោយគោរពទេ, ទាំងមិនត្រូវក្រោកឈរទទួលលោកដែរ ។ លោកអាចគង់ជិតយើងបានប្រសិនបើលោកចង់ "។

ប៉ុន្តែ នៅពេលដែលព្រះពុទ្ធយាងចូលកាន់តែជិត, សមណៈទាំងនោះក៏បានបោះបង់ចោលការសំរេចចិត្តរបស់ខ្លួនដែលបានព្រមព្រៀងគ្នា ។ ទាំងអស់គ្នាបានក្រោកឡើងទទួលព្រះអង្គ ។ ម្នាក់បានទទួលបាត្រពីព្រះអង្គ, ម្នាក់បានទទួលចីវរ, ម្នាក់ទៀតបានរៀបចំអាសនៈសម្រាប់ព្រះអង្គគង់, ម្នាក់ទៀតបានយកទឹកថ្វាយព្រះអង្គលាងជំរះ ព្រះកាយ ។

ព្រះពុទ្ធទ្រង់គង់ ហើយមានពុទ្ធដីកាថា :

- ណែមិត្តទាំងឡាយ, តថាគត ឥឡូវនេះបានត្រាសដឹងហើយ ។ ចូរអ្នកទាំងឡាយយកព្រះទ័យទុកដាក់ស្តាប់ : តថាគត នឹងសំដែងដល់អ្នកនូវព្រះធមិ ដែលតថាគតបានយល់ដឹង ។ ប្រសិនបើអ្នកប្រព្រឹត្ត បានសមស្រប, អ្នកនឹងទទួលបាននូវអ្វី ដែលអ្នកបានស្វែងរក ។

*តាបសទាំងប្រាំ បាននិយាយតបថា :*

- ណែសិទ្ធត្ថៈ, នៅពេលដែលលោកមិនបានសំរេចរកឃើញសច្ចធមិនៅពេលលោកប្រព្រឹត្តទុក្ករកម្ម តើលោកអាចជឿថា លោកបានត្រាស់ដឹងយ៉ាងពិតប្រាកដដូម្តេចកើត នៅពេលឥឡូវនេះ លោកបរិភោគ និងស្លៀកពាក់ ដូចគ្រហស្ថនោះ ?

ព្រះពុទ្ធមានពុទ្ធដីកាឆ្លើយតបថា :

តថាគតធ្លាប់បានប្រាប់អ្នករាល់គ្នាពីមុនថា តថាគត គឺជាព្រះពុទ្ធមួយអង្គ ។ ឥឡូវ តថាគត ជាព្រះពុទ្ធហើយ ហើយតថាគតប្រកាសថា តថាគតជាព្រះពុទ្ធ ។ ចូរស្តាប់តថាគត, តថាគតនឹងបង្រៀនដល់អ្នកទាំងឡាយ ។

តាបសទាំងប្រាំរូប ក៏ទទួលយល់ព្រមស្តាប់ការប្រៀនប្រដៅរបស់ព្រះបរមគ្រូ ។

## ព្រះបរមគ្រូទ្រង់សម្តែងធម៌ថា ៖

ម្នាលភិក្ខុ ! សមណៈទាំងឡាយ ត្រូវជៀសវាងអច្ចន្តភាពពីរយ៉ាង ។ តើអច្ចន្តភាពទាំងពីរនោះជាអ្វី ខ្លះ ?

១. កំណត់គោលដៅសំខាន់របស់ខ្លួន គឺសេចក្តីសប្បាយ និងសេចក្តីត្រេកត្រអាលក្នុងលោក, នេះ គឺជាអំពើថោកទាប គ្មានគតិបណ្ឌិត ហើយវាល្អសំរាប់តែមនុស្សសាមញ្ញប៉ុណ្ណោះ ។

២. ប្រព្រឹត្ត ទុក្ករកម្ម និងបតកម្ម, នេះគឺជាការឈឺចាប់, ជាហេតុនៃអកុសលកម្ម ហើយអំពើនេះ ត្រូវបានប្រព្រឹត្តតែដោយមនុស្សល្ងង់ប៉ុណ្ណោះ ។

ម្នាលភិក្ខុ ! ជៀសវាងបានអច្ចន្តភាពទាំងពីរនេះ, ព្រះពុទ្ធបានកំណត់ផ្លូវកណ្តាលដែលមានគតិបណ្ឌិត ហើយអនុញ្ញាតអោយចាប់បានពុទ្ធិដ៏ខ្ពស់បំផុតហើយនិងការបានសំរេចនូវការរំដោះទាំងស្រុង ឬ និព្វាន ។

*តើផ្លូវកណ្តាលដែលព្រះពុទ្ធ បានកំណត់គឺអ្វីខ្លះ ?*

ផ្លូវកណ្តាលនោះ ជាមាគ៌ាដ៏ប្រសើរ មានមែកប្រាំបី គឺ ៖

១. សម្មាទិដ្ឋិ

២. សម្មាសង្កប្បៈ

៣. សម្មាវាចា

៤. សម្មាកម្មន្តៈ

៥. សម្មាអាជីវៈ

៦. សម្មាវាយាមៈ

៧. សម្មាសតិ

៨. សម្មាសមាធិ

ម្នាលភិក្ខុ ! នេះគឺជាមជ្ឈិមបដិបទា ដែលនាំទៅដល់ការសំរេចបាននូវ និព្វាន ។

ព្រះបរមគ្រូ បានពិសោធផ្ទាល់នូវអច្ចន្តភាពទាំងពីរនេះ ។ កាលនៅជាព្រះអង្គម្ចាស់ សិទ្ធត្ថ លោកបានសោយសេចក្តីសប្បាយរីករាយ ដែលអាចមាននៅក្នុងលោកនេះ, ប៉ុន្តែព្រះអង្គបានមើលឃើញថា សេចក្តីសប្បាយទាំងនោះ គឺជាសេចក្តីសប្បាយបណ្តោះអាសន្ន ហើយនាំទៅដល់តែការសោកស្តាយ និងការព្រួយកង្វល់តែប៉ុណ្ណោះ ។ ព្រះអង្គ បានសាកល្បងបួសជាតាបសនៅឧរុវេលៈ, ប៉ុន្តែបានឃើញថាការបួសជាតាបសនេះ គឺជាការឈឺចាប់ និងគ្មានប្រយោជន៍ សំរាប់ការចាប់យកសច្ចធម៌បានទេ ។

ដូច្នេះ ព្រះអង្គបានហាមឃាត់ អច្ចន្តភាពទាំងពីរ នៅក្នុងបឋមទេសនាចំពោះសមណៈ ។ *ផ្លូវកណ្តាល ឬ អរិយអដ្ឋង្គិកមគ្គ* គឺជាផ្លូវឆ្ពោះទៅរកពុទ្ធិដ៏ខ្ពស់បំផុត មានសីលធម៌ដ៏បរិសុទ្ធបំផុត និងមានសង្កប្បៈ(Pensées) ជ្រាលជ្រៅបំផុត; វានាំទៅដល់ការវិវត្តន៍ដ៏សុក្រឹតសំរាប់មនុស្ស និងការរំដោះផុតទុក្ខទាំងស្រុងសំរាប់មនុស្ស ពោលគឺ និរោធ ( សេចក្តីរលត់ ) ។

## តើនិរោធ ( សេចក្តីរលត់ ) ជាអ្វីទៅ ?

មនុស្សខ្លះអាចនឹងសួរថា តើនិរោធគឺសេចក្តីរលត់ ជាអ្វី ? តើរលត់អ្វី ?

តើអ្វី ជាសេវភាព ( ការប្រើ, ការបំរើ ) ដែលយើងត្រូវប្រើសំរាប់គេចអោយផុតពីទុក្ខវេទនា ហើយមជ្ឈិមបដិបទា ( ការប្រតិបត្តិផ្លូវកណ្តាល ) យ៉ាងណាដែលអាចជាមធ្យោបាយតែមួយសំរាប់គេចចេញអោយផុតពីទុក្ខវេទនា ?

## ការប្រៀបធៀបជាមួយវេជ្ជវិទ្យា

ព្រះធម៌ អាចប្រៀបធៀបទៅនឹងវេជ្ជវិទ្យា ។ ព្រះពុទ្ធព្រះអង្គឯងត្រូវបានគេថ្វាយព្រះនាមថា " គ្រូពេទ្យដ៏ប្រសើរ " ។

វេជ្ជវិទ្យា អាចអនុវត្តទៅកើតតែកាលណាកត្តាបួនយ៉ាង ត្រូវបានប្រមូលផ្តុំ ។ វេជ្ជវិទ្យាត្រូវបញ្ជាក់ :

១. ជំងឺអ្វី ?

២. អ្វីជាមូលហេតុនៃជំងឺ ?

៣. តើអោយថ្នាំអ្វីសំរាប់បំបាត់ជំងឺនោះ ?

៤. តើស្ថានភាពសុខភាពដ៏ល្អប៉ុណ្ណា ដែលគេចង់សំរេចអោយបាន ?

## ពុទ្ធលទ្ធិសំដៅទៅរកការបំបាត់ទាំងស្រុង និងជាអវសាននៃទុក្ខវេទនាទាំងអស់

ដរាបណា គ្រូពេទ្យមិនស្គាល់ចំណុចទាំង ៤ នោះទេ គេពុំអាចសង្ឃឹមថា គ្រូពេទ្យនោះព្យាបាលជំងឺ អោយជាបានឡើយ ។

កត្តាទាំង ៤ យ៉ាងនៃវេជ្ជវិទ្យានោះ ត្រូវគ្នាដូចបេះបិទទៅនឹង " ចតុរារិយ-សច្ច " របស់ពុទ្ធលទ្ធិ ។

ប្រសិនបើយើងពិចារណាតែបន្តិចប៉ុណ្ណោះ យើងយល់បានថា តើទុក្ខវេទនាមានច្រើនយ៉ាង ហើយលំបាកលំបិនយ៉ាងណា ដែលមនុស្សជាតិបាន

ទទួលរង នោះ ។ ពិភពលោកគ្របដណ្តប់ដោយទុក្ខ ។ សេចក្តីឃ្លានស្រេក ត្រជាក់ កំដៅ ការខកចិត្ត ការបាត់បង់ ជរា ជំងឺ មរណភាព គឺជាសភាវៈរួមសំរាប់សព្វសត្វមានជីវិត ទោះជាមានឬ ក្រ ស្តេច ឬ ស្មូម ។ ជីវិតមនុស្ស គឺជាការប្រយុទ្ធជានិរន្តរ៍ ដើម្បីជៀសអោយផុតពីសេចក្តីទុក្ខព្រួយទៅតាមលទ្ធភាពដែលអាចធ្វើបាន ។ អំពើនីមួយៗ ដែលយើងបានធ្វើ ក៏ក្នុងន័យសំរាប់សុខុមាលភាពរបស់យើង ហើយក៏ ដើម្បីគេចអោយផុតពីភាពក្រីក្រ ឬពីការឈឺចាប់ដែលយើងបានយល់ដឹងនោះដែរ ទោះបីភាពក្រីក្រ ឬការឈឺចាប់នោះតិចតួច យ៉ាងណាក៏ដោយ ។ យើងបរិភោគ ក៏ព្រោះតែយើង ដឹងថាឃ្លាន យើងស្លៀកពាក់ខោអាវ ក៏ព្រោះតែយើងរងារ ។

*ពុទ្ធលទ្ធិ សំដៅទៅរកការរំដោះទាំងស្រុង និងជាអវសានពីទុក្ខតភាពគ្រប់យ៉ាងរបស់មនុស្សៈ គឺនិរោធ ( សេចក្តីរលត់ ) ឬនិព្វាន* ។ ចំណីអាហារ ឬសំលៀកបំពាក់ការពាររងារមិនអាចបញ្ចប់បានជាអវសាននូវសេចក្តីស្រេកឃ្លាន ឬត្រជាក់បានទេ ។ ថ្ងៃបន្ទាប់មកសេចក្តីស្រេកឃ្លាន និងត្រជាក់ ដដែលនោះត្រូវបានកើតមានដដែល ។

ការបំបាត់*ជាអវសាន និងទាំងស្រុង*នៃទុក្ខសោកគ្រប់យ៉ាង មានន័យថាគ្មានចំរៀកនៃទុក្ខសោកណាមួយកើតឡើងជាថ្មី ឬវិលត្រឡប់មកវិញនោះឡើយ ។

គឺមានតែព្រះពុទ្ធតែមួយអង្គគត់ដែលបានបង្រៀន*វិទ្យាសាស្ត្រស្តីពីការរំដោះអោយផុតពីទុក្ខ*ដែល ដូចជា វេជ្ជវិទ្យាស្តីពីរំដោះអោយផុតពីជំងឺដែរ, រួមមានកត្តា ៤ យ៉ាង ៖

១. ទុក្ខៈ ( ទុក្ខសច្ចៈ )

២. ហេតុនៃទុក្ខៈ ( សមុទយសច្ចៈ )

៣. ផ្លូវដែលនាំចេញផុតពីទុក្ខៈ ( មគ្គសច្ចៈ )

៤- ការរលត់ទុក្ខៈ ឬនិព្វាន ( និរោធសច្ចៈ )

កត្តាទាំង ៤ នេះមានឈ្មោះថា ចតុរារិយសច្ចៈ ។

## 1. ទុក្ខៈគឺជា អរិយសច្ចៈទីមួយ (ទុក្ខសច្ចៈ)

ព្រះពុទ្ធមានពុទ្ធដីកាថា :

" ម្នាលភិក្ខុ ! នេះគឺជាអរិយសច្ចៈនៃទុក្ខៈ ។ កើតគឺជាទុក្ខៈ, ជរា, ព្យាធិ, មរណៈ, រួមរស់ជាមួយអ្នកដែលខ្លួនមិនចូលចិត្ត, ព្រាត់ប្រាស់ពីអ្វីដែលខ្លួនស្រឡាញ់, មិនបានអ្វីដែលខ្លួនចង់បាន, ទាំងអស់នេះគឺជាទុក្ខៈ ។ សង្ខេបមក, សមាសភាគទាំងអស់នៃខន្ធទាំងប្រាំ ( ជា រូបនិងចេតសិក ) គឺជាទុក្ខៈ ។

(ជាញឹកញយ នៅក្នុងចំណោមអ្នកប្រាជ្ញសហសម័យ, គេបានថ្កោលទោសពុទ្ធលទ្ធិ ដោយអោយឈ្មោះថា" ទុទិដ្ឋិនិយម" ពីព្រោះតែពុទ្ធលទ្ធិបានរៀបរាប់ថា ពិភពលោកនេះពោរពេញដោយ សេចក្តីទុក្ខ, ទុគ្គតភាព និងសេចក្តីលំបាក ។ មិនមែនដូច្នោះទេ ពុទ្ធលទ្ធិ ពុំមែនជា ទុទិដ្ឋិនិយមទេ ។ ទុទិដ្ឋិនិយមយល់ថាពិភព-លោកនេះ ពោរពេញដោយទុគ្គតភាព ហើយ*គ្មានមធ្យោបាយណាមួយអាចគេចចេញអោយផុត បានឡើយ ។ ចំណែកឯពុទ្ធលទ្ធិវិញ បានប្រៀនប្រដៅមធ្យោបាយ ដ៏មានប្រសិទ្ធភាព បំផុត និងជាមធ្យោបាយតែមួយគត់ ដើម្បីចេញអោយផុតពីទុគ្គតភាពទាំងនោះ* ) ។

អ្នកប្រាជ្ញសម្ភារនិយមនិយាយថា : ពិតមែនហើយ នៅក្នុងលោកនេះមានទុក្ខវេទនា និងមានសេចក្តីសប្បាយ ។ រឿងសំខាន់តែមួយដែលយើងត្រូវធ្វើ គឺត្រូវខិតខំអោយអស់ពីលទ្ធភាពដែលយើងមាន ដើម្បីគេចអោយផុតពីផ្នែកអាក្រក់ ហើយចាប់យកផ្នែកល្អ ។ គ្រាប់ធញ្ញជាតិ ត្រូវបានគ្របដណ្តប់ដោយសំបក, ប្រសិនបើយើងចង់បានសាច់គ្រាប់ធញ្ញ ជាតិនោះ យើងត្រូវតែខិតខំបកសំបកចេញដើម្បីបានសាច់គ្រាប់ធញ្ញ ជាតិ ។ ដូច្នេះ គេត្រូវតែជៀសអោយផុតតាមដែលអាច

ធ្វើបាន អំពីទុក្ខវេទនា ហើយខិតខំចាប់យកអោយអស់លទ្ធភាព នូវសេចក្តីសប្បាយ។

## អ្វីជាសេចក្តីសប្បាយ ?

ចូរយើងប្រមើលមើលថា តើសេចក្តីសប្បាយនោះជាអ្វី ដែលយើងត្រូវប្រយុទ្ធដើម្បីចាប់យក ។

ឧ ទា ហ រ ណ៍

យើងសន្មតថា មានមនុស្សដ៏សែនក្រីក្រម្នាក់, ដែលមានទំលាប់រងការស្រេកឃ្លានជារៀងរាល់ថ្ងៃ ហើយស្រាប់តែរកបានមួយថ្ងៃមួយដុល្លារដោយសារពលកម្មរបស់គេ ។ អ្នកនឹកគិតទៅមើលថាតើគេសប្បាយយ៉ាងណាពេលគេត្រលប់មកលំនៅរបស់គេវិញ ហើយគេអាចហូបចុកជាមួយកូនប្រពន្ធរបស់គេនៅល្ងាចនោះ ។ ប៉ុន្តែ បើលោកមេធាវី ឬលោកវេជ្ជបណ្ឌិត ដែលធ្លាប់រកប្រាក់បានជាមធ្យមក្នុងមួយថ្ងៃ ១០០ ដុល្លារ ហើយបែរជាបានតែមួយដុល្លារទៅវិញ ក្រោយពេលបំពេញការងារអស់ពេលមួយថ្ងៃ, តើគេមានអារម្មណ៍ជាទុក្ខព្រួយយ៉ាងណា ? ព្រោះហេតុអ្វី ? ប្រាក់មួយដុល្លារដដែលគឺជា សេក្តីសប្បាយរីករាយចំពោះ មនុស្សម្នាក់ ហើយជាសេចក្តីទុក្ខព្រួយដ៏ធ្ងន់ធ្ងរ ចំពោះមនុស្សម្នាក់ផ្សេងទៀត ។ ហេតុអ្វីបានជាយ៉ាងហ្នឹង ?

តាមពិត, *វាគ្មានសេចក្តីសប្បាយ គ្មានសេចក្តីឈឺចាប់ជាបរានុម័តទេ* (Il n'y a ni plaisir ni douleur objectifs) ។ *តាមការប្រៀបធៀបគឺ វាមានសេចក្តីឈឺចាប់តិច ដែលយើងចាត់ទុកថា ជាសេចក្តីសប្បាយនោះ* ( C' est, " par comparaison moins de douleur," que nous considérons comme un plaisir) ។ តាមការជាក់ ស្តែងរកបានតែមួយដុល្លារ ក្រោយពេលធ្វើការអស់មួយថ្ងៃពុំមែនជា

ការរីករាយទេ, ប៉ុន្តែ នេះជាសេចក្តីសប្បាយចំពោះមនុស្សក្រ ពីព្រោះគេឋិតនៅក្នុងភាពគ្មានទីពឹង ដ៏ធំធេង ។

រកប្រាក់បាន ១០០ ដុល្លារ នឹងជាការទុក្ខព្រួយចំពោះអ្នកដែលធ្លាប់រកបាន ១.០០០ ដុល្លារ ។ ដោយហេតុនេះ អ្នកមិនអាចនិយាយថា : សេចក្តីសប្បាយគឺនេះ ឬនោះបានទេ ពីព្រោះសេចក្តី សប្បាយដដែលនេះ អាចជាសេចក្តីទុក្ខព្រួយចំពោះមនុស្សផ្សេង ដែលគេធ្លាប់មានកំរិតជីវភាពខ្ពង់ខ្ពស់ ។ វាមានថ្នាក់មានជាន់នៅក្នុងសេចក្តីសប្បាយ និងក្នុងសេចក្តីទុក្ខព្រួយជាការឥតប្រកែកបាន, ប៉ុន្តែ សេចក្តីសប្បាយ និងសេចក្តីទុក្ខព្រួយនេះ មិនអាចជាតថភាពបរានុម័តទេ ( Réalité objective ) ។ មនុស្សថ្នាក់មធ្យម ឋិតនៅឋានៈគ្រាន់បើ បើសិនប្រៀបជាមួយមនុស្សក្រ, ប៉ុន្តែ បើប្រៀបជាមួយមហាសេដ្ឋីវិញ, គេជាមនុស្សដ៏ទុគ៌តបំផុត ។ នៅក្នុងឈុតនៃសេចក្តីសប្បាយ និងសេចក្តីទុក្ខព្រួយនេះ យើងជាមនុស្សតែងឋិតនៅវាងអ្នកខ្ពស់ និងអ្នកទាបជាដរាប យើងគិតថា យើងមានសេចក្តីសប្បាយក្នុងការសំរេចចាប់យកបានវត្ថុអ្វីមួយ, យើងចង់បានវត្ថុនោះ, យើងជាប់ជំពាក់ចិត្តនឹងវត្ថុនោះ ។ កាលណាយើងបានវត្ថុនោះហើយ, វត្ថុនោះបាត់សម្រស់ ដែលយើងជាប់ចិត្ត ហើយយើងឋិតនៅជាអ្នកខ្វះសេចក្តីសប្បាយទៀត យើងក៏ស្វែងរកសេចក្តីសប្បាយថ្មីទៀត នៅក្នុងវត្ថុណាមួយផ្សេងទៀត ហើយយើងតែងរត់តាមរកសេចក្តីសប្បាយក្រោយមកទៀត ។ ដូច្នេះ សេចក្តីសប្បាយរមែងឋិតនៅឯនាយនៃការឈោងចាប់យករបស់យើងជាដរាប ។ យើងអាចរត់តាមចាប់យកសេចក្តីសប្បាយយ៉ាងខ្លាំងក្លាដូចម្តេចក្តី យើងក៏នៅតែតាមមិនទាន់ ពីព្រោះសេចក្តីសប្បាយនៅតែរត់ពីមុខយើងតាមល្បឿន ដដែល, បន្សល់ទុក្ខអោយយើងខកចិត្តជាដរាប ។

តាមរយៈពាក្យ " ទុក្ខៈ " ជាអរិយសច្ចៈទីមួយ, ព្រះបរមគ្រូបានចង្អុលបង្ហាញនូវ*ការរត់គេចនៃជីវិត*, ការបាននេះ និងការបាត់បង់នោះ,សេចក្តីសង្ឃឹមនេះ

និងសេចក្ដីខកចិត្តនោះ ។ ពុទ្ធិលទ្ធិមិនសំដៅតែអ្នកដែលជាប់ចិត្តនឹងការរត់តាមសេចក្ដីសប្បាយនោះទេ, ប៉ុន្តែ សំដៅ អ្នកដែលនឿយហត់ ក្នុងការរត់តាមនេះ ហើយស្វែងរកផ្លូវរំដោះខ្លួនអោយផុតពីភាពទុក្ខព្រួយ ។ អ្នកទាំងឡាយណាដែលចូលចិត្តរត់តាមសេចក្ដីសប្បាយ អាចនឹងបន្តការរត់តាមនោះ រហូតដល់ខ្លួនហត់ហោរខ្សោះដាច់ខ្យល់ស្លាប់ ។

*ពិភពលោក ទុកដូចជាគ្រែសំរាកដ៏សមរម្យមួយ ដែលនៅលើគ្រែនេះ គេបានបាចសាចបន្លាពាសពេញ* ។ អ្នកណាដែលចង់ក្រេបយករសជាតិសុខស្រួលពីដំណេកលើគ្រែនោះ ត្រូវតែត្រៀមខ្លួនក្នុងពេលដំណាលគ្នាដើម្បី រងការចាក់ឬមុតនៃបន្លាដែលរាយប៉ាយលើគ្រែនោះ ។ អ្នកត្រូវសំរេចចិត្តដោយខ្លួនឯងថាតើគ្រែបែបនេះ ជាការសប្បាយរីករាយ ឬជាការឈឺចាប់ ។

ព្រះពុទ្ធបរមគ្រូបានចង្អុលបង្ហាញថា មរណភាព ជរាភាព ការទួញសោក និងសេចក្ដីព្រួយកង្វល់ គឺជាបន្លាសំរាប់ជីវិតមនុស្ស ហើយដោយហេតុនេះ គឺជាទុក្ខៈ ឬជាសេក្ដីឈឺចាប់គ្មានអ្នកណាអាចប្រកែកបានទេ, យើងទាំងអស់គ្នាបានទទួលស្គាល់អត្ថិភាពនៃទុក្ខៈនោះយ៉ាងខ្លាំងក្លាលើសជាងអ្វី ៗ ដ៏ទៃទៀត ។

## 2. មូលហេតុនៃទុក្ខៈ គឺជាអរិយសច្ចៈទីពីរ ( សមុទយសច្ចៈ )

តើអ្វីទៅជាមូលហេតុនៃទុក្ខៈ ?

មនុស្សជំនាន់ដើមបានជឿថា មូលហេតុនៃទុក្ខៈបណ្ដាលមកពីកំហឹងនៃអាទិទេព ឬទេពធីតា ។ គេជឿថា ការវាយប្រហារដោយសត្រូវដ៏ខ្លាំងពូកែណាមួយ, សេចក្ដីទុក្ខព្រួយក្នុងរឿងស្នេហា, ភាពរាំងស្ងួត, ការរញ្ជួយផែនដី ទាំងអស់នេះត្រូវបានបណ្ដាលមកពីព្រះអាទិទេពក្រេវក្រោធខឹងសម្បារ ។ គេត្រូវតែគោរពព្រះអាទិទេព ទាំងនោះ, ថ្វាយពលីការដល់លោក ដើម្បីសុំលោកផ្ដល់ការអនុគ្រោះ។

ពួកគ្រីស្តសាសនិកជឿថា មនុស្សជាប់ជិតដាមដោយបាប ហើយជាមនុស្សទុគិត ពីព្រោះតែអាដាម (Adam) បានបរិភោគផ្លែឈើដែលត្រូវហាមឃាត់។

ពួកម៉ាហូម៉េត ( ឥស្លាមសាសនិក ) បានពន្យល់មូលហេតុនៃ*ទុក្ខៈ*តាមរយៈឆន្ទៈផ្តាច់ការដ៏កំពូលរបស់ព្រះអាល្លាស ឬអាទិទេព ។

សេចក្តីពន្យល់ទាំងអស់នេះ ពុំអាចធ្វើអោយពុទ្ធសាសនិកជនសូម្បីតែម្នាក់ពេញចិត្តបានឡើយ ពីព្រោះគេចង់បានសេចក្តីពន្យល់មានលក្ខណះវិទ្យាសាស្ត្រ ហើយមិនមែនជាសេចក្តីពន្យល់ផ្អែកលើអប្បិយជំនឿទេ ។ ការពន្យល់មានលក្ខណះវិទ្យាសាស្ត្រ គឺជាសេចក្តីពន្យល់ដែលផ្អែកលើមូលដ្ឋាន*វិចារណញ្ញាណ* គឺមិនមែនផ្អែកលើជំជឿក្នុងភ្នាក់ងារលោកកុត្តរស្រមើស្រមៃនោះទេ, និងផ្អែកលើការវិនិច្ឆ័យទៅតាមអ្វីដែលយើងមើលឃើញដោយខ្លួនយើងនៅក្នុងជីវិតនេះ ។

ព្រះបរមគ្រូមានបន្ទូលថា *មូលហេតុនៃទុក្ខៈ គឺតណ្ហាផ្ទាល់ខ្លួនយើង ឬចំណង់ ( ការជាប់ជំពាក់ចិត្ត បាបចិត្ត ស្នេហា )*។ មនុស្សម្នាក់សោកសៅចំពោះការបាត់បង់វត្ថុអ្វីមួយ ដែលមានកំរិតធ្ងន់ ឬស្រាល ដោយយោលទៅតាមការជាប់ជំពាក់ចិត្ត ដែលមនុស្សនោះមាន ចំពោះវត្ថុដែលបាត់បង់នោះ ។ មនុស្សម្នាក់យំសោក ហើយរងទុក្ខវេទនាប្រសិនបើផ្ទះរបស់គេឆេះ, ពីព្រោះគេស្រឡាញ់ផ្ទះនោះ, ប៉ុន្តែ គេពុំមានទុក្ខក្រៀមក្រមទេ ប្រសិនបើផ្ទះឆេះនោះ ជារបស់អ្នកដទៃ ។ នៅគ្រប់ទីណាដែលមានការជាប់ជំពាក់ចិត្ត ចំណង់ និងស្រឡាញ់ យើងតែងឃើញជានិច្ចនូវទុគ្គតភាពគ្រប់យ៉ាង ។

ព្រះពុទ្ធមានពុទ្ធដីកាថា :

" ម្នាលភិក្ខុ ! នេះគឺជា*អរិយសច្ចនៃសមុទយទុក្ខ* ( មូលហេតុនៃទុក្ខ )។ គឺចំណង់ ( តណ្ហា ) ដែលបណ្តាលអោយមានភពថ្មីនោះឯង, ដែលញ៉ាំងយើងអោយរត់តាមពីក្រោយនៃសេចក្តិសប្បាយ និងសេចក្តីរីករាយនៃលោកនេះ " ។

## ចំណង់ (តណ្ហា) បណ្តាលអោយមានការកើតទៀត (ភពថ្មី)

តើយើងអាចនិយាយបានឬទេ ថាតើជីវិតរួមមានអ្វីខ្លះ ?

យើងអាចអានជីវិតរបស់លោកសេកស្ប៉ៀរ (Shakespeare) ជាកវី, ឬជីវិតរបស់លោកណាប៉ូលេអុង (Napoléon) ជាអ្នកធ្វើសញ្ជ័យ, ឬក៏ជីវិតរបស់ព្រះសិទ្ធត្ថជាព្រះពុទ្ធ, ប៉ុន្តែមានអ្វី ជាកត្តាមូលដ្ឋាន ដែលតាមរយៈនេះ ជីវិតនីមួយៗត្រូវបានដឹកនាំទៅនោះ ?

មែនហើយ ជីវិតរបស់លោកសេកស្ប៉ៀរ ត្រូវបានដឹកនាំដោយ*ចំណង់ដើម្បីពិពណ៌នាប្រភេទមនុស្ស* ឬចរិតមនុស្ស ហើយបង្ហាញមនោសញ្ចេតនាដ៏ល្អិតល្អន់អំពីស្នេហាតាមរយៈចម្រៀង និងកំណាព្យ (ាំឧហបភទ) ។ យើងអាននៅក្នុងជីវិតរបស់លោក ថាតើលោកសំរេចបានជោគជ័យនៅក្នុងលំដាប់ថ្នាក់នេះប៉ុណ្ណា និងបរាជ័យប៉ុណ្ណា ។ ជីវិតរបស់ណាប៉ូលេអុង ត្រូវបានដឹកនាំដោយ*ចំណង់ដើម្បីធ្វើសញ្ជ័យ* ហើយដាក់តាំងរាជាណាចក្រ ។ យើងអាននៅក្នុងជីវិតរបស់ណាប៉ូលេអុងនូវអ្វីដែលលោកបានធ្វើសំរាប់ការណ៍នេះ, កាលណាលោកបានទទួលជោគជ័យហើយ លោកត្រូវបានដួលរំលំយ៉ាងម៉េច ។ ជីវិតរបស់ព្រះសិទ្ធត្ថ ត្រូវបានដឹកនាំដោយ*ចំណង់ដើម្បីធ្វើសញ្ជ័យលើទុក្ខៈ* ហើយយើងអាននៅក្នុងជីវិតរបស់លោកថាតើលោកបានបំពេញទុក្ករកម្មយ៉ាងណា, លោកធ្វើសមាធិយ៉ាងណា ហើយលោកបានសំរេចនិព្វានយ៉ាងណា ។

ដូច្នេះ ជីវិតរបស់យើងមាននៅក្នុងចំណង់ផ្ទាល់ខ្លួន និងការជាប់ជំពាក់ចិត្តដែលយើងមាននៅក្នុងចំណង់នេះ ។ យើងមិនអាចនឹកប្រឌិតឡើងនូវមនុស្សណាម្នាក់ ដែលគ្មានចំណង់សោះនោះទេ, ពីព្រោះ បើធ្វើដូច្នេះយើងបានដកចេញពីមនុស្សនោះ នូវអ្វីដែលជាជីវិតរបស់គេផ្ទាល់ ។

នៅគ្រប់ទីកន្លែងណាដែលមានតណ្ហាគឺចំណង់, នៅគ្រប់ទីកន្លែងនោះ, វា

តែងមានការជំពាក់ចិត្តចំពោះសមិទ្ធកម្ម, ជោគជ័យ និងបរាជ័យ, សេចក្ដីសង្ឃឹម និងការខកចិត្តរបស់គេ ។ ដោយប្រការយ៉ាងនេះ អភិក្រមនៃជីវិត ចេះតែបន្តទៅ ។ កន្លែងណាពុំមានចំណង់ គឺតណ្ហាទេ, កន្លែងនោះ ក៏គ្មានការជំពាក់ចិត្ត គ្មានជីវិត គ្មានចាស់ជរា គ្មានមរណភាពដែរ ។

អភិក្រមនៃជីវិត ចេះតែបន្តទៅដរាបណាមានចំណង់ (តណ្ហា) ដែលជាកត្តាដឹកនាំ ។ ទោះជាវាមានចរិតធំធេងយ៉ាងណាក្ដី ការផ្លាស់ប្ដូរនៅក្នុងអង្គកាយ មិនបានបញ្ឈប់អភិក្រមនៃជីវិតបានទេ ។ មរណភាព គឺគ្រាន់តែជាការផ្លាស់ប្ដូរនៅក្នុងអង្គកាយតែប៉ុណ្ណោះ ។ អភិក្រមនៃជីវិតចេះតែបន្ត ប្រសិនបើចំណង់ (តណ្ហា) នៅតែមាន, ទោះបីជាក្រោយពេលស្លាប់ទៅក៏ដោយ ។ ដោយហេតុនេះ ព្រះបរមគ្រូបានមានបន្ទូលថា : "តណ្ហា បោ ៃ នា ភវិកា" ចំណង់គឺជាមូលហេតុនៃការកើតជាថ្មី ពោលគឺតណ្ហារក្សានិរន្តរភាពនៃអភិក្រមនៃជីវិត សូម្បីក្រោយពេលស្លាប់ហើយក៏ដោយ ក៏វានៅតែបោះយើងទៅក្នុងការរត់ប្រណាំងដើម្បីសេចក្ដីសប្បាយ និងសេចក្ដីរីករាយស្រើបស្រាលនៃលោកនេះដែរ ។

ដោយហេតុនេះ ចំណង់ ឬតណ្ហា គឺជាមូលហេតុនៃទុក្ខៈ ។ ប្រសិនបើយើងចង់រំដោះខ្លួនយើងអំពីទុក្ខៈ, មធ្យោបាយតែមួយគឺ ត្រូវយកឈ្នះលើចំណង់របស់យើង ។ កាលណាគ្មានចំណង់ទេ, វាក៏ពុំមានជីវិត ហើយក៏ពុំមានទុក្ខៈដែរ ។ មាគ៌ាដើម្បីរំលត់នូវទុក្ខៈ គឺអរិយសច្ចទីបី ។

## 3. មាគ៌ាដើម្បីចេញផុតពីទុក្ខៈ គឺអរិយសច្ចទីបី (មគ្គសច្ចៈ)

មូលហេតុនៃទុក្ខៈគឺ " ចំណង់ " ។ ចូរយើងយកជ័យជំនះលើ "ចំណង់" នោះវានឹងមិនមានទុក្ខៈទេ ។ ប៉ុន្តែ តើត្រូវយកជ័យជំនះលើចំណង់យ៉ាងដូចម្ដេច ?

ព្រះពុទ្ធទ្រង់បានប្រៀបធៀប*ចំណង់ទៅនឹងភ្លើងកំពុងឆេះ* ។ ភ្លើង

ចំណង់នេះត្រូវបានបំប៉ន និងថែទាំដោយគ្រឿងឥន្ធនៈដែលជាអំពើអកុសលរបស់យើងផ្ទាល់ ។ យើងកាន់តែប្រព្រឹត្តអំពើអកុសលច្រើន, ងងើកភ្លើងតណ្ហា ក៏កាន់តែឆេះសន្ធោសន្ធៅខ្លាំងដែរ ។

ក្មេងប្រុសម្នាក់បានឃើញនៅក្នុងដៃរបស់មិត្តរួមថ្នាក់វា នូវខ្មៅដៃមួយដើមដ៏ល្អ, វាមានចំណង់យកខ្មៅដៃនោះ : តើអញនឹងទៅយកឬ ? ទេ, គឺជាអំពើឧក្រិដ្ឋ ។ ម្យ៉ាងទៀត, ប្រសិនបើជាគេទាន់, មិត្តភ័ក្តិអញនឹងមើលងាយអញទុកដូចជាចោរ ។ លោកគ្រូ ក៏នឹងធ្វើទោសអញយ៉ាងធ្ងន់ធ្ងរ " ។ ទោះជាយ៉ាងនេះក៏ដោយ គឺដោយសារតែនឹកគិតដល់ខ្មៅដៃនោះ, វាពុំអាចគ្រប់សង្កត់លើចំណង់ចង់បានខ្មៅដៃដ៏ល្អនោះបាន ហើយវាក៏បានលួចយកដោយលាក់កំបាំង ។ លើកក្រោយបន្តមក, វាបានឃើញស៊ីឡូមួយ ហើយវាមានចំណង់ចង់បានទៀត ។ លើកនេះការតស៊ូទប់ទល់នឹងចំណង់នេះពុំសូវជាខ្លាំងក្លាប៉ុន្មាន ដូចជាលើកទី១ ទេ, ពីព្រោះចំណង់ត្រូវបានទទួលកំលាំងតាមរយៈអំពើអកុសលនៃការលួចលើកទី១ រួចហើយ ។ ក្មេងប្រុសនោះ ក៏បានលួចយកស៊ីឡូនោះទៀត ។ ក្នុងផ្លូវនេះ, វាកាន់តែលួចច្រើនដង, ចិត្តបាបចង់លួច ក៏កាន់តែមានកំលាំងខ្លាំងឡើងដែរ ។ ដោយហេតុនេះ អកុសលកម្ម ដែលយើងបានបណ្តោយចិត្តតាម បានផ្តល់អោយយើងនូវបាបចិត្ត នាំអោយចង់ប្រព្រឹត្តអកុសលកម្មទាំងនោះដដែល១ *ហើយផ្តល់កំលាំងអោយចំណង់កាន់តែខ្លាំងឡើង* ។

## ក. សីល

ដូច្នេះ អំពើជាដំបូងបង្អស់ដែលយើងត្រូវធ្វើគឺ ទប់ស្កាត់ចិត្តយើងអោយនៅក្រៅអំពើអកុសលគ្រប់យ៉ាង និងអំពើអាក្រក់ទាំងអស់ ។ អំពើនេះ ព្រះពុទ្ធទ្រង់អោយឈ្មោះថា " សីល " ។ " សព្វបាបស្ស អករណំ, " ចូរអ្នកកុំធ្វើអំពើអាក្រក់ណាមួយឡើយ ។ ប្រសិនបើយើងប្រកាន់ខ្ជាប់នូវសីល ហើយមិនបាន

ប្រព្រឹត្តអំពើអកុសលណាមួយទេ, ភ្លើង-ចំណង់របស់យើង នឹងពុំទទួលវត្ថុធាតុថ្មីនៃគ្រឿងឥន្ធនៈសំរាប់ទ្រទ្រង់ភ្លើង-ចំណង់នោះ អោយឆេះឆំ ឬសន្ធោសន្ធៅបានឡើយ ។ ដោយហេតុនេះ វិន័យរបស់ពុទ្ធសាសនា មានចរិតហាមឃាត់ទាំងអស់ ។ *ចូរកុំទ្រទ្រង់ភ្លើង* - ចំណង់ដោយអំពើអាក្រក់ឡើយ ។

ប៉ុន្តែ អំពើអាក្រក់ទាំងនោះ ដែលយើងបានធ្វើនៅក្នុងជីវិត ដ៏ច្រើនឥតគណនាកន្លងទៅ ក៏បានផ្តល់កំលាំងយ៉ាងខ្លាំងក្លាជាស្រេចមកហើយលើចំណង់របស់យើងដែរ ។ យើងអាចមិនបន្ថែមកំលាំងអោយវាដោយមិនប្រព្រឹត្តអំពើអាក្រក់ថ្មី, ទោះបីជាដូច្នេះ, ក៏វានៅតែមានកំលាំងគ្រប់គ្រាន់សំរាប់ទ្រទ្រង់រលក នៃជីវិតអស់កប្បកល្បជាច្រើន ។ ប្រពលភាពនៃជីវិត ត្រូវតែបានទប់ស្កាត់ និងធ្វើអោយខ្សោយចុះ ។

## ខ- សមាធិ

ការទប់ស្កាត់និងធ្វើអោយខ្សោយចុះនូវប្រពលភាពនៃជីវិតនេះ យើងអាចធ្វើបានតាមរយៈសមាធិ ។ ដោយការពិចារណាលើសេចក្តីស្រឡាញ់ជាសកលនិងការស្រឡាញ់រាប់អានដ៏ស្មើ យើងអាចធ្វើអោយខ្សោយចុះ នូវមនោសញ្ចេតនាអមិត្ត ស្អប់ និងឥច្ឆា ។ តាមការត្រិះរិះពិចារណាលើអនិច្ចតាធម៌នៃសេចក្តីសប្បាយនៃលោកនេះ, យើងអាចធ្វើអោយចុះខ្សោយនូវការប៉ុនប៉ងចង់ស្វែងរកសេចក្តីសប្បាយទាំងនោះ ។

ចោរដឹងថាលួចទ្រព្យគេ គឺជាឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរ, ប៉ុន្តែ វានៅតែស្វែងរកឱកាសដើម្បីលួចទ្រព្យអ្នកដទៃ ហើយក៏មិនញញើតនឹងលួចដែរ នៅពេលឱកាសហុចអោយ ។ តើពីព្រោះហេតុអ្វី ? ព្រោះហេតុអ្វីបានជាមនុស្សម្នាក់ ដឹងយ៉ាងច្បាស់ថា អំពើមួយនោះអាក្រក់ហើយ ប៉ុន្តែគេនៅតែធ្វើអំពើនោះទៀត ? មែន, រឿងនេះកើតមានដូច្នេះ, ពីព្រោះអំពើអាក្រក់ធ្វើដដែលៗ ច្រើនដងទៅ អារម្មណ៍

ផ្ចិតជាប់ក្នុងចិត្តដែលបានកើតឡើង មានកំលាំងខ្លាំងណាស់ ទាល់តែយើងពុំអាចបញ្ឈប់អំពើនោះបាន ទោះបីជាយើងមានចំណង់ចង់បញ្ឈប់អំពើនោះក៏ដោយ ។ មនុស្សម្នាក់ស្រែកយំទ្រហោនៅពេលណាគេទទួលបានលទ្ធផលអាក្រក់ នៃអកុសលកម្មរបស់គេ ហើយមានចិត្តចង់បោះបង់អំពើអាក្រក់ទាំងនោះចោល ។

ប៉ុន្តែ មួយរយៈពេលក្រោយមក, គេភ្លេចអស់រលីង ហើយគេចាប់ប្រព្រឹត្តអំពើអាក្រក់ទៀត ។ នេះហើយគឺជាក្រញាំនៃបាបកម្មគ្របសង្កត់មកលើយើង ។ ប្រសិនបើយើងចង់ធ្វើអោយនិន្នាការទាំងនោះចុះខ្សោយ, ការធ្វើសមាធិគឺជាមធ្យោបាយតែមួយគត់ ។ បើឧក្រិដ្ឋជនចង់បោះបង់ឧក្រិដ្ឋកម្មដែលគេធ្លាប់តែបានធ្វើនោះ, *គេត្រូវតែធ្វើសមាធិរៀងរាល់ថ្ងៃ ពិចារណាលើអំពើអាក្រក់ដែលកើតមាននៅក្នុងអំពើឧក្រិដ្ឋទាំងនោះ* ។ គេអាចធ្វើអោយបាបចិត្តចុះខ្សោយ ហើយថ្ងៃណាមួយត្រូវរំដោះខ្លួនផុតពីឧក្រិដ្ឋកម្ម ។

កម្មវត្ថុដ៏ប្រសើបំផុតសំរាប់ការធ្វើសមាធិ គឺអនិច្ចៈ និងទុក្ខៈ ។ អ្វីៗទាំងអស់នៅ ក្នុងលោកនេះគឺ " អនិច្ចៈ" ឬ អចិរភាព ( Impermanence ) និងទុក្ខៈ ឬការឈឺចាប់ ។

ប្រជាជាតិទាំងឡាយ ត្រូវបានកកើតឡើង ហើយរលាយបាត់ទៅវិញ, រាជាណាចក្រទាំងឡាយត្រូវបានស្ថាបនាឡើង រួចបាត់បង់ទៅវិញ, ប្រាសាទដ៏ស៊ីមស្មែត្រូវបានកសាងឡើង ហើយរលំខ្ទេចខ្ទីទៅជាធូលីទៅវិញ ។ នោះហើយ គឺជាមាតិាមួយរបស់លោកនេះ ។ បុប្ផាដ៏ល្អៗ រីកស្គុសស្គាយ ទាក់ទាញចិត្តអ្នកផងទាំងពួងដែលដើរជិតនោះ, ប៉ុន្តែ នៅថ្ងៃបន្ទាប់មក បុប្ផាទាំងឡាយនោះ ក៏ត្រូវស្រពោនហើយស្វិត ។ លំអងកេសរ ឬស្រទាប់ផ្កា ធ្លាក់ចុះម្តងមួយ ម្តងមួយ ហើយទីបំផុតបុប្ផាទាំងនោះត្រូវគេបំភ្លេចចោល ។ សេចក្តីសប្បាយទាំងអស់ (កាម) ហើយនិងសមិទ្ធផលដ៏សំខាន់ៗ នៃពិភពលោក ក៏គ្រាន់តែជាការលាតត្រដាងបង្ហួតបណ្តោះអា-

សន្មមួយគ្រា២ ប៉ុណ្ណោះ ។ អ្នកដែលបានក្រេបរសជាតិនៃសេចក្តីសប្បាយ នឹងត្រូវសោកសៅ ហើយទួញយំក្នុងពេលដែលសេចក្តីសប្បាយ (កាមៈ) ត្រូវរលាយបាត់ទៅ ហើយគេនឹងទទួលរងការឈឺចាប់ដ៏ធំធេង ។ ដោយហេតុថា គ្មានអ្វីឋិតថេរទេនៅក្នុងលោកនេះ គេមិនត្រូវស្រើបស្រាលចំពោះលោកនេះទេ ។ យើងត្រូវពិចារណាលើភាពមិនឋិតថេរនៃពិភពលោកនេះ ហើយនិងលើទុក្ខសោកផ្សេងៗទៀត ។

## គ. បញ្ញា

សំរេចបាន" អនិច្ចៈ និង ទុក្ខៈ" គឺជាគុណធម៌ដ៏ខ្ពង់ខ្ពស់បំផុត ហើយមនុស្សណាដែលសំរេចបានគុណធម៌នេះ មនុស្សនោះមិនអាចជាប់ក្នុងចំណងនៃភាពមិនឋិតថេរ និងទុក្ខៈ (ការឈឺចាប់) បានឡើយ ។ កូនក្មេងម្នាក់ រត់តាមចាប់ស្រ-មោល ដរាបណាវាពុំទាន់បានយល់ថា ស្រមោលនោះជាអ្វីនៅឡើយ ។ នៅពេលណាវាបានយល់ហើយ, វាក៏លែងយកចិត្តទុកដាក់ចំពោះស្រមោលនោះទៀតហើយ ។

គុណធម៌ដ៏ខ្ពង់ខ្ពស់បំផុតនេះ សម្លាប់ទាំងស្រុងនូវចំណង់ " តណ្ហា " ដែលជាឫគល់នៃទុក្ខៈ ។

ហេតុនេះ ព្រះពុទ្ធទ្រង់ប្រៀនប្រដៅថា : ចំណង់ (តណ្ហា) គឺជាមូល-ហេតុនៃទុក្ខៈ ។ ដើម្បីរំដោះខ្លួនអោយផុតពីទុក្ខៈ, គេត្រូវតែបំផ្លាញចំណង់ទាំងស្រុង និងអស់រលីង ។ ចូរកុំបន្ថែមកំលាំងអោយចំណង់ដោយប្រព្រឹត្តអំពើអាក្រក់នោះឡើយ , ដូច្នេះ ១. សីល ធ្វើអោយចំណង់ចុះខ្សោយដោយ ការធ្វើសមាធិ ២. សមាធិ កំចាត់បង់ចំណង់ដោយការរកឃើញគុណធិមដ៏ខ្ពង់ខ្ពស់បំផុត ( La plus Haute Sagesse ) ដែលជា : ៣. បញ្ញា ។

នេះគឺជាផ្លូវនាំអោយចេញផុតពីទុក្ខ ។ ព្រះបរមគ្រូ ទ្រង់ហៅផ្លូវនេះថា

មជ្ឈិមបដិបទា (la Voie Moyenne) ពីព្រោះ ការប្រតិបត្តិនេះ បញ្ចៀសផុតពីអច្ចន្តភាពទាំងពីរ ដូចដែលយើងបានឃើញរួចហើយ ។ គុណធម៌ទាំងបីគឺ ១. សីល ២. សមាធិ, ៣. បញ្ញា, បើយើងវិភាគអោយយល់ច្បាស់លាស់នោះ ត្រូវពិចារណាកត្តាប្រាំបី គឺ :

**សីល :**

១. សម្មាវាចា ៣. សម្មាអាជីវោ

២. សម្មាកម្មន្តោ ៤. សម្មាវាយាមោ

**សមាធិ :** **បញ្ញា :**

៥. សម្មាសតិ ៧. សម្មាទិដ្ឋិ

៦. សម្មាសមាធិ ៨. សម្មាសង្កប្បោ

នេះគឺជាមជ្ឈិមបដិបទា ដ៏ជាអរិយអដ្ឋង្គិកមគ្គរបស់ពុទ្ធលទ្ធិ ។

## 4. សេចក្ដីរលត់ ឬនិព្វាន គឺជាអរិយសច្ចៈទីបួន (និរោធសច្ចៈ)

ដោយមានចំណង់ត្រូវបានបន្សាត់បង់ហើយ, អភិក្រមនៃជីវិតជាមួយនឹងការឈឺចាប់ទាំងអស់នៃជីវិត នឹងមិនបន្តទៅទៀតទេ ។ នេះគឺជានិព្វាន : ការរលត់សេចក្ដីសោកសៅ និងទុក្ខទោសទាំងអស់ ។

អស់រយៈពេលយូរប៉ុណ្ណាដែលចរន្តអគ្គីសនីឆ្លងកាត់, កង្ហារបន្តវិលអស់រយៈពេលនោះ ។ បើអ្នកបញ្ឈប់ចរន្ត, កង្ហារក៏ឈប់វិល ។ គ្មានហេតុ, នោះវាក៏គ្មានផលដែរ ។

ដូចគ្នានេះដែរ, ជាមួយនឹងការបញ្ឈប់នៃចំណង់អធិក្រមនៃជីវិត ក៏ឈប់

លែងមានដែរ ។ គឺជាការនោតល្ងង់ បើគេសួរថា : " តើមនុស្សនឹងទៅជាអ្វី ក្រោយពេលបានដល់និព្វានហើយ " ពីព្រោះវាដូចគ្នានឹងការសួរថា : " តើចលនាកង្ហារ នឹងទៅជាយ៉ាងណា កាលណាចរន្តអគ្គីសនីត្រូវផ្តាច់ " ។ វាគ្មានចលនាកង្ហារ ពីព្រោះវាគ្មានចរន្តអគ្គីសនី ។ វាគ្មានទុក្ខៈ ពីព្រោះវាគ្មានចំណង់ ។

ព្រះពុទ្ធមានពុទ្ធដីកា ចំពោះបញ្ចវគ្គីយភិក្ខុទៀតថា :

" ម្នាលភិក្ខុ តថាគតមិនបានប្រកាសថា តថាគតបានសំរេចព្រះធម៌មុនតថាគតបានសំរេចដោយខ្លួនតថាគតទេ ។ ឥឡូវនេះ តាំងតែពីតថាគតបានសំរេចគុណធម៌ដ៏ខ្ពង់ខ្ពស់បំផុតមក ហើយបានបំផ្លាញទាំងស្រុងនូវចំណង់, តថាគត គឺជាព្រះពុទ្ធរំដោះផុតពីការកើត និងការស្លាប់ហើយ " ។

ពោរពេញដោយសោមនស្សចេតនា, បញ្ចវគ្គីយភិក្ខុ បានត្រងត្រាប់គ្រប់សព្វនូវអ្វីដែលព្រះពុទ្ធបានប្រៀនប្រដៅ ។ ក្រោយការស្តាប់ធម៌ទេសនានោះ, ព្រះកោណ្ឌញ្ញៈបានយល់យ៉ាងសព្វគ្រប់ នូវវិជ្ជាដ៏ មានកិរិតខ្ពស់បំផុត : " អ្វីៗទាំងអស់ដែលកើតឡើងហើយ រមែងរលត់ទៅវិញ " ។

ព្រះបរមគ្រូទ្រង់ទតឃើញទឹកព្រះភក្រ្តដ៏ភ្លឺថ្លានៃព្រះកោណ្ឌញ្ញៈ ហើយព្រះអង្គក៏បន្លឺព្រះវាចាថា: " កោណ្ឌញ្ញបានយល់ហើយ ! កោណ្ឌញ្ញបានយល់ហើយ ! ភិក្ខុទាំងប្រាំអង្គ បានជឿយ៉ាងស៊ុក្រឹតនូវទ្រឹស្តីដែលព្រះបរមគ្រូបានប្រៀនប្រដៅ ហើយបានប្រគល់ខ្លួនជាសាវ័កដំបូងរបស់ព្រះពុទ្ធ ។ គេហៅភិក្ខុទាំងប្រាំរូប នៅពេលនោះថា " បញ្ចវគ្គីយភិក្ខុ " ។

*(នៅមានត)*

# រឿងកាឡយក្ខិនី

រឿងនេះ មាននៅក្នុងគម្ពីរធម្មបទដ្ឋកថា ភាគទី១

សម័យមួយ ព្រះបរមសាស្តាគង់នៅក្នុងវត្តជេតពន ជាអារាមរបស់អនាថបិណ្ឌិក ទៀបក្រុងសាវត្ថី ទ្រង់សំដែងធម៌ទេសនាប្រោសនាងកាឡយក្ខិនី ដោយគាថា មានបទថា *" ន ហិ វេរេន វេរានិ... ពៀរទាំងឡាយមិនដែលស្ងប់រម្ងាប់ដោយការចងពៀរទេ ..."* ដូច្នេះជាដើម ។

រឿងនេះ មានសេចក្តីថា " កាលនោះ មានគ្រួសារកុដុម្ពីក៏មួយ មានកូនប្រុសម្នាក់ ។ កាលបិតាធ្វើមរណកាលទៅ បុត្រនោះឯងតែងធ្វើកិច្ចការសព្វសារពើបំរើម្តាយ ។ មាតាឃើញកូនលំបាកដូច្នេះ ក៏និយាយលួងលោមថា " នែកូន ! ម្តាយនឹងរកប្រពន្ធអោយឯង " ។ កូននោះប្រកែក, តែដោយម្តាយអង្វរញយៗទៅ ក៏សុខចិត្តព្រមទទួលយកប្រពន្ធ ។ មាតាក៏ទៅស្តីដណ្តឹងធីតាម្នាក់ អោយធ្វើជាប្រពន្ធតទៅ តែជាអកុសល ប្រពន្ធនោះជាស្ត្រីអារ ។ ឃើញយ៉ាងនេះ ម្តាយក៏និយាយនឹងកូនថា " នែកូន ! ប្រពន្ធឯងជាស្ត្រីអារ, ធម្មតាត្រកូលដែលមិនមានកូន ប្រាកដជានឹងដាច់វង្សត្រកូលមិនខានទេ, ដូច្នេះ យើងនឹងរកប្រពន្ធអោយឯងមួយទៀត " ។

ប្រពន្ធដើមជាស្ត្រីអារនោះ បានដឹងរឿងនេះ ក៏គិតថា " ធម្មតាកូន មិនអាចប្រកែកនឹងបំណងរបស់ម្តាយបានឡើយ បើប្តីអញមានប្រពន្ធចុង នាងនោះនឹងប្រើអញដូចខ្ញុំកំដរមិនខាន ដូច្នេះ អញត្រូវតែរកដណ្តឹងប្រពន្ធអោយប្តីអញដោយខ្លួនឯង " ។ ប្រពន្ធដើមនោះ ក៏ទៅស្តីដណ្តឹងកូនក្រមុំគេម្នាក់ អោយជា

ប្រពន្ធចុងរបស់ប្ដីខ្លួន ។ ក្រោយមកប្រពន្ធដើមគិតថា " បើនាងប្រពន្ធចុងនេះ មានកូនប្រុស ឬ កូនស្រី, នាងនេះនឹងបានជាម្ចាស់ទ្រព្យក្នុងគ្រួសារ, ដូច្នេះ អញ ត្រូវតែធ្វើយ៉ាងណាកុំអោយនាងនេះបានកូន ។ ប្រពន្ធដើម ក៏និយាយជាមួយ ប្រពន្ធចុងថា " បើនាងមានផ្ទៃពោះពេលណា សូមប្រាប់ខ្ញុំកុំខាន " ។ កាលដែល នាងប្រពន្ធចុងមានគភ៌ ក៏ប្រាប់ទៅនាងប្រពន្ធដើម ។ នាងប្រពន្ធដើម បានយកថ្នាំ ពន្លូតកូនទៅលាយជាមួយបបរអោយនាងប្រពន្ធចុងបរិភោគ នាងប្រពន្ធចុង ក៏រលូត កូនទៅ ។ នាងប្រពន្ធដើមធ្វើបែបនេះអស់ពីរលើក ។ ញាតិសន្ដានប្រពន្ធចុងដឹង រឿងនេះ ក៏ស្ដីបន្ទោសប្រពន្ធដើម កុំអោយធ្វើបែបនេះ តទៅទៀត ។

លុះនាងប្រពន្ធចុង មានគភ៌លើកទី៣ នាងប្រពន្ធដើម ក៏រកមធ្យោបាយ ដាក់ថ្នាំពន្លូតកូន ដូចមុនទៀត ។ ដោយគភ៌នោះចាស់ណាស់ទៅហើយនោះ នាង ប្រពន្ធចុង ក៏រងទុក្ខវេទនាយ៉ាងក្រៃលែង ។ នៅពេលជិតស្លាប់ នាងប្រពន្ធចុង តាំង សច្ចាប្រណិធានថា " បើខ្ញុំស្លាប់ទៅ សុំអោយកើតទៅជាយក្ខិនី ស៊ីកូននាងឯង វិញ កុំខាន " ។ លុះប្រពន្ធចុងស្លាប់ទៅ ក៏កើតជាឆ្មាក្នុងផ្ទះនោះឯង ។ ប្រពន្ធដើម ក៏ត្រូវប្ដីរបស់ខ្លួនវាយស្លាប់ ហើយក៏បានកើតទៅជាមេមាន់នៅក្នុងផ្ទះនោះដែរ ។ មេឆ្មា (ប្រពន្ធចុង) ក៏ទៅស៊ីពងមាន់អស់បីលើក ។ មេមាន់ (ប្រពន្ធដើម) ក៏តាំង ប្រាថ្នាថា បើអញស្លាប់ទៅ សុំអោយអញស៊ីខ្លួនវា និងកូនវា កុំខាន ។ លុះមេមាន់ ស្លាប់ទៅ ក៏បានកើតទៅជាមេខ្លា ។ ឯមេឆ្មា (ប្រពន្ធចុង) ស្លាប់ទៅ ក៏កើតជា មេប្រើស ។ មេខ្លា (ប្រពន្ធដើម) ស៊ីកូនប្រើស អស់បីលើក ។ មេប្រើស ក៏តាំង សច្ចាថា បើអញស្លាប់ទៅ សុំអោយបានស៊ីកូនវា ព្រមទាំងវា កុំខាន ។ លុះមេ ប្រើស (ប្រពន្ធចុង) ស្លាប់ទៅ ក៏បានទៅកើតជាយក្ខិនី ។ ឯមេខ្លា (ប្រពន្ធដើម) លុះស្លាប់ទៅ ក៏កើតទៅជានាងកុលធីតា នៅក្រុងសាវត្ថី ។

លុះនាងកុលធីតា មានវ័យគ្រប់ប្រការហើយ ម្ដាយឪពុកក៏រៀបចំអោយ

មានគូរស្រករ ។ បន្ទាប់មក នាងកុលធីតា ក៏បានប្រសូត្របុត្រមួយ, រីឯនាងយក្ខិនី ក៏ក្លែងភេទទៅជាមនុស្សមកស៊ីកូននាងកុលធីតា អស់ពីរលើក ។ លុះដល់នាងមានគភ៌លើកទី៣ . នាងសុំស្វាមីបីកូនវិលត្រឡប់មកលំនៅឋានរបស់ខ្លួនវិញដោយដើរកាត់តាមវត្តជេតពន ។ មកដល់ស្រះវត្ត នាងប្រគល់កូនទៅអោយប្តីបី ហើយនាងចុះងូតទឹក, ងូតរួច នាងឡើងមកបំបៅកូន, អោយប្តីចុះងូតម្តង ។ ពេលប្តីកំពុងងូតទឹក នាងឃើញយក្ខិនីនោះ ដើរតម្រង់មករកនាងយ៉ាងលឿន នាងក៏ស្រែកយ៉ាងខ្លាំង "*យក្ខិនី ៗ*" ហើយស្ទុះសំដៅចូលទៅក្នុងវត្តជេតពន ។ ពេលនោះ ព្រះសាស្តាកំពុងសំដែងធម៌ទេសនា ។ នាងចូលទៅដល់ហើយ ក៏យកកូនទៅផ្តេកជិតព្រះបាទនៃព្រះពុទ្ធ ហើយក្រាបទូលថា " ខ្ញុំព្រះអង្គ សូមប្រគេនកូននេះចំពោះព្រះអង្គ សូមព្រះអង្គប្រទានអាយុជីវិតដល់កូនខ្ញុំព្រះអង្គផង ។ ឯយក្ខិនីដែលដេញតាមនាងកុលធីតានោះ ក៏ត្រូវបាន *សុមនទេវតា* ដែលនៅអាស្រ័យនឹងក្លោងទ្វារវត្ត ឃាត់ទុកនៅទីនោះ ។ ព្រះសាស្តា បានប្រើអានន្ទអោយទៅហៅយក្ខិនីនោះចូលមក ។ លុះចូលមកដល់ហើយ ព្រះសាស្តាមានព្រះបន្ទូលថា " ហេតុអ្វីបានជានាងធ្វើយ៉ាងនេះ, ប្រសិនបើនាងមិនបានជួបនឹងតថាគតទេ នោះការចងពៀររបស់នាងទាំងពីរ នឹងបន្តអស់កប្បកល្បទៅទៀត ពុំខាន ដូចជាការចងពៀររវាងសត្វពស់ និងសត្វស្កា, ការចងពៀររបស់ខ្លាឃ្មុំ និងដើមពង្រ ឬការចងពៀរបស់សត្វក្អែក និងសត្វមៀម ជាដើម ពុំលែងឡើយ, ហេតុដូចម្តេចបានជានាងចងពៀរវេរានឹងគ្នាយ៉ាងនេះ ព្រោះពៀរស្ងប់រម្ងាប់ទៅបាន ដោយការមិនចងពៀរ គឺវាពុំអាចរម្ងាប់ទៅបានដោយការចងពៀរទេ ។ ព្រះអង្គ ក៏ទ្រង់សំដែងនូវបទជាគាថា ថា :

*ន ហិ វេរេន វេរានិ សមន្តីធ កុទាចនំ*
*អវេរេន ច សមន្តិ ឯស ធម្មោ សនន្តនោ ។*

*ក្នុងកាលណាៗក៏ដោយ ធម្មតាពៀរទាំងឡាយក្នុងលោកនេះ មិនដែលស្ងប់រម្ងាប់ដោយការចងពៀរឡើយ តាមពិត ពៀរទាំងឡាយតែងស្ងប់រម្ងាប់ដោយការមិនចងពៀរ នេះជាធម៌មានតាំងពីយូរយារណាស់មកហើយ ។*

ព្រះអដ្ឋកថាចារ្យ ពន្យល់ថា " បុគ្គលណាមួយជេរតប ប្រហារតបទៅនឹងបុគ្គលដែលជេរ ដែល ប្រហារខ្លួន បុគ្គលនោះមិនឈ្មោះថាធ្វើអោយពៀរស្ងប់រម្ងាប់បានឡើយ ហើយមិនតែប៉ុណ្ណោះ វារឹតតែធ្វើអោយពៀរនោះមានសភាពខ្លាំងក្លាថែមទៀតផង ឧបមាដូចជា ទឹកន្លែងមួយដែលប្រឡាក់ទៅដោយវត្ថុមិនស្អាតមានទឹកមាត់ជាដើម បើគេយកទឹកមាត់ទៅលាងទឹកន្លែងដែលប្រឡាក់ស្រាប់នោះ គឺវារឹតតែធ្វើអោយទឹកន្លែងនោះប្រឡាក់ថែមទៀត ។ ប៉ុន្តែ ផ្ទុយទៅវិញបើគេយកទឹកថ្លា-ស្អាត ទៅលាងទឹកន្លែងដែលប្រឡាក់ដោយទឹកមាត់នោះ ទើបទឹកន្លែងនោះ វាអាចស្អាតទៅបាន ។ យ៉ាងណាមិញ, បើគេចង់ធ្វើអោយពៀរវេរាស្ងប់រម្ងាប់ លុះណាតែគេយកទឹក គឺ *ខន្តី* និង *មេត្តា* ប្រកបដោយប្រាជ្ញាទៅប្រើ ឬទៅលាង ទើបពៀរវេរានោះអាចស្ងប់រម្ងាប់ទៅបាន ។ នេះគឺជាមាគ៌ារបស់ព្រះខីណាស្រពទាំងឡាយ មានព្រះពុទ្ធជាដើម " ។

ពេលដែលព្រះពុទ្ធសំដែងគាថានេះចប់ នាងយក្ខិនីនោះ ក៏បានសំរេចសោតាបត្តិផល ។ ព្រះសាស្តាទ្រង់ត្រាស់ទៅកាន់នាងកុលធីតាថា " ចូរនាងអោយកូននាងទៅនាងយក្ខិនីចុះ " ។ នាងកុលធីតាទូលថា "ខ្ញុំព្រះអង្គ ខ្លាចណាស់" ព្រះពុទ្ធទ្រង់ត្រាស់ថា " កុំខ្លាចអីនាង ! យក្ខិនីនេះ មិនធ្វើអោយអន្តរាយទេ " ។ នាងកុលធីតា ក៏ប្រគល់កូនខ្លួនទៅអោយនាងយក្ខិនី; យក្ខិនីក៏ទទួលយក ហើយឱបថើប បបោសអង្អែល បំពាក់គ្រឿងអលង្ការអោយកូននោះ រួចប្រគល់ទៅអោយម្តាយវិញ ហើយក៏យំខ្សឹកខ្សួលយ៉ាងខ្លាំង ។ ព្រះសាស្តាទ្រង់ទ្រង់ត្រាស់សួរទៅនាងយក្ខិនីនោះថា ហេតុអ្វីបានជានាងយំដូច្នេះ ? យក្ខិនី ឆ្លើយថា ខ្ញុំព្រះអង្គ

ប្រាកដជាលែងបានអាហារបរិភោគ ដូចសព្វដងទៀតហើយ ។ ព្រះពុទ្ធក៏ទ្រង់ល្បួងលោម ហើយបង្គាប់អោយនាងកុលធីតា នាំនាងយក្ខិនីនោះទៅចិញ្ចឹម នៅជាមួយផង ។

ចាប់ពីពេលនោះមក នាងកុលធីតាតែងទំនុកបំរុងបបរ-បាយដល់នាងយក្ខិនី រៀងរាល់ថ្ងៃ ។ ដោយយក្ខិនីនោះ មិនធ្លាប់នៅក្នុងស្រុកភូមិ នាងកុលធីតាក៏រៀបកន្លែងអោយនៅឆ្ងាយពីភូមិដាច់តែម្នាក់ឯង ហើយតែងយកបបរ-បាយទៅជូននាងយក្ខិនីនោះ ជានិច្ច ។ ក្រោយមក នាងយក្ខិនីគិតថា " នាងកុលធីតាជាសម្លាញ់របស់អញ មានឧបការៈច្រើនណាស់មកលើអញ ដូច្នេះ គួរតែអញធ្វើតបចំពោះឧបការគុណរបស់នាងវិញ កុំខាន " ។ ដោយនាងយក្ខិនីនោះ ជាអ្នកដឹងខាងធាតុអាកាស (ឧតុនិយម) ថាឆ្នាំនេះមានភ្លៀងច្រើន ឆ្នាំនេះមានភ្លៀងតិចនោះ បើឆ្នាំណាដឹងថាមានភ្លៀងច្រើន នាងប្រាប់នាងកុលធីតាអោយធ្វើស្រែទួល, បើឆ្នាំណាដឹងថាមានភ្លៀងតិច នាងប្រាប់ឱ្យនាងកុលធីតាធ្វើស្រែទំនាប ។ ដូច្នេះហើយបានជានាងកុលធីតា ធ្វើស្រែបានផលច្រើន ជារៀងរាល់ឆ្នាំ ។ អ្នកស្រុកទាំងឡាយឆ្ងល់ណាស់ថា " នាងកុលធីតានេះ ធ្វើស្រែត្រូវ បានផលច្រើនរាល់ឆ្នាំ, ប្រហែលជានាងដឹងថាឆ្នាំនេះមានភ្លៀងច្រើន ឬតិច ទេដឹង ? " ។ នាងកុលធីតាប្រាប់អ្នកស្រុកថា ខ្ញុំធ្វើស្រែចេះតែត្រូវយ៉ាងនេះ មកពីនាងយក្ខិនីប្រាប់ខ្ញុំ, បើអ្នកទាំងឡាយចង់បានផលស្រូវច្រើនដូចខ្ញុំ ចូរអ្នកទាំងឡាយយកបាយ-បបរ ទៅជូននាងយក្ខិនីនោះទៅ នាងយក្ខិនីនឹងប្រាប់អ្នកហើយ ។ អ្នកស្រុក ក៏ធ្វើតាមនាងកុល-ធីតា ដោយនាំគ្នាយកបាយ បបរ នំ ចំណី ទៅបូជានាងយក្ខិនី ។ យក្ខិនី ក៏ប្រាប់អ្នកស្រុក ដូចជាបានប្រាប់នាងកុលធីតាដែរ ។

ចាប់តាំងពីពេលនោះមក អ្នកស្រុកទាំងអស់ ក៏ធ្វើស្រែបានផល ជារៀងរាល់ឆ្នាំ ហើយក៏តែងនាំគ្នាបូជាដល់នាងយក្ខិនី ។ យក្ខិនី ក៏ក្លាយទៅជាអ្នកមាន

បរិវារច្រើន មានលាភសក្ការៈច្រើន ល្បីល្បាញពេញផ្ទៃនគរ ។

*សេចក្តីបន្ថែម*

ព្រះពុទ្ធទាំងឡាយ ពុំមែនជាអ្នកបិទសិទ្ធិអ្នកដទៃ អោយឈរឱបដៃបណ្តោយឱ្យគេវាយតាមអំពើចិត្តនោះទេ គឺទ្រង់គ្រាន់តែបង្ហាញការពិតថា " ការចងពៀរវេរាគ្នាក្តី, ការប្រើអំពើហិង្សាសងសឹកគ្នាក្តី បើចេះតែបណ្តោយវាទៅ វាប្រាកដជាមិនងាយនឹងចប់ទេ" ។ ប្រសិនបើចង់អោយវាចប់ មនុស្សគ្រប់រូបត្រូវយកប្រាជ្ញាប្រកបដោយ *ខន្តី* និង *មេត្តា* ទៅប្រើជាមធ្យោបាយសម្រាប់រម្ងាប់ ឬបញ្ចប់វា ។ នាងកុលធីតា ជាស្រីមានប្រាជ្ញាឈ្លាសវៃទាន់ពេលវេលា យល់ច្បាស់ថា ពុំអាចមានលទ្ធភាពទប់ទល់ដោយផ្ទាល់នឹងនាងយក្ខិនីបានទេ, ដូច្នេះហើយបានជាសម្រេចចិត្តបីកូនទៅពឹងព្រះពុទ្ធ ដែលមានឥទ្ធិពលខ្លាំងឱ្យជួយសង្គ្រោះ ។ ការពឹងពាក់ព្រះពុទ្ធនេះ មិនត្រឹមតែធ្វើអោយនាងរួចផុតពីគ្រោះថ្នាក់ប៉ុណ្ណោះទេ គឺវាថែមទាំងបានធ្វើអោយនាងយក្ខិនី ជាអ្នកប្រព្រឹត្តអំពើអាក្រក់ឃោរឃៅនោះ បានយល់ស្គាល់ពីកំហុសរបស់ខ្លួន សារភាព កែប្រែខ្លួន លែងធ្វើអំពើហិង្សា ហើយត្រឡប់បែរជាចេះធ្វើអំពើល្អដល់អ្នកដទៃទៅវិញផង ។

ពុទ្ធសាសនា បានអប់រំមនុស្សគ្រប់រូបឱ្យមានព្រហ្មវិហារធម៌ចំពោះគ្នាទៅវិញទៅមក ជានិច្ច ។ ប្រសិនបើ មនុស្សណាមួយក្នុងសាសនាក្តី ក្នុងសង្គមជាតិក្តី ផ្លាស់ផ្តោយប្រព្រឹត្តអំពើអាក្រក់ទៅវិញនោះ ពុទ្ធសាសនាតែងណែនាំមនុស្សឯទៀត អោយចេះយកប្រាជ្ញាប្រកបដោយព្រហ្មវិហារធម៌ជាមធ្យោបាយ ទៅផ្ចាញ់អ្នកដែលបានប្រព្រឹត្តអំពើអាក្រក់នោះ អោយភ្ញាក់រលឹក សារភាពកំហុស ហើយវិលត្រឡប់មកប្រព្រឹត្តអំពើល្អ ដូចគេឯងវិញ ។

បើចង់ផ្ចាញ់មនុស្សអាក្រក់ អោយខំធ្វើអំពើល្អ,
បើចង់ផ្ចាញ់មនុស្សកំណាញ់ អោយធ្វើទាន,
បើចង់ផ្ចាញ់មនុស្សកុហក អោយនិយាយតែពាក្យពិត,
បើចង់ផ្ចាញ់អសប្បុរស អោយខំប្រព្រឹត្តសប្បុរស ។

ប្រែ និង រៀបរៀងដោយ
- **ម៉ែន ប្រាជ**
- **អាំ ឆន**

---

ព្រះបរមពុទ្ធោវាទ

**សុករំ សាធុនា សាធុ សាធុ បាបេន ទុក្ករំ**
**បាបំ បាបេន សុករំ បាបមរិយេហិ ទុក្ករំ ។**

*« សាធុជន ស្រឡាញ់បុណ្យ ងាយធ្វើបុណ្យ*
*ឯទុជ៌ន ចិត្តទំរន់ ធ្វើពុំកើត*
*បើបាបវិញ គេងាយធ្វើ ពុំញញើត*
*អ្នកប្រាជ្ញឆើត ធ្វើពុំកើត ព្រោះខ្ពើមបាប ។ »*

សម្តេចព្រះសង្ឃរាជ **ជួន ណាត ជោតញ្ញាណោ**
ប.អ.ស. - អ.ម.រ.
ថ្ងៃ ២៤ កក្កដា ១៩៦៨

# បុណ្យភ្ជុំបិណ្ឌ

បុណ្យភ្ជុំបិណ្ឌ ជាបុណ្យប្រពៃណីធំបងមួយ ក្នុងចំណោមបុណ្យប្រពៃណីផ្សេងៗទៀតរបស់ប្រជាជនកម្ពុជា ។ បុណ្យនេះ មានលក្ខណៈជាបុណ្យគោរពវិញ្ញាណក្ខន្ធរបស់បុព្វបុរស ញាតិសន្តាន ដែលបានធ្វើមរណកាលទៅហើយ ។

## ១. របៀបភ្ជុំបិណ្ឌរបស់ខ្មែរ ៖

ប្រជាជនកម្ពុជា ប្រារព្ធធ្វើបុណ្យភ្ជុំបិណ្ឌ ពីថ្ងៃ១រោច ដល់ថ្ងៃ១៥រោច ខែភទ្របទ រៀងរាល់ឆ្នាំ ។ ពីថ្ងៃ១រោច ដល់ថ្ងៃ១៤រោច ហៅថា*ថ្ងៃកាន់បិណ្ឌ* ហើយថ្ងៃ ១៥រោច ហៅថា *ថ្ងៃភ្ជុំបិណ្ឌ* ។

ក្នុងឱកាសកាន់បិណ្ឌនេះ, ចាស់ព្រឹទ្ធាចារ្យ យាយតា ដែលមានសទ្ធាមុតមាំក្នុងព្រះពុទ្ធសាសនា បានលះបង់ផ្ទះសំបែង កូនចៅ ទៅនៅវត្ត សមាទានសីល៥ សីល៨ ឬអតិរេកសីល ចំរើនមេត្តាភាវនា បំរើព្រះសង្ឃ និងសំអាតទីអារាមជាដើម ។ ពុទ្ធបរិស័ទចំណុះជើងវត្តនីមួយៗ បានបែងចែកគ្នាជាវេនចំនួន ១៤ថ្ងៃ ឬ ១៤បិណ្ឌ ។ ក្នុងបិណ្ឌនីមួយៗ នៅពេលយប់ គេជួបជុំគ្នាប្រគេន . ជូនភេសជ្ជៈចំពោះព្រះសង្ឃ និងចាស់ព្រឹទ្ធាចារ្យ នមស្ការព្រះរតនត្រ័យ សមាទានសីល និមន្តព្រះសង្ឃចំរើនព្រះបរិត្ត និងសំដែងធម៌ទេសនា ។ ព្រឹកឡើង ប្រគេនយាគូ ភត្តាហារ ដើម្បីឧទ្ទិសកុសលជូនចំពោះវិញ្ញាណក្ខន្ធក្រុមគ្រួសារ ញាតិមិត្តរបស់គេ ដែលបានធ្វើមរណកាលហើយនោះ ។ នៅយប់ថ្ងៃ១៤រោច គេប្រារព្ធធ្វើពិធីដូចយប់ថ្ងៃកាន់បិណ្ឌពីមុនមកដែរ ប៉ុន្តែមានលក្ខណៈឱឡារិកជាង ។ រីឯប្រជាជន និយម

ធ្វើនំផ្សេងៗ មានអន្សម នំគម ជាដើម សំរាប់ប្រគេនព្រះសង្ឃ សែនព្រេន និង ជូនឪពុកម្តាយ ចាស់ទុំ ញាតិមិត្តរបស់គេ ក្នុងឱកាសថ្ងៃបុណ្យភ្ជុំបិណ្ឌ ។ ព្រឹកឡើង ថ្ងៃ១៥រោច ដែលជាថ្ងៃភ្ជុំបិណ្ឌនេះ ពុទ្ធបរិស័ទវេនបិណ្ឌ អញ្ជើញមកចូលរួមយ៉ាង កុះករ ប្រគេនចង្ហាន់ព្រះសង្ឃ និងបង្សុកូល ដូចថ្ងៃកាន់បិណ្ឌដែរ ប៉ុន្តែថ្ងៃនេះ មានលក្ខណៈអធិកអធមជាងថ្ងៃកាន់បិណ្ឌកន្លងមក ។ នៅតំបន់ខ្លះ ពេលល្ងាចថ្ងៃ ១៥រោច គ្រួសារនីមួយៗ រៀបចំពិធីសែនព្រេនជូនដីជូនជីតាតាមទម្លាប់ ។ លុះ ព្រលឹមស្រាង១ថ្ងៃ១កើត ខែអស្សុជ គេរៀបចំនំ ចំណី ផ្លែឈើ... ដុតទៀន ធូប ដាក់ក្នុងទូកដែលធ្វើពីស្រទបចេកបណ្តែតតាមទឹក ដើម្បីជាកិច្ចជូនដំណើរដូនតា ត្រឡប់ទៅវិញ ។

## ២. ប្រភពនៃការកាន់បិណ្ឌ ៖

*ក. គម្ពីរធម្មបទដ្ឋកថា* មានសេចក្តីថាៈ មុនភទ្រកប្បនេះ ព្រះពុទ្ធព្រះនាម ផុស្សៈបានត្រាស់ដឹងក្នុងលោក, ពេលនោះ មានព្រះរាជបុត្រ៣ព្រះអង្គ របស់ស្តេច មហិន្ទរាជ ទ្រង់មានព្រះទ័យចង់ដាក់ទាន ។ ព្រះរាជបុត្រនោះ បានស្នើសុំព្រះរាជ-ទ្រព្យពីព្រះបិតា ។ ព្រះបាទមហិន្ទរាជ ពុំអនុញ្ញាតតាមសំណូមពរ របស់ព្រះរាជបុត្រ ឡើយ ។ សម័យនោះ មានពួកសត្រូវបង្កអសន្តិសុខនៅស្រុកជាយដែន ។ ព្រះបិតា បានបញ្ជូនបុត្រទាំង៣អង្គ អោយចេញទៅបង្ក្រាប ។ លុះបានជ័យជំនះ ព្រះរាជ-បុត្រទាំងនោះ ក៏ត្រឡប់មកកាន់ព្រះរាជវាំងវិញ ។ ព្រះបិតា ទ្រង់មានព្រះទ័យ សោមនស្សក្រៃលែង ហើយត្រាស់សួរថា" ម្នាលបុត្រ, តើអ្នកត្រូវការអ្វី ? " ព្រះ រាជបុត្រក្រាបទូលថា " បពិត្រព្រះបិតា, ខ្ញុំព្រះអង្គមានបំណងតែមួយគត់ គឺសុំ ព្រះរាជទ្រព្យ ដើម្បីដាក់ទាន " ។ ដំបូង ព្រះរាជបុត្រសុំដាក់ទានជានិច្ចកាល ប៉ុន្តែ

ព្រះបិតាមិនយល់ព្រម ។ តមក ព្រះរាជបុត្រ ក៏សុំត្រឹមតែ ៧ឆ្នាំ ៦ឆ្នាំ ៥ឆ្នាំ ៤ឆ្នាំ ៣ឆ្នាំ ២ឆ្នាំ ១ឆ្នាំ, ៧ខែ ៦ខែ ៥ខែ ៤ខែ ក៏នៅតែព្រះបិតា ពុំព្រម ។ លុះដល់ទីបំផុត ព្រះរាជបុត្រស្នើសុំត្រឹម ៣ខែ គឺម្នាក់ៗ ១ខែ ។ បន្ទាប់ពីបានទទួលព្រះរាជានុញ្ញាតហើយ ព្រះរាជបុត្រទាំង ៣ អង្គ ក៏ទ្រង់ប្រគល់ភារកិច្ចនេះ ទៅអោយនាយស្មៀន និងនាយឃ្លាំង ដើម្បីចាត់ចែងទាន ។ ព្រះរាជបុត្រទាំង ៣ អង្គ ព្រមទាំងបរិវារ ក៏ចូលបួសនៅជាមួយព្រះពុទ្ធព្រះនាមផុស្សៈ នោះទៅ ។

ចំណែកពួកកម្មករ ដែលនាយស្មៀនបានចាត់តាំងអោយធ្វើចង្ហាន់ថ្វាយព្រះពុទ្ធ និងភិក្ខុសង្ឃ តាមលំដាប់វេនរបស់ព្រះរាជបុត្រនោះ កើតមានសេចក្ដីប្រមាទក្នុងទាន ដោយបរិភោគចង្ហាន់មុនព្រះសង្ឃ និងបរិភោគចង្ហាន់ណា ដែលមានរសជាតិឆ្ងាញ់ពិសារមុនព្រះសង្ឃ ជារៀងរាល់ថ្ងៃ ។ ដោយសេចក្ដីប្រមាទនេះ ពួកកម្មករទាំងនោះ លុះធ្វើមរណកាលទៅ ក៏បានទៅបដិសន្ធិក្នុងឋានប្រេត សោយទុក្ខវេទនាលំបាកស្រេកឃ្លានក្រៃលែង ។ ពេលផែនដីដុះបានកំរាស់មួយយោជន៍ មានព្រះពុទ្ធមួយព្រះអង្គ ព្រះនាមកកុសន្ធៈបានត្រាស់ដឹងឡើងក្នុងលោក ។ ពួកប្រេតទាំងនោះ ក៏នាំគ្នាចូលទៅទូលសួរថា " ពេលណា ខ្ញុំព្រះអង្គបានអាហារបរិភោគ? ព្រះពុទ្ធអង្គនេះត្រាស់ថា "ចាំសួរព្រះពុទ្ធកោនាគមនៈចុះ" ។ លុះដល់ព្រះពុទ្ធកោនាគមនៈបានត្រាស់ដឹង, ពួកប្រេតទាំងនោះ ក៏បានចូលសួរដូចមុនទៀត ។ ព្រះពុទ្ធកោនាគមនៈប្រាប់ថា " ចាំសួរព្រះពុទ្ធកស្សបៈចុះ " ។ លុះដល់ព្រះពុទ្ធកស្សបៈបានត្រាសដឹង, ពួកប្រេតទាំងនោះក៏ចូលទៅសួរដូចមុនទៀត ។ ព្រះពុទ្ធកស្សបៈទ្រង់ត្រាស់ថា ពួកឯងនឹងបានអាហារបរិភោគ ក្នុងសាសនាព្រះពុទ្ធសមណ-គោតម ព្រោះញាតិរបស់ឯងព្រះនាមពិម្ពិសារ នឹងថ្វាយទានចំពោះព្រះពុទ្ធ និងភិក្ខុ-សង្ឃ ។

លុះដល់ព្រះពុទ្ធសមណគោតមត្រាស់ដឹងក្នុងលោក នាយស្មៀន ដែលជាញាតិ

របស់ប្រេតនោះ ក៏បានកើតជាព្រះបាទពិម្ពិសារ សោយរាជ្យនៅនគររាជគ្រឹះដែរ ។ ក្នុងថ្ងៃមួយ ព្រះបាទពិម្ពិសារថ្វាយទានចំពោះព្រះពុទ្ធ ព្រមទាំងភិក្ខុសង្ឃ, ពួកប្រេតទាំងអស់ បានទៅរង់ចាំទទួលផលទាន ប៉ុន្តែ ពុំបានចំណែកទានសោះ ហើយក៏នាំគ្នាទៅបង្ហាញខ្លួនអោយព្រះបាទពិម្ពិសារឃើញ ព្រមទាំងបញ្ចេញនូវសម្រែកដ៏ខ្លាំងលាន់ខ្ទរខ្ទារពេញផ្ទៃព្រះរាជវាំង ក្នុងពេលរាត្រី ។ ព្រឹកឡើង ព្រះបាទពិម្ពិសារក៏យាងទៅទូលសួរព្រះពុទ្ធព្រះសមណគោតមអំពីព្រឹត្តិការណ៍ដ៏ចម្លែកនេះ ។ ព្រះពុទ្ធត្រាស់ថា សម្រែកពីយប់មិញនោះ ជាសម្រែករបស់ពួកប្រេតដែលជាញាតិ របស់ព្រះអង្គ ព្រោះពួកគេ ពុំបានអាហារបរិភោគ អស់រយៈពេលព្រះពុទ្ធ ៤ អង្គ មកហើយ ។ រីឯទានដែលព្រះអង្គបានថ្វាយហើយ ចំពោះតថាគត និងភិក្ខុសង្ឃក្នុងថ្ងៃម្សិលមិញនោះ ពួកប្រេតមិនបានទទួលផលទេ ព្រោះព្រះអង្គ ពុំបានឧទ្ទិសទៅអោយ ។ ព្រះរាជាទូលតទៅទៀតថា " តើធ្វើដូចម្ដេច ទើបពួកប្រេតទាំងនោះបានអាហារបរិភោគ ? " ។ ព្រះពុទ្ធត្រាស់ថា " ស្អែកឡើង មហារាជត្រូវថ្វាយទានចំពោះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ហើយឧទ្ទិសថា : " *ភន្តេ ឥតោ តេសំ បេតានំ ទិព្វន្នបានំ សម្បជ្ជតុ* = បពិត្រព្រះអង្គដ៏ចំរើន ដោយអំណាចផលទាននេះ សូមបាយ និង ទឹកដ៏ជាទិព្វនេះ សំរេចដល់ប្រេតទាំងឡាយនោះចុះ " ។ ព្រឹកឡើង ព្រះរាជាទ្រង់ធ្វើតាមព្រះពុទ្ធដីកានេះ ។ ពួកប្រេតទាំងនោះ ក៏បានអាហារទិព្វបរិភោគស្កប់ស្កល់ភ្លាម លែងរងទុក្ខវេទនា ដូចពេលមុនៗទៀត ។

បន្ទាប់មក ពួកប្រេតទាំងនោះ ក៏បង្ហាញកាយអាក្រាតនទល អោយព្រះរាជាទតឃើញ ។ ព្រះបាទពិម្ពិសារ ទ្រង់មានចម្ងល់យ៉ាងខ្លាំង ក៏យាងទៅទូលសួរព្រះពុទ្ធទៀតថា " ក្នុងថ្ងៃនេះ ប្រេតទាំងនោះ បានទៅបង្ហាញកាយអាក្រាតអោយទូលព្រះបង្គំឃើញ " ។ ព្រះពុទ្ធទ្រង់ត្រាស់ថា មហារាជ ពីម្សិលមិញទ្រង់បានធ្វើ

មានតែចង្ហាន់ប៉ុណ្ណោះ ហើយមិនបានធ្វើទានសំពត់ទេ, ដូច្នេះបានជា ពួកប្រេតគ្មានសំពត់ស្លៀក អាក្រាតកាយ យ៉ាងនេះ " ។ លុះថ្ងៃស្អែកឡើង ព្រះបាទពិម្ពិសារក៏បានធ្វើចីវរថ្វាយចំពោះព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន ហើយឧទ្ទិសផលទានអោយទៅប្រេតទាំងនោះថា " *ឥតោ តេសំ ទិព្វវត្ថានិ ហោន្តុ* = សូមសំពត់ទិព្វទាំងឡាយកើតមានដល់ប្រេតទាំងឡាយនោះ ដោយផលទាននេះចុះ " ។ គ្រាន់តែឧទ្ទិសចប់ សំពត់ទិព្វ ក៏កើតមានដល់ពួកប្រេតទាំងនោះភ្លាម មិនតែប៉ុណ្ណោះប្រេតទាំងនោះ ក៏បានក្លាយខ្លួនពីអត្តភាពជាប្រេត ទៅជាអត្តភាពទិព្វ ក្នុងខណៈនោះឯង ។ ព្រះសាស្តាទ្រង់ធ្វើអនុមោទនានៅពេលនោះ ដោយតិរោ-កុឌ្ឌសូត្រ មានបទថា « *តិរោកុឌ្ឌេសុ តិដ្ឋន្តិ* = ពួកប្រេតទាំងឡាយស្ថិតនៅក្រៅជញ្ជាំងទាំងឡាយ ជាដើម ។ ដូច្នេះហើយបានជា ព្រះសង្ឃយើង និយមសូត្រតិរោកុឌ្ឌសូត្រនេះនៅក្នុងពិធីកាន់បិណ្ឌ និងភ្ជុំបិណ្ឌ ឬក្នុងពិធីទក្ខិណានុប្បទានផ្សេងៗ រហូតមកដល់សព្វថ្ងៃ ។

*ខ. គម្ពីរបេតវត្ថុ* : មានសេចក្តី ថា " ក្នុងកាលកន្លងទៅហើយ មានព្រានម្នាក់នៅក្នុងពារាណសី តែងទៅបាញ់សត្វក្នុងព្រៃចិញ្ចឹមជីវិតរាល់ថ្ងៃ ។ វេលាត្រឡប់មកផ្ទះវិញ ពួកក្មេងៗ តែងចោមរោមសុំសាច់រាល់ដង ។ ថ្ងៃមួយ ព្រាននោះ ទៅបាញ់មិនបានសត្វ ក៏បេះផ្កាត្របែកព្រៃប្រដាប់ខ្លួន និងរែកយកមកផ្ទះជាច្រើន ។ លុះដល់ទ្វារភូមិ ពួកក្មេងៗមកសុំសាច់ដូចសព្វដងទៀត, ព្រានក៏ចែកផ្កាត្របែកព្រៃអោយម្នាក់មួយស្មើងៗ ។

លុះព្រាននោះស្លាប់ទៅ បានកើតជាប្រេតអាក្រាតកាយ មានផ្កាត្របែកព្រៃប្រដាប់ក្បាលដើរទៅក្នុងទឹក សំដៅទៅផ្ទះញាតិរបស់ខ្លួនដើម្បីរកអាហារបរិភោគ។ វេលានោះ កោលិយអាមាត្យ ជាអាមាត្យព្រះបាទពិម្ពិសារ ជិះទូកទៅបង្ក្រាបការបះបោរនៅស្រុកបច្ចន្តគ្រាម ហើយបានសួរប្រេតនោះដឹងសព្វគ្រប់ប្រការ ក៏មាន

ចិត្តអាណិត ទើបនិយាយថា " សង្ខូវ[១] របស់យើងមាន ធ្វើម្ដេចអ្នកនឹងបរិភោគបាន ? " ។ ប្រេតឆ្លើយថា " ក្នុងទូកនេះ បើមានឧបាសកអ្នកតម្កល់ខ្លួននៅក្នុងត្រៃសរណគមន៍ សូមលោកអោយសង្ខូវដល់ឧបាសកនោះ ហើយឧទ្ទិសចំណែកកុសលអោយខ្ញុំចុះ " ។ កោលិយអាមាត្យក៏ធ្វើតាម ហើយប្រេតនោះ ក៏បានទទួលអនុមោទនា បានសុខសាន្ត ឆ្អែតស្កប់ស្កល់ លែងរងទុក្ខលំបាកដោយការស្រេកឃ្លានទៀត ទើបផ្ដាំថា " សូមលោកមេត្តាដល់ប្រេតឯទៀតៗផង បើលោកធ្វើកុសលឯណានីមួយហើយ សូមឧទ្ទិសចំណែកកុសលនោះឱ្យដល់ប្រេតខ្លះផង " ។

*គ-សាស្ត្រាអានិសង្សបិណ្ឌ* : មានសេចក្ដីថា" ព្រះដ៏មានបុណ្យទ្រង់ត្រាស់ចំពោះអនាថបិណ្ឌិកសេដ្ឋី ថា " អស់ម្ដាយឪពុក ញាតិកា វង្សា បងប្អូន កូនចៅរបស់ជនទាំងឡាយ ដែលស្លាប់ទៅអំពីពេលមុនៗនោះ ទោះទៅកើតទីកន្លែងណាៗក្ដី តែដល់រនោចខែភទ្របទ ដែលគេរៀបកាន់បិណ្ឌ តែងតែមកជួបជុំនៅពេលនោះ ។ ហេតុតែតេជះអានិសង្ឃនៃបុណ្យ ដែលអស់ញាតិសន្ដានបានធ្វើបាយបិណ្ឌ បាយបិតបូរ (បិត្បូរ) នាខែភទ្របទ ហើយឧទ្ទិសផលជូនទៅនោះ ក៏បានរំដោះរួចចេញអំពីនរកប្រេត នោះហោង " ។

រីឯសត្វនរកប្រេតផងទាំងឡាយ ដែលមកកាន់មនុស្សលោក ក្នុងខែភទ្របទនេះ ប្រេតខ្លះមកកើតជាកណ្ដូបខ្មោចទំយំនៅជិបូលផ្ទះ ខ្លះទំយំនៅចុងកាត់ផ្ទះធ្នឹមផ្ទះ មាត់ទ្វារផ្ទះ ជើងជណ្ដើរផ្ទះ ដើមឈើក្បែរផ្ទះ ប្រេតខ្លះមកដល់ពាក់កណ្ដាលផ្លូវ ខ្លះមកចំអើតមើលទៅមក ខ្លះបាំងដៃមើលមកពីចម្ងាយ ហើយគិតអាណិតអនិច្ចាខ្លួនថា " ឱ រូបអញអើយ ! អភ័ព្វអ្វីម្ល៉េះ មកកើតជាប្រេតនរក រងទុក្ខវេទនា ទុរាទុរន់ពន់ប្រមាណយូរឆ្នាំហើយ មានការស្រេកឃ្លានក្រៃពេក " ។

---

[១] សង្ខូវ : ( សះង្ខូវ ) អាហារធ្វើដោយប្រអូលផង់ ម្សៅស្ងួត សម្រាប់បរិភោគបានយូរ, ប្រើជាស្បៀងក្នុងវេលាដើរផ្លូវឆ្ងាយដាច់ស្រយាល, .....

សត្វនរកប្រេតទាំងនោះ កាលដល់ខែភទ្របទហើយ តែងតែបានរួចរដោះចាកទុក្ខ ដោយជនជាញាតិសន្តាន បានរៀបចំរណ្តាប់បាយបិណ្ឌ បាយបិតបូរ ឧទ្ទិសផលានិ-សង្សបញ្ជូនទៅនោះ ។ ព្រះដ៏មានបុណ្យទ្រង់ត្រាស់ថា " ហៃអនាថបិណ្ឌិក, នៅថ្ងៃភ្ជុំបិណ្ឌនោះ ត្រូវចងរំយោល ចងទង់ ពិដានដាសពាសនូវរនាំង វាំងនន ជាដើម ហើយរៀបចំរណ្តាប់គ្រឿងបណ្ណាការ គឺទៀន ធូប ផ្កាភ្ញី ស្លា ម្លូ និងគ្រឿងគន្ធ-ពិដោរ ព្រមទាំងផ្លែឈើតូចធំ នំ ចំណី ភោជនាហារ ផងទាំងឡាយបូជាព្រះសង្ឃ, ផលានិសង្សនៃបុណ្យនោះ ក៏ជូនទៅដល់ជីដូនជីតា ម្តាយឪពុក បងប្អូន កូនចៅ ញាតិផៅទាំង ៧ សន្តានដែលស្លាប់ទៅកើតជាប្រេតនរក រងទុក្ខវេទនានោះ អោយបានសម្បត្តិសួគ៌ សម្បត្តិនិព្វាន ជាស្ថានបរមសុខប្រសើរហោង " ។

ហៃអនាថបិណ្ឌិក, បុរស បុគ្គលប្រុសស្រីឯណានីមួយ បើនឹងរៀបកាន់បិណ្ឌនោះ ត្រូវអញ្ជើញអស់មេបា ចាស់ទុំផងទាំងឡាយមកអង្គុយជុំវិញ ហើយទុកលង្វែកចន្លោះកណ្តាលប្រមាណមួយហត្ថ យកត្រី សាច់ និងផ្លែឈើតូចធំ អន្សម នំគម ចេក អំពៅ ត្រាវ ដំឡូង ដូង ត្នោត ព្រមទាំងគ្រឿងបណ្ណការផង គឺយកទៀន ធូប ផ្កាភ្ញី ស្លាម្លូ ប្រេង មេ្សា មកបូជាព្រះរតនត្រ័យ ហើយសុំស្មារលា-ទោសអំពីមេបា ចាស់ទុំ ដ្បិតប្រេតនោះផ្តាំមកថា អោយអស់ញាតិកា មេបា ចាស់ទុំ ជីដូនជីតា ម្តាយឪពុក បងប្អូន កូនចៅ ស្មារលាទោសអោយផង កុំអោយមានវេរាកម្មតាមទៅឡើយ ។

បើក្នុងខែភទ្របទនោះ មិនមានអ្នកណារៀបរណ្តាប់បាយបិណ្ឌ បាយបិតបូរ បូជាព្រះរតនត្រ័យ បញ្ជូនផលទៅទេ, អស់ប្រេតនរកអម្បាលនោះ ក៏អត់បាយ អត់ទឹក ស្រេកឃ្លាន រងទុក្ខវេទនាក្រៃពេក, ម្លោះហើយ ប្រេតទាំងនោះ ក៏ជេរប្រទេចផ្តាសា មកញាតិកាទាំងឡាយ អោយហីនហោចទ្រព្យសម្បត្តិ ព្រាត់ប្រាសឪពុក ប្តីប្រពន្ធ កូន ចៅ ញាតិផៅទាំង ៧ សន្តាន ជាដើម " ។

*ឃ. សាស្ត្រាវិជ្ជាធរ* ៖ មានសេចក្ដីថាៈ មានព្រះមហាថេរមួយអង្គ ឈ្មោះព្រះឧបគុត្តត្ថេរ បានហោះជ្រែកក្រឡាមហាប្រឹថពីទៅកាន់ស្ថាននរក ។ ដោយអំណាចឫទ្ធិរបស់លោក មានផ្កាឈូកមាសប៉ុនកង់រាជរថផុះឡើងទទួលព្រះបាទលោក ។ លោក ក៏គង់ពែនលើផ្កាឈូកនោះអណ្ដែតលើពពួកនរក ។ ហេតុតែអានុភាពព្រះថេរៈ ពួកសត្វនរកបានដកដង្ហើមចេញ-ចូលស្រួលពេលនោះ ទើបនាំគ្នាសំពះព្រះថេរៈ ។ ព្រះថេរៈមានព្រះទ័យករុណា ក៏សំដែងធម៌អោយពួកនរកនោះស្ដាប់ ។ លុះបានស្ដាប់ធម៌ហើយ ក៏បានផ្ដាំនឹងព្រះថេរៈថា " បពិត្រព្រះមហាថេរ ! បើព្រះករុណា និមន្តត្រឡប់ទៅកាន់មនុស្សលោកវិញ សូមមេត្តាប្រាប់ឪពុកម្ដាយបងប្អូន កូនចៅ ញាតិផៅសន្ដានរបស់យើងខ្ញុំ មានឈ្មោះដូច្នេះៗ នៅស្រុកឈ្មោះនេះៗ សូមអោយអាសូរករុណាដល់យើងខ្ញុំ ធ្វើបុណ្យ អោយមាន ឧទ្ទិសផលទៅអោយយើងខ្ញុំផង " ។

កាលព្រះឧបគុត្តត្ថេរ ទទួលបណ្ដាំពីពួកនរកហើយ ក៏ហោះមកកាន់មនុស្សលោកវិញ ហើយបានចូលទៅថ្វាយព្រះពរព្រះមហាក្សត្រមួយអង្គ ។ ព្រះមហាក្សត្រ ទ្រង់នាំនាម៉ឺនសព្វមុខមន្ត្រី សេដ្ឋី គហបតី និងអ្នកនគរជាច្រើននាក់ ចូលទៅក្រាបបង្គំទូលព្រះពុទ្ធដ៏មានបុណ្យថា" បពិត្រព្រះដ៏មានបុណ្យប្រសើរអើយ បើគ្រូបាធ្យាយ ម្ដាយឪពុក បងប្អូន កូនចៅ ញាតិមិត្ត របស់យើងខ្ញុំ អ្នកខ្លះមិនបានធ្វើបុណ្យអោយមាន រក្សាសីលឡើយ, ធ្វើតែអំពើបាប, លុះអស់អាយុ ទៅកើតក្នុងនរក រងទុក្ខវេទនា, អស់យើងខ្ញុំជាបងប្អូន កូនចៅ នៅឯក្រោយ តើនឹងត្រូវធ្វើអំពើបុណ្យដូចម្ដេច ទើបឧទ្ទិសផលជូនទៅសត្វនរកទាំងនោះ អោយរំដោះចាកទុក្ខបាន ? " ។

ព្រះដ៏មានបុណ្យទ្រង់ត្រាស់តបថា បើមហារាជចង់ធ្វើអំពើបុណ្យ កុសលឧទ្ទិសផលជូនទៅសត្វនរកទាំងនោះអោយរំដោះរួចមក ត្រូវធ្វើដូច្នេះ គឺចាប់ផ្ដើម

ពីថ្ងៃ១រោច ខែភទ្របទទៅ ត្រូវធ្វើបាយបិណ្ឌ បាយបិតបូររាល់ថ្ងៃ ហើយត្រូវធ្វើអង្គព្រះពុទ្ធរូប ១អង្គ ១ថ្ងៃ ដរាបដល់ថ្ងៃ១៥រោច ខែភទ្របទនោះឯង ត្រូវចងពិដាន ពាសរនាំង វាំងនន ក្រាលកំរាល ត្រូវសមាទានសីល អោយបរិសុទ្ធប្រាកដ ត្រូវបោសសំអាតវត្តអារាម ព្រះវិហារ ត្រូវរៀបរណ្តាប់គ្រឿងបណ្ណាការ មានផ្កា ភ្ញីគន្ធពិដោរ ជាដើម ហើយនិមន្តព្រះគម្ពែងសង្ឃដ៏ទ្រង់សីលបរិសុទ្ធ សូត្រធមិមហា.សម័យ ត្រូវប្រកាសបួងសួងអញ្ជើញគ្រូបាធ្យាយ ម្តាយឪពុក បងប្អូន ញាតិកាដែលចែកស្ថានទៅហើយទាំងប៉ុន្មាន មួយអន្លើដោយទេវតា ហើយត្រូវនិមន្តលោកទេសនាសាស្ត្រាវិជ្ជាធរជាតក ក្នុងយប់នោះ ។

លុះព្រឹកឡើង ត្រូវធ្វើបាយបិណ្ឌ បាយបិត្សរ មានទាំងចង្ហាន់ ផ្លែឈើ និងសរពើភោជនាអាហារផង ផ្តុំផ្តងរណ្តាប់ អង្គាសដាក់បាត្រព្រះ ឧទ្ទិសផលជូនទៅដល់ពួកអសុសត្វប្រេតនរកទាំងនោះ " ។

ដោយអានុភាពនៃអំពើកុសលផលបុណ្យនោះ សត្វនរកផងទាំងឡាយ នឹងបានរដោះចេញពីទុក្ខភ័យ ពួដ៏កាលនោះ បានទៅកើតពួដ៏ស្ថានសួគ៌ទេវលោកនាយហើយសឹងអោយពរស័ព្ទសាធុការមកញាតិសន្តាន ដែលបានធ្វើបុណ្យអោយទានឧទ្ទិសស្មោះចំពោះជូនទៅនោះ អោយកើតសុខសួស្តី ទីឃាយុយឺនយូរ ទីទៃ១ពួដ៏កាលនោះហោង " ។

## សេចក្តីសង្កេត :

គម្ពីរធម្មបទ និង គម្ពីរបេតវត្ថុ ពុំបានបញ្ជាក់កាលបរិច្ឆេទនៃបុណ្យកាន់បិណ្ឌនិងភ្ជុំបិណ្ឌខ្មែរទេ ។ រីឯសាស្ត្រាអានិសង្សបិណ្ឌ និងសាស្ត្រាវិជ្ជាធរ បានកំណត់កាលបរិច្ឆេទច្បាស់លាស់ គឺពីថ្ងៃ ១រោច ខែភទ្របទ ដល់ថ្ងៃ ១៥រោចខែភទ្របទ

គម្ពីរមិលិន្ទបញ្ហា បញ្ជាក់ថា ៖ ប្រេតមាន ៤ ពួកគឺ ៖

*១. ខុត្តូបជីវី* ពួកប្រេតដែលចិញ្ចឹមជីវិតដោយខ្ទុះឈាម,

*២. ខុប្បបាសិក* ពួកប្រេតដែលស្គាល់តែទុក្ខវេទនាដោយការស្រេកឃ្លានជានិច្ច,

*៣. និជ្ឈាមតណ្ហិក* ពួកប្រេតដែលភ្លើងឆេះជានិច្ច,

*៤.បរទត្តូបជីវី* ពួកប្រេតដែលចិញ្ចឹមជីវិតដោយផលទាន ដែលគេឧទ្ទិសអោយ ។

បណ្តាពួកប្រេតទាំង ៤ ពួកនេះ មានតែពួកប្រេតទី ៤ ទេ ដែលគេឧទ្ទិសជូនទៅហើយអាចទទួលយកបាន ដូចជាពួកប្រេតជាញាតិ របស់ព្រះបាទពិម្ពិសារនោះជាដើម ។ គម្ពីរធម្មបទ ជាអដ្ឋកថា ភាសាបាលី សរសេរឡើងដោយព្រះពុទ្ធ-ឃោសាចារ្យ និងគម្ពីរបេតវត្ថុ ជាអដ្ឋកថា ភាសាបាលី សរសេរឡើងដោយព្រះធម្មបាល ។ សាស្ត្រាវិជ្ជាធរ និងសាស្ត្រាអានិសង្សបិណ្ឌ គ្មានឈ្មោះអ្នកនិពន្ធហើយមិនដឹងជាសរសេរក្នុងពុទ្ធសតវត្សទីប៉ុន្មានឡើយ ។

ការកាន់បិណ្ឌ និង ភ្ជុំបិណ្ឌនេះ ក៏ពុំដឹងជាគេផ្តើមឡើងក្នុងរជ្ជកាលស្តេចអង្គណា ? ក្នុងពុទ្ធសករាជ ឬគ្រិស្តសករាជប៉ុន្មានដែរ ប៉ុន្តែ ក្នុងព្រះរាជពង្សាវតារក្រុងកម្ពុជា រជ្ជកាលព្រះបាទអង្គដួង គ.ស ១៨៤៨ - ១៨៥៩ មានបញ្ជាក់សេចក្តីបន្តិចថា " ថ្ងៃ ១រោច ខែភទ្របទ កាន់បិណ្ឌក្នុងព្រះបរមរាជវាំង ថ្ងៃ ១៤ រោចខែភទ្របទ ព្រះរាជាចេញថ្វាយព្រះបិតរ, ថ្ងៃ ១៥រោច ខែភទ្របទ ទេសនាគាថា-ពាន់ ប៉ុណ្ណោះ ។

អ្នកប្រាជ្ញពុទ្ធសាសនាខ្លះ យល់ថាបុណ្យកាន់បិណ្ឌ និងបុណ្យភ្ជុំបិណ្ឌ របស់ខ្មែរនេះ មានប្រភពចេញពីគម្ពីរពុទ្ធសាសនា មានគម្ពីរធម្មបទដ្ឋកថា និងគម្ពីរបេតវត្ថុនេះ ជាដើម ។ រីឯសាស្ត្រាវិជ្ជាធរក្តី សាស្ត្រាអានិសង្សបិណ្ឌក្តី ក៏មានប្រភពចេញ

ពីគម្ពីរពុទ្ធសាសនាដែរ គ្រាន់តែអ្នកប្រាជ្ញខ្មែរយើងយកមកច្នៃប្រឌិត សំរបសំរួលទៅតាមលក្ខណៈពិសេសរបស់ទឹកដី និងប្រជាជនខ្មែរប៉ុណ្ណោះ ។ ទោះបីយ៉ាងណាក៏ដោយ ក៏គម្ពីរ សាស្ត្រា ដែលលើកយកមកបង្ហាញខាងលើនេះ មានគោលបំណងដូចគ្នា :

- បង្ហាញពីទស្សនៈពុទ្ធសាសនា ស្តីពីទក្ខិណានុប្បទានដែលធ្វើឡើង សំរាប់អ្នកស្លាប់ទៅហើយ ។

- ដើម្បីបង្កលក្ខណៈងាយស្រួលដល់ព្រះសង្ឃ ក្នុងការស្វែងរកបិណ្ឌបាត ព្រោះរយៈពេលនេះ អាកាសធាតុអាប់អួរ ផ្ទៃមេឃក្រាស់ដោយពពក ភ្លៀងធ្លាក់រលឹមជាប់ ។

- បង្ហាញពីមនោសញ្ចេតនារបស់គ្រួសារខ្មែរ ដែលតែងតែមានផ្ទត់សម្ពន្ធភាពយ៉ាងស្អិតល្មួតរវាងគ្នានឹងគ្នា ទោះបីជាអ្នកណាមួយក្នុងគ្រួសារ ត្រូវបាត់បង់ជីវិតទៅហើយក៏ដោយ ក៏ពុំអាចរលុប ភ្លេចបានដែរ ។

រៀបរៀងដោយ

- **ម៉ែន ឫទ្ធាខ**
- **អាំ ឆន**

# អំពីពុទ្ធិកសមាគមពិភពលោក
# (ព.ស.ព)
## THE WORLD FELLOWSHIP OF BUDDHISTS
## (WFB)

នៅក្នុងលេខនេះ " កម្ពុជសុរិយា " មានសោមនស្សចេតនានាំយកមកវំលឹកឡើងវិញ នូវប្រវត្តិនៃអង្គការអន្តរជាតិដំបូង និង ដ៏ធំមួយ របស់ពុទ្ធសាសនា, នោះគឺ *ពុទ្ធិកសមាគមពិភពលោក* ។ អង្គការនេះ ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៥០ ក្នុងទីក្រុងកូឡំបូ ប្រទេសស្រីលង្កា ដោយមានប្រតិភូតំណាងមកពីប្រទេស ២៧ ក្នុងទ្វីបអាស៊ី, ទ្វីបអឺរ៉ុប និងអាមេរិកខាងជើង (រួមទាំងរដ្ឋហាវៃផង) មកចូលរួមក្នុងការប្រជុំ ។ ស្ទើរតែគ្រប់និកាយនៃពុទ្ធសាសនាក្នុង*មហាយាន* (អាចរិយវាទ), *ហីនយាន* ( ថេរវាទ ) និងប្រពៃណី*វជ្រយាន* ត្រូវបានបញ្ជូនសមាជិកជាសង្ឃក៏មាន គ្រហស្ថក៏មាន អោយមកចូលរួមជាតំណាងក្នុងការប្រជុំនោះ ។ នោះប្រហែលជាលើកទីមួយហើយ នៅក្នុងប្រវត្តិនៃពុទ្ធសាសនា ដែលការប្រជុំបែបនេះត្រូវបានរៀបចំឡើង ។ គ្មាននិកាយ, គណៈ ឬអង្គការពុទ្ធសាសនាណាមួយមិនចង់មកចូលរួមនោះទេ ។ ដោយប្រការនេះ, ពុទ្ធិកសមាគមពិភពលោកត្រូវបានបង្កើតឡើង ហើយតាងផលប្រយោជន៍រួមរបស់ពុទ្ធសាសនិកជនក្នុងពិភពលោករាប់ រយលាននាក់ ។

ក្នុងរយៈពេលជាង ៤០ ឆ្នាំនៃអត្ថិភាពរបស់ខ្លួន, ព.ស.ព បានរីកចំរើនយ៉ាងសម្បើម ។ នៅពេលបង្កើត, មានតែមជ្ឈមណ្ឌលភូមិភាគ ២៧ នៅក្នុង ២៧ ប្រទេស នៃទ្វីបទាំងបីនៃពិភពលោកទេ, ឥឡូវនេះ ព.ស.ព មាន ៩៨ មជ្ឈមណ្ឌល

ភូមិភាគ នៅក្នុង ៣៧ ប្រទេស នៃទ្វីបទាំងប្រាំរបស់ពិភពលោក ។ ព.ស.ព មិនគ្រាន់តែបានរីកចំរើនខាងបរិមាណប៉ុណ្ណោះទេ, ប៉ុន្តែ បានដុះដាល ទាំងកម្លាំង ទាំងឯកភាព និងទាំងសាមគ្គីភាពផងដែរ ។ ព.ស.ព ត្រូវបានអង្គការអ៊ុយណេស្កូទទួលស្គាល់ ទុកជាអង្គការអន្តរជាតិក្រៅរដ្ឋាភិបាលមួយ ។ មជ្ឈមណ្ឌល ព.ស.ព បានរួបរួមគ្នាជាសមាជ, ជាសហភាព និងជាសហពន្ធ ដើម្បីបង្ហាញអោយឃើញនូវឯកភាព និងសាមគ្គីភាពរបស់ខ្លួន ។ យ៉ាងហោចណាស់ ព.ស.ព បាននាំយកពុទ្ធសាសនិកជនទាំងឡាយក្នុងពិភពលោក អោយមកជួបគ្នា ស្គាល់គ្នាទៅវិញទៅមក និងមានលទ្ធភាពទាក់ទងគ្នាយ៉ាងជិតស្និទ្ធ បង្កើតបានជាទំនាក់ទំនងរវាងពុទ្ធ-សាសនិកខាងទក្ខិណទិស ជាមួយពុទ្ធសាសនិកខាងឧត្តរទិសដោយគ្មានអស្មិមានះ ឬការរង្កៀសចិត្តនៅក្នុងមហាគ្រួសារពិភពលោក ប្រកបដោយភាតរភាព និងសហប្រតិបត្តិការ ។

គួររំលឹកឡើងវិញថា ប្រទេសកម្ពុជា ក៏បានបញ្ជូនគណៈប្រតិភូសង្ឃមួយដឹកនាំដោយព្រះមហាសុមេធាធិបតី ជួន ណាត ជោតញ្ញាណោ ព្រះសង្ឃនាយកគណៈមហានិកាយ (កាលនោះ) ទៅចូលរួមក្នុងសមាជនៅទីក្រុងកូឡុំបូ ប្រទេសសីឡុង់ (ស្រីលង្កា) ដើម្បីបង្កើតជាពុទ្ធិកសមាគមពិភពលោក ក្នុងឆ្នាំ១៩៥០ដែរ ។ បន្ទាប់មក មជ្ឈមណ្ឌលភូមិភាគពុទ្ធិកសមាគមពិភពលោកមួយ ក៏ត្រូវបានបង្កើតឡើងនៅកម្ពុជា ដែលមានទីស្នាក់ការនៅក្នុងវត្តឧណ្ណាលោម ក្រុងភ្នំពេញ ហើយនៅក្នុងឆ្នាំ ១៩៦១, មជ្ឈមណ្ឌលភូមិភាគ ព.ស.ព កម្ពុជា បានរៀបចំមហាសន្និបាត ព.ស.ព មួយ នៅទីក្រុងភ្នំពេញ ដែលបានប្រព្រឹត្តទៅពីថ្ងៃទី១៤ ដល់ថ្ងៃទី២៦ ខែវិច្ឆិកា ។ ព.ស.ព មជ្ឈមណ្ឌលភូមិភាគកម្ពុជា ត្រូវបានបាត់ឈ្មោះ បាត់សំឡេង រលំរលាយ ទាំងអង្គការចាត់តាំង ចាប់តាំងពីខែមេសា ១៩៧៥ រហូតមកដល់បច្ចុប្បន្ន ។ តើ ព.ស.ព មជ្ឈមណ្ឌលភូមិភាគកម្ពុជា នឹងរស់រានឡើងវិញដើម្បីបន្តសកម្មភាព

របស់ខ្លួនរួមចំណែកជាមួយ ព.ស.ព មជ្ឈមណ្ឌលភូមិភាគនៃប្រទេសដទៃ ក្នុងពិភពលោក ឬយ៉ាងណានោះ វាអាស្រ័យលើពេលវេលា និងស្មារតីភ្ញាក់រលឹករបស់ពុទ្ធសាសនិកជនកម្ពុជា តែប៉ុណ្ណោះ ។

ដើម្បីអោយអស់លោកអ្នកអាន បានយល់ទូលំទូលាយបន្តិច អំពីពុទ្ធិកសមាគមពិភពលោក " កម្ពុជសុរិយា " មានសេចក្តីរីករាយលើកយកប្រវត្តិសង្ខេបមកបញ្ជាក់ ដូចតទៅ ៖

## ដើមកំណើត

នៅក្នុងខែធ្នូ ឆ្នាំ១៩៤៧, " ពុទ្ធិកសមាគមទូទាំងសីឡង់ (The All Ceylon Buddhist Congress) ", នាសម័យប្រជុំប្រចាំឆ្នាំរបស់ខ្លួន លើកទី ២៨ បានចេញសេចក្តីសំរេចចិត្តមួយ ដោយឯកភាពគ្នាថា ពុទ្ធិកសមាជ ត្រូវចាត់វិធានការអញ្ជើញតំណាងទាំឡាយ អំពីប្រទេសកាន់ពុទ្ធសាសនា និងអំពីប្រទេសដែលមានសហគមន៍ពុទ្ធសាសនិកជន មកចូលរួមក្នុងពុទ្ធិកសមាជពិភពលោក ដែលនឹងត្រូវប្រព្រឹត្តទៅ នៅក្នុងប្រទេសសីឡង់ ក្នុងឆ្នាំ១៩៥០ ក្នុងគោលដៅបង្វិតពុទ្ធសាសនិកជនពិភពលោក អោយចូលជិតគ្នា, ផ្លាស់ប្តូរពតិមាន និងទស្សនះស្តីពីលក្ខណសម្បត្តិនៃពុទ្ធសាសនា នៅក្នុងប្រទេសផ្សេងៗ ហើយពិភាក្សាគ្នារកច្រក និងមធ្យោបាយ ដែលអាចធ្វើអោយសំរេចកើតមានសន្តិភាព និងសុភមង្គល ដើម្បីដល់ពុទ្ធសករាជកន្លងទៅគម្រប់ ២៥០០ ឆ្នាំ ក្នុងឆ្នាំ១៩៥៦ ក្រោយព្រះពុទ្ធអង្គបរិនិព្វានទៅ, ពិភពលោកទាំងមូល ត្រូវប្រកាន់យកគន្លងនៃការរស់នៅតាមពុទ្ធសាសនា ។

ស្របតាមទស្សនះនេះ គណៈកម្មាធិការរៀបចំមួយ ត្រូវបានបង្កើតឡើង ដើម្បីរៀបចំការងារចាំបាច់ទាំងឡាយ, ដោយមានលោកសាស្ត្រាចារ្យគុណាបាលបិយសេរះ ម៉ាឡាឡាសេកេរះ (Gunapala Piyasera Malalasekera) និង បណ្ឌិត វ.អី.អា ហ្វុងសេកា (W.E.A Fonseka) ជាលេខាធិការកិត្តិយស,

ហើយលិខិតអញ្ជើញ ក៏ត្រូវបានបញ្ជូនចេញក្នុងនាមរបស់លោកទាំងពីររូប ទៅកាន់ភាគផ្សេងៗ នៃពិភពលោក, ស្នើសុំសហប្រតិបត្តិការអំពីពុទ្ធសាសនិកជន និងអង្គ-ការពុទ្ធសាសនាទាំងឡាយ ហើយប្រកាសដំណឹងថា សមាជមួយសម្រាប់បង្កបង្កើតពុទ្ធិកសមាគមពិភពលោក នឹងត្រូវប្រព្រឹត្តទៅក្នុងសប្តាហ៍ចុងក្រោយ នៃខែឧសភា ហើយនិងសប្តាហ៍ទីមួយ នៃខែមិថុនា ឆ្នាំ១៩៥០ ។ លោកសាស្ត្រាចារ្យ ម៉ាឡាឡា-សេកេរៈ, ដែលបានទៅចូលរួមនៅក្នុងសន្និសីទនៃទស្សនវិទូខាងកើត ខាងលិច នៅឯសកលវិទ្យាល័យនៃរដ្ឋហាវ៉ៃ ក្នុងខែមិថុនា ឆ្នាំ១៩៤៩ ក៏បានឆ្លៀតឱកាសទាក់ទងជាមួយអង្គការពុទ្ធសាសនា យ៉ាងច្រើន នៅក្នុងបណ្តាប្រទេសដែលលោកគាប់ជួនធ្វើទស្សនកិច្ចតាមផ្លូវនៅក្នុងទ្វីបអាមេរិក, ទ្វីបអឺរ៉ុប និងទ្វីបអាស៊ី ហើយលោកឆ្លៀតឱកាសនោះ ចុះក្នុងបញ្ជីនូវសមានចិត្ត និងការគាំទ្រ របស់អង្គការក្នុងប្រទេសទាំងនោះ ។

កាលនោះ មានប្រតិភូ ១២៩ រូប មកពីប្រទេស ២៧ ដែលបានមកចូលរួមក្នុងសន្និសីទលើកទីមួយ ដោយមានតំណាងពីនិកាយនានានៃពុទ្ធសាសនា មានជាអាទិ៍មហាយាន, ថេរវាទ និងប្រពៃណីវជ្រយាន ។ ដោយប្រការនេះ ពុទ្ធិកសមាគមពិភព-លោក ត្រូវបានបង្កើតឡើងនៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៥០ ត្រូវនឹង ព.ស ២៤៩៣ នៅក្រុងកូឡុំបូ ប្រទេសស្រីលង្កា ក្នុងគោលដៅនាំយកពុទ្ធសាសនិកជនពិភពលោក អោយមកជួបជុំគ្នា ដើម្បីប្តូរពត៌មាន និងទស្សនៈ អំពីស្ថានភាពនៃពុទ្ធសានិកជនទាំងឡាយ ក្នុងប្រទេសផ្សេងៗ ហើយនិងដើម្បីជជែកគ្នារកផ្លូវ និងមធ្យោបាយដែលនាំអោយពុទ្ធសាសនិកជនធ្វើវិភាគទានសមស្របដល់ការធ្វើអោយកើតមានសន្តិភាព និង សុភមង្គល ក្នុងពិភពលោកទូទៅ ។

គេនៅចាំបានថា សម័យប្រជុំពេញអង្គដំបូងនៃសន្និសីទ បានប្រព្រឹត្តទៅនៅទីក្រុង កាន់ឌី (Kandy) ។ ព្រះសពព្រះតេជព្រះគុណ រីរី ណាកាយ៉ាម៉ា (Riri

Nakayama) អំពីប្រទេសជប៉ុន បានអំពាវនាវដល់ពុទ្ធសាសនិកជនទាំងឡាយក្នុងពិភពលោកប្រកបដោយហឫទ័យក្តុកក្តួល និងជលនេត្រហាម, សុំអោយជួយយកចិត្តគិតគូរ ធ្វើអោយកើតមានសន្តិភាពជានិរន្តរ៍ទូទៅក្នុងពិភពលោក ។ នៅពេលនោះ ប្រទេសជប៉ុន នៅតែឃើញរូបភាពស្ដែងៗ នៃមហាទុក្ខសោក និងវិនាសកម្មបណ្ដាលមកពីគ្រាប់បែកអាតូមិកពីរគ្រាប់ ធ្លាក់លើទីក្រុងហ៊ីរ៉ូស៊ីម៉ា និងណាហ្គាសាគីក្នុងឆ្នាំ ១៩៤៥ នៅឡើយ ។ សេចក្តីអំពាវនាវនោះ ត្រូវបានកាសែតទាំងឡាយនៅទីក្រុងកូឡុំបូ សរសេរជាចំណងជើងធំៗ នៅលើទំព័រដើមរបស់គេ ។

ប្រតិភូជាច្រើនដែលចូលរួមក្នុងសន្និសីទដំបូងនោះ បានគាំទ្រមតិបង្កើតពុទ្ធិកសមាគមពិភពលោក ( ព.ស.ព ) ហើយបោះឆ្នោតជ្រើសតាំងបណ្ឌិត គ.ប ម៉ាឡាឡាសេកេរៈ ជាប្រធានស្ថាបនិករបស់សមាគម ។ សន្និសីទបានគាំទ្រ ផងដែរនូវគោលបំណង និងកម្មវត្ថុ ដូចតទៅនេះ :

## គោលបំណង និងកម្មវត្ថុ

១. លើកស្ទួយក្នុងចំណោមសមាជិកទាំងឡាយ នូវការកាន់ និងការប្រតិបត្តិតាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធដោយម៉ត់ចត់,

២. ធានាអោយមានឯកភាព សាមគ្គីភាព និងភាតរភាព ក្នុងបណ្ដាពុទ្ធ-សាសនិកជន,

៣. ផ្សព្វផ្សាយទ្រឹស្តីដ៏ឧត្តមរបស់ព្រះពុទ្ធ,

៤. ចាត់តាំង និងអនុវត្តសកម្មភាពខាងសង្គមកិច្ច, ខាងអប់រំ និងខាងវប្បធម៌ ហើយនិងកិច្ចការមនុស្សធម៌ដទៃទៀត,

៥. ខិតខំធ្វើដើម្បីអោយមានសន្តិភាព និងសុខដុម ក្នុងចំណោមមនុស្ស,

អោយមានសុភមង្គលសំរាប់សព្វសត្វ ហើយរួមសហការ ជាមួយអង្គការទាំងឡាយ ដែលធ្វើការសម្រាប់គោលដៅដូចគ្នា ។

## ទីបញ្ជាការ (Headquarters)

១៩៥០ - ១៩៥៨ ទីក្រុងកូឡុំបូ, ស្រីលង្កា
១៩៥៨ - ១៩៦៣ ទីក្រុងរង្គូន, ភូមា
១៩៦៣ ... ទីក្រុងបាងកក, ថៃឡង់

## ប្រធាន

១៩៥០ - ១៩៥៨ លោកសាស្ត្រាចារ្យ គ.ប ម៉ាឡាឡាសេកេរៈ នៃប្រទេស ស្រីលង្កា
១៩៥៨ - ១៩៦៣ លោក អ៊ូ ចាន់ ទុន នៃប្រទេសភូមា
១៩៦៣ - ១៩៨៤ ព្រះអង្គម្ចាស់ក្សត្រី ពូន ពិស្ម័យ ឌិស្កុល នៃប្រទសថៃ
១៩៨៤ ....... លោក សន្យា ធមិសក្តិ នៃប្រទេសថៃ

## មហាសន្និបាត ( ពីឆ្នាំ ១៩៥០ - ១៩៩០ )

ទីមួយ នៅក្រុងកូឡុំបូ, ស្រីលង្កា ( ២៥ ឧសភា - ៦ មិថុនា ១៩៥០ )
ទីពីរ នៅក្រុងតូក្យូ, ជប៉ុន ( ២៥ - ៣០ កញ្ញា ១៩៥២ )
ទីបី នៅក្រុងរង្គូន, ភូមា ( ៣ - ១៧ ធ្នូ ១៩៥៤ )
ទីបួន នៅក្រុងកដ្ឋមណ្ឌុ, នេប៉ាល់ ( ១៥ - ២១ វិច្ឆិកា ១៩៥៦ )
ទីប្រាំ នៅក្រុងបាងកក, ថៃឡង់ ( ២៤ - ៣០ វិច្ឆិកា ១៩៥៨ )
ទីប្រាំមួយ នៅក្រុងភ្នំពេញ, កម្ពុជា ( ១៤ - ២២ វិច្ឆិកា ១៩៦១ )

ទីប្រាំពីរ នៅក្រុងសារនាថ, ឥណ្ឌា ( ២៩ វិច្ឆិកា - ៤ ធ្នូ ១៩៦៤ )
ទីប្រាំបី នៅក្រុងឈៀងម៉ៃ, ថៃឡង់ ( ៦ - ១២ វិច្ឆិកា ១៩៦៦ )
ទីប្រាំបួន នៅក្រុងកូឡាឡាំពួរ ប៉េណាំង, ម៉ាឡេស៊ី
( ១៣- ២០ មេសា ១៩៦៩ )
ទីដប់ នៅក្រុងកូឡុំបូ, ស្រីលង្កា ( ២២ - ២៧ ឧសភា ១៩៧២ )
ទីដប់មួយ នៅថៃឡង់, ( ២០ - ២៥ កុម្ភៈ ១៩៧៦ )
ទីដប់ពីរ នៅក្រុងតូក្យូ និង ក្យូតូ, ជប៉ុន ( ១ - ៦ តុលា ១៩៧៨ )
ទីដប់បី នៅក្រុងបាងកក និង ឈៀងម៉ៃ , ថៃឡង់
( ២២ - ២៨ វិច្ឆិកា ១៩៨០ )
ទីដប់បួន នៅក្រុងកូឡុំបូ, ស្រីលង្កា ( ២ - ៧ សីហា ១៩៨៤ )
ទីដប់ប្រាំ នៅក្រុងកដ្ឋមណ្ឌុ, នេប៉ាល់ ( ២៦ វិច្ឆិកា - ២ ធ្នូ ១៩៨៦ )
ទីដប់ប្រាំមួយ នៅក្រុងឡូសអង់ហ្សឺឡេស, ស.រ.អា
( ១៩ - ២៦ វិច្ឆិកា ១៩៨៨ )
ទីដប់ប្រាំពីរ នៅក្រុងសេអ៊ូល, កូរ៉េខាងត្បូង ( ២១-២៦ តុលា ១៩៩០ )
( មហាសន្និបាតបន្តបន្ទាប់ទៀត ពុំទាន់ទទួលបានពត៌មាន )

## មជ្ឈមណ្ឌលភូមិភាគ

សមាជិកភាពក្នុងឋានៈជាមជ្ឈមណ្ឌលភូមិភាគ ត្រូវបានអនុញ្ញាតអោយចំពោះអង្គការពុទ្ធសាសនាណា ដែលមានជំហរល្អបង្គួរ និងដែលមានកម្មវត្ថុ និងសកម្មភាពសមស្របជាមួយគោលបំណង និងកម្មវត្ថុរបស់ ព.ស.ព ។ បច្ចុប្បន្ននេះមានមជ្ឈមណ្ឌលភូមិភាគចំនួន ៩៨ នៅក្នុង ៣៧ ប្រទេស និងនៅក្នុងគ្រប់ទ្វីប នៃពិភពលោក ។

## សកម្មភាព ៖

បន្ថែមទៅលើការកោះប្រជុំ ពីរឆ្នាំម្តងៗ នៃមហាសន្និបាត និងការប្រជុំទាំងឡាយរបស់គណៈកម្មាធិការប្រត្តិបត្តិ និង ក្រុមប្រឹក្សាទូទៅ, ព.ស.ព បានដឹកនាំរៀបចំសិក្ខាសាលា និងការប្រជុំជាអន្តរជាតិជាច្រើនផ្សេងទៀត សម្រាប់មេដឹកនាំពុទ្ធសាសនា, អ្នកអប់រំ អ្នកប្រាជ្ញនានា, ទៅតាមពេលវេលាកំណត់ ដើម្បីផ្លាស់ប្តូរយោបល់ ហើយពិភាក្សាដោះស្រាយបញ្ហាទាំងឡាយដែលទាក់ទងដល់កិច្ចការពុទ្ធ-សាសនា ។ ទីបញ្ចាការ ព.ស.ព នៅក្រុងបាងកក បានជួយសម្រួលការសិក្សាពុទ្ធសាសនា និងការបួសជាភិក្ខុសង្ឃ សំរាប់យុវបុរស និង យុវនារី មកពីប្រទេសលោកខាងលិច ក៏ដូចជានៅអាស៊ីនេះស្រាប់, ហើយនិងបានបើកថ្នាក់បង្រៀនសមាធិ នៅរៀងរាល់ថ្ងៃពុធដំបូងគេ នៃខែនិមួយៗ ។

ព.ស.ព បានទទួលឋានៈជាអង្គការពិគ្រោះ សម្រាប់អង្គការអ៊ុយណេស្កូ ក្នុងក្រុមអង្គការក្រៅរដ្ឋាភិបាល ប្រភេទ «ខ» ដើម្បីតំណាងទស្សនះរបស់ពុទ្ធសាសនិកជននៅលើបញ្ហាដែលទាក់ទងនឹងការអប់រំ វប្បធម៌ និង គមនាគមន៍ នៅក្នុងសន្និសីទ និងក្នុងការប្រជុំរបស់ អ៊ុយណេស្កូ ។ ព.ស.ព ចូលរួមក្នុងសកម្មភាព និងគម្រោងការងារ ដ៏ច្រើនរបស់ភ្នាក់ងារទាំងឡាយនៃអង្គការសហប្រជាជាតិ ។ ព.ស.ព ក៏បានចាត់វិធានការផ្សេងៗដែរ ដែលស្ថិតក្នុងសមត្ថភាពរបស់ខ្លួននៅក្នុងការងារសង្គមកិច្ច និង មនុស្សធម៌ ។

## ការបោះពុម្ពផ្សាយ

លេខាធិការដ្ឋាន ព.ស.ព បោះពុម្ពសៀវភៅ ឯកសារទាំងឡាយដែលនិយាយ រាយការណ៍អំពីសកម្មភាពរបស់ ព.ស.ព និងជួយសម្រួលការសិក្សា និងការចង់ដឹងអំពីពុទ្ធសាសនាទូទៅក្នុងពិភពលោក ។ កាសែតមួយ មានចំណងជើងថា ៖ « WFB Review » ( ទស្សនាវដ្តី ព.ស.ព ) ចេញផ្សាយ ៤ ខែមួយលេខ

មានអត្ថបទជាច្រើន សរសេរដោយអ្នកប្រាជ្ញខាងពុទ្ធសាសនា និងមានពត៌មានស្ដីពីសកម្មភាពនៃពុទ្ធសាសនា នៅក្នុងពិភពលោក ។ ឈ្មុតនៃសៀវភៅ ព.ស.ព (The WFB Book Series) ជាភាសាអង់គ្លេស និង ភាសាថៃ និយាយយ៉ាងទូលំទូលាយអំពីប្រធានបទទាំងឡាយទាក់ទងដល់ពុទ្ធសាសនា ។

នៅលេខក្រោយៗ "កម្ពុជសុរិយា" នឹងខិតខំចុះផ្សាយពត៌មានដែលទាក់ទងដល់ពុទ្ធិកសមាគមពិភពលោកបន្តទៅទៀត ដើម្បីជាគុណប្រយោជន៍ដល់ការយល់ដឹងរបស់អស់លោកអ្នកអាន អំពីសកម្មភាពនៃអង្គការពុទ្ធសាសនាដ៏ធំនេះ ក្នុងការរួមចំណែកធ្វើអោយសន្តិភាព និង សុភមង្គល ក្នុងពិភពលោក កើតមានជានិរន្តរ៍ដល់សព្វសត្វ តាមរយៈព្រះធម៌ ជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ។

ឈន អៀម

# សង្គាយនាទី ២

ព្រះសម្ពុទ្ធបរិនិព្វានកន្លងទៅមួយសតវត្សហើយ ។ កាលនោះ មានភិក្ខុមួយក្រុម នៅក្នុងដែនវជ្ជី ជាអ្នកល្មោភលាភសក្ការៈ បានបញ្ញត្តនូវវត្ថុ ១០ ប្រការ ដែលផ្ទុយនឹងពុទ្ធប្បញ្ញត្តិ ។ ឯព្រះបាទកាលាសោក ក៏ជឿតាមពាក្យបញ្ចុះបញ្ចូលរបស់ពួកភិក្ខុទាំងនោះដែរ ។

វត្ថុ ១០ ប្រការនោះ គឺ :

**១. កប្បតិ សិង្គិលោណកប្បោ** ... វិនយប្បញ្ញត្តិក្នុងសន្និធិការកសិក្ខាបទ ក្នុងសុត្តវិភង្គថា « *របស់ជាយាវកាលិក* (របស់ដែលភិក្ខុអាចទទួលឆាន់បានត្រឹមតែពីពេលអរុណោះ រហូតដល់ពេលថ្ងៃត្រង់ប៉ុណ្ណោះ) *បើភិក្ខុបានទទួលប្រគេន ហើយទុកដាក់អោយកន្លងរាត្រីយកមកឆាន់ ត្រូវអាបត្តិបាចិត្តិយៈ* » ។ ពួកវជ្ជីបុត្តកភិក្ខុ សំដែងឡើងថា « *អំបិលដែលដាក់ក្នុងក្លាក់ស្នែង បើទុកអោយកន្លងរាត្រី ហើយយកមកឆាន់ជាមួយនឹងអាហារបិណ្ឌបាតដែលសាបបាន មិនត្រូវអាបត្តិឡើយ* » ។

**២. កប្បតិ ទ្វង្គុលកប្បោ** ... វិនយប្បញ្ញត្តិក្នុងវិកាលភោជនសិក្ខាបទ ក្នុងសុត្តវិភង្គថា « *ភិក្ខុឆាន់របស់ជាយាវកាលិក ក្នុងវេលាវិកាល* (ក្រោយពីពេលអរុណោះដល់ពេលថ្ងៃត្រង់) *ត្រូវអាបត្តិបាចិត្តិយៈ* » ។ ពួកវិជ្ជីបុត្តកភិក្ខុ សំដែងឡើងថា « *បើព្រះអាទិត្យជ្រេរពីត្រង់ទៅហើយប្រមាណពីរធ្នាប់ ក៏ភិក្ខុគួរឆាន់របស់ជាយាវកាលិកបាន មិនត្រូវអាបត្តិឡើយ* » ។

**៣. កប្បតិ គាមន្តរកប្បោ** ... វិនយប្បញ្ញត្តិក្នុងបឋមបវារណាសិក្ខាបទ ក្នុងសុត្តវិភង្គថា « *ភិក្ខុឃាមភោជន ហើយក្រោកចាកទីនោះទៅឆាន់*

*អនតិរិត្តភោជន* (ភោជនដែលមិនទាន់ធ្វើវិនយកម្ម គឺភោជនដែលមិនទាន់ធ្វើឱ្យទៅជារបស់គួរជាមុនសិន ដូចជារបស់ដែលមានគ្រាប់អាចដុះបានជាដើម) *ត្រូវអាបត្តិបាចិត្តិយៈ* » ។ ពួកវជ្ជីបុត្តកភិក្ខុ សំដែងឡើងថា « *បើភិក្ខុគិតថាអញនឹងចូលទៅកាន់ស្រុកដូច្នេះ ក៏ត្រូវឆាន់អនតិរិត្តភោជនបាន មិនត្រូវអាបត្តិឡើយ* » ។

៤. **កប្បតិ អាវាសកប្បោ** ... វិនយបញ្ញត្តិក្នុងឧបោសថក្ខន្ធកៈទី២ ក្នុងខន្ធកវិន័យថា « *ទីអាវាសដែលនៅក្នុងសីមាជាមួយគ្នា ភិក្ខុនឹងធ្វើសង្ឃកម្មទាំងពួង មានឧបោសថកម្មជាដើមផ្សេងគ្នាមិនគួរ បើធ្វើដូច្នេះ ត្រូវអាបត្តិទុក្កដ, កម្មដែលធ្វើនោះសោត ក៏មិនមែនជាសង្ឃកម្មឡើយ* » ។ ពួកវជ្ជី បុត្តកភិក្ខុសំដែងឡើងថា « *ត្រូវធ្វើបាន ឥតមានទាស់ឡើយ* » ។

៥. **កប្បតិ អនុមតិកប្បោ** ... វិនយបញ្ញត្តិក្នុងចម្មេយ្យក្ខន្ធកៈទី៩ ក្នុងខន្ធកវិន័យថា « *ភិក្ខុនឹងធ្វើសង្ឃកម្មទាំងពួង ត្រូវប្រជុំភិក្ខុដែលមាននៅក្នុងសីមាជាមួយគ្នា អោយមកប្រជុំព្រមជាប់ហត្ថបាសគ្នា ឬ បាននាំឆន្ទៈបរិសុទ្ធ* (គឺនាំដំណឹងភិក្ខុដែលមានធុរៈមិនបានចូលមកប្រជុំ) *នៃភិក្ខុដែលមានកិច្ចធុរៈ មិនបានមកកាន់ហត្ថបាសនោះ ទើបធ្វើបាន, បើមិនធ្វើដូច្នេះ ហៅថា ធ្វើកម្មជាពួកត្រូវអាបត្តិទុក្កដ, កម្មដែលធ្វើនោះសោត ក៏មិនមែនជាសង្ឃកម្មឡើយ* » ។ ពួកវជ្ជីបុត្តកភិក្ខុ សំដែងឡើងថា « *មិនចាំបាច់មកជួបជុំគ្នាដូច្នោះទេ បើមកដល់មុន នឹងធ្វើសង្ឃកម្មមុនបណ្តើរទៅក៏បាន ឥតមានទាស់ឡើយ* » ។

៦. **កប្បតិ អាចិណ្ណកប្បោ** ... ព្រះធម៌វិន័យពុទ្ធសាសនាមានរបៀបរៀបរៀងជាខ្នាត ជាបន្ទាត់ កំណត់ទុកមកថា នេះខុស នេះត្រូវ រួចជាស្រេចហើយ, *សេចក្តីប្រតិបត្តិជាចរិតរបស់ឧបជ្ឈាយ៍ អាចារ្យតៗមក បើត្រូវសមតាមរបៀប*

*ធម៌វិន័យនោះ ទើបអោយសិស្សានុសិស្សទាំងពួងប្រតិបត្តិតាម, បើមិនត្រូវ មិនសមទេនោះ សិស្សានុសិស្សទាំងពួង មិនត្រូវប្រតិបត្តិតាមឡើយ ។* ពួកវជ្ជីបុត្តកភិក្ខុសំដែងឡើងថា « *សេចក្តីប្រតិបត្តិជាចរិតទំនៀមទម្លាប់របស់ឧបជ្ឈាយ៍ អាចារ្យ ទោះខុសក្តី ត្រូវក្តី សិស្សានុសិស្សទាំងពួង ត្រូវប្រតិបត្តិតាមបាន ឥតមានទាស់ឡើយ* » ។

៧. **កប្បតិ អមថិតកប្បោ** ... ទឹកដោះស្រស់ដែលប្រែចាកភាពដើមហើយ តែនៅមិនទាន់ក្លាយទៅជាទធិ (ទឹកដោះជូរ, ទឹកដោះជូរឡើងពពុះ) មានវិនយបញ្ញត្តិថា « *ភិក្ខុឃាមភោជនហើយក្រោកចាកទីនោះ ហើយឆាន់ទឹកដោះជាអនតិរិត្តនោះ ត្រូវអាបត្តិបាចិត្តិយៈ* ( តាមន័យក្នុងបឋមបវារណាសិក្ខាបទ ) » ។ ពួកវជ្ជីបុត្តកភិក្ខុ សំដែងឡើងថា «*ឆាន់បាន មិនត្រូវអាបត្តិឡើយ* » ។

៨. **កប្បតិ ជលោគី បាតុំ** ... *តរុណសុរា* គឺសុរាដែលគេដាក់គ្រឿងស្រវឹងផ្សំត្រាំជាមួយគ្នាហើយ តែនៅខ្សោយ មិនទាន់ពេញជាទឹកស្រវឹងនៅឡើយ, *បើភិក្ខុផឹក ត្រូវអាបត្តិបាចិត្តិយៈ* ( តាមន័យក្នុងសុរាបានសិក្ខាបទ ក្នុងសុត្តវិភង្គ ) ។ ពួកវជ្ជីបុត្តកភិក្ខុ សំដែងឡើងថា « *តរុណសុរានោះ ភិក្ខុផឹកបាន មិនត្រូវអាបត្តិឡើយ* » ។

៩ . **កប្បតិ អទសកំ និសីទនំ** ... វិនយបញ្ញត្តិក្នុងនិសីទនសិក្ខាបទក្នុងសុត្តវិភង្គថា « *ភិក្ខុនឹងធ្វើសំពត់និសីទនៈ* ( សំពត់សំរាប់ភិក្ខុក្រាលអង្គុយ ) *ត្រូវធ្វើអោយមានជាយ, បើមិនធ្វើដូច្នេះទេ ត្រូវអាបត្តិបាចិត្តិយៈ* » ។ ពួកវជ្ជីបុត្តកភិក្ខុ សំដែងឡើងថា « *មិនបាច់ធ្វើអោយមានជាយ ក៏អាចប្រើបានដែរ មិនត្រូវអាបត្តិឡើយ* » ។

១០ . **កប្បតិ ជាតរូបរជតំ** ... វិនយបញ្ញត្តិក្នុងរូបិយសិក្ខាបទ ក្នុង

សុត្តវិភង្គថា « *ភិក្ខុមិនត្រូវទទួល ឬ ត្រេកអរចំពោះមាស ឬ ប្រាក់, បើទទួល ឬ ត្រេកអរ ត្រូវអាបត្តិបាចិត្តិយៈ* » ។ តែក្នុងមេណ្ឌកបញ្ញត្តិ ក្នុងភេសជ្ជខន្ធកៈទី ៦ ក្នុងខន្ធកវិន័យ មានពុទ្ធានុញ្ញាតអោយភិក្ខុត្រេកអរចំពោះបច្ច័យ ៤ ដែលកើតអំពីរូបិយៈ គឺ មាស ឬ ប្រាក់នោះបាន ។ ពួកវជ្ជីបុត្តកភិក្ខុ សំដែងឡើងថា « *ភិក្ខុគួរទទួល ទាំងគួរត្រេកអរចំពោះមាស ឬ ប្រាក់នោះ មិនត្រូវអាបត្តិឡើយ* » ។

បាតុភាពដែលលេចឡើងក្នុងរង្វង់នៃព្រះពុទ្ធសាសនានេះបានធ្វើអោយព្រះអរហន្តទាំងឡាយ មានការព្រួយបារម្ភចំពោះការសាបរលាបទៅ នៃព្រះពុទ្ធឱវាទ ព្រោះនេះ ជាប្រផ្នូលអាក្រក់ដំបូង ដែលវានឹងអាចចេះតែសាយភាយបន្តទៅទៀត ។ អាស្រ័យហេតុនេះហើយ ទើបលោកធ្វើការតស៊ូយ៉ាងស្វិតស្វាញ ញ៉ាំងព្រះបាទកាលាសោក ដែលលុះជឿតាមការបញ្ចុះបញ្ចូលរបស់ពួកវជ្ជីបុត្តកភិក្ខុនោះ អោយយល់ការណ៍ពិត យល់នូវធម៌វិន័យរបស់ព្រះពុទ្ធអង្គវិញ ហើយឯកភាពសំរេចព្រះទ័យរៀបចំ អោយមានជាទុតិយសង្គាយនា នោះឡើង ។

សង្គាយនាទី ២ នោះ ហៅថា « សត្តសតិកាសង្គាយនា » ក៏បាន ព្រោះមានការកសង្ឃ ចំនួន ៧០០ អង្គ មានព្រះ *រេវតត្ថេរ* ជាប្រធាន ជាអ្នកបុច្ឆាព្រះវិន័យ ព្រះសូត្រ ព្រះបរមត្ថ និងមានព្រះ *សព្វកាមិត្ថេរ* ជាអ្នកវិសជ្ជនា, ព្រះបាទកាលា-សោក ព្រះចៅក្រុងវេសាលី ជាពុទ្ធសាសនូបត្ថម្ភក៏, ធ្វើនៅវាលុការាម ក្រុងវេសាលី, ធ្វើ ៨ ខែ ទើបសំរេច, ក្រោយព្រះពុទ្ធបរិនិព្វានកន្លងទៅបាន ១០០ ឆ្នាំ ។

រៀបរៀងដោយ

**ម៉ែន ប្រាជ * អាំ ឆន**

កែសំរួលដោយ **ឱម ខែម**

# ល្បើកអង្គរវត្ត

(ត)

១៩. ផ្គួលផ្គក់សព្វសត្វផង នានាំមន្លងដោមដាក់ដល
និព្វានស្ថានមង្គល់ ប្រាប្បនិវាស្ន់ជាតជារា ។
២០. នោះអញខ្ញុំមសង្ខាត ឱសាឃ្លាត់ខ្ចិយចិន្តា
ចាប់ចងជាកាព្យា ស្ញូត្រស៍សេដ្ឋព្រះបរមី ។
២១. ស្តេចអាចផ្លាញមារា នោះពុះពាមាយាយី
បាក់បបប់បងទីដ្ឋី ទ្រើសលែងលុះដោ្យចេស្តា ។
២២. យើងខ្ញុំមស្រណោះសល់ បិតពុំយល់ព្រះធម្មា
យល់តែព្រះរូបារ ស្ថិតលើអាស្នាព្រះអង្គ ។
២៣. ទើព្វខ្ញុំមត្រេកសាធ្លា ឱនសិរសាបង្គំផ្គង
ព្រះរូបប្រសើដ្ឋទ្រង ប្រោសសត្វផងឯក្រោយណារ ។
៣៤. ស្រាច់នៃនិងផ្កាថ្លែង ចចារចែងស៍សេដ្ឋមហា
ប្រសាទទាំងប្រាំមប្រា កដ្ឋកបក័ពិចិត្រក្រៃ ។
២៥. ប្រាសាទនេះឯងណារ ព្រះឥន្ទ្រាទិព្វទេព្វថ្លៃ
ប្រើព្រះពិស្សនុការនៃ្ស ចុះមកក័ថ្យាខ្យត្រា ។
២៦. កាល្មោះអស់ចារក្រៃ មានខ្យត្រថ្លៃស្មោ្យរាជា
ស្តេចទ្រងព្រះនាម្មា ហោរព្រះបាទវង្សអស់ចារ ។

២៧. ស្ដេចមានព្រះអំណាច់ | សៃព្យស្នៀរាជដៀ្យនៅវធម្មិ
គ្រុព្វ៌គ្រងអសរា្យណារ | សិងខ្មៀមដៀ្យព្រះប៉រម៉ិ ។
២៨. ស្ដេច់មានវរជា្យ | ទ្រងនាម្នាទ្បៀវត្យិ
ពោមឆាយស្រស់សោភិ | ជាច្បងច្បស់អសស្មិ៍មផង ។
២៩. អាណៃកនោវបរិពារ | ស្រៀ្យស្រិង្គាឥត់ឯត្តង
ស្រៀ្យស្រស់ទន់ទង្វង | រៀ្យបរា្យរៀ្យងបំរើនិត្យ៍ ។
៣០. ព្រះមហាខ្សត្រត្រកូ្ល | ជាឥសូ្វរអង្គឯកខ្សត្រ
សិងមកប្រនិបុត់ | ថ្វា្យបង្គំមឥតឯត្តង ។
៣១. សិងនាំភ្ជិប្រាក់មាស់ | ច្រើនតេរដាស់ដៀ្យពាណិហោង
ដូង្វា្យនោវសួ្វយផង | ជាប្រក្រត្យិពុំដៃលអាក់្ខ ។
៣២. អាណៃកនោវទ្រាព្យ៍ផង | រត្នកៃវកងនោវមាសប្រាក់
ព្រំមព្រៃរវិសៃ្យចក់្ខ | ខៀ្សនក្រឡាកាសាផាន់្ខ ។
៣៣. អាណៃកនោវដំរិ្យ | រត្នពាជិរាជាយាន
ក្លឹងក្លស់នោវភិជាន | រាំងននឞៃបមាសមាលោ ។
៣៤. អានៃកនោវរេពល់ | ទាំងសុកលសៃនយោទ្ធា
ខុណ្ណាងមន្រ្តិយព្រាវ | គ្រុព្វគុង្គាល់ច្រើនក្រាស់ក្រៀ្យ ។
៣៥. ស្ដេចមានព្រះរាជាបុត្រ | ប្រុសពិសុទ្ធពិសៃសក្រៃ
ប្រសើឌព្រះនាមនៃ្យ | ហោវព្រះកៃតុមាលាហោង ។
៣៦. ឬព្រះរាជកូ្វមារ | បុន្យ៍សំភារក្រៃកន្លង
ឮទ្វរសព្វសា្យហោង | អស់ចារកើតកាល្មោះណា ។
៣៧. ក៏គ្រាក់តាល់ដ្ឋូចដល់ | សូ្វរសុកលត្រៃត្រើង្សា

សំដេចព្រះឥន្រ្ទា បើកទិព្វចក្ខុមើលមកហោង ។
៣៨- យល់ព្រះរាជកុមារ មានសំភារក្រៃកន្លង
ជៀងជាក់ជាច្បាស់ច្បង លើសលែងលុងលើខ្សត្រា ។
៣៩- ដឹងតើមបុត្របុរាណ ចុះចាក់ស្ថានត្រៃត្រឹង្សារ
យកប្រតិសន្ធិជា បុត្រព្រះបាទវង្សអស់ចារ ។
៤០- សំដេចព្រះឥន្រ្ទក្សាន ដឹងតៀញាណឯងអស់អាត្តិ
ជៀងជាក់សោះសព្វសារ ពើហាពិត្រពុំសន្ទិះលើ្យ ។
៤១- ទេព្វស្តេចចុះចាកស្ថាន ស្ធរភីមានពុំលុងលើ្យ
យករាជកុមារហើ្យ នាំមទៀងទោវត្រៃត្រឹង្សា ។
៤២- ព្រះឥន្រ្ទស្តេចសន្ទត់ ជាក់ជាបុត្រព្រះអង្គណារ
ស្រលេញថ្នមរាក្សារ ហាក់កើតពីឪមារា ។
៤៣- ការឈ្មោះទេព្វសួរស្ថាន នោវពុំខ្សានសាបៀណារ
សិងឈើហាព្រះសិរសារ បិទធុំមក្លិនម្ទុសរើស្យៃ ។
៤៤- ទេព្វាផងរុំជួល សិងខ្សឹកខ្សលជាទុក្ខក្រៃ្យ
ពុំអាជទុព្ភទីទ្យៃ ឡើងទោវទូលព្រះឥន្រ្ទារ ។
៤៥- បុពិតទេព្វឥសួរ ជាកុំពូលលើហាសិរសា
តៀច្បាប់ស្ថានសួគ៌ា ពុំតែលមានដូច្នេះនៃ្យ ។
៤៦- នាស្តេចយាងយោនយក បុត្រមោះមកសួគ៌ាល្បៃ្យ
យើងខ្ញុំមផងទីទ្យៃ ធុំមក្លិនម្ទុសនោវពុំខ្សាន ។
៤៧- នោះទេព្វព្រះឥន្រ្ទា ធិរាជ្ជាបនទូលថ្កាន
ថាហោតុបុត្របុរាណ អញឯងហោងទេព្វនាំមក ។
៤៨- បើដូច្នោះកុំកុំតឹង ជាទុក្ខនិងបុត្រពន្លក

អញបានជាយកមក ហៀរអញនិងជូនចុះទោរ ។

៤៩. កាល្មោះឯខ្សព្រា កែតុមាលារាជចោមចោរ

អាឡ្វៀដ្បិតធ្លាប់នោរ ប្រាសាទទាំងប្រាំមសុំស្រាច់ ។

៥០. នាមហោរពេជ្ឈយន្តរត្ន ចិញ្ចែងក្កាត់សំក្បូរក្បាច់

ព្រោងប្រុះឆ្លុះរុំលេជ ច្រាលច្រវាឈ់យល់សព្វសារ្យ ។

៥១. ដាំមដាសពាសនីទោរ រត្នឆ្លោះឆ្លោរមាសព្រោងព្រៀ

មារកដ្នកែមពីទ្យ ពេជពុពាលរត្នរៀងរាល់ ។

៥២. ពីទូរសូកាន់កែម និលលក្ខលែមកែមកបកាល

បូទុំមប្រាកពុពារិ មុក្ខដាដេចផ្លែករត្នរាយ ។

៥៣. ទាទិមទិប្តស្រស់ស្រិល ឥន្ទ្រនិលដួរាក្យ

ពិទ្រុមទ្រុតសព្វសា្យ កញ្ចក់ចៃមមាសម្នីយ ។

៥៤. ប្រាក់ប្រុះឆ្លុះព្រោងព្រាយ សែងសូរសា្យនូវបាក្សី

រូតរាក្ខផ្លាកនោរភ្ញី ល្អរប្រសើដ្ឋឥត់ផ្ទឹមបាន ។

៥៥. រុងរឿងថ្កើងល្អរស្រស់ ដោមខ្ពង់ខ្ពស់ប្រាសាទស្ឋាន

ម័ពាន់យោជ្ន៍ប្រមាណ ពីកុំពូលទៀងទាល់ក្រោម ។

៥៦. កុំពូលកុំពស់ស្រួច ស្រោងត្រដួចត្រដឹងតោម

ត្រដេចកន្តោលភ្សោម មារអាកាសវីប៉ាក្សប៉ារ ។

៥៧. ឯក្នុងប្រាសាទសួរ សិងរំឃូលភិដានដា

ភ្លើហាប្រុស់ឆ្លោះរន្ទាល់ នូវសូវាណារត្នរៀងរាយ ។

៥៨. រំឃូលទង់មាលារ នោរបូផាផងទាំងប្បា្យ

រន្ទាលភ្លើហាព្រោងព្រៀ ផ្សប់នីទោរនោរក្លិនភ្ញីយ ។

៥៩. ត្រសាក្ខត្រសៀក់ល្វេង សូរសប្ដភ្លេងភ្លាត់តន្ត្រីយ

របាំមរបៀបស្រីៗ    ទើពអក្សររេរាំមថ្វាយ ។
៦០. ប៉ីវរវរសោភា    អសអង្គារទ្រងឆោមឆាយ
ស្រឡះអង្កែក្រាយ    ឆ្មៀលឆ្វាត់ឆ្វាយស្រួលឥតឆ្គង ។
៦១. បវរវរជួបចាប់    ទ្រងគ្រើងគ្រុពប្រពាប់ផង
សិងស្រសទទង្វង    ទាំងបួនអង្គល្អរប្រពៃ ។
៦២. សំរាប់ព្រះឥន្ទ្រា    ចោមទេវាប្រសើដ្ឋក្រៃ
សេពសុក្ខសំបាត់ត្រៃ    ត្រើង្សពីភុព្ភស្ងួគ្គាល្បៃ ។
៦៣. មើលមានកាលបួព្រឹក្ស    សោតសន្ទីកខ្ពស់ត្រឈៃ
ខ្យលបក់ល្វន់ល្វាសក្រៃ    មែកស្ទោមស្លឹកប្រសព្វគ្នារ ។
៦៤. គនទោរនន្ទឱធ្យាន    សាប្យខ្សានក្នុងចិន្តា
សំរាប់អង្គឥន្ទ្រា    ជាឆ្នើមឆ្នួតអសទេព្វផង ។
៦៥. រៀអសទេព្វកញ្ញា    តែងឱសារនាំមគ្នាផង
ច្រៀងច្រូចស្វរសប្ទុំកង    លេងសប្ទុំដៀទូរទីទ្បៃ ។
៦៦. មានទាំងតើមបរិឆាត់    ខ្ពស់ដោមខ្ពាត់មែកត្រឈៃ
កុំពស់ស្រោងល្វត់ល្បៃ    ហាសិបយោជ្នបរិមន្ទល់ ។
៦៧. ទ្រងផ្ការងដូចឆាត់    ក្លិនក្លែបខ្ពាត់រ្សយោជ្នយល់
ទេព្តាផងរវល់    សេព្យស្នេហ្យសុក្ខក្លិនបួផារ ។
៦៨. ពុំដែលនិងល្ហិតល្ហែយ    ជាសុក្ខក្រៃក្នុងអាត្មា
មានអសផ្ការបរិវ៉ារ    ដុះជាជួររៀបរៀងរាយ ។
៦៩. ខ្ចីងខ្ចីមកែកាកែស    ក្លិនវិសេសផ្ទុំមភាសភាយ
រំចេកកាកែសល្បាយ    ផ្កុលភ្ជូជាន់នោរមហាហង្ស ។
៧០. ពុទ្ធលើរីកពាក់ពាន់    ផ្កាអញ្ញាន់ក្រអូបហ៊ង

រំដួលនៅវត្រយុំង　　មែកពានីពាក់តើមចំបារ ។
៧១. ចន់ធូវមានលុំនៃ　　ដុះបង់ហែរទ្រូងបុផារ
ស្រលិតស្រលុឹយច្បារ　　ស៊ីអន្ទច្រាលខៀវអន្លុង ។
៧២. ក្តាង្វារនៅស្វភ្សី　　ទ្រូងសិងភ្សីយស្រសៗ ជ្រុង
ល្ហារមាសទន់ទង្វង　　វាពាក់ពាត់ផ្ការនួនស្រឿ ។
៧៣. មុងគ្រេង្នើបូក្លាប់　　ស្រសស្រេចស្រាញ់មានរាក្សី
រំដេញមាសរីកថ្មីយ　　នៃបដាវរឿងលឿងក្រសែត ។
៧៤. អសនាងទេព្វអក្សរ　　សិងស្មោះសរអររអាណែក
ហែលហារបែះផ្ការចែក　　គ្នាក្រាលក្រងប្រដាប់អង្គ ។
៧៥. ខ្លះក្រងផ្ការំដួល　　រៀបជាផ្លូវល្អរបញ្ចង
កើតលើុងដូច្នរូបហង្ស　　កាងបាក្ខារវេហើរហោះ ។
៧៦. នាងម្ល្បជន្លប់ស្បៃយ　　ស្តើងបុប្រៀដើរផ្តេកផ្តោះ
បែះផ្ការតៀចន្លោះ　　ផ្ការម្លិះរួតនៅម្លិះលារ ។
៧៧. ក្រងជារូបកីណរី　　ល្អរពិសីមៀងមើលគ្នារ
នាងម្ល្បមុក្ខសើរ៉ា　　ក្រងជារូបសោមបន្ទិត ។
៧៨. ខ្លះក្រងជាសារិការ　　កែវពាំមផ្ការហៀហើរជិត
នៃបនិងសោមបន្ទិត　　ទុំមផ្អងផ្អៀងមៀងមើលគ្នា ។
៧៩. សិងតែច្រៀងលេងសើច　　ខ្សៀវភ្ញាក់ខ្សើចគ្រុព្វគ្នីគ្នា
នីព្យាយហើយពារនា　　សសើរដ្ឋបុន្យអង្គកោសី ។
៨០. នាងខ្លះល្អរឪតំម　　យល់សំណាំមស្រស់ប្រិមប្រិយ
អ្នកនាំមអស់ទាំងស្រៀ　　ទេព្វអក្សរចុះស្រះស្រៀ ។
៨១. ខ្លះហែលបែះផ្ការស្គុន់　　ល្អរទន់ភ្លន់សរកុំប៉្លង

ល្បាស្យនិងផ្ការលំចង់ ផ្កានិលបុលនៅស្បង់កាច់ ។

៨២. ខ្លះសោតល្អស្រង្ហោរ ធ្មេញស្រសខ្មៅរហែលល័ដាច់
ដល់ហៀរដៀកាន់កាច់ ផ្កាក្រមុត់នៅឈូកសែត ។

៨៣. ប៉ងអួតប៉ងអគ្មា ហែលវិរាហាត្រពោមដែត
វា្យទឹកលេងតៀហេតុ រាប់ដើមផ្ការឈូកសរផង ។

៨៤. បែះបានស្រេចកែក្រៀ លេងសាប្យក្នុងស្រះស្រង
នាងខ្លះហែលដិរ៉ង បែះកាច់ឈូកក្នុងជុលសា ។

" នេះបទកាក្កិ"

៨៥. ព្រះកែតសូរវង្ស មៀងមើលរូបទ្រង
អស់នាងកាញ៉ា សើចលេងក្អាកក្អាយ
សាប្យណាស់ណារ មុក្ខគួរស្នេហារ
នៅនាងទាំងហ្លា្យ ។

៨៦. ស្ដេចគិតអាឡោះ អាឡៃស្រណោះ
ពុំចងឃ្លាតឆ្ងា្យ គនគិតជន្លឹង
រំពឹងសព្វសាយ វែងគិតវែងស្ដាយ
ពុំចងឃ្លាត់ឃ្លារ ។

៨៧. វៀអសទេព្វផង នាំគ្នាត្រសង
ក្រាបទូលឥន្ទ្រា ឱ្យស្ដេចឆាប់នាំម
បុត្រស្ងួនពុំង្វារ រួសរាន់ម៉្មីម្នារ
មិនឱ្យយូរល្មុង ។

៨៨. វៀព្រះឥន្ទ្រារ ចោមចោរទេវា

អំបូរពូជពុង្ស អាស្ងួរបុត្រស្ងួន
ខ្លឹមខ្លួនវរវង្ស កប្បូរកបទ្រង
លើសលែងនានា ។

៨៩. ទើបស្តេចផ្តាំផ្ញើ ថាហៃទេពហើ
កុំគិតសង្ការ អញនិងនាំមបុត្រ
បរិសុទ្ធពុំង្ហារ ចរចាក់ឃ្លាតឃ្លារ
រួសរាន់ទៅរបោង ។

៩០. ស្តេចលោមបុត្រា ថាស្ងួនស្នេហារ
សំលេញស្នេរស្នង អាពុកឱ្យជូន
កូនស្ងួនទៅរបោង ឥឡូវជាម្តង
ឥតឯរុញរា ។

៩១. ចៅកែតសូរិយា វិសេសសេថ្លោ
ឆ្ងួតឆ្នើមលោកា លើកករបង្គំម
ប្រណំមបីតា ទើបក្រាបទូលថា
បូពិតម្ចាស់ថ្លៃ ។

៩២. ឆ្នើមអស្សលោកា ច្បងលើហទេវតា
នៅវនាស្ថានត្រៃ ត្រឹង្សាពីភុក្ត
សួរសក្តសព្វថ្ងៃ ចិត្រខ្ញុំមអាល្បៃ
ពុំចងឃ្លាត់ឆ្ងាយ ។

៩៣. សំដេចចក្កិន្ទ ចោមចៅនរិន្ទ
ស្តាប់បុត្រនោមឆ្ងាយ ថាដ្បិទស្រណោះ
អាឡោះស្ថានអាយ ស្រួលសុក្ខសាប្បាយ

ឥតឯកន្ទា ។

៩៤. ទើបស្តេចឆ្លើយឆ្លើ ថាហៃស្ងួនណើ
កុំថប់វុញវា និងពីភុក្តស្ឋាន
ភិមានសួគ៌ា អាពុកផានា
សាងឱ្យអ្នកថ្លៃ ។

៩៥. ឬបុត្រស្នេហា ស្តែងស្តាប់បីតា
សារសងស្ងួមៀ បើកឱសប៉ប្រឹម
ញញឹមប៉ប្រៃ និងព្រះចោមត្រៃ
ជាក់ជាបិតា ។

៩៦. បើស្តេចអាសូរ មេត្រីអនុកូល
អញខ្ញុំមករុណា សូមស្តេចយកស្ថាន
ភិមានទេវតា ស្អាងតាមសញ្ញា
ចិត្រខ្ញុំមបំណង ។

៩៧. ព្រះឥន្ទ្រឆ្លើយឆ្លើ ថាហៃកូនណើ
កុំគិតលើហោង បិតានិងយក
ស្ថានត្រៃត្រឹង្សារ ស្អាងឱ្យអ្នកហោង
កុំស្ងួនអារំម ។

៩៨. សំដេចទេវោ ប្រសើដ្ឋវរោ
ថ្លាថ្លៃស្ងួរសំម ស្តេចលោមបុត្រស្ងួន
ខ្លិមខ្លួនឪតំម មិនឱ្យបារំម
អស់កិចកាផង ។

៩៩. ទើបព្រះកេតុឆ្លើ ថាអំម្ចាសសៀ

ខ្ញុំមអររពេក្យហោង សូមស្ដេចប្រណិ្យ
ឃ្លាត់ខ្ចីយជាម្ដង ហោរអសទេព្វផង
មកធ្វើម្ចីម្ចារ ។

១០០. រ្យព្រះទេវោ ជាក់ជាអត្ដោ
ស្ដាប់បុត្រពុំង្ហារ បូទចិត្រចង់ឆាប់
ប្រញាប់មុះហិម្ចា ស្ដេចរៀបតៀនា
ហារទ្យៃចំណាង ។

១០១. ឱ្យអសទេវតា តាក់តែងសព្វសា
រពើកាផង ទាំងព្រះចិត្តលោក្ខ
កុបាលហោះផ្សង ផ្ដឹមពល់ស្រេចហោង
វេទបុត្រទេវតា ។

១០២. គិតគុនឱ្យយក ពេជ្ឈយន្ត័នោះមក
សាងឱ្យបុត្រា យុងយលធំមខ្ពស់
ពាន់យោជ្ជសោះសា អសទាំងទេព្ដារ
ស្វប់ស្វែងទីទ្យៃ ។

១០៣. សំដេចសក្ដោ ប្រសើដ្ឋសេដ្ឋោ
រំពឹងរំពៀ និងព្រះពិស្សនុការ
ប្រាជ្ញាឆ្មៀងវៀ យល់ល្អមតៃនៃ
ថានតែងជុំនុំម ។

១០៤. ឈ្មោះហោងរោងធម្មិ សោភាគ្គឱតឹម
ទេព្ដាជួប់ជុំម នោះល្អមឱ្យសាង
គ្រាន់និងបន្ថំម បរមីមូលជុំម

ឯមនុស្សលោកា ។

១០៥. គិតព្រមស្រេចស្រាច់ ទៀងទេព្វសំដេច
សហស្សចក្ខុ អស់បរិពារផង
សែនកោដ្ឋសំខ្សោ ទេវបុត្រទេវតា
ចុះមកជាម្តង ។

១០៦. សាងទាំងព្រះគោ ប្រសើដ្ឋវរោ
អង្គម្បូមកផង ជាអ្នករាក្សា
ទីស្ថានសព្វផង កុំឱ្យហោរមុង
ដលរាជបុត្រា ។

១០៧. កាលស្តេចនាំមបុត្រ វីស្សៃវីសុទ្ធ
មកដល់ហើយណារ ឱ្យព្រះវិស្សុកម្ម
ឯងអាជត្រួតត្រា អសទាំងបរិចាល់
ពិភុត្តស្ថានផង ។

១០៨. ទេព្វឱ្យកែនពល់ រវាតរវល់
វីករវរអើងក៏ង ប្រាំមពីលរុងង្វាស់
នគនធំមផង បានស្រេចហើយហោង
សព្វបរទេស្សា ។

១០៩. ខ្មែរសៀមភូមា ម៉នលាវល័ទា
ជ្វារចាមល្វាំការ យួនថ្នាសកែសើន
ច្រើនណាស់ត្រៀបត្រា ការរៀងហាង្សា
ទាំងក្លឹងខែតខ្លាំង ។

១១០. បាភ្វាំស្បៀងផ្លង ទុំពុនក្នុងផង

ច្រើនព្រៃព្រឡាំង ចិន្តក្លួហុកកៀន
គជីវកៀតាំ ទំក្លួយស្ទួនផ្ទាំង
ហៃហ្យហុងទាំកៀវ ។

១១១. ជីពុនជៀងម៉ៀ រំខើងក្រាស់ព្រៃ
មីមើកគកៀ ទាំក្លួយពាណើង
ខែកគួល៉ាម្បៀ ក្លួយដែកកន្លៀល
រ៉ដាក្កសៀមផង ។

១១២. លុងលុះជុំមស្រេច់ កាឈ្មោះទេវិច្ឆស្តេច់
ចេញចរទៅវផ្គង ទុកអសទីស្ថាន
តៀតានទុំន់ង ព្រះគោឈុប់ផ្គង
អគ្គេប្លូពារ ។

១១៣. នៀភ្នំមបាខែង ស្រួលបួលជាក់ស្ដែង
ព្រះវិស្សុកម្ម ឱ្យប្រាបទីស្ថាន
ដកអសព្រិក្សារ ស្បូវស្បាតបន្ថារ
ជ្រោះស្រេច់ហ្ប៉ត់ហ្ប៉ង ។

១១៤. ទេវិច្ឆឱ្យយកថ្មរ សីល្ហ៉ាសិងល្អ
ប្រសើដ្ឋកន្លង រន្ទាប់វាស់វែង
ខ្វាត់ខ្វែងជាម្តង ស្រួលស្រេចហៀហោង
ទេវិច្ឆប្រតាប់ករ ។

១១៥. ជាប្រាងប្រាសាទ ល្អរល្អះស្អាងស្អាត់
សុត្តសិងតែថ្ម មានរោងជុំនុំម
ទាំងស្រះបួនល្អរ ហោរព្រៃសិងថ្មរ

ឆ្វេងស្តាំមផងណា ។

១១៦. រោងទងខ្វាត់ខ្វែង រោងជ្រៀកយលស្តែង
ទាំងរោងក្រល៉ាហ បន្ថែមជាក់ស្បាន់
មានចន្ទ់ឆាប៉ា ទល្ហូរនាងច្រាល
មុក្ខដេចត្រលៃង ។

១១៧. កែងកប់ឱតឹម មុក្ខនាគ្គបន្សឹម
ភ្នាក់ដ្បៀខ្វាត់ខ្វែង ក្លាយជារូបសិង្ហ
ប្រែប្រឹងសំពែង ស្មើញស្វាញយលស្តែង
ហាក់រសរីសៃ្ប ។

១១៨. ប្រាសាទប្រាំមបួន រុង្រៀងផ្ទៃនួន
ឆ្លោវឆ្លាក់ក្រាស់ក្រៀ ភ្ញីវារិល្វេកលោក្ខ
ហាក់ដូចស្ពានត្រៃ ត្រឹង្យត្រិមរិសៃ្ប
មុក្ខគួរអប់រ្យមា ។

១១៩. បាលាំង្គទ្រាពូខ្សាច់ ក្បាលពេជសំរាំង
ក្លាយជាបាក្សារ គ្រុធយក្ខគន្ធប់
ទ្រផ្ដប់ក្រល៉ារ ក្លាយបែកជាផ្ការ
ឈូកផ្កាប់សួនសំម ។

១២០. មានរូបបីជាន់ ល្អរល្អះគ្រុព់គ្រាន់
ត្រសោលត្រសំម ជាសារពើរស្វេត់
រ៉ហូតដលកុំ ពូលពេជ្ជឱតឹម
បាកាន់ទាំងប្រាំម ។

១២១. មើលទោវស្រោងស្រិង ត្រដួចត្រដឹង

ជុំនាងរិលតាំម ល្អរល្អះថៃថ្លួន
សំនួនសួនសំម មើលយលជាកំ
ម្រមអ្នកឯណា ។

១២២- និងធ្វើត្រាប់បាន ហេតុបុន្យ៍ឫរាណ
សែនសោតសំខ្យា ពោរ្យបុន្យ៍សំម្តេច
សហាស្យចក្ខា និងបុន្យ៍បុត្រា
អំបួរពូជពុង្ស ។

១២៣- នោះនៃ្យទេពូបាន រន្តាប់ជាស្ថាន
ស្តេចស្តែងគួរគុង ឯស្តេចឯករាជ្ជ
ខួបខ្លាចពុទ្ធពង្ស កបរូបកបទ្រង
ឆ្មួតឆ្មើមខ្យុត្រផង។

១២៤- គុនមើលទោវប្រាង ពិស្យនុកាសាង
សក្ខសំមក្តាតហោង ឈួរតរត្ន
ពេនពាត់ភ្ញីផង ក្លាយក្លែបមុតម៉ុង
ជាក្បាលផ្លាំហា ។

១២៥- ពកាន់ទ្ធាំប្ទួន រូតប្រាំមជាន់ជួន
ចៃកជាមុក្ខរា ក្នុងក្នក់សិងក្បាច់
ស្រស់ស្រេចដូចគ្នារ ព្រះកែតុមាលា
មានបុន្យ៍ស្ទប់ស្នែង ។

១២៦- ឬព្រះពិស្ស៊ុនុការ រន្តាប់សព្វសា
ពើហាកាកុំប្លែង ជារូបកញ៉ា
កាន់ផ្ការដៀងឯង ខ្លាះកាន់កន្សែង

ឈរតៀបចន្លោះ ។

១២៧. គៀរផ្សរជុំមជាក់ ភ្លាវជារូបយក្ខ៍
រូបគ្រុធស្មានស្មោះ ឈរឈានចាំមទ្រូង
តៀបទរឥតខ្ចោះ រ៉ូបថ្ពូរ៉ឺបោះ
គ្រឹប់ផ្ទាំងនោះណារ ។

១២៨. គុនមេិលគាងឃ្លៀ ត្រឹស្ទូរពន្រៀ
សិងកែវមុក្ខតា ពីទូវពីទៀ
វៀងរាំសោភា ក្រគិតគុន្ទា
ក្រស្តាល់សព្វសៀ ។

១២៩. កុំពូលស្រួចស្រុង ឆ្លាក់ក្បាច់សំយុង
កញ្ចក់ប្រោះប្រៀ ត្រដេិតត្រដ្ឋច
ស្រោងស្រួចយលឆ្ងៀ ភ្លឺហាព្រោងក្បស់ក្បាយ
កន្តាលវីហ៊ារ ។

១៣០. ផ្ទះផ្តោងមុក្ខដេច់ សំម្រូលសំម្រាច់
ដងក្តាជូហ្វារ កែបកាលក្នុក់ពេជ
សីងលេជបន្ទា ឆ្លោវឆ្លាសល៉ដា
ភូតាន់ទាំងទ់ង ។

១៣១. ស៏សរស្តុំទ្រូង ក្រោមក្រាលសិងថ្ម
ភ្នាក់ដៀវសង្ខាង ផ្លាក់ឆ្លោវក្បូរក្បាច់
សំរេច់ឥតឆ្គង ជ្រុងជ្រួយសោតហោង
លកល្អសល្អរក្រែ ។

១៣២. ហាក់ដូចក្រល៉ោ ជុំនុំមទេវតា

នៅវសូគិល្បែ សំរាប់ព្រះឥន្ទ្រ
និវិន្ទថ្មោចោរ ត្រឹង្សសូរគិល្បែ
ល្អវឥតគុន្នា ។

១៣៣- ប្រដាប់ជាស្ថាន ក្ដាបែនសោតមាន
បាសិ្ទមទិស្សា រោងរំមក៏ក្លាត់
ស្អាងស្អាត់សោភា សិងថ្មសីលា៉
ប្រកិតក្រាស់ក្រៃ ។

១៣៤- ប្រដាប់ក្រឡា បន្ថំមសោភា
ឆ្វេងស្ដាំមប្រពៃ ស្រណុកសាប្ប
លោះលាប្បពេក្យក្រៃ្យ ហាក់ផ្ទសួគិល្បែ
ទិព្វទេព្វទេវា ។

១៣៥- ត្រងទ្វារចូលទោវ ប្រដាប់លំនៅ
មហារាជមុះហិម្មា ក៏ជាប្រសាទ
ស្អាងស្អាទរេចណា ឆ្លាក់ជាភ្ញីក្ដារ
វំឃ្លូលឆ្វាត់ឆ្វា្យ ។

១៣៦- ឆ្លាក់ជាទេព្រាក្ខ រឹងរិទ្ធិសិទ្ធសក្ក
ឈរឈាមរៀងរាយ ខ្លាះកាន់ដឹបង
ផ្គាប់ផ្គងហាក់វាយ ក្រទាករកា្យ
នៃបនៅវមាត់ទ្វារ ។

១៣៧- ទ្រងនាមមៀ្យសរ បុពេជ្ឈឥទ្ធ្វ
រឹងរិទ្ធឥទ្ធា តែងនៅវពីភាក្ខ
វាក្យាធ្យាបារ ខែតខន្ធច័ក្រវាល

ឥន្ទ្រីប្រាសនគរ ។

១៣៨- ស្តេចអាជក្រវើន និតនៅវចំរើន្យ
សួស្តិរិទ្ធិពរ ម្មុស់ផងនា១
យាត្រាចេញចរ ចូលក្នុងនគរ
ទិព្វស្ថាននោះណារ ។

១៣៩- សិងប្រុងប្រពាប់ ស្ពាម្លូវសិរ៉ាប
ទៀនធូបភ្ញីផ្ការ អសភោជុនផង
គ្រុព្វគ្រងបូជា អាទីស្ថានប្រថ្នារ
សូមជុនជួយជៀ

១៤០- ហើ្យលោកប្រពាប់ ឆាត្ញូតសិរ៉ាប
មហារាជនោះនៀ នាមហោវជីទែប
និតនៃបប្រព្រៀ ម្មុស់ផងសព្វថ្ងៃ
តែងទោវប្រថ្នារ ។

១៤១- សូមត្បៀចំណាង អនុពាលចិត្រថង
សំលេញស្នេហារ ជីទែបឯងឱ្យ
តាមតៀចិន្តា ដូចចិត្រប្រថ្នារ
ពុំឃ្លាតឡើយហោង ។

១៤២- ព្រះពីស់នុការ ជាជាងអស់សារ
ពើហាពុំឱ្យគ្គង តែងបញ្ចប្រសាទ
ស្អាងស្អាតកន្លង ផ្ទុផ្កាងនោះផង
ជុំមវិញវិលវន់ ។

" បទពុំនោល"

១៤៣. ប្រពាប់បាលាំងប្រាំមជាន់ ទ្រូតទ្រាព្យខ្សែចខាន់
សំអាងសំអាតពិពណ៌

១៤៤. មានជើងដើរកាច់វៀងរាល់ ជ្រុងជ្រោយសិងសា
រពេហាស្វូត្រប្រសើផ្ដសោភ័ ។

១៤៥. ឆ្លាវឆ្លាក់ក្បូរក្បាច់អសក្ដិ ចំលាក់ទងភ្ញី
ប្រពាន់ប្រពាក់លើគ្នារ ។

១៤៦. ឆ្វាត់ឆ្វាបីបន្ទាយល័ដា វៀបរិកបុប្ផា
មាលារំយួលសំយុង ។

១៤៧. ក្រូយក្រូលបីបន់ដួលចោមចង់ លេជទងបីរហង
ជាផ្ទូររំយួលដក់ចន្ទ ។

១៤៨. ភ្ញីវារវាងវាសវ៉ាន់ ពេនពាន់ពាក់ពាន់
ប្រវានប្រទាកក្រាសជ្រាះ ។

១៤៩. ក្លែបក្ប្បាលេជលាប្លូតលាស់ ច្រូងច្រាំងបីប្រទាស់
ក៏ឆ្លាឫមនីពារនារ ។

១៥០. ភ្ញីក្បាលេជលាប្ផ្លែផ្ការ ខ្លាប់ក្បាផ្លែជា
រូបម្មស់រេរាំមកាំនដែ្ប ។

១៥១. នារីស្រសស្រ្បិដ្ឋប្រព្យៃ ហាក់កើតឯងនៃ្ប
ក៏លេជពីក្លែបបុប្ផា ។

១៥២. ខ្លះក្បាក្លែបជាមុក្ខវា ខ្លះក្បាជាមហា
ហែមហង្សប្រសើដ្ឋបវរ ។

១៥៣. ខ្លះជានាគនៅវម្ពុរ ខ្លះជាគ្រុឌ្ឋា

ក៏ចាប់នាគ្គិានក់ស៊ីយ ។

១៥៤.ឆ្នោវធ្លាក់ចំលោក់អស់ក្ដី ក្លែបក្លាប្បជាភ្ជី

បាក់មានវិញ្ញាណរួបរស ។

១៥៥. ប្រសាទប្រាំមួរតស្រេចស្រស់ ផ្ដលផ្ទើងខ្ពងខ្ពស់

ត្រដឹងត្រតែតស្រោងស្រួច ។

១៥៦. ត្រៀស្លូវកុំពូលច្រូងច្រួច ដុងដោមបីត្រដួច

ត្រដែតកន្ដាលវិហ៊ារ ។

១៥៧. ធ្លាក់ធ្លក់ត្របកបូទុំម្នា ក្បូរក្បាច់រចនា

រំយោលសំម្រាច់ស្អាតស្អាង ។

១៥៨. គាងឃ្យាបីត្រដេច់ច្រូងច្រាង សីម្នាដាំមខាង

ត្រចៀកក្របីស្រសស្រេច់ ។

១៥៩. ដងក្តារព្វ៉ាពារមុក្ខដេច់ ឆ្នោវធ្លាក់ក្បូរក្បាច់

រំលេជបូផ្កាបីប្រវ៉ៀ ។

១៦០. មុក្ខព្រំហ្មសោតសំមធ្មើងក្រៃ ទាំងបួនទីសន្សៃ

ប្រកដ្ឋប្រកបសាបសព្វ ។

១៦១. ផ្គះផ្គាំងបីជន្នាំងជួបចប់ ផ្គះខ្វែងដួប្រសព្វ

នោវមុក្ខសំម្រាប់ឥត់ឆ្គង ។

១៦២. កាំមយួរសីម្នាដាំខ្សង ស្លិកខ្មោរនោះផង

ក៏តាំមរំលេជចូរចារ ។

១៦៣. ស៊សរស្ដំមទ្រវៀងរាល់ ជ្រូងជ្រួយសិងសា

រពេិបាស្វូតប្រកិតរៀងរួច ។

១៦៤. ផ្គះផ្គាំងជន្នាំងបង់អួច ជើងទៀនរាល់រួច់

ចំលាក់ក៏ឆ្លាក់ល្អក្រៃ ។

១៦៥. ប្រពាប់ស្រាប់បីប្រពៃ ដំបូលនោះនៃ
លើរូតប្រសាទស្រាច់ស្រេច ។

១៦៦. ផ្ទះត្រលែងកែងមុក្ខដេច់ សោតសិងស្រស់ស្រេច
ប្រសាទផ្ទះរួតកន្តាល ។

១៦៧. ប្រសាទទាំងបួនមានថ្វារ គ្រប់សព្វនៅប្រការ
បន្លាបទ្រាប់ទ្រូតលើគ្នា ។

១៦៨. ផ្ទះផ្ទាំងជន្ទាំងប្រាងប្រា សាទសួរសោភា
ចំលាក់ចំលោរអសក្តិ ។

១៦៩. ឆ្លាក់ជារូបរត្តនារី បោរភោគ្គរត្តិ
គឺស្រីប្រសើរដ្ឋសួគ៌ា ។

១៧០. រូបទ្រងបញ្ចុងសោភា ឈរឈមរៀងគ្នារ
លេងលើហាប្រសាទសោតហោង ។

១៧១. ខ្លួនមូលសំសូលឥត់ហ៉្មង ទន់ភ្លនមុក្ខឈ្មង
ប្រកបនៅវលក្ខបានខ្នាត់

១៧២. ជូតចារភ្នីញារស្អាងស្អាត់ ខ្លះបួងខ្លះកាត់
កែមកាលកែសាសោតសំម ។

១៧៣. ចង្កេះរៀងធ្មៀវមូលក្លំម ពោះសោតសឹងក្បុំម
ក៏ដូចក្រពុំបូទំម្នា ។

១៧៤. ស្រឡះសរជ្រះអង្គារ សិងពាក់មាលា
គន្ធាភូមរាក្ខកាឡី ។

១៧៥. ចងនៅវចំណាងកែស្សី ពេ្វនពាន់ទងភ្នី

សក្ដិសមបន្ទាល្អរក្រៃ ។

១៧៦. ខ្លះដោតខ្លះក្រងជប្រពៃ ខ្លះទើបយកដៃ

ស៊កសៀមកាន់ក្រងឆ្វាតឆ្វៃ ។

១៧៧. ខ្លះសោតសិទ់សក់បន្ទាំ ខ្លះសោតកាន់ជា

សំពត្តក៏ទាក់ល្មើងផង ។

១៧៨. ខ្លះកាន់ភ្ញីស្លួរទាំងទង ខ្លះកាន់នោរកុំម្រុង

ភ្ញីទេសទាំងទងល័ដា ។

១៧៩. ខ្លះប្បៀងឈ្នងឈ្មៀងមើលគ្នា ខ្លះចូលប្រវារ

កាន់ស្នាដន្ទើមទងភ្ញី ។

១៨០. ខ្លះសើចញញឹមប្រិមប្រិយ ហាក់និងស្រត្បី

សំណែះសំណាល់រួមរាក់ ។

១៨១. បើគនមើលទោវលុះដាក់ ព្រើហាព្រួចភ្ញារភ្ញាក់

ស្រមៃស្រមោលម្ដង១ ។

១៨២. ហាក់នឹងស្រដីមកផង ដឹបួច់ផ្ដោះផ្ដង

ដាក់មុក្ខលំញ៉ងចងចិត្រ ។

១៨៣. មៀងមើលទោវហៀហាក់ពិត្យ ខ្លះដើរកាន់ផ្គិត

ខ្លះកាន់សត្វសេកផងណា ។

១៨៤. បន្ទឹមនោវលើហាទងផ្ការ ខ្លះកាន់បូទុំម្ញា

នោវផ្ការកុំភ្លឹងទាំងទង ។

១៨៥. ស្លៀកខៀនខ្ទប់ចង្កេះផង អន្ទាមស្វ៉ង

កញ្ជ្រិលប្រតាបគ្រឿង្គ្រាន់ ។

១៨៦. សិងពាក់ក៉ងជើងពីជាន់ ខ្សែដៀរវាន់

រំលេចនៅវល្លិសទងភ្លី ។

១៨៧. សិងស្អាងរូបរាងសោភី គ្រឿងគ្រឿងអង្គស្រីរ្យ
កញ្ចក់ចិញ្ចៀនព្រះទុំរង ។

១៨៨. ប្រតាប់គ្រឿងគ្រឿងបាញ្ចង ឈរឈមបីរហង
ស្រលូតស្រលះអង្គារ ។

១៨៩. ហាក់ដើយាងយាសយាត្រា រៃអនអន់រេរា
រ៉ញីករ៉ញក់ផ្សាស្រើ ។

១៩០. ទង្វងញ្ចែងញ៉ងប្រីមប្រ៊ី ហាក់និងស្រដី
សំណេះសំណាល់ស្នេហារ ។

២៩១. អនឱនលំទោនអង្គា ចុក់ចងសីរលសា
ប៉ងកៀកប៉ង្កាច់ស្វរ៉ង ។

១៩២. ប្រែប្រួលមិតម្ចូលផ្សៀងផ្គង វរវាសលំញង
ទ្រទេសទ្រទន់ស្រួលស្រែច់ ។

១៩៣. ខ្លះចាប់រ៉បាំមកែភាច់ កែក្រៀចក្អកក្បាច់
ក៏ទន់ល្វនល្វាសវិលវៃ ។

១៩៤. ល្អរល្អះសះត្រាសបីប្រពៃ ឈ្នាក់ល្មមល្វិតល្វៃយ
ត្រឈៃត្រឆិតស្រួលស្រស ។

១៩៥. កែក្រៀវៀបរាប្រូវរស័ សក្កសំមនៅវកុំពស់
កុំពុងទ្រងអង្គពេញពាល ។

១៩៦. មៀងមើលយុងយលដួត្រកាល កើតក្ដួចដលដាល
ក៏ចង់នៅវចិត្រស្នេហារ ។

១៩៧. ពុំផ្អែតពុំផ្អន់នេត្រា ត្រេកសោមនស្សា

ពុំស្កប់ពុំស្កល់ចិត្តឡើយ ។

១៩៨. ចចូលមៀងមើលជាកហឿ ពុំច់ងចេញលឿ
អាឡោះអាឡៃពេក្យណា ។

១៩៩. ពុំយល់ជាថ្មសីលា លោក្យក៏រច្ចណារ
សំរាប់សំរូលជប្រព្រៃ ។

២០០. ហាក់ដូចរូបម្នុសវិសៃ្ស មើលហៀសង្ស្យ
ស្រមុទពុងពោះនិងនោវ ។

២០១. រូបទាំងម្សៅពាន់ឈរនោវ ល្អរល្អេញល្អោវ
ទាំងម្សៅពាន់ឥតមានខ្ចោះ ។

២០២. លោក្យផ្លាក់តៀនោវជុំពោះ ដៀកៀនដៀកោះ
ដៀជ្រុងដៀជ្រួយផងណា ។

២០៣. ស្រណុកសាប្យមុះហិម្នា ហាក់ស្ថានសួគ៌ា
ភីមានព្រៃត្រីង្សលើបាន្យ ។

២០៤. ផ្ទះផ្ទាំងជន្លាំងរៀងរាប្យ ឆ្លាក់ជានីព្វាយ
ព្រះរាម្ចកេរកាលយាត្រា ។

២០៥. ផ្ទារបរំម្ចយុក្ខក្រៃ្យណា ក្រិត្តិយុត់លុះមហា
កល្បីយុក់ឥលូវ៉ែ្ទះន្ងៀ ។

២០៦. កុំឱ្យម្នុសផងសង្ស៉្ស ទុកកេរក្រេ្យក្រៃ្យ
អាណៃកនីព្វាយច្រើនជាត ។

២០៧. ឆ្លោវឆ្លាក់ជារូបព្រះបាទ វេស្សវាន័នរនាដ្ឋ
ដមានរិទ្ធីចេស្តារ ។

២០៨. ច្បាំងនិងព្រះអាទិត្យ៍មុះហិម្នា ស្តេចមានជ័យា

ពន្លិកនោវវិទ្ធគួរស្នេង ។

២០៩. ហៀរធ្លាក់ធ្លាក់ជាកុំពែង បន្ទាយខ្វាតខ្វែង
នគរស្រីព្ធយុធ្យា ។

២១០. ធ្លាក់ជាប្រាសាទសោភា រុងរឿងរេច្នា
ទន្និមមន្ទលរេងរំម ។

២១១. ធ្លាក់ជាទីព្រះបន្ទំម មហាខ្សត្រឪតំម
ព្រះបាទទស្សរត្នរាជា ។

២១២. ច្បងច្បាស់លើសអស្សខ្សត្រា ជាព្រះបីតា
ព្រះរាម្នទេព្វខ្សត្រខ្សាន់ ។

២១៣. នគរនោះហោវទេព្វស្ថាន ខែតខែមហោមបូពាន្ទ
ព៌ពូកឥសីយសីលាំ ។

២១៤. ធ្លាក់ជាព្រះចន្ទដ៍រា ព្រះអាទិត្យ៍សូរិយ៉ា
រាក្សីក៏ភ្លើហាព្រោងព្រៀ ។

២១៥. ធ្លាក់ជាសោឡសស៏សួរន្យា ឥន្ទព្រហ្មសំមទាយ
នោវទេព្វនីករក្រាសគ្រៀ ។

២១៦. ធ្លាក់ជារូបព្រះឥសូរនៃ្យ ស្តេច់ស្ថិតស្ថានព្ត
កៃលាសលើសលើហាទេវតា ។

២១៧. ច្រាលច្រាស់នីរាស្មមរនា នីផាត់ជារា
ភ្យាធិមន្និល់ទាំងហ្លាយ ។

២១៨. ឥន្ទព្រំហ្មយក់្សយំមសំមទាយ មីម្ទូលមកថ្វា
បង្គំមប្រណំមសួស្តី ។

២១៩. សូមជ្យេជោកជុន្នរិទ្ធិ ស្តេចមានមេត្រី

ប្រសើរឧត្តមប្រដៀវពរបោង ។

២២០. ស្តេចជាពន្លឺលោក្យផង ទ្រង់សីលគ្រប់គ្រង

មន្ទលប់ត្រៃភពទាំងឡាយ ។

២២១. ធ្លាក់ជារូបព្រះន្រ្ទ ទ្រើសទ្រង់រិទ្ធីសាយ

ក៏គុងលើហាត្រូធរាជ្ជា ។

២២២. ហិចបោះផ្កាញក្រុងអាស្ស៊ា កាលកាច់ វីនា

វីនាសសូនសោះបាត់បង់ ។

២២៣. វៀងរាល់លុះទាល់ព្រះអង្គ ចាប់ប្រដិសន្ធិទ្រង់

ជាព្រះរាម្ចាទេពថ្លៃ ។

២២៤. ធ្លាក់មហាឫស្សីកាល្បៃ កោត្តិរិទ្ធិត្រៃ

ក៏នាំមព្រះរាមនៅព្រះលក្ខ ។

២២៥. នៅប្រសិទ្ធសីលធ្នូរប្រដីយក្ស រិទ្ធីសិទ្ធិសក្ក

ពន្លឺកពន្លឺមុះហិម្មា ។

២២៦. ធ្លាក់ជារូបព្រះរាម្ចា នៅព្រះអណ្ណជ្ជា

ក៏ស្តេចដើរទេសពន្លឺចរ ។

២២៧. ពីអង្គព្រាច់គ្រងព្រះនគរ មិត្តិលោដបវរ

លំនៅនៃនាងសេដា ។

២២៨. ធ្លាក់ជាព្រះបាទមិត្តិលោ ឱ្យអសទេវតា

លើកធ្នូរសហាស្សសធម្មទ្រង់ ។

( នៅមានត )

# គម្ពីរស្លឹករឹត

គម្ពីរនេះ កើតមាននៅប្រទេសកម្ពុជា អស់កាលយូរលង់ហើយ ។ ចាប់តាំងពីមានព្រះពុទ្ធសាសនា ផ្សាយចូលមកដល់ប្រទេសកម្ពុជាកាលណា គេឃើញមានគម្ពីរស្លឹករឹត តាំងពីពេលនោះមក ។ ក្នុងសម័យដើម, ព្រះពុទ្ធវចនៈ ទាំងព្រះវិន័យ ព្រះអភិធម្ម ទាំងបាលី សម្រាយក្តី ក្បួនហោរាសាស្ត្រ តម្រា សម្រាប់ទស្សន៍ទាយក្តី ច្បាប់ផ្សេងៗ សម្រាប់គ្រប់គ្រងប្រទេស មានច្បាប់ " ជ័យជេដ្ឋា" ជាដើមក្តី នៅក្នុងប្រទេសកម្ពុជា សុទ្ធតែគេចារចុះលើស្លឹករឹត ឬ ក្រាំងទាំងអស់ ដោយគេនិយមថាជាចាវរវត្ថុជាបរឹងមាំ តម្កល់ទុកបានយូរអង្វែង ។

ឯរបៀបដែលធ្វើស្លឹករឹតអោយបានចារជាអក្សរ កើតមានដូចតទៅនេះ :

*ក- មុនដំបូងស្វែងរកដើមស្លឹករឹត*

ស្លឹករឹត ជារុក្ខជាតិព្រៃ ដុះនៅលាយឡំជាមួយនឹងឫស្សី និងរុក្ខជាតិផ្សេងៗ ជារុក្ខជាតិមានតែដើម ធាង ស្លឹក ដុះចេញមកជាកំពូលប៉ុណ្ណោះ គ្មានមែកទេ (សម្បូរជាងគេនៅខេត្តក្រចេះ) ។ កាលណាគេត្រូវការប្រើប្រាស់ គេកាប់យកតែកំពូលរបស់វា មកកាត់ជាបីកំណាត់ :

. *កំណាត់ខាងគល់* គេយកទ្រនុងចេញ, ទ្រនុងយកទៅធ្វើជាខ្ចូច ឬចំណងផ្សេងៗ រីឯស្លឹក គេយកទ្រនុងរបស់វាមកដេរភ្ជាប់ធ្វើជារនាំង សម្រាប់បាំង ឬ ប្រក់ ។

. *កំណាត់កណ្តាល* ធ្វើជាស្លឹករឹត សម្រាប់ចារ ឬ សរសេរអក្សរជាគម្ពីរ ឬ ក្បួនច្បាប់ផ្សេងៗ ពីព្រោះវាស្មើ មិនវៀរ មិនក្រាស់-ស្តើង ។

. *កំណាត់ខាងចុង* គេដេរភ្ជាប់ដោយទ្រនុងរបស់វាធ្វើជាភ្លល់ ។

ចំពោះស្លឹករឹត ដែលគេយកមកចារជាអក្សរ ចារឹកជាគម្ពីរ ឬក្បួនច្បាប់ផ្សេងៗ, មុនដំបូង គេត្រូវយកស្លឹករឹតទៅសក សកអោយអស់ទ្រនុង ចៀរអោយស្មើ យកទៅហាលថ្ងៃអោយស្ងួត រួចហើយយកទៅហាលសន្សើមពេលយប់ ដើម្បីធ្វើអោយវាលាកត្រង់មកវិញ ។ រួចគេធ្វើប្រដាប់សម្រាប់ចោះប្រហោង ២ លៃជា ៣ ភាគ ចម្ងាយពីគ្នា ២០ សង្ទីម៉ែត្រ ត្រូវឈូសធ្វើក្របបណ្តោះអាសន្ន ប្រវែង ៥៥ សង្ទីម៉ែត្រ បន្ទារ ៥,៥ សង្ទីម៉ែត្រ ចោះប្រហោង ២ ចម្ងាយពីគ្នាដូចស្លឹករឹតដែរ យកឆ្អឹងឆត្រ ១ គូ សម្រួចអោយត្រង់ ដោតនៅប្រហោងក្របខាងក្រោម រួចយកស្លឹករឹតដែលចោះប្រហោង ២ ហើយ ទៅចោះស៊កចំដែកស្រួចទាំង ២ ។ លុះស៊កបាន ចំនួន ២០០ សន្លឹកហើយ ត្រូវយកក្របមួយទៀត ទៅដាក់ពីលើ ស៊កអោយចំប្រហោងទាំងពីរ រួចបញ្ចូលទៅក្នុងផ្ទោះ . ឃ្នាប ។ ផ្ទោះនោះ គេធ្វើដោយឈើមានខ្នីម រឹង មានប្រហោងទាំងពីរខាង ទំហំល្មមដាក់ស្លឹករឹតចូល បណ្តោយក៏ប្រវែងស្លឹករឹតដែរ ។ លុះបញ្ចូលទាំងស្លឹករឹត ទាំងក្របហើយ គេរឹតដោយដែកអង្កំ ឬ ស្នៀតអោយណែនរឹងដូចឈើ រួចហើយផ្តេកផ្ទោះច្រឹបស្លឹករឹតដែលលើសចោលទុកត្រឹមតែប្រវែង ៥៥ សង្ទីម៉ែត្រ រួចយកដែកឈូសដ៏មុត ឈូសអោយស្មើបណ្តោះអាសន្នទើបដោះចេញពីផ្ទោះ យកខ្សែទ្រនុងរឹតមកចងបណ្តោះអាសន្នរួចយកទៅ ឆ្អើរភ្លើង ឆ្អើរល្មមហើយទើបបកពង្រាយយកទៅវាយបន្ទាត់ ជា ៥ ឬ តាមតែលៃលក ។

*ខ . របៀបវាយបន្ទាត់*

មុននឹងចារ គេត្រូវវាយបន្ទាត់លើស្លឹករឹតជាមុនសិន ទើបចារទៅវាត្រង់ ។ ឯរបៀបវាយបន្ទាត់ ដូចខាងក្រោមនេះ :

គេយកឈើបន្ទះទំហំ ៖ ទោល ២ សង្ទីម៉ែត្រ បន្ទារ ៣ សង្ទីម៉ែត្រ ឈូសអោយស្អាត យកមកវាយជាផ្ទោះរាងបួនជ្រុងទ្រវែង បណ្ដោយប្រវែង ៧០ សង្ទីម៉ែត្រទទឹងប្រវែង ២០ សង្ទីម៉ែត្រអោយ រឹងមាំ រួចអារ . ក្រិត ៦ គំនូសឃ្លាតពីគ្នា ១ សង្ទីម៉ែត្រ១ ។ នៅចុងសងខាងផ្ទោះ ត្រូវចោះប្រហោងទាំង ២ ខាងអោយធំ ខាងដើមមាន ៦ ខាងចុងមានតែ ១ យកឫស្សីបិតអោយមូលស្អាត ធ្វើរបួតស៊កចូលក្នុងប្រហោងនៅចុងសងខាងផ្ទោះនោះ រួចយកខ្សែអំបោះដែលគេវេញអោយរឹងមាំ អោយឆ្មារល្មមធ្វើ បន្ទាត់បាន ទៅចងរបួតម្ខាងដែលមានតែ ១ រួចយកចុងខ្សែម្ខាងទៀតទៅចងនឹង របួតទាំង ៦ ដែលនៅចុងផ្ទោះម្ខាងទៀត ។ គេចងរបៀបនេះ ដើម្បីងាយរឹតខ្សែទាំង ៦ អោយតឹងស្មើគ្នា ។ បើខ្សែណាមួយធូរ គេរឹតតែរបួតដែលចងខ្សែនោះ ។ គេដាក់ខ្សែនីមួយ១ អោយចំកម្រិតដែលអារអង្កន់ជាស្នាម រួចយកធ្យូងយ៉ាងខ្មៅ មកបុកអោយម៉ដ្ឋលាយជាមួយទឹកអោយខាប់ យកស្រកីដូងជិអោយទក់ជ្រលក់ ទៅនឹងទឹកធ្យូង រួចលាបខ្សែបន្ទាត់ទាំង ៦ ក្ងតទៅក្ងតមក អោយសព្វ រួចយកស្លឹករឹត ទៅដាក់តម្រៀបលើក្ដារស្មើ រៀបអោយត្រឹមលើខ្សែបន្ទាត់ទាំងផ្ទោះដាក់ទទឹងស្លឹករឹតខាងដើមខាងចុង លៃទុក ៤ សង្ទីម៉ែត្រ វាយបន្ទាត់ ១ ទុកជាខ្នាតសិន រួចហើយទើបចាប់វាយបណ្ដោយស្លឹករឹត ៥ បន្ទាត់ ឬ ៦ បន្ទាត់ តាមតែពេញចិត្ត ។

*គ . របៀបចារអក្សរ*

មុននឹងចារ ត្រូវមានឧបករណ៍ ៣ គឺ ៖

១ . *ឈើទ្រនាប់* ឈើទ្រនាប់សំប៉ែតប្រវែង ៣០ សង្ទីម៉ែត្រ បន្ទារប៉ុនស្លឹករឹត ឈូសអោយស្អាត យកសាច់សំពត់ដេរស្រោបពីក្រៅ ដើម្បីចារទៅទន់ផង ទប់កុំអោយរអិលផង ។

២ . *ស្នាប់ដៃ* ស្នាប់ដៃធ្វើដោយស្លឹករឹត ១ សន្លឹក រង្វង់ប៉ុនឈើទ្រនាប់ សម្រាប់ស្រោបពីលើឈើទ្រនាប់ រួចច្រកស្លឹករឹតចូលក្នុងស្នាប់ដៃ ដើម្បីចារទៅកុំអោយរអិល ។

៣ . *ដែកចារ* ដែកចារដងឈើមូល ស្រួចដើមស្រួចចុង គេបង្កប់ដែកទាំងពីរខាង សំលៀងនឹងថ្មអោយមូល-មុត ។ (គេច្រើនយកម្ជុលដេរយន្តខាងគល់ពីព្រោះ វារឹងមុតស្អាតល្អ ) ។

ចាប់ផ្តើមចារ ត្រូវយកស្លឹករឹតមួយសន្លឹកម្តង បញ្ចូលក្នុងស្នាប់ដៃដាក់ស្នាប់ដៃនៅខាងលើបង្គាបមេដៃខាងឆ្វេង យកដែកចារកាន់ដៃខាងស្តាំ ដាក់សង្កត់លើ មេដៃ ខាងឆ្វេងលៃអោយល្មមទើបចាប់ផ្តើមចារតទៅ ចារម្ខាងអស់ហើយត្រឡប់ ចារម្ខាងទៀត ។ ចុះលេខរៀងនៅដើមសន្លឹកជូនកាលគេប្រើជាអក្សរ ។ លុះចារ រួចហើយទើបគេលុបអក្សរ ។

*ឃ . របៀបលុបអក្សរ*

កាលណាគេចារអក្សរឡើងស្លឹករឹតហើយ គេលែងហៅថា ស្លឹករឹតទៀតហើយ គឺហៅថា " សាស្ត្រា " វិញ ។ ចារហើយត្រូវលុបអក្សរទៀត ទើបមើលបាន ។

លុបអក្សរ គឺធ្វើអក្សរអោយមើលឃើញច្បាស់ ។ គេត្រូវរកធ្យូងម្រែងភ្លើងយ៉ាងខ្មៅ លាយជាមួយជ័រទឹកយ៉ាង ថ្នាក្លូវអោយចូលគ្នាសព្វ រួចយកសាច់ក្រណាត់មកចងជាកញ្ចប់ជ្រលក់ក្នុងទឹកខ្មៅ យកជូតអក្សរលើស្លឹករឹត ជូតអោយពេញទាំងអស់ ទោះជាស្លឹករឹតទទេក៏ដោយ ។ ជូតសព្វហើយ ត្រូវយកដីខ្សាច់ល្អិតម៉ត់ស្អាត ទៅបាចលើស្លឹករឹត រួចយកក្រណាត់ទៅជូត ដៃម្ខាងទ្រាប់ក្រណាត់ទាញស្លឹកសាស្ត្រា ដៃម្ខាងទៀតទ្រាប់ក្រណាត់ទប់ ។ ធ្វើដូច្នេះ ទាល់តែអស់ជ័រទឹកស្អាត

រលីងរួចយកទៅហាលថ្ងៃអោយស្ងួតស្រួល ទើបប្រមូលយកមកតម្រៀប ស្លឹកតាមលេខទំព័រ មួយកណ្ដួងៗ ដរាបដល់ចប់ ១ គម្ពីរ រួចហើយ រៀបចំឈូស ដុសខាត់ អោយស្អាត ដើម្បីទីបមាស ។

*ង- របៀបឈូសសម្អាត*

លុះដល់អក្សរមើលឃើញច្បាស់ហើយ គេត្រូវឈូស ដុសខាត់អោយស្អាតសម្រេច ដើម្បីទីបមាស ។ មុនដំបូង គេត្រូវឈូសឈើធ្វើក្រប២ទៀតសម្រេចមានទំហំ : ប្រវែង ៥៥ សង្ទីម៉ែត្រ បន្ទារ ៥,៥ សង្ទីម៉ែត្រ ទោល ២ សង្ទីម៉ែត្រ ២ បន្ទះ ចោះប្រហោង២ ដូចមុន រួចយកទ្រនុងរឹតយ៉ាងរឹងមាំ ១ គូ បិតអោយមូលស្អាត សម្រួចចុងដោតក្នុងប្រហោងក្របខាងក្រោមបញ្ឈរឡើង រួចយកស្លឹកសាស្ត្រា ស៊កតាមប្រហោងដែលមានស្រាប់តាមកណ្ដួនីមួយៗ ។ មុនដំបូង ដាក់ស្លឹកទទេពីរសន្លឹកសិន ទើបស៊កស្លឹកដែលមានអក្សរជាបន្តបន្ទាប់ដល់ចប់ លុះចប់ហើយ ត្រូវស៊កសន្លឹកទទេ ២ សន្លឹកទៀត រួចទើបបញ្ចូលទៅក្នុងផ្ទោះ រឹតអោយណែនរឹងដូចឈើ សំលៀងដែកឈូសអោយមុតស្មើ ឈូសអោយស្មើនឹងក្របទាំងពីរខាង យកក្រដាសខាត់សាច់ល្អិត ខាត់អោយស្អាតឡើងរលោង រួចហើយទើបយកទឹកម្រ័ក្សណ៍យ៉ាងថ្លា លាបពេញទាំងអស់ យកទៅហាលថ្ងៃមួយស្របក់ធំ រួចយកជាតិហិង្គុលពណ៌ក្រហម បុកអោយម៉ដ្ឋ លាយដោយម្រ័ក្សណ៍ លាបពីលើម្រ័ក្សណ៍ទៀត ទុកអោយស្ងួតល្អ ទើបចាប់ផ្ដើមទីបមាស ។

*ច - របៀបទីបមាស*

មុនដំបូង គេវាស់ចែកសាស្ត្រាជាបីភាគស្មើគ្នា ភាគខាងដើម និងខាងចុង គេទីបមាស ភាគកណ្ដាល គេទុកនៅជាជាតិហិង្គុលក្រហមដដែល ។ មុននឹងទីប គេយកមើមខ្ទឹមស ទៅបុកអោយល្អិតម៉ដ្ឋខេ យកស្បៀមុងទៅខ្ចប់ រួចជូតអោយសព្វ

ទើបយកមាសសន្លឹកសុទ្ធ ទៅបិទពីលើអោយរាបស្មើល្អ មួយសន្លឹកម្តងៗ រួចហើយ គ្របអោយជិតចំនួនពី ៧ ទៅ ១០ ថ្ងៃ ទើបបករំគាយសន្លឹកចេញ រៀបចំសឹកខ្សែ មួយកណ្តួម្តងៗ ។

*ឆ . របៀបធ្វើខ្សែសាស្ត្រា*

ខ្សែសាស្ត្រា គេធ្វើដោយអំបោះស្លាត់ ដែលមានជាតិរលោង . ទន់ គេ យកទៅជ្រលក់អោយមានពណ៌ផ្សេងៗ រួចក្រងចាក់ជាកន្ទុយកណ្តុរ ៤ ឬ ៥ ផ្លូង រឹត អោយណែន ម្ខាងធ្វើកន្លុះ ម្ខាងទៀតទុកអោយមានកន្ទុយរំភាយ ។ រួចហើយយក ខ្សែទៅដោតនៅប្រហោងស្លឹកសាស្ត្រាខាងឆ្វេងតែមួយទេ ប្រហោងខាងស្តាំទុក ចោល ។ មុនដំបូង ត្រូវដោតស្លឹកចំណងជើង បន្ទាប់មក ស្លឹកទទេ ២ សន្លឹក បន្ទាប់ មកទៀត ស្លឹកដែលមានអក្សរ ខាងចុងបំផុត ស្លឹកទទេ ២ សន្លឹកទៀត រួចបញ្ចូល កន្ទុយខ្សែក្នុងកន្លុះ រឹតអោយស្មើគ្រប់កណ្តួ ។ លុះចប់មួយគម្ពីរហើយ ត្រូវតម្រៀប ពីកណ្តួទី ១ ដល់ចប់ រួចយកក្របទាំង២ ដាក់គាបគ្នា យកខ្សែអំបោះវេញអោយរឹង ២ខ្សែ ដែលម្ខាងមានកន្លុះសឹកកន្ទុយខ្សែក្នុងកន្លុះ ទាំងពីរឆ្វេងស្តាំ ព័ទ្ធ ២.៣ ជុំ រឹត អោយណែនស្មើគ្នាចងអោយជាប់ រួចហើយយកសំបកគម្ពីរមករុំ ។

*ជ . របៀបធ្វើសំបកគម្ពីរ*

សំបកគម្ពីរ ជាគ្រឿងប្រដាប់ខាងក្រៅ គេធ្វើសម្រាប់រុំការពារគម្ពីរខាង ក្នុងអោយល្អស្អាត ស្ថិតស្ថេរបានយូរ ។ គ្រឿងប្រដាប់នេះ គេធ្វើដោយ :

. ដំបូង គេយកទ្រនុងរឹតរើសយកតែរឹងៗ មកកាត់ប្រវែងគម្ពីរ បិត អោយស្មើស្អាត យកអំបោះមកវេញធ្វើខ្សែកម្រង ក្រងអោយញឹក អោយបានទំហំធំ ជាងគម្ពីរ ៣ ដង ។

. យកសាច់ក្រណាត់សស្អាត ទៅដេរស្រោបកម្រងទ្រនុង រឹតទុកជាយ

ទាំងពីរខាង ប្រវែងល្មមបត់មកទល់គ្នា ឬ លើសបន្តិចក៏បាន ។

- យកសាច់សំពត់ល្អមានពណ៌ផ្សេងៗ ឬ ហូល ។ល។ ស្រេះអង្កាំខ្លះផង ក៏មាន រុំពីខាងក្រៅទៀត ។

- មានខ្សែដែលដេរដោយសាច់សំពត់ល្អ-សំប៉ែតប្រហែលជា ១ សង្ទី-ម៉ែត្រ ប្រវែងជាង ១ ម៉ែត្រ ដេរភ្ជាប់ទៅនឹងសាច់សំពត់ខាងក្រៅ សម្រាប់រុំ កុំអោយរាត់រាយ ។

ចប់

ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២៥៣៨ / ១៩៩៤

រៀបរៀងដោយ

សម្តេចព្រះមង្គលទេពាចារ្យ **អ៊ុំ ស៊ុំ**

អគ្គាធិការនៃពុទ្ធិកសិក្សា

ចៅអធិការវត្តមហាមន្ត្រី

រាជធានី ភ្នំពេញ

ឯកសារ

# អំពីអ្នកតា

គេគ្រាន់តែដើរកំសាន្តនៅប្រទេសកម្ពុជា គេអាចប្រទះឃើញខ្ទម តូចៗ សង់លើចន្ទល់ បិតនៅក្រោមម្លប់ឈើធំៗ ដែលភាគច្រើននៃខ្ទមទាំង នោះ មានប្រវែងជ្រុងនីមួយៗ មិនលើសពី ៨០ សង្ទីម៉ែត្រទេ ។ បែរមុខទៅ រកដើមឈើ ដែលផ្តល់ជម្រក, ខ្ទមទាំងនោះ ច្រើនតែទទេ ឬមានឫសឈើ ដែលមានរាងរៅចម្លែកបែបណាមួយ, ឬមានបំណែកថ្មធ្លាក់មួយដុំពីរ, ជួន កាលមានរូបសំណាកមួយ ។

ខ្ទមទាំងនោះ គឺជាលំនៅឋានរបស់អ្នកតា, ជាភូមិទេពតា រក្សាទឹកដី ប្រទេសកម្ពុជា ។ កាលពីដើម, មានស្តេចអ្នកតា, មានអ្នកតារក្សាខេត្រ, អ្នកតារក្សាទីប្រជុំជន, អ្នកតារក្សាភូមិ ។ អ្នកតាទាំនោះ មានឋានានុក្រមធំ-តូច, ព្រោះហេតុនេះហើយ ទើបអ្នកតាចាស់ស្រុក នៅកំពង់ត្រាច មានអ្នកតា ស្មៀនមួយ ដែលជាអ្នកពាំនាំសំណូមពររបស់ប្រជាជន ជូនទៅអ្នកតាចាស់ ស្រុក ។

អ្នកតា គឺជាម្ចាស់ទឹកដី, ដោយហេតុនេះ មានភារកិច្ចទទួលខុសត្រូវចំ-ពោះអ្វីដែលបានកើតមានឡើងនៅលើទឹកដីនេះ គឺចំពោះអ្នកតាទាំងនោះឯង ដែលគេត្រូវបន់ស្រន់ បើកាលណាមានជំងឺឆ្លងកើតឡើងឬមានជំងឺរាតត្បាត សត្វពាហនៈ, ឬក៏ប្រទេសកើតមានចលាចល, គឺចំពោះអ្នកតាហ្នឹងឯងដែល គេតែងបន់ស្រន់សុំទឹកភ្លៀង និងសុំឱ្យផលិតផលកើតមានសម្បូរពោរពាស ។

ប៉ុន្តែ បើគេចង់សិក្សាអោយស៊ីជម្រៅអំពីអ្វីដែលជាអ្នកតា គេនឹងបាន

ឃើញថា ក្រៅពីចំណងទាក់ទងដ៏តិចតួចរបស់អ្នកតា ជាមួយនឹងចំណែកដែនដី, អ្នកតាទាំងឡាយ មិនដូចគ្នានៅគ្រប់ទីកន្លែងទេ ។ ជាទូទៅ ហើយក៏ដូចជាលោក *អាដេម៉ា ឡឺក្លែរ* រៀបរាប់ដែរ, គេបានចាត់ទុកថា អ្នកតាទាំងឡាយ គឺជាព្រលឹង ឬជាវិញ្ញាណរបស់ដូនតា (បុព្វបុរស) ។ ប៉ុន្តែ ជាញឹកញយមានអ្នកតាដែលគេលើកតាំងឡើង ពីព្រោះតែការបន់ស្រន់ទាំងឡាយដែលគេបានធ្វើឡើងចំពោះដើមឈើធំណាមួយនោះ ត្រូវបានបំពេញតាមបំណងរបស់គេ, ហើយឈ្មោះ ឬ តំណាងរបស់អ្នកតាជាច្រើន ដែល ពួកកេ១បញ្ជាក់អោយឃើញថា ឈ្មោះ ឬតំណាងទាំងឡាយនោះ គឺជាឈ្មោះ ឬតំណាងរបស់ទេព្ដា សាសនាព្រាហ្មណ៍សម័យបុរាណ ។

ដោយហេតុនេះ ចំណងទាក់ទងរបស់អ្នកតា ជាមួយនឹងដើមឈើធំ១ដែលគេច្រើនតែធ្វើសម្ភារូបនីយកម្ម (matérialisation ) ដើមឈើទាំងនោះ ដោយយកឫសឈើមានទ្រង់ទ្រាយចម្លែកបែបណាមួយនោះ (មកដាក់នៅក្នុងខ្ទមអ្នកតា) បញ្ជាក់អោយឃើញថា អ្នកតាទាំងនោះ នៅក្នុងករណីមួយនោះ គឺជាព្រលឹង ឬជា វិញ្ញាណនៃរុក្ខជាតិ, ហើយប្រហែលជារុក្ខជាតិខ្លួនឯងនេះ ត្រូវបានគេចាត់ទុកថា គឺជាការភាយចេញមកអំពីដែនដី (une émanation du territoire ) ។ ក្រៅពីនេះ, នៅមានអ្នកតា នារាយណ៍ (វិស្ណុ), អ្នកតា ឥសូរ (សីវៈ), អ្នកតា ឥន្ទ (ឥន្ទ្រ), នាងខ្មៅ (កាឡី) ។ នៅស្រុកបាភ្នំ, រូបរបស់ឧមា មហិសាសុរ (Uma Mahishâsura) ក្លាយទៅជាអ្នកតាមេ-សរ ដោយការបំផ្លែងពាក្យ បំព្រួញមកពីសព្ទមហិសាសុរ (Mahishâsura ) ។

បច្ចុប្បន្ននេះ នៅពេលធ្វើពិធីប្រចាំឆ្នាំជាកិត្តិយស ចំពោះអ្នកតាមេ-សរ នៅបាភ្នំ, គេបានថ្វាយជ្រូកដែលសម្លាប់ និង ស្រោចទឹកក្ដៅកោស

ដោយអ្នកកាប់ជ្រូកជាតិចិន, ប៉ុន្តែ ខ្ញុំបានទទួលពិតមានរបៀបរាប់អំពីពិធីតាមដូចដែលគេធ្លាប់បានធ្វើ កាលពីគេនៅសម្លាប់គោឡើងកបូជាយញ្ញ ចំពោះអ្នកតា, ដោយតាចាស់ម្នាក់ ដែលឪពុករបស់គាត់ធ្លាប់បានឃើញគេសម្លាប់មនុស្សបូជាយញ្ញ ។ តាចាស់នោះ ពុំបានចាំច្បាស់នូវអ្វីដែលគេបាននិយាយប្រាប់គាត់អំពីរឿងសម្លាប់មនុស្សបូជាយញ្ញនោះទេ, ប៉ុន្តែ គាត់បានសន្និដ្ឋានថាការសម្លាប់មនុស្សបូជាយញ្ញ ក៏មិនខុសប្លែកអំពីការសម្លាប់សត្វបូជាយញ្ញដែរទេ ។ ភាពជាអចិន្ត្រៃយ៍នៃការធ្វើពិធី (rites) ឃើញនៅមានដដែលយ៉ាងល្អិតល្អន់ អស់សេចក្ដី ដែលអ្នកសង្កេតការណ៍សើៗ អាចមិនចាប់អារម្មណ៍ដល់ ។ ព្រោះហេតុនេះហើយ ទើបខ្ញុំកាន់តែចង់ដឹងអំពីក្រដាសប្អូនជ្រុងពណ៌ក្រហមបិទនៅលើច្រមុះជ្រូក ថ្វាយអ្នកតាមេ-សរ ។ ក្រដាសប្អូនជ្រុងបែបនេះ ធ្លាប់ឃើញប្រើតែនៅក្នុងពិធីបុណ្យសាសនាចិន និងវៀតណាម, ហើយក្រដាសក្រហមប្អូនជ្រុងនេះ វាអាចជាគំនិតបង្កើតឡើងដ៏រវើរវាយ (une fantaisie) មួយរបស់ចិនកាប់ជ្រូក ។ ប៉ុន្តែ ដោយបានដឹងថា គេបានគ្របក្បាលគោឡើងក ដោយកំណាត់ពណ៌ក្រហមដែរនោះ, វាកាន់តែធ្វើអោយខ្ញុំសង្ស័យថា ក្រដាសមួយដុំតូចនោះ អាចជា សំណល់ចុងក្រោយនៃកំណាត់ពណ៌ក្រហមនោះឯង ។ ហើយដោយហេតុថា, នៅនឹងជើងទួលនៃខ្ទមអ្នកតា, គេកាត់កសត្វដោយដាវយ៉ាងមុត ដោយគេបានសន្មតថា បើឈាមសត្វបាញ់ចេញចំទិសណា, តំបន់ទាំងឡាយក្នុងទិសនោះ នឹងមានភ្លៀងធ្លាក់ដោយបរិបូរ, គេអាចសន្និដ្ឋានបានយ៉ាងងាយទៀតថា វាដូចតែគ្នា, កាលណាមនុស្សម្នាក់ត្រូវគេសម្លាប់បូជាយញ្ញ ។ ក្បាលគោឡើងក ត្រូវបានគេនាំយកមកដាក់នៅចំពោះមុខអ្នកតា ៖ នៅពេលកំពុងតែរាំ, រូបដែលអ្នកតាមេ-សរចូលនោះ ក៏ទាត់បញ្ជូនក្បាលគោនោះអោយរមៀលធ្លាក់មកជើងទួល ។ អ្វីដែលអាចធ្វើឱ្យ

ព្រៃខ្លាចជាងនេះទៅទៀតនោះ, គឺកាលណាគេគិតទៅដល់សម័យដើម ដែលគេត្រូវទាត់បញ្ជូនក្បាលមនុស្ស អោយរមៀលធ្លាក់ចុះទៅជើងទួល ដូចគ្នានេះ ។

ខ្ញុំសូមបញ្ជាក់ម្តងទៀតថា ពិធីសម្លាប់មនុស្សបូជាយញ្ញ គឺគ្រាន់តែជាអនុស្សាវរីយ៍ប៉ុណ្ណោះទេ, ហើយនៅស្ទើរតែគ្រប់ទីកន្លែង គេបានបញ្ឈប់សម្លាប់សត្វបូជាយញ្ញទៅទៀតហើយ ។ នៅក្នុងប្រទេសមួយកាន់ព្រះពុទ្ធសាសនាយ៉ាងជ្រាលជ្រៅដូច្នេះ, ពិធីប្រកបដោយការបង្ហូរឈាម ត្រូវបានបិតថេរនៅអស់កាលដ៏យូរ, នេះជាភស្តុតាងបញ្ជាក់ថា ពិធីប្រកបដោយការបង្ហូរឈាមនោះ តើវាមានសារសំខាន់ប៉ុនណាទៅ នៅក្នុងអតីតកាលនោះ !

ឥឡូវនេះ, គេថ្វាយចំពោះអ្នកតា ក្រៅពីវត្ថុចាំបាច់សម្រាប់ការបូជាធ្វើពីដើមចេក និងស្លឹកចេក គឺគេថ្វាយបាយសម្លរ នំ ចំណី បារី ស្លា ព្រមទាំងទៀន និងធូបផង ។ ក្នុងករណីមានជំងឺត្រូវសែនព្រេន, គេធ្វើពែអំពីស្រទបចេក មានពំនូតដីអិដ្ឋតូចៗ បីបួនដុំដាក់នៅលើពែនោះ ប្រហែលជាពីដើម គេមានទម្លាប់សូនរូបអ្នកជំងឺដាក់នៅលើពែ, ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ, ពំនូតដីអិដ្ឋនោះ ប្រើសម្រាប់ជំនួសមនុស្ស ឬ សត្វដែលឈឺ ។ នៅទីកន្លែងជាច្រើន, មនុស្សរូបអារក្ស ឬ រូបអ្នកតា ជួនកាលជាប្រុស ជួនកាលជាស្រីត្រូវបានខ្មោចចូល ហើយខ្មោចនោះ និយាយតាមមាត់មនុស្ស ។ តាមការយល់សប្តិ, តាមប្រកាសនា (une révélation) គឺការឆ្លុះបញ្ចាំងអោយឃើញបែបណាមួយនោះ យោលទៅតាមវិបត្តិសសៃប្រសាទ, មនុស្សនោះដឹងខ្លួនថាខ្លួនត្រូវធ្វើជារូប ពោលគឺ ជារូបរាងរបស់អ្នកតា ។ ជួនកាល, មុខងារនេះ ត្រូវបានកាន់កាប់តពូជ ។ គឺរូបនេះហើយ ដែលប្រាប់អ្នកភូមិ អំពីចំណង់របស់អ្នកតាចង់បានអ្វី, គឺរូបនេះហើយ ដែលប្រាប់អោយដឹងក្រោយពេល

របៀបពិធីរួចថា ភូតបិសាចសប្បាយរីករាយ គេនឹងផ្តល់ដល់អ្នកភូមិ នូវអ្វីដែលគេបន់ស្រន់សុំ ។

ជាញឹកញយ អ្នកតាតែងមានរឿងនិទាន ដែលភ្ជាប់ទៅនឹងអ្នកតាទាំងនោះ; តាមរឿងនិទាននេះ គេអាចរកឃើញឡើងវិញ នូវទេវកថាសាសនា-ព្រាហ្មណ៍ពីបុរាណ, ព្រមទាំងពិធី (rites) សាសនាទាំងឡាយ ដែលគេបានភ្លេចហើយនោះ ឬក៏ រកឃើញដានព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ ។ ជាក់ស្តែង, ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រចុងក្រោយគេ, ដ៏ច្បាស់លាស់បំផុត និងស្រួលផ្ទៀងផ្ទាត់បំផុតនោះ គឺព្រឹត្តិការណ៍ដែលមានទំនាក់ទំនងពេលថ្មីៗបំផុត ។ ឧទា-ហរណ៍ រឿងនិទានទាក់ទងនឹងអ្នកតាកំពត រក្សាបានយ៉ាងត្រឹមត្រូវនូវអនុស្សា-វរីយ៍នៃព្រឹត្តិការណ៍ដែលបានកើតមាន នាសតវត្សន៍ទី ១៧ ។ ដទៃពីនេះ, រឿងនិទាន មានឫសគល់តាំងតែពីអតីតកាលវែងឆ្ងាយ, ប៉ុន្តែ ខ្ញុំជឿថា ការសិក្សាដោយយកចិត្តទុកដាក់អំពីរឿងនិទានទាំងឡាយនោះ នឹងមានតម្លៃណាស់ សំរាប់អ្នកប្រវត្តិសាស្ត្រ ។

រឿងនិទាន ក៏នឹងមានតម្លៃណាស់ដែរ សម្រាប់បុរាណវត្ថុវិទូ ។ ខ្ញុំសូមលើកយកឧទាហរណ៍មួយដែលខ្ញុំចាំ គឺមានអ្នកតាមួយ ដែលគេមកសុំខ្ចីចានក្បាន សំរាប់ធ្វើបុណ្យទានធំៗ ឬធ្វើបុណ្យទានជាឯកជន ។ ក្រោយពេលបានធ្វើការបន់ស្រន់ដោយមានទៀនបីដើម ធូបបីសសៃរួចហើយ, គេក៏ជីកដីនៅជើងទួល ហើយគេប្រទះឃើញចានក្បាន និងប៉ានពែងយ៉ាងច្រើន, នេះបើអ្នកតាពេញចិត្ត, ប៉ុន្តែ គេត្រូវយកចិត្តទុកដាក់នាំយកវត្ថុទាំងនោះ មកកប់នៅក្នុងទីកន្លែងដដែលវិញ ក្រោយពេលចប់កិច្ចការ, បើមិនដូចនោះទេ អ្នកឯងនឹងត្រូវជំងឺ និងមច្ចុរាជកាច់យកមិនខាន ។ ជាការណ៍ពិតណាស់, ទួល ឬ អង្គអាចជាកន្លែងជីកកកាយរកវត្ថុបុរាណ, បីដូចជាកន្លែងដ៏ច្រើនទៀត ដែលមាន

រោងអ្នកតាតាំងនៅ ។

ខ្ញុំគិតថា អត្ថបទដ៏ខ្លីនេះ គ្រប់គ្រាន់ល្មមនឹងបង្ហាញថា តើការសិក្សាអំពីអ្នកតាក្នុងស្រុករបស់ប្រទេសកម្ពុជា, ដ៏ជាអនុស្សាវរីយ៍យ៉ាងសាមញ្ញប្រកបដោយអតីតកាលវែងឆ្ងាយ និងសម្បូរខ្លឹមសារនោះ តើមានអត្ថប្រ-យោជន៍យ៉ាងណា ។ កាលណាអ្នកដើរកំសាន្ត ក្រឡេកឃើញកូនខ្ទមរញ៉ីររញ៉ៃរមួយ សង់នៅលើទួល, ក្រោមម្លប់ឈើកណ្ដាលវាលស្រែ ក្ដៅហែងដោយកំដៅព្រះអាទិត្យ, ដែលនៅក្នុងខ្ទមនោះ មានតង្វាយបន្តិចបន្តួចគ្របដណ្ដប់ដោយធូលីក្រៀមក្រញង់, អ្នកដើរកំសាន្តនោះអាចប៉ាន់ស្មានឃើញថា គឺជាលំនៅឋានរបស់ទេវៈមួយអង្គ ដែលពីដើមមានឫទ្ធានុភាព, ហើយពីដើម ត្រូវបានទទួលការគោរពបូជាអំពីតួអង្គដដែលទាំងនោះ ដែលបានតុបតែងខ្លួនយ៉ាងឆើតឆាយ ហើយរូបភាពរបស់គេ ត្រូវបានឆ្លាក់នៅលើចម្លាក់ក្រឡោត (bas-reliefs ) នៃប្រាសាទអង្គរវត្ត ។

អេឡីវីន ប៉ូរ៉េ - ម៉ាស្ប៉េរ៉ូ
( Elevine Porée - Maspero )
ក្នុងប្រ្វង់-អាស៊ី លេខ ៣៧ - ៣៨ ពិសេស
ឆ្នាំ ១៩៤៩

ប្រែសម្រួល : **ឈន អៀម**

## រឿងព្រេង

# ចេះជប់មិនស្មើប្រសប់មួយ

កាលពីព្រេងនាយ មានចៅមាណពម្នាក់ មានប្រពន្ធពីរ ។ មួយឈ្មោះនាងឆាត (១) មួយទៀតឈ្មោះនាងភើ(២) ។ គ្រប់ពេលវេលា នាងទាំងពីរ ប្តេជ្ញាធ្វើអ្វីៗទាំងអស់ ដើម្បីអោយគាប់ចិត្តប្តីជាងគូប្រជែងរបស់ខ្លួន ក្នុងន័យដណ្តើមយកឋានៈជាប្រពន្ធដើម (៣) ។ រាល់ ថ្ងៃបើកភ្នែកកាលណា មាណពឃើញប្រពន្ធភ្លោះរបស់ខ្លួន ស្ទុះស្ទាខ្វែងជើង ខ្វែងដៃ ប្រណាំងប្រជែងគ្នា ដើម្បីផ្គាប់ចិត្តគម្លែងក្រឡារបស់ខ្លួន ។ ស្ថិតក្នុងស្ថានភាពដូច្នេះ គួរណាស់តែមាណពឡើងជិនោរ រីកថ្លើម រីកប្រមាត់ ដោយមនុស្សក្នុងផ្ទះគោរពបូជាលើកតម្កើងខ្លួន ជិតស្មើនឹងព្រះអាទិទេព ។ ផ្ទុយទៅវិញ គេបែរជាមានកង្វល់ តប់ប្រមល់ក្នុងចិត្តឥតសុខសាន្ត ។ គាត់ពិចារណាថា : សកម្មភាពមានបង្កប់ទៅដោយប្រជាភិថុតិនេះ ពិតជាគ្មានអត្ថន័យសន្តិភាពទេ ។ ធាតុពិត វានឹងឈានទៅផ្ទុះបង្កាត់ ផុតបញ្ឆេះការប្រទូសរ៉ាយកាន់តែខ្លាំងឡើងៗ រហូតដល់ចាត់ទុកគ្នាជាគូសត្រូវស្លាប់រស់ នៅទីបញ្ចប់ ។ ដើម្បីអារកាត់រឿងនេះអោយបានទាន់ពេលវេលាក្នុងបរិយាកាសសន្តិភាព ចៅមាណពមានគំរោងដាក់វិញ្ញាសាមួយចំនួនអោយប្រពន្ធទាំងពីរប្រឡងប្រជែង ដើម្បីវាស់កំរិតប្រាជ្ញា ហើយធ្វើការចាត់ថ្នាក់នៅចុងបញ្ចប់ ។

ថ្ងៃមួយ ចៅមាណពបានហៅប្រពន្ធទាំងពីរមកនិយាយ ដោយវាចាទន់ភ្លន់ថា :

---

(១) & (២) បើគេដាក់ជើងល ( ្ល ) ពីក្រោមឈ្មោះទាំងពីរនេះ គេនឹងយល់ភ្លាមអំពីអត្ថន័យរបស់ឈ្មោះនេះ ជាមិនខាន ។ (៣) ប្រពន្ធទី១ ឬ ប្រពន្ធធំ

- ហៃអូនទាំងពីរ ជាទីគាប់ចិត្តរបស់បងអើយ ពេលវេលាបានតម្រូវអោយបងធ្វើការជ្រើសរើសអូនណាមួយធ្វើជាប្រពន្ធដើម ដោយឆ្លងតាមការប្រឡងសាកល្បងកិរិតប្រាជ្ញា ។ ក្រោយការប្រឡង បើអូនណាមួយបានបញ្ចេញស្នាដៃអោយបងឃើញជាមនុស្សឆ្លាតវាងវៃ ប៉ិនប្រសប់ អាចចេះដោះស្រាយគ្រប់បញ្ហាជីវិតបាននោះ បងនឹងលើកឋានះជាផ្លូវការ អោយឡើងជាប្រពន្ធទីមួយ ។

នៅពេលនេះ អូនទាំងពីរត្រូវខិតខំដោះស្រាយវិញ្ញាសាទីមួយនេះគឺ : ពេលនេះ ជារដូវប្រាំងរាំងរីះ សូមអូនទាំងពីរធ្វើយ៉ាងណារកទំពាំង(១) មកស្ងោរអោយបងបរិភោគបានមុនគេ នោះចាត់ថាជាបេក្ខជនវាងវៃ ។

យប់នោះ នាងភើ និងនាងឆាត ប្រើពេលវេលាមិនតិចម៉ោងប៉ុន្មានទេដើម្បីគិត ថ្ងៃ លៃដោះប្រស្នាប្តីអោយបានឆាប់ ។ ក្រោកពីព្រលឹម នាងភើខំរែកទឹកស្រោចគុម្ពឫស្សី ដើម្បីអោយទំពាំងឆាប់ដុះ នឹងបានជីកយកមកស្ងោរអោយប្តីពិសារ។ ឯនាងឆាតបែរជាយកភ្លើងទៅដុតគុម្ពឫស្សីទៅវិញ ។ ប្រមាណជាកន្លះខែក្រោយមកទំពាំងចេញដៃ ( មែក - ខ្នែង ) ខ្ចីល្វក់ ដែលបងប្អូនកសិករយើងធ្លាប់ហៅថា ទំពាំងភ្លើង ។ នាងឆាតកាច់ទំពាំងភ្លើងនេះ យកមកស្ងោរអោយប្តីបរិភោគបានមុន ។ ឯគុម្ពឫស្សីមួយទៀត ដែលនាងភើស្រោចទឹកនោះ ពីរខែក្រោយមក ក៏ពុំទាន់ដុះទំពាំងផង ។ ដូច្នេះ ការប្រឡងវិញ្ញាសាលើកទី ១ នេះ នាងឆាតត្រូវបានចាត់ថ្នាក់ជាបេក្ខ-ជនឆ្លាតជាង ។

នៅលើកទីពីរនេះ ចៅមាណព ចោទជាបញ្ហាថា :

បើអូនណា អាចរកទឹកសន្សើមអោយបងផឹកមួយចំអែតបានមុនគេ នោះនឹងត្រូវចាត់ទុកជាប្រពន្ធប៉ិនប្រសប់ ។

---

(១) តាមធម្មតា ទំពាំងឫស្សីគ្រប់ប្រភេទដុះតែរដូវវស្សាទេ នៅរដូវប្រាំងវាពុំដែលដុះឡើយ ។

ក្រោកតាំងពីព្រលឹម, នាងភើ បានដើរគោះ រលាស់ទឹកសន្សើមដែលជាប់នៅចុងស្មៅ ឬ ស្លឹកឈើដាក់ក្នុងផ្តិលមួយ ។

ការធ្វើដូច្នេះ ពេញមួយព្រឹកធំ នាងភើពុំអាចរកបានទឹកសន្សើមមួយលេបផង ។ ឯនាងឆាតវិញ នាងបានយកស្បៃស្អាតមួយផ្ទាំងដើរគ្រវាសផ្តិតទឹកសន្សើមដែលជាប់នៅលើស្លឹករុក្ខជាតិនានា ។ កាលណាស្បៃបានបឺតស្រូបជោរជោកដោយទឹកសន្សើមហើយ នាងយកមកពូតដាក់ផ្តិល ។ រយៈពេលមិនដល់មួយម៉ោងផង នាងឆាតរកទឹកសន្សើមបានជិតពេញមួយកូនផ្តិល យកមកឱ្យប្តីផឹក ។

នៅលើកទីបីនេះ ចៅមាណព និយាយទៅកាន់ប្រពន្ធទាំងពីរថា :

សូមអូនទាំងពីរ អាំងត្រីអោយបងបរិភោគ ។ បើអូនណាអាំងត្រីឆ្អិនយកមកអោយបងបរិភោគបានមុនគេ នោះចាត់ទុកថាជាប្រពន្ធពូកែ និងប៉ិនប្រសប់ ។ បរាជ័យដូន១គ្នាពីរលើក ធ្វើអោយនាងភើភ័យខ្លាចបាត់បង់ដំណែងជាប្រពន្ធទីមួយ នាងខំអង្គុយសម្លឹងដំបុតត្រី ដែលដាក់ផ្កាលលើរងើកភ្លើង ឥតហ៊ានងាកចេញទៅណាឆ្ងាយឡើយ ។ នាងអង្គុយប្រែប្រួលចុះឡើង១ ក្នុងបំណងធ្វើយ៉ាងណាអោយត្រីឆាប់ឆ្អិនបានមុនគេ ។ ប្រែចុះប្រែឡើងញយ១ ត្រីនោះក៏ទន់ខ្លួនបាក់ជាពីរកំណាត់ ធ្លាក់ចូលក្នុងចង្ក្រានប្រឡាក់ផេះអស់ ។ នាងខំរត់ទៅលាងត្រីឯពាងទឹកអោយបានស្អាតឡើងវិញ រួចអង្គុយអាំងត្រីជាបន្តទៀត ។ ទឹកដែលជាប់ជិតជាមខ្លួនត្រីជោរជោក បានស្រក់យ៉ាងច្រើនមកលើរងើកភ្លើង ធ្វើអោយវាចេះតែរងោចទៅ១ រហូតដល់រលត់តែម្តង ។ នាងភើអភ័ព្វ ត្រូវបង្កាត់ភ្លើងសាជាថ្មី ។ ចំណែកឯនាងឆាតវិញ លុះនាងឡុតត្រីរួចហើយ ក៏យកទៅអាំងលើរងើកភ្លើងលៃមិនអោយខ្ពស់ពេក ឬ ទាបពេក ហើយកល់វាអោយបាននឹង រួចក៏ចេញទៅអោយបាយជ្រូក និងបោក ខោអាវ ។ មួយសន្ទុះក្រោយមក នាងមកប្រែត្រីដែលបានឆ្អិនមួយចំហៀង ហើយ រួចក៏ទៅចាត់ចែងការងារទៀត ។ លុះនាងត្រឡប់មក

លើកក្រោយ ត្រីក៏បានឆ្អិនសព្វល្អ ហើយនាងក៏យកទៅជូនប្តីពិសា នៅពេលដែលនាងភើកំពុងបង្កាត់ភ្លើងសាជាថ្មីនោះ ។

ឆ្លងកាត់ការសាកល្បងគ្រប់បីដង ចៅមាណពមានមូលដ្ឋានគ្រប់គ្រាន់ដើម្បីតែងតាំងនាងឆាតជាប្រពន្ធទី ១ ពេញលក្ខណៈ ។ ចំណែកនាងភើវិញ នាងបានទទួលស្គាល់នូវប្រាជ្ញាវាងវៃ គំនិតច្នៃប្រឌិតដ៏ប៉ិនប្រសប់របស់នាងឆាត ហើយកត់សំគាល់ខ្លួនឯងថាជាមនុស្សអសមត្ថភាព ដែលសក្តិសមនឹងទទួលតំណែងជាប្រពន្ធទីពីរ តទៅ ។

ជាធម្មតា មនុស្សតែងតែប៉ុនប៉ងប្រាថ្នា ប៉ុន្តែគឺសមត្ថភាពទេ ដែលកំណត់នូវជោគវាសនារបស់ខ្លួននោះ ។

រៀបរៀងដោយ

**មៀច ប៉ុណ្ណ**

# មាន់ស្រុក និង មាន់ព្រៃ

## បទបន្ទោលកាក

នេះហ្នឹងស្រដី ពីមាន់បក្សីឆ្លើយឆ្លង
ឈ្មោះគ្នាអឹងកង ព្រោះតែបំណងទីទៃ ។
ម្ខាងជាមាន់ស្រុក អាគកធំស្លុកវាងវៃ
ម្ខាងជាមាន់ព្រៃ ដណ្តើមជាញជ័យពីគ្នា ។
មាន់ស្រុកថាវើយ អាព្រៃជម្ងើយលេលា
ម្តេចមកពាធា ចូលដល់ទីធ្លាផងអញ ។
ឯងជាតិចោកទាប ធ្លាប់ស៊ីរលាបមិនឆ្ងាញ់
អត់សាច់អត់ខ្លាញ់ លេបតែផ្កាស្មៅក្រៀមក្រោះ ។
ទ្រនំផងឯង គឺស្បូវព្រៃព្រៃងរបោះ
គ្មានគត់មត់សោះ ត្រូវភ្លៀងត្រូវខ្យល់វេទនា ។
មាន់ព្រៃបានស្តាប់ ឆ្លើយវិញប្រញាប់ឥតរា
ថាអេះស្តាប់វា ឃើញជាគ្រាន់បើជាងគេ ។
មិនដឹងខ្លួនសោះ ឯងនេះគេប្រោះទុកទេ
ចាំពេលទំនេរ វះពោះអាភេក្លែមស្រា ។
ឯងនេះអន់ណាស់ លើក្បាលមានម្ចាស់រក្សា
ដាក់ទានអាហារ អោយឯងភោក្តាត្រើមរស់ ។
ចោកទាបឥតបី បាត់សិទ្ធិសេរីកិត្តិយស
ប្រៀបបីដូចដោះ មានរូបមានឈ្មោះឥតន័យ ។

គេចាក់លុយភ្នាល់ ចាប់ឯងប្រជល់យកជ័យ
បើចាញ់លក់ភ្នែ អារកស្មោរជ្រក់តែម្តង ។
ចំណែកអញវិញ អត់ទុកទោម្នេញឡើយហោង
រស់ជុំប្អូនបង មានសេរីភាពបរិបូណ៌ ។
រស់ក្នុងព្រៃពិត តែពុំភ័យភិតដេកថ្កូវ
ជីវិតថ្លៃថ្នូរ គ្មានអ្នកត្រួតត្រាលើក្បាល ។
អង្គអញនេះនៃ ជាតិជាមាន់ព្រៃត្រកាល
វិសេសវិសាល អាចដើរលោតផ្លោះហោះហើរ ។
មាន់ស្រុកថាចឹស មើលមុខអាបីសគ្រាន់បើ
គ្មានគេសរសើរ ខំអួតហៃអើខ្លួនឯង ។
មិនដឹងខ្លួនល្ងង់ ត្រូវព្រានធ្វើជង់ចាំត្បែង
ចាប់ក្បាលព្រះស្តែង ឱ្យទៅធ្វើខែងក្នុងផ្ទាំង ។
អង្គអញមាន់ស្រុក មាឌមាំធំស្លុកហើយខ្លាំង
អាចបានតតាំង ប្រណាំងនឹងហង្សបក្សា ។
សព្វសត្វទីទៃ ទាំងស្រុកទាំងព្រៃនោះណា
សឹងកោតចេស្តា គោរពឱ្ភាពេកហោង ។
ពេលអញរងាវ ជាដួងអំពាវអ្នកផង
ឱ្យភ្ញាក់អឹងកង ងើបឡើងត្រសងធ្វើការ ។
អញរងាវផ្ទួន អាចដាស់អង្រួនសុរិយា
ឱ្យចរយាត្រា បំភ្លឺលោកាប្រញាប់ ។
សំឡេងអង្គអញ បានគេស្រឡាញ់ចង់ស្តាប់
ទោះប្រើអោយស្លាប់ សោតសឹងពុំបានប្រកែក ។

ជាជង់ទិព្វមន្ត មានឫទ្ធិពេកពន់ថ្នាកឯក
មានគុណអនេក ចំពោះមនុស្សសត្វនានា ។
បើគ្មានអញទេ នោះពុំមានមេបញ្ញា
មនុស្សសត្វរងា ទាំងព្រះសុរិយាលែងរះ ។
បើគ្មានសុរិយា តើមាននរណាជំនះ
អាចតតាំងឈ្នះ នឹងក្តីមរណាសោយសោក ។
មាន់ព្រៃថា ន ! មើលមុខអាភរដាក់ដោក
អញចង់តែខោក ប្រដៅឱ្យដឹងដៃម្តង ។
ស្តាប់ឮពាក្យឯង អញអាចជាន់កែងបានផង
អួតអាងកន្លង មុខត្រូវគេចងឥឡូវ ។
បើគ្មានសុរិយា កុំថាឡើយណាស្រែស្រូវ
ទាំងឯងក៏ត្រូវ វិនាសអន្តរាយមុនគេ ។
ហេតុនេះសុរិយា មិនរះដោយសារអាទេ
កុំភូតអាភេ នាំតែខ្មាសគេស្តាប់ឮ ។
គ្រានោះមាន់ស្រុក រងាវកែកុករន្ធឺ
មាន់ព្រៃមិនព្រើ រងាវដងឪឆ្លើយឆ្លង ។
មាន់ស្រុកអាងខ្នាយ មាន់ព្រៃដីអាយអាងស្នង
ជល់គ្នាអឹងកង ក្នុងក្តីបំណងផ្តាញ់ផ្តាល ។
លោតចឹកលោតធាក់ ឈាមហូរសស្រាក់ខ្មៅច្រាល
ហោរបាត់ដាបដាល រកកល់ដួលដេកទាំងទ្វេ ។
មិនបានដឹងខ្លួន ចាកព្រួញពួនជិតទេ
ក្រសៃភ្នែករេ ចាប់បានទាំងទ្វេហែកស៊ី ។

កញ្ច្រោងសើចឡូង ថាអញចាប់ម្តងបានពីរ
ទុកមួយផ្ញើញី គ្រាន់ចែកគ្នាស៊ីឆ្ងាញ់មាត់ ។
រឿងមាន់ឈ្លោះគ្នា កំណាព្យចងជាប្រវត្តិ
សម្រាប់ពលរដ្ឋ អានហើយត្រិះរិះអត្ថន័យ ។
ជាតិមាន់ដូចគ្នា គ្រាន់ជាមួយស្រុកមួយព្រៃ
ពុំមែនទីទៃ ចាំអីជល់គ្នាស្លាប់រស់ ។
ខ្មែរអើយសាមគ្គី ចងបាច់មូលមីរឈប់ឈ្លោះ
ជាតិមានកិត្តិយស សត្រូវឥតមោះបៀតបៀន ។
បើឈ្លោះតែគ្នា រឿងមាន់ទុកជាមេរៀន
កញ្ច្រោងពូនក្បៀន អួសពីសៃរៀនស៊ីបោង ។

**ខណ្ឌ ស៊ុនហេង**

# សេចក្តីជូនដំណឹង
# ស្តីពី
# ការប្រកាសលទ្ធផលនៃចម្លើយ " កំណាព្យប្រស្នា "
# ដែលចុះផ្សាយក្នុងទស្សនាវដ្តីកម្ពុជសុរិយា
# លេខ ១ ឆ្នាំ ១៩៩៤

គណៈកម្មការនិពន្ធនៃទស្សនាវដ្តីកម្ពុជសុរិយា មានសេចក្តីសោមនស្សរីករាយ សូមជំរាបជូនដំណឹង ចំពោះលោកអ្នកនាង ដែលបានផ្ញើចម្លើយទៅចូលរួមក្នុងការបកស្រាយ " *កំណាព្យប្រស្នា* " ដែលបានចុះផ្សាយក្នុងទស្សនាវដ្តីកម្ពុជសុរិយា លេខ១ ឆ្នាំ១៩៩៤ ថា ៖ ក្នុងចំណោមលិខិតជាច្រើនច្បាប់ ដែលទស្សនាវដ្តីបានទទួល មានតែលិខិតបួនច្បាប់ប៉ុណ្ណោះ ដែលឆ្លើយត្រូវនឹងខ្លឹមសាររបស់ប្រស្នា ។

ចំពោះលិខិតឆ្លើយត្រូវទាំងបួននេះ គណៈកម្មការពិនិត្យចម្លើយ បានរៀបចំណាត់ថ្នាក់ពីលេខ ១ ដល់លេខ ៣ ទៅតាមការប៉ិនប្រសប់ក្នុងការតែងនិពន្ធ និងទៅតាមសម្ផស្សកាព្យ ដោយប្រៀបទៅនឹងអត្ថបទចម្លើយរបស់ម្ចាស់ប្រស្នា ។

លទ្ធផលសំរេច មានដូចខាងក្រោម ៖

*លេខ ១* ត្រូវបានទៅអត្ថបទរបស់លោក **ព្រាប ភិរម្យ**
នៅសង្កាត់ផ្សារថ្មី III ខណ្ឌដូនពេញ ។

*លេខ ២* ត្រូវបានទៅអត្ថបទរបស់លោក **នួច ឌឹម**
មន្ត្រីរាជការក្រសួងធម្មការ និងសាសនា ។

*លេខ ៣* ត្រូវបានទៅអត្ថបទរបស់សមណសិស្សនាម **ម៉ិច សុផាក**
គង់នៅវត្តបទុមវតី រាជធានីភ្នំពេញ ។

*លេខ ៣ ស្ទួន* ត្រូវបានទៅអត្ថបទរបស់លោក **ចាប ចាន់ណារិទ្ធ**
បុគ្គលិកនៅរោងពុម្ព JSRC ក្រុងភ្នំពេញ ។

គណៈកម្មការ សូមអញ្ជើញម្ចាស់អត្ថបទ ដែលបានទទួលចំណាត់ថ្នាក់ពីលេខ ១ ដល់លេខ ៣ ខាងលើនេះ ទៅទទួលរង្វាន់ នៅទីស្នាក់ការរបស់ទស្សនាវដ្ដីស្ថិតនៅពុទ្ធសាសនបណ្ឌិត្យ វត្តឧណ្ណាលោម នៅរាល់ម៉ោងធ្វើការ ។

គណៈកម្មការនិពន្ធ សូមឆ្លៀតឱកាសនេះដែរ ដើម្បីសំដែងនូវអំណរសរសើរដ៏ជ្រាលជ្រៅ ចំពោះអស់លោកអ្នកនាងទាំងអស់ ដែលផ្ញើលិខិតទៅចូលរួមក្នុងការបកស្រាយប្រស្នារបស់ទស្សនាវដ្ដី ហើយគណៈកម្មការសង្ឃឹមថា អស់លោកអ្នកនាង នឹងចូលរួមកាន់តែច្រើនថែមទៀត ក្នុងការបកស្រាយ ដែលនឹងចុះក្នុងទស្សនាវដ្ដីកម្ពុជសុរិយា លេខបន្តបន្ទាប់ ។

*ភ្នំពេញ, ថ្ងៃទី ២៤ មិថុនា ១៩៩៤*

**កម្ពុជសុរិយា**

# ចម្លើយកំណាព្យប្រស្នា

. ចម្លើយប្រស្នា កម្ពុជសុរិយា លេខ ១ កៅប្អូន សូមស្រាយបញ្ជាក់
មិនលាក់បំពួន កាកគតិចុងជូន សំនួនឃ្លោងឃ្លា ។
. បងប្អូនពីរនាក់ ប្រស្នាបញ្ជាក់ មានមាឌប៉ុនគ្នា មួយគឺអង្គញ់ (១)
ជើងយើងលីលា ទ្រទ្រង់អង្គា បត់បែនជង្គង់ ។
. ពីរផ្លែអង្គញ់ (២) មូលដូចគេលញ់ មានមកយូរលង់ គេយកមកលេង
តាមបែបទម្រង់ ចាស់ក្មេងជិទង់ ពេលបុណ្យចូលឆ្នាំ ។
. បីថ្ងៃបីយប់ ល្បែងល្បាំមានគ្រប់ លេងសើចសកម្ម ល្បែងបោះអង្គញ់
កើយបោះកើយដាំ លេងតាមចំណាំ ដំណែលជូនតា ។
. អ្នកចាញ់គេជោះ ខ្លាំងតិចម្តេចនោះ សឹងមានពាក្យថា បាយក្តៅត្រជាក់
អ្នកលេងសន្យា ត្រជាក់តិចណា ក្តៅនោះខ្លាំងក្រៃ ។
. ការជោះនោះឯង ប្រស្នាបង្វែង ជាពាក្យឧបមេយ្យ បងប្អូនឈ្មោះគ្នា
ហាក់ពៀរនិស្ស័យ បីយប់បីថ្ងៃ ទើបលាលាតវង់ ។
. ព្រោះពេលគេជោះ មិនធ្វើអោយហួស បែបបទទម្រង់ យកផ្លែអង្គញ់
ភ្ជាប់ក្បាលជង្គង់ ចំអង្គញ់ផង ខុសគេចាប់ព្នៃ ។
. អង្គញ់ទាំងពីរ មានមុខនាទី ប្លែកគ្នាទីទៃ មួយនៅជើងមនុស្ស
មួយផ្លែឈើព្រៃ ល្បែងប្រពៃណី តម្រូវជួបគ្នា ។

**ខណ្ឌ ស៊ុនហេង**

(១) គ្រាប់អង្គញ់ ដែលជាសន្លាក់នៃជង្គង់ ។

(២) គ្រាប់ផ្លែអង្គញ់ទុំ សម្រាប់លេងល្បែងបោះអង្គញ់ ។

# ឆ្លើយ កំណាព្យប្រស្នា

ទស្សនាវដ្ដី

សួរអោយស្រដី បកស្រាយបញ្ហា ពីរឿងបងប្អូន
ពីរនាក់វាយគ្នា ហាក់មានកម្មពៀរ តាមជំនឿខ្មែរ ។

មួយឆ្នាំជួបម្ដង
ដេញគ្នាអឹងកង ច្រើននៅស្រុកស្រែ ពកមុខជាំមាត់
ចេញក្បាច់ស្រងែ លុះផុតថ្ងៃខែ បែកគ្នាទីទៃ ។

ខ្ញុំសូមសាកល្បង
ឆ្លើយតាមទំនង សំនួរកវី បងប្អូនពីរនាក់
មួយរស់ងព្រៃ ខ្ញុំឆ្លើយដោយខ្លី ថា ផ្លែអង្គញ់ ។

ម្នាក់ទៀតសំកុក
ចាំនៅឯស្រុក ចង់ជួបមិនធុញ មាឌមាំដូចគ្នា
ពេលជោះគេរុញ នោះគឺ អង្គញ់ នៅ ក្បាលជង្គង់ ។

អង្គញ់ទាំងពីរ
ជោះគ្នារកវី ពុំដែលរារង់ រាល់ពេលលេងល្បែង
ប្រុសស្រីជំទង់ តែងពកជង្គង់ ទាំងឆ្មេងទាំងស្ដាំ ។

អង្គញ់ជួបគ្នា

| | | |
|---|---|---|
| តែម្តងវេលា | ខ្មែរបុណ្យចូលឆ្នាំ | ប្រពៃណីជាតិ |
| ខែចេត្រគេដាំ | អង្គញ់កើយប្រាំ | បោះលេងកំសាន្ត ។ |

លេងមិនយូរថ្ងៃ

| | | |
|---|---|---|
| ក្មេងចាស់ប្រុសស្រី | ពុំដែលខកខាន | មុនបុណ្យពេលបុណ្យ |
| ថ្ងៃយប់មិនស្រាន្ត | លេងគ្រប់ទីស្ថាន | ដល់ថ្ងៃចប់បុណ្យ ។ |

បុណ្យចប់កាលណា

| | | |
|---|---|---|
| អង្គញ់បែកគ្នា | ទុរាទុរន់ | ទៅស្ថានទីទៃ |
| ដូចកាលពីមុន | រង់ចាំថ្ងៃបុណ្យ | ឆ្នាំថ្មីថ្មីទៀត ។ |

ខ្ញុំឆ្លើយប៉ុណ្ណេះ

| | | |
|---|---|---|
| ទៅតាមតម្រិះ | ដែលខ្ញុំខំឆ្លៀត | ខុសត្រូវម្តេចម្តា |
| សូមសន្តានញ្ញាតិ | បំពេញថែមទៀត | ដោយក្តីសន្តោស ។ |

**ព្រាប ភិរម្យ**

# ឆ្លើយ កំណាព្យប្រស្នា

១- ខ្ញុំកវីថ្មី

ក្មេងខ្ចីសេចក្តី ខ្លៅខ្លីបញ្ញា ថ្ងៃមួយបានអាន
កម្ពុជសុរិយា ឃើញពាក្យប្រស្នា មានអាថ៌កំបាំង ។

២- ប្រស្នាបញ្ឆោក់

« បងប្អូនពីរនាក់ ហាក់កម្មពៀរខ្លាំង បងប្អូនគ្នាពិត
តែចិត្តប្រឆាំង ប្រកាន់ទីតាំង រស់នៅទីទៃ ។

៣- បងនៅក្នុងស្រុក

ប្រកបដោយសុខ ឥតមោះគ្រោះភ័យ ប្អូននៅស្រយាល
កណ្តាលទ្រូងព្រៃ មិនមានមោះមៃ សឹងបានសុខជា ។

៤- ប្រស្នាបញ្ឆោក់

បងប្អូនពីរនាក់ មានមាឌប៉ុនគ្នា ជារៀងរាល់ឆ្នាំ
កម្មតាមផ្តន្ទា ត្រូវជួបគ្នា ម្តងជាកំណត់ ។

៥- រាល់ពេលជួបនោះ

កើតរឿងរ៉ាវឈ្លោះ វាយគ្នាប្រាកដ ជាំមាត់ពកមុខ
ពុំមាននឿយហត់ ដល់ថ្ងៃសន្ទត បែកគ្នាទីទៃ » ។

៦- «តើអ្វី? សូមឆ្លើយ

ចំណោទចោទហើយ ខ្ញុំសូមលកលៃ មួយ*ផ្លែអង្គញ់*
ជាប្អូននៅព្រៃ មួយទៀតមានន័យ *អង្គញ់ជង្គង់* ។

៧. អង្គញ់ពីរវា

មានមាឌប៉ុនគ្នា រលើបរលង់ មួយអង្គញ់ស្រុក
អង្គញ់ជង្គង់ មួយខ្មៅរលង់ គ្រាប់អង្គញ់ពិត

៨. ដើមនៅងព្រៃ

នេះឯងជាន័យ ត្រង់តាមក្រមក្រឹត្យ អង្គញ់ជង្គង់
អង្គញ់ប្រឌិត តែដូចជាពិត ព្រោះក៏អង្គញ់ ។

៩. ពិតណាស់ជង្គង់

អង្គញ់នៅក្នុង មូលកន្ទញ១ រាងពងក្រពើ
ហាប់ណែនដូចលញ់ នេះន័យអង្គញ់ ព្រៃ-ស្រុក-ប្អូន-បង ។

១០. ពេលចូលឆ្នាំថ្មី

ក្មេងខ្មែរឃ្លាតខ្លី ស្រីផងប្រុសផង លេងអង្គញ់ជោះ
ចែកជាពីរកង ដូរទីម្នាក់ដង ប្រឈមអាត្មា ។

១១. មុនលេងប្រិតប្រុង

ធ្វើប៉ាវសុីញសុង ដណ្តើមសេរ៉ា ក្រុមមួយឈ្មះប៉ាវ
ស្រែកហ៊ោខ្សៀវខ្សារ ចាប់ផ្តើមកីឡា ឡូឡាសូរវើ ។

១២. អង្គញ់ចាស់-ថ្មី

មួយដាំនៅដី អ្នកលេងឈរក្បែរ អាមួយដកខ្លួន
សម្លឹងដាក់ភ្លែ លោតរឹងទៅក្បែរ បុកប៉ុងរញ្ជួយ ។

១៣. បុកខ្លាំងត្រូវខ្លាំង

ប៉ុង១ប៉ុង១ ឥតព្រិចព្រីព្រួយ បោះត្រូវដួលអស់
ជោះគ្មានរញ្ជួយ មួយទល់នឹងមួយ ពួយប៉ុងជង្គង់ ។

១៤. នេះហៅឈ្មោះគ្នា

អស់បីទិវា ឥតហាត់ហៅរអង្គ ចប់ពេលចូលឆ្នាំ
បែកគ្នារហង់ វិលទៅរៀងអង្គ បែកគ្នាទីទៃ » ។

១៥. នេះជាចម្លើយ

ខ្ញុំពុំកន្តើយ ខិតខំលកលៃ ទំរាំរកឃើញ
គិតអស់ថ្ងៃម្លៃ សាកល្បងរកន័យ ដោយល្បិចប្រាជ្ញា ។

១៦. បើត្រូវដើមចុង

មេត្តាចុះក្នុង កម្ពុជសុរិយា លេខចេញបន្ទាប់
អោយឃើញខ្លឹមសារ សាកល្បងប្រាជ្ញា ល្បែងល្បោយល្បើកថ្មី ។

១៧. ខ្ញុំកវីក្មេង

សូមទោសឆ្លើយវែង ចង់ញែកសេចក្តី ជាការពិតស្តែង
សំនួរតែងខ្លី ចម្លើយសេចក្តី តែងវែងធម្មតា ។

១៨. បន្ទាប់សេចក្តី

ខ្ញុំកវីថ្មី សូមលើកហត្ថា ប្រសិទ្ធិពរជូន
កម្ពុជសុរិយា និងបងជេដ្ឋា នាម **ចណ្ណ ស៊ុនហេង** ។

**នួច ជីម**

ក្រសួងធម្មការ និង សាសនា

# កំណាព្យប្រស្នា

- ប្រទេសក្នុងលោក មានច្រើនគគោគ ខ្លះតូចខ្លះធំ មានស្តេចអត់ស្តេច
ស្រេចតែនិយម រាស្ត្ររួមជំនុំ គាំទ្រស្មគ្រស្មោះ ។
- នគរមួយប្លែក កើតរឿងបាក់បែក គួរអោយស្រណោះ ទាំងស្តេចមន្ត្រី
គ្មានធ្វើអ្វីសោះ គិតតែលោតផ្លោះ ចំបាំងរាំងជល់ ។
- ច្បាំងប្រជែងឫទ្ធិ ចំណាយជីវិត ធនធានរេហ៍ពល ដើងគោកដើងទឹក
វរវីកវិលវល់ វាយលុកទប់ទល់ ឈាមជោគធរណី ។
- សូមអស់លោកអ្នក ជួយស្រាយបញ្ហាក់ ដោយក្តីសំភី ស្តេចនោះហេតុម្តេច
ភ្លេចតួនាទី នាំទុក្ខញាំញី ពុំដែលហៅស្រាន្ត ។
- ស្តេចព្រះនាមអ្វី ? រាស្ត្រនិងមន្ត្រី ពលរេហ៍ប៉ុន្មាន ? នគរឈ្មោះអី ?
ស្តីតាមលំអាន ខុសត្រូវខកខាន បានចេះតែងកាព្យ ។

២៤ មិថុនា ១៩៩៤

**ខណ្ឌ ស៊ិនហេង**

# សេចក្ដីប្រកាសពត៌មាន

តាមការនិមន្តរបស់ក្រសួងធម្មការ និងសាសនា នៃព្រះរាជាណាចក្រកម្ពុជា ដោយមានការជួយឧបត្ថម្ភពីសំណាក់លោកស្រីបណ្ឌិត ហេម៉ា គូណាទីឡាគី ជំនាញការផ្នែកអភិវឌ្ឍន៍នារីនៃកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ និងមូលនិធិហិនរិច-បូល ស្ទិហ្វទុង ព្រះតេជព្រះគុណមហាថេរ បលគម វិបុលសរ ប្រធានសង្ឃនៃបរមធម្មចេតិយ បរិវេណៈ ស្រីលង្កា និងជាអគ្គលេខាធិការនៃសមាគមមហាពោធិនៃប្រទេសឥណ្ឌា បាននិមន្តមកធ្វើទស្សនកិច្ចសុឆន្ទៈ នៅព្រះរាជាណាចក្រកម្ពុជា ពីថ្ងៃទី២៣ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ ១៩៩៤ ។

ក្នុងឱកាសទស្សនកិច្ចសុឆន្ទៈនៅព្រះរាជាណាចក្រកម្ពុជា ព្រះមហាថេរមបលគម វិបុលសរ បាននិមន្តទៅទស្សនាវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ នៃ ក្រសួងធម្មការ និងសាសនា, បណ្ឌិត្យសភាព្រះសីហនុរាជ មជ្ឈមណ្ឌលវិបស្សនា នៅព្រៃកប្បិ, ប្រាសាទអង្គរវត្ត ប្រាសាទបាយន្ត និងប្រាសាទឯទៀតក្នុងតំបន់អង្គរ នៅខេត្តសៀមរាប, ព្រះបរមរាជវាំង ព្រះវិហារព្រះកែវមរកត, សារមន្ទីរជាតិ, មូលនិធិសាស្ត្រាស្លឹករឹត នៅកម្ពុជា ។

ជាមួយគ្នានោះដែរ ព្រះមហាថេរអង្គនេះបានជួបសម្ដែងការគួរសមចំពោះ សម្ដេចព្រះមហាសុមេធាធិបតី ទេព វង្ស ព្រះសង្ឃរាជគណៈមហានិកាយ, ព្រះបទុមវង្សាធិបតី ព្រះរាជតំណាងសម្ដេចព្រះសង្ឃរាជគណៈធម្មយុត្តិកនិកាយ, សម្ដេចព្រះមហាឃោសនន្ទ, ព្រះភិក្ខុស្ដេចក្រុមហ្លួង នរោត្ដម យុវនាថ, សម្ដេចក្រុមព្រះ នរោត្ដម រណឫទ្ធិ នាយករដ្ឋមន្ត្រីទី១ នៃព្រះរាជាណាចក្រកម្ពុជា, ឯកឧត្ដម ទ្រឿង មាលី នាយកខុទ្ទកាល័យព្រះមហាក្សត្រ, ឯកឧត្ដម ហៀន វណ្ណារ័ត្ន

រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា ព្រមទាំងឯកឧត្តមអនុរដ្ឋលេខាធិការ និងមន្ត្រីរាជការក្រសួងធម្មការ និងសាសនា, ព្រះអង្គម្ចាស់សីសុវត្ថិ សិរីវុឌ្ឍ ប៉ាណារ៉ា អនុរដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ព្រមទាំងធ្វើសិក្ខាសាលា ជាមួយសមណសិស្ស ២០០ អង្គ នៃពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត ផងដែរ ។

ទស្សនកិច្ចនៃព្រះមហាថេរ មបលគម វិបុលសារ នៅពេលនេះ មានសារសំខាន់ដល់ :

- ការពង្រឹងទំនាក់ទំនងរវាងព្រះពុទ្ធសាសនា នៅព្រះរាជាណាចក្រកម្ពុជា និងប្រទេសស្រីលង្កា ដែលមានតាំងពីបុរាណកាលមក,
- ជួយលើកស្ទួយវិស័យព្រះពុទ្ធសាសនា នៅព្រះរាជាណាចក្រកម្ពុជា,
- ឧបត្ថម្ភ អាហារូបករណ៍ដល់សមណសិស្សទៅបំពេញវិជ្ជានៅស្រីលង្កា,
- ជួយបោះពុម្ពសៀវភៅគម្ពីរបាលីមួយចំនួនឡើងវិញ,
- ជួយឧបត្ថម្ភ ក្នុងការបកប្រែសៀវភៅពីភាសាបរទេសមកភាសាខ្មែរ,
- ជួយផ្តល់សៀវភៅក្បួនខ្នាតខាងពុទ្ធសាសនាសំរាប់ជាឯកសារ,
- ធ្វើសេចក្តីសុំយាងសម្តេចព្រះសង្ឃរាជគណៈមហានិកាយ ទៅចូលរួមប្រជុំក្នុងសន្និសីទស្តីអំពី " ព្រះពុទ្ធសាសនា និង សន្តិភាពពិភពលោក" ដែលចាត់ចែងដោយ " World Buddhist Supreme Thathagatha Followers " នៅក្នុងខែសីហា ១៩៩៤ ខាងមុខ ។
- សន្យានឹងបញ្ជូនព្រះសង្ឃជាសាស្ត្រាចារ្យសិរីលង្កា មកកម្ពុជា ដើម្បីធ្វើការសិក្សាស្រាវជ្រាវនៅវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ និងជួយបង្រៀននៅពុទ្ធិក-វិទ្យាល័យព្រះសុរាម្រឹត ក្នុងរយៈពេល ៣ ខែ ក្នុង ១ ឆ្នាំ ។

*ភ្នំពេញ, ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ១៩៩៤*

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ




ឆ្នាំទី ៤៨ លេខ ៣ ខែ កក្កដា - សីហា - កញ្ញា
ព.ស ២៥៣៨ គ.ស ១៩៩៤

ភ្នំពេញ



# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ

ចេញរាល់ត្រីមាស ពី ពុទ្ធសាសនបណ្ឌិត្យ

ចាត់ចែងបោះពុម្ពផ្សាយដោយគណៈកម្មការមួយ មាន ៖

ទីប្រឹក្សា : **ហៀន ចណ្ណារត្ន**
នាយកការផ្សាយ : **ឈន អៀម**
និពន្ធនាយក : **យី ធន់**
និពន្ធនាយករង : **ឱម ខែម**

គណៈកម្មការនិពន្ធ

ព្រះធម្មលិខិត **លាស់ ឡាយ**, ព្រះមហាព្រហ្មមុនី **ហេង លាងហោ**,
លោក **ម៉ែន ប្រាង**, លោក **អាំ ឆន**,

## ごあいさつ

この本は、世界宗教者平和会議日本委員会と曹洞宗国際ボランティア会との共同プロジェクトとして印刷されました。

この本が、日本の宗教者とカンボジアの人々との友情のきずなとなり、カンボジアの宗教と文化の発展に貢献できれば幸いです。

## ACKNOWLEDGEMENT

The Kampuja Surya Magazine is specially printed as a cooperative project of the Japanese Committee of the World Conference on Religion and Peace (WCRP) and Japan Sotoshu Relief Committee (JSRC).

We pray that this magazine would contribute to the Friendship with Cambodian people and their religious and cultural preservation.

## និវេទនកថា

ទស្សនាវដ្តីកម្ពុជសុរិយានេះ ត្រូវបានបោះពុម្ពឡើងជាពិសេស ទុកដូចជាគម្រោងការងារ របស់គណៈកម្មាធិការជប៉ុននៃក្រុមប្រឹក្សាពិភពលោកស្តីពីសាសនា និងសន្តិភាព (WCRP) ហើយនិងគណៈកម្មាធិការជំនួយសូតូស៊ូជប៉ុន (JSRC) ។

យើងខ្ញុំអធិដ្ឋាន សូមឱ្យទស្សនាវដ្តីនេះ បានជាវិភាគទានរក្សាមិត្តភាពជាមួយប្រជាជនកម្ពុជា និងថែរក្សាសម្បត្តិសាសនានិងវប្បធម៌របស់ប្រជាជនកម្ពុជា ។

## មាតិកាអត្ថបទ

## I. អក្សរសិល្ប៍ពុទ្ធសាសនា ៖


- ព្រះធម៌របស់ព្រះពុទ្ធ (ត) ........................................ ១
- តតិយសង្គាយនា ........................................ ២៣
- បាយាសិរាជញ្ញសូត្រ ........................................ ២៦
- លោកសង្ឃខ្មែរ ........................................ ៣៣


## II. អក្សរសាស្ត្រទូទៅ ៖


- ល្បើកនគរវត្ត (ត) ........................................ ៤៨
- ជីវប្រវត្តិអ្នកព្រះភិរម្យភាសា អ៊ូ ហោ ង៉ុយ ........................ ៦៧
- ពាក្យកាព្យប្រដៅជនប្រុសស្រី ........................................ ៦៨
- លក្ខណៈពិសេសនៃជជនជាតិខ្មែរ ........................................ ៨៩
- ការសិក្សាសម័យបូរាណ ........................................ ១០០
- ចម្លើយប្រស្នាកំណាព្យ ........................................ ១០៨
- * ប្រស្នាកំណាព្យ ........................................ ១២១


## III. កណាត់ និងប្រវត្តិការណ៍ ៖


- ការចូលរួមសន្និសីទនៅសិរីលង្កា ........................................ ១២២
- ទស្សនកិច្ចរបស់គណៈប្រតិភូវៀតណាម ........................................ ១២៦
- សេចក្តីជូនដំណឹង ស្តីពីការរៀបចំបង្កើតឡើងវិញ នៃ
  ពុទ្ធិកសមាគម កម្ពុជរដ្ឋ ........................................ ១២៧

# ព្រះធម៌របស់ព្រះពុទ្ធ

(តពីកម្ពុជសុរិយា លេខ២ - ១៩៩៤)

ដោយភិក្ខុ Jagdish kasyapa

បកប្រែដោយ **ឈន អៀម**

## III. អង្គចាត់តាំងសង្ឃ

នៅក្រុងប៉េណារ៉េស, មានកូនរបស់ឈ្មួញដ៏មានទ្រព្យធនម្នាក់ឈ្មោះយសកុលបុត្ត ។ គេធុញទ្រាន់នឹងសេចក្ដីសប្បាយនៃលោកនេះ ហើយខិតខំស្វែងរកព្រះពុទ្ធ ទុកព្រះអង្គជាមគ្គុទ្ទេសក៍របស់គេ ។ ព្រះពុទ្ធបានប្រៀនប្រដៅធម៌ ដល់គេ ហើយគេក៏បានក្លាយទៅជាសាវ័ករបស់ព្រះអង្គ ។ មិត្តភ័ក្ដិរបស់យសកុលបុត្ត ៤ នាក់ទៀតគឺ វិមលៈ សុពាហុ បុណ្ណជីនៈ និងគវម្បតិ ដែលសុទ្ធតែជាកូនឈ្មួញ ដ៏មានសម្បត្តិស្ដុកស្ដម្ភនៃក្រុងប៉េណារ៉េស ក៏បានដើរតាមលំអានយសកុលបុត្ត បានចាកចេញពីលំនៅឋាន ហើយបានក្លាយជាភិក្ខុសាវ័ករបស់ព្រះពុទ្ធ ។ បន្ទាប់មកទៀតមានមិត្តភ័ក្ដិប្រមាណជាហាសិបនាក់របស់លោកទាំងនោះ ក៏បានយកតាមតំរាប់នោះដែរ ហើយបានបួសជាភិក្ខុជាមួយលោកទាំងនោះ, រួមមានទាំងអស់ហុកសិបមួយអង្គ ជាព្រះអរហន្តដែលមានព្រះពុទ្ធជាប្រមុខ ។

ព្រះសង្ឃក៏ត្រូវបានកកើតឡើង ។ ព្រះពុទ្ធទ្រង់មានពុទ្ធដីកាទៅកាន់ព្រះសង្ឃទាំងនោះថា : " ម្នាលភិក្ខុទាំងឡាយ ! ចូរអ្នកចេញដំណើរទៅ ហើយទៅ

កាន់គ្រប់ទិសទីនៃពិភពលោក ដើម្បីជាគុណប្រយោជន៍ដល់មនុស្សជាច្រើន, ដោយមេត្តាធម៌ចំពោះពិភពលោក, ដើម្បីជាប្រយោជន៍, សេចក្តីចំរើន និងសេចក្តីសុខដល់ទេវតា និងមនុស្ស ។ ម្នាលភិក្ខុទាំងឡាយ ! ចូរអ្នកប្រកាសផ្សព្វផ្សាយព្រះធម៌ដ៏ជោគជ័យ, ចូរទេសនាតាមគំរូនៃជីវិតដ៏ប្រពៃ សុក្រឹត និងបរិសុទ្ធ " ។

ក្រោយពេលបានបញ្ជូនសាវ័កទាំង ៦០ អង្គ ដំបូងទៅអស់ហើយ ព្រះអង្គទ្រង់យាងទៅកាន់ឧរុវេល ។ តាមផ្លូវ, ព្រះអង្គទ្រង់គង់ដើម្បីធ្វើសមាធិក្រោមដើមឈើមួយ នៅក្នុងកន្លែងដ៏ស្ងាត់ ហើយជ្រៅនៃព្រៃស្រោង ។ ពេលនោះ មានក្រុមយុវព្រះអង្គម្ចាស់ចំនួនសាមសិបអង្គ រត់ដេញយ៉ាងប្រកិតតាមរកស្រីពេស្យាម្នាក់ដែលបានលួចគ្រឿងអលង្ការដ៏មានតំលៃរបស់ពួកគេ ។ យុវព្រះអង្គម្ចាស់ទាំងនោះ បានសួរព្រះពុទ្ធ ក្រែងព្រះពុទ្ធបានទតឃើញស្ត្រីម្នាក់រត់តាមនេះ ។ ព្រះពុទ្ធទ្រង់មានពុទ្ធដីកាយ៉ាងថ្នមតបទៅវិញថា" ឱព្រះអង្គម្ចាស់អើយ ! តើព្រះអង្គត្រូវស្វែងរកស្ត្រីពេស្យា ដ៏ថោកទាបម្នាក់ ឬក៏ត្រូវស្វែងរកព្រះអង្គ ដោយព្រះអង្គឯង ?" ព្រះពុទ្ធចាប់ទេសនាព្រះធម៌ដល់ព្រះអង្គម្ចាស់ទាំងនោះ ។ ព្រះនេត្ររបស់យុវក្សត្រទាំងនោះ ត្រូវបានបើកហើយ បានយល់ច្បាស់ថា អស់ពេលជាច្រើនហើយដែលគេជាមនុស្សឥតបានការ, ហើយភ្លាមនោះ, ក៏បានថ្វាយខ្លួនជាសាវ័ករបស់ព្រះពុទ្ធ ហើយយាងតាមព្រះពុទ្ធ តទៅ ។

កស្សបៈ ជាប្រធាននៃនិកាយជដិល ក៏បានស្តាប់ព្រះធម៌ដែរ ហើយក៏បានក្លាយជាសាវ័ករបស់ព្រះបរមគ្រូ ។

ជាមួយនឹងសាវ័កថ្មីនេះ, ព្រះអង្គបានយាងចូលក្រុងរាជគហៈ ជារដ្ឋធានីនៃព្រះបាទពិម្ពិសារ ជាថ្មីទៀត ។ ព្រះរាជា ដោយមានមន្ត្រី និងបរិពារហែហមផង, បានយាងមកថ្វាយបង្គំព្រះពុទ្ធ ។ ទាំងអស់គ្នា បានថ្វាយខ្លួនជាឧបាសក ។ ព្រះរាជាបានថ្វាយព្រះវិហារវេឡុវ័នចំពោះព្រះពុទ្ធ ដែលបានគង់នៅទីនោះ អស់ពេលពីរខែ ។

ក្នុងរយៈពេលពីរខែនោះ ព្រះសារិបុត្ត និងព្រះមោគ្គល្លាន, ដ៏ជាគ្រូ ដ៏មាននាមល្បីល្បាញ ក៏បានកាត់មករកជួបព្រះពុទ្ធ ក្រោយពេលបានស្ដាប់ព្រះធម៌ ដែលភិក្ខុមួយអង្គ ក្នុងចំណោមភិក្ខុទាំង ៦០ អង្គ បានសំដែង ។ អ្នកទាំងពីរបានសំដែងសេចក្ដីគោរពចំពោះព្រះពុទ្ធ ហើយបានក្លាយជាសាវ័ករបស់ព្រះអង្គ ។

## IV. នៅក្រុងកបិលវត្ថុ :

ព្រះបាទសុទ្ធោទន៏ះ បានបញ្ជូននាយករដ្ឋមន្ត្រីរបស់ព្រះអង្គ ជាមួយនឹងមនុស្សមួយពាន់នាក់ ដើម្បីទៅនិមន្តព្រះពុទ្ធមកក្រុងកបិលវត្ថុ ។ មនុស្សទាំងនោះបានធ្វើដំណើរមកក្រុងរាជគហៈ, ប៉ុន្តែ ក្រោយពីបានស្ដាប់ព្រះធម៌របស់ព្រះពុទ្ធ, ទាំងអស់គ្នាបានជឿស៊ប់ក្នុងព្រះធម៌ ហើយបានសុំបួសជាភិក្ខុ ។ មនុស្សទាំងនោះបានភ្លេចនូវបេសកកម្មរបស់ខ្លួន ហើយពុំបានវិលត្រឡប់ទៅរកព្រះរាជាវិញឡើយ ។

គឺនៅក្រោយពេលព្រះរាជទូតលើកទីពីរ ដែលមានលក្ខណៈដូចគ្នានេះមកនិមន្តទៀត, នោះទើបព្រះពុទ្ធបានទទួលសេចក្ដីនិមន្តសុំយាងរបស់ព្រះបាទសុទ្ធោទនៈ ។

ព្រះពុទ្ធ មួយអន្លើដោយព្រះភិក្ខុសង្ឃ ដែលគ្រប់អង្គ សុទ្ធតែជាព្រះអរហន្ត បានទ្រង់យាងពីក្រុងរាជគហៈ ឆ្ពោះទៅកាន់ក្រុងកបិលវត្ថុ ។

មានសេចក្ដីសប្បាយរីករាយយ៉ាងខ្លាំងកើតមាននៅក្នុងទីក្រុងកបិលវត្ថុ នៅពេលដែលព្រះអង្គជាទីស្រឡាញ់ ក្រោយពេលអវត្តមានអស់ពេលជាច្រើនឆ្នាំ បានត្រឡប់មកកាន់ទីក្រុងកបិលវត្ថុវិញក្នុងឋានៈជាព្រះពុទ្ធ ស្លៀកដណ្ដប់ដោយសំពត់ពណ៌លឿងនៃចរកជន ហើយមានបាត្រសុំអាហារនៅក្នុងព្រះហស្ថ ។ ហេតុម៉្យ៉ាងព្រះបាទសុទ្ធោទនៈ ក្នុងឋានៈជាបិតា បានរំភើបញាប់ញ័រដោយសេចក្ដីសប្បាយនិងសេចក្ដីក្រៀមក្រំយ៉ាងក្រៃលែង ក្នុងពេលព្រះអង្គយាងចេញមកជួបព្រះរាជ-

បុត្ត ដែលឥឡូវនេះជាព្រះពុទ្ធ ។ ព្រះអង្គចង់ស្ទុះទៅអោបក្រសោបព្រះពុទ្ធ ហើយបន្លឺវាចាហៅយ៉ាងទន់ភ្លន់ថា " បុត្តសំឡាញ់ !" ប៉ុន្តែសន្តភាពដ៏ត្រចះត្រចង់ (l'auguste sainteté) របស់ព្រះពុទ្ធ បានញ៉ាំងអោយព្រះរាជាសំដែងនូវសេចក្តីគោរព ហើយព្រះអង្គ បានអោនក្រាបទៀបព្រះបាទាព្រះពុទ្ធ ដោយមានព្រះនេត្រពោរពេញដោយជលនេត្រ ។ ទាំងអស់គ្នាត្រងត្រាប់ស្តាប់ព្រះពុទ្ធ ហើយបានក្លាយជាសាវ័កព្រះពុទ្ធ ។ ព្រះបរមគ្រូបាននាំយកអានន្ទ ជាជីដូនមួយរបស់ព្រះអង្គ និងរាហុលជាបុត្រព្រះអង្គ ទៅក្នុងចំណោមព្រះភិក្ខុសង្ឃ ហើយក៏បានបំបួសអ្នកទាំងពីរ ។

## ទិវាចុងក្រោយរបស់ព្រះពុទ្ធ

នៅពេលនោះ ព្រះពុទ្ធបានចំណាយពេលនៃជីវិតរបស់ព្រះអង្គចំនួន ៤៥ ឆ្នាំ យាងពីមួយកន្លែងទៅមួយកន្លែង ដើម្បីផ្សព្វផ្សាយព្រះធម៌ដល់មនុស្សទាំងឡាយណា ដែលចង់ស្តាប់ព្រះធម៌នោះ ។ នៅពេលព្រះជន្មាយុគំរប់ ៨០ ឆ្នាំ, ព្រះពុទ្ធបានយល់ថា ពេលបរិនិព្វានរបស់ព្រះអង្គបានមកដល់ហើយ ។

នៅកុសិនារា, ព្រះអង្គបានផ្ទំនៅលើដីចន្លោះដើមសាលព្រឹក្សពីរដើម ព័ទ្ធជុំវិញដោយសាវ័ករបស់ព្រះអង្គ ។ ពេលនោះ ព្រះអង្គបានចូលកាន់ឈាន ហើយឆ្លងកាត់កិរិតជាបន្តបន្ទាប់ រួចបានដល់បរិនិព្វាន ។

## ជំពូកទីបួន
## អក្សរសាស្ត្រពុទ្ធសាសនា

ក្រោយព្រះពុទ្ធបរិនិព្វានទៅ សាវ័ករបស់ព្រះអង្គបានកោះប្រជុំគ្នា នៅក្រុងរាជគឫះ ដើម្បីប្រមូលផ្តុំចងក្រងសេចក្តីប្រៀនប្រដៅរបស់ព្រះពុទ្ធ ដោយខ្លាចក្រែងពាក្យប្រៀនប្រដៅទាំងនោះត្រូវភ្លេចភ្លាំង ឬបកស្រាយខុសក្នុងពេលខាងមុខ។

សភាភិក្ខុ ដែលទាំងអស់សុទ្ធតែជាព្រះអរហន្ត បានរួមប្រជុំយ៉ាងកុះករ ដើម្បីរៀបចំការងារដ៏ឧត្តុង្គឧត្តមនោះ ។ អានន្ទ កស្សបៈ ភិក្ខុជាច្រើនអង្គទៀត ដែលបានបំរើព្រះពុទ្ធដោយផ្ទាល់ និងបានត្រងត្រាប់ស្តាប់ពាក្យប្រៀនប្រដៅព្រះអង្គដោយផ្ទាល់ ក៏មានវត្តមាននៅឱកាសនោះដែរ ។

ពាក្យប្រៀនប្រដៅនោះ ត្រូវបានចារនៅលើស្លឹករឹត ហើយប្រមូលផ្ដុំដាក់ក្នុងកញ្ជើមួយ ។ នៅពេលចប់មហាសង្គាយនា, សំណេរទាំងអស់ត្រូវបានដាក់ក្នុងកញ្ជើ ៣ ។ កញ្ជើទី១ មានព្រះ *សូត្រ* ឬធម៌ទេសនារបស់ព្រះពុទ្ធ និងរបស់សាវ័កសំខាន់ៗរបស់ព្រះអង្គ ដែលទ្រង់បានសំដែងក្នុងកន្លែងផ្សេងៗ ឬក្នុងឱកាសជាច្រើនចំពោះមនុស្សផ្សេងៗគ្នា ។ កញ្ជើទី២ មានព្រះ*វិន័យ* ឬច្បាប់ និងបទបញ្ញត្តិនៃវិន័យដែលព្រះពុទ្ធបានបញ្ញត្ត សំរាប់ការប្រព្រឹត្តរបស់ភិក្ខុ ហើយនិងវត្តអារាម ។ កញ្ជើទី៣ មានព្រះ *អភិធម្ម* ឬឧទ្ទេសកថាបរមត្ថវិជ្ជានៃព្រះធម៌ (Exposés métaphysiquses) ។ ទាំងបីនេះមានឈ្មោះថា *ត្រ័យបិដក* ឬល្អីបី ។ ព្រះត្រ័យបិដកមានស្នាដៃ ដូចខាងក្រោមនេះ ៖

## ក. សុត្តបិដក

១. ទីឃនិកាយ

២. មជ្ឈិមនិកាយ

៣. សំយុត្តនិកាយ

៤. អង្គុត្តរនិកាយ

៥. ខុទ្ទកនិកាយ ។

ខុទ្ទកនិកាយ ត្រូវបានចែកចេញជា ១៥ គម្ពីរ ៖

១. ខុទ្ទកបាឋ

២. ធម្មបទ

៣. ឧទានៈ

៤. ឥតិវុត្តកៈ

៥. សុត្តនិបាត

៦. វិមានវត្ថុ

៧. បេតវត្ថុ

៨. ថេរគាថា

៩. ថេរីគាថា

១០. ជាតក

១១. និទ្ទេស

១២. បដិសម្ភិទា

១៣. អាបទាន

១៤. ពុទ្ធវំស

១៥. ចរិយាបិដក

## ខ. វិន័យបិដក

១. បារាជិកបាលី

២. បាចិត្តិយបាលី វិភង្គៈ

៣. មហាវគ្គបាលី

៤. ចុល្លវគ្គបាលី ខន្ធកៈ

៥. បរិវារបាលី

## គ - អភិធម្មបិដក

១. ធម្មសង្គណី

៣. កថាវត្ថុ

៤. បុគ្គលបញ្ញត្តិ

៥. ធាតុកថា

៦. យមកៈ

៧. បដ្ឋានា

គម្ពីរទាំងនេះ មានលក្ខណៈច្បាស់លាស់ និងជិតបំផុតទៅនឹងចំណេះដឹងនៃព្រះធម៌ ដែលព្រះបរមគ្រូបានប្រៀនប្រដៅ ។ បន្តក្រោយមក មានអដ្ឋកថា ឬអត្ថាធិប្បាយច្រើនបែប និងមានគម្ពីរពិសេសៗផ្សេងទៀត ត្រូវបានសរសេរឡើងដែលបានបង្កើនយ៉ាងសំបើមនូវទំហំនៃអក្សរសាស្ត្រនេះ ។ ក្នុងចំណោមគម្ពីរបន្ថែមចុងក្រោយ គឺមានគម្ពីរវិសុទ្ធិមគ្គរបស់ពុទ្ធឃោសៈ, ហើយនិងគម្ពីរមិលិន្ទបញ្ហា ដែលគេត្រូវយកចិត្តទុកដាក់ពិចារណា ហើយស័ក្តិសមនឹងជឿបាន ។

## ចំពូកទីប្រាំ

## ភាពប្លែកពីគេនៃពុទ្ធលទ្ធិ

( La singularité du Bouddhisme )

ប៉ុន្តែថា, ពុទ្ធសាសនិក មិនត្រូវប្រកាន់ទុកគម្ពីរព្រះត្រ័យបិដក អោយមានឋានៈដដែលមួយ ដូចគ្នានឹងគម្ពីរប៊ីប្ល៍ក្នុងចំណោមគ្រីស្តសាសនិក ឬដូចគ្នានឹងគម្ពីរកូរ៉ាន ក្នុងចំណោមពួកមហាម៉េត ឬក៏ដូចគ្នានឹងគម្ពីរវេទរបស់ពួកហិណ្ឌូ នោះឡើយ ។

ពុទ្ធសាសនិកជនមួយរូប ពុំមែនជាទាសកររបស់គម្ពីរព្រះត្រ័យបិដកទេ ។ គេពុំបានទទួលជឿដោយល្ងិតល្ងង់, ទុកគម្ពីរព្រះត្រ័យបិដកនោះជាសច្ចៈចុងក្រោយ

(La vérité ultime) ចុះមកពីអាទិទេព ឬ ជាកម្មវត្ថុនៃជំនឿ (Un objet de foi ) ដោយឥតប្រកែកបាននោះទេ ។

ព្រះពុទ្ធពុំដែលបានសុំអោយអ្នកណាមួយជឿ ដោយទាំងមិនយល់អ្វីនោះឡើយ ។

## កឡាមសូត្រ

ពួកអ្នកស្រុកកឡាមៈ នៅពេលមួយនោះ បាននាំគ្នាមកជួបព្រះពុទ្ធ ហើយក្រាបទូលសួរព្រះអង្គថា : ឱព្រះអង្គអើយ, ពួកព្រាហ្មណ៍ និងពួកគ្រូនៃនិកាយសាសនាផ្សេងៗ បានមកទាក់ទងយើងខ្ញុំព្រះអង្គ ហើយបានពន្យល់ផ្សព្វផ្សាយទ្រឹស្តីផ្សេងៗរបស់គេ ដោយម្នាក់ៗនិយាយបញ្ជាក់ថា អ្វីៗដែលគេបានប្រៀនប្រដៅ គឺជាសច្ចៈតែមួយគត់ ( La seule vérité ) ។

" ឱព្រះអង្គអើយ, យើងខ្ញុំព្រះអង្គវិលវល់អស់ហើយ មិនដឹងថាអ្វីត្រូវជឿ ឬត្រូវបដិសេធនោះទេ " ។

ឆ្លើយតបទៅនឹងសំណួរនេះ ព្រះពុទ្ធទ្រង់មិនបានទូន្មានប្រាប់អ្នកទាំងនោះថា : " ចូរអ្នកជឿតថាគតទៅ តថាគតគឺជារាជបុត្រនៃព្រះអាទិទេព ហើយតថាគត នឹងនាំអ្នកទាំងឡាយទៅកាន់ឋានសួគ៌ " នោះទេ ។ ព្រះអង្គ ក៏មិនបានផ្តន្ទាទោសពាក្យប្រៀនប្រដៅរបស់អ្នកឯទៀត ដោយទុកថាជាប្រមាថពិសិដ្ឋវត្ថុ ឬជាអញ្ញទិដ្ឋិនោះដែរ ( Comme sacrilège ou hérétique ) ។

ដំបូន្មាន ដែលព្រះបរមគ្រូផ្តល់អោយអ្នកទាំងនោះ គឺប្រកបទៅដោយមនុស្សធម៌ និងគតិបណ្ឌិតបំផុត, ព្រះអង្គមានបន្ទូលថា :

ចូរអ្នកកុំជឿអ្វីមួយ ដោយគ្រាន់តែអ្នកបានឮគេនិយាយតៗគ្នា ។ ចូរអ្នកកុំជឿអ្វីមួយ ពីព្រោះវាជាប្រពៃណីចាស់ទុំ និងកន្លងទៅរាប់ជំនាន់ហើយ ។ ចូរអ្នកកុំជឿពាក្យបរឲ្យា (Les on dits) ឬរឿងអ្វីផ្សេង ពីព្រោះមានមនុស្សនិយាយពីរឿង

នោះច្រើន ។ ចូរអ្នកកុំជឿអ្វីមួយ ដោយគ្រាន់តែបង្ហាញភស្តុតាងសរសេររបស់អ្នកប្រាជ្ញពីបុរាណណាមួយចំពោះរឿងនោះ ។ ចូរអ្នកកុំជឿអ្វីមួយ ដោយគ្រាន់តែមានសច្ចធារណ៍ណាមួយ ( Quelque présomption = ពោលគឺសេចក្តីស្មាន ដែលគេទុកជាពិត លើកលែងតែមានភស្តុតាងផ្ទុយ ) គាំទ្រដល់ទឡ្ហីករណ៍នោះ ឬពីព្រោះមានទម្លាប់ជាប់តមកជាយូរឆ្នាំ ហើយនាំគ្នាជឿថាជាសេចក្តីពិត ។ ចូរអ្នកកុំជឿអ្វីមួយ ដោយផ្អែកលើអាជ្ញា ឬអំណាចរបស់គ្រូបាអ្នក ឬរបស់អ្នកបួសទាំងឡាយឡើយ ។ " *អ្វីទាំងអស់, ដែលស្របតាមការពិសោធន៍ផ្ទាល់របស់អ្នក ហើយក្រោយការពិនិត្យល្អិតល្អន់ ឃើញថាសមស្របជាមួយវិចារណញ្ញាណរបស់អ្នក, នាំអោយបានសុភមង្គលដល់ខ្លួនអ្នកផ្ទាល់ និងមានសុភមង្គលដល់សព្វសត្វមានជីវិតផ្សេងទៀត, នោះហើយចូរអ្នកទទួលយកចុះ ទុកដូចជាសច្ចៈ ហើយចូររស់នៅ តាមដំណើរហេតុនោះចុះ* " ។

ដូច្នេះ គេអាចសិក្សាព្រះធម៌របស់ព្រះពុទ្ធ ពិចារណាព្រះធម៌នោះ ដោយស្ងប់ស្ងៀម និងប្រកបដោយគតិបណ្ឌិត ហើយទទួលជឿតាមព្រះធម៌នោះ ប្រសិនបើព្រះធម៌នោះសមស្របទៅនឹងសេចក្តីត្រិះរិះល្អិតល្អន់របស់អ្នក, ឬបដិសេធព្រះធម៌នោះចោល ប្រសិនបើព្រះធម៌នោះយល់មិនបាន ។ ព្រះពុទ្ធសាសនា មិនបង្ខំមនុស្សណាម្នាក់ អោយជឿដោយងងឹតងងល់នោះទេ, ពីព្រោះជំនឿងងឹតងងល់ គឺជាឧបសគ្គចំពោះដំណើរទៅមុខនៅក្នុងជីវិត ជាដរាប ។ *ស្មារតីនៃពុទ្ធលទ្ធិ គឺមានវិចារណកម្មយ៉ាងបរិសុទ្ធ* ។

## ដើមកំណើតនៃទស្សនាទានអំពីអាទិទេព

ពេលដែលអរិយធម៌កំពុងកកើតឡើង ហើយវិទ្យាសាស្ត្រ មិនទាន់កើតមាន, មនុស្សជំនាន់ដើមមានការភ័យខ្លាច និង អារម្មណ៍ស្ញប់ស្ញែងចំពោះបាតុភូត

ធម្មជាតិដ៏អស្ចារ្យនានា, ដោយគេជឿលើខ្មោច បីសាច ឬអាទិទេព ហើយក៏បង្កើតឡើងជាសាសនាផ្សេងៗ ។ យោលទៅតាមកំរិតយល់ដឹងរៀងៗខ្លួន, ប្រជាជាតិផ្សេងៗ បានបង្កើតអាទិទេពផ្សេងៗគ្នា និងមានជំនឿផ្សេងៗគ្នា ។

ដើមឡើយ, មនុស្សគោរពរាប់អានអាទិទេពដ៏ច្រើន, អាទិទេពរក្សាព្រៃឈើ ដងអូរ ផ្លេកបន្ទោរ ព្យុះ ខ្យល់ ព្រះអាទិត្យ និងបាតុភូតលើដីផ្សេងៗទៀត ។ អាទិទេពទាំងនោះ និងអាទិទេពរាប់មិនអស់ផ្សេងទៀត ដែលតំណាងសកម្មភាពធម្មជាតិនីមួយៗ បាននាំអោយមនុស្សយល់តមកទៀតថា ចក្រវាឡពុំមែនជាអនេក-គុណ (Multiplicité) ទេ, ប៉ុន្តែជាសកលភាពមួយ (Un Tout) ហើយនេះ គឺជាកំណើតនៃឯកាទិទេពនៃយុគសម័យថ្មីនេះ ។ សូម្បីតែអាទិទេពតែមួយក៏ដោយ ក៏គង់មានការប្រែប្រួលយ៉ាងច្រើនទៅតាមប្រជាជាតិ ឬ ប្រជាជនផ្សេងៗគ្នាដែរ ។ អាទិទេពហិណ្ឌូ ផ្សេងស្រឡះពីអាទិទេពរបស់ពួកម៉ាហូម៉េត, អាទិទេពរបស់ពួកម៉ា-ហូម៉េតខ្លួនឯងនោះទៀត ក៏ផ្សេងគ្នាស្រឡះពីអាទិទេពរបស់គ្រីស្តសាសនិកដែរ ។ ដូច្នេះ យើងពិនិត្យឃើញថា សាសនាជាច្រើនដែលមានសព្វថ្ងៃ មានលក្ខណៈផ្សេងៗពីគ្នា ពីមួយទៅមួយ ។

## ភាពខ្វះខាតរបស់សាសនាដែលមានអាទិទេព

សាសនាដែលមានអាទិទេពទាំងអស់នោះ មានគម្ពីររបស់គេផ្ទាល់ខ្លួនដែលគេបានអះអាងថាចេញមកពីព្រះឱស្ឋផ្ទាល់របស់អាទិទេពគេ តាមប្រកាសនា (la révélation = ការបង្ហាញ ឬប្រាប់អោយដឹងរឿងអាថ៌កំបាំង ) ។ សាសនាទាំងឡាយនោះអះអាងថា សាសនារបស់គេប្រកាសផ្សព្វផ្សាយសន្តិភាពសកល, ភាតរភាពសកល និងគោលឧត្តមគតិខ្ពង់ខ្ពស់ផ្សេងៗទៀត ។

ទោះបីឧត្តមគតិរបស់សាសនាទាំងឡាយខ្ពង់ខ្ពស់ ឧត្តុង្គឧត្តម ដូចម្តេចក្តី,

ប្រវត្តិសាស្ត្រពិភពលោកបានបង្ហាញភស្តុតាងថា សាសនាទាំងឡាយ រហូតមកដល់សព្វថ្ងៃនេះ បានជួយផ្សព្វផ្សាយតែជំនឿផ្តេសផ្តាស (Folles superstitions) សាសនាទាំងឡាយបានដើរផ្ទុយទៅនឹងវិទ្យាសាស្ត្រ ផ្ទុយទៅនឹងការឈានទៅមុខ នៃចំណេះដឹងដ៏ពិតប្រាកដ, សាសនាទាំងឡាយបាននាំទៅរកការបែងចែកគ្នាជាបក្សពួក ទៅរកជម្លោះ ទៅរកមនោសញ្ចេតនាអមិត្ត ទៅរកការកាប់សម្លាប់គ្នា និង ទៅរកសង្គ្រាម ។

គ្មានសង្គ្រាមសាសនាណាមួយ ទោះបីជាសង្គ្រាមសាសនារបស់ប្រទេសម៉ិចស៊ិកបុរាណកាលក្តី, របស់បូជនីយេសទ៍នៃមជ្ឈិមសម័យក្តី ឬ របស់ជីហាដ (Jihad) នៃនវសម័យក្តី អាចកើតឡើងបានដោយគ្មានការប្រកាន់លទ្ធិសាសនាងប់ងល់ហួសពេក (Un fanatisme) ដើម្បីធ្វើសង្គ្រាម និងដោយគ្មានក្រុមបព្វជិតអុជអាលសង្គ្រាមនោះទេ ។ លោកសូក្រាត ត្រូវបានគេបំពុល មិនមែនពីព្រោះលោកបាននិយាយសច្ចៈទេ, ប៉ុន្តែ ពីព្រោះសច្ចៈដែលលោកប្រកាសនោះ បានប៉ះទង្គិចជាមួយជំនឿរបស់គេ ។ ភាតរភាព ត្រូវបានប្រកាសផ្សព្វផ្សាយដោយសាសនាទាំងអស់ ប៉ុន្តែ រហូតមកដល់ពេលនេះ សាសនាទាំងឡាយនោះ បានសំរេចតែចិញ្ចឹមអរិភាពដ៏ជូរចត់ប៉ុណ្ណោះ ។

## មូលហេតុនៃការបរាជ័យ

ហេតុអ្វីបានជាសាសនាទាំងឡាយបានប្រែក្លាយទៅជាអាក្រក់ ផ្ទុយទៅនឹងឧត្តមគតិដ៏ខ្ពង់ខ្ពស់របស់ខ្លួន ? វាប្រាកដជាមានគុណវិបត្តិណាមួយ នៅក្នុងទស្សនាទាននៃសាសនា ដែលមនុស្សទាំងឡាយចង់ប្រតិបត្តិតាម, នោះគឺគ្មានអ្វីក្រៅពីអធិបញ្ញា (Injonction) ពោលគឺ ការបង្គាប់បញ្ជាដោយដាច់ខាតនៃជំនឿងងឹតងងល់ ដែលបង្កើតអោយមានបដិបក្ខភាពរវាងសាសនាមួយ និង សាសនាមួយ

ទៀត, ហើយជ្រមុជមនុស្សឆ្ពោះទៅរកអ្វីដែលគេបានជឿជាក់ស្រេចហើយនោះ ។

ព្រះពុទ្ធទ្រង់បានឃើញយល់នូវគ្រោះថ្នាក់នោះ នៅពេលព្រះអង្គមានពុទ្ធ-ដីកា ថា ៖ " ម្នាលភិក្ខុទាំងឡាយ, តថាគតប្រៀនប្រដៅព្រះធម៌របស់តថាគតដល់អ្នក ដើម្បីអោយអ្នកយកព្រះធម៌ទុកជាក្បូនសំរាប់ឆ្លងកាត់ទឹក គឺមិនមែនទុកជាទ្រព្យសម្បត្តិ ដែលអ្នកត្រូវថែរក្សាទុកនោះទេ " ។

កម្មវត្ថុដ៏ត្រឹមត្រូវរបស់សាសនា គឺប្រើសាសនាទុកជាក្បូន ។ ដោយមានជំនួយពីក្បូននេះ អ្នកអាចឆ្លងកាត់ចរន្តទឹកបាន ។ សាសនាកើតឡើង ក៏គឺសំរាប់គោលដៅអនុវត្តជាក់ស្តែងដូចនោះដែរ ។ បើគេមានក្បូនមួយ, ប៉ុន្តែ បើគេមិនប្រើក្បូនសំរាប់ឆ្លងកាត់ចរន្តទឹកទេ, ក្បូននោះក្លាយទៅជាវត្ថុឥតប្រយោជន៍ ។

ដូចគ្នានេះដែរ សាសនាទាក់ទងនឹង*ជីវិតជាក់ស្តែង ។ សាសនាត្រូវបង្ហាញផ្លូវ និងគ្រប់គ្រងចរិយារបស់យើងនៅក្នុងលោកនេះ ។* សាសនាប្រាប់យើង នូវអ្វីដែលយើងត្រូវធ្វើ និងត្រូវដឹង ។ បើយើងមិនប្រព្រឹត្ត ឬមិនរិះគិតទៅតាមអ្វីដែលសាសនាបានប្រាប់យើងទេ, សាសនាក៏មិនបានបំរើអ្វីដល់យើងដែរ ។ គេជាពុទ្ធសាសនិក, មិនមែនពីព្រោះតែគេមានសាសនានេះទេ, ប៉ុន្តែ ពីព្រោះគេរស់នៅទៅតាមអ្វីដែលព្រះពុទ្ធបានប្រៀនប្រដៅ ។

*គេថា សាសនាជាកម្មសិទ្ធិរបស់អ្នកណាមួយ កាលណាសាសនានោះក្លាយទៅជាវត្ថុមួយនៃជំនឿជាជំនួសអំពើនៅក្នុងជីវិតរបស់គេ, កាលណាសារ-សំខាន់នៃជីវិតត្រូវឧទ្ទិសចំពោះតែការប្រតិបត្តិ ឬចំពោះតែពិធីបុណ្យគ្មានជីវិត។* សាសនាដែលបានប្រឌិតឡើងបែបនេះ ជាសាសនាខ្វះតំលៃ ហើយក្លាយជាឧបសគ្គមួយ ។ ភាពមិនជោគជ័យនៃសាសនាទាំងឡាយ កើតចេញមកតែពីធាតុដែលមនុស្សចាត់ទុកសាសនាទាំងនោះ ជាវត្ថុមួយដែលត្រូវតែជឿប៉ុណ្ណោះឯង ។

**សាសនាដែលផ្អែកតែលើជំនឿផ្តាច់មុខ** (la foi) **គឺជាមូលហេតុនៃបាបធម៌គ្រប់**

*យ៉ាង សាសនាដែលដឹកនាំជីវិតរបស់អ្នកឆ្ពោះទៅ រកភាពបរិសុទ្ធ គឺជាសាសនាដ៏ពិតប្រាកដ ។*

ពុទ្ធសាសនាមិនផ្អែកលើមូលដ្ឋាន " ជំនឿផ្តាច់មុខ " ទេ ។ គេពុំមែនជាពុទ្ធសាសនិកទេ បើគេជឿព្រះពុទ្ធទុកដូចជាអាទិទេពមួយអង្គ ឬជាអ្នកលោះបាបពីព្រោះ ប្រការនេះអាចធ្លាក់ទៅក្នុងគំនិតនៃសាសនា - កម្មសិទ្ធិ ។

*ធ្វើហើយមិនមែនជឿទេ (Agir et non pas croire)* គឺជាស្មារតី ដ៏ជាក់ស្តែង ដែលនៅក្នុងស្មារតីនេះ ព្រះពុទ្ធបានប្រៀនប្រដៅព្រះធម៌របស់ព្រះអង្គ ។

## តើជំហររបស់ព្រះពុទ្ធយ៉ាងណា នៅក្នុងពុទ្ធសាសនា ?

ព្រះពុទ្ធព្រះអង្គឯងទ្រង់បានប្រកាសថា : " ម្នាលភិក្ខុទាំងឡាយ ! ចូរអ្នកដើរតាមតថាគត ទុកដូចជាមគ្គុទ្ទេសក៏របស់អ្នកក្នុងការប្រៀនប្រដៅ " ។

បើយើងមិនដើរតាមផ្លូវ ដែលមគ្គុទ្ទេសក៏ចង្អុលប្រាប់យើងទេ យើងប្រាកដជាវង្វេងផ្លូវ, ប៉ុន្តែ នេះមិនមែនជាកំហុសរបស់មគ្គុទ្ទេសក៏ទេ ។ មគ្គុទ្ទេសក៏គ្រាន់តែជាអ្នកបង្ហាញផ្លូវ, បើអ្នកដំណើរមិនដើរតាមមគ្គុទ្ទេសក៏ទេ, នោះជំនួយរបស់មគ្គុទ្ទេសក ក៏ពុំមានប្រយោជន៏អ្វីដែរ ។ ដូចគ្នានេះដែរ ព្រះពុទ្ធបរមគ្រូបានបង្ហាញផ្លូវឆ្ពោះទៅរកការរំដោះផុតពីទុក្ខ ឬទៅរកព្រះនិព្វាន ។ វាស្រេចតែយើងទេនៅពេលនោះ តើត្រូវដើរតាមផ្លូវដូចចង្អុលប្រាប់ ឬក៏មិនដើរតាម ។

## ការបូជាភ្ញីផ្កា

បើគេផ្តល់កិត្តិយសដល់មគ្គុទ្ទេសក៏របស់គេ, បើគេថ្វាយភ្ញីផ្កាដល់មគ្គុ-ទ្ទេសក៏របស់គេ, បើគេក្រាបយ៉ាងទាបនៅចំពោះមុខមគ្គុទ្ទេសក៏របស់គេ, ប៉ុន្តែ បើគេពុំគោរពវិន័យទៅតាមសេចក្តីណែនាំរបស់មគ្គុទ្ទេសក៏របស់គេទេ, តើគេសំរេច

បានគោលដៅរបស់គេទេ ? ពិតជាពុំសំរេចបានទេ ។ បើយើងមិនប្រកាន់ជីវិតរស់នៅទៅតាមអ្វីដែលព្រះពុទ្ធបានប្រៀនប្រដៅទេ នោះការថ្វាយភ្ញីផ្កា ឬការសូត្រធម៌ ក៏ពុំអាចជួយយើងបានដែរ ។

ចំពោះរឿងនេះ ខ្ញុំពុំចង់និយាយថា ការធ្វើយ៉ាងនោះ ពុំមានប្រយោជន៍ ឬពុំមែនជាពុទ្ធសាសនិក ដោយសារការថ្វាយភ្ញីផ្កានៅចំពោះព្រះភក្ត្រពុទ្ធបដិមានោះទេ ។ គឺជាករណីកិច្ចរបស់យើងទៅវិញទេ ដែលត្រូវធ្វើដូច្នេះចំពោះបុគ្គល ដែលជាអ្នកប្រៀនប្រដៅ ដ៏ពិតប្រាកដរបស់យើង ។ ប៉ុន្តែ ដើរតាមព្រះបរមគ្រូរបស់យើងជារឿងមួយ ហើយផ្តល់អភិវន្ទនកិច្ចចំពោះព្រះអង្គ គឺជារឿងមួយផ្សេងពីគ្នាស្រឡះ ។ ជាពុទ្ធសាសនិកមួយរូប មិនមែនថ្វាយភ្ញីផ្កាក្នុងព្រះវិហារ ក្នុងបំណងដូចកូនក្មេងចង់បានពរពីព្រះពុទ្ធ ដែលនាំគេទៅកាន់ឋានសួគ៌នោះទេ, ប៉ុន្តែ គេធ្វើយ៉ាងនេះ ដោយសេចក្តីកតញ្ញូ គ្មានព្រំដែនចំពោះព្រះបរមគ្រូរបស់គេ ។

## ប្រព័ន្ធវណ្ណៈ

ព្រះពុទ្ធ គឺជាតួអង្គទី១ ប្រឆាំងនឹងប្រព័ន្ធដ៏ថោកទាបនៃវណ្ណៈ ដែលបានបង្កើតឱ្យមាននូវមនោសញ្ចេតនាអ្នកទាប អ្នកខ្ពស់ ពីមនុស្សម្នាក់ ទៅមនុស្សម្នាក់ ។ ព្រះពុទ្ធបានប្រកាសថា : " មនុស្សម្នាក់ មិនអាចទៅជាមនុស្សថោកទាប ឬជាព្រាហ្មណ៍ពីកំណើតមកទេ, គឺដោយសារអំពើរបស់គេទេ ដែលគេក្លាយជាមនុស្សថោកទាប ឬជាព្រាហ្មណ៍ " ។

ព្រះអង្គបានអនុញ្ញាតអោយបួសជាភិក្ខុនៅក្នុងសាសនារបស់ព្រះអង្គ ដល់មនុស្សមកពីគ្រប់វណ្ណៈ និងមកពីគ្រប់ជំនឿ : ជាងកាត់សក់, ជាងដែក ។ អ្នកទាំងឡាយណា ដែលបានសំរេចភាពជាអរហន្ត ត្រូវបានទទួលសេចក្តីគោរព និងផ្តល់កិត្តិយសខ្ពស់នៅក្នុងសង្ឃ ។

ព្រះពុទ្ធសាសនា បានទេសនាផ្សព្វផ្សាយយ៉ាងទូលាយ នូវសេចក្ដីសន្ដោស (La tolérance) និងសេរីភាពខាងគំនិតយ៉ាងពេញលេញ ។ ព្រះពុទ្ធសាសនា ត្រូវបានផ្សព្វផ្សាយទៅក្នុងពិភពលោក មិនមែនដោយផ្លែដាវ និងកាំភ្លើងទេ ទាំងមិនមែនដោយសារធ្វើទារុណកម្ម ឬការកៀបសង្កត់ទេ, ប៉ុន្តែ គឺដោយសារគុណធម៌ និងភាពឧត្ដុង្គឧត្ដម នៃពាក្យប្រៀនប្រដៅរបស់ខ្លួនផ្ទាល់ ។

## ចំពូកទីប្រាំមួយ

# ព្រះធម៌

## សច្ចះបីយ៉ាងដ៏សំខាន់

សច្ចះបីយ៉ាងដ៏សំខាន់ ដែលផ្អែកលើសច្ចះទាំងបីនេះ ព្រះពុទ្ធបានទេសនាផ្សព្វផ្សាយព្រះធម៌នោះគឺ :

ក. អនិច្ចះ ឬ អ្វីៗមិនឋិតថេរ;

ខ. អនត្តះ ឬអ្វីៗទាំងអស់គ្មានសារជាតិ ឬអាត្ម័នជាប់លាប់ទេ;

គ. ទុក្ខះ ឬ អ្វីៗទាំងអស់ គឺជាទុក្ខ ។

*ក. អ្វីៗទាំងអស់មិនឋិតថេរ*

ចក្រវាឡនេះ ឋិតក្នុងដំណើរប្រែប្រួលជាដរាប (បរិណាមធម៌) ។ គ្មានអ្វីឋិតនៅ*ដដែល* សំរាប់រយះពេលពីរបន្តបន្ទាប់គ្នាទេ ។ សច្ចះ ពុំមែនជាទឹកថ្លុកនឹងថ្កល់ទេ, ប៉ុន្តែ ជាចរន្តទឹកហូរយ៉ាងលឿន, ជាជលវេគ (ខ្សែទឹកហូរខ្លាំង) ។ គ្មានអត្ថិ-ភាពទេ គឺ មានតែការប្រែប្រួលទៅមុខ (Il n 'y a pas une existence, il n'y a qu'un devenir) ។

ការកកើតឡើង (ឧប្បាទ) និងការបែកធ្លាយទៅវិញ (និរោធ), កត្តាទាំងពីរនេះមិនឈប់សោះឡើយ ។ រលកទឹកមួយងើបឡើង, ហើយនៅពេលលិចទៅវិញ រលកទឹកនោះបណ្ដាលអោយមានរលកទឹកមួយទៀត ហើយចេះតែបន្តដូច្នេះគ្មានទីបំផុត ។ ទឹករលកមួយងើបឡើង ពីព្រោះទឹករលកមួយលិចចុះ ហើយរលកទឹកមួយលិចចុះ ពីព្រោះតែរលកមួយទៀតងើបឡើង ។ ដោយប្រការនេះ ចលនានៃចរន្តទឹកចេះតែបន្តជានិរន្តរ៍ ។

នៅពេលជាមួយគ្នាដែលវត្ថុមួយត្រូវបានកកើតឡើង, វត្ថុនោះធ្វើដំណើរយ៉ាងទៀងទាត់ឆ្ពោះទៅរកការបែកធ្លាយទៅវិញ ។ គេហដ្ឋានដ៏ល្អមួយ ដែលទើបតែបានសាងសង់ថ្មីៗ កាន់តែចាស់ទៅពីមួយថ្ងៃ ទៅមួយថ្ងៃ រហូតដល់គេហដ្ឋាននោះត្រូវកំទេចចោល ហើយសូម្បីតែស្លាកស្លាមនៃផ្ទះនោះ ក៏ត្រូវបាត់ដែរ ។ ចលនាដើរនៃបេះដូងរបស់យើងមួយភឹបៗ ក៏បង្អិតយើងទៅជិតសេចក្ដីស្លាប់ ជាដរាបដែរ ។

អនិច្ចតាធម៌ មិនមែនជាទស្សីករណ៍ទស្សនវិជ្ជា ដែលរៀបចំតាក់តែងឡើងទេ, ប៉ុន្តែ ជាហេតុការណ៍មួយ ជាសច្ចធម៌មួយ ដែលយើងដឹងដោយវិញ្ញាណ, ហើយយើងអាចសង្កេតឃើញយ៉ាងជាក់ស្ដែងបំផុត នៅក្នុងការរស់នៅជារៀងរាល់ថ្ងៃរបស់យើង ។

គឺពីព្រោះតែការជាប់ជំពាក់ចិត្តដ៏ល្ងង់ខ្លៅរបស់យើងហើយ ទើបយើងខ្វះខាត មិនយល់សច្ចធម៌នេះបាន ហើយយើងចាត់ទុកថាពិភពលោកនេះឋិតថេរ នៅដដែលជានិច្ច ។ តើមានន័យដូចម្ដេច ហេតុការណ៍ដែលនិយាយថា " វត្ថុមួយនេះ *ឋិតថេរ* " ? តើនេះមិនមែនគ្រាន់តែនិយាយថា វត្ថុនោះអាចបំរើចំណង់ដោយឡែករបស់យើងក្នុងរយៈពេលណាមួយប៉ុណ្ណោះទេឬ ? តើវាមានអ្វីផ្សេងពីនេះទៀត ?

មិត្តរបស់ខ្ញុំម្នាក់និយាយប្រាប់ខ្ញុំថា គេបានប្រើទោចក្រយានមួយ, ម៉ាកបែបណាមួយអស់រយៈពេលជាងសាមសិបឆ្នាំ ។ ក្នុងរយៈពេល ៣០ ឆ្នាំនេះ គេបាន

ផ្លាស់ប្តូរ និងដាក់ជំនួសជាញឹកញយនូវគ្រឿងបន្លាស់សំរាប់ជួសជុល ផែទាំ និងលាប លនជាថ្មី ហើយគេនិយាយថា គឺជាទោចក្រយានតែដដែល ដែលគេបានទិញកាលពី ៣០ ឆ្នាំមុន ។ ហេតុផលនោះគឺថា ការជាប់ជំពាក់ចិត្តរបស់គេចំពោះសេចក្តីត្រូវ ការជិះទោចក្រយាននោះ ត្រូវបានបំពេញនៅក្នុងរយៈពេលនោះ, ដូច្នេះ គេនៅតែ បន្តសំគាល់ទោចក្រយាននោះថា ជាទោចក្រយានដដែល ។ តាមពិត, យើងបាន ធ្វើការសំគាល់ដូចនេះ ស្ទើរតែជាទូទៅក្នុងការអនុវត្តជាក់ស្តែង ប៉ុន្តែ ចំពោះសហជ្ញ-ញាណបរមត្ថវិជ្ជា ដ៏ពិតវិញ ពាក្យនិយាយថា " ឋិតថេរ " ឬ " ដដែល " (Durable ou identique ) គឺបង្ហាញអោយឃើញនូវអវិជ្ជាដ៏ធំធេង ។

នៅក្នុងគម្ពីរព្រះត្រ័យបិដក, កាលណាមាននិយាយពីសាវ័កអង្គណាមួយ ដែលលោកបានយល់គម្ពីរភាពនៃព្រះធម៌, នោះគឺមានន័យថា លោកដឹងច្បាស់ថា " *យំ កិញ្ចិ ឧប្បាទធម្មំ សព្វន្តំ និរោធធម្មំ* " គឺមានន័យថា " អ្វីមួយដែលបានកើត ឡើងហើយ ត្រូវរលត់ទៅវិញដោយពិតប្រាកដ " ។ បទពិសោធន៍ដ៏ពិតនៃសច្ចធម៌ នេះ នឹងអាចកើតឡើងបានតែកាលណាគេបានរំដោះផុតពីសេចក្តីជាប់ជំពាក់ចិត្ត ទាំងអស់ ទោះជាមានរូបភាពជាអ្វី ក៏ដោយ ។

ដរាបណា យើងមិនបានផ្តាច់ខ្លួនផុតពីការជាប់ជំពាក់ចិត្ត (តណ្ហា) ទេ សក្កាយទិដ្ឋិ (l'ignorance de l'identification = ពោលគឺ ទិដ្ឋិដែលប្រកាន់ថា បញ្ចក្ខ័ន្ធ ជារបស់ផងខ្លួន ជ.ណ) នឹងនៅតែមាន ហើយនិងធ្វើអោយអស់សមត្ថភាព ស្វែងយល់ធម្មជាតិប្រែប្រួល ដ៏ពិតនៃសភាវធម៌ទាំងឡាយ ។

នៅក្នុង*អភិធម្មមនវិភាសសាស្ត្រ* (Abhidhamma-manavibha sasatra) លោកនិយាយថា " មួយថ្ងៃមានម្ភៃបួនម៉ោង គឺត្រូវជាប្រាំមួយពាន់បួន រយលាន កៅសិបប្រាំបួនពាន់ ប្រាំបួនរយប៉ែតសិប (៦.៤០០.០៩៩.៩៨០) « ខណៈ

នៃមនសិការ ហើយខ័ន្ធទាំងប្រាំមែងកើតឡើង ហើយរលត់ទៅទិញដដែលៗ នៅខណៈនិមួយៗ » ។

ព្រះពុទ្ធឃោសៈ មានពុទ្ធដីកានៅក្នុងគម្ពីរវិសុទ្ធិមគ្គថាៈ តាមន័យល្អិតល្អន់, រយៈពេលនៃជីវិតរបស់ជីវសត្វ (Un être vivant) មានរយៈពេលខ្លីណាស់, គឺស្មើនឹងសម័យកាលនៃរយៈពេលរបស់គំនិតមួយ ។ ដូចគ្នានេះដែរ កង់រទេះនៅក្នុងពេលវិលទៅ ឋិតនៅតែលើចំណុចមួយនៃខ្នងកង់, ហើយនៅពេលឈប់ ក៏ឋិតនៅលើចំណុចមួយនៃខ្នងកង់, ជីវិតរបស់សព្វសត្វដែលមានជីវិត ក៏ដូចគ្នា គឺឋិតថេរតែនៅសម័យកាលដ៏ខ្លីនៃការគិត ហើយ, គ្រាន់តែគំនិតឈប់ភ្លាម, សត្វនោះ ក៏ត្រូវបានគេនិយាយថា ឈប់មានដែរ ។

" ដូច្នេះ, សត្វនៃខណៈមួយកន្លងទៅ បានរស់រួចហើយ, ប៉ុន្តែ មិនមែន *កំពុងរស់* និងមិនមែន *នឹងរស់ទេ;* សត្វនៃខណៈអនាគត *នឹងរស់* ប៉ុន្តែ *មិនបានរស់* និង *មិនកំពុងរស់ទេ,* សត្វនៃខណៈបច្ចុប្បន្ន *កំពុងរស់,* ប៉ុន្តែ *មិនបានរស់* និងមិនមែន *នឹងរស់ទេ* " ។

## អំពីកាល (Le Temps)

ប្រសិនបើសច្ចៈមានយ៉ាងនេះ, តើ *កាលៈ* គេយល់ដូចម្តេច ?

មតិ អំពីអតីត បច្ចុប្បន្ន និងអនាគត បានកើតមានតែតាមការប្រៀបផ្ទឹមទៅនឹងវត្ថុអ្វីមួយដែលយើងប្រកាន់យកថា មានអត្ថិភាពដដែល : អ្វីនេះបានកើតមាន, អ្វីនេះ កំពុងកើតមានឥឡូវនេះ និងអ្វីនេះនឹងកើតមានក្នុងពេលអនាគត ឬក៏និយាយថា ខ្ញុំបានឋិតនៅក្នុងទីនោះ, ខ្ញុំបានមកកាន់ទីនេះ ហើយខ្ញុំនឹងទៅកាន់ទីនោះ ។ម្យ៉ាងវិញទៀត, គេអាចនិយាថា ទស្សនាទានអំពីភាពមុន និងភាពក្រោយលើកឡើង*ចំពោះវត្ថុដដែល* ណាមួយ *បានបង្កើតឱ្យមានមតិអំពីកាលៈ* (l'idée

du temps) ។

ប៉ុន្តែយើងបានឃើញស្រាប់ហើយថា នៅក្នុងសកលភាពនៃអនិច្ចតាធម៌, ការសំគាល់ថាដូចគ្នា ឬថាដដែល គឺជាអវិជ្ជាដ៏ធ្ងន់ធ្ងរបំផុត ដែលចេញមកពីការជាប់ជំពាក់ចិត្ត ឬតណ្ហា ដែលព្រះពុទ្ធអោយឈ្មោះថា "សក្កាយទិដ្ឋិ" ។ មតិអំពីកាល ស្តីពីអតីត, បច្ចុប្បន្ន, និងអនាគត បានចាក់ឫសជាប់ ដរាបណាសក្កាទិដ្ឋិមិនទាន់បានផ្តាច់ចេញទេ ។

កាលណាព្រះអរហន្ត លោកបានកំទេចអវិជ្ជាអស់ហើយ, លោកមើលឃើញសច្ចះនៅកណ្តាលវាលស្អាត ដោយគ្មានលាយឡំដោយមតិអំពីអតីត ឬ អនាគតនៅក្នុងសច្ចះនោះឡើយ ។ ព្រះពុទ្ធលោកហៅអ្នកប្រាជ្ញនោះថា :" អកប្បិយោ" អ្នកឋិតនៅខាងលើនៃសេវកភាព ( ភាពជាប់ជំពាក់ ) របស់កល្បៈ, កាល ។

នៅក្នុងគម្ពីរព្រហ្មជាលសុត្ត នៃទីឃនិកាយ, ព្រះពុទ្ធក្នុងពេលព្រះអង្គចង្អុលប្រាប់មូលហេតុនៃការភ័ន្តច្រឡំរបស់ទ្រឹស្តីខុសទាំងហុកសិបពីរ ទ្រង់មានបន្ទូលថា គឺដោយហេតុតែអវិជ្ជាអំពី "បុព្វន្តៈ និងអបរន្តៈ" ឬអាទិភាព (priorité) និងបច្ឆាភាព (postériorité) ទើបនាំឱ្យកើតមានទស្សនះភាន់ច្រឡំទាំងនោះ ។

នៅក្នុងមិលិន្ទបញ្ហា ព្រះរាជាមិលិន្ទៈទ្រង់ចោទសួរដែរ ចំពោះភិក្ខុជាពហុស្សូតព្រះនាមនាគសេនថា :" ព្រះតេជព្រះគុណ, តើអ្វីជាមូលហេតុនៃកាលៈ" ? ចម្លើយតបភ្លាមចំពោះសំនួរនេះ " បពិត្រព្រះរាជា អវិជ្ជាគឺជាមូលហេតុនៃកាលៈ ។

លោកស្រី រីស ដាវីដ Rhys Davids នៅក្នុងសៀវភៅរបស់លោកស្រីស្តីពី " បញ្ហារបស់ព្រះបាទមិលិន្ទៈ" បានសាកល្បងបកស្រាយដោយពុំបានសំរេចលទ្ធផលល្អលើចំណុចដ៏សំខាន់នេះ ។ លោកស្រីបាននិយាយថា ពាក្យ " អវិជ្ជា " ដែលប្រើពុំមានន័យស្មើនឹង Ignorance = ភាពខ្លៅ ឬឥតចំណេះទេ, ប៉ុន្តែ មានន័យថា Inconnaissabilité = ភាពដែលមិនស្គាល់ ឬដឹងបាន ។ ទោះបី លោក

ស្រី មានបញ្ហាវាងវែ, លោកស្រី ក៏ពុំអាចគេចផុតពីសក្កាយទិដ្ឋិ, ហើយនៅពេលនោះ លោកស្រីបានបង្ហុសន័យដោយប្រការបែបនេះ ។ ការបកស្រាយនេះ មិនស្របជាមួយអាគតដ្ឋាន (la citation) និងជាមួយទស្សនៈរបស់ព្រះនាគសេនថេរទេ ។ ជាងនេះទៅទៀត, តើ «l'Inconnaissabilité» = ភាពមិនអាចដឹង ឬស្គាល់បាន អាចជាមូលហេតុនៃកាលៈ ឬអ្វីដទៃទៀត យ៉ាងដូចម្ដេច ? ចំពោះបញ្ហានេះ, អ្នកនិពន្ធពុំបានពន្យល់ទេ ។

## ការប្រែប្រួល (Le changement)

ប្រសិនបើកាលៈ, ទុកដូចជាសច្ចៈបរមត្ថវិជ្ជា ត្រូវបានពុទ្ធសាសនា បដិសេធ, តើការប្រែប្រួលនៃកាលៈ ត្រូវបានគេពន្យល់ដូចម្ដេច ?

ដើម្បីយល់បញ្ហានៃការប្រែប្រួលនេះ, ដំបូងយើងត្រូវមើលឃើញថា អ្វីជាការប្រែប្រួល ហើយនៅពេលណាយើងចាប់អារម្មណ៍ដឹងអំពីការប្រែប្រួលនេះ ។

ការប្រែប្រួលកើតមានជានិច្ច ពីនេះទៅនោះ ឬយកជានិមិត្តរូបចំណុចពីរ គឺពី X ទៅ Y ។ ឥឡូវនេះ យើងឃើញទារកមួយគេងនៅក្នុងអង្រឹង ដ៏មានអវយវៈតូច ហើយទន់ជ្រាយ, ដប់ឆ្នាំក្រោយមក យើងឃើញទារកនោះ បានចំរើនវ័យទៅជាកុមារម្នាក់ កំពុងរត់ លោត និងនិយាយប្រាជ្ញព្រោក ហើយយើងលាន់មាត់ថា មានការប្រែប្រួលច្រើនណាស់ចំពោះខ្លួនរបស់វា ។ ដោយប្រការដូចនេះ មតិអំពីការប្រែប្រួលកើតមានឡើង កាលណាយើងប្រកាន់យកចំណុចពីរនៃដំណើរជីវិតរបស់ក្មេង ហើយប្រៀបធៀបចំណុចទាំងពីរនោះជាមួយគ្នា ដោយមិនគិតក្នុងពេលជាមួយគ្នានោះ នូវចំណុចជាច្រើនឥតគណនា ដែលកើតមានឡើងនៅចន្លោះចំណុច X មកចំណុច Y ។ ឪពុកម្ដាយរបស់ក្មេង ដែលសង្កេតក្មេងនោះ ជាញឹកញយ ក៏ពុំ

ឃើញការប្រែប្រួលដ៏ច្រើននោះដែរ ។ ក្មេងខ្លួនឯងដែលសង្កេតសរីរៈកាយរបស់វាជាញឹកញយជាងនរណាទាំងអស់ ក៏ពុំអាចចាប់អារម្មណ៍នូវការប្រែប្រួលនោះដែរ ។ ទាល់តែក្មេងនោះធ្វើអរូបិយកម្ម (faire abstraction) ខ្លួនឯង ហើយក្រោយពីអរូបិយកម្មដូចគ្នា ដែលវាបានសង្កេត និងប្រៀបធៀបចំណុចពីរនៅក្នុងខ្លួនវា នោះទើបវាចាប់អារម្មណ៍ថា មានការប្រែប្រួលក្នុងកិរិតណាមួយ ។ ដូច្នេះ វាគ្មានជាដាច់ខាតនូវការប្រែប្រួល ចំពោះអ្នកណាដែលភ្ជាប់ខ្លួនយ៉ាងពិតប្រាកដទៅនឹងរលក នៃតថភាព នោះឡើយ ។

ការប្រែប្រួលកើតមានដោយប្រាកដចំពោះអ្នកណាដែលដកយកចេញពីតថភាព នូវចំណុចតែពីរប៉ុណ្ណោះគឺ X និង Y, ដោយមិនគិតគូរ និងបំភ្លេចទាំងស្រុង នូវចំណុចទាំងឡាយចន្លោះកណ្ដាល X1. X2. X3. - ល -, ប៉ុន្តែ កាលណាចំណុចទាំងឡាយនោះត្រូវបានគិតគូរ ការប្រែប្រួលមិនត្រូវបានគេចាប់អារម្មណ៍ទាល់តែសោះ ។ វាជាការនិយាយមិនកើត ថាតើកាលណា X ត្រូវចប់ ហើយកាលណា Y ត្រូវចាប់ផ្ដើម ។

គ្មានលទ្ធភាពណាមួយអាចកំណត់ច្បាស់លាស់ថា នៅខណៈណាដីឥដ្ឋក្លាយទៅជាក្អម ឆ្នាំង (កុម្ភការភណ្ឌ) ។

តថភាព ហូរដូចរន្តទឹកអូរ ដូចគ្នានឹងអនិច្ចធាតុ ដូច្នោះដែរ ។ នៅក្នុងតថភាពនេះ, គេពុំអាចលើកយកចំណុចអចល័តពីរ ( ដោយអរូបិយកម្ម ), ហើយប្រៀបធៀបចំណុចពីរនេះជាមួយគ្នា រួចធ្វើអោយកើតមានមតិអំពីការប្រែប្រួលបានទេ ។ អរូបិយកម្មល្ងិតល្ងង់បែបនេះ គឺជាដំណាក់មួយទៀត នៃសក្កាយទិដ្ឋិ ។

ទស្សនវិទូខ្លះ យល់ច្រឡំន័យរបស់អនិច្ចៈ ហើយហៅពុទ្ធលទ្ធិថា ខណិក-វាទ ( ក្សណិកវាទ ) ឬ «le momentané» ។ មិនមែនទេ, តើខណៈទាំងឡាយអាចត្រូវបានគេសិក្សាកើត ក្រោមពន្លឺពិតប្រាកដនៃបរមត្ថវិជ្ជា ឬទេ ? គ្មានកិរិត

ស្រី មានបញ្ហាវាងវៃ, លោកស្រី ក៏ពុំអាចគេចផុតពីសក្កាយទិដ្ឋិ, ហើយនៅពេលនោះ លោកស្រីបានបង្ខុសន័យដោយប្រការបែបនេះ ។ការបកស្រាយនេះ មិនស្រប ជាមួយអាគតដ្ឋាន (la citation) និងជាមួយទស្សនះរបស់ព្រះនាគសេនថេរទេ ។ ជាងនេះទៅទៀត, តើ «l'Inconnaissabilité» = ភាពមិនអាចដឹង ឬស្គាល់បាន អាចជាមូលហេតុនៃកាលៈ ឬអ្វីដទៃទៀត យ៉ាងដូចម្ដេច ? ចំពោះបញ្ហានេះ, អ្នកនិពន្ធពុំបានពន្យល់ទេ ។

## ការប្រែប្រួល (Le changement)

ប្រសិនបើកាលៈ, ទុកដូចជាសច្ចៈបរមត្ថវិជ្ជា ត្រូវបានពុទ្ធសាសនា បដិសេធ, តើការប្រែប្រួលនៃកាលៈ ត្រូវបានគេពន្យល់ដូចម្ដេច ?

ដើម្បីយល់បញ្ហានៃការប្រែប្រួលនេះ, ដំបូងយើងត្រូវមើលឃើញថា អ្វីជាការប្រែប្រួល ហើយនៅពេលណាយើងចាប់អារម្មណ៍ដឹងអំពីការប្រែប្រួលនេះ ។

ការប្រែប្រួលកើតមានជានិច្ច ពីនេះទៅនោះ ឬយកជានិមិត្តរូបចំណុចពីរ គឺពី X ទៅ Y ។ ឥឡូវនេះ យើងឃើញទារកមួយគេងនៅក្នុងអង្រឹង ដ៏មានអវយវៈតូច ហើយទន់ជ្រាយ, ដប់ឆ្នាំក្រោយមក យើងឃើញទារកនោះ បានចំរើនវ័យទៅជាកុមារម្នាក់ កំពុងរត់ លោត និងនិយាយប្រាជ្ញប្រោក ហើយយើងលាន់មាត់ថា មានការប្រែប្រួលច្រើនណាស់ចំពោះខ្លួនរបស់វា ។ ដោយប្រការដូចនេះ មតិអំពីការប្រែប្រួលកើតមានឡើង កាលណាយើងប្រកាន់យកចំណុចពីរនៃដំណើរជីវិតរបស់ក្មេង ហើយប្រៀបធៀបចំណុចទាំងពីរនោះជាមួយគ្នា ដោយមិនគិតក្នុងពេលជាមួយគ្នានោះ នូវចំណុចជាច្រើនឥតគណនា ដែលកើតមានឡើងនៅចន្លោះចំណុច X មកចំណុច Y ។ ឪពុកម្ដាយរបស់ក្មេង ដែលសង្កេតក្មេងនោះ ជាញឹកញយ ក៏ពុំ

ឃើញការប្រែប្រួលដ៏ច្រើននោះដែរ ។ ក្មេងខ្លួនឯងដែលសង្កេតសរីរៈកាយរបស់វា ជាញឹកញយជាងនរណាទាំងអស់ ក៏ពុំអាចចាប់អារម្មណ៍នូវការប្រែប្រួលនោះដែរ ។ ទាល់តែក្មេងនោះធ្វើអរូបិយកម្ម (faire abstraction) ខ្លួនឯង ហើយក្រោយពីអរូបិយកម្មដូចគ្នា ដែលវាបានសង្កេត និងប្រៀបផ្ទឹមចំណុចពីរនៅក្នុងខ្លួនវា នោះទើបវាចាប់អារម្មណ៍ថា មានការប្រែប្រួលក្នុងកិរិតណាមួយ ។ ដូច្នេះ វាគ្មានជាដាច់ខាតនូវការប្រែប្រួល ចំពោះអ្នកណាដែលភ្ជាប់ខ្លួនយ៉ាងពិតប្រាកដទៅនឹងរលក នៃតថភាព នោះឡើយ ។

ការប្រែប្រួលកើតមានដោយប្រាកដចំពោះអ្នកណាដែលដកយកចេញពីតថភាព នូវចំណុចតែពីរប៉ុណ្ណោះគឺ X និង Y, ដោយមិនគិតគូរ និងបំភ្លេចទាំងស្រុង នូវចំណុចទាំងឡាយចន្លោះកណ្ដាល X1. X2. X3. - ល ., ប៉ុន្តែ កាលណាចំណុចទាំងឡាយនោះត្រូវបានគិតគូរ ការប្រែប្រួលមិនត្រូវបានគេចាប់អារម្មណ៍ទាល់តែសោះ ។ វាជាការនិយាយមិនកើត ថាតើកាលណា X ត្រូវចប់ ហើយកាលណា Y ត្រូវចាប់ផ្ដើម ។

គ្មានលទ្ធភាពណាមួយអាចកំណត់ច្បាស់លាស់ថា នៅខណៈណាដីអិដ្ឋក្លាយទៅជាក្អម ឆ្នាំង (កុម្ភការភណ្ឌ) ។

តថភាព ហូរដូចរន្តទឹកអូរ ដូចគ្នានឹងអនិច្ចតាធម៌ ដូច្នោះដែរ ។ នៅក្នុងតថភាពនេះ, គេពុំអាចលើកយកចំណុចអចល័តពីរ ( ដោយអរូបិយកម្ម ), ហើយប្រៀបផ្ទឹមចំណុចពីរនេះជាមួយគ្នា រួចធ្វើអោយកើតមានមតិអំពីការប្រែប្រួលបានទេ ។ អរូបិយកម្មល្ងិតល្ងង់បែបនេះ គឺជាដំណាក់មួយទៀត នៃសក្កាយទិដ្ឋិ ។

ទស្សនវិទូខ្លះ យល់ច្រឡំន័យរបស់អនិច្ចៈ ហើយហៅពុទ្ធលទ្ធិថា ខណិក-វាទ ( ក្សណិកវាទ ) ឬ «le momentané» ។ មិនមែនទេ, តើខណៈទាំងឡាយអាចត្រូវបានគេសិក្សាកើត ក្រោមពន្លឺពិតប្រាកដនៃបរមត្ថវិជ្ជា ឬទេ ? គ្មានកិរិត

ព្រំដែនច្បាស់លាស់ អាចត្រូវគេកំណត់បានរវាងចំណុចដែលខណៈមួយត្រូវចប់ ហើយខណៈមួយទៀត ត្រូវចាប់ផ្ដើមទេ ។ គឺវាគ្រាន់តែសំរាប់សម្រួលការអនុវត្ត របស់យើងប៉ុណ្ណោះ ដែលយើងកំណត់ចំណុចនោះ ។

អ្នកប្រាជ្ញដែលបានជំនះអវិជ្ជានៃអរូបបិយកម្ម ឬ សក្កាយទិដ្ឋិ ចាត់ទុកធម្មជាតិរបស់អនិច្ចតាធម៌ ទៅនឹងឧត្តមនិមិត្តដ៏សុទ្ធសាធ (la véritable vision) ហើយលោកមិនចាប់អារម្មណ៍ចំពោះការប្រែប្រួលដ៏តិចតួចឡើយ ។ លោកក្លាយទៅជា និទ្វាវន្ទៈ " Nirdvavanda " គឺជាអ្នករំដោះផុតពីគូផ្ទុយគ្នា គឺស្រឡាញ់ និងស្អប់, សោមនស្ស និង ទោមនស្ស, ហើយចេះតែបន្តទៅ ។

( នៅមានត )

* * *

# វិរិយេន ទុក្ខមច្ចេតិ

## ឆ្លងផុតទុក្ខលំបាកបាន ដោយសេចក្ដីព្យាយាម

ពុទ្ធភាសិត

# គតិយសង្គាយនា

នៅដើមសតវត្សទី៣ នៃពុទ្ធសករាជ មានស្តេចមួយអង្គព្រះនាម *ធម្មា-សោក* បានឡើងគ្រងរាជ្យនៅក្រុងបាតលិបុត្រ ។ ព្រះមហាក្សត្រអង្គនេះ ទ្រង់មានព្រះរាជសទ្ធាជ្រះថ្លា និង ឧបត្ថម្ភព្រះពុទ្ធសាសនាយ៉ាងមុតមាំបំផុត ធ្វើអោយភិក្ខុ-សង្ឃបរិបូណ៌ដោយ *ចតុប្បច្ច័យ* (១) ។

ចំណែកពួកតិរ្ថិយ (២) ឃើញដូច្នេះ ក៏មកបន្លំខ្លួនចូលបួសជាច្រើន ក្នុងពុទ្ធសាសនា ដើម្បីលាភសក្ការៈ ។ លុះបួសហើយ ពួកអន្យតិរ្ថិយទាំងនោះ បានប្រព្រឹត្តផ្តេសផ្តាស ខុសនឹងវិន័យពុទ្ធប្បញ្ញត្តិ ធ្វើអោយល្អក់ កករ សៅហ្មង ប៉ះពាល់ដល់កិត្យានុភាពនៃពុទ្ធសាសនា ។ សភាពការណ៍នេះ បានធ្វើអោយភិក្ខុសង្ឃបរិសុទ្ធមួយចំនួន រត់ចោលវត្តអារាម លែងធ្វើឧបោសថអស់រយៈកាល ៧ ឆ្នាំ ។

ព្រះបាទធម្មាសោក លុះទ្រង់ជ្រាបហេតុការណ៍នេះ ក៏ទ្រង់ចាត់អោយពួកអាមាត្យទៅទូលព្រះសង្ឃ ដែលពុំព្រមធ្វើឧបោសថនោះថា « *សូមភិក្ខុសង្ឃ*

---

(១) ចតុប្បច្ច័យ : ចីវរ, បិណ្ឌបាត, សេនាសនៈ, គិលានភេសជ្ជៈ ។

(២) តិរ្ថិយ (អ.ថ ដិរៈថិ) មនុស្សចំពូកខ្លះ ដែលប្រព្រឹត្តកាន់សាសនាឆ្វេងទីទៃពីព្រះពុទ្ធ-សាសនា ដូចយ៉ាងប្រឹងដេកននៀលលើគំនរដីខ្សាច់កំពុងក្តៅ, បរិភោគអាហារត្របាក់ ដូចសុនខជាដើម ដោយប្រកាន់អាងថា វត្តប្រតិបត្តិដែលខ្លួនប្រព្រឹត្តនោះ អាចនឹងចម្លងខ្លួនឯងនិងអ្នកដែលជឿកាន់តាមអោយបានដល់ត្រើយ គឺសេចក្តីសុខ ... (វចនានុក្រមខ្មែរ) ។

*ព្រមព្រៀងគ្នាធ្វើឧបោសថ តាមធម្មតាឡើងវិញទៅ»* ។ ភិក្ខុសង្ឃបរិសុទ្ធ នៅតែពុំព្រមចូលធ្វើឧបោសថ តាមព្រះរាជបញ្ជាឡើយ ព្រោះពិនិត្យឃើញពួកតិរ្ថិយដែលក្លែងបួសជាភិក្ខុសង្ឃទាំងឡាយ ចូលធ្វើឧបោសថជាមួយដែរ ។ ពួករាជអាមាត្យ ក៏ធ្វើគតភិក្ខុសង្ឃបរិសុទ្ធ ដែលពុំព្រមចូលធ្វើឧបោសថនោះ អស់ពីរ-បីអង្គទៅ ។

ព្រះបាទធម្មាសោក លុះជ្រាបបញ្ហានេះ ក៏ទ្រង់មានព្រះហឫទ័យតក់ស្លុតរន្ធត់ឥតឧបមា ហើយបានយាងទៅតាមវត្តនានា សាកសួរព្រះសង្ឃថា " *តើពួកអាមាត្យដែលបានធ្វើគតព្រះសង្ឃនោះ ទទួលបាបតែឯងទេ ឬក៏ខ្ញុំព្រះកុណាជាអ្នកទទួលផលបាបដែរ ?* " ។ ព្រះសង្ឃខ្លះឆ្លើយថា " *ព្រះអង្គ ជាអ្នកទទួលផលបាបដែរ ព្រោះព្រះអង្គជាអ្នកប្រើពួកអាមាត្យ* " ។ ព្រះសង្ឃខ្លះទៀត ឆ្លើយថា "*ព្រះអង្គ ឥតទទួលផលបាបទេ ព្រោះព្រះអង្គ មិនមែនជាអ្នកធ្វើគតភិក្ខុសង្ឃទាំងនោះឡើយ* " ។

ចម្លើយទាំងនេះ រឹតតែធ្វើអោយព្រះរាជា មានព្រះទ័យសង្ស័យមិនអស់មិនហើយ និងរឹតតែធ្វើអោយព្រះអង្គតក់ស្លុតខ្លាំងឡើងៗ ។ ព្រះសង្ឃ មួយចំនួនទូលព្រះរាជាថា " *បើព្រះអង្គមិនអស់ព្រះទ័យក្នុងបញ្ហានេះទេ សូមព្រះអង្គយាងទៅសាកសួរព្រះមហាមោគល្លីបុត្តតិស្សត្ថេរទៅ ព្រោះលោកជាអ្នកប្រាជ្ញ* " ។ ព្រះមហាក្សត្រ ក៏ទ្រង់សព្វព្រះរាជហឫទ័យចាត់រាជអាមាត្យអោយទៅនិមន្តព្រះមហាមោគល្លីបុត្តតិស្សត្ថេរ មកកាន់ព្រះបរមរាជវាំង ដោយមានមហាពិធីបដិសណ្ឋារៈយ៉ាងមហោឡារិកក្រៃលែង ។

បន្ទាប់មក ព្រះរាជាទ្រង់ទូលព្រះមហាថេរថា " *ខ្ញុំព្រះករុណា បានចាត់រាជអាមាត្យអោយទៅទូលព្រះភិក្ខុសង្ឃថា សូមអោយព្រះសង្ឃព្រមព្រៀងគ្នាធ្វើឧបោសថដូចធម្មតាវិញទៅ ប៉ុន្តែ រាជអាមាត្យទាំងនោះ បែរជាធ្វើគតភិក្ខុសង្ឃដែលពុំព្រមធ្វើឧបោសថនោះទៅវិញ, តើខ្ញុំព្រះករុណា ជាអ្នកទទួលផល*

*បាបដែរឬទេ ?* " ។ ព្រះមហាមោគល្លីបុត្តតិស្សត្ថេរ ទូលថា " *ព្រះសម្មតិទេព ! ព្រះអង្គឥតទទួលផលបាបក្នុងបញ្ហាធ្វើគតភិក្ខុសង្ឃទាំងនោះទេ ព្រោះព្រះអង្គពុំមានវធកចិត្ត* (បំណងធ្វើគត) *ឡើយ* " ។ ព្រះមហាក្សត្រ ទ្រង់សព្វព្រះរាជហឫទ័យអស់មន្ទិលសង្ស័យក្នុងបញ្ហានេះ ហើយទ្រង់មានព្រះទ័យជ្រះថ្លាចំពោះព្រះពុទ្ធសាសនាកាន់តែខ្លាំងឡើងថែមទៀត ។

ជាមួយនោះ ព្រះរាជាក៏ទ្រង់បានជ្រាបអំពីមូលហេតុដែលនាំឱ្យភិក្ខុសង្ឃបរិសុទ្ធ មិនព្រមធ្វើឧបោសថ ដោយហេតុតែមានពួកតិរ្ថិយបន្លំបួសក្នុងពុទ្ធសាសនាចូលធ្វើឧបោសថជាមួយដែរនោះ ។ ស្ដេចទ្រង់បញ្ជាអោយគេផ្សឹកពួកតិរ្ថិយបួមផ្លួសទាំងអស់ ចំនួន ៦ ម៉ឺនរូប ។

បន្ទាប់មក ព្រះមហាមោគល្លីបុត្តតិស្សត្ថេរ បានជ្រើសរើសព្រះថេរៈដែលទ្រទ្រង់ព្រះត្រៃបិដក ចាក់ធ្លុះបដិសម្ភិទាញាណ ចំនួន ១០០០ អង្គ ប្រជុំធ្វើតតិយ-សង្គាយនានេះឡើង ។ សង្គាយនានេះ ហៅថា សហស្សិតសង្គាយនា ក៏បាន ព្រោះមានការកសង្ឃចូលរួមចំនួន ១០០០ អង្គ ។ សង្គាយនានេះ មានព្រះមហាមោគល្លី-បុត្តតិស្សត្ថេរជាប្រធាន, ព្រះបាទធម្មាសោក ជាពុទ្ធសាសនូបបត្ថម្ភក៏, ធ្វើនៅអសោការាម, ក្រុងបាតលិបុត្រ, ធ្វើ៩ខែ ទើបសំរេច ក្រោយពុទ្ធបរិនិព្វានកន្លងទៅបាន ២៣៤ ឆ្នាំ ។

ឯវិធីធ្វើសង្គាយនាលើកទី៣ នេះ មានរបៀបដូចសង្គាយនាទី១ ដែរ ។

រៀបរៀងសង្ខេបដោយ

- លោក **ម៉ែន ប្រាន**

- លោក **អាំ ឆន**

# បាយាសិរាជញ្ញសូត្រ

បាយាសិរាជញ្ញសូត្រនេះ មាននៅក្នុងសុត្តន្តបិដក (គម្ពីរព្រះត្រៃបិដក ភាសាបាលី និងខ្មែរ ក្បាលទី ១៧) ជាសូត្រមួយមានរបៀបចោទ-ឆ្លើយបង្ហាញពីទស្សនៈពុទ្ធនិយម ដែលអះអាងថា "លោកដទៃមាន, ឧបបាតិកសត្វមាន និងកម្មផលមាន" ។ សូត្រនេះ មានលំនាំសង្ខេប ដូចតទៅ :

សម័យនោះឯង ព្រះបាទបាយាសិរាជញ្ញ : ទ្រង់ស្តេចចូលទៅកាន់ក្រឡាបន្ទំក្នុងវេលាថ្ងៃ បានទតឃើញពួកព្រាហ្មណ៍ និងគហបតី អ្នកក្រុងសេតព្យៈ កំពុងចេញពីក្រុងឆ្ពោះទៅកាន់ទិសខាងជើង ។ លុះទ្រង់ទតឃើញហើយ ក៏សួរខត្តាមាត្រ ( អាមាត្រអ្នកដោះស្រាយប្រស្នាដែលគេសួរបាន ) ថា "ចុះពួកព្រាហ្មណ៍ និងគហបតីចេញពីក្រុងសេតព្យៈទាំងហ្វូង១ ឆ្ពោះទៅកាន់ព្រៃធ្នង់ខាងជើងនោះធ្វើអ្វីហ្ន៎ ?" ។ ខត្តាមាត្រក្រាបទូលថា "សូមទ្រង់មេត្តាប្រោស ដ្បិតមានសមណៈមួយអង្គព្រះនាមកុមារកស្សបៈ ជាសាវ័កព្រះសមណគោតមគង់នៅទីនោះ ជាមួយនឹងភិក្ខុសង្ឃ៥០០ អង្គ ។ ព្រះសមណៈអង្គនោះ លោកជាបណ្ឌិត មានកេរ្តិ៍ឈ្មោះ មានប្រាជ្ញា ជាពហុស្សូត មានបដិភាណដ៏ល្អ ជាអ្នកត្រាស់ដឹងផង ជាព្រះអរហន្តផង ។ ឯពួកព្រាហ្មណ៍ និង គហបតីទាំងអស់នុ៎ះ ចូលទៅជួបនឹងសមណៈឈ្មោះកុមារកស្សបៈនោះឯង" ។

ព្រះបាទបាយាសិ កាលទ្រង់ព្រះសណ្តាប់ដូច្នេះហើយ ក៏ទ្រង់ត្រាស់ទៅអាមាត្រនោះថា" ចូរអ្នកទៅរកពួកព្រាហ្មណ៍ និងគហបតីទាំងអស់នោះ ហើយឃាត់គេថា ព្រះបាទបាយាសិនឹងចូលទៅជួបព្រះសមណៈឈ្មោះកុមារកស្សបៈនោះដែរ, ហេតុនេះ ចូររង់ចាំព្រះអង្គផង" ។ លំដាប់នោះ ព្រះបាទបាយាសិដែលមានពួកព្រាហ្មណ៍ និងគហបតី អ្នកក្រុងសេតព្យៈហែហមព្រះអង្គផង ក៏ចូលទៅរកព្រះកុមារ

កស្សបៈដ៏មានអាយុ ដែលកំពុងគង់នៅក្នុងព្រៃធ្មង់ ។ ក្រោយពីបានសំណេះសំណាល រាក់ទាក់ សួរសុក្ខទុក្ខហើយ ទើបព្រះបាទបាយាសិ ទ្រង់ត្រាស់ទៅនឹងកុមារកស្សបៈដ៏មានអាយុ ថា " បពិត្រកស្សបៈដ៏ចំរើន, ខ្ញុំតែងនិយាយយ៉ាងនេះ និងយល់ឃើញយ៉ាងនេះថា "លោកដទៃមិនមាន ពួកសត្វជាឧបបាតិកៈ (សត្វស្លាប់ហើយកើតទៀត) មិនមាន ផលវិបាករបស់កម្មទាំងឡាយដែលសត្វធ្វើល្អ ធ្វើអាក្រក់មិនមាន" ។

*- កុមារកស្សប :* " អាត្មាភាពបានឃើញ បានឮបុគ្គលដែលធ្លាប់និយាយយ៉ាងនេះ យល់យ៉ាងនេះហើយ, តែមិនសមបើបុគ្គលនោះនិយាយយ៉ាងនេះ យល់យ៉ាងនេះ ដូច្នេះសោះ ។ បពិត្ររាជញ្ញៈ បើដូច្នេះ អាត្មាភាពនឹងសួរមហាបពិត្រក្នុងដំណើរនេះថា" ព្រះច័ន្ទ និងព្រះអាទិត្យ នៅក្នុងលោកនេះ ឬនៅក្នុងលោកដទៃ ជាទេវតា ឬជាមនុស្ស ?

*- បាយាសិ :* ព្រះច័ន្ទ និងព្រះអាទិត្យនៅក្នុងលោកដទៃ ជាទេវតា គឺមិនមែនជាមនុស្សទេ ។

*- កុមារកស្សប :* បើតាមបរិយាយនេះ សូមមហាបពិត្រថែរព្រះយោ-បល់យល់យ៉ាងនេះវិញថា លោកដទៃមាន ពួកសត្វជាឧបបាតិកៈមាន ផលវិបាករបស់កម្មទាំងឡាយដែលសត្វធ្វើល្អ ធ្វើអាក្រក់មាន ។

*- បាយាសិ :* ព្រះកស្សបៈដ៏ចំរើន ពោលយ៉ាងនេះ ក៏គួរម្យ៉ាងដែរ ប៉ុន្តែខ្ញុំនៅតែមានសេចក្តីយល់ឃើញថា លោកដទៃមិនមាន ពួកសត្វជាឧបបាតិកៈមិនមាន ផលវិបាករបស់កម្មទាំងឡាយមិនមាន ព្រោះពួកមិត្ត អាមាត្រ និងញាតិសាលោហិតរបស់ខ្ញុំក្នុងលោកនេះ ជាអ្នកប្រព្រឹត្តអកុសលកម្ម, លុះសម័យក្រោយមក ពួកគេមានអាពាធឈឺធ្ងន់ ដែលខ្ញុំដឹងថាមុខជានឹងមិនស្បើយចាកអាពាធនេះទេ, ខ្ញុំចូលទៅរកពួកមិត្តអាមាត្រទាំងនោះ ហើយនិយាយថា " មានសមណៈពួកមួយ និយាយថា ពួកជនឯណាប្រព្រឹត្តអកុសលកម្ម ពួកជននោះ លុះបែកធ្លាយរាងកាយទៅ តែងទៅ

កើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរក; ដូច្នេះអ្នកទាំងឡាយ សុទ្ធតែជាអ្នកប្រព្រឹត្តអំពើអាក្រក់, បើពាក្យរបស់សមណព្រាហ្មណ៍ទាំងនោះ ជាពាក្យពិតមែន អ្នកទាំងឡាយ លុះបែកធ្លាយរាងកាយទៅ មុខជានឹងទៅកើតជាកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរក ពុំខាន ។ បើយ៉ាងនេះមែន អ្នកទាំងឡាយត្រូវមកប្រាប់យើងថា លោកដទៃមាន ពួកសត្វជាឧបបាតិកៈមាន ផលវិបាករបស់កម្មទាំងឡាយដែលសត្វធ្វើល្អ ធ្វើអាក្រក់មាន ។ ពួកអាមាត្រទាំងនោះ ទទួលយល់ព្រមថា ករុណាថ្លៃវិសេសដូច្នេះ ហើយស្លាប់ទៅ តែមិនឃើញមកប្រាប់ ទាំងមិនបញ្ជូនបម្រើមកឡើយ ។ សេចក្ដីដូចបានទូលមកនេះ ទើបធ្វើអោយខ្ញុំមានគំនិតយល់យ៉ាងនេះថា លោកដទៃមិនមាន ពួកសត្វជាឧបបាតិកៈមិនមាន ផលវិបាករបស់កម្មទាំងឡាយមិនមាន ។

- *កុមារកស្សប :* មហាបពិត្រ សំគាល់ហេតុនេះដូចម្ដេច ? ពួកបុរសរបស់មហាបពិត្រក្នុងដែននេះ ចាប់បានចោរដែលប្រព្រឹត្តអាក្រក់មកថ្វាយមហាពិត្រ ហើយទូលថា បពិត្រព្រះអង្គដ៏ចំរើន អ្នកនេះជាចោរ ហើយព្រះអង្គទ្រង់សព្វព្រះទ័យដាក់អជ្ញាដល់ចោរនេះយ៉ាងណា សូមដាក់មកចុះ ។ ពេលនោះ ព្រះមហាបពិត្រមានបន្ទូលអោយគេចងស្លាបសេកបុរសជាចោរនោះ ហើយអោយនាំយកទៅសម្លាប់ ។ ពេជ្ឈឃាត ក៏នាំចោរនោះទៅអោយអង្គុយត្រង់កន្លែងសំរាប់ពិឃាត, ចុះបើពួកចោរនោះនឹងអង្វរពួកពេជ្ឈឃាតថា សូមពេជ្ឈឃាតបង្អង់សិន ចាំខ្ញុំទៅផ្ដែផ្ដាំពួកញាតិមិត្ររបស់ខ្ញុំ ហើយសិមមកវិញ តើបានឬទេ ? ឬក៏ ពួកពេជ្ឈឃាតទាំងនោះ ចេះតែកាត់ក្បាលចោរដែលកំពុងទួញយំ ដោយឥតយោគយល់ទេ ?

- *បាយាសិ :* បពិត្រព្រះកស្សបៈដ៏ចំរើន ចោរនោះនឹងអង្វរពួកពេជ្ឈ-ឃាតអោយបង្អង់ ដើម្បីទៅប្រាប់ញាតិមិត្ត សាច់សាលោហិតសិន ហើយសិមមក

វិញ មិនបានទេ, ពួកពេជ្ឈាតនឹងចេះតែកាត់ក្បាលចោរដែលកំពុងទូញយំនោះ ពុំខានឡើយ ។

- *កុមារកស្សបៈ* ថ្វាយព្រះពររាជញ្ញៈ អម្បាលយ៉ាងចោរនោះ ជាមនុស្សជាតិដូចគ្នាត្រឡាំង ម្ដេចគង់អង្វរពួកពេជ្ឈឃាតជាមនុស្សជាតិដូចគ្នា មិនបាន, ចំណង់បើពួកមិត្រ អាមាត្រ របស់មហាបពិត្រ សុទ្ធតែជាអ្នកប្រព្រឹត្តអំពើអាក្រក់ លុះបែកធ្លាយរាងកាយទៅ បានទៅកើតក្នុងកំណើតតិរច្ឆាន ប្រេត អសុរកាយ នរក ហើយ ធ្វើម្ដេចឡើយនឹងអង្វរនិរយបាល (យមរាជ) ថា "សូមបង្អង់សិន ចាំខ្ញុំយកដំណឹងទៅទូលមហាបពិត្រថា លោកដទៃមាន ពួកសត្វជាឧបបាតិកៈមាន ផលវិបាករបស់កម្មមាន ដូច្នេះបាន ! " ។

- *បាយាសិ :* ព្រះកស្សបៈដ៏ចំរើន យល់យ៉ាងនេះគួរដែរហើយ ប៉ុន្តែ ខ្ញុំនៅតែយល់ថា លោកដទៃមិនមាន ពួកសត្វជាឧបបាតិកៈមិនមាន ផលវិបាកនៃកម្មមិនមាន ព្រោះពួកញាតិមិត្តរបស់ខ្ញុំក្នុងលោកនេះ បានប្រព្រឹត្តធ្វើនូវកុសលកម្មច្រើន ក្រោយមក ពួកញាតិមិត្តទាំងអស់របស់ខ្ញុំមានអាពាធជាទម្ងន់ ។ កាលខ្ញុំដឹងថា អ្នកទាំងនោះ មុខជានឹងមិនជាសះស្បើយបាន ខ្ញុំក៏ចូលទៅរកពួកញាតិមិត្តទាំងនោះ ហើយនិយាយថា សមណព្រាហ្មណ៍ពួកខ្លះ ពោលថា ពួកជនណាបានធ្វើអំពើល្អ, លុះស្លាប់ទៅ នឹងបានទៅកើតក្នុងសុគតិសួគ៌ទេវលោក, ឥឡូវនេះ អ្នកទាំងឡាយ សុទ្ធតែជាអ្នកធ្វើនូវអំពើល្អ, ដូច្នេះ បើពិតដូចពាក្យសមណព្រាហ្មណ៍ទាំងនោះថាមែន, អ្នកទាំងឡាយ លុះស្លាប់ទៅប្រាកដជាទៅកើតក្នុងស្ថានសួគ៌ទេវលោកដោយពិត, បើអ្នកបានទៅកើតទីនោះមែន អ្នកទាំងឡាយគប្បីមកប្រាប់យើងថា លោកដទៃមាន ពួកសត្វជាឧបបាតិកៈមាន ផលវិបាករបស់កម្មទាំងឡាយមាន ។ ពួកញាតិទាំងនោះ ឆ្លើយថា ករុណាវិសេស ប៉ុន្តែមិនឃើញមកប្រាប់ ទាំងមិនឃើញបញ្ជូនបម្រើមកឡើយ ។ ហេតុនេះហើយដែលនាំអោយខ្ញុំយល់ថា លោកដទៃមិនមាន ពួកសត្វជា

ឧបបាតិកៈមិនមាន ផលវិបាករបស់កម្មទាំងឡាយមិនមាន ។

- *កុមារកស្សបៈ* : អាត្មានឹងធ្វើការឧបមាមួយថ្វាយមហាបពិត្រថា មានបុរសម្នាក់ធ្លាក់ទៅក្នុងរណ្ដៅលាមក លិចចុះទាំងក្បាល ។ ពេលនោះ មហាបពិត្រត្រាស់បង្គាប់រាជបុរសអោយស្រង់បុរសនោះអំពីរណ្ដៅលាមក ហើយសំអាត ស្អិតស្អាងកាយបុរសនោះ ប្រដាប់ដោយសំលៀកបំពាក់ដ៏ល្អឆើត លាបប្រេងម្សៅ ដ៏ប្រណីត ហើយអោយទៅនៅក្នុងប្រាសាទដ៏ស្អាត ចាត់ចែងបំរើដោយកាមគុណ ៥ យ៉ាងសប្បាយរីករាយ, តើបុរសនោះ នៅតែមានសេចក្ដីប្រាថ្នានឹងមុជចុះទៅក្នុងរណ្ដៅលាមកនោះទៀត ឬទេ ?

- *បាយាសិ* : បពិត្រព្រះកស្សបៈដ៏ចំរើន រណ្ដៅលាមកមិនជាទីពេញចិត្ត ជារបស់មិនស្អាតផង ជាចំណែកនៃរបស់មិនស្អាតផង មានក្លិនស្អុយផង ជាចំណែករបស់មានក្លិនស្អុយផង, បុរសនោះប្រាកដជាពុំចុះទៅក្នុងរណ្ដៅលាមកនោះវិញទេ ។

- *កុមារកស្សបៈ* : ថ្វាយព្រះពររាជញ្ញៈ យ៉ាងហ្នឹងមែនហើយ មនុស្សទាំងឡាយជារបស់មិនស្អាត មានក្លិនស្អុយ គួរធុញទ្រាន់ គួរខ្ពើមរអើមដល់ទេវតាទាំងឡាយ, ក្លិនមនុស្សធុំអាក្រក់ ផ្សាយឡើងទៅកាន់ស្ថានទេវតា ចំនួន ១០០ យោជន៍ ។ ពួកមិត្តញាតិរបស់មហាបពិត្រ ជាអ្នកធ្វើអំពើល្អ លុះស្លាប់ទៅ បានទៅកើតក្នុងស្ថានទេវលោកហើយ នឹងមកប្រាប់ថា លោកដទៃមាន ពួកសត្វជាឧបតិកៈមាន ផលវិបាកនៃកម្មមាន ដូចម្ដេចបាន ? ។ ដូច្នេះ សូមមហាបពិត្រ បែរយោបល់យល់យ៉ាងនេះវិញថា លោកដទៃមាន ពួកសត្វជាឧបបាតិកៈមាន ផលវិបាកនៃកម្មទាំងឡាយមាន ដោយហេតុនេះចុះ ។

- *បាយាសិ* : ព្រះកស្សបៈដ៏ចំរើន ពោលយ៉ាងនេះគួរដែរហើយ ប៉ុន្តែខ្ញុំនៅតែយល់ថា លោកដទៃមិនមាន ពួកសត្វជាឧបបាតិកៈមិនមាន ផលវិបាកនៃកម្មទាំងឡាយមិនមាន ព្រោះថា ពួកញាតិមិត្តរបស់ខ្ញុំច្រើនណាស់ ដែលជាអ្នកធ្វើអំពើ

ល្អ ។ សម័យមួយ ពួកញាតិខ្ញុំទាំងនោះមានអាពាធជាទម្ងន់ ។ ខ្ញុំបានចូលទៅផ្ដាំអ្នកទាំងនោះថា បើអ្នកស្លាប់ពីទីនេះ ហើយកើតក្នុងស្ថានសួគ៌, អ្នកទាំងឡាយចូរមកប្រាប់យើងថា លោកដទៃមាន ពួកសត្វជាឧបបាតិកៈមាន ផលវិបាកនៃកម្មទាំងឡាយមាន ។ ពួកញាតិមិត្តរបស់ខ្ញុំទាំងនោះទទួលយល់ព្រមថា ករុណាវិសេស រួចស្លាប់ទៅ ។ តាំងពីពេលនោះមក ខ្ញុំមិនមានឃើញអ្នកទាំងនោះមកប្រាប់ ទាំងមិនបញ្ជូនបំរើមកប្រាប់សោះ ។ ដំណើរនេះហើយដែលនាំអោយខ្ញុំនៅតែយល់ថា លោកដទៃមិនមាន ពួកសត្វជាឧបបតិកៈមិនមាន ផលវិបាកនៃកម្មទាំងឡាយមិនមាន ។

*- កុមារកស្សបៈ* ៖ អើ, បើដូច្នេះ អាត្មាភាពនឹងទូលសួរមហាបពិត្រក្នុងដំណើរនេះវិញ, មហាបពិត្រពេញព្រះទ័យក្នុងប្រស្នានេះយ៉ាងណា សូមមហាបពិត្រព្យាករណ៍យ៉ាងនោះចុះ ។ បពិត្ររាជញ្ញៈ ១០០ ឆ្នាំរបស់មនុស្ស[១] ត្រូវជា ១ យប់ ១ថ្ងៃ របស់ទេវតាជាន់តាវតឹង្ស, ៣០រាត្រីនុ៎ះ ត្រូវជា ១ខែ, ១២ខែ ត្រូវជា ១ ឆ្នាំ ។ រាប់ឆ្នាំនោះបាន ១០០០ ឆ្នាំទិព្វ ជាប្រមាណនៃអាយុទេវតាជាន់តាវតឹង្ស ។ ពួកញាតិមិត្តរបស់មហាបពិត្រ អ្នកធ្វើអំពើល្អ លុះបែកធ្លាយរាងកាយទៅបានទៅកើតក្នុងស្ថានសួគ៌ជាមួយពួកទេវតាជាន់តាវតឹង្ស, ចុះបើពួកញាតិមិត្តទាំងនោះមានគំនិតថា ចាំយើងទាំងឡាយអោយគេបំរើអោយស្កប់ស្កល់ដោយកាមគុណទាំង៥ ជាទិព្វបានពីរ-បីថ្ងៃសិន សិមទៅប្រាប់ដល់ព្រះបាទបាយាសិ តើបានឬទេ ?

*- បាយាសិ* ៖ បពិត្រព្រះកស្សបៈដ៏ចំរើន, មកមិនទាន់ទេ ព្រោះថាខ្ញុំមុខជានឹងស្លាប់ទៅយូរហើយ ។ ចុះនរណាមកប្រាប់ព្រះអង្គថា ពួកទេវតាជាន់តាវតឹង្សមាន ? ឬថាទេវតាជាន់តាវតឹង្សមានអាយុវែងយ៉ាងនេះ, ខ្ញុំមិនទាន់ជឿទេ ។

*- កុមារកស្សបៈ* ៖ ថ្វាយព្រះពររាជញ្ញ ៖ ! មនុស្សខ្វាក់ពីកំណើត មិនដែល

(១) ១០០ ឆ្នាំ របស់មនុស្ស ស្មើនឹង ១ ថ្ងៃទិព្វ របស់ទេវតា ។

ឃើញរូបខ្មៅ-ស មិនដែលឃើញរូបសម្បុរក្រហម លឿង ខ្មៅ ជាដើមទេ, មិនដែលឃើញផ្កាយទាំងឡាយ មិនដែលឃើញព្រះច័ន្ទ ព្រះអាទិត្យទេ ។ មនុស្សខ្វាក់នោះមុខជានិយាយយ៉ាងនេះថា រូបខ្មៅ ស ក្រហម លឿង ខៀវ ជាដើមគ្មានទេ ព្រះចន្ទ ព្រះអាទិត្យគ្មានទេ, បុគ្គលអ្នកឃើញរូបព្រះអាទិត្យ ព្រះចន្ទ ក៏គ្មានដែរ ។ បពិត្ររាជញ្ញៈ ! កាលបើមនុស្សខ្វាក់និយាយយ៉ាងនេះ ឈ្មោះថានិយាយត្រូវ ឬទេ ?

- *បាយាសិ :* បពិត្រព្រះកស្សបៈដ៏ចំរើន, ! មិនត្រូវទេ ព្រោះរូបខ្មៅ ឬ ស មាន, បុគ្គលអ្នកឃើញរូបខ្មៅ ឬ ស មាន, រូបផ្កាយមាន, រូបព្រះអាទិត្យ ព្រះចន្ទមាន, បុគ្គលអ្នកឃើញរូបផ្កាយ ព្រះអាទិត្យ ព្រះចន្ទ ក៏មាន ។ បើបុរសខ្វាក់ពីកំណើតនិយាយថា អាត្មាអញមិនស្គាល់របស់នុ៎ះ អាត្មាអញមិនឃើញរបស់នុ៎ះ ទើបត្រឹមត្រូវ ។ ប៉ុន្តែ បើបុរសខ្វាក់ពីកំណើតនិយាយថា របស់ទាំងនោះមិនមានទេ, ការនិយាយដូច្នេះ ឈ្មោះថាមិនត្រឹមត្រូវឡើយ ។

- *កុមារកស្សបៈ :* យ៉ាងហ្នឹងមែនហើយ, អង្គមហាបពិត្រ ទុកដូចជាមនុស្សខ្វាក់ពីកំណើត ។ សូមមហាបពិត្រជ្រាបថា លោកដទៃ បុគ្គលមិនគប្បីឃើញដោយមំសចក្ខុទេ, មានតែពួកសមណព្រាហ្មណ៍ដែលអាស្រ័យក្នុងទីសេនាសនៈ ដ៏ស្ងាត់ ក្នុងព្រៃតូច-ធំ មិនមានសេចក្ដីប្រមាទ មានព្យាយាមដុតកំដៅកិលេស មានចិត្តឆ្ពោះទៅកាន់ព្រះនិព្វាន បាននូវទិព្វចក្ខុ ទើបឃើញលោកនេះផង លោកដទៃផង ពួកសត្វជាឧបបាតិកៈផង ។ ដូច្នេះ សូមមហាបពិត្រ ធ្វើការយល់ជាថ្មីវិញទៅ ទើបប្រសើរ ។

*(នៅមានត)*

រៀបរៀងដោយ

**អាំ ឆន, ម៉ែន ប្រាជ**

ឯកសារ

# លោកសង្ឃខ្មែរ

**កំណត់របស់អ្នកបកប្រែ :** ខ្ញុំបានបកប្រែអត្ថបទនេះឡើង ដើម្បីបង្ហាញដល់អ្នកអានជាតិខ្មែរយើងថា តើលោកហ្វ្រង់ស្វា ម៉ារទីនី, អ្នកប្រាជ្ញបារាំងម្នាក់ បានមើលឃើញលោកសង្ឃ និងសង្គមខ្មែរ ដោយទស្សនៈបែបណា ។ ខ្ញុំចង់លើកយកទស្សនៈនោះមក ដើម្បីលាតត្រដាងអោយអ្នកអានខ្មែរយើង បានយល់ដឹងពីតម្លៃវប្បធម៌របស់សង្គមផងខ្លួន ។

ជាការណ៍ពិត, មានសេចក្ដីរៀបរាប់ខ្លះនៅក្នុងអត្ថបទបកប្រែនេះ ពុំបានសមស្របទៅនឹងការយល់ដឹងជាក់ស្ដែងរបស់សង្គមយើង ឬក៏ពុំក្បោះក្បាយ អស់សេចក្ដីទេ ឧទាហរណ៍ដូចជាក្នុងចំណុចរៀបរាប់អំពីការបួស ជាដើម ។ ប៉ុន្តែ ខ្ញុំ (អ្នកបកប្រែ) មិនបន្ថែម ឬបន្ថយខ្លឹមសារនោះទេ គឺទុកឱកាសជូនអ្នកអានយើង ពិចារណាលើការយល់ដឹងរបស់លោកហ្វ្រង់ស្វា ម៉ារទីនី ដែលលោកបានសរសេរអត្ថបទនេះ ក្នុងរង្វង់ឆ្នាំ ១៩៤៩ ដោយខ្លួនឯងចុះ ដើម្បីលោកអ្នកអានយើងធ្វើការប្រៀបធៀបការយល់ដឹងនោះ ទៅនឹងការយល់ដឹងអំពីលោកសង្ឃ ឬអ្វីៗដែលយើងមានក្នុងពេលបច្ចុប្បន្ន ។ ម្យ៉ាងទៀត ខ្ញុំសូមឧទ្ទិសអត្ថបទនេះ ទុកជាឯកសារសិក្សាស្រាវជ្រាវ ផងដែរ ។

***

លក្ខណៈមួយ ក្នុងបណ្ដាលក្ខណៈទាំងឡាយដែលផ្ដុំផ្សំធ្វើអោយប្រទេសខ្មែរត្រូវបានគេចងចាំ ជាមួយនឹងចរិយាសីលធម៌ខ្ពស់របស់ប្រទេសខ្មែរនោះ គឺមនុស្សទាំងនោះ ដែលគេឃើញត្រាច់ចរទៅមក ស្លៀកដណ្ដប់សំពត់ពណ៌លឿង ប្រកបដោយដំណើររម្យទម ហើយថ្លៃថ្នូរណាស់ ។ មនុស្សទាំងនោះគឺ បព្វជិតពុទ្ធ-

សាសនិក ឬលោកសង្ឃ ។

លោកសង្ឃ មានច្រើនណាស់នៅប្រទេសខ្មែរ ។ នៅពេលមកដល់, អ្នកដំណើរបរទេស តែងជួបប្រទះលោកសង្ឃ ទាំងនៅទីក្រុង ទាំងនៅស្រុកស្រែ ។ តួលេខជាផ្លូវការផ្ដល់អោយដោយក្រសួងធម្មការ ចង្អុលប្រាប់ថា បច្ចុប្បន្ននេះ ក្នុងព្រះរាជាណាចក្រទាំងមូល មានលោកសង្ឃ ៣៧.៥៣៣ អង្គ គង់នៅក្នុងបណ្ដាវត្ត ២.៦៥៣ (១) ។

ជនជាតិខ្មែរដែលចូលសាងផ្នួស មិនប្រកាសថាបួសអស់មួយជីវិតនោះទេ ។ គេបួស ហើយគេសឹកពីផ្នួសវិញ តាមចិត្តគេចង់ ។ ប៉ុន្តែថា, ប្រពៃណីមួយដែលប្រហែលត្រូវបានគេកាន់តាមយ៉ាងម៉ឺងម៉ាត់រហូតមកដល់បច្ចុប្បន្ន តម្រូវអោយយុវជនចូលទៅនៅវត្ត សាងផ្នួសមួយរយៈកាល ។ ក្នុងពេលថ្មីៗនេះ, យុវជន ត្រូវទៅនៅវត្ត តាមធម្មតាពីមួយឆ្នាំទៅបីឆ្នាំ ។ ប្រពៃណីនេះ មានគោលដៅសន្សំកុសលសម្រាប់ជាតិក្រោយ, កាលពីបុរាណកាល វាបានផ្ដល់អត្ថប្រយោជន៍ជាពិសេសអោយយុវជនបានសិក្សា និងទទួលការអប់រំបានល្អប្រសើរ ។

ចំពោះកូនប្រជាជនកាលពីជំនាន់ដើម ប្រពៃណីនៅវត្ត សាងផ្នួសនេះ គឺជាមធ្យោបាយតែមួយគត់ សម្រាប់រៀនអក្សរអោយចេះអាន ចេះសរសេរ ។ ដោយសារការអនុវត្តនេះជាទូទៅ, ទើបនៅប្រទេសខ្មែរ គ្មានអនក្ខរជនភេទប្រុសឡើយ ។

ហើយដោយសារបានទទួលការអប់រំនេះនៅក្នុងវត្ត, ទើបជនជាតិខ្មែរមានចិត្តគំនិតជឿសាសនា និងមានការគោរពដ៏ចម្លែកចំពោះលោកសង្ឃ ។

គ្មានកន្លែងណាងាយស្រួល និង ឆាប់រហ័សជាងនៅប្រទេសខ្មែរឡើយ,

(១) នេះជាស្ថិតិលោកសង្ឃ និងវត្ត ក្នុងឆ្នាំ ១៩៤៩ ។ មុនឆ្នាំ ១៩៧០ លោកសង្ឃ មាន ៦៥.០៦២ អង្គ និងវត្ត ៣.៣៦៩ ក្នុងទូទាំងប្រទេស ។ តាមស្ថិតិជាផ្លូវការ ក្នុងឆ្នាំ ១៩៩៤ ត្រឹមខែមីនា មានលោកសង្ឃ ៣២.៤៤៩ អង្គ និងមានវត្ត ៣.១៩៦ ( ឈ.អ ) ។

បើគេចង់ប្រមូលប្រាក់កាសអោយបានសន្ធឹកសន្ធាប់ សំរាប់អំពើជាកុសល, សំរាប់ធ្វើទាន ប្រគេនលោកសង្ឃ, សម្រាប់កសាងវត្ត, កសាងសាលាបាលី ។

ឥទ្ធិពលលោកសង្ឃ មកលើប្រជារាស្ត្រខ្មែរ មានកំឡាំងធំធេងណាស់ ។ រូបកាយលោកសង្ឃ ត្រូវបានគេចាត់ទុកថាជាវត្ថុពិសិដ្ឋ និង ពុំអាចបំពារបំពានបានឡើយ ដរាបណាលោកសង្ឃនោះនៅតែទ្រទ្រង់ស្បង់ចីពរ ។ សូម្បីតែលោកសង្ឃមួយរូប បានប្រព្រឹត្តឧក្រិដ្ឋកម្ម, ក៏គេត្រូវតែសុំអោយផ្សឹកឧក្រិដ្ឋជននោះ ជាមុនសិនទើបអាចប្តឹងចោទប្រកាន់ទៅតុលាការបាន ។

គេមិនអាចនិយាយទៅកាន់លោកសង្ឃ ដូចជានិយាយទៅកាន់មនុស្សធម្មតានោះទេ ។ ដូចគ្នានេះដែរ, ដើម្បីនិយាយទៅកាន់ព្រះរាជា និងទៅកាន់ក្សត្រាក្សត្រី, ជនជាតិខ្មែរត្រូវប្រើភាសាមួយដោយឡែកជាដាច់ខាត, ក៏ដូចគ្នានេះដែរ ដើម្បីនិយាយទៅកាន់លោកសង្ឃ ជនជាតិខ្មែរត្រូវប្រើវាក្យសព្ទដោយឡែក ដែលពុំមែនជាវាក្យសព្ទប្រើសម្រាប់មនុស្សទូទៅ ហើយដែលជាវាក្យសព្ទជិតទៅភាសាក្នុងវាំង ។

លោកសង្ឃ ត្រូវបានរួចផុតពីបន្ទុកសាធារណៈគ្រប់យ៉ាង, លោកសង្ឃមិនរួមចំណែកក្នុងកិច្ចការគ្រប់គ្រងរដ្ឋទេ, ហើយមិនបោះឆ្នោតទេ ។ ជាគោលការណ៍, លោកសង្ឃមិនធ្វើនយោបាយទេ ។ លោកសង្ឃមិនអាចប្តឹងគេឡើងតុលាការ ហើយក៏មិនអាចធ្វើជាសាក្សីនៅសាលាជម្រះក្តីដែរ ។

លោកសង្ឃ មិនត្រូវប្តឹងពីគេទេ សូម្បីរូបលោកត្រូវបានគេជេរប្រមាថ, ត្រូវបានគេវាយប្រហារ ឬត្រូវបានគេលួចយកទ្រព្យសម្បត្តិ ក៏ដោយ ។

ដើម្បីបានបួសទៅជាភិក្ខុ, សាមណេរត្រូវមានព្រះជន្ម ២០ វស្សាបរិបូរ ។ បេក្ខសមណៈនោះ ត្រូវមានសេចក្តីយល់ព្រមពីឪពុក ម្តាយ ហើយ, ប្រសិនបើមានប្រពន្ធ, ត្រូវមានសេចក្តីអនុញ្ញាតពីប្រពន្ធរបស់ខ្លួន ។ បេក្ខសមណៈនោះ មិន

ត្រូវធ្លាប់បានសម្លាប់ (មនុស្ស) ឬលួច (ទ្រព្យសម្បត្តិ) ហើយត្រូវធ្វើអោយបានជាទីពេញចិត្ត នូវសំណួរទាំងឡាយ ដែលចៅអធិការវត្ត (ឧបជ្ឈាយ៍) បានចោទសួរ ដូចតទៅនេះ :

- អ្នកមានអាយុម្ភៃឆ្នាំ ហើយឬ ?
- អ្នកមានបាត្រ សម្រាប់ទៅសុំមានអាហាររបស់អ្នក ហើយឬ ?
- ស្បង់ចីពរសម្រាប់ភិក្ខុភាវៈរបស់អ្នកគ្រប់គ្រាន់ ហើយឬ ?
- អ្នកមានដំបៅ មានផ្លក (abcés) នៅលើខ្លួន ឬទេ ?
- អ្នកមានកើតស្រែង ឬទេ ?
- អ្នកមានកើតកមរមាស់ ឬទេ ?
- អ្នកមានកើតរោគឫសដូងបាត ឬទេ ?
- អ្នកមានកើតជំងឺឃ្លង់ ឬទេ ?
- អ្នកឯងជាខ្ញុំគេ ទេឬ ?
- អ្នកជាមនុស្សប្រុស ឬ ?
- អ្នកបានទទួលការយល់ព្រមពីឪពុកម្ដាយ ឬពីនាយចៅហ្វាយ ហើយឬ ?
- អ្នកមានជំពាក់បំណុលគេ ឬទេ ?
- អ្នកមានជាប់ព្រះរាជកំណែនដែរ ឬទេ ?
- អ្នកជាមនុស្សពិតប្រាកដ, ពុំមែនជាយក្ស ឬនាគ ទេឬ ?

ការចូលក្នុងសហគមន៍សង្ឃ ត្រូវបានហាមឃាត់ ដោយពុំអាចតវ៉ាបានចំពោះជនណាដែលបានសម្លាប់ (មនុស្ស) ឬដោយគ្រាន់តែបានលួច (ទ្រព្យសម្បត្តិគេ) ។

ជនពុំមែនជាពុទ្ធសាសនិក អាចត្រូវបានអនុញ្ញាតឱ្យបួសជាបព្វជិតបាន ។ ហេតុដែលគ្រាន់តែបានអានរូបមន្តសុំចូលសហគមន៍ (សង្ឃ) មានន័យថា ជននោះ

បានលាអំពីសាសនាផ្ទាល់របស់ខ្លួនរួចហើយ ។

ការចូលបួសក្នុងពុទ្ធសាសនារបស់យុវជនម្នាក់ បង្កើតបានជានាក ដ៏គួរអោយចាប់អារម្មណ៍ចងចាំណាស់ ។ ដំបូង គ្រួសាររបស់យុវជនរៀបចំបាយទឹកជូនព្រៀងលាន ញាតិមិត្ត ។ រួចដល់ថ្ងៃកំណត់, យុវជនត្រូវបានគេដង្ហែទៅកាន់វត្តដោយជិះលើខ្នងសេះមួយ ដែលគេបានបំពាក់គ្រឿងលំអយ៉ាងប្រណីត ឬមិនប្រណីតទៅតាមមាន ឬ ក្រ ។

នៅលើស្មាឆ្វេងរបស់យុវជន, មានក្រមាទេសឯកពណ៌ស ពានាពាក់ឈៀង ដែលសំគាល់ថា យុវជននោះបានចាកចេញពីជីវភាពជាគ្រហស្ថហើយ ។ មនុស្សប្រុសម្នាក់ កាន់ខ្សែបង្ហៀរសេះ, មនុស្សប្រុសម្នាក់ទៀត កាន់ក្លស់បាំងពីលើក្បាល ។ ក្រុមគ្រួសារ ញាតិមិត្រ រៀបជាក្បួនដង្ហែពីក្រោយ ដោយមានដៃកាន់ទេយ្យទានសម្រាប់វត្តផង ។ ក្រុមអ្នកភ្លេង លេងបន្ទរតាមសង្វាក់ដើរ, ចំណែកអ្នករាំពាក់មុខយក្ស ប្រដាប់ដោយដំបង និងដាវ កំពុងរាំចាក់ក្បាច់ក្រមាច់ក្រមើម នៅពីខាងមុខក្បួន ដែលហាក់ដូចជារាំងមិនអោយក្បួនធ្វើដំណើរទៅមុខបាន ។ ការរៀបរាប់លំអិតទាំងអស់នេះ ដូចជាការហូបចុក, សេះ អ្នកកាន់បង្ហៀរសេះ គឺសម្រាប់តែរំលឹកឡើងវិញ នូវកាលៈទេសៈដែលព្រះពុទ្ធអង្គឯង បានចាកចោលជីវ-ភាពគ្រហាវាស ។ ពួកអ្នករាំក្លែងខ្លួនជាបីសាច (យក្ស) បង្ហាញនូវការវាយប្រហារដែលកងទ័ពមារបានធ្វើចំពោះព្រះពុទ្ធ ។

មុនពិធីបំបួសចាប់ផ្ដើម, នវមាមកជន (នាគ) ត្រូវជ្រើសរើសឧបជ្ឈាយ៍ដោយខ្លួនឯង ។ លោកសង្ឃជាឧបជ្ឈាយ៍ គឺជាព្រះថេរៈដែលមានអាយុផ្នួសយ៉ាងតិចដប់វស្សាឡើងទៅ ។ ដល់ថ្ងៃកំណត់ ឧបជ្ឈាយ៍នឹងជួយឧបត្ថម្ភនវមាមកជន ក្នុងឋានៈជាអ្នកបំបួស ហើយនិងឋិតនៅជាមគ្គុទ្ទេសក៍ខាងស្មារតីរបស់ភិក្ខុថ្មីនោះ,

ទទួលបន្ទុកជាអ្នកប្រៀនប្រដៅ អោយលុះក្នុងផ្លូវសង្គ្រោះ ។ គឺឧបជ្ឈាយ៍នេះហើយ ដែលអោយត្រៃសរណគមន៍ និងអោយសីល ១០ របស់ព្រះពុទ្ធដល់អ្នកបួសថ្មី ។

ដើម្បីកំណត់ឋានានុក្រម ថ្នាក់ ដែលភិក្ខុត្រូវប្រកាន់យក នៅក្នុងសហ-គមន៍សង្ឃ ថ្ងៃនិងម៉ោង (ខែ ឆ្នាំ) នៃការបួសរបស់នវភិក្ខុ ត្រូវបានកត់ត្រាទុក យ៉ាងម៉ត់ចត់ ។

ពិធីបំបួស ពុំមែនចេះតែធ្វើឡើងនៅរដូវណា ក៏បាននោះទេ, ប៉ុន្តែ ប្រ-ព្រឹត្តទៅបានតែនៅក្នុងខែខ្មែរ ពិសាខ, ជេស្ឋ និងអាសាឍ ពោលគឺ សម័យកាល ចាប់ផ្ដើមពីថ្ងៃទី ១៥ មេសា ដល់ថ្ងៃទី ១៥ កក្កដា ប៉ុណ្ណោះ, ហើយចំពោះឆ្នាំដែល មានដប់បីខែវិញ (១), រហូតទៅដល់ថ្ងៃទី ១៥ សីហា គឺមានន័យទៀតថា នៅពេល មុនរដូវវស្សា (រដូវភ្លៀង) ដែលជាសម័យកាលម្យ៉ាង តមសាច់ (សម្រាប់សាសនា កាតូលិក) មានរយៈពេលបីខែ ហើយដែលធ្លាក់ចំរដូវភ្លៀង ។ គឺជារដូវធ្វើបុណ្យទាន យ៉ាងប្រពៃ ។ នៅក្នុងសម័យកាលនេះ លោកសង្ឃ មិនអាចធ្វើដំណើរឆ្ងាយ ឬសឹក បានទេ ។

* * *

ក្នុងការទទួលសាងផ្នួស, យុវជន ត្រូវតាំងចិត្តកាន់ខ្ជាប់នូវសីល១០ របស់ ពុទ្ធសាសនា ដែលមានដូចតទៅ :

១. មិនសម្លាប់,

២. មិនលួច,

៣. មិនប្រព្រឹត្តមិច្ឆាចារ ផ្ទុយនឹងសីលធម៌,

៤. មិននិយាយកុហក,

---

(១) ខែខ្មែរ គិតតាមចន្ទគតិ គឺមានពី ២៩ ទៅ ៣០ ថ្ងៃ ។ ដើម្បីទូទាត់ការយឺតយ៉ាវ បណ្ដាលមកពីគិតបែបនេះ, គេត្រូវបន្ថែមខែទីដប់បី ប្រហែលជានៅពេលបីឆ្នាំម្ដង ។

៥. មិនផឹកទឹកស្រវឹង,

៦. មិនបរិភោគខុសពេលអនុញ្ញាត,

៧. មិនមើលទស្សនីយភាព ដែលធ្វើអោយវិញ្ញាណស្រើបស្រាល ដូចជា របាំ ចម្រៀង ភ្លេង,

៨. មិនប្រើប្រាស់គ្រឿងតែងខ្លួន, ទឹកអប់, អលង្ការ ទាំងមិនលំអខ្លួនដោយផ្កា,

៩. មិនប្រើប្រាស់អាសនៈខ្ពស់ ឬគ្រែធំ,

១០. មិនប៉ះពាល់មាស ឬប្រាក់ ។

សីលទាំងដប់នេះ គឺជាករណីយកិច្ចតម្រូវដាច់ខាត សម្រាប់អ្នកបួសទាំងអស់, មានតែគ្រហស្ថទេ អាចទទួលកាន់សីលប្រាំ ខាងដើមបាន ។

គឺដោយសារតែសីលទីមួយ ដែលហាមឃាត់មិនអោយបំបាត់ជីវិតសត្វនោះហើយ ទើបលោកសង្ឃមិនអាចធ្វើការងារស្រែចំការបាន ។ ក្នុងពេលជីកកកាយដី, លោកអាចសម្លាប់ជន្លេន ឬ សត្វល្អិត ដែលរស់នៅក្នុងដី(១) ។

ដោយសារតែការហាមឃាត់នេះ ទើបមានចំនួនឆ្កែអាវ៉ាសែ និងឆ្មា ជាច្រើន ដែលគេយកមកប្រោសចោលក្នុងរបងវត្ត ។ លោកសង្ឃប្រោសប្រណី ផងដែរ នូវសត្វចង្រៃ និង សត្វល្អិតមានពិស, ខ្លា, ពស់, ក្អែប, ខ្ទួយ ។

សីលទីបី តម្រូវអោយលោកសង្ឃឋិតនៅក្នុងព្រហ្មចរិយភាព ជាដាច់ខាត, លោកត្រូវជៀសវាងសម្លឹងមើលស្ត្រី និងស្រីក្រមុំ, មិនត្រូវឋិតនៅក្នុងបន្ទប់ម្នាក់ឯងជាមួយស្ត្រី ហើយត្រូវជៀសពីផ្លូវស្ត្រី ប្រសិនបើផ្លូវនោះស្ងាត់ ។

គ្រហស្ថត្រូវចៀសវាងផិតក្បត់ចិត្តស្វាមី ឬភរិយា (អតិចរិយា), អបាយ-

(១) គប្បីបន្ថែមថា វិន័យហាមមិនអោយភិក្ខុកាប់ដើមឈើ និង ជីកច្រូសស្មៅ ផងដែរ ។

មុខ, កាមតណ្ហា ផ្ទុយពីធម្មជាតិ ។ ម៉្យាងទៀត,គេត្រូវវៀរចាកមេថុន (មេថុនវិរតិ) ក្នុងថ្ងៃសីល ។

គេមិនអនុញ្ញាតអោយអ្នកបួសភ្លក្សភេសជ្ជៈបិតមានមេ (មេរ័យ) ប៉ុន្តែគេយល់ព្រមជាទូទៅថា កាលណាស្រាប្រើជាវត្ថុផ្សំជាថ្នាំ ជាមួយនឹងសារជាតិថ្នាំមួយទៀត, លោកសង្ឃមានអាពាធអាចឆាន់បាន ។ ឧទាហរណ៍, ករណីស្រាកាំងគីណាប្រើសម្រាប់ព្យាបាលជំងឺគ្រុនចាញ់ ។ ភេសជ្ជៈធម្មតារបស់លោកសង្ឃ គឺតែ ។

លោកសង្ឃ តាមធម្មតាឆាន់ចង្ហាន់ពីរដង ក្នុងពេលព្រឹក ។ បន្ទាប់មកចាប់ពីម៉ោង១២ថ្ងៃត្រង់ រហូតដល់ព្រឹកស្អែក, លោកសង្ឃមិនត្រូវឆាន់ចង្ហាន់ឡើយ ប៉ុន្តែថា ទឹកផ្លែឈើខ្លះ ត្រូវបានគេអត់ឱន ដូចជាទឹកផ្លែក្រូចពោធិ៍សាត់ច្របាច់ ឬទឹកអំពៅ ដែលគាបហើយ ។

លោកសង្ឃមិនត្រូវមើលរបាំ មិនត្រូវស្តាប់ចម្រៀង និងមិនត្រូវស្តាប់ភ្លេង ។ ទោះជាមានការហាមឃាត់នេះ វត្តជាច្រើន តែងមានវង់ភ្លេងតូចមួយសម្រាប់កំដរពុទ្ធសាសនិកជន ដែលមកចូលរួមក្នុងពិធីបុណ្យសាសនា ។

ជាទូទៅ, លោកសង្ឃសឹង (ដេក) នៅលើកន្ទេលធម្មតា ក្រាលនៅលើក្តារនៃកុដិ ។ នៅស្រុកស្រែ គេអាចមើលឃើញកុដិទាំងឡាយទទេស្អាត គ្មានទូ តុ គ្មានកៅអី គ្មានគ្រែទេ ។ នៅភ្នំពេញវិញ កុដិទាំងឡាយច្រើនតែមានគ្រឿងសង្ហារិមមានទូមួយ និងមានបណ្ណាល័យមួយ ។ ជាការណ៍ពិត, គ្រឿងសង្ហារិមទាំងនោះ គឺជាអំណោយរបស់សប្បុរសជនប្រគេន ។

គេហាមមិនអោយអ្នកបួស គង់នៅលើអាសនៈខ្ពស់ ។ គង់បានតែចំពោះធម្មកថិកសំខាន់ៗ ប៉ុណ្ណោះ ។ លោកឡើងគង់ ដោយមានជើងវាយផ្ទែននៅលើគ្រែទេសន៍ ដែលមានកំពស់ ៧០ សង្ទីម៉ែត្រ ។

លោក មិនត្រូវទទួលយកប្រាក់សម្រាប់ខ្លួនដោយផ្ទាល់ទេ, ប៉ន្តែ លោក

លោកអាចទទួលយកសម្រាប់វត្តបាន ។

មែនហើយ, ខ្ញុំបានជំរុញយ៉ាងទទូចអោយអ្នកចូលមកមើលវត្ត ដាក់ប្រាក់កាសបន្តិចបន្តួច មុនគេចាកចេញទៅ, ដូចដែលគេធ្លាប់បានធ្វើសម្រាប់ព្រះវិហារគ្រីស្ត ដូច្នោះ ។ ខ្ញុំគ្រាន់តែបង្គាប់គេថា កុំអោយដាក់ប្រាក់ក្នុងដៃលោកសង្ឃ, ប៉ុន្តែ ទុកប្រាក់នោះនៅក្បែរអាសនៈព្រះ ឬ ហៅកូនក្មេងលោកមកទទួល (តែងមានកូនក្មេងជានិច្ចនៅក្នុងវត្ត ហើយប្រគល់ប្រាក់អោយទៅក្មេងទៅ ) ។

នៅស្រុកសៀម, លោកសង្ឃពុំមានការក្រែងល្អែងដើម្បីទទួលយកប្រាក់ដែលទេសចរណ៍បរទេសហុចអោយលោកនោះទេ ។

***

លោកសង្ឃត្រូវកោរព្រះកេស ( សក់ក្បាល ), ពុកចង្ការ និងរោមចិញ្ចើមទាំងអស់ចេញ ។ លោកកោរពីរដងក្នុងមួយខែ គឺនៅថ្ងៃបន្ទាប់ចុងបំផុតខាងខ្នើត នឹងថ្ងៃបន្ទាប់ចុងបំផុត ខាងរនោច ។ លោកសង្ឃនិមន្តជើងទទេ, ប៉ុន្តែអាចការពារកំដៅថ្ងៃ ដោយឆត្រជាទូទៅមានពណ៌ស ឬ ពណ៌លឿង ។ មានបទបញ្ញត្តិអោយលោកសង្ឃដើរជើងទទេ, ប៉ុន្តែ ក្នុងការជាក់ស្តែង, គេបានអត់ឱនអោយពាក់ស្បែកជើងផ្ទាត់បាន បើសិនជាស្បែកជើងនោះមានពណ៌ និងមានទ្រង់ទ្រាយបែបណាមួយ ( សមស្រប ) ។

កាលជំនាន់ដើម, ស្បង់ចីពរលោកសង្ឃ ត្រូវបានដេរធ្វើពីកំណាត់សម្លៀកបំពាក់រហែករយ៉ីរយ៉ៃរើសតាមផ្លូវ និងមានពណ៌ធូលីដី ។ ចាប់ពីនេះហើយទើបស្បង់ចីពរឥឡូវនេះ មានពណ៌ដី ឬ ពណ៌លឿង ។ គឺដើម្បីរំលឹកកំណាត់សំពត់រយ៉ីរយ៉ៃនេះទៀត, ទើបចីពរដែលលោកសង្ឃដណ្តប់ មិនត្រូវបានដេរ ធ្វើឡើងភ្ជាប់គ្នាជាថ្មី ។

លោកសង្ឃ ត្រូវក្រោកពីសំណឹង ពីព្រលឹមស្រាងៗ ។ វត្តធំមួយ នៅក្នុងសង្កាត់របស់ខ្ញុំ, នៅពេលម៉ោងប្រាំកន្លះព្រឹក, តែងបន្លឺស្គររគាំងជាច្រើនអន្លូង ។ កាលបើឮសញ្ញានេះ លោកសង្ឃទាំងឡាយតើនឡើង ។ ខ្ញុំឃើញលោកសង្ឃទាំងនោះ និមន្តចេញទៅលប់លាងខ្លួន និងស្រង់ទឹកនៅម៉ាស៊ីនទឹកមួយ ដែលអាចមើលឃើញតាមចន្លោះរបងបរិវេណ ។ បន្ទាប់មក លោកសង្ឃទាំងនោះ និមន្តបាត់ទៅដើម្បីទៅថ្វាយបង្គំព្រះ ឬ បោសសំអាតបន្ទប់កុដិរបស់លោក ហើយដោយមានលោកនេន ( សាមណេរ ) ជួយផង លោកបោសសំអាតទីធ្លាវត្តទៀត ។

នៅប្រមាណម៉ោងប្រាំពីរ, លោកសង្ឃបានចេញពីវត្តជាជួរ ដើម្បីបិណ្ឌបាតចង្ហាន់ ។ លោកនិមន្តពីក្រោយគ្នាបន្តបន្ទាប់ ដោយមានទឹកព្រះភក្ត្រសមរម្យ, ភាវនាធមិដោយព្រះនេត្រសម្លឹងចុះ, គ្រងចីវរពណ៌លឿងយ៉ាងផ្ចិតផ្ចង់ ដែលធ្វើអោយដំណើររបស់លោកថ្លៃថ្លាពេកណាស់ ។ លោកសង្ឃទាំងនោះ កាន់នៅក្នុងដៃ ឬស្ពាយលើស្មាឆ្វេងដោយមានខ្សែ នូវបាត្រសម្រាប់អោយពុទ្ធបរិស័ទដាក់ចង្ហាន់ចូល ។

កាលណា ការបិណ្ឌបាតចប់ហើយ, លោកត្រឡប់មកវត្តវិញ ដើម្បីថ្វាយបង្គំព្រះ និងឆាន់ចង្ហាន់បន្តិចបន្តួច ។

មុនពេលចាប់ផ្ដើមឆាន់ចង្ហាន់, លោកតែងបាចចំណីអាហារបន្តិចអោយទៅសត្វដែលចោមរោមលោក ដូចឆ្កែ, ឆ្មា, ហើយក៏មិនភ្លេចអោយចំណីដល់សត្វបក្សាបក្សីដែរ ។

ក្រោយពេលចង្ហាន់ព្រឹកទីមួយនេះរួច ដែលមានរយៈពេលខ្លីណាស់ផង, លោកសង្ឃទាំងឡាយចេញទៅកាន់មុខរបររបស់លោក ។ លោកខ្លះ បង្រៀនដល់លោកនេន (សាមណេរ) អោយចេះអាន ចេះសរសេរ, ហើយបើមានសាលារៀននៅក្នុងវត្ត, លោកក៏ជួយបង្រៀនដល់កូនចៅអ្នកស្រុកផងទៀត ។ លោកខ្លះទៀត

សិក្សាអត្ថបទបាលី, សូត្រធម៌ថ្វាយបង្គំព្រះ ឬក៏ស្មឹងស្មាធិ៍ (ធ្វើសមាធិ), លោកខ្លះទៀត ដោយមានលោកនេនជួយផង, បានធ្វើការជួសជុលវត្តអារាម ។

គឺនៅម៉ោងដប់មួយកន្លះ ទើបលោកសង្ឃឆាន់ចង្ហាន់លើកទីពីរ និងលើកចុងក្រោយប្រចាំថ្ងៃ ។ លោកឆាន់ដោយព្រះហស្តស្តាំ ដោយមិនកាន់ចានមករកមាត់ដូចជនជាតិចិនស៊ីបាយនឹងចង្កឹះនោះទេ ។ លោកឆាន់តែទឹកបន្តិចបន្តួច ។ ឆាន់ចង្ហាន់រួចរាល់ហើយ, លោកលាងព្រះហស្ត និងជម្រះព្រះឱស្ឋ ។ លោកត្រូវដុសលាងព្រះទន្ត (ធ្មេញ) យ៉ាងម៉ត់ចត់ ដើម្បីកុំអោយមានសំណល់អាហារជាប់ទៅនឹងព្រះទន្ត (ធ្មេញ) ហើយអោយព្រះឱស្ឋរបស់លោកបាត់ក្លិនរសជាតិនៃអ្វីដែលលោកទើបតែនឹងឆាន់រួច ។

យើងបាននិយាយរួចហើយថា លោកសង្ឃនឹងមិនឆាន់ទៀតទេ រហូតដល់ថ្ងៃស្អែក ។ សូម្បីនៅពេលចុះទៅសួរសុខទុក្ខ (ក្នុងភូមិ), លោកក៏មិនអាចទទួលឆាន់ស្ករ នៅពេលថ្ងៃរសៀលបានដែរ ។

ក្រោយពេលចង្ហាន់នេះ, លោកអាចថយទៅក្នុងបន្ទប់ ឬកុដិ ហើយសម្រាក ( សឹង ) រហូតដល់ម៉ោងពីរ ។ នៅពេលនោះ លោកក៏បានបន្តការងារដូចកាលនៅពេលព្រឹកដែរ ។

ដើម្បីការពារខ្លួនទល់នឹងចំណង់ទៅរកអំពើអាក្រក់, កាលណាលោកសង្ឃអង្គណាមួយ ត្រូវចេញទៅក្រៅវត្ត សូម្បីទៅសួរសុខទុក្ខញាតិញោម ក៏ដោយ, លោកអង្គនោះ ត្រូវតែមានសហភាគរះមួយអង្គតាមទៅជាមួយ ។ លោកមិនអាចចូលទៅក្នុងផ្ទះមួយអង្គឯង ឬ និយាយទៅកាន់មនុស្សស្រីម្នាក់ឯង ឬក៏ និមន្តទៅតាមផ្លូវតែមួយ ជាមួយមនុស្សស្រី បើផ្លូវនោះស្ងាត់ ។

កាលពីដើម, គេហាមលោកសង្ឃមិនអោយចេញក្រៅវត្តទេ នៅពេលយប់, វៀរលែងតែក្នុងករណីបន្ទាន់, ដូចជាត្រូវបានគេនិមន្តអោយទៅព្យាបាលអ្នក

ជំងឺ ។ ប៉ុន្តែ បញ្ញត្តិនេះ ហាក់ដូចជាត្រូវបានគេបន្ធូរបន្ថយហើយ, យ៉ាងហោចណាស់ក៏នៅក្នុងទីក្រុងភ្នំពេញដែរ ។

ទោះជាដូច្នោះក៏ដោយ, ក៏អ្នកបួសជាតិខ្មែរ, បើពិនិត្យជាទូទៅ, តែងប្រកបដោយសីលធម៌ដ៏សុក្រឹតណាស់ ។ គឺនៅក្នុងស្រុកខ្មែរ លើសលប់ជាងនៅក្នុងរដ្ឋកាន់ពុទ្ធសាសនាឯទៀត, ដែលគេសង្កេតឃើញមានលោកសង្ឃ ដ៏គួរអោយជាប់អារម្មណ៍បំផុត ដោយសារលោកមានមេត្តាធម៌, មានចរិយាសុភាពរាបសារ, មានការផ្តាច់ព្រះទ័យពីការជាប់ជំពាក់ក្នុងទ្រព្យសម្បត្តិនៃលោកនេះ ។

គេអាចមើលឃើញផងដែរ, ជាពិសេស នៅក្នុងបណ្តាវត្តអារាមតាមខេត្ត, នូវមនុស្សប្រុសស្រី ដែលច្រើនតែជាចាស់ៗ ស្លៀកពាក់ស ។ នោះគឺជាអ្នកកាន់សីល ភេទជាគ្រហស្ថ ដែលមានប្រាថ្នាកាន់សិក្ខាបទពុទ្ធសាសនា យ៉ាងតឹងរ៉ឹងដោយមិនចាំបាច់បួស ។

បច្ចុប្បន្ននេះ, គ្មានអ្នកបួសភេទស្ត្រីពិតប្រាកដនៅប្រទេសខ្មែរទេ ម្យ៉ាងទៀត អ្នកបួសភេទស្ត្រី នៅគ្រប់កាលៈទេសៈមានតិចតួចណាស់ ។ ទ្រឹស្តីពុទ្ធសា-សនា ក្នុងបណ្តាទ្រឹស្តីជួយសង្គ្រោះ ( សត្វលោក ) ទាំងអស់ គឺជាទ្រឹស្តីមួយដែលសំដែងការស្អប់យ៉ាងខ្លាំងចំពោះស្ត្រីភេទ ។ ប្រពៃណីបានពណ៌នាថា ការអោយស្ត្រីចូលបួស ត្រូវបានអនុញ្ញាតជាមួយនឹងការទើសទាល់យ៉ាងខ្លាំងបំផុត ដោយព្រះពុទ្ធ-អង្គឯង ដែលនៅទីបំផុត ព្រះអង្គបានយល់ព្រមតាមពាក្យអង្វររបស់ព្រះមាតាចិញ្ចឹមរបស់ព្រះអង្គ គឺព្រះនាងមហាបជាបតី, និងតាមអន្តរាគមន៍សុំរបស់សាវ័ក ជាទីគាប់ព្រះទ័យរបស់ព្រះអង្គ គឺព្រះអានន្ទ ។

ប៉ុន្តែ គេអាចប្រដូចស្ត្រី ដែលគេហៅថាដូនជី ទៅនឹងអ្នកបួសភេទស្រីបាន ។ ដូនជី គឺជាអ្នកជឿស៊ប់ក្នុងសាសនា (ធម្មនិដ្ឋា) ដែលស្លៀកពាក់ស កោរក្បាលហើយដែលរស់នៅកាន់សីល និង ប្រព្រឹត្តតបកម្មតឹងរ៉ឹង ដូចជាការរស់នៅរបស់

លោកសង្ឃដែរ ។ តែងតែទៅកាន់វត្តយ៉ាងជាប់លាប់, ដូនជីបានបំពេញសេវភាពតូចតាចចំពោះព្រះសង្ឃ, ដូចជាតុបតែងអាសនៈព្រះ, ធ្វើការងារដេរប៉ះ ជាដើម ។ ប៉ុន្តែថា ដូនជីស្នាក់អាស្រ័យនៅក្រៅបរិវេណនៃវត្តទេ[(១)] ។

***

ថ្វីបើពុទ្ធសាសនា ត្រូវបានគេចាត់ទុកថា ជាសាសនាគ្មានអាទិទេព[(២)] ក៏ដោយ, ក៏ប្រជាជនខ្មែរតែងអង្វរករព្រះពុទ្ធ, បន់ស្រន់ព្រះអង្គ និងថ្វាយគ្រឿងសក្ការៈចំពោះព្រះអង្គ ។ វាជាការណ៍ពិតណាស់ ចំពោះមនុស្សម្នាជាប្រជាជន, ព្រះពុទ្ធ គឺជាព្រះអាទិទេព ដែលគេតែងអំពាវនាវសុំជំនួយពីព្រះអង្គ ដែលគេសង្ឃឹមថា ព្រះអង្គ នឹងអាណិតអាសូរជួយគេ តាមរយៈការអង្វរករ និងគ្រឿងតង្វាយ ។

ប៉ុន្តែថា ការគោរពបូជាតាមបែបពុទ្ធសាសនា បើប្រៀបធៀបទៅនឹងសាសនាដទៃទៀត គឺមានពិធី (rites) តិចតួចទេ ។ម្យ៉ាងទៀត នៅក្នុងពិធីបុណ្យទានភាគច្រើនដែលមានចរិតសាសនា, ព្រះសង្ឃបានចូលធ្វើអន្តរាគមន៍តិចជាងអាចារ្យ ដែលជាអ្នកធ្វើពិធីបន់ស្រន់ក្រៅសាសនាផង និងជាម្ចាស់នៃពិធីបុណ្យផង ។

វាគ្មានអ្វីគួរអោយប្រៀបផ្ទឹមទៅនឹងបុណ្យម៉ែស (Messes) របស់យើង (គឺរបសគ្រីស្តបរិស័ទ) បានទេ ។ លោកសង្ឃមិនមែនជាអ្នកធ្វើពិធីដ៏សកម្ម

(១) កាលសម័យនោះ (ឆ្នាំ១៩៤៩) ដូនជីសង់ផ្ទះ ឬខ្ទមក្រៅបរិវេណវត្ត ដើម្បីរស់នៅប្រកបដោយធម៌ និងធ្វើការបំរើព្រះសង្ឃ មិនដូចកាលសម័យបច្ចុប្បន្ននេះទេ, ទាំងដូនជីទាំងពុំមែនដូនជី ដណ្តើមកាន់កាប់ជីវត្ត កុដិ សាលា រហូតដល់វិហារ ដើម្បីធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួន និងរស់នៅយ៉ាងច្រឡោងខាម និងឥតអៀនខ្មាស ។ (ឈ.អ)

(២) Cf à ce sujet. *Evolution de la pensée bouddhique* par le Docteur F. Martinie in France-Asie Nos 19, 20 et 21.

ខាងអាថិកំបាំងពិសិដ្ឋ ឬខាងពលីការសាសនាទេ ។ តាបស ទើបជាអ្នកសកម្មក្នុងការងារនេះ, ដ៏ជាគំរូមួយនៃជីវភាពអ្នកបួស ។ កាលណាលោកសង្ឃចូលរួមធ្វើអន្តរាគមន៍, គឺច្រើនតែតាមការសូត្រធម៌ប៉ុណ្ណោះ ។

វាមានថ្ងៃដែលតួនាទីជាគ្រូប្រៀនប្រដៅធម៌នេះ ត្រូវបានស្ដែងឡើងជាពិសេស ។ នោះគឺនៅថ្ងៃទីមួយ និងថ្ងៃទីប្រាំបីខាងរនោច[១] ។ ជនជាតិខ្មែរ ហៅថ្ងៃនោះថា ថ្ងៃសីល ។ ពាក្យសីល គឺជាពាក្យក្លាយពីបាលីថា សិលះ, « ករណីយកិច្ចរបស់អ្នកកាន់សាសនា, ការប្រតិបត្តិសាសនា » ។ ថ្ងៃសីល គឺជាថ្ងៃត្រូវប្រតិបត្តិតាមបញ្ញត្តិសាសនា ដែលស្របនឹងថ្ងៃឧបោសថនៃអត្ថបទបាលី ។

នៅថ្ងៃនោះ ការងារធម្មតារបស់វត្ត ត្រូវផ្អាក ។ ឧបាសក ឧបាសិកា ទៅកាន់វត្តយ៉ាងច្រើន ដើម្បីស្ដាប់ធម៌ និង ស្ដាប់ទេសនា ។ ស្ត្រីជាភាគច្រើនតែងនាំយកគ្រឿងតង្វាយ មានចំណីអាហារ, ផ្លែឈើ, ផ្កា, ធូប ទៅកាន់វត្ត ។

នៅពេលស្ដាប់ធម៌ទេសនា ដែលទូន្មានអោយពុទ្ធបរិស័ទចិញ្ចឹមជីវិតស្របតាមការប្រៀនប្រដៅរបស់ព្រះបរមគ្រូ, អោយប្រតិបត្តិតាមអោយបានល្អ នូវសីលទាំងប្រាំបីខាងដើម, ហើយអោយកាន់បានជាដាច់ខាត នូវសីលប្រាំខាងដើម, ពុទ្ធ-បរិស័ទទាំងឡាយ តែងមានអារម្មណ៍ចង់ក្លាយខ្លួនទៅជាមនុស្សប្រសើរ ។ នៅថ្ងៃនោះ គេតែងបង្ហាញខ្លួនគេថា ជាមនុស្សល្អ និងមានសប្បុរសធម៌យ៉ាងពិសេស ។ ខ្ញុំបានឃើញអ្នកខ្លះទិញសត្វចាបជាប់ទ្រុង ហើយបើកគ្រប់លែងចាបទាំងនោះ ទៅក្នុងអាកាស ។ គេខំចៀសវាងជម្លោះ និងពាក្យទ្រគោះបោះបោក ។ អ្នកមានជំនឿស៊ប់ក្នុងសាសនា មិនផឹកទឹកម៉េវយ ហើយអ្នកខ្លះទៀត តមមិនបរិភោគអាហារ ។

(១) តាមធម្មតា ថ្ងៃសីលមាន ៤ ដងក្នុងមួយខែ គឺថ្ងៃ ៨ កើត ៨ រោច, ថ្ងៃពេញបូណ៌មី និងថ្ងៃខែដាច់ ។ ទេស្នា ច្រើនតែរៀបចំឱ្យមាននៅថ្ងៃពេញបូណ៌មី និងថ្ងៃខែដាច់ប៉ុណ្ណោះ ។ (ឈ.អ)

ប៉ុន្តែ គប្បីបញ្ជាក់ថា នៅក្នុងឱកាសនោះ ស្ត្រីបានយកចិត្តទុកដាក់ជាពិសេស ប្រព្រឹត្ត ការតមអាហារ ហើយនាំគ្នាទៅស្វ្រតធម៌នៅវត្ត ។

ក្នុងបណ្ដាថ្ងៃទាំងបួននោះ, មានថ្ងៃពីរមានសារសំខាន់ជាពិសេស នៅក្នុង ជីវភាពសាសនា : ថ្ងៃចុងបំផុតខាងខ្នើត និងថ្ងៃចុងបំផុតខាងរនោច ។ ថ្ងៃនោះ គឺជាថ្ងៃដែលលោកសង្ឃបង្កើនទ្វេឡើងនូវតបកម្ម និងតមអាហារយ៉ាងតឹងរ៉ឹង, ត្រូវ បានគេកត់សម្គាល់ជាពិសេស ដោយការអានបាតិមោក្ខ ហើយនិងការសារភាព យ៉ាង ឱឡារិកសម្រាប់ភិក្ខុ នូវទោសកំហុសទាំងឡាយរបស់ខ្លួន (សំដែងអាបត្តិ) នៅចំ-ពោះមុខសហធម្មិកទាំងអស់របស់វត្ត ។

នៅពេលល្ងាច, ក្រោយពេលព្រះអាទិត្យលិច ភិក្ខុសង្ឃទាំងឡាយប្រជុំ គ្នានៅខាងមុខអាសនៈព្រះពុទ្ធរូប អង្គុយជុំវិញភិក្ខុដែលត្រូវអានបាតិមោក្ខ ហើយ រាប់អាបត្តិទាំងពីរយម្ភៃប្រាំពីរ ដែលមាននៅក្នុងរូបមន្តសំដែងអាបត្តិ ។

នៅពេលកំពុងរាប់នោះ, ភិក្ខុសង្ឃដែលដឹងខ្លួនថាបានប្រព្រឹត្តកំហុសណា មួយ ក្នុងបណ្ដាកំហុសទាំងនោះ, ចូលខ្លួនឆ្ពោះទៅរកព្រះចៅអធិការវត្ត ហើយក្រាប ថ្វាយបង្គំ ប្រកាសប្រាប់យ៉ាងឮអំពីអំពើបាបរបស់ខ្លួន ។ មេវត្តស្ដីបន្ទោសភិក្ខុនោះ ឬ ក៏ដាក់ទោសដល់ភិក្ខុនោះ, ឬក៏សុំអោយព្យួរទោស ឬមួយអោយបណ្ដេញចេញ (ផ្សឹក) ទៅតាមទម្ងន់នៃទោស ។

ការព្យួរទោស ឬការបណ្ដេញចេញភិក្ខុមួយរូប មិនអាចត្រូវបានប្រកាស សម្រេចដោយចៅអធិការវត្តបានទេ, ប៉ុន្តែ អាចប្រកាសសម្រេចបានតែតាមអាជ្ញា-ធរសង្ឃ ( Autorités ecclésiatiques ) ប៉ុណ្ណោះ ដែលយើងនឹងរៀបរាប់ នៅក្នុងអង្គការចាត់តាំង ។

ដោយលោក François Martini
in France-Asie N0 spécial 37-38
បកប្រែ **ឈន អៀម**

# ល្បើកអក្ខរវិធី

( ក )

២២៩- ទេវតាពីជន្ទប់អង្គ សោតសិងតែទ្រង

ដុំនិះទីទ្វៀអសក្តិយ ។

២៣០- ទេវតាខ្លាះជិះដីរ្យ ខ្លាជិះពាជី

ខ្លាះសោតជិះលើហរាជហង្ស ។

២៣១- ខ្លាះជិះកង្ហោកពេនតុង ខ្លាះសោតជិះអង្គ

នៀគាល់សហស្សលៀងភា ។

២៣២- ជិះរមាសជិះសិង្ហជិះខ្លា ខ្លាះជិះយក្សា

នាគ្គាគន្ទប់ទាំងឬារ្យ ។

២៣៣- សិងហោះចុះមកប្រញាយ ទីទ្វៀខ្វល់ខ្វាយ

សិងលើកពុំបានលើរ្យណា ។

២៣៤- ធ្លាក់រូបព្រះបាទរាមា ស្តេចមានចេស្តារ

ក៏លើកបានដូចបំណង ។

២៣៥- បាននាងសេតាដូចប៉ង មុះហិម្មាឯងហ្វោ

សំដែងនោវរិទ្ធប្រកដ្ឋ ។

២៣៦- ធ្លាក់ជាព្រះទធ្វារត្ន នាំមព្រះរាជ្ជបុត្រ

នោវបុត្រប្រសារត្រកូល ។

២៣៧- ពេិឮ្ហព្រះក្រុងរាពុប៉រម៉ីស្វូរ ចុះមកពុំឃូវ

ប្រក្ខុតប្រលុងចេស្តារ ។

២៣៨- លីគ្រើងព្រះទុំរុំងផ្កាញផ្កា នៅរកោវទាន់ម្នា
នាគ្គាំនៅនាគ្គបញ្ចង ។
២៣៩- ស្តេចបានធ្នូវនោះមុន្តទ្រង់ កោះកំាមបីដំរង
ពិព្រំមមាសវាំព្យផ្កាញផ្កា ។
២៤០- ក្រុងរាព្ភស្វរកាម៉ា លុះលុតវន្ទា
បង្គំមប្រណំមព្រះអង្គ ។
២៤១- ធ្លាក់ជាព្រះរាម្មស្តេចគុង នៅវស្ឋានកុំលុង
នគរស្រីព្រឹទ្ធយុធ្យា ។
២៤២-ហៀព្រះរាម្មនៅនាងសេតា ព្រះលក្ខ់អណុជ្ជា
ទាំងបីក៏ស្តេចចេញវៀ ។
២៤៣- ដើរទេសចេញចាក់ដលព្រៃ ស្វនធិកក៏ព្រៃ
ត្រមោចតែបីអង្គា ។
២៤៤- ធ្លាក់រូបមហាយក្សា រីវាន់មុះហិម្នា
ក៏ឆក់សេតានាំម្នរត្ត ។
២៤៥- ធ្លាក់រូបព្រះលក្ខ់ប្រកដ្ឋ ស្មោះតាមប្រយុធ់
ក៏បាននៅវព្រៃព្រឹក្សា ។
២៤៦- ធ្លាក់ជាព្រះរាម្មថ្លៃងសរ ភិរ្យាគ្គលុះមរ
កន្ទាល់នៃព្រៃព្រឹក្សាន ។
២៤៧- ធ្លាក់ជាព្រះលក្ខ់ប្រែបាន លោបងបួសបាន
ជាមហាឫស្សីថ្លៃថ្លារ ។
២៤៨- ធ្លាក់រូបនាងស្វរបណក្ខា ស្វែងស្វាះយាត្រា
សំណាក់ព្រះបាទពីរពុង្ស ។

២៤៩. លួងលោមចច្ចាចោត់ចង់ ស្មោះស្មានព្រះអង្គ
ត៍ត្រឹកនៅរកល់មាយារ ។

២៥០. ធ្លាក់ជាព្រះលក្ខ័ក្រោធ្ចា ក៏កាន់ខាន់ថ្លា
ក្រវិសហាសវិលវៀ ។

២៥១. ចិក់សក់ច្រុតច្រុំកាត់ដៀ អាស្រូវពេត្យក្រៀ
ហោវមហាទូវយស់មុះហិម្នា ។

២៥២. ធ្លាក់ទោះផែនផ្សាអាស្ងួព មកយកបាណ៌ក្លា
នាំមទោវដល់ព្រះនគរ ។

២៥៣. ធ្លាក់ជារូបមហាក្រុងខរ នាំពលរឹករវរ
ប្រញាប់ប្រ៉ៃយុធរឿនរ៉ង ។

២៥៤. ធ្លាក់ជាមហាខ្យុត្រពីពុង្ស ផ្កាញូអាស្ងូវ៉ាបង
វិនាសទាំងពលយោទ្ធា ។

២៥៥. ធ្លាក់ជាមហារឹកកាល៉ា ជាប្រើសមាសមហា
យាត្រានាខាងអាស្រ៉ម ។

២៥៦. ធ្លាក់ជាសេតាឪតំម លើកដៀបង្អឹម
អង្វរព្រះវៀមរាជ្ញា ។

២៥៧. ធ្លាក់ជារូបព្រះរាម្នា តាមប្រើសមាសណា
ក៏ត្រេចក្នុងភ្នំមគីរី ។

២៥៨. ធ្លាក់ជារូបរាត្តនាមិប្តី កាលោ៉ានោររីទ្ធី
ប្រែជាព្រាហ្មណ៍ព្រិទ្ធិសីល៉ា ។

២៥៩. ចូលឆក់រត្នរាជសេតា ហោះដៀវីប៉ា
ច្រលំមនឹងស្ងួរិយាទ្បៀ ។

២៦០. ធ្លាក់ជាជ្គតាយុងងន្សៃ កាងស្លាប់ខ្ពស់ក្រៃ
ស្រឡប់ង៉ងិតបាត់សុង ។
២៦១. ធ្លាក់ជារាពុ្កនាទ្រើសទ្រង បោះចិញ្ចៀនព្រះទុំរ៉ង
ក៏ត្រូវចំអេងជ្គតាយុះ ។
២៦២. បាក់ខ្លួបស្រយ៉ាបធ្លាក់ចុះ ក្រុងរាពុ្កហោះឆ្ពោះ
ក៏ដលនគរលុង្កា ។
២៦៣. ធ្លាក់ជារូបព្រះរាម្នា បាញ់ប្រើសកាល៉ា
អសុរក៏លុះម៉ខ្សៃ ។
២៦៤. ហើយធ្លាក់ជាព្រះអង្គថ្លៃ វិលវឹងមកន្សៃ
ពុំឃើញទីវឹតន្និតា ។
២៦៥. ត្រមោចតែពីអង្គារ សែនសោយសោកា
ក៏ស្ដេចត្រេចរកមហៃសៀ ។
២៦៦. ផ្កាំងម្ស្សនោះសោតអសក្ដី ធ្លាក់ជាទូភី
ប្រយុត់ប្រល៉ងនឹងបារ ។
២៦៧. ង្នៀងង្ហុផ្ទៀងផ្អងវេរា ផ្ទួលបាមរនា
កន្ទាល់លើហាមហាប្រថ្ពៀ ។
២៦៨. ហើយធ្លាក់ជារូបទូភី ត៏នឹងពាលៀ
ពាលីរ្យិទ្ធីលើសក្រៃ ។
២៦៩. ពាលីផ្ទួលទូភីខ្សៃ និតនោវព្រះព្រៃ
កុំលុងបរពត្តគោប៊ា ។
២៧០. ផ្កាំងម្ស្សនោះសោតធ្លាក់ជា ស្ងួគ្រីបឯងណារ
ក្ទួវគ្រងអស់មុក្ខមន្ត្រីយ ។

២៧១. ផ្ទាំងម្ប្យនោះសោតធ្លាក់ជា ពាលីរ្យមុះហិម្ពា
ក្រមាស្ពុយក្បាលទូភី ។
២៧២. ឆក់នាំងប្រឹងប្រានតំក្រី ចោលក្បាលទូភី
ទុំឈាបនៅផ្ទារគោប៉ា ។
២៧៣. ផ្ទាំងម្ប្យពាលីក្រោធ្វា និងស្វគ្រិបរាជ្ជា
ប្រយុធប្រយាត្តវីលវៀ ។
២៧៤. សិងមានកុំលាំងទីទ្យេ ខាស់ខ្មែងជាញ្ជៀ
ប្រជួបប្រចាប់សោះសា ។
២៧៥. ហិចហោះក៏កាន្ទ់ខាន្ត័ថ្វា ពាក់ពាន់នៅវត្មា
កន្ទាលអកាស័នុភី ។
២៧៦. ស្វគ្រិបថ្វាញដៃពាលី វត្តចូលគីរី
នៃក្ពាំមកតុងបុព្ពា ។
២៧៧. ឬផ្ទាំងម្ប្យនោះសោតណារ ជាព្រះរាម្ពា
ស្តេចព្រេច់តាមរកម្ពេស្យ ។
២៧៨. ពើពព្វះពានយក្ខ័អនិត្តិថ្យ ស្តេចមានបរម៉ុ
ក៏ផ្គួលន្មៀយក្ខ័មរនា ។
២៧៩. ហើ្យធ្លាក់ជាព្រះយាត្រា យាងយាសលីលា
រំលុងន្មៀយក្ខ័នោះទោវ ។
២៨០. ប្រទាះស្វគ្រីបយំមនោវ ហៀ្យនាំមព្រះទោវ
នគរខាះខិនប្ចូរី ។
២៨១. ផ្ទាំងម្ប្យស្វគ្រីបធិប្តីយ តំនិងពាលី
ប្រយុត្តកន្ទាលវីប៉ា ។

២៨២. ហើយធ្លាក់ជាព្រះរាម្នា ថ្លែងសរក្រុងពា-
លីលុះក័ខ្សែជីវិត ។

២៨៣. ផ្កាំងម្យជាព្រះសីលា នឹងអសពលស្វា
ចិត់សិបអាខោភីនី ។

២៨៤. ស្តេចដាក់ប្របផ្នែរនាទ្បី ទៀបជើងគិរី
នៃគុន្ធមាតបរិពត្ត ។

២៨៥. ផ្ទាំងម្យស្តែងស្តេចសន្ធត់ ត្រាសប្រើអង្គត់
ហានុមានមុះហិម្មា ។

២៨៦. ឱ្យទោវអញ្ជើញក្រុងមហា ជុំពូវរាជ្ជា
គិតរិះជុំនុំមច់ងថ្មល ។

២៨៧. ផ្ទាំងម្យនោះធ្លាក់អសកល ធ្វើជាមន្ទល
ប្រាសាទប្រសើដ្ឋពិចិត្រ ។

២៨៨. ធ្លាក់ជាហានុមានស្ទួយស្ទាត់ ទៃនទិព្វជពិចិត្រ
សៀវ៉សន្ទៀមហាជុំពូវ ។

២៨៩. ហោះទាន់អង្គត់នៅវផ្លូវ អង្គត់ឱបទោវ
នាស្ទាហានុមានឯងនៀ ។

២៩០. ផ្ទាំងម្យសោតធ្លាក់ល្អក្រៃ ជាព្រះបន្ទាវជៀ
សំដេច់ព្រះរាម្មរាជ្ជា ។

២៩១. ផ្ទាំងម្យនោះសោតធ្វើជា ស្តេចប្រែកាយ៉ា
ជាព្រះន្រៀសាក់សាធ្ន ។

២៩២. ធ្លាក់ជាជុំពូវនរនាដ្ឋ ប្រណំមក្រាបបាទ
ន្រៀរាម្មាទេពថ្លៃ ។

២៩៣. ផ្ទាំងម្សៅជាព្រះជេស្ឋជៀវ ស្តេចប្អូកហារទៀវ
ស្រណោះទេវីសោតា ។

២៩៤. ស្តេចប្រើហនុមានមុះហិម្ពា នាំមព្រះសន្ទរា
ទៅស្លរព្រះរាជទេវី ។

២៩៥. ធ្លាក់ជាហនុម៉ានជក្របី ហោះដៀវជុលធី
ក៏ទៅនគរលុង្ការ ។

២៩៦. ធ្លាក់ជាឥន្ទជិតមុះហិមា ថ្លែងសរនាគា
ក៏ចងហនុម៉ានជម្ទោ ។

២៩៧. ធ្លាក់ជាក្រុងរាព្វ៍មោហា កុំលោរម្វលហោ
ព្វំដឹងនឹងកើតអន្តរាយ ។

២៩៨. ចាញ់កលមាយាឱបា្យ លុះលាញខ្មាត់ខ្មាយ
វិនាសទាំងស្ឋានមន្ទល ។

២៩៩. ឬផ្ទាំងម្សៅធ្លាក់អសកល់ ធ្វើជាចងថ្នល
កន្តាល់នៃ្សមហាស្រមុទ្ទ ។

៣០០. ឬផ្ទាំងម្សៅសោតប្រកដ្ឋ ធ្លាក់ជាអង្គុត
ក៏នាំមនៅវសាព្រះន្រៀ ។

៣០១. អង្គុត់ជួបជលបន្ទាយ យកនង្គុត់វាតវ៉ា្យ
ក៏ផ្លាយបន្ទាយប្រកដ្ឋ ។

៣០២. ផ្ទាំងម្សៅធ្លាក់ជាអង្គុត់ ពេញពាះប្រយុធ
និងភក់គិនៀ្សមុះហិម្ពា ។

៣០៣. អង្គុត់សង្គត់សីរសា ផ្តាប់ផ្តល់ភស្សធ្ថា
ក៏យាព្រះខាន្តប៊ីសំមព៉ង ។

៣០៤- ហើយផ្លាក់ផ្ទាំងម្ស្យសោតហោង អង្គុត់ទ្រើសឃ្មង
ក៏ដលសាលាប្រកដ្ឋ ។

៣០៥- ឆ្លាក់ជាអាមាត្យម្ស្យរត្ន មកអញ្ជើញអង្គុត់
ក៏ទៀនប្រញាប់ទៅវថ្វាត់ ។

៣០៦- ផ្ទាំងម្ស្យឆ្លាក់ឆ្លៅវពីចិត្រ ជាប្រាសាទរត្ន
ភីមានក្រុងភាពប្រកដ្ឋ ។

៣០៧- ហើយឆ្លាក់ជាព្រះអង្គុត់ វិលវៀឆក់ម៉កដ្ឋ
អំពីព្រះសីរភាពនា ។

៣០៨- ផ្តេកផ្តោះហោះលើវីហ៊ា ក្រុងភាពមុះហិមា
ក៏ក្រោធពន្លឹកប្រជិយក្ន ។

៣០៩- ហើយឆ្លាក់ជាសេណាយក្ន សិងន្យអង្ក្រាក់
ទាំងប្អូនក៏ហោវបានក្លារ ។

៣១០- ហោះតាមប្រយុទ្ធសោះសា អង្គុត់មុះហិមា
ក៏ចាប់នោវជើងវាយភាត្ត ។

៣១១- ឆ្លាក់ជាក្រុងភាពខ្ទាលក្តាត់ ឱ្យបើកឆាត់រត្ន
ដៀបាំងស្រឡប់ស្វីយ៉ា ។

៣១២-ផ្ទាំងម្ស្យជាសូគ្រិបភាដ្ឋា នាំមអសពល់ស្វា
ទៅវកាច់រុំលាងឆាត់ដៀ ។

៣១៣- ឆ្លាក់ជាគំមភូកាលើសក្រៃ ខាស់ខែងវិលវៀ
ចាប់បានសូគ្រិបភាដ្ឋា ។

៣១៤- នាំមទោវថ្វ្យក្រុងភាពនា ហានុមានមុះហិមា
កាល៉ាផ្ទាប់នោវខ្លោងថ្វារ ។

៣១៥. ទោះត្រូវគំម្ហូកាដួលផ្កា សន្ធប់នៅវនា
កន្តាលប្រវាលប្រថ្ពី ។
៣១៦. ធ្លាក់ជារាព្ជ់នាធិប្ដី ឱ្យទ្ទងភិរី
ប្រាមអសមន្ត្រីយយោធ្ធា ។
៣១៧. ធ្លាក់រូបពីភេកអរាណុជ្ជា គន់គ្ងវហោរាចា
សំដែងនៅវក្សួនសាស្ត្រសៃ្យ ។
៣១៨. ធ្លាក់ជាក្រុងរាព្ភខ្វាលក្រៃ្យ ក្យក៏កាងដៀ្យ
បន់ដេញពីភេកអរាណុជ្ជា ។
៣១៩. ផ្ទាំងម្ស្យនោះសោតហោងណា លោក្យ៍ធ្លាក់ឆ្លោវជា
ពីភេករត្ថចូលទាព្វជៀ្យ ។
៣២០. ធ្លាក់ជាព្រះរាម្ឋទេព្វថ្លៃ ទ្រង់ក្ទូវណាក្រៃ
ទទួលពីភេកហោរ៉ា ។
៣២១. ផ្ទាំងម្ស្យធ្លាក់ជារាព្ភ៍នា ត្រាសប្រើយក៏្យា
នៅវរាក្ខសៃនចេញចរ ។
៣២២. ចូលចាំមព្រៃ្យព្រិក្សាករ ចាំមក្លាត់ពានរ
គឺបោក្ខបាក្ខសេណា ។
៣២៣. ផ្ទាំងម្ស្យសោតធ្លាក់ជាមហា រោក្ខរាក្ខមុះហិម្មា
ប្រយុធនៅវរាក្ខសៃនខ្ធរ ។
៣២៤. ឯពលយក្ខ៏សៃននីករ ពះពលពានរ
ប្រាំមម៉ឺនប្រយុត្ធខែងខំម ។
៣២៥. ដកដើមព្រឹក្សាគាល់ដិម ខ្លះស្ទុះស្ទួយភ្ញុំម
ប្របោកប្របែកភ្លើងច្រាល ។

៣២៦- ពានរាំរុករានដេញដាល់ ស្អុតស្លាប់ក្រាស់ក្រាល
រុង្គាតរុង្គាល់ទាំងព្រៃ ។

៣២៧- ធ្លាក់ជាក្រុងរាព្អ៍អ៊ីក្រែ ទាះក៏កាងដៃ
ក៏ទ្រូងអំមពរភូសា ។

៣២៨- ផ្ទាំងម្ប្សក្រុងរាព្ភមុះហិមា បេិកឆាត្រជៃយា
បាំងឱ្យង្ហូធិតពានរ ។

៣២៩- ធ្លាក់ជាព្រះរាម្មថ្លែងសរ អរិទ្ធិចន្ទ័បវរ
វិលាងវិលិមឆាត់ដៃ ។

៣៣០- ផ្ទាំងម្ប្សក្រុងរាព្ភក្រោធក្រៃ ប្រើអាមាត្យនៃ្យ
អញ្ជើញគិមភូកាមកណារ ។

៣៣១-ផ្ទាំងម្ប្សគិម្ភការាជ្ជា លើកទាព្វ៍លីលា
ព្រះរៀមស្តេចយលអស្ចារ ។

៣៣២- ផ្ទាំងម្ប្សធ្លាក់ជាគិម្ភកា ធាត់ធំមសាម្មា
ប្រយុត្តនិងព្រះលក្ស៊្មា ។

៣៣៣- ព្រះលក្ខ័ថ្លែងសរក៏ផ្លា ផ្តួលគិមភូការ
ក៏លុះអំណាច់ព្រះអង្គ ។

៣៣៤- ផ្ទាំងម្ប្សឥន្ទរជិតឆោមយុង ថ្លែងសរបាញ់បង
សូពាន៍ក៏ជានាគិា ។

៣៣៥- ពាន្ទ៍ពាកព្រះលក្ខ៍អាណុជ្ជា នោវអសពល់ស្វា
ក្រញោន៧ទីទៃ្យ ។

៣៣៦- ផ្ទាំងម្ប្សព្រះរាម្មខ្វាលក្រៃ្យ កាច់កោវទាន្ទ៍ដៃ្យ
និងបោះឱ្យឆែះសូគិា ។

៣៣៧. ធ្លាក់ជាក្រុធរាជមុះហិមា ហិចហោះមកណា
ក៏នាគនោះវត់ខ្ចាត់ខ្ចាយ ។

៣៣៨. ផ្ទាំងម្សៅព្រះលក្ខ័ពន្រ្យ ទ្រើសទ្រង់រិទ្ធីសាស្រ្ដ
ក៏ទ្រងកោវទាន់សរថ្លា ។

៣៣៩. ផ្ដលឥន្ទ្ររជិតយក្ស៍ា កន្ដាល់ភក្សថ្លា
វិនាសទាំងពល់យក្ខយុង ។

៣៤០. ផ្ទាំងម្សៅសោតធ្លាក់ជាក្រុង វាត់ក្រោធ៍បទប៉ង
ព្រះរាជ្ជបុត្រច្បងណា ។

៣៤១. ទស្សមុក្ខសែនសោស្យសោក់កា ក៏កាន់ខាន់ថ្លា
ក៏ហ្វូតមហាក្រិយ ។

៣៤២. យក្ខកាន់សីរសាខ្សត្រី សេតាទីរ
ប៉ុនប៉ងពីយាជឱ្យមរ ។

៣៤៣. ផ្ទាំងម្សៅធ្លាក់ជាមហាសរ លើកពល់ចេញចរ
ប្រយុត្តនៅវអង្គុតណា ។

៣៤៤. អង្គុតក៏កាន់ខាន់ថ្លា ផ្លាញមហាសរណា
ក៏លាញវិនាស់អន្ដរាយ ។

៣៤៥. ធ្លាក់ជាក្រុងមហាអគ្គិក្សា នៅវព្រះលក្ខពន្រ្យ
ក៏ពីប្រយុត្តនៅវគ្នា ។

៣៤៦. ព្រះលក្ខ័ទ្រងស័ផ្លាញផ្លា ផ្ដលអគ្គិក្សមហា
យក្ស៍ានៅវពល់នាស់ន្សៃ ។

៣៤៧. ផ្ទាំងម្សៅធ្លាក់ជាត្រីសីរ លើកពល់មកមីរ
សំញើញសំញៀងរឿនរុង ។

៣៤៨. ធ្លាក់ជាព្រះរាមស្តេចតុង កៅវទាន្ទបីដីរ៉ង
បុនប៉ងទទួលយក្សា ។

៣៤៩. ធ្លាក់ជាពីភេកហោរ៉ា បង្គំមរាជ្ជា
ស្ងមយាត់ព្រះរាមស្តេចឈ្យប់ ។

៣៥០. ផ្ទាំងម្ប្យធ្លាក់ជាឪសុប្ប៍ ហានុម៉ានប្រត្តិរុព្វ
ប្រយុត្ធនៅវត្រីសីរណា ។

៣៥១. ត្រីសីរថ្លែងសរសាក្កថ្លា ហានុមានមុះហិមា
ឪសុបក៏ស្ទុះចូលចាប់ ។

៣៥២. បានកៅវទាន្ទ៍ទាញបីក្រល៉ាប់ វិលវៀងឆ្វេងឆាប់
សំម្លាប់អសុរត្រីមុក្ក ។

៣៥៣. ផ្ទាំងម្ប្យធ្លាក់ជាវនតុក្ក លេិកពលគ៍គ្រុគ
ក៏កាន្ទកៅវទាន្ទសរថ្លា ។

៣៥៤. ធ្លាក់ជាពីភេកសេណា ក៏កាន់ខាន្ទថ្លា
ទទួលប្រយុត្ធរឿនរុង ។

៣៥៥. ពីភេកស្ទុះស្វែងដុត្រនង ពាះអង្គនៅវអង្គ
ក៏ដួលនៅវវាលមរនា ។

៣៥៦. ផ្ទាំងម្ប្យធ្លាក់ជាមហា ក្បាលធំមមុះហិមា
ក្រទាក៏កាន់ដិបង ។

៣៥៧. ឪសុប៍សេណារទ្រើសឃ្មង កាន់ខាន្ទបីសំពង
ក៏ពាះប្រយុត្ធមុះហិម្មា ។

៣៥៨. ពាក់ពានប្រវានផងគ្នា ឪសុប់មុះហិម្មា
ក្រទាក៏ផ្តួលមហាក្បាល ។

៣៥៩. ផ្ដាំងម្ស្យជាទស្សមុក្ខមារ ម៉ីមីជាប់ជាល់
ក៏កាន់ដិបងផ្គារងរ ។

៣៦០. ធ្លាក់ជាក្របិនកែស្សរ កាន់ខាន្តុំចេញចរ
ទទួលប្រយុត្តសោះសារ ។

៣៦១. ក្របិនកែស្សមុះហិម្មា ផ្តលទស្សមុក្ខណា
វិនាសទាំងពលយក្ខ័យស់ ។

៣៦២. ផ្តាំងម្ស្យជាមុក្ខរាក្ខខាស៍ លើកពលគ្រែលក្រាស
ក៏កាន់ដិបងបង្វិល់ ។

៣៦៣. ធ្លាក់ជារូបមហាខុន្ទិល ក៏កាន់ដិបងពេជ្ជម្មី
ប្រយុត្តនៅមុក្ខរាក្ខា ។

៣៦៤. ខុនីលវៀវខែងខា ផ្តលមុក្ខរាក្ខា
ក៏លុះខ្សិនខ្សែមរនា ។

៣៦៥. ផ្តាំងម្ស្យធ្លាក់គុំក្រមា សរឯងមុះហិម្មា
ក៏កានដិបងគួរស្វែង ។

៣៦៦. ធ្លាក់ជាខុន្ទិលជាញជែង កាន់ដិបងខាះខែង
ទទួលប្រយុត្តយក្សា ។

៣៦៧. ខុន្ទិលរឹងមុក្ខមុះហិម្មា ផ្តលកុំក្រមា
ធារាវិនាសខ្សិនខ្សែ ។

៣៦៨. ផ្តាំងម្ស្យសោតធ្លាក់ជានៀ ហ្វាលចាក់លើសក្រៀ
ក៏កាន់ដិបងក្រវិយ ។

៣៦៩. ធ្លាក់ជារូបក្បាំពាលី កាន់ខាន្ទុំជ្យេស្ស្រៀ
ទទួលប្រយុត្តយក្សា ។

៣៧០. សត្វពាលីរិទ្ធីមុះហិម្នា មុត់មហាយក្សា
វិនាសសាប់សូនអសហៀ ។

៣៧១. ទស្សមុក្ខមាឯឯឥតត្រៀ ឥតពុំនាក្ខ់លឿ
វិនាសសូនសោះដូរអាសា ។

៣៧២. រំពឹងទន្ទឹងពលមារ ពីក្រោវចក្រវាល
ក្រោមបាទសូមៃនា្យណា ។

៣៧៣. ផ្ទាំងម្ប្បជាព្រះរាម្នា ស្តេចមានចេស្តា
រិទ្ធីបរម៉ីសោតសំម ។

៣៧៤. ស្តេចគុងលើហស្វគ្រីបឱដិម ហ៊ាក្សាស្គុះស្គួយភ្នំម
ពន្លីកនោវរិទ្ធីប្រក់ដួ ។

៣៧៥. ឆ្លាក់ជាភាព្យ់គុងរាជរថ់ ទិមសិងប្រែប្រត់
ប្រយុត្តនិងព្រះនរបុ្តី ។

៣៧៦. ហោះផ្សងកន្តាលនុភ្សី សៃណាសេណៀ
អាណោកអសុរដ្ឋទាហាន ។

៣៧៧. សេណាសោតសិងតែមាន ជុំនិះសព្វប្រាន
ដៀអង្គអាសុរដ់សេណី ។

៣៧៨. ខ្លាះជិះសឹងសារាជ្ជសី ជិះគោរដឹរី
ជិះតោរ៉មាសម្ហឹង្សា ។

៣៧៩. ជិះគោរមៀងមីសកា លៀងភាត៉ា
បារម្ហាំប្រើសទ្រាសី ។

៣៨០. ជិះគុជជិះលាពាជី ជិះហង្សឥន្ទ្រីយ
ជិះខ្លារ៉មាស់ភ្លើងច្រាល ។

៣៨១. ជិះសីហ្ននាត់នៅវនាដ្ឋនា ជិះជុំកាភារ
កែលីននៅវខ្សិនមន្ត្រ ។

៣៨២. ជិះខ្ទីងឌីតាសឌីតជិះសរ រង្កានូវម្ភរ
នូវមៀមពាក់ព្រៃចរណី ។

៣៨៣. ខ្លះជិះសន្ទតកាកីរ្យ ម៉ាំស៊ាំរាជ្ជសី
ភិមខ្សៀនូវត្រៀសិង្កា ។

៣៨៤. ខ្លះជិះកង៉ាំកល៉ោ ខ្លះជិះចាំម៉្រោ
ប្រដាប់ជុំនិះគ្រុឌ្ឋប្រាន ។

៣៨៥. ខ្លះជិះអាត្តីយលវន្ត៍ អង្គអាត្តីយស្បាន់
គីសឹងនៅវស្ថានដូប្រកដ្ឋ ។

៣៨៦. ខ្លះជិះខ្លាទិមរាជ្ជវត្ត មក្ខនាយដ៏ប្រកដ្ឋ
អាណៃកអាស្វូរកាល៉ោ ។

៣៨៧. ស្ញើញស្ញិញញ្ញើញញ្ញទាន្ទា ចង្កមផ្លាញផ្លា
ប្រទើសប្រទៃងច្រូងច្រាង ។

៣៨៨. ប្រៀវប្រត់បរបទវីវាង ក្រ្យាក់អូតអាង
សំពៀងសំបើរ្យមដពន្លឹក ។

៣៨៩. ពលស្វាមុះហិម្មាឥភ្លឹក ចច្ចូលចាប់ចិក
យក្សាកន្ត្រាក់កាន់ខ្ជាប់ ។

៣៩០. យក្ខយស្ស៊ីខែងខាស់ចាបកាប់ ស្វាំប្រែក្រលាប់
ចំម្បាប់តន្ទ្រិមអារុណ ។

៣៩១. ពានរបាស្ស៍ពេត្យក្តាត់ សិងគុងនីរពាត់
ពុំចុតពុំទ្រុតដលម្ប្ស ។
៣៩២. យក្ខ័សោតខាះខែងខំមជួយ យក្ខ័ពីស្វា១
ជ្រោមព្រួតប្រចាប់សោះសា ។
៣៩៣. ពានរវិលវៃមុះហិមា ជេិងជាន់យក្ស៍ា
នោះសង្កត់ទាល់ដីរ្ស ។
៣៩៤. ដៃ្សពីចាប់ចិកសីរសី យក្ខ់ម្ប្សលើកស៊ី
ក្រវាសក្រវីបោក់ខ្ចាត់ ។
៣៩៥. ចោលចុះយក្ខ់ដួលញញមាត់ ជេិងធាក់យក្ខ់ខ្ចាត់
ក៏ដួលទាំងពីស្លាប់ស្លឹង ។
៣៩៦. យក្ខ័ខ្លះក៏កាន់លំពែង ស្វាចាប់សំពៀង
ក្រវីក្រវាសយក្ខ់ដួល ។
៣៩៧. ស្វាខ្លះចាប់ជេិងយក្ខ់យួរ ខ្លះចាប់ករមួល
ច្រមិញច្រមុចជាន់ដីយ ។
៣៩៨. ស្វាខ្លះចាប់ចិកសីរស៊ៀ បង់ហាត់ហៀដីយ
ក្រវីក៏កេរខាំមក្បាល ។
៣៩៩. ស្វាខ្លះពារពាះខាំមថ្កាល់ ស្វាខ្លះមាក់ង្វារ
ក៏ខាំមនៃ្យឆ្អឹងចំនីរ្ស ។
៤០០. ខាំមមុក្ខមាត់ពាក់ជេិងពី ខ្លះខាំក៏កេរ
ជេិមភ្លោវសន្ទាក់ស៉សៃ្ស ។
៤០១. ស្វាខ្លះខាំជេិងខាំមដៃ្ស ស្វាខ្លះខាំមផ្ទៃ
ក្រញៀក្រពៀងមិកមួល ។

៤០២. ស្វាខ្លះស្ទុះស្ទាត់ចាប់ផ្តួល ខាំមផងថង់ហួរ
យក្សាស្រូវទាងស្លុតស្លាប់ ។

៤០៣. យក្សខ្លះក្រដូវថ្ងូលចាប់ ស្វាប្រែប្រក្រឡាប់
ចំបាប់បោក្ខយក្សសន្លប់ ។

៤០៤. ស្វាខ្លះជុសជៀងដាល់តប់ ខ្លះច្រានប្រទុញ
ប្រទាះប្រពានដំប្រពាក់ ។

៤០៥. ខ្លះចាប់កាន់កៀកករយក្ស ខ្លះឆក់កន្ត្រាក់
ដៃវៀយក្សបំបាក់សោះសា ។

៤០៦. យក្សខ្លះបាក់ខ្នងបាក់ស្មា ស្លុតស្លាប់លើគ្នា
គុន្ទាពុំបានលើរហោង ។

៤០៧. ស្វាខ្លះកាន់ខាន្តបីសំពង ខ្លះកាន់នោវដិបង
ក្រវែងក្រវាសដុក្រវិ ។

៤០៨. ស្វាខ្លះចូលចាប់សីង្ឃី ខ្លះចាប់គោប្សិ
ចាប់តោរមាសល្បៀងភាទ្បៃ ។

៤០៩. ខ្លះចាប់ម្ចាំស្វាំរាជ្ជសី ខ្លះចាប់ដំរី
ជន្លែងប្រភេជមុះហិមា ។

៤១០. ស្វាខ្លះដៃឱបចាប់លា ស្វាខ្លះចាប់ខ្លា
ក៏ពានក៏កេរឃ្មួរយោះ ។

៤១១. ខ្លះហែកទាញទុងបន្ទោះ ដៀរដៃកត្បុះ
សង្កត់សង្កិនញាំមញើយ ។

៤១២. បែនបុក់ច្រចាច់កិតជ្បៀ ជាន់ផ្ចាប់ផ្ចាល់ដី
ក្រវិក្រវែងឥតប្រម៉ាណ ។

៤១៣. ខ្លះកាច់រាជរថអស្សយាន ខ្លះសោតលោតខាំម
កងកាំមក៏បាក់ដុំបុទ ។

៤១៤. ខ្លះស្ទុះភេចយក្ខដុំប្រកដ្ឋ ធ្លាក់ពីរាជរត្ត
ប្រយុតប្រចាប់ផងគ្នា ។

៤១៥. អស្វរធាត់ធំមក្រទា រឹងរូសហាន់ក្លារ
ប្រយុតប្រយាតនៅវកុំលាំង ។

៤១៦. ខ្លះខែងជាញជែងរូសរាំង ប្រកួតប្រណាំង
ប្រទាះប្រទូសរិលវែយ ។

៤១៧. ពល់ស្វាមុះហិម្មានិរភៃ្យ សិងហ៊្វិកហ៊្វិជៃ
ម្មោម្មាះរិទ្ធិផង ។

៤១៨. ចាប់ដីរីគុជសីនៅវសឹង កាងក៏ដ៏សន្ធឹង
ក៏រឹងឆក់ឆ្វលបាទទា ។

៤១៩. ចាប់ចោលទោរលើហាយក្សា បាក់ក៏បាក់ស្មា
បាក់ខ្នងបាក់ជើងបាក់ដៃ្យ ។

៤២០. ក៏មុក្ខខ្ចាត់ទោរទីទៃ្យ ស្តុតស្លាប់ពេក្យក្រៃ
រំង្ហោករំងោលរំតែល ។

៤២១. ខ្លះដួលផ្លុះផ្លាស្សពោះទ្រេល រំនាប់រំនែល
ប្រពាន់ប្រពាក់លើបាគ្នា ។

៤២២. យក្ខខ្លះខែងខាស៍មុះហិមា ស្ទាស្ទុះបីក្រទា
ប្រច្វប់ប្រចាប់ចុងដៃ្យ ។

៤២៣. ស្វាសោតក្រេវក្រោធជាញជៃ្យ ខាះខែងរិលវៃ្យ
លោតចាប់ពានលើយលផ្ទើង ។

៤២៤. ខ្លះពាន់ពាត់ជើងនឹងជើង ជ្រៀសោតប្រឹងលើង
ប្រចាប់ប្រកាប់និព្វរត្ន ។

៤២៥. ប្រចាប់តន្ទើមអារុណ៍ ឆក់ឆាប់វៀស្ទាត់
ក្រលេកក្រឡាប់ក្រវី ។

៤២៦. ស្វាខ្លះចូលចាប់ដីរី សង្កត់ហៀជ្ជីយ
បង្វិលសំរុញសំរុក ។

៤២៧. ស្វាខ្លះពាពះឈមមុក្ខ ទុងទាញដកភ្លក់
បង់ហាត់ដីរីដួលទ្រោម ។

៤២៨. ពះយក្ខ័ប្រជីយុត់ត្រលោម ចំម្បាំងចំណោម
អធិកពន្លិកមុះហិម្មា ។

៤២៩. អសសៃណាពល់ពានរា ស្ទាស្ទុះចាប់សរ
អារុណ៍អសុរសៃណា ។

៤៣០. ចាប់បានកិនកាច់សោះសារ គ្រុព្វអស់ទាំងស្វា
ចំបាំងទាព់ស្រូចក្រាស់ក្រៃ ។

៤៣១. ស្វាខ្លះក៏កាន់ទង់ជៀ ខ្លោះខ្លាំងវិលវៀ
ផ្លេកផ្លោះក៏ហោះត្រដូច ។

៤៣២. ក្រសោបចាប់សរកាច់ក្ដូច់ ពុំឱ្យលេងរួច
ប្រដួចខាំមកាច់និងមាត់ ។

៤៣៣. យក័្សានិងស្វាសិងស្ទាត់ ប្រយុតប្រយាត់
ប្រចាក្ខប្រកាប់ច្រើនក្រៃ ។

៤៣៤. បាក្ខដូចរូបរសរីសៃ ក្បួរក្បាច់ដ្ឋប្រពៃ
ចំលាក់ចំលោវវេច្ចណារ ។

(នៅមានត)

# ជីវប្រវត្តិ
# អ្នកព្រះភិរម្យភាសា អ៊ូ ហៅ ង៉ុយ
## ( ១៨៦៥ - ១៩៣៦ )

( ស្រាវជ្រាវដោយ **យី ធន់** )

អ្នកព្រះភិរម្យភាសា អ៊ូ, ឈ្មោះពេញ **អ៊ុក អ៊ូ** ហៅ **ង៉ុយ** កើតនៅ គ.ស ១៨៦៥ ( ព.ស ២៤០៨ ) នៅភូមិព្រៃអណ្តូងស្វាយ ឃុំកំបូល ស្រុកភ្នំពេញ, ខេត្តកណ្តាល ។

- បិតាលោកនាម *អ៊ុក* ធ្វើមេឃុំកំបូល មានគោរម្យងារ ជា " ចៅពញាធម្មធារា " ។ ចៅពញា អ៊ុក ជាប់ជាសាច់ញាតិនឹងម្ចាស់អង្គប៉ុក ។

- មាតាលោកនាម *អៀង* ជាបុត្រីរបស់ចៅពញា ម៉ុក មេឃុំស្ពានថ្ម ស្រុក ខេត្តជាមួយគ្នា ។ មាតា និងបិតាលោក ត្រូវជាបងប្អូនជីទួតមួយនឹងគ្នា ។ លោកជាកូនទីពីរនៅក្នុងគ្រួសារ ។

កាលពីនៅវ័យកុមារ លោកបានរៀនសូត្រលេខនព្វន្ត អក្សរសាស្ត្រ នៅវត្តអង្គបឹងចក ភូមិបែកស្គរ ឃុំបែកចាន ក្នុងស្រុកកំណើតរបស់លោក ។ កុមារ អ៊ុក អ៊ូ ជាក្មេងម្នាក់ឧស្សាហ៍រៀនសូត្រ ។ លោកបានបួសជាសាមណេរ នៅក្នុងវត្តនោះ ។ ប៉ុន្មានឆ្នាំក្រោយមក លោកបានលាចាកសិក្ខាបទ ទៅបំរើមាតាបិតា ហើយបានធ្វើជាស្មៀនរបស់ឪពុកលោក ក្នុងការដើរហូតពន្ធស្រូវអាជ្ញាហ្លួង ។ លុះអាយុបាន ២១ ឆ្នាំ លោកបានបំពេញឧបសម្បទាជាភិក្ខុ នៅក្នុងវត្តដដែល ដោយមានព្រះឧបជ្ឈាយ៍នាម *សាស់* និងលោកគ្រូសូត្រស្តាំនាម *ជ្រក* ជាកម្មវាចា, លោកគ្រូ

សូត្រឆ្វេងនាម *អ៊ុង* ជាអនុស្សាវរីយ៍ ។ ភិក្ខុ *អ៊ូ* បានរៀនសូត្រធម៌អាថ៌ និងរៀនប្រែព្រះត្រៃបិដក ដំបូងក្នុងសំណាក់លោកគ្រូអាចារ្យ " ទិត្យ " នៅវត្តអង្គបឹងចក ។ បន្ទាប់មក លោកបានស្វែងរករៀនវិបស្សនាកម្មដ្ឋាន ក្នុងសំណាក់លោកអាចារ្យជាច្រើនកន្លែងទៀត ។ លោកបានគង់ក្នុងផ្នួសជាភិក្ខុបាន ៥ ឆ្នាំ ។ លុះចេះដឹងល្មមប្រើការបានហើយ លោកបានលាចាកសិក្ខាបទ មកប្រកបជីវភាពជាគ្រហស្ថវិញ ។ ក្រោយពេលលោកចាកផ្នួសមក លោកបានជួយធ្វើការឪពុករបស់លោក ដែលជាមេឃុំដោយមានងារជាក្រមផងជាស្មៀនផង ។ ដល់ពេលស្រុកភ័ន្តប្រែ លោកលាឈប់លែងធ្វើការរាជការ ហើយរស់នៅជាកសិករធម្មតា ។

លោកជាអ្នកមានវោហារលែបខាយ ប្រាជ្ញាវាងវៃ ចេះចាំរឿងរ៉ាវ ពីបុរាណ១ ទាំងគតិលោក ទាំងគតិធម៌ជាច្រើន ព្រមទាំងចេះច្រៀង ចេះភ្លេង និងជាអ្នកចម្រៀងខ្សែដៀវយ៉ាងចំណាន ធ្វើអោយកសិករឯទៀតស្រឡាញ់រាប់អានទុកលោកជាអ្នកប្រាជ្ញក្នុងភូមិស្រុក ហើយគេនិយមហៅលោកថា "ភិរម្យង៉ុយ" ។ លោកភិរម្យង៉ុយ មានមាឌធំ ដុះក្បាលពោះ កាត់សក់ជ្រងខ្លី ទុកពុកមាត់ខាងលើ និយមស្លៀកសំពត់ចងក្បិន ពាក់អាវកត្រង់ ឡេវធំ ពាក់ស្បែកជើងផ្ទាត់ និងមួកសំបុក ។ ពេលដើរទៅណាមកណា លោកមានបង្វិច និងឈើច្រត់កាន់ ជានិច្ច ។ ពេលលោកសូត្រកំណាព្យ លោកតែងដេញខ្សែដៀវកំដរ ។ ខ្សែដៀវរបស់គាត់អាចដោះចេញពីគ្នា ហើយតម្លើងបានភ្លាម១ កាលណាគាត់ត្រូវការប្រើ ។ ពេលណា លោកត្រូវការច្រៀង លោកស្រាយបង្វិចយកឃ្លោក សាដៀវមកផ្គុំនឹងឈើច្រត់បានជាដង ជាផ្លែ ហើយដាក់ខ្សែ រួចផ្ទាប់នឹងពោះ ធ្វើផឹតប៉ោង១ ហើយដេញយ៉ាងពិរោះ ។

ពេលរដូវរំហើយ ក្រោយពីការងារស្រែចំការបានចប់សព្វគ្រប់ លោកតែងត្រូវបានប្រជាជនអញ្ជើញអោយទៅច្រៀង ឬ ទេសនា ក្នុងពេលមានបុណ្យ

មាន ពីភូមិមួយទៅភូមិមួយ ។ លោកមិនបានទារប្រាក់កំរៃឈ្នួលពីប្រជាជនទេ ប៉ុន្តែ ដោយសេចក្តីគោរពស្រឡាញ់ ប្រជាជនតែងប្រមូលបច្ច័យ ស្រូវអង្ករជូនលោក តាមសទ្ធា ។ ពេលធ្វើដំណើរឆ្លងកាត់ក្រុងភ្នំពេញ លោកតែងឈប់សំចតនៅវត្ត ឧណ្ណាលោម ហើយឆ្លៀតពេលនោះ ដើម្បីពិគ្រោះពិភាក្សាជាមួយសាមណេរ ភិក្ខុ-សង្ឃ អំពីបញ្ហាផ្សេងៗដែលទាក់ទងនឹងព្រះពុទ្ធសាសនា ។

ក្នុងការច្រៀងក្តី ទេសនាក្តី លោកតែងលើកយកបញ្ហាដែលជាបច្ចុប្បន្ន-ភាពក្នុងពេលនោះ មកធ្វើជាប្រធានបទ ដូចជាច្រៀង :

- អំពីការប្រកបមុខរបររកស៊ីធ្វើស្រែចំការ,
- អំពីការជ្រើសរើសពូជស្រូវ,
- អំពីភាពក្រីក្រតោកយ៉ាករបស់ប្រជាជន និង មូលហេតុរបស់វា,
- អំពីអវិជ្ជា អនក្ខរភាពរបស់ប្រជាជនខ្មែរ,
- អំពីភាពស្ពឹកស្រពន់ មិនសកម្ម ស្ទាបាប់ខាងធ្វើពលកម្មដាំដុះ,
- អំពីការបែកបាក់សាមគ្គី ឈ្លោះទាស់ទែងតែគ្នាឯង ទាំងគ្រហស្ថ ទាំងអ្នកបួស,
- អំពីការជិះជាន់សង្កត់សង្កិនរបស់បរទេស មកលើប្រជាជនខ្មែរ,
- អំពីការបាត់បង់ឯករាជ្យ និង អត្តភាពខ្មែរ,
- អំពីការវេចរីលនៃវប្បធម៌ អក្សរសាស្ត្រខ្មែរ ។ ល ។

កិត្តិស័ព្ទល្បីល្បាញខាងសំនួនវោហាររបស់កវី អ៊ូ នេះ បានឮខ្ចរខ្ចាយទៅដល់ព្រះមហាក្សត្រ ។ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូងព្រះស៊ីសុវត្ថិ បានត្រាស់ហៅលោកអោយចូលគាល់ និងច្រៀងថ្វាយ ។ ហ្លួងព្រះស៊ីសុវត្ថិពេញព្រះទ័យនឹងថ្វីមាត់របស់លោកណាស់ ទើបអនុញ្ញាតឱ្យលោកចូលបំរើក្នុងក្រុមភ្លេងព្រះបរម-រាជវាំង ហើយប្រទានងារជា "អ្នកព្រះភិរម្យភាសា អ៊ូ" ប៉ុន្តែ ដោយនៅពេលនោះ

មាននាយក្រុមបារាំងម្នាក់ឈ្មោះអ៊ួ ដែរនោះ ទើបហ្លួងព្រះស៊ីសុវត្ថិទ្រង់ត្រាស់ឱ្យហៅថា " ង៉ុយ" វិញ ដើម្បីកុំឱ្យច្រឡំគ្នា ។ ដូច្នេះបានជាលោក មានឈ្មោះ ១ ទៀត ថា " ង៉ុយ " ឬ ក្រុមង៉ុយ រៀងដរាបមក ។

កិត្តិស័ព្ទរបស់អ្នកព្រះភិរម្យភាសាអ៊ូ មិនគ្រាន់តែល្បីរន្ទឺនៅក្នុងប្រទេសទេ ប៉ុន្តែ បានសាយភាយទៅដល់ប្រទេសថៃ ថែមទៀត ។ ស្តេចសៀម ក្រុមព្រះទំរង់រាជានុភាព និងលោកសីដេស ជាតិបារាំង បានចូលគាល់ហ្លួងព្រះស៊ីសុវត្ថិ ។ ពេលប្រគំភ្លេងទទួលភ្ញៀវបរទេសនោះ អ្នកព្រះភិរម្យភាសា អ៊ូ ហៅ ង៉ុយ ប្រគំឈ្នះគេខាងខ្សែដៀវ ។ កិត្តិស័ព្ទរបស់លោក បានផ្សាយដល់ស្រុកសៀម ។ ស្តេចសៀម បានធ្វើរាជសារមកសុំអញ្ជើញអ្នកព្រះភិរម្យភាសាង៉ុយ ទៅច្រៀងថ្វាយ ឯក្រុងបាងកក ។ លោកបានធ្វើដំណើរទៅនៅស្រុកសៀម អស់រយៈពេល ៣ ខែ ហើយបានទទួលសេចក្តីរាប់អានពីសំណាក់ព្រះមហាក្សត្រ និងមន្ត្រីសៀម ។ ពេលនោះ ស្តេចសៀមបានប្រទានងារ ជាភិរម្យភាសា " ផៃរ៉ោះលឿកីន " និងប្រទានឡេវអាវប្រាក់ខ្លួង ព្រមទាំងប្រាក់ និងវត្ថុផ្សេងៗទៀត ជាច្រើន ។ មានដំណាលថា ក្នុងពេលធ្វើដំណើរត្រឡប់ពីប្រទេសសៀមវិញ លោកបានឆ្លងកាត់តាមខេត្តបាត់ដំបង ។ ពេលនោះ នៅខេត្តបាត់ដំបង មានអ្នកចម្រៀងមាត់ឯកម្នាក់ឈ្មោះភិរម្យ យូ ។ ដោយឮល្បីថា អ្នកព្រះភិរម្យភាសាអ៊ូ ពូកែច្រៀង លោកភិរម្យ យូ ក៏មកសុំច្រៀងភ្នាល់ ។ ភិរម្យ យូ បានសួរព្រះភិរម្យង៉ុយថា " *ភ្នំព្រះសុមេរុនៅឯណា ? មានទំហំប៉ុណ្ណា ? កំពស់ប៉ុន្មានយោជន៍ ? ពីនេះទៅ បើសិនជាវាស់ តើមានប៉ុន្មានគីឡូម៉ែត្រ ?* " ។ ព្រះភិរម្យង៉ុយ ឆ្លើយថា " *បើលោកឆ្ងល់យ៉ាងនេះ តើលោកចង់ឱ្យខ្ញុំឆ្លើយត្រង់ ឬ ឱ្យឆ្លើយកុហក ?* " ។ ភិរម្យ យូ ថា*បើសួរត្រង់ ត្រូវតែឆ្លើយឱ្យត្រង់* ។ ភិរម្យង៉ុយ ក៏ឆ្លើយកែដោះសារថា មានប៉ុណ្ណេះគីឡូ ប៉ុណ្ណេះម៉ែត្រ ហើយបើគិតពីបាត់ដំបងទៅ មានចម្ងាយផ្លូវ

ប៉ុណ្ណោះទៀត បើភិរម្យ យូ មិនជឿ ត្រូវទៅមើលចុះ ។ ភិរម្យ យូ ព្រមទទួលជឿ ហើយភិរម្យង៉ុយ ក៏សួរវិញថា " *តើពីផ្សារបាត់ដំបងទៅភ្នំពេញ បើទៅតាមថ្នល់ តើមានប៉ុន្មានគីឡូ ? បើទៅតាមទន្លេសាបវិញ តើមានប៉ុន្មានគីឡូ ?* " ភិរម្យ យូ ក៏ទាល់ឆ្លើយមិនរួច ហើយភិរម្យង៉ុយ ច្រៀងបង្អាប់ភិរម្យ យូ យ៉ាងច្រើន ថា *កន្លែងធ្លាប់ទៅមក ហើយជាប្រទេសរបស់ខ្លួនឯង ភិរម្យ យូ មិនដឹងទៅហើយ ទៅសង្វាតសួរកន្លែងមិនដែលទៅ បើទោះជាខ្ញុំកុហក ក៏ត្រូវតែជឿខ្ញុំដែរ* ។ ភិរម្យ ង៉ុយ បង្អាប់ទាល់តែភិរម្យ យូ ទាល់ចុះពីកន្លែងច្រៀង ហើយប្រជាជនអ្នកស្តាប់ ទះដៃសរសើរភិរម្យង៉ុយយ៉ាងខ្លាំង ។ លោកប្រមុខខេត្តបាត់ដំបង បានប្រគល់ រង្វាន់នៃជ័យជំនះដល់ភិរម្យង៉ុយ គឺសេះស ១ ក្បាល និងប្រាក់សុទ្ធ ៤០០ រៀលទៀត ។ ដូច្នេះហើយបានជា អ្នកចម្រៀងនានា មានការញញើតលោកណាស់ មិនសូវមាននរណាហ៊ានច្រៀងតតាំងនឹងថ្វីមាត់លោកឡើយ មានតែជំទប់ *សាន់* នៅឃុំភ្លើងឆេះរទេះ ស្រុកភ្នំពេញ ដែលជាមិត្តភក្តិ និងជាដៃគូរបស់គាត់ម្នាក់ប៉ុណ្ណោះ ទើបអាចតបតនឹងលោកបាន ។ ពេលអ្នកចម្រៀងទាំងពីរនេះ ទៅច្រៀងនៅកន្លែងណា មនុស្សម្នាប្រុសស្រី នៅភូមិស្រុកឆ្ងាយៗ បានភ្លូកទៅស្តាប់ជាច្រើន ។

នៅពេលក្រោយមកទៀត លោក ស៊ីដេស បាននាំព្រះភិរម្យភាសា អ៊ូ ទៅជួបលោកស្រី ស៊ុយហ្សាន កាប៉ឺឡេស (Suzanne Karpeles) ដែលជានាយកវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ នៅភ្នំពេញ ។ នៅឆ្នាំ ១៩៣០ អ្នកស្រីនាយកសុំអោយអ្នកព្រះភិរម្យភាសា ច្រៀងកំណាព្យរបស់គាត់ឡើងវិញទាំងអស់ បែបរង្វើលៗ ដើម្បីអោយអ្នកប្រាជ្ញនៅវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ កត់ត្រាទុក ។ ជារង្វាន់នៅពេលនោះ អ្នកស្រី *ស៊ុយសាន* បានអោយលោក នូវប្រាក់ ១ រៀល ជានិមិត្តរូបនៃការស្រឡាញ់វប្បធម៌ អរិយធម៌ខ្មែរ ។ ដោយចង់រក្សាទុកស្នាដៃនេះ

អោយបានយូរអង្វែង សំរាប់មនុស្សជំនាន់ក្រោយ ពុទ្ធសាសនបណ្ឌិត្យ បានចាត់ចែងបោះពុម្ព ស្នាដៃរបស់លោកជាប្នូនច្បាប់ ហើយក្រោយមក បានបោះបញ្ចូលគ្នាជាមួយច្បាប់ វិញ ។

តាមពិត ស្នាដៃរបស់លោកមានច្រើន ប៉ុន្តែគេមិនបានកត់ត្រា ព្រោះលោកតា ង៉ុយ ជាកវីដែលបង្កើតស្នាដៃដោយច្រៀងផ្ទាល់មាត់ ។

ស្នាដៃរបស់លោកដែលយើងរកឃើញ រហូតដល់សព្វថ្ងៃ មាន ៥ គឺ :

១. ច្បាប់ល្បើកថ្មី " បទកាកគតិ " ( ឆ្នាំ ១៩២២ ),

២. ច្បាប់កេរ្តិ៍កាលថ្មី " បទព្រហ្មគីតិ " ( ឆ្នាំ ១៩២២ ),

៣. សេចក្តីរំលឹកដាស់តឿន " បទពាក្យ ៧ " ( ឆ្នាំ ១៩៣១ ),

៤.ច្បាប់ប្រដៅទូន្មានជនប្រុសស្រី " បទពាក្យ ៧ " ( មិនដឹងកាល-បរិច្ឆេទ ),

៥. បណ្តាំក្រមង៉ុយ " បទព្រហ្មគីតិ " ( គ្មានកាលបរិច្ឆេទ ) ។

ក្រៅពីស្នាដៃខាងលើនេះ នៅមានស្នាដៃផ្សេងទៀតដែលគេរកមិនឃើញឯកសារសរសេរ ហើយដែលអ្នកស្រាវជ្រាវពីមុនៗ បានចាត់ទុកថាជាស្នាដៃរបស់អ្នកភិរម្យភាសាអ៊ូ ដែរ គឺចម្រៀងស្តីអំពី :

- ការប្រែប្រួលនៃស្រុកទេស,
- កតញ្ញូកតវេទី,
- ត្រៃលក្ខណ៍,
- ចម្រៀង ស្រី ប្រុស...

អ្នកភិរម្យភាសា អ៊ូ មានភរិយាឈ្មោះ អ៊ិន ។ លោកមានបុត្រចំនួន ៦ នាក់ សុទ្ធតែប្រុស គឺ :

១. ឈ្មោះ ដួង

២. ឈ្មោះ ចេង

៣. ឈ្មោះ ចា

៤. ឈ្មោះ ចិន

៥. ឈ្មោះចុង

៦. ឈ្មោះចេវ

ក្នុងចំណោមកូនគាត់ទាំង ៦ នាក់ មានម្នាក់ដែលមានទេពកោសល្យខាងសំនួនវោហារប្រហាក់ប្រហែលគាត់នោះគឺ កូនទី ៥ ដែលគេនិយមហៅថា អាចារ្យចុង ។ មានពតិមានខ្លះទៀតថា គាត់នៅមានចៅម្នាក់ទៀត ដែលមានវោហារល្បីខាងច្រៀងអាយ៉ៃដែរ ហើយមានរូបរាងស្គមស្តើង ដែលគេធ្លាប់ឮឈ្មោះថា នាយស្លឹក ។ នៅពេលច្រៀងអាយ៉ៃ នាយស្លឹកតែងបង្ហាញខ្លួនគាត់ថា " *ស្រុកខ្ញុំនៅឯលិចពោធិចិនតុង កូនអាចារ្យចុង ចៅអាចារ្យង៉ុយ* " ។

អ្នកព្រះភិរម្យភាសា អ៊ូ បានទទួលអនិច្ចកម្ម នៅថ្ងៃសុក្រ ៦ កើត ខែមិគសិរ ព.ស ២៤៧៩ គ.ស ១៩៣៦ ក្នុងជន្មាយុ ៧១ ឆ្នាំ ដោយជំងឺទល់លាមក ។

## សង្គមបរិយាកាសនៅកម្ពុជា

( ពីឆ្នាំ ១៨៦៥ ដល់ឆ្នាំ ១៩៣៦ )

នៅក្នុងរយះពេលជាង ៧០ ឆ្នាំនេះ នៅប្រទេសកម្ពុជា គេឃើញមានព្រឹត្តិការណ៍សំខាន់ៗជាច្រើន ដែលធ្វើអោយមានវិបរិតទូទាំងប្រទេស ទាក់ទងដល់គ្របវិស័យរបស់សង្គម និង ប៉ះពាល់ដល់ភាពរស់នៅរបស់ប្រជាជនខ្មែរទូទាំងប្រទេស ។

ប្រជាជនកម្ពុជា បាត់បង់សិទ្ធិ សេរីភាព និងអ្វីៗដែលខ្លួនធ្លាប់មានពីមុនៗ

មក ក្នុងឋានៈជាម្ចាស់ប្រទេស ចាប់ពីឆ្នាំវក គ.ស ១៨៨៤ (១) គឺក្នុងពេលដែលពួកអាណានិគមបារាំង បានប្រើអំណាចរំលោភទាំងកំរោលមកលើអធិបតេយ្យភាពរបស់ប្រទេសកម្ពុជា ដោយលែងទទួលស្គាល់កម្ពុជា ក្នុងលក្ខណៈជាប្រទេសស្ថិតក្នុងអាណាព្យាបាលរបស់ខ្លួន ។ ផ្ទុយទៅវិញ បារាំងបានចាប់យកកម្ពុជា ធ្វើជាប្រទេសអាណានិគមរបស់ខ្លួន តែម្តង ។

ចាប់តាំងពីពេលនោះ គេឃើញមានការសើរីរៀបចំប្រទេសឡើងវិញនៅគ្រប់វិស័យ ទៅតាមប្រព័ន្ធគ្រប់គ្រងបារាំង ទាំងខាងរដ្ឋបាល ទាំងខាងសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ អប់រំ សិក្សាធិការ ដូចជា ៖

- មានការតែងតាំងមន្ត្រីភាគច្រើន ជាជនបរទេស ក្នុងអង្គការរដ្ឋបាលអោយត្រួតត្រាប្រទេសខ្មែរ,
- មានការវាស់វែងបែងចែកដីធ្លី និងប្រគល់កម្មសិទ្ធិអោយប្រជាជនដើម្បីងាយដកហូតពន្ធដារ,
- មានការបោះពុម្ពក្រដាស់ប្រាក់ថ្មីជំនួសប្រាក់សុទ្ធ (២),
- ប្រមូលទ្រព្យសម្បត្តិឃ្លាំងព្រះរាជទ្រព្យ យកទៅដាក់រតនាគាររួម ហៅថា Trésor unique du Royaume (៣),
- ការផ្សព្វផ្សាយវប្បធម៌ និង អរិយធម៌លោកខាងលិចនៅក្នុងប្រទេសរាប់តាំងពីអក្សរ ភាសា សីលធម៌រស់នៅ សម្លៀកបំពាក់ សិល្បៈ ភ្លេង របាំ រាំច្រៀង - ល - ។

ម្យ៉ាងទៀត នៅក្នុងឆ្នាំ ១៩១៤ - ១៩១៨ សង្គ្រាមលោកលើកទីមួយបានផ្ទុះឡើងនៅប្រទេសអឺរ៉ុប ។ ពិតមែនតែសង្គ្រាមនោះ មិនកើតឡើងលើទឹកដីរបស់យើង ប៉ុន្តែផលវិបាករបស់សង្គ្រាមនេះ បានប៉ះពាល់យ៉ាងធ្ងន់ធ្ងរ មកលើប្រជាជនកម្ពុជា ។ ដោយសារប្រទេសកម្ពុជា ជាប្រទេសអាណានិគមរបស់បារាំង

ដូច្នេះ ឈាមខ្មែរ ក៏កំពប់ខ្ចាយ ដោយសារបារាំងធ្វើសង្គ្រាមនៅអឺរ៉ុបដែរ ។ ពេលនោះ បារាំងបានចាប់ប្រជាជនខ្មែរបុរសៗ អោយធ្វើទាហាន ហើយមួយចំនួនធំ ត្រូវបានចាត់បញ្ជូនអោយទៅជួយច្បាំងបារាំង ។ ទាហានមួយចំនួន បានពលីនៅលើសមរភូមិ ដោយឥតមានស្គាល់ឈ្មោះ និងស្រុកកំណើតរបស់គេឡើយ [៤] ។

ប្រជាជនកម្ពុជាដែលនៅក្នុងស្រុក ត្រូវទទួលរងទុក្ខវេទនា ដោយសារការហ៊ុំព័ទ្ធសេដ្ឋកិច្ចពីខាងក្រៅ ដោយសារគ្រោះធម្មជាតិ ( ទឹកជំនន់ និងរាំងស្ងួត ) បណ្ដាលអោយមានទុរ្ភិក្សជាទូទៅពេញប្រទេស ។ ជំងឺតម្កាត់កើតឡើង ហើយឆ្លងរាលដាលយ៉ាងរហ័ស ដោយសារខ្វះថ្នាំសង្កូវ ។ រីឯពួកអាណានិគមវិញ គិតតែជិះជាន់ទារពន្ធដារលើមនុស្ស សត្វ និងឧបករណ៍ សម្ភារៈសព្វសារពើ ដើម្បីយកទៅចំណាយក្នុងសង្គ្រាម និងដើម្បីស្តារប្រទេសរបស់គេឡើងវិញ ក្រោយពេលសង្គ្រាមបានចប់ទៅវិញ ។ ការប្រមូលពន្ធដារលើទំនិញ និងការហ៊ុំព័ទ្ធសេដ្ឋកិច្ច និងការខកខានមិនបានផលិត បណ្ដាលមកពីគ្រោះរាំងស្ងួត នាំអោយមានអតិផរណាទំនិញសព្វសារពើចេះតែឡើងថ្លៃរៀងរាល់ថ្ងៃ ។ ទន្ទឹមនឹងព្រឹត្តិការណ៍ខាងលើនេះ ពួកឈ្មួញបរទេស និងអ្នកប្រកបមុខរបរលក់ដូរ ឆ្លៀតឱកាសកេងប្រវ័ញ្ច គៃបន្លំយកចំណេញ ដើម្បីធ្វើមានបានពីលើខ្នងប្រជាជនខ្មែរ ដែលភាគច្រើនជាកសិករមិនសូវបានរៀនសូត្រ ទាំងខាងអក្សរសាស្ត្រ ទាំងខាងលេខនព្វន្ត ។

---

(១). នៅក្នុងសៀវភៅឈ្មោះ " រាជាធិបតេយ្យកម្ពុជា និងព្រះរាជបូជនីយកិច្ចដើម្បីឯករាជ្យ (La Monarchie Cambodgiènne et la Croisade Royale pour l'Indépendance) " សម្តេចព្រះនរោត្តម សីហនុ បានរៀបរាប់យ៉ាងពិស្តារ អំពីខ្លឹមសារអនុសញ្ញាឆ្នាំ ១៨៨៤ ( ទំព័រ ៥៣ និង បន្តបន្ទាប់ ) ។

- ឯកសារមហាបុរសខ្មែររបស់លោក អេង សុត, ត្រង់រជ្ជកាលព្រះនរោត្តម ភាគខាងចុង ។

(២) នៅមុនសតវត្សទី ១៥ ការផ្លាស់ប្តូរទំនិញសំខាន់ៗ ក្នុងការលក់ដូរក្នុងស្រុក និងក្រៅប្រទេស គេធ្វើអោយមានការផ្លាស់ប្តូរទៅវិញទៅមក ដោយយកទំនិញប្តូរនឹងទំនិញ យកមាសទៅប្តូរក៏មាន (សៀវភៅ Le Cambodge បោះពុម្ពផ្សាយដោយក្រសួងឃោសនាការ នៃរាជរដ្ឋាភិបាលកម្ពុជា ភ្នំពេញ, ឆ្នាំ ១៩៦២),

- កំណត់ហេតុស្តីអំពីទំនៀមទម្លាប់របស់ប្រទេសកម្ពុជា, របស់ ចូវ តាក្វាន់ (Mémoires sur les coutumes du Cambodge de Tcheou Takouan; Œuvres postumes de Paul Pelliot Adrien - Maisonneuvre Paris 1951),

- សិលាចារឹកស្តុកកក់ធំ,

លុះមកដល់ឆ្នាំ ១៥៩៥ ក្នុងរជ្ជកាលព្រះសត្ថាទីមួយ គេបានរកឃើញមានប្រាក់ ដែលបោះចាយលើកដំបូង ។ រហូតមកដល់រជ្ជកាលព្រះអង្គឌួង ទើបមានការបោះប្រាក់ចាយសាជាថ្មី ក្នុងរវាងឆ្នាំ ១៨៤៧ ។ ( ឯកសារមហាបុរសខ្មែរ ត្រង់រជ្ជកាលព្រះអង្គឌួង ) ។

- សៀវភៅ La Monarchie Cambodgiènne និងសៀវភៅ Le Cambodge ដូចបញ្ជាក់ខាងលើ ។

(៣) បារាំងបានប្រមូលសម្បត្តិព្រះរាជទ្រព្យយកទៅដាក់រតនាគាររួម នៅក្នុងឆ្នាំ ១៨៩១ សូមអានឯកសារមហាបុរសខ្មែរ ។

(៤) កាលពីមុនឆ្នាំ១៩៧៥ គេឃើញមានរូបសំណាកធ្វើអំពីស្ពាន់យ៉ាងធំ តម្កល់កណ្តាលសួន នៅខាងកើតស្ថានទូតបារាំង ត្រង់ម្តុំវត្តចិនដំដែក ដែលគេនិយមហៅថា រូបពីរ ។ រូបសំណាកនោះ បារាំងបានកសាងដើម្បីឧទ្ទិសចំពោះទាហានបារាំង និងខ្មែរ ដែលបានពលីជីវិតក្នុងការជួយច្បាំងបារាំង ។ ក្រោយឆ្នាំ ១៩៧៥ ក្នុងពេលដែលខ្មែរក្រហមឡើងកាន់អំណាច រូបសំណាកនេះ ត្រូវបានគេកំទេចចោលទាំងស្រុង ។

—



រូបថតឯកសារ : ពិធីសម្ពោធវិមានមតកជន ( ហៅរូបពីរ ) នៅឆ្នាំ ១៩២៥

Fête d'inauguration du Monument aux Morts 1925

# ពាក្យកាព្យ
## ប្រដៅជនប្រុសស្រី (១)

១ ខ្ញុំសូមបង្គំព្រះសម្មា សម្ពុទ្ធណាៗក្នុងត្រៃភព
ចំរើនកម្មដ្ឋានក្រោមពោធិ៍ម្លប់ ខ្ញុំសូមគោរពនមស្សការ ។
ព្រះចមចក្រពិននិរន្តឫទ្ធិ ជាម្ចាស់ជីវិតលើសិរសា
សូមថ្វាយបង្គំព្រះករុណា សូមទ្រង់មេត្តាប្រោសប្រណី ។
ឱនកាយបង្គំប្រណម្យនឹក សូមក្រើនរំលឹករាស្ត្រប្រុសស្រី
ធ្លាប់ជ្រកទីពឹងព្រះបារមី ឱ្យរៀនបាលីទៅបរលោក ។
សរណគមន៍បីឱ្យប្រតិបត្តិ កំចាយកំចាត់ក្តីទុក្ខសោក
រូបយើងសព្វថ្ងៃថ្លៃមិនថោក បានមកភពភាន់ទាន់សាសនា ។
៥ ផ្លូវប្រេតនរកទៅញឹកញយ គួរកុំបណ្តោយតាមតណ្ហា
គួរគិតសង្វេបឃាត់សង្ខារ សង្ឃឹមព្រះសិរអារ្យនឹងមកត្រាស់ ។
ជម្ពូទ្វីបនេះធំបំផុត មួយម៉ឺនយោជន៍គត់ដំណែលព្រះ
សត្វស្លាប់តាមកម្មមិនចាំចាស់ អាយុខ្លីណាស់ក្រាស់អកុសល ។
រូបំ អនិច្ចំ អនត្តា កើតរូបកាលណាកម្មតាមដល់
តាមដានដរាបបាបអោយផល បាបខ្លះសេសសល់ពីនរក ។
ខ្លះមកអំពីប្រេតតិរច្ឆាន ខ្លះមកពីស្ថានសួគ៌សោយសុខ
វេរាតាមរកបានឃើញមុខ ចុះមករងទុក្ខទទួលកម្ម ។

(១) កកន. ចំណងជើងពេញលេញរបស់អត្ថបទនេះ ដាក់ថា ពាក្យកាព្យប្រដៅជនប្រុសស្រី ឱ្យបដិបត្តិតាមគន្លងព្រះពុទ្ធសាសនា ។

អ្នកធ្លាក់ទៅរងនរកប្រេត ដើមហេតុពីព្រោះដាច់សីល ៥
ទឹកក្តៅខ្ទះដែកទៅដេកត្រាំ រាប់លានកោដិឆ្នាំទំរាំរួច ។
១០ មកកើតជាមនុស្សស្ថានកណ្តាល មិនរាងមិនចាលដល់តិចតួច
ប្រពន្ធកូនគេនៅតែលួច សត្វធំសត្វតូចរឹតសម្លាប់ ។
ស្រាវីតតែផឹកឱ្យស្រវឹង គុណទោសមិនដឹងប្រឹងចាក់កាប់
ស្រុកឃ្លានបំពានធ្វើលើច្បាប់ មិនស្តាប់ពុទ្ធដីកាព្រះអង្គផ្តាំ ។
ពិតមែនជាមិនឮព្រះឱស្ឋ ព្រះសង្ឃទ្រង់ប្រោសឱ្យសីល ៥
ទទួលរំពេចភ្លេចមិនចាំ ប្រព្រឹត្តសាងកម្មមិនព្រមលែង ។
កើតមកពូជពង្សពេញជាមនុស្ស សេចក្តីត្រូវខុសចាំជាក់ស្តែង
សម្លាប់រូបសត្វឥតគិតក្រែង បំពេញរូបឯងឱ្យធំធាត់ ។
សម្លាប់មិនថាសត្វឈ្មោលញី យកសាច់មកស៊ីឱ្យឆ្ងាញ់មាត់
ទទួលសីលភ្លើធ្វើឱ្យភ្លាត់ លក់សត្វឱ្យព្រាត់មេព្រាត់កូន ។
១៥ ព្រាត់គូកំសត់វដ្តសង្សារ ដូចលក់ជីតាលក់ជីដូន
ពុំនោះលក់បងបំបែកប្អូន ងងឹតឈឹងសូន្យមើលមិនយល់ ។
ខ្លះទៅនរកមិនទាន់មក ខ្លះឃ្លាតទៅជ្រកពួកអសុរ
ជរនសង្ខារឡប់វិលវល់ អំពល់តែកើតស្លាប់កើតស្លាប់ ។
កម្មកិតតាមខ្លួនមិនដែលឃ្លាត គ្រប់ប្រាំរយជាតិមិនដែលឆាប់
សត្វជ្រូកមាន់ទាគេចាក់កាប់ សម្រាប់គេស៊ីជាអាហារ ។
សត្វគោក្របីដីរសេះ គេជិះគេទឹមជាធម្មតា
គេកាប់លក់សាច់ផ្តាច់សង្សារ រកចិត្តមេត្តាកុរុណាគ្មាន ។
រូបខន្ធរលត់រលាយទៅ សល់នៅសង្ខារនឹងវិញ្ញាណ
វេទនាសញ្ញានឹកស្រុកឃ្លាន សន្និដ្ឋានថាដូចអ្នកមានគុណ ។

សត្វញីសត្វឈ្មោលអន្ទោលទុក្ខ អាពុកឬម្ដាយពីជាតិមុន
ជាតិមកពីរងទោសទុក្ខធ្ងន់ ព្រែងស៊ុនទៅលើសាច់ញាតិឯង ។
ជ្រូកគោក្របីនៅតូចស្គាវ គេក្រៀកវះក្រៀវឃើញស្ដែង១
បើគិតឱ្យសព្វគ្រប់កន្លែង ជួនព្រែងជាតិមនុស្សមកជាសត្វ ។
អ្នកពីងនឹងអ្នកធ្វើដែដល់ ចៅក្រមអកុសលជំនុំកាត់
បញ្ជីទាំងពីរឈ្មោះមិនបាត់ គេចាត់ធ្វើទោសទាំងអស់គ្នា ។
មិនមានអ្នកណាធ្ងន់ណាស្រាល យមបាលវះក្រៀវគ្រប់វេលា
មានលោកយមរាជរាជសភា ជំនុំគិតគ្នាមើលបញ្ជី ។
បញ្ជូនអ្នកធ្វើចុះនរក ជំនុំឃុំទុកអ្នកទិញស៊ី
ទិញសត្វស្លាប់រស់ទោះឈ្មោលញី ទាំងពីរចំណែកចំណាំមុខ ។
អ្នកមួយទិញស៊ីមិនរួចខ្លួន ត្រីមងត្រីអួនយួនដូរលក់
អណ្ដែងក្រាញ់ឆ្ដោដៀបរស់ផ្អក់ ចង់ទិញស្ងោរជ្រក់ទៅតថ្លៃ ។
ឃើញច្បាស់ជារស់មិនទាន់ងាប់ អង្គុយបង្គាប់ឱ្យយួនវៃ
រកខ្យល់ច្រឡោតដោតញ័រដៃ ឃើញក្សួយស្រាប់១មិនទិញយក ។
អានេះបន្ទូរលែងមិនបាន ត្រូវច្រំផាក់ច្រានឱ្យជ្រុលជ្រក
ទម្លាក់ឱ្យជ្រៅរងទុក្ខសោក លែលកអ្នកទោសរឿងអ្នកទិញ ។
អ្នកទៅឃើញត្រីនៅបម្រះ វេទនាចិត្តណាស់ប្រាសដើរចេញ
អ្នកនេះត្រូវលែងឱ្យទៅវិញ មានសៃហ្វលិញគិញក្នុងនរក ។
ឱ្យជូនខ្លាចព្រែងវង្វេងផ្លូវ ត្រួតមើលខុសត្រូវគ្រប់ភូមិស្រុក
បើកក្រាំងសៀវភៅកត់ឈ្មោះទុក បញ្ជីពីរមុខបាបនឹងបុណ្យ ។
ប្រគល់យមរាជយមបាល ដាក់ស្រាលដោយស្រាលធ្ងន់ដោយធ្ងន់
អ្នកសាងមគ្គផលស្គាល់ទោសគុណ ទៅសោយសុខមុនតាមទុនទាន ។

អ្នកសាងធុនទាបភាពអកុសល  មិនចង់បានផលសួគ៌និព្វាន
ប្រព្រឹត្តអាក្រក់រកល្អគ្មាន  មិនហ៊ានកាន់សីលថាខ្លាចដាច់ ។
មិច្ឆាទិដ្ឋិចូលពេញទី  បញ្ឆើសម្រាំងតាំងសម្រេច
ចុះវង្សអាជីវកភ្លុក្យស៊ីអាចម៍  ព្រោះពោលបង្កាច់ព្រះពុទ្ធដីកា ។
វចីទុច្ចរិតមានគ្រប់យ៉ាង  មានសីលមិនសាងអាងផឹកស្រា
ឮលោកសំដែងធម៌ទេសនា  ពីរោះពិស្ដារមិនដឹងស្ដាប់ ។
អស់យើងគួរស្ដាយជាតិកំណើត  សំណាងមកកើតក្នុងភទ្ទកប្ប
អគារវិន័យព្រះប្រញ្ញត្ត  ជាឫសគល់ច្បាប់គួររក្សា ។
៣៥ សីល ៥ ចងចាំឱ្យប្រាកដ  កុសលកម្មបថ ១០ ប្រការ
កុំឈ្លោះប្រកែកពីធម៌អាថ៌  ប្រកាន់សាសនាឱ្យប្រាកដ ។
កើតមកជាមនុស្សមានសខ្មៅ  មានប្រាជ្ញមានខ្លៅមានក្រខ្សត់
មានខ្លាំងមានខ្សោយដោយបែបបទ  សន្មតថាល្អក៏មិនបាន ។
ជម្ពូទ្វីបនេះមនុស្សកម្មក្រាស់  ព្រះពុទ្ធតែងត្រាស់មិនដែលខាន
ហេតុនេះមហាជនទាំងប៉ុន្មាន  សម្រាកសម្រាន្តសម្រួលចិត្ត ។
បំណាច់សម្ដេចព្រះទ្រង់ញាណ  កាលហៀបនិព្វានមានក៏រឹត
ផ្ដាំមហាអានន្ទឱ្យអាណិត  អានុជអ្នកប្រឹតប្រោសសត្វផង ។
សត្វផុងទៅក្នុងជ្រោះជ្រាំជ្រៅ  តថាគតនៅនាំចំឡង
ដាក់ដល់និព្វានអស់ហ្មត់ហ្មង  រួចពីចំណងវដ្ដសង្សារ ។
៤០ នៅសល់សង្ស័យសត្វខាងក្រោយ  នន្ទអើយទុកអោយព្រះសិរអារ្យ
អាណិតសត្វណាស់ណ៎ាអ្នកណ៎ា  តថាគតជិតនិព្វានហើយ ។
ព្រះឱស្ឋព្រះអង្គល្មមស្រណោះ  សប្បុរសទាំងអស់កុំកន្តើយ
ប្រះខ្នងដេកលើកន្ទេលខ្មើយ  កុំស្ងៀមមាត់ឡើយរំលឹកគុណ ។

ខ្លួនខ្ញុំកំណើតរាស្ត្រអ្នកស្រែ    ខូចខិលខ្ជិលដែរពីកាលមុន
កាលមោហ៍បាំងបិទងងឹតស៊ុន    ធ្វើបាបនឹងបុណ្យទម្ងន់ស្មើ ។
មិនស្មោះតែរួចចតុរាបាយ    អស់លោកទាំងឡាយកុំសរសើរ
ខ្ញុំជូនដំណឹងតាមដំណើរ    ព្រោះខ្ញុំគ្រាន់បើជាងអ្នកល្ងង់ ។
ជាតិក្រោយកុំឱ្យខ្ញុំល្ងីល្ងើ    ជាតិនេះចាស់ស្ទើរខ្ញុំប្រឹងស្ទង់
ប្រឹងស្ទុះឱ្យរួចពីអន្លង់    ភ័យភិតខ្លាចផុងទៅក្នុងភក់ ។
ក្នុងភពសង្សារខ្ញុំសង្ស័យ    សព្វថ្ងៃខ្ញុំភ័យខ្លាចនរក
ម្យ៉ាងទៀតខ្មើមជាតិអាជីវក    ជាតិល្មោភហួបល្មក់ព្រោះល្មិលគុណ ។
ច្រើនល្មើសបន្ទុលបន្ទោសព្រះ    ខ្ញុំភ័យខ្ញុំណាស់ក្រែងខ្ញុំស៊ុន
ខ្ញុំសូមស្មារលាទោសពីមុន    សូមបុណ្យជួយបាំងបាបឱ្យបាត់ ។
ឱ្យបានទាន់តួព្រះសិអារ្យ    ឱ្យបែកប្រាជ្ញាឆ្លាតបរមត្ថ
ព្រះអង្គទេសនាទ្រង់ប្រោសសត្វ    សូមលុះអរហត្តដូចបំណង ។
*បំណាច់ខ្ញុំផ្សាយច្បាប់រំលឹក*    *អស់លោកជួយនឹកសទ្ធាផ្សង*
*ធ្វើបុណ្យចែកផលដល់ខ្ញុំផង*    *នឹកឈ្មោះម្តង១ដូចធម្មតា ។*
សប្បុរសប្រុសស្រីគប្បីស្តាប់    ឈ្មោះច្បាប់ **កន្លងព្រះឱវាទ**
ឱកាសឱ្យគិតប្រើតប្រាថ្នា    ទាន់ព្រះសិអារ្យទាំងប្រុសស្រី ។
កុំរៀនព្រហើនប្រហែសធ្វេស    កើតក្នុងប្រទេសរាជបុរី
ឱ្យមានបារម្ភភ្ញាក់ស្មារតី    សីល៥ ប្រាំបីខំសិក្សា ។
ជាតិមនុស្សជាន់ខ្ពស់ពីបុរាណ    គេបានជួបជាក់ឃើញភក្ត្រា
បានគ្រងរងត្រាប់ព្រះពុទ្ធដីកា    បានលុះសោតាអរហត្តហោះ ។
យើងទាន់តែត្រឹមពាក្យបណ្តាំ    បណ្តូលសីលប្រាំជាកេរ្តិ៍កោះ
កិច្ចការកងកម្មចាំមិនអស់    របស់ឫសគល់គួររក្សា ។

នេះចប់ចំណែកខាងបាសក    កុំធ្វើអាក្រក់រាល់រូបបា
រំពឹងក្រែងចួបព្រះសិរអារ្យ    នមស្សការគោរពរំលឹកគុណ ។
ព្រះចមចក្រពង្សមុនីនាថ    កំពូលផុតជាតិជាងមហាជន
ទ្រង់សោយសម្បត្តិសម្បើមបុណ្យ    សម្បូណ៌លើសលន់លុបលោកា ។
៦០ លោកកីយដឹងហើយគួរកោតខ្លាច    ទ្រង់មានអំណាចព្រះចេស្ដា
គួរស្ដាប់ព្រះរាជឱង្ការ    បន្ទូលត្រូតត្រាគួរត្រងត្រាប់ ។
ព្រះទ័យទ្រង់ត្រេកស្រឡាញ់សង្ឃ    ប្រមាណសែនអង្គក្នុងភទ្ទកប្ប
ព្រះពុទ្ធទ្រង់ប្រឹតប្រាមប្រញប្ត    *ឈ្មោះច្បាប់បាដិមោក្ខសំវរសីល ។*
*ចែកចេញជាកងសិក្ខាបទ*    *កំណត់ពីររយម្ភៃប្រាំពីរ*
មិនឱ្យមានមោះហ្មងមន្ទិល    អ្នកបួសកុំខ្ជិលកាន់ឱ្យខ្ជាប់ ។
*បាណាអទិន្នាជាបឋម*    *ជាតិរូបទៀតផ្សំត្រូវជាដប់*
លោកសង្ឃឥឡូវកាន់មិនសព្វ    *កាន់ក្នុងបន្ទប់លាយបន្ទំ ។*
*បន្តិចលុយកាក់លាក់សម្ងាត់*    *ទោសត្រូវអាបត្តិលាក់សម្ងំ*
*បាសកធ្វើទានគ្មានអារម្មណ៍*    *សន្សំតែទ្រព្យក្ដៅក្រហាយ ។*
៦៥ *ប្រសិនបើកាន់ច្បាប់ព្រះពុទ្ធ*    *មិនមានធម្មយុត្តិមហានិកាយ*
*បើចេះខ្លាចក្រែងមិនក្លែងក្លាយ*    *សមសុខសប្បាយមិនទាស់ផ្ទា ។*
*លោកសង្ឃគ្រប់វត្តមានធំតូច*    *សង្ឃខ្លះខិលខូចសង្ឃខ្លះជា*
*បរិស័ទ្យថ្កោលទោសគ្រូឧបជ្ឈាយ៍*    *មានពាក្យនិន្ទាតែរាល់វត្ត ។*
*បាដិមោក្ខពីររយម្ភៃប្រាំពីរ*    *អ្នកល្ងង់ហើយខ្ជិលចាំមិនស្ទាត់*
*កងបាចិត្តិយនឹងទុក្កដ*    *ចូលមាត់ចូលកមិនដឹងខ្លួន ។*
*កងបាចិត្តិយកៅសិបពីរ*    *និស្សគ្គិយ៍សាមសិបបារាជិកបួន*
*បើចេះហើយចាំឱ្យមាំមួន*    *ល្អបរិសុទ្ធសួនមិនសាយសុស ។*

ប៉ុន្តែសិក្ខាមិនសូវចាំ ចំណាំត្រង់ណោះចោលត្រង់ណោះ
ត្រង់ណាដែលដឹងជាខ្លួនខុស ហ៊ានឈ្លោះពីព្រោះគេមិនដឹង ។
៧០ សង្ឃាទិសេស ប្រហែសបាន ដប់បីសន្ធាន ប្រមាណថ្លឹង
បើធ្លាប់សង្រួបឱ្យយ៉ាងតឹង មិនអរមិនខឹងមិនខាតខុស ។
ឥន្ទ្រីយ៍ប្រាំមួយ នាំឱ្យភ្លាត់ ជាចិត្តិយ៍ទុក្កដ លាយចំរុះ
ឥន្ទ្រីយ៍ត្រចៀកភ្នែកច្រមុះ ភ្នែកមើលណោះណោះឃើញសុសសាយ ។
សោតិន្ទ្រិយោស្វរតិចខ្លាំង ចក្ខុន្ទ្រិយំឃើញជិតឆ្ងាយ
ជិវ្ហិន្ទ្រិយាពោលនាយអាយ សើចលេងសប្បាយចំអន់គ្នា ។
បរិស័ទ្យអាបត្តិទុក្កដញឹក បារាជិកច្រើនណាស់តែឧបជ្ឈាយ៍
ទ្រព្យក្នុងសំបាច់សំបូណ៌ហៀវ ត្រូវទោសអទិន្នាគរុភណ្ឌ ។
ទ្រព្យសង្ឃជាដើមគឺចំណាំ អវហារម្ភៃប្រាំចាំគ្មេរគ្មាន់
ឱបទុកខ្នះខ្នែងក្រែងមិនគ្រាន់ អវហារប្រាំជាន់បារាជិក ។
៧៥ ម្យ៉ាងទៀតទ្រព្យសង្ឃក្នុងចំណែក កិបទុកមិនចែកឱ្យលោកភិក្ខុ
គ្រឿងយាវជីវកកាលិក ទុកខ្លួបល្ងាចព្រឹកម៉ោតែឯង ។
ម្យ៉ាងទ្រព្យគេហៃចូលវិហារ ជាសកបូជាដល់គម្ពែង
គេវេរបាលីមានខ្លីវែង គេតែងនឹងថាសង្ឃស្ស ។
ប្រកាសប្រគេនជំនុំសង្ឃ ចំពោះគ្រប់អង្គថាទេមះ
លោកសង្ឃសាធុគ្មានសល់ម្នាក់ សង្ឃរាជទុកដាក់មិនចែកចាយ ។
ខ្ញុំបាទថែងតាមខ្ញុំចេះចាំ អវហារម្ភៃប្រាំបែកបរិយាយ
នេះសុទ្ធតែសីលផ្ទួសអន្តរាយ លោកសង្ឃទាំងឡាយកុំប្រព្រឹត្ត ។
ពីព្រោះឥន្ទ្រីយ៍ទាំង ៦ លោកណាមិនព្រួយមិនប្រុងគិត
លោភោមោហោបាំងងងឹត សិស្សមានគំនិតមិនហ៊ានថា ។

៨០ សូមមានសន្តោសសំដែងច្បាប់ ព្រះសង្ឃកុំចាប់ចងទោសា
ខ្លួនខ្ញុំសូមសុំបវារណា ប្រោសប្រាណមេត្តាគ្រប់បណ្តាសង្ឃ ។
ខ្ញុំមិនមានពោលពាក្យបង្កាច់ ខ្លាចសីលលោកដាច់ខ្ញុំដម្រង់
ដម្រូវតែតាមច្បាប់ព្រះអង្គ ព្រះឱស្ឋត្រឹមត្រង់ត្រូវមាត្រា ។
កាលអង្គសម្តេចព្រះចមភព បន្ទូលប្រារព្ធគ្រប់ប្រការ
ប្រកាសប្រាកដបទសិក្ខា ប្រញប្តប្ដេជ្ញាមហាបរិស័ទ្យ ។
ភិក្ខុភិក្ខុនីអស់អរហន្ត អានន្ទមិនទាន់បានអរហត្ត
ព្រះធម៌វិន័យកុំឱ្យបាត់ ប្រយ័ត្នឱ្យគង់ប្រយោជន៍យូរ ។
*ក្រោយនោះព្រះអង្គចូលនិព្វាន អរហន្តហោះធ្យានមានជាគ្រូ*
*មិនមានអក្ខរាណាដាក់ទូ ទេសនាបង្ហូរពីព្រះឱស្ឋ ។*
៨៥ ព្រះអគ្គសាវកគ្រប់ព្រះអង្គ ព្រះទ័យស្រោចស្រង់ទ្រង់សន្តោស
សំដែងធម៌អាថ៌មេត្តាប្រោស បាបបុណ្យគុណទោសនឹងសីលទាន ។
ឈ្វេងយល់ថាធម៌នឹងសូន្យស្ងាត់ អរហន្តអរហត្តចូលនិព្វាន
សង្ឃសេក្ខបុគ្គលមិនទ្រង់ញាណ មិនមានអក្ខរាណាតែងទុក ។
*ព្រះធម៌ប្រាំបីម៉ឺនបួនពាន់ ស្រេចលើអានន្ទចាំទំនុក*
*ដំណែលព្រះអង្គដឹងគ្រប់មុខ ជង្រុកធម៌អាថ៌បហារអានន្ទ ។*
ជាព្រះអនុជអាណិតសត្វ ក្រែងបាត់បិដកមិនគ្រប់គ្រាន់
ព្រះធម៌ប្រាំបីម៉ឺនបួនពាន់ គ្មេរគ្មាន់ខ្នះខ្នែងចាត់ចែងចារ ។
ចេះចប់អភិធម្មចាំរហូត វិន័យព្រះសូត្រ ៥ ប្រការ
ប្រកាសអស់អង្គអរហន្តា បិដកឯណាជាឫគល់ ។
៩០ បរមត្ថព្រះសូត្រអានន្ទចាំ វិន័យទាំង ៥ ឧបាលីយល់
អរហន្តទាំងអស់កើតរវល់ អំពល់អំពីរឿងធម៌អាថ៌ ។

ព្រះបាទអជាតសត្រូវ ជួយគិតជម្រូវព្រះសាសនា
សម្មតិឱ្យឈ្មោះហៅក្សត្រា ព្រោះព្រះមហាក្សត្រិយ៍ចូលគំនិត ។
និយាយឱ្យដឹងដើមកំណើត កកើតអក្ខរាចារស្លឹករឹត
បកប្រែបាលីសេចក្ដីពិត ពិនិត្យត្រឹមត្រូវតាមពុទ្ធដីកា ។
ទសជាតក៍ទាំង ១០ មានគ្រប់វត្ត ប្រែត្រូវប្រាកដព្រះគាថា
ព្រះធម៌សូត្រមន្ត ឬសូត្រដារ អ្នករៀនអក្ខរាពីរចំណែក ។
*ចំណេះចំណាំចាំដោយខ្លួន ខ្លះរៀនមានក្បួនចាស់ចារចែក*
បានភ្នាល់ព្រោះអាងឃើញនឹងភ្នែក កើតឈ្លោះប្រកែកប្រកួតខឹង ។
៩៥ *ប្រកាន់តែខាងខុសរហូត មិនរៀនមេសូត្រឱ្យចេះដឹង*
*អាងចេះតែកកាប៉ុណ្ណឹង ខំប្រឹងចំអើតអួតខ្លួនត្រូវ ។*
*ក្ដៅណាស់ពីរឿងយោជាយ៉ោ ដំឡើងភ្នែកស្មោមុខក្រញូវ*
*ថាធ្លាប់យោនាពីខ្មោចឪ ឥឡូវយ៉ោណាមិនសុខចិត្ត ។*
អ្នកម្នាងអាងស្រះតួប្រាំបី ឱ្យដឹងបាលីជាក៏រឹត
ផ្សំតួមេសូត្រប្រឹងប្រែប្រឹត ព្រោះត្បិតឱ្យត្រឹមត្រូវមាត្រា ។
អ្នកបួសគ្រប់វត្តគ្រប់នគរ **ស** ដាក់ជើង **ល** រាប់ស្លស្លា
បើ **ស** ជើង **ម** រាប់ស្មស្មា អ្នកមានប្រាជ្ញាល្មមស្ដាប់បាន ។
កុំល្ងង់ទាល់ងាប់ធ្លាប់មិនដឹង បើខឹងខ្ញុំឃាត់ថាឱ្យខាន
**ខ** ដាក់ជើង **ម** ពីបុរាណ ក្មេងតូចប៉ុន្មានស្គាល់ ខ្ម ខ្មា ។
១០០ *ជាតិរាស្ដ្រចាស់ក្មេងកុំចិត្តខ្មាំង គួរខ្មាសបារាំងអ្នករាជការ*
*ដើមហេតុអំពីព្រះករុណា ឱ្យសាងសាលាប្រែបាលី ។*
ទ្រង់ចាំទំនៀមពីបុរាណ ហើយបានជំនុំព្រមកុង្សីយ
បំណាច់ធ្វើស្ដេចគ្រងផែនដី ទិសទាំងប្រាំបី រំពៃគ្រប់ ។

ព្រះកាយពលមិនរវល់វែក ព្រះទ័យរំលែកទាំងថ្ងៃយប់
ចូលទែនបន្ទំទីបន្ទប់ បន្ទូលមិនឈប់រាល់វេលា ។
មេត្តាប្រោសប្រាណអ្នកមានស័ក្តិ ព្រះទានលុយកាក់គ្រប់ភ្នាក់ងារ
ទ្រង់ត្រួតស្ត្រីសុំស្រីង្គារ ក្រែងគ្រូនរងាមិនបានសុខ ។
ព្រះទ័យមេត្តាសព្វមនុស្សសត្វ សោយរាជសម្បត្តិសមៀមស្ដុក
ព្រះកាយប្រកបគង់ស្រណុក ព្រះទ័យវិតក្កជាធម្មតា ។
១០៩ *មួយព្រួយនឹងឱបព្រះនគរ ពីរព្រួយនឹងពព្រះសាសនា*
*បីត្រួតលោកសង្ឃកាន់សិក្ខា សង្រួមកិរិយាមិនបរិសុទ្ធ ។*
*នឿយណាស់ព្រះនេត្រព្រះកាណ៌ា ព្រះឱស្ឋត្រួតត្រាច្រើនបំផុត*
*ដាស់តឿនបំភ័យពួកកុលបុត្រ ឱ្យប្រុងលំឱតសង្រួមកាយ ។*
*បានចេញប្រកាសដាក់ប្រាកដ ប្រគេនគ្រប់វត្តទោះជិតឆ្ងាយ*
*លោកសង្ឃមិនត្រូវស្រើបសប្បាយ អស់ល្បែងទាំងឡាយគ្រប់ចំពូក ។*
*មិនត្រូវចំពោះស្ដាប់តន្ត្រី កុំបីមើលរាំវានាំភ្លូក*
*កុំដើរភ្លើ១មើលអុំទូក អ្នកបួសធ្វើលោកមិនត្រូវការ ។*
*បើមានត្រូវកិច្ចដើរយប់ថ្ងៃ សង្ឃបងនិស្ស័យចាស់វស្សា*
*កុំដើរទីមស្មាទៅណា១ អ្នកចេះសិក្ខាគេទាស់ភ្នែក ។*
១១០ *លោកនេនកុំសុំលុយចិនចាយ បិណ្ឌបាតតែបាយម្នាក់១វែក*
*គ្រឿងម្ហូបចំណីបាសកចែក កុំស្ពាយពុនវែកវាចោកឫក ។*
*របស់បាសកគេប្រគេន ប្រគល់លោកនេនបានលោកភិក្ខុ*
*ចិញ្ចឹមជីវិតនឹងបាយទឹក បិណ្ឌបាតតែព្រឹកយប់សូត្ររៀន ។*
លោកណាត្រឹមត្រូវមិនសូវខុស ស្ទេ្យមស្ទាត់ទៅចុះកុំអន់អៀន
លោកណាមិនចេះកុំរេះរៀន ពាក្យប្រៀនប្រដៅឱ្យផ្ដើលភ្ជាក់ ។

*ពីព្រោះព្រះអង្គបានផ្ដាំផ្ញើ វិន័យស្ថិតលើស្ដេចមហាក្សត្រ*
*ព្រះមហាចមពង្សទ្រង់ជំពាក់ ចំពោះធុរៈនឹងសាសនា ។*
ពីត្រឹមនោះវៀងជរាបមក ដល់ស្រុកគោកធ្លកមានសាវតារ
ប៉ុន្មានរាជ្យហើយមិនដឹងថា ដល់មកករុណាយើងសព្វថ្ងៃ ។
១១៩ ហេតុនេះលោកសង្ឃប្រុងពិនិត្យ សៀវភៅស្លឹករឹតមានរាល់ដៃ
ផ្ទៀងមើលសិបផូកវិនិច្ឆ័យ បើនៅសង្ស័យឱ្យសិក្សា ។
លោកសង្ឃចាស់ខ្ចីគប្បីស្ដាប់ ឈ្មោះ **ច្បាប់គន្លងព្រះពុទ្ធដីកា**
បង្គំថ្វាយដល់ព្រះករុណា សូមទ្រង់មេត្តាជ្រាបព្រះទ័យ ។
ក្រែងជួនប្រទះពាក្យផ្ដាំឆ្គង ពុំត្រូវទំនងក្រឹត្យវិន័យ
សូមទានសន្ដោសអត់ទោសពៃរ៍ ក្រួញក្រាបសិរសីក្រោមព្រះបាទ ។
ព្រះសង្ឃទាំងអស់ទោះតូចធំ អភ័យទោសខ្ញុំសូមអនុញ្ញាត
ពាក្យខ្ញុំមិនមានពោលប្រមាថ សង្ឃជាល្អស្អាតខ្ញុំមិនថា ។
ខ្ញុំពោលតែលោកធ្វើអាក្រក់ បើខ្ញុំកុហកខូចមុសា
ហេតុនោះខ្ញុំសូមបវារណា និង្ឃីតាសង្ខេបតែប៉ុណ្ណេះ ។
១២០ *ក្មេងណាប្រាថ្នាបួសធ្វើសង្ឃ ឱ្យស្វែងដឹងរង់រៀនដឹងរេះ*
*ឱ្យមើលជម្រាប់លោកអ្នកចេះ កុំដេកតែអេះតិះដៀលគ្នា ។*
អ្នកម្ដាយឪពុកឱ្យឈ្មោះ **អ៊ុំ** ពូជពង្សអំបូរខ្មែរអ្នកជា
អាពុកឈ្មោះ **អ៊ុក** មានស័ក្ដិងារ ចៅពញាធម្មធារាធ្វើមេស្រុក ។
ក្នុងខែត្រភ្នំពេញឃុំកំបូល ជាប់ផៅត្រកូលម្ចាស់អង្គ **ម៉ុក**
អាពុកអ្នកម្ដាយឈ្មោះពញា **ម៉ុក** គាត់ធ្វើមេស្រុកឃុំស្ពានថ្ម ។
អ្នកម្ដាយអាពុកបងប្អូនជិត ជីទួតមួយពិតពូជចិត្តល្អ

ចាស់ទំផ្សំផ្គុំជាដំណា បង្កកើតខ្ញុំទូលបង្គំ ។
បង្កើតអំពីដើមគំនិត ភ័យភិតខ្លាចបាបចង់បានបុណ្យ
បានបែកចែងច្បាប់ប្រាប់មហាជន ប្អូនច្បាប់ពីមុនជូនរាជការ ។
១២៥ បោះពុម្ពសៀវភៅចែកសព្វសាយ បណ្ណាល័យចាត់ថ្វាយព្រះករុណា
មិនបានថ្វាយផ្ទាល់ដល់ហត្ថា សូមទ្រង់មេត្តាប្រោសប្រណី ។
ឱនកាយប្រណម្យសូមអនុញ្ញាត្ត ក្រាបក្រោមព្រះបាទព្រះបារមី
ចែងច្បាប់បរមត្ថអត្ថបាលី សេចក្ដីចែងចប់ម្ល៉េះហើយហោង ។

**ព្រះភិរម្យភាសា អ៊ូ ពៅ ខ៉ុយ**

# លក្ខណៈពិសេស នៃជនជាតិខ្មែរ

ជនជាតិខ្មែរ ភាគច្រើនមានសម្បុរស្រអែម គឺមិនខ្មៅពេក មិនសពេក មានកំពស់មធ្យមប្រមាណ ១៦០ ស.ម សម្បុរភ្នែកទ្រង់ខ្មៅ សក់រួញ ឬរួញអង្កាដី មិនធាត់ មិនស្គម លលាដ៍ក្បាលមិនវែង មិនមូល គឺកណ្តាល (Meso-cephalic) បបូរមាត់មិនក្រាស់ពេក មិនស្តើងពេក ។ លក្ខណៈដូច្នេះ យើងអាចប្រៀបធៀបស្រដៀង ឬលក្ខណៈដូចពួកមនុស្សនៅលើកោះមេឡាណេស៊ី (Melanesia) តាំងនៅលើផ្ទៃមហាសមុទ្រប៉ែកខាងកើត ខាងត្បូង និងខាងលិចប្រទេសអូស្ត្រាលី (Australia) ។ មេឡាណេស៊ី ប្រកបដោយកោះច្រើនណាស់ មានកោះនូគីនេ New Guinea ជាដើម មានប្រជាជនច្រើនអំបូរ ។ គេចែកជាក្រុមធំបីគឺ Papuan Negroid និង Melanesian ។ ពាក្យថា Melanesia ជាពាក្យក្រិក ញែកបានពីរម៉ាត់ : Melas (ខ្មៅ) និង Nesos (កោះ) រួមជា Melanesia ប្រែថា កោះមានមនុស្សសម្បុរខ្មៅ ។ តែមនុស្សលើកោះដែលហៅថាមេឡាណេស៊ីនោះ មានពណ៌ខ្មៅល្មមទេ សក់រួញ បបូរមាត់ និងលលាដ៍ក្បាលមិនធំ មិនតូច ។

ឯប្រជាជាតិខ្មែរសព្វថ្ងៃ ប្រើពាក្យថា *មេ* ឬ *ម៉េ* ។ អ្នកមានមុខដំណែងក្នុងឃុំ -ស្រុក គេតែងហៅថា មេឃុំ មេស្រុក មេកន្ទ្រាញ មេបា មេធ្មប់ មេកងមេទ័ព ។ ល ។ ប្រវត្តិខ្មែរពីអតីតៈ បញ្ជាក់អោយឃើញថា យកស្រីជាធំ គឺបូជាស្ត្រីភេទ ឧទាហរណ៍ : ព្រះនាងរាជិនី ឬ លីវយី ជារាជិនីប្រមុខខ្មែរ សម័យផ្តើមប្រវត្តិសាស្ត្រ ។ បើយើងពិចារណាវប្បធម៌ជនជាតិមេឡាណេស៊ី ដូចពោលមកហើយនោះ ក៏ឃើញថាមានលក្ខណៈស្រដៀងគ្នាទៀត គឺជនជាតិមេឡាណេស៊ីនេះ

រាប់ពូជខាងម្ដាយជាគោល (Maternally) ក្នុងការបន្តពូជក្នុងគ្រួសារមួយៗ ។ លោកសឺដេស (G. Coedes) បាននាំសំដីលោក Vanleur មកអាងក្នុងសៀវ.ភៅរបស់លោកថា ពួកមនុស្សនៅលើផ្ទៃសមុទ្រដែលគេអោយឈ្មោះ Austro-nesoid នេះ សុទ្ធតែលើកម្ដាយជាធំទាំងអស់ (Matriachate) ។

*ជំនឿអ្នកតា* : ប្រជាជាតិខ្មែរសព្វថ្ងៃ មានជំនឿម្យ៉ាង យ៉ាងខ្ជាប់ខ្ជួនថា នៅតាមភូមិ ឃុំ ស្រុក ខេត្ត និងនគររបស់ខ្លួន មានវិញ្ញាណក្ខន្ធបុព្វបុរសខ្លួន ដែលមានឈ្មោះថាអ្នកតា បីបាច់រក្សាទៅតាមជាន់ថ្នាក់ ។ អ្នកតាទាំងឡាយនោះ ចេះរៀបចំតំបន់ស្រុកទេស ហើយរើសចៅភ្នាក់ងារដែលមានបច្ចេកទេស អោយទៅនៅប្រចាំ ដូចជា អ្នកតាព្រះឥសូរ, អ្នកតាព្រះនារាយណ៍, អ្នកតាដងកើ ជាអ្នកចាំត្រួតត្រា រក្សាអាណាខេត្តប្រទេសកម្ពុជាទាំងមូល ។ ឯនៅតាមខេត្ត គេប្រគល់តំណែងជូនដល់អ្នកតាឃ្លាំងមឿង តែនៅតាមស្រុកដោយច្រើន គេហៅតំណែងទៅតាមស្រុកដែលអ្នកតានៅ, ឧទាហរណ៍ : អ្នកតាបាណន់ ( បាត់ដំបង ) អ្នកតាពមសីមា, អ្នកតា ប ( បប៉ៃលិន ) ។ ល ។ នៅតាមផ្ទះសំបែង គេប្រគល់អោយអ្នកតាមេភូមិ ដែលមានឈ្មោះថាព្រះភូមិ ជាអ្នករក្សាអាណាខេត្ត ត្រឹមបរិវេណភូមិប៉ុណ្ណោះ ។ ក្នុងសៀវភៅព្រះរាជពិធីទ្វាទសមាស បានសន្និដ្ឋានតាមសេចក្ដីក្នុងច្បាប់ព្រះរាជគ្រូមហាឫសីបន្ទូលទុក លេខ ត.៥០ ថា មានពាក្យថា « អ្នកទេព្ដា » ច្រើនអន្លើក្នុងបទបួងសួង ។ ពាក្យ « អ្នកទេព្ដា » នេះ អាចរួញទៅជាអ្នកតា ។ ពាក្យនេះ ឃើញថាមិនអាចក្លាយទៅបានទេ ព្រោះនៅទំព័រទី១ លោកថាពាក្យថា « អ្នកតា » ជាភាសាខ្មែរ គូគ្នានឹង « អ្នកដូន » ។ យើងយកពាក្យថា « អ្នកតា » មកពិចារណាមើល តើដូចពាក្យថា « អ្នកទេពតាទេ ? » យើងក៏ឃើញថា : ពាក្យថា អ្នកតា ជាពាក្យខ្មែរសុទ្ធ ដូចលោកអាងមែន ប៉ុន្តែ ពាក្យថា អ្នកទេពតា ជាពាក្យកូនកាត់ខ្មែរ + បាលី ។ ម្យ៉ាងទៀត ខ្មែរមានពាក្យថា អ្នកដូន

ក្លាយមកពីអ្នកទេពដូន បានឬអី ? ឆ្លើយថា មិនអាចដូច្នេះបានទេ គឺពាក្យថា អ្នកតា ក៏ជាអ្នកតារបស់ខ្មែរ ឯពាក្យថាទេពតា ក៏ជាទេវតារបស់ឥណ្ឌា ទើបត្រូវ ។

ខ្មែរយើងរាប់អានអ្នកតា តាំងពីបូរាណកាលមក ។ កំណត់កត់ហេតុចិន សម័យរាជវង្សឆិន ( ព.ស ៨០៨ . ៩៦២ ) បានពោលដល់ប្រទេសនគរភ្នំថា អ្នកស្រុកនគរភ្នំ គោរពរាប់អានខ្មោច ទេវតាណាស់ គេធ្វើរបដំណែលដោយសិរីទ្ធិ ។ ដល់ខ្មែរឡើងកាន់ភាពជាមហាអំណាច រវាង ព.ស ១៣៥០ . ១៨៥០ ក៏ឃើញថា នៅកាន់ខ្ជាប់អ្នកតា នៅឡើយដែរ ។

តាមកិច្ចការស្រាវជ្រាវ មានទស្សនៈយល់ឃើញអំពីរឿងអ្នកតា ដូចតទៅនេះ :

ប្រជាជនខ្មែរ តាំងពីបូរាណព្រេងនាយ មានការគោរពបូជារហូតដល់អោយអភិសិទ្ធិផ្សេងៗ ក្នុងក្រុមរបស់ខ្លួន អោយដល់វីរបុរសដែលបានបង្ហូរឈាមការពារអំបូរ និងទីលំនៅនៃអំបូររបស់ខ្លួន ។ វីរបុរសដូចនេះ មានឈ្មោះថាជាអ្នកតស៊ូ ។ ពាក្យថា ត នេះ មានន័យពីរគឺ ១. បានដល់ន័យថាភ្ជាប់, ២. បានដល់ន័យថា ការពារ ឬស៊ូ ។ ពាក្យថា ត បើធ្វើអោយទៅជាករណនាម ទៅជាតំណ (បន្ត), តំណ បើជានាមនាមដែលជាឈ្មោះវត្ថុ ឬមនុស្ស យើងមានពាក្យថាថ្ន (វត្ថុដែលតគ្នា) អ្នកត (គឺអ្នកតស៊ូ) ។ តាមលំអានប្រពៃណី និងរបៀបភាសាខ្មែរ ដូចជំរាបមកនេះ ឃើញថា ពាក្យថា « អ្នកតា គួរវិវត្តន៍មកអំពី " អ្នកត " » ។ ឯពាក្យមួយទៀតគឺ ពាក្យថា « តល្ល » ដែលធ្លាប់ប្រើពីបូរាណ សព្វថ្ងៃសរសេរថា " ដល់ " បើធ្វើអោយទៅជានាម ត្រូវថា « ត្នល់ » ។ សព្វថ្ងៃថា « ថ្នល់ » (ផ្លូវដែលសន្ទឹងពីម្ខាងទៅដល់ម្ខាង) ។ មនុស្សដែលយកដៃអោយទៅដល់អ្នកម្នាក់ទៀត ហៅថា អ្នកដល់ (អ្នកដាល់) បើតាមលំអាននេះឃើញថា ពាក្យថា «អ្នកត» គួរគូនឹងពាក្យថា អ្នកតល្ល (អ្នកដល់) ។ អ្នកទាំងពីរនេះ សុទ្ធតែខ្លាំងពូកែទាំងអស់

គឺជាអ្នកតទល់នឹងសត្រូវ ដើម្បីស្រុកទេសរបស់ខ្លួន ។ ពាក្យទាំងពីរម៉ាត់នេះ គួរក្លាយមកជា អ្នកតា, អ្នកដូន ដូច្នេះ ។

ប្រជាជនពួក Pigmoid, Negroid , Papuan ហើយនិង Melanesian នៅលើកោះដែលហៅថា Melanesia នោះ តាមសេចក្តីរាយការណ៍របស់លោក Roland W. Force បានអោយដឹងថា ប្រមុខ ឬមេនាំក្រុមរបស់ខ្លួន ត្រូវតែជា «អ្នកតស៊ូ» ដ៏ល្បី ហើយមានឈ្មោះសំឡេងល្អ (prowess) ទើបត្រូវជ្រើសរើសជាប្រមុខរបស់គេបាន ។ ពួកអ្នកនៅម្តុំកោះ នៃអាណាបរិវេណអូស្ត្រាលីនេះ និយមធ្វើរូបគោរព ព្រោះគេមានជំនឿក្នុងរូបគោរព ( Totemic belief ) នេះ យ៉ាងខ្ជាប់ខ្ជួន ។ ខ្ញុំជឿជាក់ថា រូបគោរពដូច្នេះ គឺជារូបតំណាងវីរបុរសរបស់ពួកខ្លួនជាមិនខាន, ត្រង់នេះ យើងគួរប្រៀបធៀបនឹងខ្មែរយើងដែលគេសាងរូបអ្នកតា ដើម្បីជាតំណាងវីរជនដែលតស៊ូដើម្បីការពារពូជ ឬទឹកដីរបស់ខ្លួន ( សព្វថ្ងៃ យើងឃើញគេសាងរូបសំណាកអ្នកពូកែ សឹងគ្រប់ខេត្ត ប៉ុន្តែគេនិយមហៅថា អនុស្សាវរីយ៍ទៅវិញ ) ។

*អំពីការសែនព្រេន បន់ស្រន់ :* តាមសេចក្តីរាយការណ៍របស់លោក Roland ដដែលនេះ បានបញ្ជាក់ថា « .... គ្រឿងឧបករណ៍ប្រើក្នុងពិធី (បួងសួងថ្វាយដល់ខ្មោច) នោះ គេត្រូវត្រះត្រៀមយ៉ាងវិចិត្របញ្ចង់ ។ ក្នុងពិធីនេះតែងតែមានការជប់លៀង និងមានរបាំរាំរែកផង ។ អ្នកកោះ Melanesia នោះមានការខ្លាចវិញ្ញាណក្ខន្ធបុព្វបុរស, ខ្លាចខ្មោច, ខ្លាចស្ពានទី, រហូតដល់ខ្លាចរបស់ដែលគេមើលមិនឃើញ (ដូច្នេះ កាលបើមានអ្វីមួយ) កើតឡើង គេតែងតែបួងសួង បន់ស្រន់ថ្វាយនេះ-នោះ ដោយមានមេមត់ (Behaviour) ជាអ្នកបញ្ចូលរូប... » ។

តាមសេចក្តីរាយការណ៍នីរបស់លោក Roland ដូចជំរាបមកនេះ គួរ

គួរអោយជឿតែម្តងថា ប្រជាជាតិខ្មែរ គួរបានបន្តទំនៀមការសែនព្រេន លៀង អារក្សថ្វាយតង្វាយដល់ខ្មោចបិសាច ឡើងអ្នកតា មកពីពួក Melanesia ជាមិនខាន !

*អំពីគ្រឿងអាវុធ :* អំពីការប្រើអាវុធ ធ្នូ ព្រួញ សរ ស្នា លំពែង ។ ល ។ ខ្មែរយើងហាក់ដូចទើបតែឈប់ប្រើអាវុធបែបនេះ នៅពេលមិនយូរកន្លងមកហើយ ។ ការប្រើអាវុធបែបនេះ ខ្មែរធ្លាប់ប្រើមកយូរយារណាស់ហើយ ភ័ស្តុតាងដែលយើងសំអាងក្នុងរឿងនេះ គេឃើញមានសេចក្តីក្នុងសិលាចារឹកចាម្ប៉ា ថា *កៅណ្ឌិន្យ* ក្រោយពីបានលំពែងអំពីព្រាហ្មណ៍អស្វទមន កូនរបស់ទ្រោណៈហើយ ក៏គ្រវែងទៅដើម្បីជាគ្រឿងសំគាល់ដល់កន្លែងតាំងក្រុងនាអនាគត-កាល ស្រេចហើយបានអភិសេករួមរស់ជាមួយព្រះរាជបុត្រីស្តេចនាគ ព្រះនាម ព្រះនាងសោមា .... ។ ភ័ស្តុតាងក្នុងរឿងនេះមួយកន្លែងទៀត យើងបានមកពីកំណាត់កត់ហេតុរបស់រាជទូតចិនពីរគណៈប្រតិភូគី កាំងថៃ និងជួយិង ថា កៅណ្ឌិន្យ អាចមកពីប្រទេសឥណ្ឌា ឬមាលេយ៍ បានយល់សប្តថាបុព្វបុរស (ទេវតាបុព្វបុរស) របស់ខ្លួន បានអោយធ្នូមកខ្លួន ហើយបានដឹកនាំខ្លួនអោយទៅដោយសារសំពៅជំនួញ ។ ព្រឹកឡើងបានទៅកាន់ព្រះវិហារ (បូជនីយដ្ឋាន) នៅទីនោះ បានឃើញធ្នូនៅនឹងគល់ឈើរបស់បិសាច ។ តមក បានដោយសារសំពៅមកដល់ក្រុងនគរភ្នំ ដោយអំណាចទេវឫទ្ធិស្តេចស្រីនៃនគរនេះ ព្រះនាម លិវ យី ចង់ប្លន់ដណ្តើមយកសំពៅ ដោយហេតុនេះ កៅណ្ឌិន្យ ទើបបាញ់សរពីធ្នូសិល្ប៍របស់ខ្លួនត្រូវ សំពៅព្រះនាង លិវ យី ។ ដោយការភិតភ័យ ទើបព្រះនាងញ៉មចាញ់ ។ កៅឌិន្យបានយកព្រះនាងជាភរិយា .... » ។

នៅតាមផ្ទាំងជញ្ជាំងថ្មនៅអង្គរ យើងអាចសង្កេតឃើញពលទាហាន ឬព្រះរាជាកាន់ធ្នូ ឬលំពែងជាប់នៅដៃច្រើនណាស់ រាប់មិនអស់ ។

ខ្មែរមានអាវុធដូច្នេះ គួរជឿថាមានពូជមកពីពួកមនុស្សនៅតាមកោះនានានៃអូស្ត្រាលីដែរ ព្រោះមនុស្សដូចពោលមកនេះ មានប្រើធ្នូ ប្រើសរ រហូតដល់សព្វថ្ងៃ ។

*ទិសខ្មោច :* គួរអោយសង្កេតថា ទិសផ្សេងៗ ដែលខ្មែរយើងហៅសព្វថ្ងៃ ជាពាក្យខ្មែរសុទ្ធ គ្មានខ្ចី ឬ ច្រឡំយកសំដីជាតិណាមកប្រើទេ ។ អំពីការសន្មតហៅទិសថា ខាងជើង ខាងត្បូង ខាងកើត និងខាងលិចដូច្នេះ អាចកើតឡើងដោយសារពិធីកប់ខ្មោច ។ ខ្មែរពីបូរាណ មុនទទួលកាន់លទ្ធិពុទ្ធសាសនា គង់និយមការកប់សាកសព ក្រោយពេលស្លាប់ទាំងអស់ ។ លុះដល់សព្វថ្ងៃ យើងក៏ឃើញថាប្រជាជាតិនៅតែនិយមកប់សាកសពនៅឡើយ ។

ឯទិសដែលខ្មែរខ្លាច មិនហ៊ានដេកបែរក្បាលទៅរកសព្វថ្ងៃគឺ ទិសខាងលិច (ជួនកាល ហាក់ដូចជាមិនហ៊ានបែរក្បាលទៅខាងត្បូងផង) ប្រពៃណីដូច្នេះគង់មកអំពីពិធីកប់សាកសព គឺគេនិយមអោយក្បាលសពទៅទិសខាងលិច ឬខាងត្បូង ។ ឯហេតុផលដែលយើងអាង ហាក់ដូចជាថា ទិសខាងកើត បានដល់កំណើតដែលយើងកើតជាមនុស្ស លុះដល់យើងបាត់បង់ជីវិតទៅ ហាក់ដូចជាកំណើតមនុស្សលិចបាត់ទៅដែរ ។ បើតាមទស្សនៈខ្ញុំផ្ទាល់ ខ្មែរបូរាណ ប្រហែលជឿថា ទិសដែលព្រះអាទិត្យរះ គឺជាកំណើតរបស់មនុស្ស ឯទិសដែលព្រះទិន្នករលិចទៅវិញនោះ ប្រៀបបាននឹងការចាកលោកនេះទៅវិញនៃមនុស្សម្នាក់ៗ ។

ទស្សនៈខាងលើនេះ គ្រាន់តែព្រាងៗ ស្រពិចស្រពិល មិនច្បាស់លាស់ យើងអាចជឿថា ខ្មែរជំនាន់មុន អាចមានហេតុច្រើនលំដូលាយជាងនេះទៅទៀត ក៏សឹងបាន ។ ហេតុដែលបុព្វបុរសខ្មែរយើងមានពិធីដូច្នេះ អាចមានទំនាក់ទំនងអំពីជំនឿខាងលទ្ធិ ដែលយើងបង្កើតយូរណាស់ មុនទទួលកាន់ព្រះពុទ្ធសាសនាម្ល៉េះ ។

តាមលទ្ធផល ដែលអ្នកប្រាជ្ញបុរាណវិទ្យា ( Archeologist ) បាន

ពិនិត្យរកទិសសាកសពដែលគេបានជីកឃើញនៅយុគណេអូលីទិច (Neolithic) នៅលើផ្ទៃដីប្រទេសថៃ មានលក្ខណៈជាភាគរយ ដូចតទៅនេះ :

- សពបែរក្បាលទៅទិសខាងត្បូង មាន ២១,៩%
- សពបែរក្បាលទៅទិសខាងលិចឆៀងខាងជើង មាន ៣៤,១%
- ឯទិសក្រៅពីនេះ មានលទ្ធផល ២ - ៣ % ប៉ុណ្ណោះ ។

ជំនឿខ្មែរអំពីទិសខ្មោច ដូចជំរាបមកនេះ ក្រៅអំពីមានលក្ខណៈដូចគ្នានឹងសាកសពដែលគេបានជីកឃើញសពមនុស្សជំនាន់ Neolithic ហើយ ក៏នៅមានលក្ខណៈដូចគ្នានឹងពួកមនុស្សដែលលោក ពីវេត P. Pivet ហៅថា « ពួកសមុទ្រ » (Oceanien) ។ ពួកសមុទ្រនេះ ខ្ញុំសំដៅយកមនុស្ស ដែលលោក ជីន យូឌីន បានពោលទុកក្នុងសៀវភៅរបស់លោក (Foot Note) ថា គឺជាពួកឥណ្ឌូណេស៊ី ចាកន (Jakan) មេនត្រា (Mentra) សេមាំង (Semung) និង សាកៃ ( Sakai ) ។ នេះជាឧបករណ៍ ក្នុងការប្រៀបធៀប :

ជាតិឥណ្ឌូណេស៊ី និយមកប់ខ្មោចអោយបែរក្បាលទៅទិសខាងលិច ព្រោះគេជឿថា នៅទិសនេះមានរូងដែលអាចចុះទៅកាន់ពិភពបាតាលបាន - រូងនេះជាផ្លូវដែលព្រះអាទិត្យចុះទៅបញ្ចាំងរស្មីនៅពិភពបាតាល ក្រោយដែលបញ្ចាំងលើមនុស្សលោករួចហើយ ។ ជួនកាល កប់ខ្មោចនៅពេលព្រះអាទិត្យកំពុងតែអស្ដង្គត ដើម្បីអោយព្រះអាទិត្យជួយនាំវិញ្ញាណក្ខន្ធទៅផង ។

ពួកអ៊ូស៊ុន (Ousun) ក៏និយមអោយសពបែរក្បាលទៅខាងលិចដែរ ព្រោះមានជំនឿថា ពិភពបាតាលនៅខាងលិច ។

ពួកមេនត្រា (Mentra) និយមកប់ខ្មោចដោយអោយសាកសពអង្គុយ ឬឈរបែរមុខទៅខាងលិច ( ពិធីនេះទេដឹង ដែលខ្មែរអ្នកមានឋានន្តរសក្តិខ្ពស់បានទទួលមក .... ព្រោះដោយច្រើន ខ្មែរអោយសពអង្គុយក្នុងកោដ្ឋ ... » ) ។

ពួកសេមាំងនៅប្រទេសម៉ាឡេស៊ី មានជំនឿថា មនុស្សស្លាប់ហើយ វិញ្ញាណក៏នឹងធ្វើដំណើរទៅកាន់ស្រុកដែលមានដើមស្រល់ (Screw Pines and Match-Pines) នៅទីនោះ មានរូងដែលជាផ្លូវនៃព្រះអាទិត្យគោចរ ក្រោយថ្ងៃលិច ។

ពួកនេគ្រីតូស (Negritos) និងពួកសាកៃ ដែលនៅលើជ្រោយម៉ា-ឡេស៊ី ក៏និយមកប់សាកសពបែរទៅខាងលិចដែរ ព្រោះមានជំនឿថា ទិសនេះជាផ្លូវដែលខ្មោចដើរ ។

រួចមកហើយនេះ យើងកំពុងតែស្រាវជ្រាវរកដាន ដើម្បីដើរអោយដល់ចំណុចដែលថា « តើ *ខម* និង *ខ្មែរ* ជាជាតិតែមួយ ឬផ្សេងគ្នា ? »

តាមលក្ខណៈផ្លូវកាយ និងវប្បធម៌នៃសង្គម ដែលស្រដៀង ឬដូចគ្នារវាងជនជាតិខ្មែរ និងពពួកមនុស្សបុរាណ ដែលសព្វថ្ងៃរស់នៅលើផ្ទៃមហាសមុទ្រប៉ាស៊ីហ្វិក និងតាមព្រៃព្រឹក្សាជ្រៅក្នុងអាស៊ីអាគ្នេយ៍នោះ ឃើញថា ល្មមនឹងវិនិច្ឆ័យរកតំណបថា ប្រជាជាតិខ្មែរសព្វថ្ងៃ ភាគខ្លះមានពូជតំណអំបូរពីជនជាតិដែលសព្វថ្ងៃមានជីវភាពរស់នៅស្រដៀងយុគថ្មនៃព្រេងនាយ ។ ពពួកមនុស្សបុរាណអស់នោះ គឺជាមនុស្សដែលមានឈ្មោះថា អូស្ត្រូឡូអ៊ីត មេឡានេសូអ៊ីត Austroloid Melanesoid ។ ប្រជាជនដែលហៅថា Austroloid និង Melanesoid នោះ បានដល់អំបូរជាតិនានាដែលសព្វថ្ងៃហៅថា Papuan; Negritos; Melanesian; Semung ។ ល ។ អំបូរមនុស្សដូចពោលមកហើយនេះឯងបានចោលគំរោងឆ្អឹង និងគ្រឿងប្រើប្រាស់រាត់រាយ ដេរដាសពាសពេញលើភាគទាំង ៥ នៃអាស៊ីអាគ្នេយ៍យើង ។ តមក អ្នកប្រាជ្ញបុរាណវិទ្យា (Archeologits) បានរកឃើញ ហើយអោយយើងជ្រាបថា ពពួកមនុស្សអស់នេះហើយដែលធ្លាប់ឃើតយកដែនដីអាស៊ីអាគ្នេយ៍នេះ ជាទីអាស្រ័យរហូត តាំងពីយុគថ្មចាស់

ដែលហៅថា យុគប៉ាលីអូលីទីក (Palaeolithic period) ដល់យុគថ្មថ្មី ដែលហៅថា Neolithic ដូចជិរាបមកតាមលំដាប់ស្រាប់ហើយ ។ ជំនាន់យុគថ្មចាស់ និងថ្មកណ្ដាល ឃើញថាមនុស្សបុរាណ មិនបានសាងអារ្យធម៌ទុកច្រើនទេ, គេបានរកឃើញត្រឹមតែគ្រឿងប្រើប្រាស់ដែលធ្វើពីថ្ម ត្បូង ឆ្អឹងសត្វ ព្រមទាំងវប្បធម៌ម៉្យាង ដែលហៅថាMegalith និង Microlith គឺជាវប្បធម៌ថ្មតម្រៀប ឬថ្មជួរ; កូនចៅមនុស្សបុរាណពួកនេះ មាននៅទូទៅសព្វថ្ងៃ ។ លោក James Hornell បាន មានប្រសាសន៍ថា : « ពួកមនុស្សដែលមានដើមកំណើតលើជ្រោយឥណ្ឌូចិន ឬ តាមកោះនានានេះ បានផ្សាយទៅនៅពាសពេញលើផ្ទៃដី ដែលហៅថាឥណ្ឌាសព្វថ្ងៃនេះ មុនសម័យកាលចូលមករុករាននៃជនជាតិអារ្យៈ » ។

សេចក្ដីនេះ សអោយឃើញថា ពួកមនុស្សបុរាណដែលជាពូជខ្មែរមួយភាគនេះ ធ្លាប់បានចូលទៅនៅពេញប្រទេសឥណ្ឌា មុនយុគដែលជាតិអរិយកៈចូលមករុករាននៅសម័យដែលប្រទេសឥណ្ឌា មិនទាន់បានកកើតជាប្រទេសនៅឡើយម៉្លេះ ។ នៅសម័យនោះ បើតាមលក្ខឋានខាងព្រះពុទ្ធសាសនាប្រាប់ថា ពួកជនដែលនៅមុនជាតិអរិយកៈនេះ មានឈ្មោះថាមិលក្ខៈ គឺជនមិនមានស៊ីវិល័យ ឬមនុស្សថោកទាប ។ ពេលនោះ ពូជខ្មែរត្រូវជនអរិយកៈបង្អាប់ណាស់ គេស្អប់មិនប៉ានអោយចូលរួមសង្គមរបស់គេទេ ព្រោះពួកអរិយកៈប្រកាន់ជាតិ ប្រកាន់ថ្នាក់ណាស់ (ព្រះពុទ្ធជាម្ចាស់របស់យើង ព្រះអង្គមិនពេញព្រះទ័យនឹងអំពើឈ្លានពានមនុស្សនៃជាតិអរិយកៈទេ ) ។

ភស្តុតាងដែលអោយឃើញម៉្យាងទៀតថា ពួកមនុស្សអំបូរ Austro Asiatic បានធ្លាប់នៅលើដី ដែលសព្វថ្ងៃហៅថាឥណ្ឌានោះ គឺគេបានជួបគ្រឿង

ប្រើប្រាស់ ដែលហៅថា Shouldered celts ឬ Shouldered Tenen គឺគ្រឿងឧបករណ៍ជាថ្ម មានលក្ខណៈដូច «ដឹងមានស្មា» ជារបស់ប្រចាំពួក Austro Asiatic ។ យុគ Neolithic នេះ នៅពាសពេញត្រង់ទិសជ្រុងខាងជើង ឆៀងខាងកើតនៃផ្ទៃដីប្រទេសឥណ្ឌា និងប៉ែកខាងជើងប្រទេសចិន ព្រមទាំងមានទូទៅនៅលើផ្ទៃដីភាគកណ្តាលនៃអាស៊ីអាគ្នេយ៍ ។ លោក R.C.Majumdar អ្នកប្រាជ្ញល្បីឈ្មោះម្នាក់ បានពោលថាពួក Dravidian ឬដែលហៅថាអារ្យជននេះ បានចូលរុករានដែនដី ដែលសព្វថ្ងៃមានឈ្មោះថាឥណ្ឌានេះ ពីទិសខាងត្បូងឆៀងខាងលិច ជាហេតុរុញអោយពួជមនុស្សដើមនៅឥណ្ឌាពីមុននេះ ទៅនៅឥណ្ឌាប៉ែកខាងកើត និងខាងត្បូងទៅវិញ ។

លុះចំណេរកាលតមក ពួកមនុស្សដែលត្រូវពួកអរិយកៈបណ្តេញនេះ បាននាំគ្នារត់ភៀសខ្លួនទៅនៅអាស៊ីអាគ្នេយ៍ ដោយបាននាំអារ្យធម៌ជំនាន់ដើមរបស់ខ្លួនជាប់មកផង ។

ដល់ត្រង់នេះ សូមបញ្ជាក់ថា ពួកមនុស្សដែលហៅថាអំបូរ Austro Asiatic នៅប៉ែកខាងឥណ្ឌា បានរត់មកនៅរួមជាមួយ Austro Asiatic ដូចគ្នាដែលនៅស្រេចហើយលើផ្ទៃដីអាស៊ីអាគ្នេយ៍នេះ ។ ប៉ុន្តែពួកខាងក្រោយនេះ យើងនៅមិនទាន់ដឹងថា ជាអំបូរជាតិណា, មកពីប៉ុន្មានឆ្នាំហើយ នៅឡើយទេ ។

រឿងនេះ យើងគួរប្រគល់អោយលោក Eric Seidenfaden ដែលលោកបានមានប្រសាសន៍ក្នុងសៀវភៅមួយរបស់លោក ដែលគេបានប្រែជាភាសាថៃ ឈ្មោះជាតិវង្សវិទ្យា (ឆាតិវង្សវិទយ៉ា) ២៥១៩ ទំព័រ ៧-៨, សេចក្តីថា : «ប្រមាណ ៣៥០០ ឆ្នាំមកហើយ ជនជាតិដែលនិយាយភាសា Austro Asiatic អំបូរមន-ខ្មែរ បាននាំគ្នាភៀសខ្លួនពីឥណ្ឌាប៉ែកខាងជើង មកនៅអាស៊ីអាគ្នេយ៍នេះ ។

អំបូរមន - ខ្មែរ ។ ឯឆ្នាំនោះ គេប្រមាណ ៣៥០០ ឆ្នាំមុននេះ ។

ដូច្នេះ ជំនឿកាលពីយូរណាស់ហើយ ដែលថាខ្មែរដើម គឺជាតិឥណ្ឌានោះ ហាក់ដូចជាខុស គួរមានពាក្យស្លោកថ្មីថា ឥណ្ឌាដើម គឺជាតិខ្មែរទៅវិញ ទើបហាក់ដូចត្រូវល្អជាង !

តទៅនេះ យើងត្រូវរកទីកន្លែងដែលអំបូរមន-ខ្មែរ ពីសម័យ ៣៥០០ មុននេះ បានមកនៅលើទឹកដីអាស៊ី ។ តែសូមយល់ថា មុនយុគដែលអំបូរមន-ខ្មែរ ពីដែនដីដែលហៅថាប្រទេសឥណ្ឌាសព្វថ្ងៃមកអាស៊ីអាគ្នេយ៍នោះ មានមនុស្សជាបុព្វបុរសមន-ខ្មែរ បាននៅស្រេចអស់ហើយ ពួកនេះ បើយើងសំអាងទៅតាមល័ក្ខឋានបុរាណវត្ថុ ដែលជីកឃើញនៅ *បានឆៀង* ( និងជំរាបតទៅនៅយុគលោហៈ ) បានអោយដឹងថា ពួកមនុស្សដែលនៅអាស៊ីអាគ្នេយ៍ ពិសេស គឺត្រង់ភូមិភាគផ្ទៃកណ្ដាលនៃអាស៊ីអាគ្នេយ៍ នៅភាគឦសានថៃ និងប្រទេសលាវ មានវប្បធម៌ខ្ពស់ណាស់ទៅហើយ ។

ដើម្បីជាប្រយោជន៍ក្នុងការស្រាវជ្រាវអំពីកន្លែង ដែលមន-ខ្មែរ មកនៅនោះ យើងត្រូវអាងឯកសារដែលជាប្រយោជន៍ក្នុងរឿងនេះ ហើយសឹមយើងសរុបយកន័យខ្លះមកនិយាយ ។

*(នៅមាន ត )*

ស្រាវជ្រាវដោយ **ហៀន ចណ្ណារ័ត្ន**

# ការសិក្សាសម័យបុរាណ[១]



នៅប្រទេសកម្ពុជា ការសិក្សាកើតមានហើយ តាំងពីសម័យព្រេងនាយ ។ តែការសិក្សានេះ ដើមឡើយមាននៅតែក្នុងព្រះរាជសំណាក់ ។ ព្រះរាជកុមារា ព្រះរាជកុមារី បុត្រធីតា មន្ត្រីតូចធំ សុទ្ធតែបានទទួលការសិក្សាបរិបូណ៌ ។ ប្រទេសកម្ពុជា កាន់ព្រះពុទ្ធសាសនា និងសាសនាព្រាហ្មណ៍ ។ ដូច្នេះ ការសិក្សាស្ថិតក្នុងឥទ្ធិពលនៃសាសនាទាំងពីរនេះ ។

## សម័យនគរភ្នំ ( Founan )

នៅសម័យនគរភ្នំ ការសិក្សាបានចម្រើនហើយ ។ ភិក្ខុ-សាមណេរ បានទទួលការសិក្សារហូតដល់វិជ្ជាជាន់ខ្ពស់ ។ កាលនោះ មានព្រះថេរះអង្គខ្លះបានរៀនដល់ភូមិសិក្សាកំរិតខ្ពស់ ចេះវិជ្ជាច្រើនប្រការ មានភាសាសាស្ត្រជាដើម ដូចព្រះមហាថេរ **សង្ឃបាល**[២] ។ ក្នុងរជ្ជកាលព្រះបាទកៅណ្ឌិន្យ គ្រិស្តសតវត្សទី៥ ព្រះមហាថេរះអង្គនេះបាននិមន្តទៅកាន់ប្រទេសចិន ។ ព្រះចៅក្រុងចិន ទ្រង់ប្រោស

(១) ដកស្រង់ចេញពីទស្សនាវដ្ដីខេមរយានកម្ម លេខ ៧ ឆ្នាំ១៩៦៨ ។

(២) Culture et Civilisation Khmers No.6 សកលវិទ្យាល័យព្រះសីហនុរាជ ភ្នំពេញ

ប្រាណណាស់ ។ ព្រះមហាថេរ **សង្ឃបាល** បានប្រែព្រះត្រៃបិដក និងគម្ពីរវិសុទ្ធិមគ្គ ទៅជាភាសាចិន នៅការិយាល័យនគរភ្នំ (Founan quan) នាប្រទេសចិន ។ ស្នាព្រះហស្តជាភាសាចិន មានសេចក្តីវិសេសវិសាលណាស់ ពុំមានអ្នកណាម្នាក់ អាចស្នានបានថាជាស្នាដៃខ្មែរឡើយ ។ ដូច្នេះហើយបានជា ព្រះចៅក្រុងចិនសព្វព្រះរាជហឫទ័យ ហើយថ្វាយព្រះអង្គជាសិស្ស ។ ទ្រង់បានកសាងវត្តមួយប្រគេនសម្រាប់ឱ្យគង់នៅ ដោយក្តីក្សេមក្សាន្ត ។ លទ្ធិពុទ្ធសាសនាមហាយាន ក្នុងសកលលោក បានស្គាល់ព្រះនាម **សង្ឃបាល** នេះច្បាស់លាស់ណាស់ ។ គេថែមទាំងបានចារឹកព្រះនាមនេះ ទុកនៅក្នុងគម្ពីរព្រះត្រៃបិដកចិនទៀតផង ។ កេរ្តិ៍ឈ្មោះប្រទេសកម្ពុជា អណ្តែតត្រសែតខ្ពង់ខ្ពស់ត្រឡុងត្រឡាយ ដោយសារព្រះមហាថេរអង្គនេះ រហូតដល់សព្វថ្ងៃ ។

## សម័យចេនឡា

ក្នុងសម័យនេះ ការសិក្សាក៏លូតលាស់ចម្រើនណាស់ដែរ ។ អ្នកសិក្សាអក្សរសាស្ត្រសំស្ក្រឹត បានទទួលការសិក្សាខ្ពង់ខ្ពស់ហើយដែរ ។ ក្នុងរាជសំណាក់មានត្រកូលមន្ត្រីជាន់ខ្ពស់មួយ មានការចេះដឹងដ៏ពិសេស បានជាប្រធានមន្ត្រីច្រើនរាជ្យ តាំងពីរជ្ជកាលព្រះបាទរុទ្រវរ្ម័ន គ.ស ៥១៤ រហូតមកដល់រាជ្យព្រះបាទជ័យវរ្ម័នទី១ គ.ស ៦៨១ ។ ក្នុងត្រកូលនេះ មានមន្ត្រីម្នាក់ឈ្មោះសិង្ហវីរៈ ជាចិន្តកវីឯក ក្នុងរាជ្យព្រះបាទឦសានវរ្ម័ន គ.ស ៦២៦ ។ កាព្យលោក ជាកាព្យជើងឯក ។ លោកមានបុត្រាមួយឈ្មោះសិង្ហទត្ត ធ្វើជាគ្រូពេទ្យ ហើយជាអ្នកប្រាជ្ញនៅក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី១ ។ ព្រះរាជាអង្គនេះ តែងតាំងលោកជានាយកក្រុងអាឍ្យបុរៈ ។ លោកសិង្ហទត្តនេះហើយ ដែលតែងអត្ថបទសិលាចារឹកអង្គជំនីក[(១)] សរសើរបិតាលោក

(១) អង្គជំនីក = ពុទ្ធិកសិក្សាឆ្នាំទី ២, លេខ ៨, ទំព័រ ៩ ។

ថា « ជាកវីជើងឯក ចេះតែងកាព្យដ៏ប្រសើរ ដែលគេផឹកមិនចេះឆ្អែត » ។

## សម័យមហានគរ

មកដល់ពេលនេះ ការសិក្សាឡើងដល់ថ្នាក់ខ្ពស់បំផុត ។ មានអ្នកប្រាជ្ញច្រើននាក់ ទាំងអ្នកប្រាជ្ញផ្នែកព្រះពុទ្ធសាសនា ទាំងផ្នែកសាសនាព្រាហ្មណ៍ ខ្លះជាបុរោហិត ខ្លះជាព្រះរាជគ្រូ ( រាជគុរុ ) ។ ក្នុងរាជសំណាក់ មានមហាវិទ្យាល័យជាន់ខ្ពស់ សម្រាប់ព្រះរាជត្រកូល ។ នៅក្នុងវត្តជ័យស្រី (ព្រះខាន់) ព្រះនាងឥន្ទ្រទេវីជាព្រះអគ្គជាយានៃព្រះបាទជ័យវរ្ម័នទី៧ ទ្រង់ជាសកលវិទ្យាធិការ ។ នៅក្នុងវត្តរាជវិហារ (តាព្រហ្ម ) ព្រះមហាថេរថ្នាក់បណ្ឌិតមាន ១៨ អង្គ, ជាសាស្ត្រាចារ្យ មាន ២៧៤០ អង្គ[១] ។ ទាំងអស់នេះជាសក្ខី[២] ទូការសិក្សានាសម័យនោះ ។ ស្នាដៃអ្នកប្រាជ្ញទាំងនេះ មានតម្លៃរកកាត់ថ្លៃមិនបាន រកគួរប្រៀបបានដោយកម្រ សូម្បីតែកវីព្រាហ្មណ៍ ដែលនៅក្នុងប្រទេសទន្លេគង្គា (ឥណ្ឌា) ក៏ពុំអាចយកឈ្នះបានឡើយ ។ អ្នកសិក្សាទាំងប៉ុន្មាន កាលបើបានឃើញស្នាដៃកវីបុរាណ ពិសេស ស្នាដៃកវីសិវសោម ទិវាករ ព្រះនាងឥន្ទ្រទេវី កិតិបណ្ឌិត សូរ្យកុមារ ។ ល ។ ហាក់ដូចបានក្រេបទឹកអម្រឹតដែលគេផឹកមិនចេះឆ្អែត ។

សេចក្តីដូចបានពោលដោយសង្ខេបមកនេះ សបញ្ជាក់ថា ប្រទេសកម្ពុជាយើង មានការសិក្សាតាំងពីសម័យបុរមបុរាណ ហើយមានការសិក្សាតាំងពីថ្នាក់ទាបដល់ថ្នាក់ខ្ពស់ ទៀតផង ។ ឯការចាត់ថ្នាក់សិក្សាវិញសោត ទោះបីយើងមិនបានដឹងជាលំអិត ក៏យើងអាចយល់បានថា មិនមានអ្វីប្លែកពីសម័យក្រោយ គឺក្នុងគ្រិស្តសតវត្សទី១៩ ប៉ុន្មានឡើយ ។

---

(១) ប្រវត្តិពុទ្ធសាសនាប្រទេសខ្មែរ ទំព័រ ៨៩ ។

(២) សរសរ, បង្គោល ។

ការសិក្សាយើងសម័យបច្ចុប្បន្ននេះ មានការចាត់ថ្នាក់ប្រកបដោយរបៀបរៀបរយល្អទៅតាមកាលៈទេសៈ ។ តែភូមិសិក្សានៅទន់ខ្សោយនៅឡើយ មិនទាន់បានទទួលលទ្ធផលគួរអោយពេញចិត្ត បានន័យថា យើងដើរមិនទាន់ដល់បុព្វបុរសយើង នៅឡើយទេ ។

## សម័យក្រោយមហានគរ

ការសិក្សាយើងក្នុងគ្រឹស្តសតវត្សទី១៦ ទី១៧ ទី១៨ ធ្លាក់ចុះទន់ខ្សោយណាស់ ស្ទើរតែរលត់ទៅហើយ ។ តែទោះបីយ៉ាងណា ក៏ការសិក្សានេះគ្រាន់តែរៀវស្ងួចតូច តែមិនដល់ថ្នាក់ដាច់នោះឡើយ ហើយចេះតែបន្តបានវៀងរហូតមកដល់សម័យយើងនេះ ។ លទ្ធិសាសនាព្រាហ្មណ៍រលត់បាត់ទៅហើយ តែប្រពៃណីសិក្សាតាមបែបព្រាហ្មណ៍នោះ បានជាប់ស្ថិតស្ថេររហូតមកដល់បច្ចុប្បន្ននេះ ។ សព្វថ្ងៃយើងកាន់ពុទ្ធសាសនា ការសិក្សាតែងតែផ្អែកលើពុទ្ធសាសនា តែប្រពៃណីការសិក្សានៅយកតាមលទ្ធិសាសនាព្រាហ្មណ៍នៅឡើយ គឺយើងឱ្យកូនចៅទៅនៅវត្ត ព្រះមហាថេរ គឺ សម្តេចព្រះសង្ឃរាជ រាជាគណៈ ឋានានុក្រម ចៅអធិការ ជាសា-ស្ត្រាចារ្យ ជាអាចារ្យ ជាគ្រូ ពោលគឺ វត្តជាសាលារៀន វត្តជាសកលវិទ្យាល័យ ។ វិជ្ជាគ្រប់បែបយ៉ាងស្ថិតនៅក្នុងវត្ត ។ វត្តជាជង្រុក ឬឃ្លាំងសារពើវិជ្ជា គឺ អក្សរ-សាស្ត្រ គណិតសាស្ត្រ ហោរាសាស្ត្រ ពេទ្យសាស្ត្រ សិល្បសាស្ត្រ យុទ្ធសាស្ត្រ វិស្សុកម្មសាស្ត្រ ។ ល ។ កុលបុត្រ កុលធីតា សុទ្ធតែជាសិស្សវត្ត ។ ចេញពីវត្តទៅអាចជាព្រះមហាក្សត្រ សេនាបតី នាម៉ឺន មន្ត្រីកាន់ក្រសួងត្បូងការនៅក្នុងប្រទេស ។ ពាក្យ «ក្រសួង»(១) ខ្មែរបុរាណ ហៅថា « ទ្រូង » ។

(១) ពាក្យនេះ សៀមខ្ចីយកទៅប្រើ តែអានថា«ទ្រូង»មិនបាន ដោយភាសាសៀមជាអំបូរភាសាថៃ-ចិន ហើយអានទៅជា«ស្វង=សួង គឺអក្សរជ្រ ឬទ្រ ទៅជាអក្សរ«ស» ដូចបទខ្មែរមួយថា «ខ្មែរជ្រៃយោគ» ថៃថា « ខ្មេនសៃយោគ » ។ ជ្រៃវ៉ា > សៃវ៉ា, ទ្រង់ជ្រាប > សុងសាប ។

នេះហើយជាប្រពៃណីការសិក្សារបស់យើងពីបុរាណ បានជាគេហៅវត្តថា «ក្តី = កុដិ» បានន័យថា អ្នកដែលចេញពីវត្ត សុទ្ធជាអ្នក « ដឹងក្តី » ។

នៅក្នុងសតវត្សទី ១៦, ទី១៧, ទី១៨, តាមការដែលបានដឹងមកថា ការសិក្សារបស់យើងចុះរៀវរោយពន់ពេកណាស់ ។ ក្នុងសម័យនោះ មិនមែនតែការសិក្សាទេ អ្វីៗក៏ធ្លាក់ស្រឹមចុះទាំងអស់ នៅក្នុងប្រវត្តិសាស្ត្ររបស់យើង ។ គេថា បើលោកលាញហើយ ធមិក៏នឹងត្រូវលាញទៅដែរ បើលោកចម្រើន ធមិក៏ត្រូវចម្រើនដែរ ។ តែលោកក៏ត្រូវពឹងធមិ បើលោកដើរម្នាក់ឯង ឥតមានធមិ នោះមុខជាផ្ទុះឆេះចេញជាភ្លើង ។

## ក្នុងសតវត្សទី ១៩

មកដល់សម័យនេះ ការសិក្សាចាប់ផ្តើមចម្រើនឡើងវិញ ។ សាស្ត្រាច្បាប់ សាស្ត្រាល្បែង សាស្ត្រាទេសន៍កើតឡើងច្រើន ។ ការសិក្សាវិជ្ជាជាន់ខ្ពស់ក៏កើតមាន ឡើងវិញ ។ មានចាត់ចែងអោយសិក្សាភាសាបាលីនៅក្នុងក្រុង ក្នុងវត្តធំៗ ។ អ្នកប្រាជ្ញក៏កើតមានច្រើនដែរ ។ ក្នុងព្រះរាជសំណាក់ក៏មានការសិក្សា នៅតាមវត្តអារាមទាំងឡាយទូទៅ នៅក្នុងព្រះរាជាណាចក្រក៏សុទ្ធតែមានការសិក្សា ។

ក្នុងរាជ្យព្រះបាទហរិរក្សរាមា ( ព្រះអង្គដួង ) ព្រះអង្គជាមហាស្តម្ភ ដ៏ប្រសើរក្នុងការសិក្សា ។ ទ្រង់ជាអ្នកប្រាជ្ញ ទ្រង់ជាកវី ទ្រង់ជាបណ្ឌិត ទ្រង់ជាអ្នកនិពន្ធដ៏វិសេស ហើយទ្រង់ក៏ជាសាស្ត្រាចារ្យឯក ទៀតផង ។

ក្នុងសម័យនោះ ព្រះបរមរាជវាំងឧដុង្គជាសកលវិទ្យាល័យ ដែលមានព្រះអង្គទ្រង់ជាសកលវិទ្យាធិការ ។ ទ្រង់បង្រៀនវិជ្ជាអក្សរសាស្ត្រខ្មែរ វិជ្ជាកាព្យ វិជ្ជា-និពន្ធ ទ្រង់បង្រៀនបាលី បង្រៀនធមិ ទស្សនវិជ្ជាពុទ្ធសាសនា និងវិជ្ជាផ្សេងៗទៀតផ្ទាល់ព្រះអង្គ ។ ក្រៅពីរាជភារកិច្ចគ្រប់គ្រងដឹកនាំប្រទេសដ៏ធ្ងន់ធ្ងរ ទ្រង់បាន

ឆ្លៀតព្រះបរមរាជវរោកាសដ៏មានតម្លៃរបស់ព្រះអង្គទៅក្នុងការសិក្សា ទ្រង់បង្រៀនព្រះបរិយត្តិធម៌ដល់ភិក្ខុសាមណេរទៀតផង ។ ព្រះរាជដំណាក់ឃ្លាំង ដែលនៅចំពីមុខព្រះទីនាំងទេវាវិនិច្ឆ័យឧដុង្គ ជាមន្ទីរសិក្សា ។ ព្រះរាជបរិវារ ក៏បានទទួលការសិក្សា ។ ក្រៅពីភារកិច្ចរបស់ខ្លួន ម្នាក់ៗសិក្សាបរិយត្តិធម៌ រៀនបែបបទផ្សេងៗ តាមបំណងរៀងៗខ្លួន ដូចជាភិក្ខុសាមណេរ នៅ តាមវត្តអារាមដែរ ។

ចាស់ទុំបានដំណាលថា ក្នុងរដូវកាន់បិណ្ឌ ១៥ ថ្ងៃ ទូទាំងព្រះរាជាណាចក្រ ក្នុងព្រះរាជសំណាក់ក៏មានធ្វើរាជពិធីនេះដែរ គឺមានការធ្វើវត្តព្រឹក វត្តល្ងាច ទៀបភ្លឺ ។ ពេលព្រឹក ព្រះរាជបរិវារធ្វើវត្តព្រឹក ហើយសូត្របទបរាភវសូត្រ ដូចនៅក្នុងវត្តអារាមដែរ ។ គេសូត្របទនេះពិរោះណាស់ សម្លេងឮគ្រលួចទៅលើអាកាស ឮរហូតចេញទៅក្រៅព្រះបរមរាជវាំងទៀតផង ។ កាលនោះ មានអ្នកស្រែម្នាក់ ក្រោកពីព្រលឹមចេញទៅភ្ជួរស្រែ លុះលីនឹមដើរដល់មុខព្រះបរមរាជវាំង ឮបទពិរោះពេកភាំងស្មារតី គាំងដើរទៅមុខពុំរួច ចេះតែលីនឹមត្រឡប់ចុះត្រឡប់ឡើង ទាល់តែចប់បទបរា ទើបដឹងខ្លួនដើរទៅស្រែរួច ។ បទនេះ គួរពិរោះពិត ព្រោះសុទ្ធតែសម្លេងស្រីស្មុំ ក្រមការ ដែលបានសិក្សាពីព្រះឱស្ឋផ្ទាល់នៃព្រះករុណាជាម្ចាស់ជីវិត ត្រឹមត្រូវទៅតាមខ្នាតបន្ទាត់ មិនមែនចេះតែស្រែកឱ្យតែឮង៉ែង៉ៗ នោះឡើយ ។

ការសិក្សាវិជ្ជាភាសាខ្មែរនៅក្រោមព្រះរាជូបត្ថម្ភនេះ ហ្មត់ចត់ណាស់ ។ ពាក្យមួយម៉ាត់ៗដែលអានចេញមក សុទ្ធតែត្រឹមត្រូវជាភាសាខ្មែរ ដែលហៅថា បោរីវាចា ( ភាសាអ្នកក្រុង ) ដូចពាក្យថា *«ពស់»* ត្រូវអានតួ «ស» ជាទន្តជៈ (dental) ប្រកបអោយឮខ្យល់ «ស» ចេញមកតាមជើងធ្មេញ ។ ពាក្យថា *«ពោះ»* ត្រូវអានកំបុត ព្រោះវិសគ្គៈ ឬ វិសជ្ជនីយ គ្រាន់តែរះមុខ ដូច្នេះជាដើម ។

ព្រះករុណាជាម្ចាស់ជីវិត ទ្រង់ជាកវីឯក ។ ទ្រង់បង្រៀនពាក្យកាព្យ បង្រៀនឱ្យចេះតែងសេចក្ដីជាកាព្យត្រឹមត្រូវឥតខ្ចោះតាមលក្ខណៈបទ និងតាមជើង

កាព្យដែលមានចែងក្នុងកាព្យវិជ្ជា ដូចសាស្ត្រាកាកី ដែលជាព្រះរាជនិពន្ធស្រាប់ ។ សិស្សកវី ក្នុងព្រះរាជសំណាក់ សុទ្ធតែបានប្រឡង ដោយព្រះអង្គផ្ទាល់ស្តេចចេញប្រថាប់ជាប្រធានក្នុងការប្រឡង ។

ចាស់ទុំបានដំណាលថា ដងមួយនោះ ពេលប្រឡងសិស្សកវី ព្រះករុណាជាម្ចាស់ជីវិត ស្តេចចេញមកប្រថាប់ជាប្រធាននៅក្នុងព្រះរាជដំណាក់ឃ្លាំង សិស្សកវីចូលមកប្រឡងពីរនាក់ម្តង១ ចំពោះព្រះភក្ត្រ ។ ការប្រឡងនេះ ពុំមានការសរសេរទេ គឺសិស្សកវីត្រូវសូត្រកាព្យផ្ទាល់មាត់តែម្តង ។ សិស្សកវីម្នាក់អង្គុយក្នុងបន្ទប់ សិស្សកវីម្នាក់ទៀតអង្គុយនៅក្រៅបន្ទប់ ។ ទ្រង់ត្រាស់បង្គាប់ឱ្យកវីក្នុងបន្ទប់ចេញ «អឺយ» មុន, កវីទីមួយបញ្ចេញថ្វីមាត់ចប់ កវីនៅក្រៅបន្ទប់ចេញ «អឺយ» តបវិញភ្លាម មិនឱ្យបាត់ផ្សេងសំដីមិត្តខ្លួនទាន់ទេ ។ កវីទាំងពីរលេងសំដីផ្តោះផ្តង ឆ្លងឆ្លើយគ្នាហូរចេញជាពាក្យកាព្យ ចាប់ចុងចួនរណ្តំគ្នាយ៉ាងពីរោះណែងណង គ្មានឱ្យរអាក់បន្តិចឡើយ ។

ព្រះករុណាដែលទ្រង់ជាមេប្រយោគ បានផ្ទៀងព្រះកាណ៌ចាំស្តាប់ ។ កាលបើឃើញថាត្រឹមត្រូវហើយ ទ្រង់សព្វព្រះរាជហឫទ័យណាស់ ទ្រង់ព្រះសរួល ហើយប្រទានរង្វាន់តាមការគួរ ទើបតែងតាំងជាកវីពេញលក្ខណៈ ។ សេចក្តីនេះបញ្ជាក់ថា ការសិក្សាសម័យនេះ ចាប់ផ្តើមចម្រើនហើយ ។ ក្នុងព្រះរាជសំណាក់មានការសិក្សាជាពិសេស ។ នៅតាមវត្តអារាមទូទៅក្នុងព្រះរាជាណាចក្រ ក៏មានការសិក្សាដែរ ។ តើគេសិក្សាតាមរបៀបយ៉ាងណា ?

ការសិក្សាប្រព្រឹត្តទៅតាមប្រពៃណីដើមដដែល ។ មានតែកុមារាទេ ដែលបានទទួលការសិក្សា ។ ឯកុមារីវិញ ទោះបីពុំមានការហាមឃាត់ជាផ្លូវការ តែមានទំនៀមចងទូទៅពេញប្រទេសថា មិនគួរនឹងឱ្យស្ត្រីសិក្សាទេ វៀរលែងតែនៅក្នុងព្រះរាជសំណាក់ ។ ហៅថាការសិក្សាសម័យនោះ លោកសំដៅទៅលើការរៀន

អក្សរ រៀនអាន សូត្រកំណាព្យ សូត្រ លេខនព្វន្ត ធម៌អាថ៌ និងរៀនវិជ្ជាជីវៈ ។ ក្នុងការរៀនវិជ្ជាជីវៈ ខាងប្រុសៗ គេរៀនអារ ចាំង ឈូស ដាប់ឈើ ធ្វើផ្ទះ តុ ទូ ទូក ក្តារ ឥដ្ឋ គ្រឿង ត្បាញកញ្ជើ ល្អី កញ្ច្រែង ។ ល ។ ឯស្រីវិញ រៀនរវៃសូត្រ អំបោះ ត្បាញ ធ្វើគោម ចង្កៀង ទៀន ធូប ។ ល ។ នៅពេលរៀនចេះចប់ម្តងៗ គេធ្វើពិធីប្រឡងសាកចំណោះសិស្ស ។ ពិធីប្រឡងដែលមានភាពឧឡារិកអធិក អធមជាងគេ ច្រើនធ្វើនៅឱកាសមហាកឋិន ។ បន្ទាប់ពីប្រឡងខាងអក្សរ លេខ និងធម៌អាថ៌រួច ស្រីៗត្រូវទៅបញ្ចេញស្នាដៃខាងវិជ្ជាជីវៈទៀត ។ គេដាក់ឱ្យសិស្សស្រីទាំងនោះ រវៃអំបោះ ត្បាញសំពត់ ដេរជាស្បង់ ជ្រលក់ពណ៌ឱ្យហើយជាស្រេចក្នុងមួយថ្ងៃមួយយប់ ដើម្បីយកទៅដាក់វេរប្រគេនព្រះសង្ឃនៅឱកាសមហាកឋិន ។ នៅពេលប្រឡងនេះ ឧបាសក ឧបាសិកា ពីទីជិតឆ្ងាយ ចាស់ ក្មេង ក្រមុំ កំលោះ បានមកមូលមីរ ចោមរោមជិតជុំមើលសិស្សប្រឡង យ៉ាងសប្បាយរីករាយអធិក អធម ។

*(នៅមានត)*

រៀបរៀងឃ្លាឃ្លោងឡើងវិញ

ដោយ **មៀច ប៉ុណ្ណ**

# ចម្លើយកំណាព្យប្រស្នា
## កម្ពុជសុរិយា លេខ២
### ពាក្យ៧

មុននឹងអធិប្បាយស្រាយខ្លឹមសារ កំណាព្យប្រស្នាការឆ្លើយឆ្លង
ខ្ញុំម្ចាស់ចំណោទចោទចំបង សំដែងបំណងផងអាត្មា ។
អរគុណដោយស្មោះអស់លោកអ្នក ចូលរួមរាក់ទាក់ឆ្លើយប្រស្នា
ទោះបីត្រូវខុសខំដោះសា កម្ពុជសុរិយាសូមស្វាគមន៍ (១) ។
តទៅសូមជូននូវចម្លើយ ពិនិត្យរួចហើយអង្គប្រជុំ
ប្រទេសដែលឆេះសង្គ្រាមធំ ប្រជាទួញយំទុក្ខឥតល្ហែ ។
មិនមែននគរផងនានា ថៃ ឡាវ ភូមា វៀតណាម ខ្មែរ
នោះគឺល្បែងអុកលេងអ៊ូអែ គេចេះហូរហែទាំងឆ្ងាយជិត ។
ប្រស្នាកំបាំងតាំងសំណួរ ហាក់ពុំគាប់គួរនឹងការពិត
ថាស្ដេចមន្ត្រីឥតបីគិត ថ្លើមខ្មៅងងឹតបង្ហូរឈាម ។
មែនហើយរឿងនេះប្រឌិតទេ នគរយើងគេស្អប់សង្គ្រាម
ចង់តែជាតិរស់ខ្ពស់កិត្តិនាម មើលភ្លាមដឹងថាប្រស្នាក្លែង ។
ពាក្យថានគរ គឺ « ក្ដារអុក » ក្រឡាហុកបួនជូនច្បាប់ល្បែង
សងខាងមានស្ដេចរិទ្ធិចិញ្ចែង គោលបួនតាក់តែងប្រៀបមន្ត្រី ។
អែបស្ដេចទាំងទ្វេមាននាងពីរ រូបល្អសោភីហាក់មហេសី
ម្ខាង១មានកូនត្រីប្រាំបី ប្រស្នាហាស្ដីជាពលរេហ៍ ។

---
(១) សូមសំដែងស្វាគមន៍

ទូកបួនសេះបួនទ័ពទឹកគោក កញ្ជ្រោលកញ្ជ្រោកគ្មានទំនេរ
ឈ្នះចាញ់ស្លាប់រស់ឥតខ្វល់ទេ ស្រេចគេអ្នកលេងបានសន្មត ។
ចម្បាំងរាំងជល់វាល់ល្ងាចព្រឹក គគ្រេងគគ្រឹកពិតប្រាកដ
អុកប៉ុងម៉ុងម៉ាំងមិនមានហត់ សន្មតសង្គ្រាមឈាមដាបដាល ។
« ក្រឡាក្តារអុកហុកសិបបួន » « នឹងកូនសាមពីរកាព្យដំណាល »
ម្ខាងសម្ខាងខ្មៅរលោងច្រាល សេះឆ្លាក់តែក្បាលជាសំគាល់ ។
ស្តេចគោលនិងនាងកំពូលស្រួច ពីធំទៅតូចអាចមើលយល់
ទូកមូលសំប៉ែតទាបតូចទាល់ កូនត្រីរេហ៍ពលសំបកងារ ។
នេះឯងល្បែងអុកកាព្យប្រស្នា កម្ពុជសុរិយាអំពាវនាវ
ត្រូវចេះលេងស្ទាត់កុំព្រាវៗ តែក៏កុំភ្លាវលេងលង់យូរ ។
ជនណាងប់រក់ជក់អុកខ្លាំង ច្រើនស៊ីបាយក្តាំងម្ហូបផ្អមជូរ
ប្រពន្ធបងប្អូនកូនរអ៊ូ ព្រោះចាំបាយយូរយឺតការងារ ៕

ភ្នំពេញ, ថ្ងៃទី ២៩ - ០៨ - ៩៤

**ខណ្ឌ ស៊ុនហេង**

## វិទ្ធាន់លេខ ១

# ចម្លើយប្រស្នាកំណាព្យ

(បទពាក្យ ៧)

១ . ឱនកាយប្រណិប័តន៍ម្ចាស់ប្រស្នា កម្ពុជសុរិយាលេខចេញថ្មី
សួរពីក្សត្រាគ្រងទឹកដី ហេតុអ្វីនាំរាស្ត្រធ្វើចម្បាំង ?

២ . តើនគរនោះនៅឯណា មន្ត្រីសេនាសុទ្ធតែខ្លាំង
មានប៉ុន្មាននាក់ស្ម័គ្រតតាំង ចូលច្បាំងទប់ទល់លុះដល់មរណ៍ ។

៣ . ស្តេចមានព្រះនាមហៅអ្វីដែរ អោយអ្នកពូកែខិតខំរក
ឆ្លើយឆ្លងជាកាព្យទើបបានយក ផ្ញើមក៏អោយទាន់ពេលកំណត់ ។

៤ . ខ្ញុំសូមសាកល្បងលងបញ្ហា បកស្រាយប្រស្នាមិនប្រាកដ
ជាត្រូវឬខុសសូមទានអត់ ទោសទាត់លត់ចោលតាមធមិព្រះ ។

៥ . រឿងស្តេចអផ្សុកចង់ច្បាំងគ្នា ចោទក្នុងប្រស្នាក្រប្រទះ
ឆ្លើយតាមដើមដានលំអានចាស់ គឺច្បាស់ជា **ស្តេចអុកចក្រគ្គ** ។

៦ . ស្តេចនោះមានឈ្មោះហៅថា **ខុន** មហេសីល្វតល្វន់ស្រស់បញ្ចង់
គេហៅថា **នាង** ក្នុងរឿណរង្គ នៃបនិត្យអែបអង្គក្សត្របណ្តូល ។

៧ . រីឯសេនាក្រឡា ច.[(១)] ក្រីទាំងពីរនាក់គេហៅ **គោល**
**អស្សានិក**[(២)] ពីរមិនមែនទោល ទ័ពទឹកគេពោល **ទូក** សេនា ។

---

(១) ច . ក្រី សូមអានថា "ចាក់ក្រី " ដើម្បីអោយជួនក្នុងជើងកាព្យ ។ ក្រឡាចក្រី សំដៅឧកញ៉ាក្រឡាហោម និងឧកញ៉ាចក្រី ដែលជាសេនាបតីក្នុងសម័យបុរាណ ។

(២) អស្សានិក : ទ័ពសេះ

៨ . បត្តានីក[១] ថ្មើរជើងមានប្រាំបី កង គេហៅ **ទ្រី** តាមភាសា
អ្នកលេងល្បែងអុកស្គាល់គ្រប់គ្នា វីរាជសីមាតី **ភ្ជាវអុក** ។
៩ . ស្តេចអុកច្បាំងគ្នាមានតម្រា ដោយសារមនុស្សកើតរោគអផ្សុក ។
ប្រើ **ធ្វូក** ប្រើ **ទ្រី** អោយវាយលុក លេងអុកជាល្បែងល្បងប្រាជ្ញា ។
១០. ច្បាំងក្នុងចត្រង្គហាក់មែនពិត មានស្តេចមានឫទ្ធិមានសេនា
ធ្វើសឹកសង្គ្រាមយុទ្ធនាការ ក្រសាលកាយាការកំសាន្ត ។
១១. បត្តានីកថ្មើរជើងឈរជួរមុខ ចាំវាយសំរុកតទល់ប្រាណ
កុំអោយសត្រូវរុលចូលបាន រំខានពួនស្ទាក់គ្រប់ក្រឡា ។
១២. ជួរក្រោយសេនាង្គខ្លាំងពូកែ នៅក្បែរអមខាងមហាក្សត្រា
ចាំចុះវាយឆ្នក់ផ្តក់ប្រហារ បង្ការប្រយោលពីចម្ងាយ ។
១៣. មានទូកទ័ពទឹកសន្ទឹកពីរ កងការពារទីធំទូលាយ
ទិសត្រង់ទាំងបួនបត់បានងាយ ជិតឆ្ងាយរហ័សដូចចិន្តា ។
១៤. អស្សានីកទ័ព**សេះ**ជិះមនោម័យ ជាញូជ័យពីរកងខ្លាំងអស្ចារ្យ
អាចផ្លោះរំលងបីក្រឡា ប្រាំបីទិសាជុំវិញប្រាណ ។
១៥. ទ័ពសេះប្រៀបបានកាំភ្លើងធំ អាចផ្លោងជញ្ជាំការពារស្ថាន
ការពារមន្ត្រីនិងក្សត្រក្សាន្ត កុំអោយខ្មាំងប៉ានរុលចូលជិត ។
១៦. នៅក្បែរទ័ពសេះមានមន្ត្រី សេនាបតីពីររូបពិត
ឆ្វេងស្តាំចាំគាល់សុទ្ធមានឫទ្ធិ ទុកជាជំនិតព្រះមហាក្សត្រ ។
១៧. សេនាប្រៀបបាននឹងអង្គរ័ក្ស ឫទ្ធាអន័ត្ឋចាំវាយកាត់
ក្រែងទ័ពទូកសេះមិនប្រយ័ត្ន ខ្មាំងកាត់មកជិតព្រះភូមី ។

---

(២) បត្តានីក : ទ័ពថ្មើជើង

១៨. សេនាអាចវាយតាំងបាន ប្រាំស្ពានជិតខ្លួនការពារទី
រំដោះមហាក្សត្រម្ចាស់ជីវី និងរត្ននារីអគ្គមហេសី ។
១៩. ទៅក្រោយវាយឆ្វេងពីរទិសា ទៅមុខប្រហារបានទិសបី
វាយត្រង់វាយឆ្វេងដណ្តើមជ័យ សេនីយ៍អាចវាយរុលសំរុក ។
២០. អគ្គមហេសីសោកគួរស្ញែង ហ្វទ័យចំបែងគង់មិនសុខ
តែងចូលរួមច្បាំងការពារស្រុក ស្តេចស្តែងតែងទុកអែបអង្គា ។
២១. ទ្រង់មានព្រះទ័យស្វាមីភក្តិ ដូចសីតាស្ម័គ្រតាមរាមា
ហ៊ានយកជីវិតទៅពាំងពារ រាំងរាសត្រូវទិសឆ្វេងប្អូន ។
២២. ចុងក្រោយនោះគឺព្រះគម្ពែង អង្គឯងជាស្តេចសឹងថ្មីកក្បួន
ប្រាំបីទិសាជុំវិញខ្លួន ខ្មាំងគួនគុំកៀកមិនបានឡើយ ។
២៣. រីស្តេចម្ខាងទៀតក៏ដូចគ្នា រៀបពលយោធានៅបង្អើយ
បង្ហូកស្រែកហៅឮខ្ញៀវៗ ឆ្លងឆ្លើយប្រកាសសង្គ្រាមជ័យ ។
២៤. ទ័ពទាំង**សាមពីរ**ពេញកម្លាំង តពាំងតាមក្បួនយុទ្ធទីទៃ
ខាងណាមានប្រាជ្ញាវាងវៃ តែងដណ្តើមជ័យបានរាល់គ្រា ។
២៥. ចម្លើយពេលនេះចារចែងចប់ លើកម្រាមដៃដប់ឱនសិរសា
គារវៈចំពោះម្ចាស់ប្រស្នា ខុសឆ្គងមេត្តាអធ្យាស្រ័យ ។

*ភ្នំពេញ, ថ្ងៃទី ៩ ខែ សីហា ឆ្នាំ ១៩៩៤*

**សុខ សុមនោ**

រង្វាន់លេខ ២

# ចម្លើយកំណាព្យប្រស្នា

( បទកាកគតិ )

ឃើញប្រស្នាភ្លាម
អារម្មណ៍មិនស្ងៀម គិតស្រាយបញ្ហា នឿយហត់មិនគិត
ចង់ល្បងប្រាជ្ញា ចេញចោទប្រស្នា ត្រូវការអ្នកដោះ ។
*« នគរមួយប្លែក*
*កើតរឿងបាក់បែក គួរឱ្យស្រណោះ ទាំងស្ដេចមន្ត្រី*
*គ្មានធ្វើអ្វីសោះ គិតតែផ្ដេកផ្ដោះ ចម្បាំងរាំងជល់ ... »* ។
ដកន័យប៉ុណ្ណឹង
មករិះរំពឹង គន់គិតខ្វាយខ្វល់ លៃស្រាយប្រស្នា
ដោះសាចម្ងល់ ទៅតាមការយល់ យោបល់ដោយឡែក ។
ស្ដេចនគរនោះ
មិនមែនស្ដេចមនុស្ស ដូចបានវែកញែក គឺឈ្មោះស្ដេចល្បែង
**ចត្រង្គ** អង្គឯក សេនាបែងចែក ជើងគោកជើងទឹក ។
ស្ដេចព្រះនាម **ខុន**
ទ្រង់មានប្រពន្ធ នាម **នាង** ថ្កើងឫក ស្មុំគ្រធ្វើសង្គ្រាម
ចិន្តាឥតភ្លឹក តស៊ូវរឹក រួមនឹងភស្ដា ។

មេទ័ពជើងគោក

ឈ្មោះ**គោល**មានជោគ អគ្គសេនា ជូនកាលឈ្មោះ **មុិក**
តាមចិត្តគេថា សេនាអស្សពាហ៍ នាមាជា **សេះ** ។

លោតផ្លោះផ្លាញភ្លែត

ក្រឡាក្រឡៀត បានប្រាំបីទិស សេនាជើងទឹក
មាន **ទូក** ជំនិះ បញ្ចាបញ្ចិះ ទ័ពទឹងចូលច្បាំង ។

សេនាជួរមុខ

ជាកម្លាំងបុក សុទ្ធសឹងអ្នកខ្លាំង នោះគឺពល **ត្រី**
ទាំងប្រាំបីបាំង ការពាររារាំង ពលខ្លាំងបរបក្ស ។

តួអង្គក្សត្រា

មេបញ្ចាការ គង់កណ្ដាលថ្នាក់ អមដោយសេនា
ធំៗពីរនាក់ គោលសេះទូកជាក់ សុទ្ធតែមានគូ ។

នៅអែបនឹងទ្រង់

មានតែតួអង្គ នាងនាថនរូ ស្ថិតនៅជួរក្រោយ
សុទ្ធសឹងជាតួ បញ្ចាតស្ងូ ក្នុងសង្គ្រាមជ័យ ។

អង្គទ័ពប្រយុទ្ធ

ដប់ប្រាំមួយគត់ ទាំងពលសេនីយ៍ ទាំងស្ដេចមេទ័ព
ទាំងទូកសេះគ្គី ទាំងនាងក្សត្រី មហេសីក្សត្រក្សាន្ត ។

ខាងទ័ពសត្រូវ

តាមក្បួនតម្រូវ មានគ្នាប្រមាណ ជួរមុខជួរក្រោយ
ដប់ប្រាំមួយប្រាណ តួឯកអង្គមាន ដូចគ្នាទាំងអស់ ។

ពេលចូលវាយលុក

សេនាជួរមុខ ប្រាំបីនាក់ស្មោះ ស្ម័គ្រវាយប្រហារ
ស្លាប់ស្វាងរលោះ លុកលុយបង្ហួស រុលចូលទីខ្មាំង ។

មេទ័ពខាងក្រោយ

ឥតមានបណ្ដោយ ជួយជាកម្លាំង ការពារឆ្វេងស្ដាំ
ចងចាំប្រឆាំង ផាយស៊ីផ្ទងផាំង អុកបែកខ្ចាត់ខ្ចាយ ។

សង្គ្រាមតយុទ្ធ

ពុំមានស្លុងស្លុត ស្លាប់សូន្យអន្ដរាយ សល់កាន់តែតិច
ក៏មិនជិនណាយ ស្លាប់រស់ឥតស្ដាយ ព្រោះចង់ឈ្នះឈ្នាន ។

ផែនដីរដ្ឋា

មាននាមឈ្មោះថា **ភ្ការអុក** កំសាន្ដ លេងល្បែងប្រាជ្ញា
ទោះស្ដេចអ្នកមាន រាស្ដ្រផងព្រេងលាន លេងរាល់ថ្ងៃខែ ។

ភ្នំពេញ, ថ្ងៃទី ០៤ ខែសីហា ឆ្នាំ១៩៩៤

**មៀច ប៉ុណ្ណ**

មន្ត្រីក្រសួងធម្មការ និង សាសនា

រង្វាន់លេខ ៣

# ឆ្លើយកំណាព្យប្រស្នា

១. កម្ពុជសុរិយា

ចោទជាប្រស្នា ថារដ្ឋមួយប្លែក ទាំងស្ដេចមន្ត្រី
កើតរឿងបាក់បែក ឈ្លោះទាស់ជជែក ចម្បាំងរាំងជល់ ។

២. ច្បាំងប្រជែងឫទ្ធិ

ចំណាយជីវិត ធនធានរេហ៍ពល ដើងគោកដើងទឹក
វរវីកវិលវល់ វាយលុកទប់ទល់ ឈាមជោគផែនដី ។

៣. ខ្ញុំសូមសាកល្បង

លើកល្បើកសាសង ឆ្លើយឆ្លងសំដី តើនគរនោះ
ឈ្មោះនគរអី ស្ដេចព្រះនាមអ្វី ពលប៉ុន្មានគ្នា ។

៤. នគរខុសគេ

ស្ដេចនិងពលរេហ៍ ឥតគ្មេរការងារ គឺ « **ចតុរង្គ-**(១)
**នគរ** » នោះជា រដ្ឋកាប់ចាក់គ្នា ស្ដេចព្រះនាម*ខុន* ។

៥. រដ្ឋចែកជាពីរ

វិលវល់វក់វី ពលរដ្ឋភ័យកុន ទ័ព **ទូក** បើកក្ដោង
ទ័ព **សេះ** ក្រាញលុន រុញ **ត្រី** ទៅមុន ជនអត្តឃាត ។

៦. ទ័ពត្រីប្រឈម

អាធាត់អាស្ដម អួតអាងលុបមាឌ ប្ដេជ្ញាទៅមុខ
រុកការពារជាតិ សេះឆ្លោះឆ្លោងឃ្លាត **គោល** កាត់វាយផ្ដាច់ ។

---

(១) ចត្រង្គ

៧. ថ្លែងពីទ័ពទូក

ក្រឹត១គ្រូក១ ចែវលឿនប្រញាប់ ឃើញសេះជាប់កុន
ដ្បិត **នាគ** ដេញចាប់ បើកខ្វាកបុកខ្ទាប់ សម្លាប់នាងក្បៀយ ។

៨. ពលទោ **ក្រិចក**

ឃើញទូកងើបមក យារជើងប្រល័យ ទូកនោះភ្លេចខ្លួន
សប្បាយនឹងជ័យ ត្រីបកចឹកក្បៀយ សេះកុនក្រឡា ។

៩. ត្រីបកចំណាប់

ហក់លោតក្រឡាប់ ចាប់សេះប្រហារ ដ្បិតវេដេញខុន
ត្រូវដួលបះផ្ងារ ខុនម្ខាងឡាំប៉ា សេនារត់ប្រាស ។

១០. មន្ត្រីពលរេហ៍

ស្លាប់ព្រោះការ(១) មេ ប្រយុទ្ធស្វិតណាស់ ពលត្រីប្រាំបី
សេះពីរជើងចាស់ ទូកពីររហ័ស គោលពីរនឹងធឹង ។

១១. នាងមួយជួយត្រី

ការពារដែនដី រួមដៃគ្នាប្រឹង សាមពីរក្រឡា
ចែកគ្នាស្មើធឹង ម្ខាង១ពីតប្រឹង វាយយកឈ្នះដៃ ។

១២. សម្តេចខុនម្ចាស់

ទាំងពីរមុខក្រាស់ ប្រឈមរាល់ថ្ងៃ សកលពលរេហ៍
ស្វ័ជីវិតក្បៀយ ធនធានអន្តរាយ វិនាសសូន្យអីយ ។

ថ្ងៃទី ២៩ កញ្ញា ឆ្នាំ ១៩៩៤

**ឆ្វេច ជីម**

ក្រសួងធម្មការ និងសាសនា

(១) ការពារ

# សេចក្តីជូនដំណឹង

ស្តីពី

# ការប្រកាសលទ្ធផលនៃចម្លើយ «កំណាព្យប្រស្នា» ដែលចុះផ្សាយក្នុងទស្សនាវដ្តី លេខ ២ ឆ្នាំ១៩៩៤

គណៈកម្មការនិពន្ធនៃទស្សនាវដ្តីកម្ពុជសុរិយា មានសេចក្តីរីករាយ សូមប្រគេន និងជូនដំណឹងចំពោះព្រះតេជព្រះគុណគ្រប់ព្រះអង្គ និងអស់លោក អ្នកនាងដែលបានឆ្លើយប្រស្នាកំណាព្យ ចុះក្នុងទស្សនាវដ្តីកម្ពុជសុរិយា លេខ ២ ឆ្នាំ១៩៩៤ ថា ក្នុងចំណោមលិខិតចម្លើយទាំងអស់ មានលិខិតចំនួន ១២ ឆ្លើយត្រូវសំណួរ ។

គណៈកម្មការ បានធ្វើការចំរាញ់សិរិតសំរាំងយកតែអត្ថបទដែលឆ្លើយត្រូវល្អជាងគេចំនួន ៣ ដើម្បីរៀបចំណាត់ថ្នាក់ពីលេខ ១ ដល់លេខ ៣ ។ ចំពោះអត្ថបទដទៃទៀតដែលត្រូវដែរ តែសម្ផស្សកាព្យមិនសូវល្អ គណៈកម្មការសំរេចជូនរង្វាន់លួងទឹកចិត្តស្មើគ្នា ។

ដោយឡែក មានអត្ថបទពីរទៀតដែលឆ្លើយខុស តែមានអត្ថន័យគួរអោយពិចារណានោះ គណៈកម្មការក៏សំរេចជូនរង្វាន់លើកទឹកចិត្តដែរ ។

លទ្ធផលសំរេច មានដូចខាងក្រោម :

ក. រង្វាន់លេខ ១ : (ប្រាក់ចំនួន ៧០.០០០ រៀល) ត្រូវបានទៅលោក **សុខ សុមនោ** ផ្ទះលេខ ៨ អឺ០៣ ផ្លូវលេខ ១១១ សង្កាត់អូរឫស្សីទី១

ខ័ណ្ឌ ៧ មករា ក្រុងភ្នំពេញ ។

ខ. រង្វាន់លេខ ២ : (ប្រាក់ចំនួន ៥០.០០០ រៀល) ត្រូវបានទៅលោក **មៀច ប៉ុណ្ណ** មន្ត្រីក្រសួងធម្មការ និងសាសនា,

គ. រង្វាន់លេខ ៣ : (ប្រាក់ចំនួន ៤០.០០០ រៀល) ត្រូវបានទៅលោក **នួច ឋឹម** មន្ត្រីក្រសួងធម្មការ និងសាសនា,

ឃ. រង្វាន់លួងចិត្ត : (ប្រាក់ចំនួន ៥.០០០ រៀល) ចំនួន ៩ រង្វាន់ប្រគេន-ជូនអ្នកឆ្លើយត្រូវដែលមិនបានទទួលចំណាត់ថ្នាក់ ចំនួន ៩ រូប ដូចខាងក្រោម :

១. លោក **ភិម សោភ័ណ្ឌារិទ្ធិ** បុគ្គលិករោងពុម្ព ជេ.អេស.អ.ស៊ី (JSRC) ភ្នំពេញ,

២. ភិក្ខុ **ឃុន ស៊ិក** សមណសិស្ស គង់នៅវត្តនិរោធរង្សី ឃុំនិរោធ ស្រុកមានជ័យ ភ្នំពេញ,

៣. ភិក្ខុ **ផល សុភា** សមណសិស្ស កុដិលេខ ៨, វត្តឧណ្ណាលោម ភ្នំពេញ,

៤. ភិក្ខុ **គយ សុមេធ** កុដិលេខ ៨, វត្តឧណ្ណាលោម ភ្នំពេញ,

៥. ភិក្ខុ **សាគ សក្ការះ** បរមបណ្ឌិតោ , វត្តមហាមន្ត្រី ភ្នំពេញ,

៦. ភិក្ខុ **ប៊ិច សុផាត** កុដិលេខ ១៧, វត្តបទុមវតី ភ្នំពេញ,

៧. **ចិប៉ុល គីមហេង** កុដិលេខ ១៧, វត្តបទុមវតី ភ្នំពេញ,

៨. នារី **លាស់ រ៉ាជុំ** សិស្សថ្នាក់ទី១១ (I) វិទ្យាល័យព្រះកុសុមៈ ខេត្តក្រចេះ,

៩. លោក **សុខ ស៊ីថា** និស្សិតមហាវិទ្យាល័យពាណិជ្ជសាស្ត្រ ភ្នំពេញ,

៥ – រង្វាន់លើកទឹកចិត្ត : (ប្រាក់ចំនួន ៥.០០០ រៀល) ចំនួនពីររង្វាន់ ប្រគេនចំពោះ :

១. ភិក្ខុ **សោម សុមុនី** បទុមវង្សា វត្តឧណ្ណាលោម ភ្នំពេញ,

២. ភិក្ខុ **ព្រហ្ម សុជាតិ** វត្តអង្គ រយៀប ខេត្តកំពង់ស្ពឺ,

គណៈកម្មការនិពន្ធ សូមនិមន្ត និងអញ្ជើញជ័យលាភី ដូចមាននាមខាងលើ ទៅទទួលរង្វាន់នៅបណ្ណាធិការដ្ឋានទស្សនាវដ្ដី ដែលស្ថិតនៅពុទ្ធសាសនបណ្ឌិត្យ វត្តឧណ្ណាលោម នៅរាល់ម៉ោងធ្វើការ ។

គណៈកម្មការនិពន្ធ សូមឆ្លៀតឱកាសដ៏ប្រពៃនេះ ដើម្បីសម្ដែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តម **ចណ្ណ ស៊ិនហេង** អ្នកតំណាងរាស្ត្រមណ្ឌលព្រៃវែង ដែលបានបរិច្ចាគបច្ច័យផ្ទាល់ខ្លួន ដើម្បីផ្ដល់ជារង្វាន់ជូនជ័យលាភី ចាប់តាំងពីទស្សនាវដ្ដីលេខ ១ រហូតមក ។

*ភ្នំពេញ, ថ្ងៃទី ១៩ តុលា ១៩៩៤*

**កម្ពុជសុរិយា**

# កំណាព្យប្រស្នា (*)

## (បទរលកខ្ទប់ច្រាំង)

* កាព្យប្រស្នា ការប្រឌិត គិតប្រដូច បញ្ហាតូច ពង្រីកធំ ប្រមុំដាក់
អ្នកចេះដឹង ប្រឹងប្រែងដោះ អស់ថ្នាំងថ្នាក់ ចារបណ្ដាក់ ចាក់បណ្ដោយ ដោយប្រាជ្ញា ។
* កើតគំនិត គិតកំណាព្យ កាព្យចុងចួន សៀងសំនួន សួនសំណំ សមប្រាថ្នា
ចិតប្រាមោទ ចោទប្រមូល ចូលចិន្ដា ចាកឥច្ឆា ការសោកសោយ ដោយវិរិយៈ ។
* សូមសណ្ដាប់ ស័ព្ទសំដែង តែងចំណោទ ជូនពាក្យចោទ ជាចំណង ចងជិតជាក់
មុជអោយជ្រៅ ទៅឆ្ងាយ ស្រាយតាមវគ្គ ពិតពុំលាក់ ពីលោកអ្នក វិមង្សា ។
* « មានពងសត្វ មួយចម្លែក ផ្លែកពីគេ ពងមួយទេ ទ្វេញាស់បាន កូនត្រៀបត្រា
ជាបក្សី ជាម្រឹគី ជាមច្ឆា ឧរង្គណា តាមអក្ខរា ចារចងទុក ។
* សត្វអ្វីខ្លះ ញាស់ពងមួយ រងួយងោក សូមអធ្យោគ ព្រោកប្រាជ្ញលេងតែងទំនុក
មុននឹងថា សូមវិចារ ចំពោះមុខ ស៊ុតគ្រលុក ពេកពុំជា នាលោកិយ » ។

**ខណ្ឌ ស៊ុនហេង**

(*) លោកអ្នកនាង ដែលរកចម្លើយកំណាព្យនេះឃើញ នឹងបានទទួលរង្វាន់ជាប្រាក់ រួមមាន : រង្វាន់តាមចំណាត់ថ្នាក់ពីលេខ១ ដល់លេខ៣ ព្រមទាំងរង្វានផ្សេងទៀត មានរង្វាន់លួងចិត្ត និងរង្វាន់លើកទឹកចិត្ត ។

# ការចូលរួមសន្និសីទ នៅ ស៊ីរីលង្កា

តាមសេចក្តីអញ្ជើញរបស់អង្គការពុទ្ធសាវ័កពិភពលោកនៃព្រះបរមតថា-គត (The world Buddhist Supreme Tathagata Followers Organization) ឯកឧត្តម *ឈន អៀម* អនុរដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា និងព្រះធម្មលិខិត *លាស់ ឡាយ* ប្រធានថេរសភា អនុគណស្រុកមានជ័យ រាជធានីភ្នំពេញ និងជាចៅអធិការវត្តសន្សំកុសល (ភ្នំពេញ) បាននិមន្តនិងអញ្ជើញទៅចូលរួមសន្និសីទលើកទី២ របស់អង្គការនេះ ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃ១១ ដល់ថ្ងៃ១៣ ខែកញ្ញា ឆ្នាំ១៩៩៤ នៅទីក្រុងកណ្ឌី និងកូឡុំបូ ប្រទេសស្រីលង្កា ។

ដោយឡែក លោក *យី ធន់* ទីប្រឹក្សាអមក្រសួងធម្មការ និងសាសនា ក៏ត្រូវបានអង្គការនោះអញ្ជើញអោយចូលរួមក្នុងឋានៈជាអ្នកសង្កេតការណ៍ នៅក្នុងសន្និសីទនោះដែរ ។

សន្និសីទលើកទី២ នៃអង្គការ ព.ស.ព.ប.ត.នេះ បានចាប់ផ្តើមបើកពិធីនៅឯទីក្រុងកណ្ឌី ដែលនៅទីនោះមានព្រះស្តូបមួយ ដែលគេកសាងឡើងដើម្បីតម្កល់ព្រះចង្កូមកែវរបស់ព្រះសម្មាសម្ពុទ្ធ ។ នៅក្នុងឱកាសបើកនោះ សហប្រធានអង្គការ ព.ស.ព.ប.ត. បានប្រគេនចំពោះព្រះតេជព្រះគុណ*លាស់ ឡាយ* នូវប័ណ្ណទទួលស្គាល់ជាសមាជិករបស់អង្គការ ។

នៅថ្ងៃបន្ទាប់មក សមាជិកនៃសន្និសីទទាំងអស់ បានចូលជួបសម្តែងការគួរសមចំពោះ ឯកឧត្តមប្រធានាធិបតី ប្រទេសស៊ីរីលង្កា នៅទីក្រុងកូឡុំបូ ។

សិទ្ធិសីទបានបញ្ចប់កិច្ចការរបស់ខ្លួន នៅថ្ងៃ១៣ កញ្ញា ១៩៩៤ នៅទីក្រុងកូឡុំបូ បន្ទាប់ពីបានអនុម័តយកថ្ងៃពិសាខបូជារៀងរាល់ឆ្នាំ ធ្វើជា « *ទិវាសន្តិភាពពុទ្ធសាសនាពិភពលោក* » និងពិធីជូនរង្វាន់ចំពោះសមាជិកដែលមានស្នាដៃ ។

នៅថ្ងៃបន្ទាប់មកទៀត ដោយមានការឧបត្ថម្ភពីព្រះតេជព្រះគុណ *ម. វិបុលសរៈមហាថេរ* សហអគ្គលេខាធិការនៃអង្គការ ព.ស.ព.ប.ត. នៃប្រទេសស្រីលង្កា គណៈប្រតិភូបានអញ្ជើញទៅទស្សនារាជធានីពីសម័យបូរាណ របស់ប្រទេសស្រីលង្កា គឺក្រុងអនុរាធបុរៈ ដ៏ល្បីល្បាញ និងសម្បូរទៅដោយសំណង់ប្រាសាទបូរាណបាក់បែក ។ ក៏នៅក្នុងឱកាសនោះដែរ ព្រះតេជព្រះគុណ *ម.វិបុលសរៈមហាថេរ* បានធ្វើការអំពាវនាវចំពោះសប្បុរសជន និងពុទ្ធិកសមាគមទាំងអស់នៅប្រទេសស្រីលង្កា អោយជួយឧបត្ថម្ភចំពោះការរស់ឡើងវិញនៃពុទ្ធ-សាសនានៅកម្ពុជា ។ ជាការឆ្លើយតបវិញ សហប្រធានអង្គការពុទ្ធសាវ័កពិភពលោកនៃព្រះបរមតថាគត នៃប្រទេសកូរ៉េ ព្រះតេជព្រះគុណ *សេរ៉ គីយុងបូ ធម្មរាជ* បានធ្វើអំណោយជា ប្រាក់ចំនួន ១៤០០$ (មួយពាន់បួនរយ) ដុល្លារអាមេរិក និងសមាគមពុទ្ធសាសនា របស់ព្រះតេជព្រះគុណ *ម.វិបុលសរៈ មហាថេរ* ក៏បានធ្វើអំណោយជាប្រាក់ចំនួន ១៣៥០$ (មួយពាន់បីរយហាសិប) ដុល្លារអាមេរិកដែរ ដើម្បីទិញសំបុត្រយន្តហោះ ប្រគេនសមណសិស្ស១០ អង្គដែលនឹងត្រូវនិមន្តទៅសិក្សានៅប្រទេសស្រីលង្កា ។

គណៈប្រតិភូ បានវិលត្រឡប់មកមាតុប្រទេសវិញ នៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ ១៩៩៤ ។

***

# ដំណើរទស្សនកិច្ចរបស់ គណៈប្រតិភូនៃមជ្ឈមណ្ឌលជាតិនៃវិទ្យាសាស្ត្រសង្គម និងមនុស្សសាស្ត្រវៀតណាម នៅក្រសួងធម្មការ និងនៅពុទ្ធសាសនបណ្ឌិត្យ

កាលពីព្រឹកថ្ងៃទី ២៤ ខែតុលា ឆ្នាំ១៩៩៤ ឯកឧត្តម *ហៀន វណ្ណរត្ន* រដ្ឋលេខាធិការនៃក្រសួងធម្មការ ព្រមទាំងមន្ត្រីរាជការរបស់ក្រសួងជាច្រើនរូបទៀត បានទទួលស្វាគមន៍គណៈប្រតិភូរបស់មជ្ឈមណ្ឌលជាតិ នៃវិទ្យាសាស្ត្រសង្គម និងមនុស្សសាស្ត្រវៀតណាម ដែលដឹកនាំដោយលោក *ផាំ ឌិក ថាញ់* ប្រធានវិទ្យាស្ថានសិក្សាអំពីអាស៊ីអាគ្នេយ៍ ។ ឯកឧត្តម ឯកអគ្គរដ្ឋទូតវៀតណាម ប្រចាំនៅប្រទេសកម្ពុជា ក៏មានវត្តមានក្នុងឱកាសនោះដែរ ។

កិច្ចពិភាក្សាគ្នាក្នុងឱកាសនោះ បានប្រព្រឹត្តទៅក្នុងបរិយាកាសកក់ក្ដៅរាក់ទាក់ និងយោគយល់គ្នាទៅវិញទៅមក ។ ភាគីទាំងពីរ បានផ្ដោតការពិភាក្សាទៅលើបញ្ហាស្រាវជ្រាវ និងការផ្លាស់ប្ដូរឯកសារ ក្នុងការសិក្សាផ្នែកពុទ្ធសាសនា និងជំនឿផ្សេងៗ ។

បន្ទាប់ពីពិធីសំណេះសំណាលនៅទីស្ដីការរដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនាមក គណៈប្រតិភូ ក៏បានទៅទស្សនាពុទ្ធសាសនបណ្ឌិត្យទៀត ។ នៅទីនោះ គណៈប្រតិភូត្រូវបានឯកឧត្តម *ឈន អៀម* អនុរដ្ឋលេខាធិការក្រសួងធម្មការ និង

លោក *ឱម ខែម* នាយកវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ទទួលស្វាគមន៍យ៉ាងរាក់ទាក់កក់ក្ដៅ ដូចនៅឯក្រសួងដែរ ។

ឯកឧត្តម *ឈន អៀម* បានធ្វើសេចក្ដីរាយការណ៍ជូនភ្ញៀវយ៉ាងសង្ខេបស្ដីពីការស្ដារឡើងវិញ និងដំណើរការរបស់ពុទ្ធសាសនបណ្ឌិត្យ ក្នុងពេលបច្ចុប្បន្ន ។

ជាការឆ្លើយតប លោក *ផាំ ឌិក ថាញ់* ប្រធានគណៈប្រតិភូ បានអះអាងថា លោកនឹងខិតខំជួយផ្ដល់ឯកសារទាំងឡាយ ដែលវិទ្យាស្ថានលោកមាន ចំពោះពុទ្ធសាសនបណ្ឌិត្យ ដើម្បីរួមចំណែកក្នុងស្ដារវិទ្យាស្ថាននេះឡើងវិញ ។

ដំណើរទស្សនកិច្ចនៅពុទ្ធសាសនបណ្ឌិត្យ របស់គណៈប្រតិភូវៀតណាមនេះ បានបញ្ចប់នៅវេលាម៉ោង ១០ និង ៣០ នាទីព្រឹក ក្នុងបរិយាកាសរីករាយកក់ក្ដៅបំផុត ។

# សេចក្តីជូនដំណឹង

"កម្ពុជសុរិយា" មានកិត្តិយស និងមានសេចក្តីរីករាយ សូមជម្រាបសាធារណជនថា « **ពុទ្ធិកសមាគម កម្ពុជរដ្ឋ** » ត្រូវបានរៀបចំបង្កើតឡើងវិញ និងចាប់ផ្តើមធ្វើសកម្មភាពបំរើឧត្តមគតិរបស់ខ្លួន ដើម្បីជាគុណប្រយោជន៍ដល់ពុទ្ធសាសនា និង សង្គមជាតិយើង ក្នុងពេលដ៏ខ្លីខាងមុខនេះ ។

" ពុទ្ធិកសមាគមកម្ពុជរដ្ឋ " គឺជាសមាគមសប្បុរស ឥតគិតកម្រៃ ដ៏ដំបូងមួយដែលត្រូវបានបង្កើតឡើងតាំងពីឆ្នាំ ១៩៥២ ឋិតក្រោមព្រះបរមរាជូបត្ថម្ភ នៃព្រះមហាក្សត្រជាទីសក្ការៈរបស់យើង ដើម្បីបំរើឧត្តមប្រយោជន៍សង្គមជាតិ និងពុទ្ធសាសនា តាមរយៈការផ្តល់អាហារូបករណ៍ដល់សមណសិស្ស បញ្ជូនអោយទៅបន្តការសិក្សានៅបរទេស និងតាមរយៈសកម្មភាពចូលរួមក្នុងប្រជាសង្គ្រោះ ក្នុងការផ្សព្វផ្សាយសាសនា វប្បធម៌ អក្សរសាស្ត្រ ព្រមទាំងប្រពៃណី ទំនៀមទម្លាប់ល្អ របស់ជាតិយើង ។ មកដល់ថ្ងៃ ១៧ មេសា ១៩៧៥ សកម្មភាព និងអត្ថិភាពផ្ទាល់របស់ "ពុទ្ធិកសមាគមកម្ពុជរដ្ឋ" ត្រូវបានគេបញ្ចប់ ហើយត្រូវគេផ្តិលផ្តាច់ឫសគល់ រលាយ រលត់រហូតមកដល់ពេលនេះ !

ដោយនឹកស្តាយស្នាដៃ និងតម្លៃគំនិតរបស់បុព្វជនយើង ក្នុងការបានបង្កើត "ពុទ្ធិកសមាគមកម្ពុជរដ្ឋ" ម្យ៉ាង, និងម្យ៉ាងទៀត ដោយពុំអាចឱបដៃមើលសង្គមជាតិ និងពុទ្ធសាសនាយើង ខ្វះថាមពលមួយផ្នែកជួយអភិវឌ្ឍអោយបានជាភិយ្យោភាពនោះ, ទើបមានព្រះសង្ឃ និងពុទ្ធសាសនិកជនមួយក្រុម បានស្ម័គ្រព្រះទ័យ និងស្រុះស្រួលចិត្តផ្តើមរៀបចំលក្ខន្តិកៈសមាគមជាថ្មី ដើម្បីប្រើជាត្រីវិស័យដឹកនាំ "ពុទ្ធិកសមាគមកម្ពុជរដ្ឋ" ឡើងវិញ ។ ឆាប់ៗនេះ "ពុទ្ធិកសមាគម កម្ពុជរដ្ឋ" នឹងចេញមុខបង្ហាញខ្លួនជាសាធារណៈ ចាប់ផ្តើមបំពេញបេសកកម្មបំរើសាសនា និងសង្គមជាតិ តាមគន្លងរបស់បុព្វជនខ្លួន !

"កម្ពុជសុរិយា" មានអំណរសាទរណាស់ ចំពោះការកើតមានឡើងវិញ នៃ"ពុទ្ធិក

សមាគមកម្ពុជរដ្ឋ" ដែលជានិមិត្តរូបសញ្ញាមួយដ៏ល្អ បើកផ្លូវទៅរកការបង្កើត«ពុទ្ធិកសមាគមពិភពលោក (The World Fellowship of Buddlhists) មជ្ឈមណ្ឌលភូមិភាគកម្ពុជា» ឡើងវិញ ។

ប្រជាពលរដ្ឋយើងជាច្រើននៅចាំបានថា ប្រទេសកម្ពុជាធ្លាប់ជាសមាជិកស្ថាបនិកមួយ នៃពុទ្ធិកសមាគមពិភពលោក ដែលត្រូវបានបង្កើតឡើងនៅប្រទេសស្រីលង្កាតាំងពីឆ្នាំ ១៩៥០, ហើយធ្លាប់បានរៀបចំទទួលបើកមហាសន្និបាតលើកទី៦ នៃពុទ្ធិកសមាគមពិភពលោក នៅសាលចតុមុខ ទីក្រុងភ្នំពេញ ក្នុងឆ្នាំ ១៩៦២ ។

តាមរយៈការកើតឡើងវិញ នៃ"ពុទ្ធិកសមាគមកម្ពុជរដ្ឋ", "ពុទ្ធិកសមាគមពិភពលោក មជ្ឈមណ្ឌលភូមិភាគកម្ពុជា" នឹងមានលក្ខណៈងាយស្រួល ដើម្បីកកើតឡើងវិញ ជាប្រាកដ, ដែលនេះជាច្រកមួយដ៏ប្រពៃ នាំសង្គមជាតិ និងពុទ្ធសាសនាកម្ពុជា ចូលក្នុងឆាកពុទ្ធសាសនាសកលលោក !

អាស្រ័យហេតុនេះ "កម្ពុជសុរិយា" សូមផ្សព្វផ្សាយដំណឹងអំពីការកើតមានឡើងវិញ នៃ "ពុទ្ធិកសមាគមកម្ពុជរដ្ឋ" និងសូមអំពាវនាវដល់ប្រជាពលរដ្ឋកម្ពុជា ទាំងព្រះសង្ឃ ទាំងគ្រហស្ថ មេត្តាជួយឧបត្ថម្ភ គាំទ្រ "ពុទ្ធិកសមាគមកម្ពុជរដ្ឋ" តាមរយៈការស្ម័គ្រចិត្តធ្វើជាសមាជិក និងផ្តល់វិភាគទាន ទេយ្យទាន ឬអំណោយជាថវិកាដល់ "ពុទ្ធិកសមាគមកម្ពុជរដ្ឋ" ដែលមានទីស្នាក់ការបណ្តោះអាសន្ននៅជាមួយពុទ្ធសាសនបណ្ឌិត្យ ក្នុងវត្តឧណ្ណាលោម ក្រុងភ្នំពេញ ។

កម្ពុជសុរិយា

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ



ព្រះពុទ្ធបដិមានៅប្រាសាទបាយ័ន អង្គរធំ គ្រឹស្តសតវត្សទី ១១

---

ឆ្នាំទី ៤៨ លេខ ៤ ខែ តុលា - វិច្ឆិកា - ធ្នូ

ព.ស ២៥៣៨ គ.ស ១៩៩៤

ភ្នំពេញ

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ

ចេញរាល់ត្រីមាស ពី ពុទ្ធសាសនបណ្ឌិត្យ

ចាត់ចែងបោះពុម្ពផ្សាយដោយគណៈកម្មការមួយ មាន ៖

ទីប្រឹក្សា : ហៀន ចណ្ឌារត្ន
នាយកការផ្សាយ : ឈន អៀម
និពន្ធនាយក : យី ធន់
និពន្ធនាយករង : ឱម ខែម

គណៈកម្មការនិពន្ធ

ព្រះធម្មលិខិត លាស់ ឡាយ, ព្រះមហាព្រហ្មមុនី ហេង លាងហោ,
លោក ម៉ែន ប្រាង, លោក អាំ ឆន,

## ごあいさつ

この本は、世界宗教者平和会議日本委員会と曹洞宗国際ボランティア会との共同プロジェクトとして印刷されました。

この本が、日本の宗教者とカンボジアの人々との友情のきずなとなり、カンボジアの宗教と文化の発展に貢献できれば幸いです。

## ACKNOWLEDGEMENT

The Kampuja Surya Magazine is specially printed as a cooperative project of the Japanese Committee of the World Conference on Religion and Peace (WCRP) and Japan Sotoshu Relief Committee (JSRC).

We pray that this magazine would contribute to the Friendship with Cambodian people and their religious and cultural preservation.

## និវេទនកថា

ទស្សនាវដ្ដីកម្ពុជសុរិយានេះ ត្រូវបានបោះពុម្ពឡើងជាពិសេស ទុកដូចជាគម្រោងការងារ របស់គណៈកម្មាធិការជប៉ុននៃក្រុមប្រឹក្សាពិភពលោកស្ដីពីសាសនានិងសន្តិភាព (WCRP) ហើយនិងគណៈកម្មាធិការជំនួយសូតូស៊ូជប៉ុន (JSRC) ។

យើងខ្ញុំអធិដ្ឋាន សូមឱ្យទស្សនាវដ្ដីនេះ បានជាវិភាគទានរក្សាមិត្តភាពជាមួយប្រជាជនកម្ពុជា និងថែរក្សាសម្បត្តិសាសនានិងវប្បធម៌របស់ប្រជាជនកម្ពុជា ។

# មាតិកាអត្ថបទ


## I. អក្សរសិល្ប៍ពុទ្ធសាសនា

- ព្រះធម៌របស់ព្រះពុទ្ធ (ត) ១
- សង្គាយនា ទី៤ ១៨
- បាយាសិរាជញ្ញ សូត្រ (ត ចប់) ២០
- អង្គការចាត់តាំងព្រះសង្ឃពុទ្ធសាសនិក នៅកម្ពុជា ៣១

## II. អក្សរសាស្ត្រទូទៅ

- ល្បើកអង្គរវត្ត (ត ចប់) ៤៨
- សេចក្ដីរំលឹកដាស់តឿន (ព្រះភិរម្យភាសា អ៊ូ) ៦២
- លក្ខណៈពិសេស នៃជនជាតិខ្មែរ (ត) ៧៧
- ការសិក្សាសម័យបូរាណ (ត ចប់) ៨៥
- និមិត្តរូបនិយមនៃប្រាសាទហិណ្ឌូ និងប្រាសាទខ្មែរ ៩៥
- របៀបទស្សន៍ទាយទឹកភ្លៀង ១០៩
- ប្រវត្តិឃុំដូនសរ (ស្វាយរៀង) ១១៦
- ស្វាមី ៥ ប្រការ, ភរិយា ៧ ប្រភេទ ១២៣
- សេចក្ដីជូនដំណឹង កំណាព្យប្រស្នា ១៣១

## III. កំណត់ និងប្រវត្តិការណ៍

- សិក្ខាសាលាជាតិ ស្ដីពី ព្រះពុទ្ធសាសនា និងការអភិវឌ្ឍន៍សង្គមខ្មែរ ១៣៤
- ពិធីទទួលគម្ពីរព្រះត្រៃបិដក ១៣៧

# ព្រះធម៌របស់ព្រះពុទ្ធ

( តពីកម្ពុជសុរិយា លេខ៣ . ១៩៩៤ )

ដោយភិក្ខុ Jagdish Kasyapa

បកប្រែដោយ **ឈន អៀម**

*ខ. គ្មានសារជាតិ : គ្មានអាត្ម័ន (អនត្តៈ)*

ការមិនដឹង (អវិជ្ជា) អំពីការប្រែប្រួល បានបង្កើតអោយមានអវិជ្ជា កាន់តែធ្ងន់ធ្ងរអំពីសារជាតិ និងអំពីអាត្ម័ន ។

## សារជាតិ (La substance)

ប្រសិនបើ*ការប្រែប្រួល គឺជាការណ៍ពិត*, វាត្រូវតែមានអ្វីមួយជាមូលដ្ឋាន ឬសារជាតិណាមួយដែលនៅលើមូលដ្ឋាន ឬសារជាតិនោះ ការប្រែប្រួលបានកើតឡើង ។ ចិញ្ចៀនមួយ, ពែងមួយ, ប្រាក់កាក់មួយ ទាំងអស់គឺជាសំនួនវោហារនៃការប្រែប្រួលរបស់លោហធាតុដដែល : មាស ។ មាសបិតនៅតែជាមាសដដែលគ្មានប្រែប្រួលនៅក្នុងការប្រែប្រួលទាំងអស់នោះទេ ។ ហេតុនេះ ការប្រែប្រួលបណ្តែអោយមើលឃើញអ្វីមួយដែលបិតថេរជាអចិន្ត្រៃយ៍, និងគ្មានការផ្លាស់ប្តូរ ។ ពួកតក្កវិទូនិយមលោកអារិស្តូត ហៅការប្រែប្រួលទីមួយថា : *គុណភាព (qualité)* និងហៅការប្រែប្រួលមួយទៀតថា *សារជាតិ (substance)* ។ ទទ្បីករណីនេះត្រូវបានគេអធិប្បាយពង្រីក ហើយសារជាតិអចិន្ត្រៃយ៍ ឬ "សស្សតៈ" ក៏ចាប់ផ្តើម

ត្រូវបានគេទទួលយកទុកដូចជាគោលការណ៍របស់វា ។

ទស្សនវិទូខ្លះ បានហៅសារជាតិជាអចិន្ត្រៃយ៍នេះថា " *បរមាណូ* " ឬ "អាត្ម័ន," *ប្រាក្រឹតិ* " ឬចុងក្រោយ," *បទថិះ* " ឬ សច្ចភាព," *ព្រហ្ម* " ឬមនសិ-ការលោកធាតុ (ចំពោះអ្នកទាំងឡាយណា ដែលបានមើលឃើញនៅក្នុងសារជាតិតាមទស្សនវិស័យសាសនា), ហើយនិងឈ្មោះហៅផ្សេងៗទៀត ។

នៅពេលដែលការប្រែប្រួល ត្រូវបានគេទទួលស្គាល់ថាមានមែន, សារ-ជាតិបែបណាមួយនោះ ឬភាពឋិតថេរអចិន្ត្រៃយ៍ (សស្សតះ) បែបណាមួយនោះ ក៏ត្រូវបានគេទទួលស្គាល់ថាចាំបាច់ដែរ ។ នេះគឺជាដំណាក់កាលមួយទៀត របស់សក្កាយទិដ្ឋិ ។

ប៉ុន្តែ យើងបានឃើញស្រាប់ហើយថា ក្រោមពន្លឺនៃសច្ចភាពរបស់អនិច្ចះ, *កាលះ* និង*ការប្រែប្រួល* (បរិណាមះ) ទាំងពីរនេះ ត្រូវបាត់មុខ; ហើយទីណាដែលគ្មានការប្រែប្រួល, ការភាន់ច្រឡំដែលជឿថាមានសារជាតិ ក៏មិនអាចកើតមានបានទេ ។

មាស មាននៅដដែលក្នុងចិញ្ចៀន ក្នុងពែង ឬក្នុងប្រាក់កាក់ *តែកាលណាយើងចាត់ទុកមាសតាមទស្សនវិស័យជាក់ស្តែង,* ប៉ុន្តែ តាមន័យបរមត្ថវិជ្ជាសុទ្ធសាធវិញ គ្មានកំទេចមាសណាមួយឋិតនៅដដែល ក្នុងខណៈពីរបន្តបន្ទាប់គ្នាទេ ។ មាសក៏ទទួលរងអភិក្រមនៃអនិច្ចះដូចគ្នាដែរ ។ យើងហៅវាថាមាស ដរាបណាការជាប់ជំពាក់ចិត្តនៃចំណង់របស់យើង ឬតណ្ហា ត្រូវបានភ្ជាប់ទៅនឹងមាសនោះ ។ ប្រសិនបើមាសនោះ ត្រូវគេដុតអោយទៅជាធូលី, យើងក៏លែងហៅវាថាមាសដែរ ពីព្រោះ លែងបំពេញចំណង់របស់យើងបានទៀតហើយ ។

បណ្ឌិត (Le saint) ដែលបានជំនះអវិជ្ជានេះ ស្តីអំពីសារជាតិ ឬទស្សនះ "សក្កាយទិដ្ឋិ " ហើយ, តែងចាត់ទុកមាស ឬផេះ ដូចតែគ្នា ។

# អាត្ម័ន ឬព្រលឹង

កាលណាកំហុសនៃការវិនិច្ឆ័យដដែល ស្ដីពីការប្រែប្រួលនេះ ត្រូវបានគេយកមកអនុវត្តចំពោះមនុស្ស ឬ ចំពោះសត្វមានជីវិតវិញ, វាក៏បង្កើតអោយមានទស្សនាមានភ័ន្តច្រឡំ ស្ដីពីព្រលឹងដែរ ។

យើងឥឡូវនេះ ពុំមែនជាមនុស្ស ដូចដែលយើងជាមនុស្សក្នុងខណៈមុននេះទេ, យើងបានប្រែប្រួលខាងផ្លូវចិត្ត និងផ្លូវកាយហើយ ។

នៅក្នុងដំណាក់ផ្សេងៗគ្នានៃជីវិតរបស់ខ្លួន មនុស្សម្នាក់បានទទួលរងការប្រែរូប ប្រែធាតុទាំងស្រុង ទាំងក្នុងស្មារតី ទាំងក្នុងរូបកាយ ។ ថ្វីបើមានការប្រែប្រួលទាំងនោះក្ដី យើងក៏នៅតែយល់យ៉ាងមុតមាំថា យើងជាបុគ្គលដដែល, មានភាពដូចដដែល (l'identité) ។

បញ្ហាដែលមានជាធម្មតានោះ គឺជាបញ្ហានេះ : តើគេពន្យល់ភាពដដែល (l'identité) នេះ នៅក្នុងការប្រែប្រួលយ៉ាងដូចម្ដេច, ពន្យល់ភាពដូចគ្នា (le semblable) ក្នុងភាពផ្សេងគ្នា (le différent) យ៉ាងដូចម្ដេច ?

ឆ្លើយតបនឹងបញ្ហានេះ, ទស្សនវិទូខ្លះបានលើកយកអត្ថិភាពនៃអាត្ម័នអចិន្ត្រៃយ៍មួយនៅក្នុងមនុស្ស ដែលរក្សាភាពដដែលរបស់ខ្លួន នៅក្នុងដំណើរនៃការប្រែប្រួល ខាងចិត្ត និងកាយ, ពីព្រោះអាត្មន័ ជាភាវៈលោកុត្តរៈ, ដោយហេតុនេះវាក្លនងហួសស្មារតី និងរូបកាយទៅទៀត ។ ទោះបីមនុស្សប្រែប្រួលនៅក្នុងស្មារតី និងរូបកាយរបស់គេក៏ដោយ, អាត្មន័របស់គេឋិតថេរជាអចិន្ត្រៃយ៍ ហើយជាអាត្មន័ដដែល, ដូច្នេះ មនុស្សសំគាល់ខ្លួនថាជាបុគ្គលភាពដដែល ។

*ហេតុនេះ ត្រូវរកអោយឃើញសារសំខាន់ក្នុងការជឿថា មានព្រលឹងមួយ សំរាប់ពន្យល់ភាពដដែលនៅក្នុងការប្រែប្រួលរបស់មនុស្ស ។*

ចូរយើងទាញយកសេចក្ដីសន្និដ្ឋានតក្កវិជ្ជាអំពីទឡ្ហីករណ៍ខាងលើ ហើយ

ចូរយើងមើលអោយឃើញរហូតដល់ទីណា ទើបវាមានការយល់ដ៏ជាទីពេញចិត្ត ។

ប្រសិនបើ វាមានសារសំខាន់ដើម្បីជឿថា មានកត្តាអចិន្ត្រៃយ៍មួយសំរាប់ពន្យល់ភាពដដែល (l'identité), ការពន្យល់នេះ ក៏ត្រូវតែជាការពន្យល់មួយ ដ៏ជាប់លាប់ សំរាប់អ្វីៗទាំងអស់, ដោយពន្យល់រាល់ភាពដដែល នៅក្នុងភាពផ្សេងគ្នា ទោះជាភាពដដែលនៃកៅអី ឬភាពដដែលនៃផ្ទះក៏ដោយ ។ ខ្ញុំដឹងថា កៅអីរបស់ខ្ញុំ គឺកៅអីដដែល ដូចដែលខ្ញុំបានទិញវាកាលពីមួយឆ្នាំកន្លងទៅ ។ ជាមួយគ្នានេះ ខ្ញុំក៏ដឹងថា កៅអីខ្ញុំបានប្រែប្រួលច្រើន ពីព្រោះវាមានជើងមួយបាក់ ហើយថ្នាំរបស់វាចង់របក ។ តើខ្ញុំអាចពន្យល់ភាពដដែល (l'identité) នៃកៅអីរបស់ខ្ញុំនៅក្នុងដំណើរប្រែប្រួលទាំងស្រុងយ៉ាងដូចម្ដេចកើត ? តាមទ្រឹស្ដីខាងលើនេះ តើខ្ញុំត្រូវនឹកគិតប្រឌិត*អាត្ម័នកៅអីអចិន្ត្រៃយ៍មួយ* *(une âme-chaise permanente)* ដែលហួសពីកៅអីវត្ថុ ដែលរក្សាបានភាពដដែលនៃកៅអី នៅពីក្រោយការប្រែប្រួលទាំងឡាយបានឬទេ ? ពេលនោះ ក៏រអាចមានអាត្ម័ន-តុ, អាត្ម័ន-ស្លាបព្រាកា ហើយមានអាត្មន័មួយសំរាប់វត្ថុនីមួយៗ, ពីព្រោះវត្ថុទាំងអស់រក្សាភាពដដែលរបស់ខ្លួន ទោះបីវត្ថុទាំងនោះប្រែប្រួលក៏ដោយ ។ នេះគឺជាលទ្ធផលដែលយើងបានឈានដល់ ហើយដែលជាលទ្ធផលមិនសមហេតុ-ផលសោះ ។

ការប្រើពាក្យ Âme=អាត្មន័ នៅក្នុងបន្ទាត់ខាងលើ, ខ្ញុំមិនសំដៅថា ជាញាណសក្ដិនៃចិត្តទេ (la faculté psychique), ប៉ុន្តែសំដៅថា ជាកត្តាអចិន្ត្រៃយ៍មួយ, ឥតប្រែប្រួល, ឋិតវន្ត ទោះជាមានលក្ខណៈជាអ្វីក៏ដោយ ។ សង្ខេបមក ប្រសិនបើកត្តាជាអចិន្ត្រៃយ៍ វាមានសារសំខាន់ដើម្បីពន្យល់ភាពដដែលរបស់មនុស្ស (ដែលជាចិត្ត និងដែលត្រូវគេស្គាល់តាមឈ្មោះនានា ដូចជា អាត្មន័ ជីវៈ អាត្មា បុរុសៈ . ល .), វាត្រូវតែមានសារសំខាន់ដើម្បីពន្យល់ភាពដដែលនៃវត្ថុផ្សេងៗឯទៀតទាំងអស់ ទោះជាកៅអីក្ដី តុក្ដី ស្លាបព្រាកាក្ដី ។

## ភាពដូចគ្នា ឬភាពផ្សេងគ្នា

គេអាចលើកឡើងជាសេចក្តីសង្ស័យ ហើយនិយាយថា : ប្រសិនបើនៅក្នុងមនុស្ស ពុំមានកត្តាដូចគ្នាសុទ្ធសាធ (un facteur identique) និងអចិន្ត្រៃយ៍ទេ តើអ្នកដែលធ្វើអំពើមួយជាមនុស្សដដែល (le même) ឬជាមនុស្សផ្សេងពីមនុស្ស ដែលទទួលលទ្ធផលនៃអំពើនោះ ?

សំណួរដដែលនោះ ត្រូវបានគេចោទសួរចំពោះព្រះនាគសេនថេរ ដោយព្រះបាទមិលិន្ទ ហើយចម្លើយគឺ *មិនមែនអ្នកដដែល ហើយក៏មិនមែនអ្នកផ្សេង* ។ ព្រះនាគសេន បានអោយឧទាហរណ៍នេះច្បាស់លាស់ ចំពោះព្រះបាទមិលិន្ទ ថា :

បពិត្រព្រះរាជា, ចូរព្រះអង្គសន្មតថា មនុស្សម្នាក់ដុតចង្កៀងមួយ តើចង្កៀងនោះឆេះពេញមួយរាត្រី ឬទេ ?

- ព្រះករុណា, ចង្កៀងអាចឆេះរហូតដល់ថ្ងៃរះ ។

- បើអីចឹង, តើអណ្តាតភ្លើងដែលឆេះនៅយាមទី១ នៃរាត្រី គឺជាអណ្តាតភ្លើងដដែល (la même flamme) ដូចគ្នានឹងអណ្តាតភ្លើងដែលឆេះនៅយាមទី២ ឬទេ ?

- ទេ, មិនមែនអណ្តាតភ្លើងដដែលទេ ។

- ឬតើអណ្តាតភ្លើងនៃយាមទី២ ជាអណ្តាតភ្លើងដដែល និងអណ្តាតភ្លើងដែលឆេះនៅយាមទី ៣ ដែរឬទេ ?

- ទេ, មិនមែនអណ្តាតភ្លើងដដែលទេ ។

- បើអីចុះ, មានតែមានចង្កៀងមួយសំរាប់យាមទី១, ចង្កៀងមួយទៀតសំរាប់យាមទី២ ហើយមួយទៀត សំរាប់យាមទី៣ ?

- មិនមែនទេ, ពន្លឺចេញមកពីចង្កៀងដដែល អស់រាត្រីទាំងមូល ។

« បពិតព្រះរាជា, ដូចគ្នានេះដែរ ភាពបន្តនៃមនុស្ស ឬវត្ថុមួយត្រូវបាន

វក្សា ។ មនុស្សមួយបានកើតឡើង, មនុស្សមួយទៀតត្រូវបាត់ទៅ ហើយការកើតឡើងថ្មី ក៏ត្រូវមានឡើងដំណាលគ្នា ។ ដូច្នេះ *មិនមែនដដែល, មិនមែនមួយទៀត,* (ni le même, ni un autre) មនុស្សម្នាក់នឹងបន្តរហូតដល់ដំណាក់ចុងក្រោយនៃមនសិការអាត្មារបស់គេ » ។

យើងអាចប្រៀបផ្ទឹមក្នុងទីនេះ មនុស្សទៅនឹងចង្កៀង ដោយមានចិត្ត ឬមនសិការទុកដូចជាអណ្តាតភ្លើង ដែលមានអភិក្រមពិសេស ប្រកបដោយដំណើរប្រែប្រួលជាប្រចាំ ។ នេះពុំចង្អុលបង្ហាញថា រូបកាយ មានលក្ខណះអចិន្ត្រៃយ៍ ហើយឋិតថេរទេ, វាក៏ប្រព្រឹត្តទៅតាមអភិក្រមពិសេសរបស់វាដែរ ។

ដូចច្នេះមនុស្សដែលប្រព្រឹត្តអំពើមួយ និងមនុស្សដែលទទួលលទ្ធផលនៃអំពើនោះ មិនមែនជាមនុស្សដដែល ឬមនុស្សផ្សេងទេ, ប៉ុន្តែវាមានចរន្តទឹកតែមួយគត់នៅក្នុងចរន្តទឹកនោះ រលកនីមួយៗ អោយកំណើតដល់រលកមួយទៀត ។

## ឧទាហរណ៍

ភ្លើងដែលគេអុជនៅចុងចំការម្ខាង បានឆេះចំការទាំងមូល រាលរហូតដល់ចុងចំការម្ខាងទៀត ។ តើភ្លើងដែលឆេះចុងក្រោយគេ គឺជាភ្លើងដដែល ដែលត្រូវបានគេអុជនៅចុងម្ខាង ឬក៏ជាភ្លើងផ្សេងស្រឡះ ? គឺមិនមែនជា*ភ្លើងដដែល* ទាំងមិនមែនជា*ភ្លើងផ្សេង* ទេ ។ ប៉ុន្តែ ភ្លើងនៅក្នុងសំណុំរបស់វា គឺជានិរន្តរភាពមួយ, ជាអភិក្រមមួយ, ជាទន្លេមួយ, ជាចរន្តទឹកមួយ ។

អភិក្រមនៃមនសិការនៅក្នុងមនុស្ស គឺជាអភិក្រមដដែលដូច្នេះ ។ ទោះបើជាអំពើឬជាគំនិតជាកុសលក្តី ឬជាអកុសលក្តី នៅក្នុងទីនេះ, នឹងមានផលវិបាកនៅក្នុងទីឯនោះ ។

*វាគ្មានកត្តាអចិន្ត្រៃយ៍នៅក្នុងមនុស្សទេ, គ្មានអាត្ម័នទេ (ព្រលឹង) ប៉ុន្តែ មានតែចិត្ត (l'esprit) ក្នុងចលនាប្រែប្រួលជាដរាបនោះ ។*

# មនុស្សជាអ្វី ?

*បើសិនជាគ្មានអាត្ម័ន (ព្រលឹង) នៅក្នុងខ្លួនយើងទេ, តើអ្វី១ដែលបង្កបង្កើតជាអត្តភាពមនុស្សបានមកពីអ្វី? " មនុស្ស " ជាអ្វី? ពាក្យថា "ខ្ញុំ" មានទាក់ទងនឹងអ្វីខ្លះ កាលណាយើងប្រើពាក្យនេះ ?*

ដើម្បីយល់សំណួរនេះ, អ្នកខ្លះបានឈានទៅជឿថា វាត្រូវតែមាន "សារ-ជាតិសួល" ឬ "អត្តសញ្ញាណដ៏ពិតប្រាកដ" (Identité véritable) មួយ នៅក្នុងមនុស្ស ។ ចំពោះសារជាតិសួល ឬ អត្តសញ្ញាណពិតនេះ, គេបានអោយឈ្មោះថា អាត្ម័ន (ព្រលឹង) ជីវៈ, អាត្មា - ល - ។

ប៉ុន្តែ បើយើងត្រិះរិះប្រកបដោយបញ្ញា កត្តាបែបនេះ មិនមែនជាកត្តាចាំបាច់សំរាប់អះអាងដើម្បីយល់ "មនុស្ស" ទេ ។ មនុស្សត្រូវបានកផ្តុំឡើងដោយចិត្ត និងរូបធាតុ (d'esprit et de matière) ដែលទាំងពីរនេះ ឋិតក្នុងសភាពប្រែប្រួល ដែលនៅក្នុងការប្រែប្រួលនេះ ខណៈមួយបង្កើតអោយមានខណៈមួយទៀតឥតឈប់ឈរ, រហូតទាល់ដល់អ្វីដែលអភិក្រមនេះ ត្រូវបានបញ្ឈប់ ហើយបានរកឃើញការរំលត់អភិក្រមនេះ នៅក្នុងស្ថាននិព្វាន ។

តើរទេះ ជាអ្វី ? តើពាក្យរទេះ ទាក់ទងទៅនឹងអ្វីខ្លះ កាលណាពាក្យនេះត្រូវបានគេយកទៅប្រើ ? រទេះផ្គុំដោយកង់ ទូក ក្រង់ ភ្លៅ កាំ និងផ្នែកដទៃច្រើនទៀតដែលផ្គុំជារទេះនោះ ។ ក្រៅពីផ្នែកទាំងនេះ វាគ្មានរទេះទេ ។ រទេះមានអត្ថិភាពនៅក្នុង និងដោយសារផ្នែកទាំងឡាយដែលផ្គុំជារទេះ ។

# បញ្ចក្ខន្ធ ឬ ខន្ធប្រាំ

គឺដូចគ្នានេះដែរ មនុស្សកើតមាននៅក្នុង និងដោយសារចិត្ត និងរូបកាយ ។ គ្មានអាត្ម័ន, (ព្រលឹង) ទេ ។ ព្រះពុទ្ធទ្រង់មានបន្ទូលថា កាលណាមនុស្ស

ជឿថា គេបានរកឃើញអាត្មននេះដែលគេតែងនិយាយច្រើនគ្នា នោះគេរកឃើញតែសភាវៈរូបកាយ និងចេតសិក (Les états corporels et mentaux) ដែលមានប្រាកដប៉ុណ្ណោះ ។

ចូរយើងយកឧទាហរណ៍បី ហើយយើងខិតខំស្វែងយល់ ថាតើនៅក្នុងន័យណាដែលពាក្យថា «ខ្ញុំ» ត្រូវបានយើងយកមកប្រើ ។

កាលណា ខ្ញុំនិយាយថា «ខ្ញុំនៅទីនេះ» ឬថា «ខ្ញុំបាននៅទីនោះ», តើពាក្យថា «ខ្ញុំ» មានន័យដូម្តេច ?

ក្នុងទីនេះ ស័ព្ទ «ខ្ញុំ» ត្រូវបានយកមកប្រើ សំរាប់សំគាល់ទីតាំងដោយឡែកនៃខ្លួនរបស់ខ្ញុំ ប៉ុណ្ណោះ ។ ខ្ញុំនិយាយថា សៀវភៅនៅឯនោះ, ស្លាបប៉ាកានៅឯនោះ ហើយនៅក្នុងការពង្រីកគំនិតដូចគ្នានឹងពាក្យនិយាយថា «ខ្ញុំនៅទីនោះ» ។ ក្នុងទីនេះ តើមិនគ្រាន់តែជាការចង្អុលប្រាប់កន្លែងផ្សេងៗ ដែលសៀវភៅ ស្លាបប៉ាកា និង «ខ្ញុំ» តាំងនៅប៉ុណ្ណោះទេ ឬអ្វី ? ដូច្នេះ «ខ្ញុំ» នៅក្នុងឧទាហរណ៍ខាងលើ មានន័យថា ខ្លួនខ្ញុំ ហើយគ្មានអ្វីក្រៅពីនេះទេ ។

ចូរយើងលើកយកឧទារណ៍ទីពីរថា : «ខ្ញុំគិត» ក្នុងនេះ តើពាក្យ*«ខ្ញុំ»* មានន័យដូចម្តេច ?

ជាក់ស្តែងគឺពុំមែនរូបកាយទេ, ពីព្រោះហេតុដែលគិត តើមានន័យយ៉ាងណា ចំពោះរូបកាយ ? នោះគឺមានន័យថាចិត្តដឹង «l'esprit connaisseur» ពីព្រោះតាមការពិត គឺចិត្ត ( l'esprit ) ទេ ដែលគិត ។

ក្នុងឧទាហរណ៍ទីបី : « ខ្ញុំធ្វើសុន្ទរកថា » ពាក្យ «ខ្ញុំ» មិនតំណាង ឬមួយរូបកាយ ឬមួយចិត្តដោយផ្ទាល់ទេ, ប៉ុន្តែ តំណាងអំពើរួមនៃពាក្យទាំងពីរ (une action jointe des deux) ។ អណ្តាត (កាយ) មិនអាចនិយាយកើត ដោយឥតជំនួយពីចិត្ត (l'esprit) ដែលគិតទេ ឬក៏ចិត្តបញ្ចេញគំនិតកើត ដោយគ្មាន

អណ្តាត ក៏ទេដែរ ។ សុន្ទរកថាមួយ អាចធ្វើទៅកើតដោយគ្មានអណ្តាត ក៏ទេដែរ ។ សុន្ទរកថាមួយអាចធ្វើទៅកើត ទាល់តែមានអណ្តាត និងចិត្តរួមជាមួយគ្នា ។

ហេតុនេះ យើងឃើញថា ពាក្យថា " ខ្ញុំ " ត្រូវបានប្រើ ជួនកាលសំដៅកាយ និងចិត្ត ពីព្រោះមនុស្សបានកកើតឡើងពិតប្រាកដ ដោយសារសភាវៈរូប កាយ និងចិត្ត (états corporels et mentaux) ។

ប្រសិនបើគេវិភាគវែងឆ្ងាយបន្តិច, វាមានកត្តាប្រាំ ជាសភាវៈកផ្ទុំ ។ កត្តាប្រាំនេះ មានឈ្មោះថាបញ្ចខន្ធ ដែលមានដូចខាងក្រោម ៖

១. រូប (ធាតុទាំងបួន, ប្រាណ, វិញ្ញាណ, ទំនាក់ទំនងគ្នានៃវិញ្ញាណ)

២. វេទនា (អារម្មណ៍រីករាយ , លំបាក ឬ សោះអង្គើយ)

៣. សញ្ញា (ការស្គាល់គំនិត ៖ សញ្ញា )

៤. សង្ខារ (សំយោគនៃសភាវៈចេតសិក និងសំយោគនៃសភាវៈមុខនាទី; បណ្តាញវិញ្ញាណ សញ្ចេតនា និង ចេតសិក) (Synthèse des états mentaux et synthèse des états fonctionnels; complexes sensoriels, affectifs et mentaux) ។

៥. វិញ្ញាណ (មនសិការ) ។

បញ្ចខន្ធនេះ កផ្ទុំជាភាវៈរួមមួយ ដែលហៅថាមនុស្ស ។ មនុស្សមិនអាចកើតមានក្រៅពីខន្ធទាំងប្រាំនេះកើតទេ ។ ដូចគ្នានឹងតុមួយ មិនអាចកើតបានក្រៅពីជើងទាំង ៤ ហើយនិងក្តារទាំងឡាយដែលសំរាប់ធ្វើតុនោះដែរ ។

ខន្ធទាំងប្រាំនេះ មិនអាចឋិតនៅបានជាអង្គភាពដាច់ឡែកដោយខ្លួនឯងទេ ប៉ុន្តែ ឋិតនៅបានជាសង្ខតធាតុ (ជាធាតុផ្សំគ្នា) ដែលធាតុនីមួយៗ មានអភិក្រម ឬ និរន្តរភាពរបស់ខ្លួនផ្ទាល់ ។

គ្មានអង្គភាពណាមួយស្ថិតវន្ត អាចកើតមាននៅទីណាមួយកើតទេ វាមាន

តែជានិរន្តរភាព និងភាពផ្ទុំគ្នាប៉ុណ្ណោះ ។

## ការកកើតទៀត ឬ កំណើតថ្មី

*ប្រសិនបើគ្មានអាត្មន (ព្រលឹង) ដដែលទេ (une âme identique) តើអ្វីដែលត្រូវបានកើត និងកើតទៀត ?*

នេះគឺជាប្រស្នាអាថ៌កំបាំងមួយចោទចំពោះមនុស្សច្រើនគ្នា ។ ព្រះពុទ្ធសាសនា ពិចារណាថា មនុស្សស្លាប់នៅឯប៉េណារ៉េស អាចទៅកើតនៅឯបត្នៈ ក្នុងរូបភាពជាឆ្កែ ទៅតាមកម្មរបស់គេ ។ តើអ្វីដែលចាកចោលខ្លួនមនុស្ស ដែលស្លាប់នៅប៉េណារ៉េស ធ្វើដំណើររហូតដល់បត្នៈ ហើយមកចូលកំណើតជាសត្វឆ្កែ ? ប្រសិនបើគ្មានអាត្មនដដែល (une âme identique) ដែលអន្ទោលដូច្នោះទេ, តើគេអាចយល់រឿងនេះ ដូចម្តេចបាន ? តើការស្លាប់របស់មនុស្សម្នាក់អាចត្រូវបានភ្ជាប់ទៅនឹងកំណើតនៃសត្វមួយទៀត យ៉ាងដូម្តេច ?

ព្រះពុទ្ធសាសនា មិនជឿការអន្ទោលជាតិបែបនេះទេ ។ វាគ្មានអ្វីចេញពីរូបកាយមួយ ហើយចូលទៅក្នុងរូបកាយមួយទៀតទេ ។

ធម្មជាតិ ត្រូវបានគ្រប់គ្រងដោយក្រឹត្យក្រមបដិច្ចសមុប្បាទ (La loi de succession dépendante) ។ អ្វីៗទាំងអស់ កើតមានដោយអាស្រ័យកាលៈទេសៈពីមុន ហើយអ្វីៗទាំងអស់ ត្រូវផ្តល់កំណើតអោយទៅកាលៈទេសៈខាងក្រោយដែលចេញមកពីអ្វីៗពីមុននោះឯង ។

យើងបានឃើញរួចហើយ នៅក្នុងជំពូកស្តីពីបដិច្ចសមុប្បាទ ថាចំណង់ (តណ្ហា) បង្កើតអោយមានការជាប់ជំពាក់ចិត្តចង់មានភព (l'Attachement à l'Existence), ហើយភពនេះបន្តវេននាំទៅរកកំណើត (ជាតិ) ។ ចំណង់របស់បុគ្គលហៀបស្លាប់ បង្កើតឡើងនូវការជាប់ជំពាក់ចិត្ត ដែលនាំអោយមានការបន្ត

អភិក្រមជីវិត (ភព) ហើយនាំទៅកាន់កំណើត (ជាតិ) ថ្មី ។

គ្មានអ្វីមួយដែលចេញពីខ្លួនមនុស្សហៀបស្លាប់ ហើយចូលទៅក្នុងខ្លួននៃកូនង៉ែដែលទើបកើតនោះទេ, ប៉ុន្តែ អត្ថិភាពទាំងពីរ ត្រូវឋិតនៅក្នុងអភិក្រមតែមួយនៃចំណង់ (តណ្ហា) និងការជំពាក់ចិត្ត (ឧបាទាន), មួយធ្វើអោយមួយទៀតកើតឡើង ។

## ឧទាហរណ៍

ចូរយើងលើកយកសង្គ្រាមមួយរយឆ្នាំ រវាងប្រទេសអង់គ្លេស និង ប្រទេសបារាំង ។ គេពុំអាចនិយាយថា ការប្រយុទ្ធបានប្រព្រឹត្តទៅបន្តបន្ទាប់ ដោយគ្មានការផ្អាកអស់រយៈពេល ១០០ ឆ្នាំនោះទេ ។ គឺជាការមិនអាចមានទេ ។ តាមពិត, ការប្រយុទ្ធជាច្រើនលើក ច្រើនសា បានកើតឡើងនៅក្នុងទីកន្លែងផ្សេងៗគ្នា ។

ការប្រយុទ្ធនេះ អស់ពេល១០០ឆ្នាំ, ប៉ុន្តែ ដោយមានចន្លោះផ្អាកយូរៗ ។ ចុះតើត្រូវធ្វើយ៉ាងណា អោយការប្រែប្រួលក្នុងខ្លួនមនុស្សអាចបញ្ឈប់ចរន្តបាន? ក្រោយមរណភាពនៃមនុស្សម្នាក់, សាកសពត្រូវគេយកទៅដុត, ប៉ុន្តែ ពុំបានដុតចំណង់ (តណ្ហា) ទេ ដែលភ្ជាប់ពីជីវិតមួយទៅជីវិតមួយទៀត ។ ព្រឹត្តិការណ៍ទាំងអស់នោះ ត្រូវបានចងភ្ជាប់គ្នាពីមួយទៅមួយ ហើយត្រូវបានគេនិយាយថា " សង្គ្រាមមួយរយឆ្នាំ " ។

ទោះបីជា មានចន្លោះពីការប្រយុទ្ធមួយទៅការប្រយុទ្ធមួយទៀត អស់ពេលយូរក៏ដោយ, មនោសញ្ចេតនាជាអរិភាពបានឋិតនៅរវាងប្រជាជាតិទាំងពីរ ។ អារម្មណ៍ជាអរិភាពនេះ ហើយនិងការជាប់ជំពាក់ចិត្ត ដើម្បីដណ្តើមជ័យជំនះលើសត្រូវ បានកើតមានអស់ពេលមួយសតវត្ស, រីឯការប្រយុទ្ធផ្សេងៗទាំងអស់ នៅក្នុងកន្លែងផ្សេងៗ ដោយមានចន្លោះផ្អាកការប្រយុទ្ធផ្សេងៗ ត្រូវបានចាត់ទុកដូចជាឋិតក្នុងអភិក្រមតែមួយដដែល ។

គឺមានទំនងដូចគ្នាដែរ ដែលរូបកាយរបស់មនុស្ស ហើយនិងរូបកាយរបស់ឆ្កែ គឺជាសមរភូមិប្រយុទ្ធពីរ ដែលសង្គ្រាមដដែល (La même guerre) បានប្រព្រឹត្តទៅ, ពីព្រោះសមរភូមិទាំងពីរ គឺជានិរន្តរភាពនៃរលកជីវិតដដែល (ភព), ចំណង់ (តណ្ហា) ដដែល និងការជាប់ជំពាក់ចិត្ត (ឧបាទាន) ដដែល (La continuation du même flot de vie, du Désir et de l'Attachement) ។

ការប្រយុទ្ធផ្សេងៗ ត្រូវបានចាត់ទុកដូចជាផ្នែកនៃសង្គ្រាមដដែល, គឺពុំមែនពីព្រោះ*អាវុធដដែល ឬទាហានដដែល* ត្រូវបានគេដឹកជញ្ជូនពីសមរភូមិប្រយុទ្ធមួយ ទៅសមរភូមិប្រយុទ្ធមួយទៀតនោះទេ ប៉ុន្តែ ពីព្រោះការប្រយុទ្ធ ត្រូវបានប្រព្រឹត្តទៅក្នុងនិរន្តរភាពនៃមនោសញ្ចេតនាអរិភាពដដែល រវាងប្រជាជាតិទាំងពីរ ។

មនសិការនៃការប្រយុទ្ធ (La conscience de lutte) បានរត់ពីសមរ-ភូមិចំបាំងមួយ ទៅសមរភូមិមួយទៀត ដោយគ្មានអាក់ខាន ឬគ្មានដាច់ ។ ដូចគ្នានេះដែរ មនសិការនៃមនុស្សហៀបស្លាប់ហូរចូលទៅក្នុងខ្លួនមួយទៀត ទៅតាមកម្មរបស់គេ ។ ពុំមានកត្តាណាមួយដែលអន្ទោលទៅចាប់កំណើតថ្មីទេ, ប៉ុន្តែ គឺជាភាពបន្តមិនដាច់ (និរន្តរភាព) នៃភ្លើងដែលឆេះនៅកន្លែងមួយ ហើយរាលដាលទៅនោះឯង, អណ្តាតភ្លើងនីមួយៗ បង្កើតអោយមានអណ្តាតភ្លើងមួយទៀត, ដរាបណានៅតែមានគ្រឿងឥន្ធនៈ ។

នេះមានឈ្មោះថា " *បដិសន្ធិ (Re-naissance)* " នៅក្នុងទស្សន-វិជ្ជាពុទ្ធសាសនា ។

## គោលការណ៍ដឹកនាំជីវិត

គេអាចចោទជាសំណួរថា : " តើអស់ពេលប៉ុន្មាន ដែលរលកជីវិតនេះបន្តដុះដាល ហើយបិតថេរ ? ហើយមានគោលការណ៍អ្វីដែលចង្អុលណែនាំ និងថែរក្សារលកនៃជីវិតនេះ ?

ព្រះពុទ្ធបានប្រៀនប្រដៅថា គឺ តណ្ហា ឬការជាប់ជំពាក់ចិត្ត (L'Attachement) ដែលអាស្រ័យដោយតណ្ហា, ជាសភាវៈទ្រទ្រង់អភិក្រមនៃជីវិត ។ អភិក្រមនៃជីវិតចេះតែបន្តកកើត និងដុះដាល ដរាបណាតណ្ហានៅតែមានវត្តមាន ។

យើងបានឃើញវត្ថុដ៏ល្អមួយ ហើយយើងមានតណ្ហា ឬការជាប់ជំពាក់ចិត្តចំពោះវត្ថុនោះ, ពេលនោះហើយដែលយើងចាប់ផ្ដើមក្ដួចចិត្តពោងស្អិត (ឧបាទាន) ក្នុងចំណង់ចង់បានវត្ថុនោះ ។ ពេលនោះ យើងត្រូវឆ្លងកាត់ភាពសង្ឃឹម ភាពអស់សង្ឃឹម ជោគជ័យ និងបរាជ័យគ្រប់ជំពូក ។ ដោយប្រការនេះឯង ដែលអភិក្រមនៃជីវិតត្រូវប្រព្រឹត្តទៅ, រលកនៃមនសិការត្រូវបានទ្រទ្រង់ ។

វាគ្មានព្រលឹង ឬអាត្មាទេ ។ បុគ្គលភាពរបស់យើង មាននៅក្នុងធម្មជាតិនៃចិត្តរបស់យើងដែលជាចរន្តមួយ, ហើយយើងជាអ្នកទទួលខុសត្រូវចំពោះកំណកំណើតនៃចរន្តនេះ ។

ព្រះពុទ្ធមានពុទ្ធដីកានៅក្នុងគាថាទីមួយនៃធម្មបទថា ៖ ភាវៈទាំងអស់ កើតឡើងដោយមានចិត្តជាហេតុ, មានចិត្តជាប្រធាន ហើយកើតចេញពីចិត្ត ។

## ធម្មជាតិនៃចិត្ត

យើងកំពុងតែរៀនសូត្រជាប្រចាំនូវរឿងអ្វីមួយ ហើយយើងកំពុងតែភ្លេចនូវរឿងអ្វីមួយផ្សេងទៀត ។

នៅពេលយើងដើរតាមផ្លូវ យើងឃើញមនុស្សណាម្នាក់ដើរមក ហើយយើងស្គាល់មនុស្សនោះ ថាជាអ្នកណាច្បាស់លាស់, ប៉ុន្តែ នៅពេលបន្តដំណើរនៅលើផ្លូវ យើងក៏ភ្លេចមនុស្សនោះទៅហើយ អនុស្សាវរីយ៍អំពីមនុស្សនោះ ត្រូវរលុបបាត់ទៅ ។ នៅពេលនោះ, វត្ថុណាមួយផ្សេងទៀត, ឧទាហរណ៍ដូចជារទេះ ឬជាផ្ទះបានទាក់ទាញអារម្មណ៍របស់យើង ហើយយើងបានយកចិត្តទុកដាក់ ។ ក្នុងពេលបន្ត

ដំណើរលើផ្លូវឆ្ងាយទៅ, រូបភាពនោះ ក៏បានរលុបបាត់ទៅដែរ, ដូចជាលើកទីមួយដូច្នោះ, ហើយរូបភាពផ្សេងទៀត ក៏នឹងត្រូវប្រព្រឹត្តទៅយ៉ាងដូច្នោះទៀត ។

ដោយប្រការយ៉ាងនេះឯង ដែលយើងស្គាល់ជានិច្ចនូវវត្ថុមួយ ហើយយើងភ្លេចវត្ថុមួយទៀត ហើយវត្ថុថ្មីមួយត្រូវបានស្គាល់ ហើយក៏ត្រូវភ្លេចវិញ គ្មានទីបំផុត ។ តាំងតែពីយើងកើតមក អភិក្រមស្គាល់ ហើយភ្លេចទៅវិញ បានហូរដូចជាទឹករលក ដោយគ្មានអាក់ខាន ។

ដូចគ្នានេះដែរ កាលណាយើងឈប់ទទួលអារម្មណ៍ពីខាងក្រៅ ដូចជាពេលយើងដេកលក់ អភិក្រមនេះមិនត្រូវបានបញ្ឈប់ទេ ពីព្រោះថា នៅពេលនោះ, អារម្មណ៍ពីមុនៗរបស់យើង បានងើបឡើង ហើយលិចបាត់ទៅវិញ ។

ប៉ុន្តែ យើងមិនភ្លេចវត្ថុនីមួយៗ តាមបែបដូចគ្នាទេ ។ វត្ថុណាមួយដែលទាក់ទាញអារម្មណ៍របស់យើងខ្លាំង ត្រូវបានភ្លេចទៅវិញយ៉ាងយឺតយ៉ាវ, ពីព្រោះដំណើររំភើប ឋិតថេរនៅក្នុងស្មារតីអស់រយៈពេលមួយវែងបន្តិច ។

ម្យ៉ាងវិញទៀត, វត្ថុណាមួយដែលមិនទាក់ទាញអារម្មណ៍យើងខ្លាំងក្លាទេ, ប៉ុន្តែ គ្រាន់តែបានឃើញ ឬជួបប៉ុណ្ណោះ ត្រូវបានភ្លេចទៅវិញយ៉ាងឆាប់រហ័សដែរ ។

## ឧទាហរណ៍

យ៉ាងណាមិញ នៅពេលដើរតាមផ្លូវ ចិត្តរបស់យើងនៅតែនឹកគិតយ៉ាងយូរក្នុងការជួបដំរីមួយ, បើទោះបីជាយើងបានដើរហួសដំរីតាំងពីយូរហើយ ក៏យើងនៅចងចាំដំរីបានយូរជាងការជួបមនុស្សម្នាក់ ដោយគ្មានលក្ខណៈអ្វីពិសេស ។ មនុស្សនោះ ត្រូវបានភ្លេច នៅពេលដែលមនុស្សនោះកន្លងហួសពីភ្នែកយើងទៅ ។

*អ្វីដែលភ្លេច មិនមែនបាត់ ឬរលុបបាត់ទេ ។*

ទោះបីជាយើងភ្លេចឆាប់ ឬក្រភ្លេចនូវវត្ថុទាំងឡាយទាំងពួង ដែលយើង

អាចស្គាល់, វត្ថុទាំងឡាយនោះបានកប់នៅក្នុងសតិរបស់យើង (Notre esprit) ។ វត្ថុទាំងឡាយនោះ មិនមែនបាត់ទាំងស្រុងទេចំពោះយើង ។ វត្ថុទាំងអស់ដែលភ្លេចត្រូវបានដក់នៅជាបំរុងនៅក្នុងសតិរបស់យើង, សតិរបស់យើង គឺជាឃ្លាំងដាក់របស់បំរុងមួយដ៏ធំសំបើម និងដ៏អស្ចារ្យ ដែលគំនិត និងអារម្មណ៍ទាំងអស់ ដែលយើងមានតាំងតែពីកើតមកម្ល៉េះ ត្រូវបានរក្សាទុកនៅកន្លែងរបស់ខ្លួនផ្ទាល់ ។ រឿងអ្វីទាំងអស់ ដែលយើងបានគិត, ដោយអារម្មណ៍ ឬធ្វើ, គឺមាននៅក្នុងទីនោះឯង ។

យើងអាចធ្វើអោយរស់ឡើងវិញនូវរឿងណាក៏ដោយ ក្នុងបណ្ដារឿងទាំងនោះ កាលណាយើងចង់ ។ ហេតុបានជាយ៉ាងនេះ ពីព្រោះ សតិរបស់យើង (notre esprit) មានកត្តាពីរ ៖ ១. ស្គាល់, ដឹង (ដោយវិញ្ញាណ) និងធ្វើក្នុងជីវិតរស់នៅបច្ចុប្បន្ន, ២. ឃ្លាំង ត្រៀមបំរុងដ៏ធំសំរាប់គំនិត និងអារម្មរណ៍ទាំងអស់ដែលភ្លេច ។

ចិត្តវិទូ ហៅកត្តាទី១ ថា *សម្បជញ្ញៈ* (Le conscient) និងហៅកត្តាទី២ ថា *អឡ្បសម្បជញ្ញៈ (Le subconscient)* ។

## សកម្មភាពដ៏ខ្លាំងបំផុតរបស់អឡ្បសម្បជញ្ញៈ

ជាទូទៅ គេជឿថាអ្វីដែលជាសម្បជញ្ញៈ គឺមានជីវិត, មានសកម្មភាព ហើយអ្វីដែលភ្លេច ឬធ្លាក់ក្នុងអឡ្បសម្បជញ្ញៈ ឋិតនៅងាប់ស្ងួក ឬដេកលក់ ។ នេះគឺជាការច្រឡំដ៏ធំនៃទស្សនាទាន ។ គំនិតទាំងអស់ឋិតនៅក្នុងអឡ្បសម្បជញ្ញៈ មានសកម្មភាពជានិច្ច ហើយប្រយុទ្ធដើម្បីចេញមកនៅក្នុងសម្បជញ្ញៈ ហើយវាលេចចេញភ្លាម កាលណាវាមានឱកាស ។ លោកប៊ែរ សុន (Bergson) មានប្រសាសន៍ថា *"អ្វីដែលយើងបានដឹងដោយវិញ្ញាណ, បានស្វែងរក និងមានបំណងតាំងពីវ័យក្មេងមក បានមានវត្តមាននៅទីនេះ, ទោរទន់មកលើពេលវេលាបច្ចុប្បន្ន, រលាយខ្លួនជាមួយវា ហើយត្បុលមកទល់របងសម្បជញ្ញៈ ដែលយាំងផ្លូវមិន*

*អោយចេញ* ។ ព្រះពុទ្ធទ្រង់មានពុទ្ធដីកាដូចគ្នាដែរថា ៖ បុគ្គលភាពរបស់យើងបច្ចុប្បន្ននេះ គឺជាលទ្ធផលនៃអ្វីទាំងអស់ដែលយើងបានធ្វើ បានទទួលការពិសោធន៍ ឬបានគិតគូរតាំងតែពីដើមមក ។

បុគ្គលភាពរបស់ចោរ ខុសប្លែកពីបុគ្គលភាពរបស់បណ្ឌិត ពីព្រោះអ្នកទាំងពីរបានគិត និងបានធ្វើផ្សេងៗពីគ្នានៅក្នុងអតីតកាល ។ អ្វីដែលកន្លងទៅហើយមិនមែនកន្លងទៅហើយចប់ត្រឹមនោះទេ, ប៉ុន្តែ វានៅតែមានចលនាយ៉ាងខ្លាំងក្លាបំផុតនៅក្នុងបច្ចុប្បន្នកាលនេះ ។ អំពើហើយនិងគំនិតរបស់យើងកន្លងទៅ រមែងអន្ទោលតាមយើងជានិច្ច "កៀកកិត បីដូចកង់រទេះតាមកៀកកិតជើងគោដែលអូសរទេះ ឬដូចស្រមោលអន្ទោលតាមប្រាណ ដូច្នោះ" ។

ដូច្នេះ មនុស្សបានកើតឡើងយ៉ាងដូចសុទ្ធសាធ ទៅតាមរូបភាពដែលមនុស្សនោះបានគូរទុកនៅក្នុងអឡ្បសម្បជញ្ញៈរបស់គេផ្ទាល់ ដែលនៅក្នុងនេះ មតិនីមួយៗ ដែលគេបានធ្វើនៅក្នុងពេលណាមួយនោះ ឥឡូវនេះបានងើបឡើង សំដែងចេញទៅតាមបែបបទដោយឡែកៗ ។ នេះគឺជាអ្វីដែលគេហៅថាជីវិត ឬ អាត្មារបស់មនុស្ស ។ យើងបច្ចុប្បន្ន គឺជាលទ្ធផលដែលយើងអតីតកាលបានធ្វើ ឬកសាងឡើងដោយខ្លួនយើង ។

ក្រៅពីសតិ (l'esprit) របស់យើងដែលរួមមានសម្បជញ្ញៈ និងអឡ្បសម្បជញ្ញៈ ដូចយើងបានឃើញរួចហើយ, វាគ្មានកត្តាលោកុត្តរៈណាមួយ ដូចជាព្រលឹង ឬអាត្មាទេ ។

ខ្លួនយើង គឺជាសតិផ្ទាល់របស់យើង ។ មនុស្សម្នាក់ជាមនុស្សបរិសុទ្ធកាលណាអឡ្បសម្បជញ្ញៈរបស់គេពោរពេញទៅដោយគំនិត និងអារម្មណ៍បរិសុទ្ធហើយមនុស្សម្នាក់មិនបរិសុទ្ធ កាលណាអឡ្បសម្បជញ្ញៈរបស់គេ រួមមានគំនិតគ្រប់បែបយ៉ាងដែលអាក្រក់ និង ប្រកបដោយអកុសល ។

*មានអ្នកខ្លះ អាចជំទាស់ទៅនឹងគំនិតនេះថា ប្រសិនបើការពិសោធន៍ទាំងអស់របស់យើង ទោះបីតិចតួចបំផុតដូចម្ដេចក្ដី ត្រូវបានកត់ត្រាក្នុងអឡ្ឋ-សម្បជញ្ញៈ, តើពីព្រោះហេតុអ្វីបានជា យើងមិនអាចរំលឹកឡើងវិញបាននូវភាគច្រើននៃបទពិសោធន៍ទាំងឡាយនោះ ?*

នោះគឺបណ្ដាលមកពីកំលាំង ឬភាពទន់ខ្សោយនៃអឡ្ឋសម្បជញ្ញៈ របស់យើង ដែលយើងអាច ឬយើងមិនអាចធ្វើអោយលេចឡើងនូវអនុស្សាវរីយ៍ អំពីឃ្លាំងស្តុកដ៏ធំនោះរបស់អឡ្ឋសម្បជញ្ញៈ ដែលនៅក្នុងនេះ អ្វីៗទាំងអស់ឋិតថេរនៅ ។ មនុស្សដែលធ្វើសមាធិ ហើយបានហ្វឹកហ្វឺនសម្បជញ្ញៈរបស់គេអោយនឹងន ហើយប្រមូលផ្តុំ រមែងសំរេចបាននូវអនុស្សរណញ្ញាណ (un pouvoir de rappel) ខ្ពស់ជាងអនុស្សរណញ្ញាណរបស់មនុស្សធម្មតាដែលសម្បជញ្ញៈរបស់គេហិចហើរ ហើយមិនឋិតថេរ ។ សម្បជញ្ញៈកាន់តែស្ងប់ ហើយប្រមូលផ្តុំខ្លាំង, ឥទ្ធិពលក៏កាន់តែមានខ្ពស់ទៅលើអឡ្ឋសម្បជញ្ញៈ ។ ព្រះពុទ្ធបានហ្វឹកហ្វឺនបានយ៉ាងសុក្រឹតបំផុត *នូវសម្ប-ជញ្ញៈរបស់ព្រះអង្គ ដែលនាំអោយព្រះអង្គអាចទាញយកចេញពីអឡ្ឋសម្បជញ្ញៈនូវអនុស្សរណញ្ញាណអំពីបទពិសោធន៍ទាំងឡាយនៅក្នុងជាតិពីមុនៗ ដ៏ច្រើន ។* នេះពុំមែនជាហេតុការណ៍ដ៏អស្ចារ្យទេ ។ អ្វីៗទាំងអស់ដែលឋិតថេរនៅក្នុងអឡ្ឋ-សម្បជញ្ញៈ, អ្វីៗទាំងអស់នោះអាចត្រូវនឹកឃើញឡើងវិញ ក្រោយមានការហ្វឹកហ្វឺនដ៏សមស្រប ។

ជីវិតរបស់អឡ្ឋសម្បជញ្ញៈ មិនមែនចាប់ផ្ដើមជាមួយកំណើតរបស់យើងក្នុងភពនេះទេ, ប៉ុន្តែ ជីវិតរបស់អឡ្ឋសម្បជញ្ញៈនេះចេញមកពីជម្រៅនៃកាលដែលកាន់តែធំឡើងៗ ។ ជីវិតនេះបានដក់ជាប់នូវអ្វីៗទាំងអស់ដែលបានចូលមកក្នុងជីវិត ។

*(នៅមានត)*

# សង្គាយនា ទី៤

បន្ទាប់ពីធ្វើសង្គាយនាទី ៣ ចប់ភ្លាម ព្រះមហាមោគ្គលីបុត្តតិស្សត្ថេរ ដោយមានការឧបត្ថម្ភពីព្រះបាទធម្មាសោកនោះ បានចាត់តាំងព្រះមហាថេរសំខាន់ៗ អោយនិមន្តទៅកាន់តំបន់នានា ដើម្បីផ្សព្វផ្សាយពុទ្ធសាសនា ។ ព្រះមហាថេរទាំងឡាយនោះ គឺ :

១. ព្រះមជ្ឈន្តិកត្ថេរ ទៅកាន់ដែនកស្មីរ និងគន្ធារៈ ។

២. ព្រះមហាទេវត្ថេរ ទៅកាន់មហិស្សកមណ្ឌល ។

៣. ព្រះរក្ខិតត្ថេរ ទៅកាន់វនវាសីប្រទេស ។

៤. ព្រះយោនកធម្មរក្ខិតត្ថេរ ទៅកាន់អបរន្តកជនបទ ។

៥. ព្រះមហាធម្មរក្ខិតត្ថេរ ទៅកាន់មហារដ្ឋ ។

៦. ព្រះមហារក្ខិតត្ថេរ ទៅកាន់យោនករដ្ឋ ។

៧. ព្រះមជ្ឈិមត្ថេរ និងព្រះថេរបួនអង្គទៀត គឺ : ព្រះកស្សបគោតត្ថេរ ១ ព្រះអឡកទេវ-ត្ថេរ ១ ព្រះទុន្ទុភិស្សរត្ថេរ ១ ព្រះសហស្សទេវត្ថេរ ១ ទៅកាន់ប្រទេសទាំងឡាយក្នុងតំបន់ភ្នំហិមពាន្ត ។

៨. ព្រះសោណត្ថេរ និង ព្រះឧត្តរត្ថេរ ទៅកាន់សុវណ្ណភូមិ ។

៩. ព្រះមហិន្ទត្ថេរ ទៅកាន់លង្កាទ្វីប ។

ក្នុងការផ្សព្វផ្សាយពុទ្ធសាសនាទៅកាន់តំបន់នានានោះ គេសង្កេតឃើញថា ព្រះមហិន្ទត្ថេរ ដែលត្រូវជាព្រះរាជបុត្រនៃព្រះបាទធម្មាសោក បានធ្វើអោយព្រះពុទ្ធសាសនា រីកចំរើនយ៉ាងឆាប់រហ័សជាងគេនៅលង្កាទ្វីប ។ ព្រះបាទទេវានម្បិយតិស្ស: ជាព្រះចៅលង្កាទ្វីប ព្រមទាំងរាជវង្សានុវង្ស មន្ត្រីរាជការ និងប្រជារាស្ត្រ ស្ទើរតែទាំងអស់ សុទ្ធសឹងជាពុទ្ធ-តាសនិក ។

ព្រះបាទធម្មាសោក បានបង្កលក្ខណៈជួយឧបត្ថម្ភជាបន្តបន្ទាប់ ក្នុងការពង្រីក

ពុទ្ធសាសនា នៅលង្កាទ្វីប ដោយទ្រង់បានបញ្ជូនព្រះនាងមិត្តាថេរី (ភិក្ខុនី) ជាព្រះរាជបុត្រី អោយទៅបន្ថែមទៀត ។

ព្រះមហិន្ទត្ថេរ ទ្រង់ចាត់អោយយកព្រះបរមសារីរិកធាតុ និងមែកមហាពោធិ-ព្រឹក្ស ទៅដាំទុកសំរាប់គោរពបូជានៅអនុរាធបុរី ដែលជាព្រះរាជធានីនៃលង្កាទ្វីប ។

សម័យកាលនោះ មានកុលបុត្រជ្រះថ្លាចូលបួសក្នុងព្រះពុទ្ធសាសនាយ៉ាងច្រើន ។ ថ្ងៃមួយ ព្រះបាទទេវានម្បិយតិស្សៈទ្រង់ទូលសួរព្រះមហិន្ទត្ថេរថា «តើព្រះពុទ្ធសាសនា ឈ្មោះថាបានប្រតិស្ឋានចាក់ឫសកែវជាប់ស៊ប់ ឥតកម្រើក នៅក្នុងលង្កាទ្វីបនេះហើយ ឬនៅ?» ។ ព្រះមហិន្ទត្ថេរ ថ្វាយព្រះពរថា «ព្រះពុទ្ធសាសនា ដែលឈ្មោះថាបានប្រតិស្ឋានចាក់ឫសកែវជាប់ស៊ប់ ឥតកម្រើកនោះ លុះត្រាតែអ្នកបួសក្នុងសាសនានេះ បានសិក្សា គោរពព្រះវិន័យ ចេះចាំស្ទាត់ ម៉ត់ចត់ ហើយអាចបង្ហាត់បង្រៀនគ្នាបានផង» ។

កាលបើទ្រង់ឈ្វេងយល់ច្បាស់ថា ព្រះវិន័យជាឫសកែវនៃព្រះពុទ្ធសាសនាដូចនេះហើយ ព្រះចៅក្រុងលង្កាទ្វីប ក៏ទ្រង់ចាត់អោយរៀបចំមហាមណ្ឌប ដើម្បីព្រះសង្ឃប្រជុំធ្វើសង្គាយនាទី ៤ នេះឡើង ។

ចតុត្ថសង្គាយនានេះ មានរបៀបធ្វើដូចបឋមសង្គាយនាដែរ គ្រាន់តែប្លែកគ្នាត្រង់សង្កត់ធ្ងន់ទៅលើព្រះវិន័យជាង ប៉ុណ្ណោះ ។ ព្រះមហិន្ទត្ថេរជាអ្នកសួរ ព្រះអរិដ្ឋត្ថេរជាអ្នកឆ្លើយ, មានការកសង្ឃចំនួន ៦៨០០០ អង្គ បានចូលរួមធ្វើជាសង្គីតិកាចារ្យ នៅមហា-មណ្ឌបថូបារាម ក្រុងអនុរាធបុរីនៃលង្កាទ្វីប, ធ្វើដប់ខែទើបចប់, ក្នុងពុទ្ធសករាជ ២៣៦ មានព្រះចៅទេវានម្បិយតិស្សៈ ជាសាសនូបត្ថម្ភក៍ ។

(សូមរង់ចាំអានសង្គាយនាទី ៥ និងសង្គាយនាខ្មែរ នៅលេខក្រោយទៀត)

រៀបរៀងដោយ **ម៉ែន ប្រាជ** និង **អាំ ឆន**

# បាយាសិរាជញ្ញសូត្រ

(តចប់)

- *បាយាសិរាជញ្ញៈ* ៈព្រះកស្សបៈដ៏ចំរើន ពោលយ៉ាងនេះគួរដែរ ប៉ុន្តែ ខ្ញុំព្រះករុណានៅតែមិនជឿ ពីព្រោះ ខ្ញុំព្រះករុណាឃើញពួកសមណព្រាហ្មណ៍មានសីលបរិសុទ្ធ មានធម៌ល្អ ចង់តែរស់ មិនចង់ស្លាប់ ប្រាថ្នាតែសេចក្តីសុខ ស្អប់ខ្ពើមសេចក្តីទុក្ខ ។ បើសមណព្រាហ្មណ៍ទាំងនោះដឹងថា យើងទាំងឡាយ កាលបើស្លាប់ពីលោកនេះទៅ ប្រាកដជាបានសេចក្តីសុខប្រសើរជាងឥឡូវនេះ ពួកសមណព្រាហ្មណ៍ទាំងនោះ ប្រាកដជាសម្លាប់ខ្លួន ដើម្បីបានទៅទទួលសេចក្តីសុខនោះហើយ ប៉ុន្តែមិនដូច្នោះទេ ខ្ញុំឃើញតែពួកសមណព្រាហ្មណ៍មានសីលបរិសុទ្ធ មានធម៌ល្អទាំងអស់នោះ ចង់តែរស់ មិនចង់ស្លាប់ ស្អប់ខ្ពើមសេចក្តីទុក្ខ ចង់បានតែសេចក្តីសុខ ។ នេះមកតែពីសមណព្រាហ្មណ៍ទាំងនោះ ក៏មិនដឹងដែរថា កាលបើពួកយើងស្លាប់ពីលោកនេះទៅ ប្រាកដជាបានទៅទទួលសេចក្តីសុខប្រសើរក្នុងលោកដទៃឡើយ ។

- *កុមារកស្សបៈ* ៈ អើ បើដូច្នេះ, អាត្មាធ្វើសេចក្តីប្រៀបមួយប្រាប់មហាបពិត្រជ្រាបថា កាលពីព្រេងនាយ មានបុរសម្នាក់មានប្រពន្ធពីរ ប្រពន្ធមួយមានកូនប្រុសមួយ មានអាយុ១០ឆ្នាំ ឬ១២ឆ្នាំ ប្រពន្ធមួយទៀត កំពុងតែមានគភ៌ និងជិតសម្រាល ។ នៅពេលនោះ ព្រាហ្មណ៍ជាស្វាមី ក៏ធ្វើមរណកាលទៅ មាណពជាកូនក៏និយាយនឹងព្រាហ្មណីជាម្តាយចុងថា ទ្រព្យសម្បត្តិទាំងអស់ណាទោះមានវិញ្ញាណ ឬឥតវិញ្ញាណ ទ្រព្យទាំងអស់នោះជារបស់ខ្ញុំ ឯអ្នកមិនត្រូវបានចំណែកតិចតួចឡើយ ។ នាងព្រាហ្មណី ឆ្លើយតបនឹងមាណពនោះវិញថា ចូរអ្នកបង្អង់សិន ទម្រាំអញសម្រាលកូនរួច ។ បើកូនអញនោះជាកូនប្រុស, នោះវានឹងត្រូវបានសម្បត្តិតិចតួចដែរ បើជាកូនស្រី នោះវានឹងបានធ្វើជាភរិយារបស់អ្នក ។

នាងព្រាហ្មណី, កាលបើមាណពនោះ ចូលទៅនិយាយឱ្យប្រគល់ទ្រព្យឱ្យខ្លួនញយដងពេក ក៏កាន់កាំបិតចូលទៅក្នុងបន្ទប់ ហើយវះពោះខ្លួនឯង ដោយគិតថា បើកូនក្នុងគភ៌នោះជាប្រុស ឬស្រី អាត្មាអញគង់ដឹងច្បាស់ ។ ហេតុតែល្ងង់មិនឈ្លាសវៃ ស្វែងរកព្រទ្យមរតកដោយមិនត្រូវទំនង ក៏ដល់នូវសេចក្ដីវិនាសទាំងខ្លួនផង ទាំជីវិតផង ទាំងកូនក្នុងផ្ទៃផង ទាំងទ្រព្យសម្បត្តិផង ។

បពិត្ររាជញ្ញៈ, ព្រះអង្គជាបុគ្គលល្ងង់ ស្វែងរកបរលោកដោយខុសទំនង គង់នឹងដល់នូវសេចក្ដីវិនាស ដូចព្រាហ្មណីដែលស្វែងរកទ្រព្យខុសទំនងនេះឯង ។ ពួកសមណព្រាហ្មណ៍មានសីលល្អ មានធម៌ល្អ ឋិតនៅយូរអង្វែងដរាបណា ដរាបនោះ ពួកសមណព្រាហ្មណ៍ទាំងនោះ រមែងបានបុណ្យច្រើន បានប្រតិបត្តិជាប្រយោជន៍ ដល់ជនច្រើន ដើម្បីសេចក្ដីសុខដល់ជនច្រើន ដើម្បីប្រយោជន៍ដល់សត្វ-លោក ព្រមទាំងទេវតា និងមនុស្សទាំងឡាយ ។

*បាយាសិរាជញ្ញៈ* : ព្រះករុណានិយាយយ៉ាងនេះគួរដែរ ប៉ុន្តែ ខ្ញុំមិនទាន់ជឿនៅឡើយ ព្រោះខ្ញុំធ្លាប់ឱ្យគេបោះចោរទាំងរស់ទៅក្នុងខ្ទះ ហើយឱ្យបិទមាត់ខ្ទះឱ្យជិត ទើបឱ្យលើកខ្ទះនោះដាក់លើជើងក្រាន រួចដុតភ្លើង ។ កាលដឹងថាចោរនោះស្លាប់ហើយ ទើបឱ្យគេដាក់ខ្ទះចុះ ហើយបើកគម្របសន្សឹមៗ ពិនិត្យមើលម៉ត់ចត់ ដោយបំណងថា ចាំមើលព្រលឹងចោរនោះចេញទៅ ប៉ុន្តែយើងមិនឃើញព្រលឹងចោរនោះចេញទៅសោះ ។

*កុមារកស្សបៈ* : ឥឡូវនេះ អាត្មាភាព សូមសួរមហាបពិត្រវិញថា ព្រះអង្គធ្លាប់ផ្ទំក្នុងវេលាថ្ងៃ ហើយទ្រង់សុបិនឃើញសួនច្បារ ព្រៃព្រឹក្សា ជាដើម ឬទេ ? ហើយសម័យនោះ មានពួកស្រីស្នំក្រមការក្មេងចាស់ ចាំរក្សាព្រះអង្គឬទេ ? ពួកអ្នកអង្គុយចាំរក្សាព្រះអង្គនោះ បានឃើញព្រលឹងរបស់ព្រះអង្គកំពុងចេញ កំពុងចូលដែរឬទេ?

*បាយាសិរាជញ្ញៈ* ៖ ករុណា, ខ្ញុំធ្លាប់ផ្ទំលក់ក្នុងវេលាថ្ងៃ ហើយធ្លាប់សុបិនឃើញសួនច្បារ, ឃើញព្រៃព្រឹក្សាជាដើមដែរ នៅពេលកំពុងសុបិននោះ ក៏មានស្រីស្នំក្រុមការអង្គុយចាំថែរក្សាដែរ ប៉ុន្តែ អ្នកទាំងនោះពុំបានឃើញព្រលឹងរបស់ខ្ញុំ កំពុងចេញទៅ និងចូលមកវិញនោះទេ ។

*កុមារកស្សបៈ* ៖ អម្បាលស្រីស្នំក្រុមការនៅរស់ គង់ពុំឃើញព្រលឹងរបស់មហាបពិត្រកំពុងរស់នៅកាលចូល ឬ ចេញទៅផង ចំណង់បើមនុស្សស្លាប់ទៅហើយ មហាបពិត្រនឹងទតឃើញព្រលឹងកាលចេញទៅ និងចូលមកដូចម្តេចបាន ។

*បាយាសិរាជញ្ញៈ* ៖ លោកម្ចាស់ពោលយ៉ាងនេះក៏គួរដែរ ប៉ុន្តែខ្ញុំធ្លាប់បានឱ្យគេថ្លឹងចោរម្នាក់មុននឹងយកគេទៅសម្លាប់ ។ ការសម្លាប់នោះ មិនបានធ្វើឱ្យមានឈាមហូរចេញ ឬរបកស្បែកត្រង់កន្លែងណាមួយទេ ។ កាលចោរនោះស្លាប់ហើយ ខ្ញុំបានឱ្យអាមាត្យថ្លឹងសាកសពចោរនោះម្តងទៀត (ដោយជញ្ជីងដដែល) ។ ឃើញថាទម្ងន់សាកសពចោរនោះ ធ្ងន់ជាងរូបចោរនោះកាលកំពុងរស់នៅ ។ ហេតុនេះហើយដែលខ្ញុំមិនជឿថាមានអ្វីចេញពីចោរទៅកើតទេ ។

*កុមារកស្សបៈ* ៖ ថ្វាយព្រះពររាជញ្ញៈ ដុំដែកដែលគេកំពុងដុតឆេះរន្ទាលច្រាលឆ្អៅ នឹងទៅជាដុំដែកស្រាលផង ទន់ផង ។ លុះដុំដែកនោះរលត់ ភ្លើងត្រជាក់ទៅវិញ នឹងទៅជាដុំដែកធ្ងន់ជាងផង រឹងជាងផង ។ កាយនេះឯងក៏ដូច្នេះដែរ, កាលបើប្រកបដោយអាយុផង ភ្លើងធាតុផង វិញ្ញាណផង កាយនេះនឹងទៅជាស្រាលផងទន់ផង ប៉ុន្តែបើកាយនេះប្រាសចាកអាយុ ប្រាសចាកធាតុភ្លើង, ប្រាសចាកវិញ្ញាណពេលណាហើយ, ពេលនោះ កាយនេះនឹងទៅជាកាយធ្ងន់ផង រឹងផង ។

*បាយាសិរាជញ្ញៈ* ៖ ខ្ញុំមិនទាន់ជឿបានទេ ព្រោះខ្ញុំធ្លាប់ឱ្យពេជ្ឈឃាតយកចោរទៅសម្លាប់ ហើយធ្វើសាកសពនោះមិនឱ្យខូចស្បែក សាច់ សរសៃ ឆ្អឹង ខួរក្នុងឆ្អឹងត្រង់កន្លែងណាមួយសោះ ក្រែងលោយើងបានឃើញព្រលឹងចោរនោះចេញទៅ

ប៉ុន្តែមិនឃើញសោះ ឯភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ របស់ចោរនោះក៏នៅដដែល ប៉ុន្តែ លែងឃើញ លែងឮ លែងដឹងរសជាតិ លែងដឹងផោតព្វៈទាំងអស់ ។ នេះហើយដែលខ្ញុំមិនជឿលោកម្ចាស់ ។

*កុមារកស្សបៈ* ៖ ថ្វាយព្រះពរ, ឥឡូវអាត្មាធ្វើការប្រៀបធៀបថ្វាយថា កាលពីព្រេងនាយ មានបុរសផ្លុំស័ង្ខម្នាក់កាន់ស័ង្ខដើរទៅកាន់ជនបទ លុះចូលទៅដល់ស្រុកមួយ ក៏ឈរផ្លុំស័ង្ខ៣ ដង រួចដាក់ស័ង្ខចុះ ហើយអង្គុយចុះក្បែរទីនោះ ។ លំដាប់នោះ ពួកអ្នកជនបទមានការត្រិះរិះថា ចុះសំឡេងនោះជាសំឡេងអ្វី បានជាពិរោះម្ល៉េះ ។ មនុស្សទាំងនោះ ក៏ដើរចូលទៅជិតអ្នកផ្លុំស័ង្ខ ហើយសួរថា សំឡេងអម្បាញ់មិញនេះ ជាសំឡេងអ្វីបានជាពិរោះម្ល៉េះ ? បុរសអ្នកផ្លុំស័ង្ខនិយាយថា នេះគឺជាសំឡេងស័ង្ខ ។ មនុស្សទាំងនោះ ក៏ចាប់ស័ង្ខលើកឡើងដើម្បីរកមើលសំឡេងរបស់វា តែមិនឃើញសោះ ហើយនិយាយនឹងស័ង្ខនោះថា នែស័ង្ខ អ្នកចូរបន្លឺសំឡេងឡើង ។ ស័ង្ខនៅតែមិនបន្លឺសំឡេងសោះ ។

អ្នកផ្លុំស័ង្ខក៏គិតថា មនុស្សទាំងអស់នេះហៅពេញជាល្ងង់ មិនសមបើនាំគ្នាមកស្វែងរកសំឡេងស័ង្ខដោយខុសទំនងដូច្នេះសោះ ។ កាលពួកមនុស្សកំពុងរោម មើលអ្នកផ្លុំស័ង្ខ គាត់ក៏ចាប់ស័ង្ខឡើងផ្លុំ ៣ ដង រួចក៏ចេញពីទីនោះទៅ ។

មនុស្សទាំងអស់នោះ ក៏ត្រិះរិះដូច្នេះថា ធម្មតាស័ង្ខនេះ លុះតែកាលណាបានផ្សំនឹងបុរសផង ផ្សំនឹងសេចក្តីព្យាយាមផង ផ្សំនឹងខ្យល់ផង ទើបស័ង្ខនេះបន្លឺសំឡេងបាន ។ បើស័ង្ខនេះ មិនផ្សំដោយធាតុទាំងនេះទេ វាក៏បន្លឺសំឡេងមិនបានឡើយ ។ បពិត្ររាជញ្ញៈ កាយនេះ កាលបើប្រកបដោយអាយុ ដោយភ្លើងធាតុ ដោយវិញ្ញាណ វាអាចសម្រេចឥរិយាបថដេក ដើរ ឈរ អង្គុយបាន, ត្រចៀកស្តាប់សំឡេងបាន ច្រមុះក៏ធុំក្លិន អណ្តាតក៏ដឹងរសជាតិ ប៉ុន្តែបើវាមិនប្រកបដោយអាយុ ដោយភ្លើងធាតុ និងវិញ្ញាណទេ កាយនេះ ក៏សម្រេចឥរិយាបថអ្វីមិនបាន, លែងឮ លែង

ឃើញជាដើម ដូច្នោះដែរ ។

*បាយាសិរាជញ្ញៈ* ៖ ព្រះកុមារកស្សបៈប្រៀបធៀបមកក៏គួរដែរ ប៉ុន្តែ ខ្ញុំមិនអាចលះបង់ទិដ្ឋិរបស់ខ្ញុំបានទេ ព្រោះព្រះបាទបសេនទិកោសលក្តី ព្រះរាជាដទៃក្តី ប្រជារាស្រ្តក្តី ដឹងច្បាស់ថា ខ្ញុំ (ព្រះបាទបាយាសិ) ធ្លាប់និយាយថា លោកដទៃមិនមាន សត្វជាឧបបាតិកៈមិនមាន ផលរបស់កម្មដែលគេធ្វើល្អក្តី ធ្វើអាក្រក់ក្តីមិនមាន ។ បើខ្ញុំលះបង់ការយល់ឃើញ ( ទិដ្ឋិ ) នេះចេញ អ្នកផងគេនឹងស្តីបន្ទោសថា ខ្ញុំជាមនុស្សល្ងង់ខ្លៅ ប្រកាន់តែសេចក្តីខុស, ដូច្នេះ ខ្ញុំមុខជាត្រឡប់ទៅកាន់ទិដ្ឋិដដែលនេះវិញ ។

*កុមារកស្សបៈ* ៖ អើ បើដូច្នេះ អាត្មាភាពនឹងធ្វើឧបមាមួយថ្វាយមហាបពិត្រថា កាលពីព្រេងនាយ មានបុរសជាអ្នកចិញ្ចឹមជ្រូក បានចេញពីស្រុករបស់ខ្លួនទៅកាន់ស្រុកដទៃ បានឃើញលាមកក្រៀមដ៏ច្រើន ដែលគេបោះបង់ចោល ។ បុរសនោះបានឃើញហើយ ក៏មានសេចក្តីត្រិះរិះថា លាមកក្រៀមនេះត្រូវជាចំណីជ្រូករបស់អញ គួរតែអញយកលាមកក្រៀមនេះទៅ ; បុរសនោះ ក៏លាសំពត់បង់កកើបលាមកនោះដាក់វេចជាបង្វេចលើកទូល ហើយដើរទៅ ។ កាលបុរសនោះ កំពុងដើរតាមផ្លូវ មេឃក៏បង្អុរភ្លៀងមួយមេធំ លាមកក្នុងបង្វេចក៏ត្រូវរលាយ ហើយហូរធ្លាក់រហូតដល់ចុងជើង បុរសនោះមិនលះបង់ នៅតែទ្រាំទ្រទូលតទៅទៀត ។ មនុស្សទាំងឡាយឃើញហើយ ក៏ពោលថា នៃវើយ ! ឯងជាមនុស្សឆ្កួតទេឬ បានជាទូលបង្វេចលាមកដែលកំពុងហូរស្រោចតាំងពីក្បាល រហូតដល់ចុងជើងដូច្នេះ ។ បុរសអ្នកទូលលាមកឆ្លើយថា អ្នកទាំងឡាយទេតើ ជាមនុស្សឆ្កួត មនុស្សលេលា, បានជាអញថាដូច្នោះ ព្រោះលាមកនេះជាបាយជ្រូករបស់អញ ។ បពិត្ររាជញ្ញៈ, មហាបពិត្រប្រកាន់យ៉ាងនេះ ក៏ដូចជាអ្នកទូលលាមកនេះដែរ ។ សូមមហាបពិត្រលះបង់ទិដ្ឋិនោះចោលទៅ ។

*បាយាសិរាជញ្ញៈ* ៖ ព្រះកស្សបៈដ៏ចម្រើន ពោលយ៉ាងនេះសមដែរហើយ

ប៉ុន្តែ ខ្ញុំមិនអាចលះបង់ទិដ្ឋិនេះបានទេ ។

*កុមារកស្សបៈ* ៖ អើ បើដូច្នេះ អាត្មាភាពធ្វើការប្រៀបធៀបមួយទៀតថា កាលពីព្រេងនាយ មានបុរសពីរនាក់ជាសម្លាញ់នឹងគ្នា នៅក្នុងជនបទមួយជាមួយគ្នា ។ គ្រានោះ បុរសជាសម្លាញ់បានបបួលបុរសជាសម្លាញ់ថា នែសម្លាញ់ មកយើងនឹងទៅកាន់ជនបទនោះ ក្រែងជួនជាយើងបានទ្រព្យសម្បត្តិបន្តិចបន្តួច ។ បុរសជាសម្លាញ់ កាលបានឮសំដីបបួលដូច្នេះ ក៏ព្រមទៅ ។ បុរសទាំងពីរបានចូលទៅកាន់ស្រុកមួយដែលគេបោះបង់ចោល ក៏បានឃើញសម្បកធ្មៃជាច្រើន ដែលគេចោលក្នុងទីនោះ ។ បុរសទាំងពីរនាក់នោះក៏និយាយគ្នាថា នែសម្លាញ់ សម្បកធ្មៃដ៏ច្រើននេះគេចោលហើយ ដូច្នេះ យើងចងបាច់សម្បកធ្មៃនេះមួយបាច់ម្នាក់យកទៅ ។ បុរសនោះ ក៏ចងសម្បកធ្មៃនោះជាបាច់បានមួយបាច់ម្នាក់ ហើយក៏លីយកទៅ ; មិនជាឆ្ងាយប៉ុន្មានពីទីនោះ គេបានចូលទៅក្នុងស្រុកមួយទៀត ឃើញសរសៃធ្មៃជាច្រើនដែលគេចោលនៅទីនោះ ។ បុរសជាសម្លាញ់ម្នាក់ និយាយទៅកាន់សម្លាញ់ម្នាក់ទៀតថា នែសម្លាញ់ យើងត្រូវការសម្បកធ្មៃ ព្រោះចង់បានសរសៃរបស់វា ។ ឥឡូវនេះសរសៃធ្មៃនេះគេចោលគគោកស្រាប់ហើយ ដូច្នេះ អ្នកចូរចោលសម្បកធ្មៃ របស់អ្នកទៅ ឯខ្ញុំក៏ចោលសម្បកធ្មៃរបស់ខ្ញុំដែរ ហើយយើងទាំងពីរកាន់យកសរសៃធ្មៃទាំងនេះវិញទៅ ។ បុរសជាសម្លាញ់ម្នាក់និយាយថា បាច់សម្បកធ្មៃនេះ ខ្ញុំបានចងត្រឹមត្រូវ ហើយលីមកអស់ចម្ងាយផ្លូវដ៏វែងហើយ ដូច្នេះ ខ្ញុំនឹងមិនចោលវាឡើយ ឯបុរសជាសម្លាញម្នាក់ទៀតនោះ ក៏ចោលបាច់សម្បកធ្មៃរបស់ខ្លួន ហើយកាន់យកសរសៃធ្មៃវិញ ហើយក៏ធ្វើដំណើរតទៅទៀត ។ មិនយូរប៉ុន្មាន ក៏បានទៅដល់ស្រុកមួយ បានឃើញសំពត់ដែលត្បាញពីសរសៃធ្មៃជាច្រើន ដែលគេចោលក្នុងទីនោះ ។ អ្នកលីសរសៃធ្មៃនិយាយទៅកាន់សម្លាញ់ដែលលីសម្បកធ្មៃថា យើងត្រូវការសម្បកធ្មៃក្តី សរសៃធ្មៃក្តី ដើម្បីធ្វើសំពត់ ឥឡូវ បើសំពត់ដែលធ្វើពីសរសៃធ្មៃ គេចោល

គគោកស្រាប់ហើយ ដូច្នេះ អ្នកត្រូវចោលបាច់សម្បកធ្មៃ ឯខ្ញុំក៏ចោលសរសៃធ្មៃដែរ ហើយយើងទាំងពីរនាក់កាន់យកសំពត់ធ្វើពីសរសៃធ្មៃវិញ ។ អ្នកលីសម្បកធ្មៃនៅតែមិនព្រមចោល ឯអ្នកលីសរសៃធ្មៃ បានបោះបង់ចោលសរសៃធ្មៃ របស់ខ្លួន ហើយកាន់យកសំពត់ធ្វើពីសរសៃធ្មៃនោះវិញ ហើយនាំគ្នាធ្វើដំណើរទៅទៀត ។ លុះទៅដល់ស្រុកមួយ បានឃើញសំពត់សម្បកឈើជាច្រើនដែលគេចោល, ឃើញកប្បាសជាច្រើន, ឃើញសរសៃកប្បាសជាច្រើន, ឃើញសំពត់ធ្វើពីសរសៃកប្បាសជាច្រើន, ឃើញដែកជាច្រើន, ឃើញប្រាក់ជាច្រើន, ឃើញមាសជាច្រើន ដែលគេចោល ហើយបុរសជាសម្លាញ់នោះ និយាយទៅកាន់សម្លាញ់ដែលលីសម្បកធ្មៃថា យើងត្រូវការសម្បកធ្មៃក្តី សរសៃធ្មៃក្តី សំពត់សម្បកឈើក្តី សំពត់សរសៃកប្បាសក្តី ដែកក្តី ស្ពាន់ក្តី ក៏ដើម្បីប្រយោជន៍ដល់មាសនេះឯង, ឥឡូវមាសនេះ គេចោលគគោកស្រាប់ហើយ ដូច្នោះ អ្នកចូរចោលបាច់សម្បកធ្មៃទៅ ឯខ្ញុំនឹងចោលបង្វេចប្រាក់ដែរ យើងទាំងពីរនាក់នឹងយកតែបង្វេចមាសទៅវិញ ។ សម្លាញ់អ្នកលីសម្បកធ្មៃនិយាយថា បាច់សម្បកធ្មៃនេះ ខ្ញុំបានចងបាច់ស្រួលបួលហើយ ហើយបានលីមកពីទីឆ្ងាយណាស់ បើអីចឹងខ្ញុំមិនចោលរបស់នេះទេ ។

លំដាប់នោះ បុរសជាសម្លាញ់នោះក៏ចោលបង្វេចប្រាក់ ហើយយកតែបង្វេចមាស ។ តមកទៀត បុរសទាំងពីរក៏បានចូលទៅដល់ស្រុករបស់ខ្លួនវិញ ។ មាតាបិតា ប្រពន្ធ កូន និងពួកមិត្ត អាមាត្យរបស់បុរសអ្នកស្ពាយបង្វេចមាស អបអរស្វាគមន៍ចំពោះបុរសនោះយ៉ាងក្រៃលែង ។ បុរសស្ពាយបង្វេចមាសនោះ ក៏បានសេចក្តីសុខសោមនស្ស ព្រោះហេតុតែមាសនោះ ។ ឯមាតា បិតា ប្រពន្ធ កូន មិត្តអាមាត្យ របស់បុរសអ្នកលីបាច់សម្បកធ្មៃនោះមិនត្រេកអរ ហើយស្តីបន្ទោសបុរស

នោះ ។ បុរសលីសម្បុកធ្មៃ ក៏មិនបានសេចក្តីសុខសោមនស្ស ព្រោះហេតុតែសម្បុកធ្មៃនោះ ។ បពិត្ររាជញ្ញៈ មហាបពិត្រក៏ប្រហែលដូចជាបុរសអ្នកលីសម្បុកធ្មៃនោះឯង សូមមហាបពិត្រលះបង់ទិដ្ឋិអាក្រក់នោះចេញ ព្រោះទិដ្ឋិអាក្រក់នោះ មិនមែននាំមកនូវប្រយោជន៍ដល់ព្រះអង្គ ពិតជានាំសេចក្តីទុក្ខដ៏យូរអង្វែងដល់ព្រះអង្គ ។

*បាយាសិរាជញ្ញៈ* ៖ ខ្ញុំមានចិត្តត្រេកអរ ជ្រះថ្លាហើយ ដោយសារសេចក្តីឧបមារបស់ព្រះកស្សបៈដ៏ចម្រើន តាំងពីដំបូងមកម្ល៉េះ ប៉ុន្តែ ខ្ញុំចង់ស្តាប់បញ្ហាបដិភាណដ៏ពិចិត្តនេះទៀត ។ បពិត្រព្រះកស្សបៈដ៏ចម្រើន ធម៌ដែលព្រះកស្សបៈបានសំដែងដោយអនេកបរិយាយយ៉ាងនេះ ភ្លឺច្បាស់ណាស់ ដូចជា គេផ្ងាររបស់ដែលផ្កាប់ ។ បពិត្រព្រះកស្សបៈដ៏ចម្រើន ខ្ញុំសូមដល់នូវព្រះគោតមដ៏មានព្រះភាគផង ព្រះធម៌ផង ព្រះសង្ឃផង ជាទីពឹង ជាទីរលឹក ចាប់ដើមពីថ្ងៃនេះតទៅ សូមព្រះកស្សបៈដ៏ចម្រើន ចាំទុកនូវខ្ញុំព្រះករុណា ថាជាឧបាសក ដល់នូវសរណៈស្មើដោយជីវិត មិនតែប៉ុណ្ណោះទេ ខ្ញុំត្រូវការនឹងបូជាមហាយញ្ញ សូមព្រះកស្សបៈដ៏ចម្រើន ប្រៀនប្រដៅខ្ញុំផង ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ អស់កាលជាយូរអង្វែងដល់ខ្ញុំ ។

*កុមារកស្សបៈ* ៖ ថ្វាយព្រះពររាជញ្ញៈ ពួកមនុស្សសម្លាប់គោ ពពែ ចៀមជាដើម តែងដល់សេចក្តីវិនាស ទាំងបដិគ្គាហកៈ ( អ្នកទទួល ) ក៏ជាអ្នកយល់ឃើញខុស មានសេចក្តីត្រិះរិះខុស មានវាចាខុស មានការងារខុស មានការចិញ្ចឹមជីវិតខុស មានសេចក្តីព្យាយាមខុស មានសតិខុស មានសមាធិខុស មានក្នុងយញ្ញវិធីណា យញ្ញ-វិធីនោះ មិនមានផលច្រើនទេ មិនមានអានិសង្សច្រើនទេ ។ បពិត្ររាជញ្ញៈ ប្រៀបដូចអ្នកភ្ជួរនាំយកពូជមិនល្អ ជាពូជស្អុយ មិនដុះ ទៅព្រោះក្នុងស្រែមិនល្អ មិនបានគាស់រំលើងដង្កត់ និងបន្លាចេញ ទាំងភ្លៀងសោត ក៏មិនបានបង្អុរចុះមកដោយល្អ ពូជទាំងឡាយនោះ នឹងដល់នូវការដុះ លូតលាស់បានដែរឬទេ អ្នកភ្ជួរត្រូវបានផល

បរិបូរដែរឬទេ ?

*បាយាសិរាជញ្ញៈ* ៖ បពិត្រព្រះកស្សបៈដ៏ចំរើន, មិនបានទេ ។

*កុមារកស្សបៈ* ៖ បពិត្ររាជញ្ញៈ ប្រសិនបើពួកមនុស្សមិនសម្លាប់គោ មិនសម្លាប់ពពែ ចៀម ឬសត្វមានជីវិតផ្សេងៗទៀត ទាំងពួកបដិគ្គាហកៈ គឺអ្នកទទួលសោត ក៏មានសេចក្ដីយល់ត្រូវ មានវាចាត្រូវ មានការងារត្រូវ មានការចិញ្ចឹមជីវិតត្រូវ មានសេចក្ដីព្យាយាមត្រូវ មានសតិត្រូវ មានសមាធិត្រូវ, ក្នុងយញ្ញវិធីបែបនេះ ទើបជាយញ្ញវិធីមានផលច្រើន មានអានិសង្សច្រើន ប្រៀបដូចអ្នកភ្ជួរយកពូជ និងនង្គ័លចូលទៅក្នុងព្រៃ អ្នកនោះយកពូជដ៏ល្អ ជាពូជដាក់គ្រាប់គ្រប់បរិបូរ ជាពូជអាចដុះបាន ទៅព្រោះក្នុងស្រែដ៏ល្អ គឺស្រែដែលគេបានភ្ជួររាស់ហើយ ទាំងដង្គត់ បន្លា ក៏យកចេញហើយ ទាំងភ្លៀងក៏បង្អុរចុះជោគជាំទៀត ពូជនោះដល់នូវការដុះ លូតលាស់ដ៏ល្អ ឯអ្នកភ្ជួរសោតទៀត ក៏បានទទួលផលបរិបូរដែរ ។

បន្ទាប់ពីបានសួរដេញដោល និងបានស្ដាប់ការពន្យល់ ដោះស្រាយអធិប្បាយរបស់ព្រះកស្សបៈមក ព្រះបាទបាយាសិរាជញ្ញៈ បានផ្ដើមធ្វើទានចំពោះសមណព្រាហ្មណ៍ មនុស្សកំសត់ និងស្មូមយាចកទាំងឡាយ, តែក្នុងទាននោះ ស្ដេចបាយាសិ ឱ្យតែបាយចុងអង្ករ និងជ្រក់ ។ ចំណែកសាច់សំពត់វិញ ក៏ឱ្យតែសំពត់ណាដែលមានសាច់គ្រាស់គគ្រើមមិនជាទីពេញចិត្ត ។ ការឱ្យទាននោះ មានមាណពម្នាក់ឈ្មោះឧត្តរៈអ្នកចាត់ចែងជំនួស ។ ព្រះអង្គពុំបានធ្វើដោយផ្ទាល់ខ្លួនទេ ។ ឧត្តរមាណពឱ្យទានហើយ ក៏ឧទ្ទិសយ៉ាងនេះថា ដោយផលនៃការឱ្យទាននេះ សូមឱ្យខ្ញុំបានជួបព្រះបាទបាយាសិតែក្នុងជាតិនេះ, ជាតិក្រោយទៀត សុំកុំឱ្យខ្ញុំបានជួបឡើយ ។ ស្ដេចបាយាសិបានឮដំណឹងថា ឧត្តរមាណពឧទ្ទិសយ៉ាងដូច្នោះ ក៏ឱ្យហៅឧត្តរមាណពមកសួរថា អ្នកបានឧទ្ទិសថាសុំឱ្យជួបខ្ញុំតែជាតិនេះ ជាតិក្រោយទៀត កុំឱ្យជួបនឹងខ្ញុំឬ ? មាណពនោះឆ្លើយថា ករុណាវិសេស ដូច្នេះមែន ។ ព្រះបាទបាយាសិ សួរថា ហេតុ

អីក៏ដូច្នេះ ? ឧត្តរមាណពក៏ក្រាបទូលថា ខ្ញុំព្រះអង្គតែងឱ្យភោជន មានសភាពយ៉ាងនេះ ក្នុងទានរបស់ព្រះអង្គ គឺបាយចុងអង្ករ មានជ្រក់ជាម្ហូប ដែលព្រះអង្គមិនសព្វព្រះទ័យសោយទាល់តែសោះ សូម្បីតែប៉ះពាល់ដោយព្រះបាទ ក៏មិនឱ្យប៉ះផង; ម្យ៉ាងទៀត សំពត់មានសាច់គគ្រាតគគ្រើមដែលព្រះអង្គមិនសព្វព្រះទ័យ សូម្បីប៉ះពាល់ដោយព្រះបាទ ក៏មិនឱ្យប៉ះពាល់ផង ព្រះអង្គឱ្យខ្ញុំចាត់ចែងសំពត់បែបនោះក្នុងទានរបស់ព្រះអង្គ ។ កាលទ្រង់បានសណ្តាប់ពាក្យនេះរបស់ឧត្តរមាណពហើយ ព្រះអង្គក៏បញ្ជាថា យើងធ្លាប់បរិភោគភោជនបែបណា ចូរអ្នកតាក់តែងភោជនបែបនោះ ឱ្យជាទានចុះ, យើងធ្លាប់ស្លៀកសំពត់បែបណា អ្នកចូរតាក់តែងសំពត់បែបនោះ ឱ្យជាទានចុះ ។ ឧត្តរមាណពបានធ្វើតាមបញ្ជារបស់ព្រះបាទបាយាសិសព្វគ្រប់ ។ គ្រានោះព្រះបាទបាយាសិ ឱ្យទានដោយមិនគោរព, មិនបានឱ្យដោយព្រះហស្តផ្ទាល់ព្រះអង្គ ឱ្យទានដោយមិនផ្ចិតផ្ចង់ ឱ្យទានដោយបោះឱ្យ លុះបែកធ្លាយរាងកាយទៅ ក៏បានទៅកើតជាមួយពួកទេវតាជាន់ចាតុម្មហារាជិកា ក្នុងសេរីសកវិមាន (វិមានប្រាក់ មានដើមច្រេសធំមួយ ដុះនៅជិតទ្វារវិមាននោះ ទើបលោកហៅថា សេរីសកវិមាន) ជាវិមានស្ងាត់ស្ងួនតែម្នាក់ឯង ។ ចំណែកឧត្តរមាណពចាត់ចែងទានរបស់ព្រះបាទបាយាសិនោះ បានឱ្យទានដោយគោរព ឱ្យទានដោយដៃខ្លួនឯង ឱ្យទានដោយផ្ចិតផ្ចង់ ឱ្យទានដោយមិនបានបោះឱ្យ លុះបែកធ្លាយរាងកាយទៅ ក៏បានទៅកើតក្នុងស្ថានសួគ៌ទេវ-លោក ជាមួយពួកទេវតាជាន់តាវត្តិង្ស ។

សម័យនោះឯង ព្រះ **គវម្បតិ** ដ៏មានអាយុ តែងនិមន្តទៅសម្រាកនៅសេរីសកវិមាន ជារឿយៗ ព្រោះទីនោះឯងជាទីស្ងាត់ ។ ពេលនោះ ព្រះអង្គបានជួបនឹងបាយាសិទេវបុត្រ ហើយទ្រង់សួរថា ឧត្តរមាណពជាអ្នកចាត់ចែងទាន របស់ព្រះ

អង្គនោះ តើទៅកើតក្នុងទីណា ? ។ ឧត្តរមាណពជាអ្នកខ្វល់ខ្វាយក្នុងទានរបស់ខ្ញុំ បានឱ្យទានដោយគោរព បានឱ្យទានដោយដៃខ្លួនឯង ឱ្យទានដោយផ្ចិតផ្ចង់ បានទៅកើតក្នុងស្ថានសុគតិសួគ៌ទេវលោក ជាមួយពួកទេវតាជាន់តាវត្តិង្ស ។ ចំណែកខ្ញុំ បានឱ្យទានដោយមិនគោរព, មិនបានឱ្យដោយដៃខ្លួនឯង, មិនបានផ្ចិតផ្ចង់ ឱ្យទានដោយបោះឱ្យ លុះបែកធ្លាយរាងកាយ គឺបន្ទាប់ពីមរណៈមក ក៏បានមកកើតក្នុងសេរីសក-វិមាន ជាវិមានស្ងាត់ ជាមួយពួកទេវតាក្នុងជាន់ចាតុម្មហារាជិកា ។

បពិត្រព្រះគវម្បតិដ៏ចម្រើន កាលបើព្រះអង្គនិមន្តទៅកាន់មនុស្សលោកវិញ ព្រះអង្គមេត្តាប្រាប់ដល់មនុស្សលោកទាំងអស់ផង នូវសេចក្ដីដែលខ្ញុំព្រះករុណាបានរៀបរាប់ប្រគេនមកនេះ ។

**ចប់**

សម្រួលចាកព្រះត្រៃបិដក

ដោយ

**ម៉ែន ប្រាជ្ញ និង អាំ ឆន**

# អង្គការចាត់តាំង
# ព្រះសង្ឃពុទ្ធសាសនិក
## នៅប្រទេសកម្ពុជា

លោកសង្ឃ ឬភិក្ខុសង្ឃនៅប្រទេសកម្ពុជា រួមផ្ដុំជាអង្គភាពមួយ មានការចាត់តាំង ដែលឋានានុក្រមរបស់អង្គភាពនេះ នាពេលបច្ចុប្បន្ន ត្រូវបានកំណត់ដោយព្រះរាជក្រម ចុះថ្ងៃទី ៩ ខែកុម្ភៈ និង ព្រះរាជក្រម ចុះថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ ១៩៤៣ ។ ព្រះរាជក្រមទាំងពីរនេះ ត្រូវបានកែសម្រួលដោយព្រះរាជក្រម ចុះថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ១៩៤៨ ។

ព្រះសង្ឃខ្មែរ ទោះបីជាប្រកាន់តាមបែបហីនយាន ដូចគ្នានឹងព្រះសង្ឃប្រទេសសីឡង់ ប្រទេសសៀម ប្រទេសលាវ និងប្រទេសភូមា ក៏ដោយ, ក៏មានឯករាជភាពទាំងស្រុង ហើយក៏គ្មានចំណងសម្ភារៈ ឬ នយោបាយណាមួយជាមួយព្រះសង្ឃទាំងឡាយនៃប្រទេសដទៃ ដែលប្រកាន់តាមបែបហីនយាននោះទេ ។ ព្រះសង្ឃខ្មែរ គឺជាអង្គការសាសនាជាតិ ។ ផ្ទុយពីពួកកាតូលិក, ពុទ្ធសាសនិកជន មិនទទួលស្គាល់មេដឹកនាំកំពូលបរទេសណាមួយ មកលើប្រជាជាតិរបស់គេទាំងឡាយទេ ។

នាយកនៃព្រះសង្ឃខ្មែរ គឺព្រះរាជា ។ ប៉ុន្តែ ព្រះរាជា បើនិយាយអោយចំទៅ ព្រះអង្គពុំមែនជានាយកសាសនាទេ បើគេប្រៀបផ្ទឹមអំណាចទាំងឡាយរបស់ព្រះអង្គ ទៅនឹងអំណាចរបស់ស្ដេចប៉ាប ( Pape ) ជាឧទាហរណ៍ ។ ព្រះរាជា គឺជាអ្នកការពារសាសនាទៅវិញទេ ។ ក្នុងឋានៈជាម្ចាស់ប្រជាជាតិ, ព្រះរាជា គឺជាម្ចាស់នៃមនុស្សទាំងឡាយ ទោះបីចូលសាងផ្នួសហើយ ក៏នៅតែជាមនុស្ស (sujets) របស់ព្រះអង្គតែដដែល ។ ភស្តុតាងអំពីរឿងនេះ គឺថា បើព្រះរាជា

តែងតាំងមន្ត្រីសង្ឃទាំងឡាយ ជាអាទិ៍ គឺព្រះសង្ឃនាយកនៃគណៈទាំងពីរ, ព្រះអង្គមិនអាចធ្វើអន្តរាគមន៍ ដូចស្តេចប៉ាប ទៅក្នុងកិច្ចការសាសនាទេ ដែលទ្រឹស្តីរបស់សាសនា មិនអាចត្រូវកែប្រែបាន ។

## អំពីគណៈទាំងពីរ

ព្រះសង្ឃខ្មែរ ចែកចេញជាពីរគណៈ គឺគណៈមហានិកាយ និង គណៈធម្មយុត្ត ។

គណៈមហានិកាយ(១) គឺជាគណៈទីមួយកើតនៅក្នុងប្រទេសកម្ពុជាហើយកផ្តិជាភាគច្រើនលើសលប់ ។ ក្នុងចំនួនភិក្ខុសង្ឃ ៣៧.៥៤៣ អង្គ ក្នុងព្រះរាជាណាចក្រ, មានភិក្ខុសង្ឃមហានិកាយ ៣៦.០២៦ អង្គ(២) ។

គណៈធម្មយុត្ត ត្រូវបាននាំចូលមកក្នុងប្រទេសកម្ពុជា ក្នុងឆ្នាំ ១៨៦៤ ដោយព្រះសុគន្ធ,(៣) ជាភិក្ខុមួយអង្គ ដែលបានសិក្សានៅទីក្រុងបាងកក ក្នុងវត្តមួយ របស់និកាយនេះ ។

ពួកធម្មយុត្ត(៤) ពោលគឺ « អ្នកទាំងឡាយដែលបានភ្ជាប់ខ្លួនទៅនឹងព្រះធម៌ » មានចំនួនតែ ១.៥២៧ ប៉ុណ្ណោះ ក្នុងប្រទេសកម្ពុជាទាំងមូល, ។ បើតាមពួកអ្នកកាន់តាមគណៈធម្មយុត្តអះអាងថា ពួកធម្មយុត្តមានល្បីឈ្មោះដោយសារការ

---

(១) បាលី : មហា = ធំ, និកាយ = ក្រុម, ពួក, សមាគម

(២) តួលេខផ្តល់អោយដោយក្រសួងធម្មការ (ខេត្តបាត់ដំបង ក៏បានរួមបញ្ចូលក្នុងស្ថិតិនេះដែរ ) ។ នេះជាស្ថិតិក្នុងរង្វង់ឆ្នាំ ១៩៤៩ ។

(៣) សុគន្ធ ( ពាក្យបាលី-សំស្ក្រឹត ) អ្នកមានក្លិនក្រអូប ។

(៤) ធម្មយុត្ត ជាពាក្យផ្សំពីបាលី ធម្ម ( សំ. ធម៌ះ ) « ច្បាប់,ក្រឹត្យក្រម, (សាសនា) » និង បាលី យុត្ត ( សំ. យុក្តះ ) « ប្រកបដោយ, ស្របតាម » ។

គោរពប្រតិបត្តិ, របៀបស្លៀក និងគ្រងស្បង់ចីពរត្រឹមត្រូវ, ភាពតឹងរ៉ឹងក្នុងការកាន់វិន័យរបស់គេ ។ គឺជាគណៈដ៏មានឥទ្ធិពលបំផុតនៅក្នុងវាំង ។ ព្រះរាជា ហើយនិងរាជត្រកូលធំៗ កាន់តាមគណៈធម្មយុត្ត ។ ប៉ុន្តែ, ផ្ទុយទៅនឹងកិត្តិនាមដ៏ធំរបស់ខ្លួន, គណៈនេះ ហាក់ដូចជាពុំបានពង្រីកឥទ្ធិពលរបស់ខ្លួនបានច្រើនទេ តាំងតែពីការបង្កើតមក ។ បច្ចុប្បន្ន មានវត្តទាំងអស់ក្នុងទូទាំងប្រទេសកម្ពុជា រួមទាំងខេត្តបាត់ដំបងផងចំនួន ២.៦៥៣ វត្ត ដែលក្នុងចំនួននេះ មាន ២.៥៦១ វត្ត របស់គណៈមហានិកាយ ។

## ភាពខុសគ្នារវាងនិកាយទាំងពីរ

( Distinction entre les deux sectes )

ពាក្យ « secte » = ( និកាយ ) ដែលគេមានទម្លាប់ប្រើ, ពុំចំន័យទេ, បើតាមខ្ញុំយល់ ។ គួរនិយាយថា « ordre » = (គណៈ) "គណៈ" មហានិកាយ និង"គណៈ"ធម្មយុត្តវិញ, ដូចយើងធ្លាប់និយាយ គណៈដូមីនីកាំង និងគណៈហ្វ្រង់ស៊ីស្កាំង ( ordre des Dominicains et des Franciscains ) ។ ពីព្រោះភាពខុសគ្នារវាងមហានិកាយ និងធម្មយុត្ត មិនប៉ះពាល់លើគោលការណ៍របស់សាសនាទេ, ប៉ុន្តែ ប៉ះពាល់តែលើបែបបទ (la façon) ដែលត្រូវកាន់វិន័យសាសនា ។ គណៈទាំងពីរមានធម៌តែមួយដូចគ្នា មានគម្ពីរតែមួយ ហើយដែលសរសេរជាភាសាបាលី ។ សូម្បីតែរូបភាពខាងក្រៅ, ក៏គណៈទាំងពីរពុំបង្ហាញអោយឃើញនូវអ្វីដែលប្លែកគ្នាដែរ ។ ពីព្រោះ សូម្បីតែស្បង់ចីពរ ក៏ដូចគ្នាដែរ ។ កាលពីជំនាន់ដើម, នៅតាមផ្លូវថ្នល់ គេអាចស្គាល់ថា លោកអង្គនេះធម្មយុត្ត, លោកអង្គនោះមហានិកាយបាន ដោយសាររបៀបគ្រងចីពរ ។ ប៉ុន្តែ សព្វថ្ងៃនេះ គេពុំអាចសំគាល់ថាលោកអង្គនេះជាធម្មយុត្ត ឬជាមហានិកាយបាន តាមរយៈចីពរដែលកាត់ ហើយផ្គុំដោយបំណែកដូចគ្នា មានពណ៌លឿងខ្ចី ឬពណ៌ដី (ពណ៌ក្រាក់ខ្មុរ) ដូចគ្នានោះទេ ។

សញ្ញាសំគាល់ខាងក្រៅតែមួយគត់នោះគឺ របៀបកាន់បាត្រ ពោលគឺ ឆ្នាំងដែលលោកសង្ឃស្ពាយ ឬកាន់ផ្ទាល់ដៃ សម្រាប់សុំចង្ហាន់នៅពេលព្រឹក ។ លោកសង្ឃមហា-និកាយ ស្ពាយបាត្រលើស្មាដោយសារខ្សែ ឬបន្ទះក្រណាត់មួយ, ចំណែកលោកសង្ឃធម្មយុត្ត កាន់ទ្របាត្រដោយដៃ(១) ។ អ្វីដែលងាយកត់សំគាល់បំផុតនោះគឺ ហេតុការណ៍ដែលនិកាយទាំងពីរអានបាលីផ្សេងពីគ្នា ។ លោកសង្ឃមហានិកាយមើលបាលីទៅតាមសូរសព្ទខ្មែរ, ចំណែកឯការសូត្ររបស់លោកសង្ឃធម្មយុត្ត មានសំនៀងជិតទៅនឹងការសូត្ររបស់លោកសង្ឃសិង្ហឡៈ (ស្រីលង្កា) ។

គេគួរតែស្វែងរកហេតុផលនៃការកែទម្រង់នេះ នៅឯស្រុកសៀមឯនោះ

(១) លោក Adhemar Leclère បានហ៊ានរហូតដល់ពោលថា នោះហើយជាការផ្សេងគ្នាទាំងអស់រវាងនិកាយទាំងពីរ ហើយថា ស្ថាបនិកគណៈធម្មយុត្តនៅប្រទេសខ្មែរ បានសំរេចការកែ ទម្រង់របស់ខ្លួនតែត្រឹមធ្វើអោយមានការទ្របាត្រដោយដៃប៉ុណ្ណោះ ។

« មូលហេតុជាដើមចមនៃការកែទម្រង់នេះ, តាមគេនិយាយប្រាប់ខ្ញុំ, គឺថាទម្លាប់ស្ពាយបាត្រលើស្មា គឺជារបស់ពួកព្រាហ្មណ៍ ហើយថាទម្លាប់កាន់បាត្រនៅដៃ គឺមានប្រភពពីព្រះពុទ្ធ ។ អ្នកបួសម្នាក់បាននិយាយប្រាប់ខ្ញុំថា ព្រះពុទ្ធ មុនបានត្រាស់ជាព្រះពុទ្ធ បានស្ពាយបាត្រលើស្មា ដូចតាបសឯទៀតៗ ក្នុងសម័យកាលព្រះអង្គដែរ, ប៉ុន្តែថាព្រះអង្គបានឈប់ស្ពាយបាត្រដូច្នោះ នៅពេលព្រះអង្គបានរកឃើញសច្ចៈទាំងបួន ។ ខ្ញុំមិនដឹងថា តើអ្នកបួសនេះ បានរកឃើញសេចក្តីលំអិតនេះនៅឯណា, ប៉ុន្តែ ខ្ញុំសង្កេតឃើញថា រឿងនេះត្រូវបានអ្នកបួសខ្មែរមួយចំនួនធំចេះដឹង ហើយយករឿងនេះជាហេតុធ្វើការកែទម្រង់បញ្ចូលមកក្នុងស្ថាប័នពុទ្ធសាសនានៅប្រទេសខ្មែរ ដោយលោកសង្ឃមួយអង្គព្រះនាមព្រះសុគន្ធ ។ ក្នុងការនាំយកការកែទម្រង់នេះ ព្រះសុគន្ធប្រហែលជាប្រាថ្នាបង្ខិតទៅជិតព្រះពុទ្ធ ដោយត្រាប់តាមបែបបទកាន់បាត្រ » Loc cit ។

គ្មានអត្ថបទណាមួយតាមខ្ញុំដឹង ឬតាមការដឹងរបស់អ្នកបួសទាំងឡាយ ដែលខ្ញុំបានសួរអាចយកមកបញ្ជាក់សេចក្តីអះអាងនេះបានទេ ។

វិញ ។ នៅសម័យនោះ, យោងតាមកាលប្បវត្តិផ្សេងៗ, ការកាន់ក្រឹត្យវិន័យសាសនា មានភាពធូររលុង, ទំនៀមទម្លាប់លោកសង្ឃ កាន់តែបាត់បង់ពីសច្ចធម៌ដើមរបស់ខ្លួនជារៀងរាល់ថ្ងៃ, ក្បួនខ្នាតវិន័យ, សៀវភៅវិន័យសម្រាប់លោកសង្ឃពុទ្ធសាសនិក ក៏លែងត្រូវបានគេប្រតិបត្តិតាមយ៉ាងម៉ត់ចត់ហើយ ។ ការកែទម្រង់ គឺគ្រាន់តែត្រឡប់មករកការកាន់ក្រឹត្យវិន័យ, មករកសីលធម៌, មករកការប្រតិបត្តិតាមក្បួនច្បាប់ម៉ត់ចត់នោះវិញ ។ ព្រោះហេតុនេះ គេពុំអាចចាត់ទុកព្រះសង្ឃធម្មយុត្ត ថាជានិកាយថ្មីបានទេ ។ គឺជាគណៈធម្មតាមួយរបស់សាសនាមួយដដែល ( Une même Eglise ) ដែលតម្រង់ឆ្ពោះទៅរកការគោរពប្រតិបត្តិសាសនា អោយបរិសុទ្ធជាង, ក៏ដូចគ្នានឹងគណៈផ្សេងៗនៃសាសនាកាតូលិក របស់លោកខាងលិចប្រណាំងប្រជែងគ្នាខាងការប្រតិបត្តិតឹងរ៉ឹង និង ខាងការប្រព្រឹត្តតបះ (Ascétisme) ដូច្នោះ ។ ប៉ុន្តែ ការពង្រីកបានដ៏តិចបំផុត, ដែលនិកាយនេះធ្វើបាននៅស្រុកខ្មែរ, គឺជាភស្តុតាងបញ្ជាក់អោយឃើញនូវភាពគួរដល់កាលស្ដួចស្ដើងណាស់ (Le peu d'opportunité) នៃការកែទម្រង់របស់ព្រះសុគន្ធ សម្រាប់ព្រះសង្ឃខ្មែរ ។

## លោកសង្ឃបុរាណ និង លោកសង្ឃសម័យ

ជម្លោះរវាងលោកសង្ឃដែលគេហៅថា សម័យ និងបុរាណ ដែលបានកើតមានឡើងនៅក្នុងចំណោមគណៈមហានិកាយ បានផ្ទុះឡើងយ៉ាងធ្ងន់ធ្ងរ, ពីព្រោះ, ម្ដងនេះ, ជម្លោះកើតឡើងមកពីការបកស្រាយផ្ទាល់នៃអត្ថបទគម្ពីរ ។

លោកសង្ឃមួយចំនួន បានរៀនចេះដឹងវិទ្យាសាស្ត្ររបស់លោកខាងលិច, ជាពិសេស បានយល់ដឹងទស្សនវិជ្ជាឥណ្ឌា, ហើយដោយឡែក បានចេះដឹងតាមស្នាដៃរបស់អ្នកប្រាជ្ញអឺរ៉ុប ស្ដីពីពុទ្ធសាសនា ។ ការរៀនចេះដឹងចំណេះទាំងនោះបានជាស់អោយព្រះសង្ឃទាំងនោះកើតមានស្មារតីរិះគន់ ហើយជម្រុញអោយលោក

ទាំងនោះ រៀបចំជាថ្មីនូវការយល់ដឹងអំពីធម៌អាថ៌ ។ ព្រះសង្ឃជាអ្នកប្រាជ្ញទាំងនោះ ដែលជុះដាលដោយស្មារតីថ្មី បានទទួលឈ្មោះថា លោកសង្ឃសម័យ (១) ។ ជម្លោះ ដែលនៅពីដើមទីមានលក្ខណៈខ្លាំងក្លា, ហាក់ដូចជាបានស្ងប់ទៅវិញពីមួយថ្ងៃទៅមួយថ្ងៃ ក្នុងលំដាប់ដែលចំនួនលោកសង្ឃជាប់សញ្ញាបត្រសាលាបាលីជាន់ខ្ពស់ កាន់តែកើន ឡើង ។ លោកទាំងនោះ ក៏ក្លាយជាសាស្ត្រាចារ្យ នៅក្នុងសាលាបាលីជាន់ដំបូង មាននៅគ្រប់ខេត្តនាពេលបច្ចុប្បន្ននេះ ។ ដូច្នេះ វិបត្តិនេះហាក់ដូចជាត្រូវរលាយដោយខ្លួនឯង ដោយសារអ្នកបួសបានទទួលការអប់រំយល់ដឹងដូចគ្នា ។

## ឋានានុក្រមបព្វជិត

ព្រះរាជា ជាប្រមុខមួយអង្គគត់ នៃព្រះសង្ឃខ្មែរទាំងមូល ។

និកាយនិមួយៗ ក្នុងបណ្តានិកាយទាំងពីរ មាននាយកផ្ទាល់របស់ខ្លួន ដែលហៅថា សង្ឃនាយក ។ នាយកនៃនិកាយទាំងពីរ មិនចំណុះគ្នាទៅវិញទៅមកទេ, នាយកនិមួយៗ យកព្រះទ័យទុកដាក់តែចំពោះលោកសង្ឃ និងវត្តនៃគណៈរបស់ខ្លួន។

នាយកនៃនិកាយទាំងពីរ ត្រូវបានតែងតាំងឡើងដោយព្រះរាជា ។ ព្រះអង្គបានជ្រើសរើសនាយកទាំងពីរ ក្នុងបណ្តាមន្ត្រីសង្ឃជាន់ខ្ពស់ថ្នាក់ឯកទាំងពីរ ។

មន្ត្រីសង្ឃត្រូវបានចាត់ថ្នាក់ជាបួនក្រុម ហៅថា រាជាគណៈ ។

ការតម្លើងកិត្តិយសដល់ថ្នាក់រាជាគណៈ ត្រូវរក្សាទុកថ្វាយព្រះមហាក្សត្រជាអ្នកសំរេច យោងតាមសេចក្តីស្នើសុំរបស់ព្រះសង្ឃនាយកនៃនិកាយទាំងពីរ និងពីយោបល់របស់រដ្ឋមន្ត្រីក្រសួងធម្មការ ។

---

(១) មានក្រមមួយរបស់ព្រះករុណាជាម្ចាស់ជីវិតតម្កល់លើត្បូង ហាមឃាត់មិនអោយប្រើឈ្មោះ « លោកសង្ឃសម័យ » និង « លោកសង្ឃបុរាណ » ។ ក្រមដដែលនេះ, ដែលធ្វើឡើងក្រោយពីការងាររបស់គណៈកម្មការសិក្សា, បានកំណត់ចំនួនកំណាត់សំពត់សប្រាប់ដេរភ្ជាប់ធ្វើជាចីវរ, ស្បង់ ។

ថ្នាក់រាជាគណៈនីមួយៗ ត្រូវបានជ្រើសរើសយកក្នុងក្រុមបន្ទាប់ខាងក្រោម ។

ដើម្បីអាចតែងតាំងភិក្ខុអង្គណាមួយ អោយមានមុខងារជារាជាគណៈថ្នាក់ចត្វា ដែលជាក្រុមក្រោយគេបាន, ភិក្ខុអង្គនោះ ត្រូវមានអាយុផ្នួសយ៉ាងតិច ២០ វស្សា(១) ។

ការតម្លើងកិត្តិយសទីឋានានុក្រម ត្រូវរក្សាទុកថ្វាយព្រះសង្ឃនាកយកនៃនិកាយសាមីជាអ្នកសម្រេច, ដោយមានសេចក្តីយល់ព្រមពីរដ្ឋមន្ត្រីក្រសួងធម្មការផង ។

## ងារនៃមន្ត្រីសង្ឃ

នៅក្នុងនិកាយនិមួយៗ, ក្រុមនិមួយៗនៃរាជាគណៈ មានចំនួនមន្ត្រីសង្ឃជាកំណត់ ហើយមានងារផ្សេងៗគ្នា ប៉ុន្តែមានឋានៈស្មើគ្នាទៅវិញទៅមក ។

ក្រុមដែលខ្ពស់ជាងគេ ពោលគឺក្រុមមួយ ( ហៅថា ថ្នាក់ឯក ) មានសមាជិកបីរូប សម្រាប់គណៈមហានិកាយ, និងមានតែសមាជិកពីររូបសម្រាប់គណៈធម្មយុត្ត ។

ងាររបស់គណៈទាំងពីររៀងៗខ្លួន មានដូចតទៅនេះ :

| មហានិកាយ | ធម្មយុត្ត |
|---|---|
| ១. ព្រះធម្មលិខិត | ១. ព្រះមង្គលទេពាចារ្យ |
| ២. ព្រះពោធិវង្ស | ២. ព្រះពុទ្ធាចារ្យ |
| ៣. ព្រះវនរ័ត្ន | |

(១) វស្សា = ឆ្នាំបួស ។ មកពីពាក្យបាលីថា វស្សៈ = ភ្លៀង, អាយុផ្នួស ត្រូវបានគិតតាមរដូវភ្លៀង ។

វាជាគណៈនៃក្រុមទីពីរ (ហៅថា ថ្នាក់ទោ) មានចំនួនសមាជិកប្រាំមួយរូប សម្រាប់គណៈមហានិកាយ, និងមានចំនួនសមាជិកបីរូប សម្រាប់គណៈធម្មយុត្ត :

| មហានិកាយ | ធម្មយុត្ត |
|---|---|
| ១. ព្រះមហាវិមលធម្ម | ១. ព្រះមហាព្រហ្មមុនី |
| ២. ព្រះពុទ្ធឃោសាចារ្យ | ២. ព្រះធម្មឧត្តម |
| ៣. ព្រះធម្មឃោសាចារ្យ | ៣. ព្រះអរិយកស្សប |
| ៤. ព្រះឃោសធម្ម | |
| ៥. ព្រះសាសនមុនី | |
| ៦. ព្រះមុនីកោសល | |

វាជាគណៈនៃក្រុមទាំងបី ( ហៅថា ថ្នាក់ត្រី ) មានចំនួនសមាជិកប្រាំមួយរូប សម្រាប់គណៈមហានិកាយ, និងមានសមាជិកបួនរូប សម្រាប់គណៈធម្មយុត្ត :

| មហានិកាយ | ធម្មយុត្ត |
|---|---|
| ១. ព្រះសិរីសម្មតិវង្ស | ១. ព្រះអរិយវង្ស |
| ២. ព្រះពុទ្ធវង្ស | ២. ព្រះញាណវង្សី |
| ៣. ព្រះសាក្យវង្ស | ៣. ព្រះធម្មកវីវង្ស |
| ៤. ព្រះឧបាលិវង្ស | ៤. ព្រះមហាវីរវង្សាចារ្យ |
| ៥. ព្រះញាណវង្ស (ថ្មី) | |
| ៦. ព្រះសុមេធវង្ស (ថ្មី) | |

វាជាគណៈនៃក្រុមទីបួន (ហៅថា ថ្នាក់ចត្វា) មានចំនួនសមាជិកម្ភៃរូប សម្រាប់គណៈមហានិកាយ, និង មានចំនួនសមាជិកដប់ពីររូប សម្រាប់គណៈ

ធម្មយុត្ត (១) :

| មហានិកាយ | ធម្មយុត្ត |
|---|---|
| ១. ព្រះធម្មវិបស្សនា | ១. ព្រះបទុមវង្សា |
| ២. ព្រះសមាធិធម្ម | ២. ព្រះធម្មមុនី |
| ៣. ព្រះញាណកោសល | ៣. ព្រះវជីរមេធា |
| ៤. ព្រះសិរីសង្ឃាមមុនី | ៤. ព្រះអរិយមុនី |
| ៥. ព្រះសិរីវិសុទ្ធិ | ៥. ព្រះទេពមោលី |
| ៦. ព្រះធម្មវង្សា | ៦. ព្រះធម្មត្ថេរ |
| ៧. ព្រះញាណសំវរៈ | ៧. ព្រះអមរាភិរក្ខិត |
| ៨. ព្រះធម្មសំវរៈ | ៨. ព្រះមហារាជធម្ម |
| ៩. ព្រះឥន្ទមុនី | ៩. ព្រះរតនមុនី |
| ១០. ព្រះទេពមុនី | ១០. ព្រះធម្មត្រ័យលោកាចារ្យ |
| ១១. ព្រះវិន័យមុនី | ១១. ព្រះធម្មវរោត្តម |
| ១២. ព្រះទេពសត្ថា | ១២. ព្រះញាណវីរិយៈ |
| ១៣. ព្រះសីលសំវរៈ | |
| ១៤. ព្រះគម្ពីរត្ថេរ | |
| ១៥. ព្រះអរិយមគ្គញាណ | |
| ១៦. ព្រះវិភទ្ទញ្ញាណ | |

(១) នៅក្នុងអត្ថបទរបស់លោក François Martini, លោកពុំបានរៀបរាប់ងារ របស់មន្ត្រីសង្ឃថ្នាក់ចត្វា ទាំងពីរគណៈទេ ដោយលោកយល់ថាពុំចាំបាច់ ។ ខ្ញុំ (ឈ.អ) បានស្រង់យកមករៀបរាប់នូវងារនៃមន្ត្រីសង្ឃថ្នាក់ចត្វា ដើម្បីបំពេញការយល់ដឹងរបស់ របស់លោកអ្នកអាន ។ ឈ . អ

១៧. ព្រះបវរសត្ថា

១៨. ព្រះញាណវិសុទ្ធិវង្ស

១៩. ព្រះធម្មវិសុទ្ធិវង្ស

២០. ព្រះបិដកធម្ម

ឋានានុក្រម, ដ៏ជាឋានៈក្រោមបន្ទាប់នៃឋានៈរបស់ក្រុមក្រោយគេ (ហៅថា ថ្នាក់ចត្វា) នៃរាជាគណៈ មានងារ ហៅថាព្រះគ្រូ, បាឡាត់, វិន័យធម្ម, វិន័យធរ, សមុហ៍, បៃដីកា (ងារសៀម) និងលេខាធិការ ដែលយើងនឹងបញ្ជាក់មុខងារនៅខាងមុខ ។

## សភាសង្ឃ

មានសភាសង្ឃបីប្រភេទ :

I- មានសភាជាន់ខ្ពស់ ឬ ថេរសភាពីរ : ថេរសភាមួយសម្រាប់និកាយនីមួយៗ ហើយឋិតនៅអមសង្ឃនាយកនៃគណៈរៀងៗខ្លួន ។

II- សភាកិរិតមួយ ឬ សាលាគណ : សាលាគណនីមួយៗ ឋិតនៅអមមេគណនីមួយៗ ។

III- សភាកិរិតពីរ ឬសាលាអនុគណ ឋិតនៅអមអនុគណ ។

ថេរសភានីមួយៗ ត្រូវមានប្រធានមួយរូប និង សមាជិកប្រាំបួនរូប សម្រាប់គណៈមហានិកាយ, និងមានសមាជិកប្រាំរូប សម្រាប់គណៈធម្មយុត្ត ។ សភានីមួយៗ មានលេខាធិការមួយរូប និងអនុលេខាធិការមួយរូប ។ សមាជិកនៃសភាទាំងនោះ ត្រូវបានតែងតាំងឡើងដោយព្រះមហាក្សត្រ តាមសេចក្ដីស្នើសុំរបស់ព្រះសង្ឃនាយក និង បន្ទាប់ពីយោបល់របស់រដ្ឋមន្ត្រីក្រសួងធម្មការ ។ សមាជិកទាំងឡាយ ត្រូវបានជ្រើសរើសយកក្នុងចំណោមមន្ត្រីជាន់ខ្ពស់ ។ ប្រធាន ត្រូវជ្រើសរើសយកក្នុងរាជាគណៈថ្នាក់ឯក ។ ចំណែកឯលេខាធិការ ត្រូវជ្រើសយកក្នុងចំណោម

ព្រះភិក្ខុសង្ឃ ទីឋានានុក្រម ។

សភាសង្ឃផ្សេងៗទាំងនោះ ត្រូវចេះដឹងកិច្ចការខាងសាសនាយ៉ាងម៉ត់ចត់ ព្រមទាំងយល់ដឹងអធិករណ៍សាសនា ភ្ជាប់នឹងកិច្ចការខាងអាណាចក្រផង ។

ថេរសភា គឺជាសាលាជាន់ខ្ពស់ខាងសាសនា ដែលមានសមត្ថកិច្ចត្រឹមត្រូវតាមគន្លងច្បាប់ ដើម្បីសម្រេចដោយគ្មានបើកផ្លូវឧទ្ធរណ៍ នូវកិច្ចការទាំងឡាយដែលជាកម្មវត្ថុនៃក្រមដីកា (សេចក្តីសំរេច) របស់សាលាគណ, កាលណាក្រមដីកានេះ ត្រូវបានភាគីណាមួយតវ៉ា ។ ថេរសភា អាចត្រូវបានរដ្ឋមន្ត្រីក្រសួងធម្មការ តាមរយៈព្រះសង្ឃនាយក ប្តឹងអោយជំនុំជម្រះរឿងថ្មីៗបាន ។

សាលាគណទាំងឡាយ បង្កបង្កើតជាសភាក៏រិតទីមួយដែលមានសមត្ថកិច្ចត្រឹមត្រូវតាមគន្លងធម៌ ដើម្បីដោះស្រាយកិច្ចការទាំងឡាយ ដែលជាកម្មវត្ថុនៃក្រមដីកា (សេចក្តីសំរេច) របស់សាលាអនុគណ, កាលណាក្រមដីកានោះត្រូវបានភាគីណាមួយបដិសេធ ឬភាគីណាមួយសើរើប្តឹងសាជាថ្មី ឬក៏មានរឿងថ្មីទៀត ដែលលោកចៅហ្វាយស្រុកបានបញ្ជូនមកសាលាគណដោយផ្ទាល់ ដើម្បីពិនិត្យពិចារណា ។

សាលាអនុគណទាំងឡាយ គឺជាសភាក៏រិតទីពីរ ដែលមានសមត្ថកិច្ចត្រឹមត្រូវតាមគន្លងធម៌ ដើម្បីពិនិត្យដោះស្រាយជាដំបូង, ហើយតាមគំនិតផ្តើមនៃភាគីសាមី ឬគំនិតផ្តើមរបស់ចៅហ្វាយស្រុក, នូវរឿងទាំងឡាយណាដែលបាននិយាយខាងលើ ហើយដែលរឿងទាំងឡាយនោះ បានកើតមានឡើងនៅលើដែនដីរបស់ស្រុក ។

## ការប្តឹងពីលោកសង្ឃអោយតុលាការជំនុំជម្រះ

គេមិនអាចកោះលោកសង្ឃអោយឡើងតុលាការបានទេ ។ គេមិនអាចចោទប្រកាន់លោកសង្ឃនៅមុខតុលាការ ដោយមិនបានផ្សឹកជាមុនទេ ។

ជាគោលការណ៍ ព្រះសង្ឃនាយកដែលជាអ្នកសំរេចផ្សឹកលោកសង្ឃណាមួយ ក្រោយមានសេចក្តីសំរេចរបស់ថេរសភាសាមី ។ ប៉ុន្តែ តាមការជាក់ស្តែងកាលណាមានបព្វជិតណាមួយ ត្រូវបានគេចោទប្រកាន់ថាមានទោសជាបទល្មើសមជ្ឈិមនៃនីតិសាមញ្ញ ដែលចាំបាច់ត្រូវវិនិច្ឆ័យទោសជាបន្ទាន់ទៅមុខតុលាការមានសមត្ថកិច្ច, លោកគ្រូមេគណ ដែលគ្រប់គ្រងលើបព្វជិតនោះ, តាមពាក្យស្នើសុំមានហេតុផលរបស់ចៅហ្វាយខេត្តសាមី, មានសិទ្ធិដើម្បីសំរេច, ប្រសិនបើត្រូវផ្សឹក, និងមានសិទ្ធិដើម្បីដំណើរការផ្សឹកលោកសង្ឃមានទោសនោះ រួចហើយលោកគ្រូមេគណ ត្រូវរាយការណ៍ភ្លាមទៅព្រះសង្ឃនាយកនៃគណៈរបស់ខ្លួន ។

## មេគណ និង អនុគណ

ខេត្តនិមួយៗ ពោលគឺ ខេត្តនិមួយៗនៃព្រះរាជាណាចក្រ, បង្កើតបានជាគណ ដែលដឹកនាំដោយលោកគ្រូមេគណ មានមុខងារទីរាជាគណៈ ។

លោកគ្រូមេគណ ដែលត្រូវឡើងផ្ទាល់មកព្រះសង្ឃនាយក, ត្រូវឋិតក្រោមរដ្ឋអំណាចរបស់ក្រសួងធម្មការ ។ យើងបានឃើញហើយថា លោកគ្រូមេគណ ត្រូវបានសភាក៏រឹតទីមួយ គឺសាលាគណជួយក្នុងការងារ ។ សភានេះ មានសមាជិកបួនរូបគឺ លោកគ្រូមេគណ ជាប្រធាន, លោកគ្រូបាឡាត់គណ, លោកគ្រូវិន័យធរគណ, និងលោកគ្រូសមុហ៍គណ ។

លោកគ្រូអនុគណ ជាប្រមុខនៃស្រុកនិមួយៗ ។ លោកមានងារទីឋានានុក្រម ឋិតនៅក្រោមអំណាចផ្ទាល់របស់មេគណរបស់ខេត្ត ។

លោកគ្រូអនុគណ ត្រូវបានសភាក៏រឹតទីពីរ គឺ សាលាអនុគណ, ជួយក្នុងការងារ ។ សាលាអនុគណៈ មានសមាជិកបីរូបគឺ លោកគ្រូអនុគណ ជាប្រធាន, លោកគ្រូ វិន័យធរ, និងលោកគ្រូសមុហ៍ ។

ចំពោះគណៈធម្មយុត្ត, មិនមានលោកគ្រូអនុគណ និងមិនមានសាលាអនុគណទេ ។ គណៈធម្មយុត្ត មិនតម្រូវអោយមានសាលាគណមួយសម្រាប់ខេត្តនីមួយៗទេ, គឺដោយសារគណៈធម្មយុត្តមានវត្តតិច ។ ក្នុងករណីនេះ, « លោកចៅហ្វាយខេត្តផ្ទាល់ ទទួលបន្ទុកមើលការខុសត្រូវ ឬ, ក្នុងករណីចាំបាច់, ជួយធ្វើអោយមានដំណើរការល្អដល់វត្តអារាមទាំងឡាយរបស់និកាយនេះ » ។

ទីក្រុងភ្នំពេញ បង្កបង្កើតទៅជាគណមួយ សម្រាប់គណៈនីមួយៗ ដោយមានលោកគ្រូមេគណ និងសាលាគណ រៀងៗគណៈ ។ ប៉ុន្តែថា, គណរបស់រដ្ឋធានីមិនមានអនុគណ និងសាលាអនុគណទេ ។

លោកគ្រូមេគណ ត្រូវបានតែងតាំងឡើងតាមសេចក្ដីសម្រេចរបស់ព្រះសង្ឃនាយកនៃគណៈនីមួយៗ ក្រោយពីបានសេចក្ដីយល់ព្រមពីរដ្ឋមន្ត្រីក្រសួងធម្មការ ។ ការតែងតាំងនេះបាននាំអោយមានជាស្វ័យប្រវត្តិ នូវការតម្លើងឋានន្តរសក្តិ ទីរាជាគណៈ ដោយព្រះមហាក្សត្រ ។

ត្រូវបានតែងតាំងដោយព្រះសង្ឃនាយកនៃគណៈនីមួយៗ, ដោយសេចក្ដីយល់ព្រមពីរដ្ឋមន្ត្រីក្រសួងធម្មការ, និងតាមសេចក្ដីស្នើរបស់លោកគ្រូមេគណផងគឺ : បាឡាត់គណ, អនុគណ, វិន័យធរ, សមុហ៍ ។ ក៏ដូចគ្នានេះដែរ សម្រាប់លេខាធិការ របស់សាលាគណ និងអនុលេខាធិការរបស់សាលាអនុគណ ។

## ការគ្រប់គ្រងវត្តអារាម

វត្តអារាមនីមួយៗ ត្រូវបានដឹកនាំដោយលោកគ្រូចៅអធិការមួយអង្គដោយមានលោកគ្រូសូត្រស្តាំ ឬចៅអធិការរង និងលោកគ្រូសូត្រឆ្វេងជួយក្នុងការងារដឹកនាំផង ។ នៅគ្រប់វត្តអារាម មានអាចារ្យម្នាក់ ភេទជាគ្រហស្ថ ដែលមានតួនាទីជាអ្នកសម្របសម្រួលកិច្ចការខាងអាណាចក្រ ។

លោកគ្រូចៅអធិការ ត្រូវបានតែងតាំងឡើងដោយព្រះសង្ឃនាយក នៃគណៈរបស់ខ្លួន តាមសេចក្ដីស្នើសុំរបស់លោកគ្រូអនុគណាសាមី និងបន្ទាប់ពីយោបល់របស់លោកគ្រូមេគណ ហើយនិងសេចក្ដីយល់ព្រមរបស់ចៅហ្វាយខេត្ត ។ សម្រាប់គណៈធម្មយុត្ត, គឺមានតែសេចក្ដីស្នើសុំតែងតាំងរបស់លោកគ្រូមេគណ ជាមួយនឹងសេចក្ដីយល់ព្រមរបស់ចៅហ្វាយខេត្តប៉ុណ្ណោះ ពីព្រោះគណៈធម្មយុត្តពុំមានអនុគណទេ ។

លោកគ្រូចៅអធិការ, ពាក្យសាមញ្ញហៅថាមេវត្ត, គឺជាបុគ្គលថ្នាក់ខ្ពស់បំផុតរបស់វត្ត ។ លោកត្រូវឃ្លាំមើលភិក្ខុ សាមណេរ និងសិស្សានុសិស្ស ដែលរៀនសាលាវត្ត, ដោយសម្របសម្រួលខ្លួនលោកទៅតាមវិន័យសាលា និងទៅតាមច្បាប់លោកីយជាធរមាននាពេលបច្ចុប្បន្ន ។ លោកទទួលបន្ទុកខុសត្រូវលើលោកអាចារ្យដែលគ្រប់គ្រងលើទ្រព្យសម្បត្តិ, សង្ហារិម និងអសង្ហារិមជារបស់វត្ត ។ វាក៏ជាករណីយកិច្ចរបស់មេវត្តផងដែរ ក្នុងការប្រកាន់យករាល់គំនិតផ្ដើមទាំងឡាយសំរាប់ធ្វើឱ្យមានការរីកចំរើនខាងបញ្ញាស្មារតី និងសីលធម៌របស់ភិក្ខុសាមណេរ និងសិស្សានុសិស្ស ។

លោកអាចារ្យប្រចាំវត្ត គឺជាតំណាងរបស់ភិក្ខុ សាមណេរ និងពុទ្ធបរិស័ទចំណុះវត្ត ក្នុងការរក្សាទំនាក់ទំនងជាមួយរដ្ឋអំណាច នៃព្រះរាជាណាចក្រ សម្រាប់កិច្ចការខាងអាណាចក្រ ។

## ការត្រួតពិនិត្យមើលវត្តអារាម

ទោះបីជាត្រូវដាក់អោយឋិតនៅក្រោមរដ្ឋអំណាចរបស់សាលាអនុគណប្រចាំស្រុកសម្រាប់គណៈមហានិកាយ, និងនៅក្រោមអំណាចរបស់សាលាគណ ឬ, បើគ្មានទេ, ក្រោមអំណាចរបស់ថេរសភា សម្រាប់គណៈធម្មយុត្តក៏ដោយ, ក៏វត្ត

អារាមទាំងឡាយក្នុងព្រះរាជាណាចក្រ គង់ត្រូវឋិតនៅក្រោមការត្រួតពិនិត្យរបស់ព្រះសង្ឃចៅអធិការមួយអង្គ ដែលជាប្រតិភូរបស់ព្រះសង្ឃនាយកនៃគណៈនីមួយៗ ។

ចំពោះកិច្ចការនេះ, ក្រមចុះថ្ងៃទី ១១ ខែតុលា ឆ្នាំ១៩៤៦ បានបែងចែកវត្តអារាមទាំងឡាយខាងគណៈមហានិកាយជាប្រាំផ្នែកអធិការកិច្ច :

ផ្នែកទីមួយ មានខេត្តកណ្ដាល, និងខេត្តកំពង់ស្ពឺ ។

ផ្នែកទីពីរ មានខេត្តកំពង់ឆ្នាំង, ពោធិ៍សាត់, កំពង់ធំ និងសៀមរាប ។

ផ្នែកទីបី មានខេត្តព្រៃវែង, និងស្វាយរៀង ។

ផ្នែកទីបួន មានខេត្តកំពង់ចាម, ក្រចេះ និងស្ទឹងត្រែង ។

ផ្នែកទីប្រាំ មានខេត្តកំពត និងតាកែវ ។

វត្តទាំងឡាយខាងគណៈធម្មយុត្ត បង្កបង្កើតបានតែមួយមណ្ឌលអធិការកិច្ចប៉ុណ្ណោះ សម្រាប់ផ្ទៃព្រះរាជាណាចក្រទាំងមូល ។

ព្រះសង្ឃ-អធិការ ត្រូវបានជ្រើសរើសឡើងដោយរដ្ឋមន្ត្រីក្រសួងធម្មការ លើបញ្ជីមួយ មាននាមបេក្ខសមណៈពីរអង្គ សម្រាប់បុស្តិ៍នីមួយៗ ដែលត្រូវបានព្រះសង្ឃនាយកនៃគណៈនីមួយៗ ជ្រើសរើសហើយផ្ដល់មកអោយ, ក្នុងបណ្ដាមន្ត្រីសង្ឃទីរាជាគណៈ ឬទីឋានានុក្រម ដែលមិនមែនជាសមាជិកថេរសភា ។

ព្រះសង្ឃ-អធិការទាំងឡាយចុះធ្វើអធិការកិច្ចនៅរៀងរាល់បួនខែម្ដងក្នុងវត្តនីមួយៗ ឋិតក្នុងសមត្ថកិច្ចរបស់លោក ។ ក្រៅពីការធ្វើអធិការកិច្ចតាមកាលកំណត់, ព្រះសង្ឃ-អធិការទាំងឡាយ អាចត្រូវបានព្រះសង្ឃនាយក នៃគណៈនីមួយៗ ប្រគល់ភារកិច្ចអោយបំពេញបេសកកម្មផ្សេងទៀត ឬអោយចុះធ្វើការអង្កេតផ្នែកសាសនា ។ មុខការរបស់ព្រះសង្ឃ-អធិការទាំងឡាយនោះមាន :

- ត្រួតមើលការអនុវត្តអោយបានល្អ សម្រាប់លោកសង្ឃទាំងអស់នូវ

អត្ថបទបទដ្ឋានទាំងឡាយ និងបទបញ្ញត្តិច្បាប់ទាំងអស់ ដែលផ្សាយចេញពីអាជ្ញាធរសាសនា ឬខាងអាណាចក្រ;

- ធ្វើអោយវត្តអារាមទាំងឡាយចូលរួមចំណែកក្នុងការអភិវឌ្ឍន៍វប្បធម៌ប្រជាប្រិយ៍ និងជួយផ្សព្វផ្សាយពីចំណេះដឹងខាងអនាម័យ;

- ត្រួតមើលការគ្រប់គ្រងវត្តអារាមអោយបានដំណើរការល្អ;

- ត្រួតមើលការគ្រប់គ្រងទ្រព្យគរុភណ្ឌ អោយបានល្អ;

ព្រះសង្ឃ-អធិការ មានសិទ្ធិធ្វើការព្រមានសាមញ្ញ នៅនឹងកន្លែងចំពោះលោកសង្ឃទាំងឡាយណា ដែលប្រព្រឹត្តផ្ទុយពីវិន័យ, ដែលការសង្កេត បែបនេះលោកយល់ថា ជាការណ៍នាំអោយមានប្រយោជន៍ ។

នៅចំពោះមុខការរំលោភបំពានជាក់ស្តែង ឬការប៉ះពាល់ធ្ងន់ធ្ងរដល់ក្រឹត្យវិន័យ, ប្រសិនជាត្រូវធ្វើ, លោកសង្ឃ-អធិការ មានសិទ្ធិប្តឹងសាលាគណ និងសាលាអនុគណអំពីរឿងនេះបាន ។

ក្នុងករណីមានវិវាទស្តីពីការបកស្រាយធម៌អាថ៌ គម្ពីរ ដីកា, ព្រះសង្ឃអធិការ ពុំមានលក្ខណសម្បត្តិ ដើម្បីសំរេចកិច្ចការនេះទេ ។ លោកត្រូវនាំយករឿងវិវាទនេះ មកទូលព្រះសង្ឃនាយក ។

នៅពេលបញ្ចប់អធិការកិច្ច, ព្រះសង្ឃ-អធិការ ត្រូវធ្វើសេចក្តីរាយការណ៍ជាលាយល័ក្សណ៍អក្សរដាក់ប្រគេនព្រះសង្ឃនាយក ដើម្បីលោកបានជ្រាប, ប្រសិនបើសេចក្តីរាយការណ៍នោះ ព្រះសង្ឃនាយកយល់ថាមានប្រយោជន៍ លោកផ្តល់ទៅអោយរដ្ឋមន្ត្រីក្រសួងធម្មការបានជ្រាបផងដែរ ។ នៅក្នុងសេចក្តីរាយការណ៍ព្រះសង្ឃ-អធិការ ត្រូវយកព្រះទ័យទុកដាក់បញ្ជាក់ចំណុចនីមួយៗ ក្នុងបណ្តាចំណុចរៀបរាប់ ខាងក្រោមនេះ :

១. ការពិនិត្យកត់សំគាល់ដែលលោកបានធ្វើ,

២. វិធានការដែលលោកបានចាត់ និងដំបូន្មាន ឬការព្រមាន ដែលនាំអោយលោកត្រូវផ្តល់ ឬត្រូវធ្វើនៅផ្ទាល់ទីកន្លែង,

៣. វិធានការដែលលោកស្នើ ដើម្បីធ្វើអោយបានល្អប្រសើរនូវសភាព-ការណ៍ ដែលលោកបានពិនិត្យឃើញ ។

## សេចក្ដីសន្និដ្ឋាន

ដូចគេធ្លាប់បានឃើញហើយ, ព្រះសង្ឃពុទ្ធសាសនិកនៅប្រទេសខ្មែរ បង្កបង្កើតជាអង្គភាពមួយមានការចាត់តាំងយ៉ាងរឹងមាំ ។ រចនាសម្ពន្ធដ៏រឹងមាំរបស់ព្រះសង្ឃពុទ្ធសាសនិកខ្មែរ, ដែលហាក់ដូចជាជាន់ត្រួតទៅលើរដ្ឋបាលនៃព្រះរាជាណា-ចក្រដូច្នោះ, បានផ្ដល់អោយព្រះសង្ឃពុទ្ធសាសនិកខ្មែរ មានពលានុភាព និងស្វ័រភាពដោយឥតសង្ស័យឡើយ ។ រចនាសម្ពន្ធនេះ បានរួមចំណែកទានយ៉ាងស័ក្តិសិទ្ធិដល់ការរក្សាកិត្យានុភាព និង ឥទ្ធិពលសីលធម៌ និងនយោបាយ ដែលព្រះសង្ឃបានអនុវត្តមកលើប្រជាជនខ្មែរ ។

François Martini (ហ្វ្រង់ស្វា ម៉ារទីនី)

in France-Asie-Numero spécial 37-38

បកប្រែ : **ឈន អៀម**

# ល្បើកអង្គរវត្ត

( តចប់ )

" នេះបទភាគិ "

៤៣៥- ផ្ទាំងម្យ្យសោតនៃ្យ ធ្លាក់ជាព្រីក្សព្រៃ្យ
បរពត្តគោហ៊ា និតនៅវនាស្ថាន
ហោមបូរពាននា្យណា ជាស្ថានព្រះមហា
ឥសៀ្យឯងនៃ្យ ។

៤៣៦- ឬសីនោះណារ ទ្រើសទ្រុងនាម្នា
ព្រះក្រិត្យ៍ថ្លាថ្លៃ មានរិទ្ធិតែជះ
ដបាះក្រាសក្រៃ្យ ស្មឹងស្មាតនោះនៃ្យ
សូតសិលស្វាធ្យាយ ។

៤៣៧- រឹងរឹទ្ធចេស្ដារ លើសលែងអសមហា
ឬស្សីសំមទា្យ ឬស្សីក្រញូក្រាប់
ដូរាបសព្វសា្យ សោតសិងខ្វលខ្វាយ
ចូលមករន្ធា ។

៤៣៨- ផ្ទាំងម្យ្យប្រក់ដួ ធ្លាក់ជាបរពត្ត
សុមេរុឯងណា ធ្លាក់ជាភីមាន
ស្ថានព្រៃព្រឹង្សា ធ្លាក់ជាចូលា
មុនីថ្លាថ្លៃយ ។

៤៣៩- ហៀ្យលោក្យ៍ធ្លាក់ជា សូតារធាតុមហា

រាជជីកាប្រពៃ ភ្នំមយុគន្ធរ
ភ្នំមករវិកនៃ ឥសិន្ធរ ៗ
សុរុស្សសោភាន់ ។

៤៤០. ភ្នំមនិមិន្ធរ វិនន់តក្កបវរ
ភ្នំមអស្សកាន់ រ៉េវៀលស្ថាន័
ភ្នំមសត្តបរិភន់ ស្រមុទ្ធសិងខាន្ធ
ជ្រះជ្រៅមុះហិម្មា ។

៤៤១. ហៀវផ្លាក់ជាភ្នំម ត្រីកូតបន្សំម
រ់ងចាផ្ទារមហា សុមេរុបរពត្ត
ប្រកដ្ឋក្កាត់ណា ហៀវលោក្យផ្លាក់ជា
ស្ថានអរាសោរភត្ត ។

៤៤២. ហៀវលោក្យផ្លាកជា ស្ថានកុំពែងមហា
នរុក់ឧសុប្ត បរវារម្ស្សៗ
ប្រាំមប្អូនជន្តប់ នរុកធំមកុំរុប់
សាមសិបស្ថានណា ។

៤៤៣. នរុកលើហនោះ ពៀនាមហោវឈ្មោះ
ហោវសញ្ជិតមហា នរុកក្រោមនោះ
សោតឈ្មោះនាម្មា ហោវកាលសូត្រមហា
នរុកន្យនៃ ។

៤៤៤. អន្ទាប់នោះណា ហោវសំឃាតមហា
នរុកក្រូព្រៀ អន្ទាប់នោះទោវ
ហោវរោរុព្ភនៃ ម្សនោះនាមហោវ

មហារៅរុព្ធហ្វោ ។

៤៤៥. ម្យ៉ាងនោះអាក្រក់ ហៅវជាប់នរុក
វិបាកកន្លង ម្យ៉ាងហៅវមហាជាប់
ដូវ៉ាបរុបវ៉ង វិបាកក្តាត់ហោង

ពន្លិករអសក្តិ ។

៤៤៦. នរុកម្យ៉ាងនោះ តៅ្យនាមហៅវឈ្មោះ
មហារអវីចី មើលមុក្ខគួរខ្លាច
តុំអាជស្រដ៊្យ ស្ពានទាំងប្រាំមបី

ដុំពូកនោះណារ ។

៤៤៧. នរុកឪសុប្ត៌ ប្រាំម្យ៉ាងដន្តប់
បរិវារផងនៃ្យ នរុកធំម១
បូកផ្សំមផងគ្នា អស់ទាំងនោះណា

មូរ្យសែសិបប្ចូន ។

៤៤៨. សិងជាកុំពែង ឆ្លកឆ្លាះខ្ញាត់ខ្វែង
ថ្កលថ្នាក់ថៃរថ្ចូន ត្រាំមសឹងមូតល្អក់
អាក្រក់អសខ្លួន នរុកពឹងពួន

ច្រាសប្រាលសិងភ្លើង ។

៤៤៩. ឝុរនៃឝ្ងូវឆាប់ នរុកស្ទុត់ស្លាប់
ខ្សិនហៀ្យគេិតឡើង បន្ទារផ្តោវ....
ពេញពាសជាប់ដើង ក្រាស់គ្រៀ្យសិងភ្លើង

វ៉ណាក់អាត្មា ។

៤៥០. បាក្សីត្បាតក្អែក ចរចិកហ្វូរហែក

ជញ្ជែងភោគ្គា ស្លាប់ហៀរសរិញ
អំម្ពេញឈើហផ្សា ផ្លែរន្ធត់ពារះពារ
ប្រកាប់ឆក់អ៊ីវ ។

៤៥១. នរុកខ្លះសោត យំមភូបាលក្រេវក្រោធ
ចាប់ចិកសីរសី ឆ្លូវឆាំងវា្យវាយ
ចាក្ខកាប់ក្រវិយ ដួលដេកដៀវដីវ
ដែកជុំច្រូញច្រាល ។

៤៥២. ឆុរឆែះជាភ្លើង ភោរភាវលេជលឿង
បំម្រាស់ផ្កាប់ផ្ងារ កាលមុនហេតុចិត្រ
ពុំគិតធ្វូនស្រាល ឆោកឆុកបន្ទាល
ដុតសត្វទាំងរស ។

៤៥៣. នរុកម្ប្យនោះនៃ្យ ចុងជើងចុងដៃ្យ
ដុតអន្តាត់ណា ជាក់ច្រូលច្រវាក់
អន្ទាក់កូនា ទ្រូងដែកសោះសារ
ជាល់មាត់នោះផង ។

៤៥៤. នរុកម្ប្យណា ពោះធំមមុះហិមា
អាក្រក់កន្លង ជាប្រែតតេរច្ឆាន
សាមានពេក្យហោង ម្ប្យនោះសោតច៉ង
សក័ខ្ចាប់នឹងគ្មារ ។

៤៥៥. នរុកម្ប្យនោះនៃ្យ ចងជើងច៉ងដៃ្យ
ផ្កាប់ដើមព្រឹក្សា ខ្លះនៅវងក្នុង
ខ្លះឡើងរ៉កា ដែកដើមមុះហិមា

សិងឆែះជាភ្លើង ។

៤៥៦. អ្នកខ្លះថង់រោល ខ្លះឡើងខ្លះចោល
ខ្លះយកក្បាលចុះ ព្រេជនឹងដីរ
ខ្លះដិពាពោះ ភេិជពាំមហែកពោះ
យកហែកខាំមសីៀ ។

៤៥៧. ឯនរុក់ផង ច្រើនពាណិកន្លង
អាណែកដាសដេរ ស្រដៀងពុំយល
ពុំស្គាល់លើ្យហោង ទោះប្រុសស្រៀផង
សឹងមានត្រូព់អង្គ ។

៤៥៨. ផ្ទាំងម្យនោះណា ព្រះកែតុមាលា
មានបុន្យកន្លង គុងលើហាក្រប៉ា
សំដេចឯងហោង ស្តេចម្យរ្យផង
ក្រាបថ្វាយបង្គំ ។

៤៥៩. សិងលាទោវស្រុក រៀបមុន្រ្តីយមុក្ខ
អាណែកថ្កើងថ្កុម តៀយល់សំម្បត្តិ
មហាក្សត្រឱតំម ទីទៃ្យតូចធំម
ថ្កើងក្រៀមុះហិម្មា ។

៤៦០. សឹងជិះគុជ្ជសា ធាធំមឱទា
ហោវហានសោះសា មើលអ្សរេហាពល
សុកលយោធ្ធា កាន់គ្រើងត្រូព់គ្នា
ខែលពារលំពែង ។

៤៦១. ខ្លះពាក់មួកស្បែក ខ្លះពាក់មួកដែក

មាត់ស្វាសំព្វែង ខ្លះកាន់សេលា៉
ធ្នូទួនដងវែង ខ្លះកាន់លំពែង
ត្រៀមមុក្ខ៧ពីរ ។

៤៦២. សឹងពាក់ក្រោះក្រាស់ កាន់គ្រឿងសាហស្ស
អាវុធមុតថ្លា កាន់គ្រឿងអាវុធ
ប្រកិតជាសដេរ មុក្ខមាត់មួមីរ
មួម្ងរសោះសា ។

៤៦៣. មើលឯអរព្ភិរម ទងជ្យើលយុំម
ក្លឹងក្លោះឆាប៉ា បើកបាំងខ្សែព្រៃថ្លៃ
តាំទៃព្រំព្រឹក្សា ជិះសេះជិះលា
ហែរ៧ឆ្នាំមុក្ខ ។

៤៦៤. តន្ត្រីយព្រែស័ង្ខ ភិរីរំគាំង
ពាត្ថឹគងហ្ងរទុក ស្រទ្បៀសំភោ
ពិនពាត់ឮជុក ពលជើងគ៉គុក
គ៉គិកមុះហិម្ហា ។

៤៦៥. ស្តេចខ្លះទ្រងផ្តាក់ ខ្លះស្តាប្យប្រទាក់
ព្រះខាន្តមុតថ្លា ខ្លះទ្រងកោវទាន្ត
លំពែងជ្បា ក្នុងរ្ងូរដា
ខែលជ្យែល្អថ្កើង ។

៤៦៧. លើកទាព្វចេញទោវ មុះមុក្ខសំពោវ
ទ្បៀនពលប្វ្ងសឡើង ពលរំពត់សស្រាក់
តោ្យទាព្វរុងរឿង ស្ងួរសាប្ងូថ្កិមថ្កើង

ពៀសាប់មនុស្សា ។

៤៦៨. រៀអសខ្សត្រៀ ជារាជទេវី
ស្តេចផងនោះណា ស៊ីងពាក់ទិកមាស់
ជាសជារេចនា ប្រដាប់ថ្លៃថ្លា
ល្អរ១ ទីទៃ ។

៤៦៩. ននាដូនារី ស្រស់ស្រេចប្រិមប្រិយ
សក្តិសំមប្រពៃ ហៅ១ទេវី
ខ្សត្រីថ្លាថ្លៃ តាមពៀទាព្វជៀ
ថ្កុំបថ្កើងរាជ្ជា ។

៤៧០. ឆ្ពោះទោវនគរ បូរីប៉ាវ
ខែតខាន្ទ័សេម៉្មា ដៀទីដៀទិស
លំនៅរអាជ្ញា ខ្សែមខ្សាន់ឡៀ
ប៉ីបូរសព្វស្បា ។

៤៧១. រៀផ្តាំងឯលេជ នោះសោតសិងស្តេច
ហោវបួរិពារបញ្ចូឈុប ច្បាំងនិងទូភី
ហោវសត្វគុំរូព្ភ នោះឯងសោតសព្វ
ក្រៀមុក្ខសោតណា ។

" **នេះបធពុំនោល** "

៤៧២. កាលណោះពីស្បនុកានោះន្ទៀ ពាត់ពែងឆាប់ក្រៀ
ក៏កាន់សឹងការខ្មីយឃ្នាត់ ។

៤៧៣. ជាងម្ប្សធ្វើជាប្រសាទ ប្រសើដ្ឋស្អាងស្អាត់

កុំនូវកុំនាប់បីប្រព្យៃ ។

៤៧៤. ទាំងប្រាំមព្រោងព្រៀថ្លាថ្លៃ សិងមានដំឡៃ
ពិចិត្រនៅវេចវេក្ខា ។

៤៧៥. ប្រាសាទនីម្ស្យសោតណា មានទ្វារចេញជា
ប្រាំមពីល១ជាន់ជុំម ។

៤៧៦. ចត្តុរសន្ស្រៃស័សរស្តំម មាលមាសទែងទុំម
ក៏ទ្រងប្រាំមពីលជាន់ជិត ។

៤៧៧. ស័សរទ្រូងម្ស្យមានពាណិ ឆ្លាក់ជាភ្ញីវារ
ត្របកប្បូរទំមដួបវរ ។

៤៧៨. វេច្នាជារូបម៉ករ គ្រុព្វជ្រើងស៉សរ
ក៏ពាន់ក៏ញុំភ្ញីមាស ។

៤៧៩. ក្នុងក្នក់កញ្ចក់ពេញពាស់ តាមតៀផ្ទៃផ្ចាស័
រំលេជរំលុងឆ្លុះឆ្លោរ ។

៤៨០. ច្រាសច្រាលបីរន្ទាលល្ពោរ មាលមាសឆ្អិនឆ្អោរ
ត្រចង់ត្រចះឆើតឆ្ងាយ ។

៤៨១. ត្របកប្បូទំមរីករាយ រៀងរាល់សព្វសាយ
ប្របាកប្រពាន់ទងភ្ញី ។

៤៨២. ក្តារបែនត្រែគ្រែនមាសថ្មី ឆ្លាក់ជាទងភ្ញី
ជាគ្រុធច្ចូលចាប់នាគ៉ា ។

៤៨៣. ហោះទ្រូវត្រែគ្រែនសុវណ្ណា កែកាន់ហាត្ថា
ក្រអើតក្រអួនស្នែរស្និត ។

៤៨៤. រូបនាគហៀហាក្តុំកុំណើត រូបរស់បង្កើត

ក៏ពាននៅរជើងគ្រុធគ្រុឌ ។

៤៨៥. បង់អួចបង់អួមរត្នរៀង សាស្ត្រសព្វជើងទៀន
រ៉ាបច៉ាប់ស្បរ៉ាល់រាវ្យ ។

៤៨៦. ពោធ្យទ្វារប្រាសាទសព្វសា ជាងជាអស្ចារ
ក៏ចាប់នៅរទងភ្ញីវារ ។

៤៨៧. គ្រុឌជ្រុងប្រាសាទរត្នរាវ្យ ឆ្លាក់ច្រើនពាណរិណាស់
ជិះរេកជិរ៉ាស់ភាប់ផង ។

៤៨៨. រូបរាជ្ជសីហ៍ហោះផ្សង ចាប់អិរីត្យ៍ឃ្នង
សំដែងនៅរដែកចេស្តា ។

៤៨៩. កែស្បររាជ្ជសីសោតណា ចេញពីគោហ៊ារ
រកចាប់នៅរគុជ្ជាផង ។

៤៩០. រូបគ្រុធចាប់នាគហោះផ្សង អសសារពើផង
អារំណែករានន្តគុន្នា ។

៤៩១. រូបហង្សចុះចាប់ប្ញជា ទំមទៀវ្ធទិមគ្នា
ប្រចិកប្រចាប់ទងភ្ញី ។

៤៩២. ត្របកប្ញទំមរីកថ្មី រូបសត្វបាក្សី
ក៏សៀវស្លួរទំមភ្ញីទង ។

៤៩៣. រូបសេចសារីកាសោតហោង ទំមទិមផ្អៀងផ្អង
ក៏ចិកន្សៀកែ្សសរផ្ការ ។

៤៩៤. វិរូបបាក្សីផងណា ច្រើនពាណរិភាក្សា
ខ្លះហើរខ្លះទំមលោតលេង ។

៤៩៥. សាស្ត្រសព្វប្រាសាទធំមធេង ជាងនៅរសិងល្បែង

ប្រដាប់វេច្ចណាពីពាណិ ។

៤៩៦. មុក្ខដេចប្រក់លើហយានរាជ ហង្សកែមកាលម្ករ
ក៏ពាំមរត្នក៏ភ្វីមាស ។

៤៩៧. ស្រកីស្រកាស្រស់ស្រេច ភ្វីវារល្បាលេច
ត្របក់ប្វទំមរីករព្យ ។

៤៩៨. ត្រីស្វរកុំព្វលគាងឃ្វាយ មាសមៃនោមឆាព្យ
ប្រតែតត្រជីងដោមដ្វច ។

៤៩៩. កុំព្វលកុំពស់ស្រោងស្រួច ក្នុងក្នក់រាល់រួច
កុំនើងកុំនួចទិកទាល់ ។

៥០០. រូបទេព្ទប្រណំមរៀងរួច ក៏កាន់ក៏ក្វច
ពីពាណិប្វផ្ការផងត្រូព្វ ។

៥០១. ជ្រុងសារព្វើរស្វតស្បាសព្វ ទាំងប្រសាទត្រព្វ
សិង្ហរូបស្រ្បីទេព្វអក្សរ ។

៥០២. កាន់ផ្ការឈ្វកមាសដ្ឋបវរ ទ្រងភស្រ្តាពរ
ក៏ឈរត្រព្វរូបរត្នរាល់ ។

៥០៣. រានបាលត្រព្វទ្វាររុងឆ្នា រៀងរួចទោវទាល់
កុំព្វល់កុំពែងក្រោមក្រៃ្យ ។

៥០៤. ភ្នាក់ដៃរូបនាគសន្ទឹង សង្ហាងឆ្វេងស្តាំម
ឯក្បាលក៏លើកព៉ពារិ ។

៥០៥. វេច្ចណាផ្អៀងផ្អងសោះសា ពៀនោវមាត់ទ្វារ
ប្រសាទប្រសើដ្ឋមុះហិម្មា ។

៥០៦. កែវណារហង្សាហៅរ៉ា កែសៃនល្បៀងភារ

ក៏ឈរជាជួររៀងរាប ។

៥០៧. ប្រែប្រឹងបីសន្ធឹងកេរក្សា មៀងមើលសព្វសារ
ប្រយោជន៍ប្រយាត់គ្រប់គ្នា ។

៥០៨. ទិមទែងមាសម្សៀបីរន្ទា រុងរឿងច្រាសច្រាល
ចំលាក់ចំលៀវស្រស់ស្រេច ។

៥០៩. ច្រូងច្រាងរុងរឿងក្បូរក្បាច់ រូបរាងស្រស់ស្រេច
រំលេចនៅក្បាច់ផ្កើនផ្កោរ ។

៥១០. មានរូបនោះសោតល្ពេញល្ពោរ សព្វតៀបលំនោវ
ឥតខ្វាះចន្លោះលឿណា ។

៥១១. អរិរត្ន័មាសមែចាំមនោរ ស្បាសព្វទ្វារក្រោរ
រំហើតរំហាងរាល់រាប ។

៥១២. ល្អរ១បីត្រចោះឆើតឆាប ផ្កិនផ្កោរព្រោងព្រាប
ពីចិត្រនៅរត្នវេកា ។

៥១៣. ហាក់ដូចភិមានឥន្ទ្រា ចុះចាក់សួរគា
ក៏ស្រុតមកនៅផែនដី ។

៥១៤. ជាងម្សប្រដាប់ខ្លានខ្ជីយ ជារូបបាក្សី
នៅរូបអរិរត្ន័សំមទ្យ ។

៥១៥. សឹងជាងជាហង្សសព្វសារ សត្វផងទាំងឲ្យ
ដៀប្រពាណិទីទ្វៀនា១ ។

៥១៦. យលម្ករបវរថ្លៃថ្លា ហែលលេងលីលា
លលែកន្ទាលជុតរធី ។

៥១៧. ភ្លក់ភ្លោរស្មើស្មាទាំងថ្វី ស្រកាស្រកី

រូបហានិញ្ញាណរូបរស់ ។

៥១៨. វាតវ៉ាទិកខ្ចាយខ្ពងខ្ពស់ អសរអង្គស្រេចស្រស់

ប្រដាប់សឹងមាសច្រាសច្រាល់ ។

៥១៩. រូបនាគលោលើកព៌ារ អរឯងបិត្រអាល

ក៏ហែលលេងលើហជុលសា ។

៥២០. ឃ្លាតខ្លាញបាក់ដេញមេឆា ត្រីផងនានា

វេរានឹងនាគនោះណា ។

៥២១. រូបរាងសីហ៍ហៀវបោះ ប្រែប្រានស្ទាត់ស្ទុះ

ក៏ចាប់អំម្រិត់យុងឃ្មង ។

៥២២. យន្តកែស្បូររាជសីហផង ចរចេញលេងលង

ក៏ហោះកន្តាលនុត្តី ។

៥២៣. ចុះចាប់ទ់ងកែស្បូរភ្វី ចាប់បានចាប់ឥ្យ

រូបហានរូបរសរីស្បៃ ។

៥២៤. ប្រែប្រិងបិសន្ទឹងរិលវៀ នេត្រនោះរំពៀ

ក្រលេកក្រលួងបិសំលុឹង ។

៥២៥. យន្តម្យូធ្វើជារូបហង្ស ឈរឈុប់ប្រែប្រឹង

ក្រឡឹកក្រឡេវនេត្រា ។

៥២៦. យន្តស្មាន់នៅរយន្តល្បៀងភា ពាយុទ្ធនិងគ្នា

កន្តាលនៃអាកាសកង ។

៥២៧. យន្តហង្សរាជរូបឥត់ឆ្គង ចរចេញលេងលង

ក៏ហោះកន្តាលវីហ៊ា ។

៥២៨. វីយន្តតីលេនលីលា ទៀបនឹងម្នោរា

ប្រយុទ្ធកន្តាលនុត្តិ ។

៥២៩. យន្តហង្សក៏សឹងពាំមភ្ញី ទាំងទងវិរកថ្មី
ត្របកបូទំមសុវណ្ណា ។

៥៣០. យន្តគ្រុធឆៀងឆាប់នាគា នាគពាន្ធហត្ថា
សំដែងនោវរិទ្ធិបិពន្លិក ។

៥៣១. រូបខ្លាចាប់អង្គអិរិត្យ ក្រាបក្រោមព្រៃព្រឹក្ស
ក្រលាស់ក្រលាប់បានព្រៃ ។

៥៣២. ហាក់ដូចរូបរសរិស្សៃ សន្ធឹសំមពេត្យព្រៃ
ក៏ស្មោះលោលោតរិលវៃ ។

៥៣៣. រូបគុជ្ជសាស្ទីមស្តៃ គោតគោរព្រេជព្រៃ
ក៏ស្រប់ក្រោមម្លុបរអាថ្ងា ។

៥៣៤. រូបគោរូបគោម៉ហឹង្សា រូបហង្សនានា
អាណែកអាន័ន្តណាស់ន្ទៃ ។

៥៣៥. រូបបាក្សីផងក្រាសព្រៃ ទំមដៀព្រឹក្សព្រៃ
ប្រចិកប្រចាប់ទងភ្ញី ។

៥៣៦. រូបខ្លះសោតលេងដៀជឺ ខ្លះលើកទងភ្ញី
ក៏ទំមលេងលើបាព្រឹក្សា ។

៥៣៧. រូបសឹកនោវរូបសារិកា ទំមទីមខាងគ្នា
ក៏ចិកនៃបូផាផង ។

៥៣៨. រូបកីណរីសោតហោង យាងយាសផ្ទៀងផ្គង
ទាំងគួរបាក្សារេរាំម ។

៥៣៩. កែងកាងយាងយាសបីទន្ទាំម បានបទ់លំនាំម

ជួជាយជួជួរកែងករ ។

៥៤០. ផ្ទៀបនាងទេព្វអក្សរ ទ្រងភស្ត្រាពរ

ក៏កាន់នៃយភ្ញីទាំងទង ។

៥៤១. វេរាំមទន់ភ្លួនលំញង ស្រស់ស្រេចឥតឆ្គង

ស្រឡូតស្រលាះឆោមឆាយ ។

៥៤២. កាលណោះព្រះកែតុមាលា ពិសេសសោភា

ស្តេចឱ្យប្រពាប់សព្វគ្រឿង ។

៥៤៣. ទើបស្តេចឱ្យរៀបប្រពាប់ ប្រាស់ប្រើពលទាព្វ

ឱ្យរៀបនោវគ្រឿងគ្រឿងដៃយ ។

៥៤៤. ល្បើកនេះបូរាណរាជយូរលុង តែតំពីក្នុងនគរវាត់

លើកតាមប្រពាប់បុនវ៏ខ្សត្រ រាជរត្នព្រះកែតុមាលាថ្លៃ ។

៥៤៥.ស្តេចមានបុនវ៏ផ្ទើងប្រសើដ្ឋខ្លង ស្ថិតស្ថានយូវលុងឪដិមព្រៀ

គ្មាន់គៀនិងមកប្រលាំងដៃយ ខ្សត្រថ្លៃស្តេចគុងសុក្ខខ្សែមខ្សាន ។

- ចប់ -

# សេចក្តីរលឹកដាស់តឿន

ពាក្យកាព្យរបស់

ព្រះភិរម្យភាសា អ៊ូ ហៅ ឧ៊ុយ

១. អ្នកព្រះភិរម្យភាសា អ៊ូ លើកដៃទាំងគូប្រណម្យផ្ចង់
បង្គំព្រះពុទ្ធគ្រប់ព្រះអង្គ ព្រះធម៌ព្រះសង្ឃប្រសើរសាយ ។
ព្រះគុណគ្រូឧបជ្ឈាយាចារ្យ មាតាបិតាបង្កើតកាយ
បង្កើតប្រាជ្ញាថ្លាវែងឆ្ងាយ ខ្ញុំសូមអធិប្បាយថែងពាក្យជូន ។
ព្រះពុទ្ធសករាជព្រះសាសនា អតិកន្តាកន្លងធ្ងន
ពីរពាន់បួនរយចិតសិបបួន ជួនខែនិងថ្ងៃគ្មានកន្លង ។
ដើមឆ្នាំមមែក្នុងត្រីស័ក ពិសាខភ្លៀងធ្លាក់កាត់ទឹកម្តង
មួយរោចថ្ងៃសៅរ៍កើតសៅហ្មង ឮពាក្យអ្នកផងទាស់ទែងគ្នា ។
៥. មិនបានកាប់ចាក់ដល់បាក់បែក ថ្ងៃនេះជជែកថ្ងៃស្អែកជា
ចាក់ដោតរាលរោលពោលពណ៌នា និន្ទាដៀលត្មះចាស់បុរាណ ។
*ពួកចាស់ដៀលត្មះអ្នកប្រាជ្ញថ្មី* រឿងធម៌បាលីស្តីប្រមាណ
ប្រមាថទៅមកមិនឈប់ខាន ហាមប្រាមមិនបានមិនបាត់មាត់ ។
ព្រះធម៌ព្រះពុទ្ធតែមួយអង្គ លោកសង្ឃបួសរៀនមានដោយវត្ត
*សង្ឃខ្លះចេះស្ទើរមិនចាំស្ទាត់* *ភ្លើៗ សូត្រភ្លាត់មិនត្រូវខ្យល់ ។*

គេប្រាប់ថាខុសប្រកាន់ខឹង មិនដឹងជាខ្លួនរៀនមិនដល់
មិនដែលសួរគេព្រោះមិនឆ្ងល់ សម្គាល់ថាខ្លួនត្រូវមិនខុស ។
អ្នកប្រាជ្ញលោកស្ទូត្រចំបាលី ថាគេធមិថ្មីស្ដីបន្តុះ
បន្ទោសទៅមកឆ្លើយឆ្លងឈ្លោះ មិនព្រមចំណុះខុសចំណាំ ។
១០. ចំណែកធំណោះចេះរាល់ខ្លួន បារាជិកបួនវិន័យប្រាំ
មហាវគ្គចុល្លវគ្គអាទិកម្ម ព្រះអង្គគ្មានផ្ដាំឱ្យឈ្លោះគ្នា ។
ផ្ដាំឱ្យតែកាន់សិក្ខាបទ អ្នកបួសរាល់វត្តត្រូវសាមគ្គា
ព្រះពុទ្ធរបរាលវិហារ វន្ទាគោរពរាល់យប់ថ្ងៃ ។
នមស្ការបង្គំធមិបីបទ ស្ទូត្រហាហបមាត់នឿយជើងដៃ
មិនដឹងប្រាកដរតនត្រ័យ មិនចេះសង្ស័យសួរអ្នកណា ។
*អ្នកប្រាជ្ញលោកស្ទូត្រចំបាលី ប្រែចេញសេចក្ដីឱ្យពិស្ដារ*
*អ្នកខ្លៅមិនស្ដាប់តាមពុទ្ធដីកា គេថាខ្លួនខុសប្រកាន់ខឹង ។*
ធមិសម្ពុទ្ធស្ទូត្រលាន់ៗ ព្រះពុទ្ធឃពាន់ខ្លះមិនដឹង
ជឿជាក់ថាចេះចប់ប៉ុណ្ណឹង មិនប្រឹងរៀនប្រែបកបរិយាយ ។
១៥ . ចេះហើយមិនដឹងថាខ្លួនខុស មិនព្រមចំណុះអ្នកប្រាជ្ញប្រាយ
បាលីច្រឡំពាក្យនិស្រាយ នឹកស្ដាយបែបចាស់មិនផ្លាស់ចេញ ។
គេថាស្ទូត្រធមិមិនចេះប្រែ បានបុណ្យខ្លះដែរតែមិនពេញ
បើចេះប្រែផងបានចំណេញ ខ្លួនរឹតទន្ទេញតែបែបចាស់ ។
ចចេសទទឹងរឹងជជែក ប្រកឹងប្រកែកប្រកួតម្នះ
ម្នាៗ សត្រូវនឹងធមិព្រះ ជាតិក្រោយក្រឡាស់ជាល្ងង់ខ្លៅ ។
មានកាលត្រឡប់ជាគថ្លង់ មម៉េងមម៉ីងឆ្កួតមួម៉ៅ
ពីព្រោះមិនស្ដាប់ប្រាជ្ញប្រដៅ ហ្នឹងហៅចេះហើយមិនប្រសប់ ។

ប្រសិនបើឱនខ្លួនខ្លបខ្លាច អ្នកប្រាជ្ញកាលណាលោកនឹងស្អប់
ធមិអាចិអ្នកណានឹងចេះចប់ កុំកាន់ទន្លាប់ទម្លោយខ្លួន ។
២០. ទម្លាក់ឱ្យទាបសុភាពវ័យ ព្រះសូត្រវិន័យធំជាងក្បួន
ព្រះអភិធម្មជាម៉ាំមួន ចេះហើយប្រធ្វូនគួររៀនទៀត ។
ពាក្យពីបុរាណជាពាក្យងាយ ពាក្យក្បួនទូលាយស្រណុកជ្រៀត
ឯពាក្យគម្ពីរទីចង្អៀត គួរឆ្ងៀតជ្រើសរកយកឱ្យបាន ។
ឱ្យបែកគំនិតគិតច្រើនផ្លូវ មួយខុសមួយត្រូវជាពីរស្ថាន
គេប្រាប់ថាខុសគួរឈប់ខាន ឃើញត្រូវប៉ុន្មានប្រមូលយក ។
ព្រះឱស្ឋព្រះអង្គទ្រង់ទេសនា អ្នកប្រាជ្ញចែងចារចងទុកមក
ព្រះសូត្រវិន័យលោកលៃលក ប្រែសព្ទសៀតសឹកច្រើនប្រការ ។
ពាក្យពិតប្រាកដបទបាលី ប្រែចេញសេចក្ដីឃើញពិស្ដារ
គួរស្ដាប់ឱ្យស្ដែងសិនសុំថា កុំអាងតម្រាតម្រាប់ចាស់ ។
២៥. តម្រាយបុរាណយូរអង្វែង មិនលែងច្រឡំមានលើសខ្វះ
អ្នកប្រាជ្ញជំនុំឃើញខុសណាស់ ចោលខ្លះទុកខ្លះដោយពិស្ដារ ។
យ៉ាងធមិ " តិរោក" ពីបុរាណ មិនដឹងជាបានពីគ្រូណា
សូត្រលាយចម្រុះខុសអក្ខរា មិនបានជាការប្រយោជន៍អ្វី ។
អ្នកប្រាជ្ញឃើញខុសច្រើនអន្លើ រុះរើរៀបចំផ្សំបាលី
អ្នកខ្លៅហៅធមិតិរោកថ្មី សម្ដីបែបឡកចំអកខឹង ។
សង្ខេបរឿងសូត្រធមិត្រូវខុស កូនចៅប្រុសៗ គួរខំប្រឹង
ប្រឹបរកអ្នកប្រាជ្ញប្រើឱ្យដឹង សម្លឹងអក្ខរាឱ្យប្រាកដ ។
ប្រការមួយទៀតចាស់ជាន់មុន ធ្វើបុណ្យអភិសេកបែកច្រើនបទ
ច្រើនបែបរាប់អានគ្មានកំណត់ សន្មតថាធ្វើតាមបុរាណ ។

៣០. អាចារ្យមួយប៉ែកអភិសេកខ្ទិល បង្វិលពពិលរំពេចបាន
អាចារ្យមួយថាធ្វើតាមដាន លំអានគម្ពីរបឋមត្រាស់ ។
ទេសន៍ទសជាតក៏ចប់អភិសេក ព្រឹកស្អែករៀបចំមធុបាយាស
មានមារលើកពលច្បាំងដេរដាស ធ្វើច្រាសត្រឡប់ក្រោយជាមុន ។
បើធ្វើឱ្យត្រូវតាមសាស្ត្រា នាងនាថសុជាតាគេមានគុណ
ថ្វាយមធុបាយាសព្រះមានបុណ្យ និមន្តទៅផ្សងបីដងត្រាស់ ។
ទេវតាផ្អើលចុះពេញផែនដី គ្រប់ទិសប្រាំបីមីរដេរដាស
កក្រើកញាប់ញ័រទាំងអាកាស អរណាស់ថ្វាយសព្ទសាធុការ ។
ហេតុនេះអ្នកចេះចាំនិទាន ធ្វើរោងធ្វើរានថ្វាយទេវតា
អ្នកប្រាជ្ញចេះថ្មីស្រដីថា អាចារ្យនាំធ្វើខាតប្រយោជន៍ ។
៣៥. អាកាសទេវតានៅស្ថានខ្ពស់ គេខ្ចីមជាតិមនុស្សក្លិនអសោច
ឧស្សាហ៍ដាក់នំឱ្យហិនហោច ចំណោញស្រមោចចោមរោមស៊ី ។
អាចារ្យមួយទៀតចេះរៀបចំ ប្រណម្យសំពះក្រុងពាលី
ព្រះឥសូរព្រះនារាយណ៍មានរឹទ្ធិ ពេញទីចោលព្រៃសរណគមន៍ ។
ចំណីចំណែកចែកដាក់ពៃ ចំណោញបានផ្អែកវាស៊ីនំ
នាងហ៊ីងធរណីថាជាធំ សូមសុំទឹកដីសាងកុសល ។
អាចារ្យជាន់ចាស់ដោះសង្ស័យ ថារតនត្រ័យគេតម្កល់
តម្កើងលើកឡើងជាដើមផល ប្ដឹងដល់ទេវតាជាសាក្សី ។
សសង្ខារិករលើកគុណ ធ្វើបុណ្យអភិសេកព្រះពុទ្ធថ្មី
បូជាភ្ញីផ្កាស្លាបារី គ្រប់ទិសប្រាំបីសឹងឱ្យមាន ។
៤០. អភិសេកព្រះពុទ្ធតាំងកសាង តំណាងព្រះពុទ្ធដ៏ទ្រង់ញាណ
រំលឹកទេវតាជាប្រធាន ប្រាថ្នានិព្វានស្ថានផុតទុក្ខ ។

ថាបើទេវតាខ្ចីមចំណី ស្អប់ស្លាបារីមិនចង់ជក់
បិសាចភ្លើ១មិនលែងភ្លក់ អារក្ខទេវតាមិនលែងសោយ ។
នំនែកចំណីឆ្អែតស្កប់ស្កល់ សេសសល់បានប្រេតគ្នាស៊ីក្រោយ
ស៊ីគ្រាន់រួចរស់ព្រោះគេឱ្យ បានដោយមគ្គផលកុសលដារ ។
លោកសូត្រតិរោកតែរាល់ព្រឹក យំកិញ្ញ៉ីច្រូចទឹកថែមយថា
បញ្ជូនអានិសង្សដល់ជូនតា ប្រាថ្នាដូចម្ដេចក៏សឹងបាន ។
ក្រែងជូនតាណាទៅជាប្រេត ឬមួយអណ្ដែតជាតិរច្ឆាន
លើសខ្វះប៉ុណ្ណោះខុសប៉ុន្មាន រាប់អានទេវតាប្រាថ្នាសុខ ។
៤៥. ថាបើទេវតាមិនព្រមសោយ កុំឱ្យតែខុសចុះនរក
នរូកើតភាន់ផុងក្នុងភក់ វិវក់ក្នុងវាលវដ្ដសង្សារ ។
មិនដាច់សង្ស័យដូចអរហត្ត លោកកាត់កាមគុណនិងតណ្ហា
ត្រង់ភ្លឹងមិនឯាកពឹងទេវតា ប្រាថ្នានិព្វានគ្មានត្រឡប់ ។
ឃើញផ្លូវមិនផុតភពទាំងបី ធម៌អាថិបាលីចេះមិនចប់
មិនចោលសីល៥ កម្មបថ១០ វាវរៀបឱ្យសព្វកុំឱ្យសល់ ។
សម្បត្តិសួគ៌សុខកើតពីទាន ឈោងយកនិព្វានឈានមិនដល់
មិនដើរហួសសោតាមគ្គផល តម្កល់និព្វានទុកដោយឡែក ។
នេះចប់ចម្លើយអ្នកប្រាជ្ញចាស់ ប្រាជ្ញថ្មីចង់ឈ្នះប្រឹងប្រកែក
ប្រាកដនិព្វានជាស្ថានឯក ចំណែកសោតាក្នុងតែបាន ។
៥០. ជ្រះថ្លាធ្វើបុណ្យក៏ធ្វើចុះ ទានណាខាតខុសត្រូវឱ្យខាន
អារុក្ខអារក្ខកុំរាប់អាន ជាស្ថានទាបថោករកធ្វើអ្វី ។
សង្ខេបរឿងសូត្រធម៌ត្រូវខុស កូនចៅស្ដាប់ចុះទាំងប្រុសស្រី
អ្នកប្រាជ្ញពួកចាស់នឹងពួកថ្មី គប្បីចូលចិត្តជឿពួកណា ។

បើរឿងសូត្រធម៌អាថ៌បាលី គួរចូលប្រាជ្ញថ្មីខំសិក្សា
ប្រយោគប្រធានមានមាត្រា រាជការបានធីប្រឡងជាប់ ។
ប្រាជ្ញចាស់ជាន់មុនធ្វើបុណ្យទាន ធ្វើរានទេវតាដោយសារធ្លាប់
អ្នកឆោតល្ងង់ខ្លៅគ្នាខ្លាចងាប់ អាចារ្យបង្គាប់គ្នាធ្វើទៅ ។
បើបែរជាខានមិនបានខុស មិនបាបធ្លាក់ចុះនរកជ្រៅ
បើធ្វើទេវតាមិនជ្រកនៅ ស្ពានគេសន្ទៅសន្ធឹងហោះ ។
៥៥. ហេតុនេះគួរគិតគួររំពឹង ជញ្ជឹងកុំឱ្យសល់ចន្លោះ
ចាស់មុនមានគុណរាប់មិនអស់ មិនឱ្យចោលសោះក៏មិនបាន ។
គួរគិតឱ្យគ្រប់សព្វអន្លើ គួរធ្វើឬគួរបង្អង់ខាន
បើធ្វើមិនខាតបង់ប៉ុន្មាន បើខានក៏គ្មានទោសទាស់អ្វី ។
ប៉ុន្តែមិនបាត់ពាក្យចាក់ដោត ដ្បិតមនុស្សច្រើនឆោតទាំងប្រុសស្រី
ពោលថាធ្វើបុណ្យតាមប្រាជ្ញថ្មី អាយុថយខ្លីជាងដូនតា ។
ពាក្យនេះសង្ខេបស្លេះមួយប៉ែក មានឈ្មោះប្រកែកច្រើនប្រការ
មិនចំប្រាកដគម្ពីរណា ពោលថាទឹកដីនេះគ្មានគុណ ។
អ្នកប្រាជ្ញនាំឱ្យអ្នកខ្លៅឆ្ងល់ សាយសុសសួរដល់ពួកអ្នកមុន
អ្នកមួយរេរារង់រែកពុន មិនទាន់ចូលស៊ុនសិបម្នាង១ ។
៦០. អ្នកក្រោយបណ្តោយសួរអ្នកមុន ថាដីមានគុណប៉ុន្មានយ៉ាង
សម្គាល់គោលអ្វីជាតឹកតាង មានអាងឃើញក្នុងគម្ពីរណា ។
អ្នកម្នាងថាអាងនគរកាយ បរមត្ថអធិប្បាយក្នុងសាស្ត្រា
ធាតុទឹកតួ .ន. អង្គអក្ខរា ជាគុណមាតាពីរដណ្តប់ ។
ធាតុទឹករំលឹកពី . សេម្ហ៍ រំកិយកនិ.រហូតចប់
ធាតុដី . កេសាទំសំសព្វ បញ្ចប់ . បិត្តិគុណបិតា ។

អ្នកចេះបិដកឆ្លើយបីដង ថានោះជាកងពួក . កេសា
ហៅធមិអាចម៍នោមក៏ល្មើមល្មោ អ្នកណារំលឹកគ្មានប្រយោជន៍ ។
អ្នកមួយថាភាវនាកុំឈប់ ជាទីអសុភផ្លូវអសោច
អសារឥតការស្លាប់ជាខ្មោច គេដុតឆេះខ្មោចគ្មានខ្លឹមសារ ។
៦៥. គួរគិតកុំស្ដាយកុំស្រណោះ រូបរាងទាំងអស់ជាអនិច្ចា
អនិច្ចំមិនទៀងល្អៀងសង្ខារ សង្ស័យរូបានេះមិនបាន ។
សរសៃសាច់ស្បែកសង្វេគគ្រប់ ជាសាកអសុភកម្មដ្ឋាន
របស់ខាងក្នុងទាំងប៉ុន្មាន មុខជាមិនខានរលាយបាត់ ។
ទឹកដីខាងក្រៅក៏មានគុណ ព្រោះដីកើតមុនទើបកើតសត្វ
កើតសត្វរូបកាយអធិប្បាយកាត់ លើកឡាត់លះឃ្លាឱ្យយ៉ាងខ្លី ។
គម្ពីរត្រៃភេទដើមសាសនា ត្រៃយុតត្រៃតាគ្រប់ជាបី
ព្រះពុទ្ធចេញសាងអាងទឹកដី សន្សំបារមីក្នុងភទ្ទកប្ប ។
ភទ្ទកប្បនេះមានព្រះពុទ្ធ ៥ បានរៀនចេះចាំជាសណ្ដាប់
សម្ដែងថាចុះនរកមួយកប្ប លោកប្រាប់ថាព្រោះជេរទឹកដី ។
៧០. អ្នកម្ខាងថាអាងរៀនសាស្ត្រា ប្រែអស់គាថាបទបាលី
ព្រះពុទ្ធទតគ្រប់ភពទាំងបី ត្រង់គុណទឹកដីមិនឃើញមាន ។
កេសាអក្ខរាទាំង ៥ តួ មិនគួរបើយកមកសន្និដ្ឋាន
យើងចេះដឹងដែរតែមិនហ៊ាន ដូចពោលបំពានហួសពុទ្ធដីកា ។
ពាក្យនេះអ្នកខ្លៅកើតសង្ស័យ សព្វថ្ងៃនៅក្នុងឧបេក្ខា
មិនទាន់ដាច់ស្រេចទៅខាងណា មិនឃើញពិស្ដារស្ដាប់មិនបាន ។
ម្យ៉ាងទៀតប្រាជ្ញថ្មីស្ដីដៀលត្មះ ចង្ហាន់ថ្វាយព្រះថាឱ្យខាន
ដ្បិតព្រះមិនឆាន់នៅពេញចាន របស់ប៉ុន្មានបានអាចារ្យ ។

របៀបរាប់បាត្រមានកន្ទោង មួយឈោងពីរឈោងហៅបាយដារ
បាយដាក់ហ្នឹងតើឱ្យអ្នកណា អសារឥតការឥតប្រយោជន៍ ។
៧៩. អ្នកម្នាងថាអាងដាក់ឱ្យប្រេត ដោយហេតុគ្នាឃ្លានគ្នាហិនហោច
គ្នាស៊ីខ្ទុះឈាមក្លិនអសោច បិចបោចចែកទានគ្នាស៊ីផង ។
ប្រេតត្រូវជាញាតិធមិតិរោក គ្នាបានងើបមកព្រោះគេផ្សង
បានស៊ីដោយសារដារម្ដងៗ បានដូចបំណងបំណាច់នឹក ។
ចង្ហាន់ថ្វាយព្រះត្រូវបូជា អាចារ្យវន្ទាសូត្ររំលឹក
ព្រះពុទ្ធមានគុណមុនលោកភិក្ខុ បាយទឹកជាទានមានមគ្គផល ។
ព្រះពុទ្ធមិនឆាន់មិនចេះស៊ី យើងអាងបាលីឧទ្ទិសដល់
តម្កើងចង្ហាន់លើកតម្កល់ សេសសល់ប្រគេននេនសាមណេរ ។
សមណៈបួសរៀនមានសីល ១០ ប្រសប់ប្រសើរគ្រាន់បើដែរ
បញ្ជូនមគ្គផលដល់ឪម៉ែ បង្វែរឧទ្ទិសតាមប្រាថ្នា ។
៨០. អ្នករេគំនិតគិតតែកាញ់ ចូលបទកំណាញ់ក្រៅតម្រា
ទុកស៊ីមាត់ឯងឆ្ងាញ់ពីសា ខ្លាចបានអាចារ្យស៊ីខាតទុន ។
ម្យ៉ាងទៀតប្រាជ្ញថ្មីស្រដីផ្ដាច់ ថាពូនភ្នំខ្សាច់មិនបានបុណ្យ
ជីកដីល្បៀនភ្នែកវែកតត្រុន ដឹងបានជាគុណប្រយោជន៍អ្វី ។
នាំគ្នាអុជធូបហែទក្សិណ អាចារ្យនោះឆ្អិនខាងបាលី
ហើយមានចេះធមិបំបួសដី មិនដឹងជាដីឆ្លើយថាម្ដេច ។
អ្នកមួយថាពូនភ្នំខ្សាច់ស្អាង តំណាងចេតិយព្រះសរពេជ្ញ
ព្រះសារីរិកធាតុយើងមិនភ្លេច ដ្បិតបុណ្យយើងតិចទៅមិនដល់ ។
បើធ្វើដោយវាលកណ្ដាលថ្ងៃ គង់ជាប់និស្ស័យបានកុសល
បើដើមពោធិ៍ពិតរីតបានផល តម្កល់ដើមពោធិ៍យកជាម្លប់ ។

៨៥. ពូនភ្នំតម្កើងពោធិព្រឹក្ស រលឹកដល់អង្គព្រះចមភព
ច្រះក្តារ ៤ ផ្ទាំងបង្ខាំងផ្ទប់ កុំឱ្យកំពប់ហៀរហូរដី ។
បើចេះរំលឹកបានបុណ្យណាស់ ជឿចុះប្រាជ្ញចាស់កុំជឿថ្មី
ប្រាជ្ញចាស់ក៏ចេះប្រែបាលី បរលោកលោកិយ៍ក៏ចាស់ដឹង ។
ចាស់ម្យ៉ាងចាស់ពិតគំនិតពាល ចាក់ដោតរោលរាលនាំក្មេងខឹង
ចាស់ម្យ៉ាងផឹកស្រាក្លាស្រវឹង ចាស់ហ្នឹងហៅក្មេងក៏សឹងបាន ។
ចាស់ជាន់ពីមុនច្រើនខ្លាចច្បាប់ ធ្វើតាមតម្រាប់ចាស់បុរាណ
បុរិនគរធ្លាប់រាប់អាន តែខានខ្លាចខុសក្បួនតម្រា ។
ច្រើនជឿតម្រាប់ក្បួនលោកិយ៍ មានកូនប្រុសស្រីត្រូវរៀបការ
សម្លាប់ជ្រូកមាន់ស៊ីហ៊ឺហា ផឹកស្រាលៀងវិភ្នែកជដែកឈ្លោះ ។
៩០. បណ្តោយឱ្យយកគ្មានទេ មេបាធ្វើគេក្រែងមិនរស់
នាំកូនសែនខ្មោចអសោចិ៍ឈ្មោះ ពីព្រោះមានប្តីមិនរៀបការ ។
រៀបកិច្ចមង្គលមានច្រើនយ៉ាង ពួកចាស់ច្រើនអាងក្បួនតម្រា
បើតាមតម្រាយព្រះសូត្រថា មេបានាំកូនចុះនរក ។
បុត្តទារស្សសង្គហោ ហើនោគាមោធមិរអ្នកស្រុក
សង្គ្រោះកូនផុងទៅក្នុងភក់ ហ្នឹងហៅអាពុកពន្លិចកូន ។
បើធ្វើមង្គលឱ្យរួចបាប រួចពៀរជរាបអស់តាដូន
មង្គលយ៉ាងល្អបរិសុទ្ធសូន្យ ប្រមូលបងប្អូនស៊ីម្ហូបស្លា ។
ជ្រូកមាន់កុំចាំបាច់សម្លាប់ តែសាកមានស្រាប់ទិញពីផ្សារ
ផ្សំកូនប្រុសស្រីគាល់មេបា អាចារ្យប្រមូលអស់ចាស់ទុំ ។
៩៥. ប្រុសស្រីអង្គុយកាន់ពពិល បង្វិលប្រាំបួនដណ្តប់ជុំ
ធ្វើកិច្ចមង្គលក្នុងជំនុំ ផ្សំផ្គុំកូនប្រុសនឹងកូនស្រី ។

ចាស់ៗ ធ្វើច្រើនធ្វើក្នុងឆោត ចង់ឱ្យគេកោតនាលោកិយ៍
យើងធ្វើយ៉ាងតិចក្រឡេចខ្លី បានប្ដីប្រពន្ធដូចៗ គ្នា ។
ហៅកូនសង្គ្រោះម្ដាយអាពុក រួចទោសរួចទុក្ខអស់មីងមា
អាពុកសង្គ្រោះគ្មានវេរា អាវាហវិវាហមង្គល ។
មិនគួរបង្គាប់ឱ្យកោរជុក ហេតុម្ដាយអាពុកនាំរវល់
អាចារ្យតែងក្បួនឱ្យអំពល់ ពន្យល់អ្នកល្ងង់ឱ្យបង់ទ្រព្យ ។
អ្នកខ្ជិលគេជឿសីលមាំមួន ពាក្យក្បួនតម្រាគេមិនរាប់
គេថាមិនរស់ពីព្រោះធ្លាប់ មិនស្លាប់ពីព្រោះមិនធ្វើធ្មេញ ។
១០០.យ៉ាងដូចចិនយួននៅជាក់ផ្សារ ស្រុកស្រែចំការក្រុងភ្នំពេញ
កើតឡើងដុះសក់មិនកោរវិញ រវល់ដូរទិញអង្គុយលក់ ។
ប៉ុន្តែជាតិចិនល្មោភស៊ីសាច់ តមដាច់មិនដែលស៊ីព្រហក់
ខ្មែរៗ ប្រហែលខ្វះម្ទេសជ្រក់ ទូលស្រូវកន្ទក់ទៅដូរចិន ។
ហេតុតែជាខ្មែរសម្បុរខ្មៅ គំនិតគិតឆៅមិនស្ងួវឆ្អិន
រកស៊ីមិនឆ្អែតជឿថៃសិន អាចិកវាកិនទារទាល់បាន ។
១ កើតអស្សុជសម្លាប់មាន់ ចំអិនគ្រប់គ្រាន់ដួសដាក់ចាន
រៀបសែនព្រះភូមិតាមបុរាណ ថាខានខុសក្បួនប្រពៃណី ។
ហ្នឹងហៅចាស់ឆោតនាំក្មេងព្រើល ហែកមាត់មាន់មើលចង្កាពីរ
អាដែងព្រះភូមិមានឈ្មោលញី ថាសែនរកស៊ីបានផលស្រូវ ។
១០៥.មានជូនដូនតាទៅស្រុកប្រេត បណ្ដែតសំប៉ានច្រានសំពៅ
សំពះអារក្ខជួរខាងឪ ខាងម៉ែក៏ត្រូវមិនសូវខុស ។
ថ្វាយចេកថ្វាយស្រាជារង្វាន់ ខ្មោចចូលជិះជាន់រូបស្រីប្រុស
កូនចៅអើយជឿពុទ្ធដីកាចុះ រូបស្លាប់ពីព្រោះតែផលកម្ម ។

រូបសុខដោយសារតែផលបុណ្យ កាលជាតិពីមុនខ្ជាប់សីល ៥
ជាតិនេះអាយុអង្វែងឆ្នាំ កូនចៅអ្នកចាំជឿឱ្យជាក់ ។
ឱ្យចេះពិចារណាចិត្តឯងផង ស្តាប់ធម៌ម្តងៗ គួរឱ្យភ្ញាក់
កុំផ្ញើរូបកាយនឹងអារក្ខ ក្រែងធ្លាក់ទៅក្នុងចតុរាបាយ ។
បើចង់អាយុវែងយឺនយូរ គោរពគុណាគ្រូអាពុកម្តាយ
បើចង់រកស៊ីសុខសប្បាយ ផ្ញើកាយនឹងគុណរតនត្រ័យ ។
១១០. នមស្ការបង្គំពេលល្ងាចព្រឹក ភាវនារំលឹករាល់យប់ថ្ងៃ
កុំថាធម៌ណាថោកណាថ្លៃ សង្ស័យត្រូវសួររាជបណ្ឌិត្យ ។
*កុំឱ្យមន្ទិលធម៌ថ្មីចាស់ មួយធម៌ក្រដាស់មួយស្លឹករឹត*
*រាជការជំនុំរួមគំនិត រិះគិតតម្កើងព្រះសាសនា ។*
តម្កល់សីល ៥ សីល ៨ ឱ្យមនុស្សប្រុសស្រីរួមរក្សា
ផ្ទាត់ផ្ទៀងខ្លាចល្អៀងព្រះពុទ្ធដីកា ពិនិត្យអក្ខរាយកត្រឹមត្រូវ ។
ជំនុំបោះពុម្ពដាក់ក្រដាស ជាការរហ័សធ្វើសៀវភៅ
ឱ្យមានសូត្ររៀនច្រើនតទៅ ទុកនៅជាកេរ្តិ៍អង្វែងឆ្ងាយ ។
*សព្វថ្ងៃអ្នកខ្លៅស្អប់អ្នកប្រាជ្ញ ពោលខ្លាំងគិតខ្លាចព្នុសសាយ*
*ថាធម៌សៀវភៅធម៌ក្លែងក្លាយ អធិប្បាយខ្សឹបៗ តែគ្នាឯង ។*
១១៥. ឱ្យស្ទៀមពីថ្ងៃនេះតទៅ ឯធម៌សៀវភៅផែនដីតែង
មិនមែនអ្នកប្រាជ្ញណាប៉ានក្លែង ខ្លាចក្រែងរាជការចាប់ដាក់គុក ។
គម្ពីរស្លឹករឹតជាគំរូ តម្កល់ក្នុងទូចាក់សោរទុក។
គម្ពីរសៀវភៅប្រើគ្រប់មុខ ទំនុកបម្រុងក្នុងសាសនា ។
ចាស់ៗ ជាន់មុនមានគំនិត គម្ពីរស្លឹករឹតជួលគេចារ
ពុំនោះជាវគេដោយជ្រះថ្លា ច្រើនមានប្រាជ្ញាតិចអ្នកចេះ ។

សង្ខេបបទបែបរឿងប្រដៅ ទូន្មានអ្នកខ្លៅឈប់ទុកស្នេះ
*សុំក្រើនអ្នកប្រាជ្ញមានតម្រេះ កុំតិះដៀលត្មះចាស់ជាន់មុន ។*
*កុំថាចាស់ល្ងីតល្ងង់ល្ងីល្ងើ ក្រែងពារទៅលើអ្នកមានគុណ*
*កុំពោលថាចាស់ថយថោកធុន ក្រែងស៊ុនទៅលើគ្រូអាគ្នា ។*
១២០.ដ្បិតសិស្សនឹងគ្រូមិនអ្នកក្រៅ ជាក្មួយជាចៅជាជីតា
ជាសាច់ខាងមាតា ឬ បិតា ព្រះកម្មវាចាចារ្យខ្លះជាបង
ខ្លះត្រូវជាធំខ្លះជាមា ជាគ្រូឧបជ្ឈាយ៍បំបួសផង
ប្រដៅសព្វថ្ងៃវាយម្តងៗ ព្រោះលោកបំណាងចង់ឱ្យចេះ ។
ដល់ខ្លួនរៀនចាំជាក់បាលី ឡើងពាក្យសម្តីអាងតម្រេះ
តម្រូវខាងណោះខុសខាងណេះ ដៀលតិះថាគ្រូខ្លួនខ្លៅល្ងង់ ។
លោកគ្រូមិនដឹងប្រឹងតែអរ ខំផ្ញើអង្ករបាវការុង
ស្ករក្អមស្ករស្រោក់លោក់មិនគង់ ចង់ថ្កើងពូជពង្សល្បីកេរ្តិ៍ឈ្មោះ ។
ខ្លួនចេះបន្តិចកំប៉ិចឡើង ចចើងចចេសជជែកឈ្លោះ
ចេះកប់ពពកយកកំពស់ បន្ទុះបន្ទន់គុណទាបទៅ ។
១២៥.បើចិត្តចង់ធំកុំចចើង គួរលើកតម្កើងគុណទុកនៅ
ទោសនោះធ្លាក់ចុះនរកជ្រៅ ម្នៅៗ ឱ្យបាបពីព្រោះមាត់ ។
ព្រោះមាននិទានពុទ្ធឃោសា អាងចេះសាស្ត្រាគម្ពីរស្ទាត់
ថាចេះលើសគ្រូ ៧ បំភ្លាត់ បំប្លែងកំចាត់ឱ្យទណ្ឌកម្ម ។
ប្រដូចនិទានតែប៉ុណ្ណេះ អស់លោកក៏ចេះបានរៀនចាំ
ផ្តួចផ្តើម ១ ឃ្លាជាពាក្យផ្តាំ ដូចមានចំណាំចំណោទជូន ។
ទំនុកបុរាណមានប្រាជ្ញា ចេះថែងបញ្ហាសាស្ត្រាក្បួន
ទុកឱ្យអ្នកក្រោយដោះសំនួន បើគិតឱ្យមួនគួរមានភ័យ ។

ចំណោទថាសត្វបរោខោ អង្គុយមែកពោធិ៍ស៊ីផ្លែជ្រៃ
បុរសខុសជ្រុលគ្មានលក់ថ្លៃ បង់គោក្របីទាំងមេកូន ។
១៣០.បុរសម្នាក់ទៀតឡើងដើមឈើ បេះផ្លែខាងលើចែកបងប្អូន
ស៊ីផ្អែតបន្តិចភ្លេចគល់សូន្យ បុរសម្នាក់បានកូនភ្លេចគុណម្តាយ ។
ចំណោទពីរបីចំណែកនេះ គួររិះឱ្យជិតកុំគិតឆ្ងាយ
កុំឆ្ងល់នឹងពាក្យពោលអធិប្បាយ ប្រឹងគិតដោះស្រាយប្រាជ្ញាស្រាប់ ។
និយាយដើមគ្រូដោយកំបាំង មានខ្សឹបមានខ្លាំងពោលបង្អាប់
បង្អើលឱ្យអ្នកដទៃស្តាប់ បង្អន់ដូចកាប់គាស់ឫសគល់ ។
ស៊ីផ្លែឆ្ងាញ់ផ្អែមតាមទុំខ្ចី ឫសលិចក្នុងដីមើលមិនយល់
មិនយកជីចាក់កប់គុណទល់ អំពល់ឱ្យបាបអំពីមាត់ ។
ពីមុនកាលកើតមានរូបកាយ អ្នកម្តាយចិញ្ចឹមបានធំធាត់
នាំយកទៅទុកឱ្យនៅវត្ត រៀនចេះចាំស្ទាត់បំភ្លេចគុណ ។
១៣៥.ភ្លេចគោក្របីទាំងមេកូន សាបសូន្យកុសលដែលសាងមុន
សាងក្រោយសាងឱ្យតែខាតទុន ពីព្រោះបាបស៊ុនស៊ីយពីចិត្ត ។
ពិចារណាគួរតែកោតខ្លាច ខ្លួនបានជាប្រាជ្ញព្រោះគ្រូប្រិត
ប្រឹងប្រៀនប្រដៅច្បាប់ក្រមក្រិត្យ អាណិតដល់គុណធ្ងន់អនេក ។
អនាគតកាលទៅខាងមុខ ចូរចងចាំទុកដល់ស្អែកៗ
កុំស្អប់ចាស់ថ្មីស្តីដោយឡែក មើលចែកចាត់ចិត្តថ្លឹងឱ្យស្មើ ។
ធ្វើបុណ្យឱ្យស្មោះកុំរើសស្ម័គ្រ បាលីបីថ្នាក់ចាំហើយតើ
មនោសេដ្ឋីចិត្តប្រសើរ ប្រសប់គ្រាន់បើធ្វើបុណ្យបាន ។
ប្រាជ្ញថ្មីធ្វើតិចធ្វើតាមចុះ កុំថាគេខុសហើយឈប់ខាន
ប្រាជ្ញចាស់ធ្វើច្រើនតាមបុរាណ ច្រើនលើសប៉ុន្មានបានដោយបទ ។

១៤០-កុំធ្វើដោយរាប់អានស្រឡាញ់ ទុកជាកំណាញ់ហួសកំណត់
កំណើតមគ្គផលជឿប្រាកដ សន្មតថាបានច្រើនប្រការ ។
កុំធ្វើប្រកាន់ដោយយល់មុខ ហៅបុគ្គលិកមានគ្មានផលា
តាំងចិត្តចុះផ្លូវឧបេក្ខា រក្សារូបសុខដល់ស្វាមិនាយ ។
ស្វាមិនោះបើចង់ឱ្យឆាប់ដល់ សាងមគ្គសាងផលកុំរាយមាយ
ឃើញគេខុសចិត្តកុំមើលងាយ កុំពោលនិយាយកាន់ម្ខាងៗ ។
អ្នកប្រាជ្ញថ្មីត្រូវដោយឡែក ចំណែកប្រាជ្ញចាស់ត្រូវដោយយ៉ាង
កាន់យកទាំងពីរជាទីអាង សន្សំខំសាងនឹងបានសុខ ។
ពីថ្ងៃនេះទៅនៅឱ្យនឹង ស្ងៀមមាត់ឱ្យឃើងខ្លាចនរក
ពីព្រោះឈ្លោះគ្នារៀងរាល់ស្រុក បឹងថ្លុកត្រពាំងរាំងប្រេះដី ។
១៤៥-មិនឈ្លោះពីរឿងក្បើរឿងកោះ ឬទ្រព្យរបស់គោក្របី
នេះឈ្លោះពីធមិចាស់ធមិថ្មី ក្តៅចិត្តកើតក្តីរកចាញ់ឈ្នះ ។
បើក្តីពីស្រែពីចម្ការ ចៅក្រមសាលាងាយជម្រះ
នេះក្តីពីធមិថ្មីធមិចាស់ នោះក្រែងតែព្រះទើបកាត់បាន ។
មនុស្សភូតកុហកឆក់ឆបោក ឆ្នាំនេះស្រូវថោកវាស្តួអត់បាយ
ក្រលុយក្រកាក់ខ្វះប្រាក់ចាយ មហាជនទាំងឡាយកើតវេទនា ។
ភិរម្យខ្ញុំបាទដើមឈ្មោះ **អ៊ី** ពូជពង្សអម្បូរខ្មែរអ្នកជា
អាពុកឈ្មោះ **អ៊ុំភ** មានស័ក្តិងារ ចៅពញាធម្មធារាមេស្រុក ។
ក្នុងខេត្តភ្នំពេញឃុំកំបូល ពូជពង្សត្រកូលម្ចាស់អង្គ **ម៉ុភ**
ជីតាខាងម្តាយឈ្មោះពញា **ម៉ុភ** គាត់ធ្វើមេស្រុកឃុំស្ពានថ្ម ។
១៥០-អ្នកម្តាយអាពុកបងប្អូនជិត ជីទួតមួយពិតពូជចិត្តល្អ
ជូនតាផ្សំផ្គុំជាតំណ បង្កើតមកជាខ្ញុំបាទ ។

ពូជខាងអាពុកមានប្រាជ្ញា ច្រើនចេះសាស្ត្រាចាំក្បួនខ្នាត
ត្រកូលខាងម្ដាយប្រាជ្ញាឆ្លាត រូបរាងច្រើនស្អាតគ្មានគេស្អប់ ។
ខ្ញុំឮមនុស្សឈ្មោះពីធមិរអាថិ គិតក្រែងសាសនាប្រែត្រឡប់
ខ្ញុំចាប់អធិប្បាយពុំសាយសព្វ សន្មតថាចប់ម្ល៉េះឯងហោង ។

—— * ——

រាជ្យហ្លួងពីមុន រកស៊ីរែកពុន មានក្រមានភ័ព្វ
រាជ្យលោកឥឡូវ ត្រូវខំឱ្យញាប់ តែខ្ជិលច្រើនជាប់
ខ្មោះជើងខ្មោះដៃ ។
តាំងពីឆ្នាំច ចាំជាតំណ ទំនិញឡើងថ្លៃ
ចងក្បិនឱ្យតឹង ប្រឹងកុំសំចៃ សញ្ជឹងយប់ថ្ងៃ
កុំឱ្យក្រខ្សត់ ។
បើចង់ស្រាលខ្លួន រៀនសូត្រឱ្យមួន ឱ្យមាំឱ្យស្ទាត់
កុំចេះស្ទាក់ស្ទើរ ល្ងីល្ងើឥតបទ បើចេះប្រាកដ
ប្រាក់រត់តាមហៅ ។

## " ច្បាប់លឿកថ្មី "

អ្នកព្រះភិរម្យភាសា " អ៊ូ " ហៅ ង៉ុយ

# លក្ខណៈពិសេសនៃជនជាតិខ្មែរ

(ត)

តទៅនេះ យើងងាកមកពិចារណាអំពីភូមិភាគដើមកំណើត **មន-ខ្មែរ** នៅភូមិភាគខាងត្បូងភ្នំហិមាល័យ ដូចតទៅ :

**ភ្នំហិមាល័យ** (Himalayas) ជាភ្នំធំ មានជួរវែងអន្លាយ ប្រចាំអាស៊ីភាគកណ្តាល តាំងនៅរវាងប្រទេសទីបេត៍ (Tibet) ឥណ្ឌា និង ប៉ាគីស្ថាន (Pakistan) ។ ជួរភ្នំដ៏វែងអន្លាយនេះ បើវាស់ពីទីដើមកំណើតទន្លេហិណ្ឌូ (Indus) ដែលនៅប៉ែកខាងជើង ជួរភ្នំខាងត្បូងឆៀងខាងលិចប្រទេសទីបេត៍ ត្រង់ម្តុំភ្នំកៃលាស (Kailas) មកដល់ទីដើមកំណើតទន្លេព្រហ្មបុត្រ (Brahmaputra) ដែលមានពីកើតនៅត្រង់ចុងជួរភ្នំហិមាល័យ ខាងកើតឆៀងខាងលិចប្រទេស មានប្រវែង ២.៤០០ គីឡូម៉ែត្រ មានកំពូលខ្ពស់ ៨.៨៨២ ម៉ែត្រ ។ កំពូលភ្នំទាំងឡាយនេះ មានលក្ខណៈធំខ្ពស់ស្កឹមស្កៃ តាំងនៅខាងត្បូងវាលធំទីបេត៍ ។ នៅប៉ែកខាងជើងនៃជួរភ្នំធំៗនេះ គឺជួរភ្នំ Kun-Lun ដែលតាំងនៅក្នុងអាណាខេត្តប្រទេសទីបេត៍ ។

នៅទិសខាងជើង បន្ទាប់ពីជួរភ្នំយក្សនេះ មានកន្លែងធំៗពីរកន្លែង ដែលយើងគួរយកមកពិចារណា នូវដើមកំណើតអំបូរជាតិយើង : កន្លែងទី១ គឺ ប៉ាមីរ (Pamir) ទី ២ គឺ កស្មីរ (Kashmir) ។

Pamir : ឈ្មោះកន្លែងនេះ អ្នកស្រុកនៅទីនោះ ហៅថា Bami (គួរអោយសន្និដ្ឋានថា តាមច្បាប់កម្លាយភាសានៃនិរុត្តិសាស្ត្រ (Philology) ថាមកពី

ពាក្យថា *ឧប្បមេរុ* បានដល់ទីខ្ពស់បន្ទាប់ពីភ្នំ *សុមេរុ* ជាភូមិភាគតាំងនៅលើខ្នង ជួរភ្នំចោតសន្លឹម (Lofty mountains region) ឬ ម្យ៉ាងទៀត គេហៅថា ដំបូលលោក (The roof of the world) ផ្ទៃទីឧប្បមេរុនេះ ភាគច្រើនតាំង នៅក្នុងសហភាពសូវៀត (រុស្ស៊ី) ភាគតូចពីរទៀត តាំងនៅលើផ្ទៃដីចិន និង អាហ្វហ្គានិស្ថាន ( Afghanistan ) ។

ជួរភ្នំខ្ពស់ៗទាំងឡាយ ដូចជា Himalayas, the Kara Koram, the Kunlun ។ ល ។ បានមកជួបគ្នានៅទីនោះ ជាហេតុអោយមានឈ្មោះថា ប៉ាមីរក្នុត (Pamir knot) នៅត្រង់ខាងលិចឧប្បមេរុ ជាប់នឹងជួរភ្នំហិមាល័យ ប៉ែកខាងត្បូង គឺស្រុកកស្មីរ (Kashmir) ។

Kashmir : ភូមិភាគនេះ តាំងនៅខាងជើងរដ្ឋបញ្ជាប់ (Punjab) ខាងកើតជាប់ប្រទេសទីបេត៍, ចិនខាងត្បូង គឺផ្ទៃដីប្រទេសឥណ្ឌា ខាងលិចជាប់ ប្រទេសប៉ាគីស្ថាន, ខាងជើងទល់ប្រទេសអាហ្វហ្គានិស្ថាន និងចិន មានទំហំដី ៨៤.៤៧១ តារាងម៉ែល៍ ឬ ១៣៥.១៣៣ គម$^{២}$

ពាក្យ Kashmir នេះ សន្និដ្ឋានថាជាពាក្យតែមួយ និងពាក្យថា កស្មីរ ដែលមានប្រាកដក្នុងអដ្ឋកថាបាលី ភូមិវគ្គនៃព្រះពុទ្ធសាសនា ក្នុងកថានេះថា កស្មីរ ជានគរមួយ ក្នុងចំណោម ២១ នគរ ដែលព្រះពុទ្ធកាលទ្រង់មានព្រះជន្មគង់នៅ បានទ្រង់ផ្សាយសាសនាព្រះអង្គទៅដល់ ។

ភូមិភាគកស្មីរនេះ កាលពីព្រេងនាយយូរណាស់មកហើយ គង់នៅដាច់ពី ផ្ទៃដី ដែលហៅថា *ជម្ពូទ្វីប* ។ ដែលថាដូចនេះ ព្រោះអ្នកប្រាជ្ញខាងធរណីសាស្ត្រ (Geologist) និងអ្នកប្រាជ្ញបុរាណសាស្ត្រ (Archeologist ) ថា ក្រោយ ជំនាន់លិចទឹកកក ប្រមាណ ១០០.០០០ ឆ្នាំ អាណាបរិវេណដែលតាំងនៅតាមដង ស្ទឹងមេគង្គ (គឺចាប់តាំងពីទល់ដែនបញ្ជាប់ ដែលនៅខាងជើងរហូតដល់ផ្ទៃដីអស្សាំ)

គង់ជាទន្លេ ព្រោះគេមិនអាចរកឃើញវត្ថុចំណាស់ក្នុងយុគ ប៉ាឡេអូលីទិក (Palaeolithic) សោះ ។

បើដូច្នេះ ឃើញថាប្រទេសឥណ្ឌានៅជំនាន់នោះ គង់បែកជាពីរផ្នែកគឺ អាណាបរិវេណប៉ែកខាងជើងទន្លេមេគង្គា ដែលរាប់ចាប់ពីរដ្ឋបញ្ជាប់ដល់កស្មិរ មួយផ្នែកហៅថា *ឧត្តរ* និងប៉ែកខាងលិចឆៀងខាងត្បូងនៃភូមិភាគទន្លេគង្គា តាំងពីរដ្ឋពិហារ រហូតដល់ជាប់ផ្ទៃសមុទ្រ មួយផ្នែកទៀត ហៅថា *កោះព្រីង* ឬ *ជម្ពូទ្វីប* ដូច្នេះ ។

ត្រង់នេះ យើងឃើញថា អាណាបរិវេណត្រង់បញ្ជាប់ និងកស្មិរ ជាភូមិភាគមានផ្ទៃដីដោយឡែក ។ ក្នុងគម្ពីរព្រះអភិធម្ម បានប្រាប់ថា នៅសម័យបូរាណមានបួនទ្វីប : ឧត្តរកុរុទ្វីប, បុព្វវិទេហទ្វីប, អមរគោយានទ្វីប និងជម្ពូទ្វីប ។ ដូច្នេះ យើងឃើញថា ក្នុងទ្វីបទាំងបួននេះ មានទ្វីបមួយនៅប៉ែកខាងជើង ឈ្មោះថា *កុរុ* (ឧត្តរកុរុ =កុរុ នៅខាងជើង) ។ ក្នុងមហាសតិបដ្ឋានសូត្រ ក៏បានប្រាប់ថា ស្តេចចក្រពត្រ ព្រះនាម *មន្ធាតុរាជ* ធ្លាប់នាំបរិវារដែលតាមស្តេចមកពីទ្វីបទាំងបីដូចពោលនោះ មកតាំងនៅទាំងបីកន្លែងលើប្រទេសឥណ្ឌា គឺពួកដែលនាំមកពីឧត្តរកុរុ អោយតាំងស្រុកនៅត្រង់កុរុ (កុរុខាងជើង) ពួកមកពីបុព្វវិទេហទ្វីប អោយតាំងនៅលើផ្ទៃដីទេហរដ្ឋ ពួកមកពីអមរគោយានីទ្វីប អោយតាំងនៅលើផ្ទៃដីដែលហៅ*អមរន្តៈ* ។

ពាក្យថា *កេសមីរ* (Kashmir) និង*កស្មីរ* ជាពាក្យតែមួយពិតប្រាកដ តែយើងសង្ស័យថា ពាក្យថា *កស្មីរ* នេះ ជាពាក្យតែមួយនិង *កុរុ* បានឬទេ ? តាមភស្តុតាងបានចង្អុលពីលើមក ដូចបានជម្រាបមកនេះ ឃើញថាជាភូមិភាគតែមួយជាមួយគ្នា គឺនៅត្រង់ភាគភាគខាងជើងនេះម្យ៉ាង ម្យ៉ាងទៀត តាមកម្លាយភាសា ដែលវេចរឹលរាប់ពាន់ឆ្នាំមកនេះ ឃើញថា ពាក្យទាំងពីរម៉ាត់នេះ ច្បាស់ជា

ក្លាយពីមួយមកមួយបាន ឧទាហរណ៍ ពាក្យដែលវេចរីលដូច្នេះ គឺ ឧប្បមេរុ អ្នកស្រុកនៅទីនេះថា *បាមីរ* (Bamir) អង់គ្លេសសរសេរថា *(Pamir)* (ពាមីរ) ; បារាំងសរសេរថា *Palmyr* (ពាលមីរ) ឯពាក្យថា *សុមេរុ* អភិធម្មថា *សិនេរុ* ខ្មែរថា *ភ្នំព្រះស្មេរ* សៀមថា *ធុងព្រះមេន* (វាលមេរុ) ដូច្នេះជាដើម ទើបសូមសរុបថា *Kasmir កស្មីរ* និង *កុរុ* ជាពាក្យតែមួយ ។

ពីសម័យបុរាណ គឺអាចនៅក្នុងសម័យដែលមានទន្លេខ័ណ្ឌកណ្ដាល រវាងជម្ពូទ្វីប និងភ្នំហិមាល័យនេះ សម័យនោះគឺជាសម័យមុនសាសន៍អរិយកៈ ចូលរុករានឥណ្ឌា ពួកអ្នកកោះជម្ពូទ្វីប មិនដែលមាននរណាហ៊ានឆ្លងទៅត្រើយម្ខាងសោះ ព្រោះទន្លេកាលណោះធំណាស់ បើមាននរណាបានឆ្លងទៅ គង់ស្លាប់គ្មានជីវិតត្រឡប់មកវិញបាន ពួកអ្នកជម្ពូទ្វីបបានត្រឹមតែមើលឃើញកំពូលភ្នំហិមាល័យខ្ពស់កប់ពពកដូច្នេះ អាចគង់គិតថា ភ្នំខ្ពស់អស់នោះ សុទ្ធតែជាទីនៅនៃពួកអ្នកមានឫទ្ធិចេស្ដាបារមីខ្ពស់ ទើបពួកគេនាំគ្នាយល់ឃើញថា នៅលើភ្នំខ្ពស់ៗនោះ សុទ្ធតែទីនៅរបស់ពួកអ្នកមានឫទ្ធិ ។ កំពូលភ្នំដែលខ្ពស់ជាងគេនោះ គេអោយឈ្មោះហៅថា *មេរុរាជ* មានស្រះអនោដាត ដែលមានកំផែងកែវ ៧ ជាន់ មានកំពង់មុជទឹក ៤, កំពង់អស់នោះ សម្រាប់ពួកអ្នកវិសេស ដូចជា មាណព, កុម្ភណ្ឌ, គន្ធព, អសុរ, វិទ្យាធរ, កិន្នរ, គ្រុឌ ហើយនិងពួកជដិល ។ រីឯភ្នំដែលមានកំពស់ទាបចុះមកតាមលំដាប់ (ត្រង់ដែលយើងហៅថា ឧប្បមេរុ) នោះ មានឈ្មោះខុសគ្នា មាន ៧ ជួរ ។ ជួរមួយៗ មានឈ្មោះដូចតទៅគឺ : សុទស្សនៈ, ករវិក, ឥសិន្ធរ, យុគន្ធរ, នេមិន្ធរ, វិន័នតកៈ, អស្សកណ្ណ ។ ក្នុងរវាងចន្លោះភ្នំមួយៗ មានទន្លេខ័ណ្ឌ មានឈ្មោះដូចគ្នាថា *សីទន្ដរ* ទាំងអស់ ទន្លេអស់នោះមានសរសៃល្អិតណាស់ សូម្បីតែសរសៃតូចមួយរបស់សត្វក្ងោក ក៏អាចលិចទៅបាន ។

ឯដងភ្នំដែលទាបជាងគេ ឬ ដែលមានផ្ទៃរាបល្មមនោះ ជាទីនៅរបស់

អសុរ, យក្ស, វិទ្យាធរ, គន្ធព ឬ ពួកអមនុស្ស ។ ពាក្យថា *អសុរ* គួរបានដល់ជនជាតិដែលគ្មានសេចក្តីក្លាហាន គឺមិនអាចស៊ូ ។ បើពិចារណាតាមប្រវត្តិសាស្ត្រឥណ្ឌា តាមគម្ពីរព្រះវេទ ក៏ឃើញថាពួកជនជាតិ *អរិយកៈ* មានចូលមកវាយពួក *មិលក្ខៈ* ពីទិសខាងជើងឆៀងខាងត្បូងនៃតំបន់ដែលហៅថាកស្មីរដែរ ។ ពួកអ្នកស្រុកដើម គឺពួកមិលក្ខៈ ដែលពួកអរិយកៈ បង្អាប់ថាជាទាសៈទស្សនេះ បានចាញ់ដៃពួកអរិយកៈ ហើយនាំគ្នារត់មកនៅរាត់រាយក្នុងភូមិភាគ ដែលហៅថា ទក្សិណ-រធសោល (ខាងត្បូង) ។ សេចក្តីនេះ ឃើញថាត្រូវនឹងទស្សនៈលោកអ្នកប្រាជ្ញប៉ែកខាងបុរាណសាស្ត្រ និងប្រវត្តិសាស្ត្រ ដូចពោលហើយថា ពួកអំបូរមន-ខ្មែរបាននាំគ្នារត់មកពីភាគខាងជើងភ្នំហិមាល័យ ហើយបានមកនៅភាគខាងត្បូង រហូតដល់អាស៊ីអាគ្នេយ៍យើងនេះ ។

ដល់មកត្រង់នេះ ខ្ញុំសូមសរុបសេចក្តីថា ពាក្យថា *កុមេរុ* អាចក្លាយទៅជា { កុរុ / កស្មីរ / Kashmir } បានហើយ បើយើងចាប់សេចក្តីភស្តុតាងទាំងឡាយដូចពោលមកហើយនេះថា អំបូរមន-ខ្មែរ បានមកពីខាងជើងភ្នំហិមាល័យ ដូច្នេះមែន ក៏ឃើញថា តំបន់ខាងជើងភ្នំហិមាល័យ គួរជារដ្ឋកស្មីរ ។ ពាក្យ ថា*កស្មីរ* និងពាក្យថា*ខ្មែរ* នេះ ស្រដៀងគ្នាណាស់ គួរអោយចាប់អារម្មណ៍យ៉ាងសមហេតុផលថា ពាក្យថា *កស្មីរ* ស្រដៀងនឹងពាក្យថា *កមីរ* ។ ពាក្យថា *កមីរ* នេះ មានប្រាកដនៅក្នុងសិលាចារឹកចាម (ដូចធ្លាប់អាងមកពីមុនៗស្រាប់ហើយ) ពួកទូតចិន ក្នុងសម័យរាជវង្សសុង (Song period) បានមកស្រុកខ្មែរ ក្នុងសម័យកណ្តាល នៃគ្រិស្តសតវត្សទី៧ បានហៅខ្មែរថា*គិមិ* (Ki-mir) ដូច្នេះ ឬដែលចិនកន្លាំង ហៅថា *គិមិត* ។

ពាក្យ *កមីរ* ក្នុងសិលាចារឹក មានលក្ខណៈជិតដូចពាក្យថា *កស្មីរ* ជាទីបំផុត ឃើញថាពាក្យ *កមីរ* នេះ គង់មានកម្លាយរេចរឹលដូចពាក្យឯទៀតដែរ ។ តាមប្រវត្តិសាស្ត្រគ្រប់មជ្ឈដ្ឋាននៃអ្នកប្រាជ្ញប្រាប់ថា បុព្វបុរសជាតិ*កមីរ* នេះ មកពីឥណ្ឌា ។ ដូច្នេះ បើអ្នកប្រាជ្ញខ្មែរ ចិន និងអឺរ៉ុប បានទទួលស្គាល់ថា *កមីរ* នេះ គឺជាតិ *ខ្មែរ* នោះឯងហើយ យើងក៏គួរទទួលថា ពាក្យថា «ខ្មែរ» នេះ គឺជាពាក្យតែមួយនឹងពាក្យថា « កស្មីរ » នេះដែរ ។

ឥឡូវនេះ គឺបានសេចក្តីកាន់តែច្បាស់ហើយថា ជនជាតិដែលភៀសខ្លួនមកពីខាងជើងភ្នំហិមាល័យ ក៏គឺជនជាតិអំបូរខ្មែរតែម្តង ព្រោះយើងសំអាងទៅតាម

១ . មិត្តអ្នកប្រាជ្ញ

២ . ប្រវត្តិសាស្ត្រយុគថ្ម

៣ . ទីស្ថាន

៤ . កម្លាយពាក្យរេចរឹល ផ្លូវនិរុត្តិសាស្ត្រ (Philology)

កម្លាយពាក្យនេះ មានដូចតទៅ : ខ្មែរ ខ្មេរ ក្មេរ កមីរ កុរុ កុមេរុ ដូច្នេះ ។

ខ្ញុំមានទស្សនៈដូច្នេះ គឺគ្រាន់តែលើកយកមកជូនអស់លោក និងប្អូនៗអនុជនពិចារណា ដើម្បីជាផ្លូវរកដើមកំណើតប្រវត្តិសាស្ត្រជាតិ តែប៉ុណ្ណោះ ។

តាមទស្សនៈដែលសមគួរទៅតាមហេតុផលខាងលើនេះ តើអស់លោកនិងប្អូនៗ យល់ថាតើ **មន** និង **ខ្មែរ** អ្នកណាកើតមុន ? តាមទស្សនៈខ្ញុំ, ខ្ញុំសូមជម្រាបយ៉ាងផ្តាច់ព្រាត់ថា កាលដើមឡើយ ពាក្យថា **មន** មិនទាន់មានប្រាកដទេ ។ **មន** ឬជាតិដែលនិយាយភាសាអំបូរ **ខ្មែរ-មន** ទាំងឡាយ កាលជំនាន់ព្រេងនាយ ដូចបានជម្រាបមកតាមលំដាប់នោះ គង់បានហៅខ្លួនឯងថាជាតិ *កស្មីរ* ឬ *កមីរ* តែម្តង ! ឯពាក្យថា *មុណ្ឌៈ* ក្តី *មន* ក្តី កើតជាខាងក្រោយទេ ។ ឯពាក្យថា

**មន.ខ្មែរ** ទើបតែអ្នកប្រាជ្ញអាឡឺម៉ង់ឈ្មោះ Wilhem Schmidt សន្មតហៅមុនគេបង្អស់ ប្រមាណជិតចិតសិបឆ្នាំមកហើយប៉ុណ្ណោះឯង ។ ក្នុងពង្សាវតារយោនកៈ ឬ ក្នុងដំណាក់កាលនៃគម្ពីរចាម ទេវិវង្ស ហៅ *មន* ថា *មេង* បាលីថា មេង្គបុត្ត (កូនជាតិមេង ) ពាក្យថា *មេង* ស្រដៀងគ្នានឹងពាក្យចិនទាជីវ ដែលហៅខ្មែរយើងបច្ចុប្បន្ននេះថា *ការមៀង* ឬ *ការមេង* ភាសាវៀត ហៅខ្មែរថា Cao Mien។ ពាក្យថា *មេង្គបុត្ត* និងពាក្យថា *មេង* ដែលចិនហៅនោះ ស្រដៀងគ្នាណាស់ ។

ហេតុដែលញែកខ្មែរមួយក្រុមប៉ែកខាងលិច អោយទៅជា *មន* ហើយញែកខ្មែរខាងកើតអោយទៅជា *ខម* នេះ អាចជានយោបាយ ក្នុងជំនាន់ពុទ្ធសតវត្សទី១៩ កន្លងមកហើយ ក៏សឹងបាន ។

ដល់មកត្រង់នេះ ខ្ញុំសូមជម្រាបអស់លោក និងប្អូនៗ ដើម្បីរំលឹកថា «យើងកំពុងតែបណ្តែតអារម្មណ៍ក្នុងការស្រាវជ្រាវរកអោយឃើញថាតើ *ខម* និង *ខ្មែរ* ជាជនជាតិតែមួយ ឬអ្វី ? នៅត្រង់ផ្នែកកណ្តាល យើងបានវែកញែកអំពីដើមកំណើតមនុស្សនៃយុគថ្មថ្មី ដែលហៅថា Neolithic Period គឺមានអាយុប្រមាណ ៣.៥០០.៥០០ ឆ្នាំ មុនគ្រីស្តសករាជ ហើយផ្នែកចុងខាងក្រោយបង្អស់យើងបានមកដល់ចំណុចមួយដែលថា អំបូរ *មន.ខ្មែរ* ទាំងអស់ បានភៀសខ្លួនរត់ដោយភ័យសង្គ្រាមពីភូមិភាគប៉ែកខាងត្បូងភ្នំហិមាល័យ ត្រង់កន្លែងដែលហៅថា *កស្មីរ* សព្វថ្ងៃនេះ » ។

តទៅនេះ សូមពិនិត្យតទៅទៀត :

## ដំណើរអំបូរមន.ខ្មែរ មកកាន់អាស៊ីអាគ្នេយ៍

អំពីដំណើរ*មន.ខ្មែរ* រត់ពីដែនខាងត្បូងនៃភ្នំហិមាល័យ មកកាន់អាស៊ីអាគ្នេយ៍ បើយើងពិចារណាតាមលំនាំបុរាណវិទ្យា និងប្រវត្តិសាស្ត្រ ឃើញថា មិន

មែនមកម្ដងមួយក្រុមនោះទេ គឺថា រត់ភៀសខ្លួនច្រើនលើក ច្រើនគ្រារាប់មិនអស់ ហើយច្រើនរយសតវត្សផង គឺរាប់តាំងពីយុគថ្មចាស់ ដែលហៅថា Palaeolithic Period ចុះមក មុនយុគគម្ពីរព្រះវេទ រហូតដល់សម័យក្សត្រិយ៍កនិស្សកៈនៃរាជវង្សកុសាណៈ ក្នុងសតវត្សទី៧ - ៨ ។

នៅប្រទេសឥណ្ឌា ត្រង់រដ្ឋបញ្ចាប់ ដែលនៅជិតកស្មីរនោះ គេបានរកឃើញគ្រឿងប្រើប្រាស់ ដែលហៅថា Pebble (ថ្មក្រួស) ក្នុងស្ទឹង Soan ។ វប្បធម៌បែបនេះ ហៅថា Soan Culture មានលក្ខណៈដូច Pebble ដែលបានរកឃើញនៅប្រទេសម៉ាឡេស៊ី និង លាវ ។ រឿងនេះ ធ្លាប់បានជម្រាបមកហើយ ដូច្នេះទើបឃើញថា នៅយុគនោះ ពួកមនុស្សយុគ Palaeolithic មានរត់មកនៅអាស៊ីអាគ្នេយ៍ទៅហើយ ។ នៅយុគ Mesolithic ក៏មានរកឃើញគ្រឿងប្រើប្រាស់ជាពូថៅ ថ្មរំលីង ដែលជាស្នាដៃកាន់តែល្អឡើង (Handaxe) ទាំងលើផ្ទៃដីឥណ្ឌា ថៃ, លាវ, យួន រហូតដល់ឥណ្ឌូណេស៊ី ។ លុះដល់យុគថ្មថ្មី គេក៏បានរកឃើញគ្រឿងប្រើប្រាស់ ដែលហៅថា Shouldered celt លើផ្ទៃដីឥណ្ឌាប៉ែកខាងជើងផុត, និងទូទៅលើផ្ទៃដីអាស៊ីអាគ្នេយ៍ ។ ដូច្នេះ ក៏ឃើញថានៅយុគថ្មថ្មី ឬ Neolithic Pariod នេះ មានមនុស្សពីឥណ្ឌាមកនៅអាស៊ីអាគ្នេយ៍ កាន់តែច្រើនឡើងហើយ ។

*(នៅមានត)*

សិក្សាស្រាវជ្រាវ ដោយ

**ហៀន ចណ្ណារក្ខ**

# ការសិក្សាសម័យបុរាណ

## (តចប់)



ការសិក្សាចែកជា ៤ ជាន់ គឺ :

## ជាន់ដើម (ថ្នាក់ដំបូង) = រៀនសរសេរ

កាលកុមារដឹងក្ដីហើយ មានអាយុប្រមាណ ៧, ៨, ៩, ១០ ឆ្នាំ មាតាបិតាតែងនាំកូនទៅឱ្យសិក្សានៅវត្ត រៀបចំសំពត់ ខោអាវ ខ្លួនប្រាណកូន ហើយរើសរកថ្ងៃល្អ ៗ គេច្រើនរើសយកថ្ងៃព្រហស្បតិ៍ ព្រោះថ្ងៃនេះជាទេព្ដាសំដី ហើយគេជឿថា កុមារចាប់ផ្ដើមរៀននៅថ្ងៃនេះ នឹងចេះដឹងឆាប់ ៗ រើសថ្ងៃបានហើយ នាពេលព្រឹក មាតារៀបអាហារភោជន ទុកជាចង្ហាន់ប្រគេនលោក ។ លុះរៀបរួចហើយស្វាមីភរិយានាំកូនទៅវត្ត ចូលទៅលោកគ្រូចៅអធិការ ក្រាបបង្គំបីដង បង្គាប់កូនឱ្យថ្វាយបង្គំបីដង ហើយលើកភោជនាហារប្រគេន ទើបថយមកអង្គុយនៅទីសមគួរលើកដៃប្រណម្យទូលថា :

*« ព្រះតេជព្រះគុណម្ចាស់ ! ខ្ញុំព្រះករុណាទាំងពីរនាក់ នាំកូនឈ្មោះ ( ... ) មកប្រគេនទុកជាសិស្ស ឱ្យសិក្សាចំណេះវិជ្ជា មានអក្សរ ជាដើម ។*

*សូមព្រះតេជព្រះគុណមេត្តាប្រោសបង្ហាត់បង្រៀនច្បាប់លោក ច្បាប់ធម៌ ចំណេះវិជ្ជាគ្រប់ប្រការឱ្យទាន ។ ខ្ញុំព្រះករុណាទាំងពីរនាក់ សុំតែភ្នែក និងឆ្អឹងទេ សាច់ឈាមប្រគេនព្រះតេជព្រះគុណទាំងអស់ »* ។ ពាក្យនេះ មានន័យថា សូមមេត្តាបង្រៀនសព្វសារពើវិជ្ជា បើនៅទាស់ខុសឆ្គងត្រង់ណា កាយ ឬ វាចាចិត្ត មេត្តាប្រោសពត់ប្រដៅឱ្យទាន ឱ្យទាល់តែបានទៅជាមនុស្សចេះដឹងនឹងគេឡើង ។ និយាយទូលលោកហើយ បែរមកនិយាយនឹងកូនថា :

*កូន ! ម៉ែ ឪ នាំកូនឯងមកប្រគេនព្រះតេជព្រះគុណឱ្យសិក្សា រៀនសូត្រ ។ កូនត្រូវប្រតិបត្តិព្រះតេជព្រះគុណកុំបីឱ្យមានឆ្គាំឆ្គង មើលបម្រើទឹកក្តៅ ទឹកត្រជាក់តាមកាលគួរ ហើយខំប្រឹងរៀនសូត្រឱ្យចេះដឹង ឱ្យម៉ែឪបានសប្បាយចិត្ត ធ្វើវង្សត្រកូលយើងឱ្យថ្កុំថ្កើនរុងរឿង តទៅ »* ។

កុមារដែលមាតាបិតា បានប្រគល់ឱ្យទៅលោកគ្រូបាធ្យាយហើយ ដេកនៅក្នុងវត្តរហូត និងប្រណិប័តន៍គ្រូអាចារ្យតទៅ ។ តែសព្វថ្ងៃនេះ ទំនៀមនេះ មិនទៀងទាត់ទេ ។ កុមារទៅរៀននៅក្នុងវត្តតែពេលថ្ងៃ លុះដល់ពេលល្ងាចវិលមកដេកឯផ្ទះវិញ ។ ទំនៀមនេះហើយ ជាប្រពៃណីខ្មែរយើងពីបូរាណ ។ បើពិនិត្យពិចារណាឱ្យបានហ្មត់ចត់ទៅ នេះមិនមែនជាទំនៀមទម្លាប់ខ្មែរយើងសុទ្ធសាធទេ ។ កាលដើមឡើយ ជារបស់ព្រាហ្មណ៍ ។ ក្នុងគម្ពីរព្រាហ្មណ៍ ដូចច្បាប់មនុ ( loi de manu ) ឬ ច្បាប់គ្រឹហ្យសូត្រ ស្ដីថា កូនព្រាហ្មណ៍ កាលបើដល់អាយុសិក្សាហើយ ( ១០, ១១, ១២ ឆ្នាំ ) មាតាបិតាត្រូវយកទៅប្រគល់ឱ្យឫសីជាអធ្យាបក ( គ្រូបង្រៀន ) ដើម្បីសិក្សាត្រៃវេទ (ត្រយីវិទ្យា ) ។ កុមារព្រាហ្មណ៍នេះ ហៅថាព្រាហ្មណ៍ចារិន ឬព្រាហ្មណ៍ចារី (អ្នកប្រព្រឹត្តឱ្យបានទៅជាព្រាហ្មណ៍ ឬប្រព្រឹត្តឱ្យបានក្តីប្រសើរ) ។ នៅជាមួយគ្រូ រកអាហារភោជន រក្សាភ្លើងតទៅ រហូតដល់ចេះត្រៃវេទ និងវេទាង្គ (អង្គរបស់វេទ) ៦ ប្រការគឺ :

១ . កល្បៈ សិក្សាឱ្យចេះធ្វើពិធីបូជា,

២ . សិក្សា សិក្សាសូរសាស្ត្រ,

៣ . ឆន្ទ សិក្សាក្បួនកាព្យ,

៤ . និរុត្តិ សិក្សាអានវេទឱ្យត្រឹមត្រូវតាមជើងកាព្យ,

៥ . វ្យាករណ សិក្សាវេយ្យាករណ៍ (បានិណិ),

៦ . ជ្យោតិស្ឋ សិក្សាតារាសាស្ត្រ ។

លុះចេះវេទ ចេះវេទាង្គសព្វគ្រប់ហើយ ទើបទទួលបាននាមថាបារគូ (អ្នកដល់នូវត្រើយនៃវិជ្ជា ) ។ ដល់វិលមកផ្ទះវិញ ទើបមាតាបិតារៀបពិធីប្រសិទ្ធីឱ្យបានពេញជាព្រហ្មណ៍ពេញលក្ខណៈ គឺ ទ្វិជៈ «កើតពីរដង» គឺកើតពីមាតាម្តង និងកើតចេញពីត្រៃវេទម្តងទៀត ។ ប្រពៃណីដូចបានរៀបរាប់មកនេះ ហៅថា ឧបនយ-សំស្ការ គឺពិធីប្រសិទ្ធីកូនអោយបានជាព្រាហ្មណ៍ពេញលក្ខណៈ ។ ពាក្យថា ឧបនយ-សំស្ការ មានពីរម៉ាត់គឺ **ឧបនយ** (ឧប + នី) ប្រែថា « នាំយកទៅប្រគល់ឱ្យ (អធ្យាបក=គ្រូ) + **សំស្ការ** (សំ + ស + ការ) ប្រែថា «សម្រាំង, ប្រសិទ្ធី» ។ សំស្ការនេះ នៅប្រទេសឥណ្ឌាសម័យបូរាណទាំងអស់មាន ៤០ ប្រការគឺ ក្នុងជីវិតព្រាហ្មណ៍ម្នាក់ៗ រាប់តាំងពីកើតរហូតដល់ស្លាប់ទៅវិញ ត្រូវធ្វើសំស្ការ ៤០ ដង ។ ឧទាហរណ៍ មានគភ៌ លម្ពនសំស្ការ (ពិធីធ្វើឱ្យឧទរមានគភ៌) រហូតដល់អាវាហវិវាហ-សំស្ការ[១] ជាទីបំផុត ។ តែសព្វថ្ងៃនេះ គេច្រើនធ្វើតែ ១២ ប្រការទេ ។ ដោយឡែកប្រទេសខ្មែរយើង មិនប្រើពាក្យសំស្ការនេះទេ ព្រោះយើងកាន់ព្រះពុទ្ធសាសនា ។ តាមពុទ្ធសាសនា យើងប្រើពាក្យមង្គល (សេចក្តីចម្រើន) ជំនួសវិញ ។ យើងនិយាយ

(១) ន័យដើម អាវាហ = ពង្រត់មក, វិវាហ=ពង្រត់ទៅ គឺពង្រត់យកកូនស្រី, តមក មានន័យថា « នាំទៅ, នាំមក គឺនាំទៅរៀបការឯផ្ទះខាងស្រី ឬ ផ្ទះខាងប្រុស ។

ថា អាវាហវិវាហមង្គល (មង្គលរៀបការ) នាមករណមង្គល (មង្គលឱ្យឈ្មោះ) សិប្បុគ្គហានមង្គល (មង្គលឱ្យរៀន) ។ល។ ដូច្នេះ យើងយល់បានថា ការសិក្សាពុទ្ធ-សាសនា តែប្រពៃណីជាព្រាហ្មណ៍ ផ្សំនឹងទំនៀមខ្មែរ កើតបានទៅជាអារ្យធម៌ មួយឡើង ដែលផ្សេងពីព្រះពុទ្ធសាសនា និងលទ្ធិព្រាហ្មណ៍ ។

## ឧបករណ៍សិក្សា

- *កុដិ ឬ សាលា* ជាសាលារៀន គ្មានតុ កៅអីទេ ។ សិស្សទាំងអស់រៀនរួមគ្នាតែកន្លែងមួយ ។ ពេលព្រឹក មិនអាចរៀនបានទេ ព្រោះជាពេលលោកបិណ្ឌបាត ។ ដូច្នេះ ការសិក្សា ច្រើនប្រព្រឹត្តទៅនៅពេលរសៀល ចាប់ពីពេលឆាន់ត្រង់រួចទៅ ។

- *ក្ដារឈ្នួន* ធ្វើពីបន្ទះឈើស្រាល (ដើមគរ) ទទឹង០,២៥ម បណ្ដោយ ១,២០ម មុខម្ខាងឈូសស្អាត លាបពណ៌ខ្មៅ[1] សំរាប់សសេរ មុខម្ខាងទៀតគ្រាន់តែឈូសរំលីង តែមិនលាបពណ៌ទេ ព្រោះមិនប្រើសំរាប់សសេរឡើយ ។

- *ដីស :* គឺដីដែលមានពណ៌ស គេច្រើនយកដីឥដ្ឋនៅបាតស្រះ បាតស្ទឹង បាតទន្លេ មកលញ់ឱ្យមូលប៉ុនៗម្រាមដៃ ហាលថ្ងៃឱ្យស្ងួត ទើបយកមកសរសេរ ។

- *ទឹកល្បប់ :* គឺទឹកដែលលាយឡំដោយសំណុសផ្សេងៗ ដូចជា ផង់ធ្យូង ម្រែងភ្លើង លាយជាមួយទឹកបាយ គេលាយទុកក្នុងត្រឡោកដូង ឬ ក្នុងកូនក្អម សម្រាប់លុបក្ដារខៀន ។

ពេលរៀន លោកគ្រូនិមន្តទៅកាន់ទីកន្លែងរៀន ។ សិស្សអង្គុយជួបជុំគ្នាដោយពួកៗ តាមថ្នាក់ គឺសិស្សទើបរៀនសរសេរ សិស្សរៀនមើលសាស្ត្រាច្បាប់

(១) គេច្រើនប្រើធ្យូងដើមឆ្លក សំរាប់លាបឱ្យខ្មៅ ។

សាស្ត្រាល្បែង សាស្ត្រាទេសន៍ ។ លោកគ្រូនិមន្តទៅជិតសិស្សថ្មីមុនគេ ហើយបង្គាប់ឱ្យអង្គុយបត់ជើង ឱ្យដាក់ក្ដារខៀននៅលើភ្លៅ ស៊កដៃឆ្វេងទ្រក្ដារ ដៃស្ដាំកាន់ដីសសរសេរ ។ ដំបូង លោកគ្រូដាក់ច្បាប់ឱ្យ[1] បង្គាប់ឱ្យកាន់ដីស ឱ្យសរសេរពីឆ្វេងទៅស្ដាំ ។ លោកដឹកដៃឱ្យរៀនសរសេរ ។ ជួនកាលបង្គាប់ឱ្យសិស្សដឹកបន្ទាត់គាប ហើយបង្គាប់សិស្សឱ្យសសេរអក្សរតាមចន្លោះបន្ទាត់គាបនោះ មិនឱ្យសរសេរហួសទៅលើបន្ទាត់ ឬឱ្យធ្លាក់ចុះមកក្រោមបន្ទាត់ទេ ។ ជាពិសេស លោកគ្រូសរសេរបទនមស្ការ ៣ បទ ជាអក្សរមូល ទុកជាច្បាប់អាទិតាំង គឺ :

**នមោ** = សូមនមស្ការ

**ពុទ្ធាយ** = ចំពោះព្រះពុទ្ធ

**សិទ្ធំ** = សូមឱ្យបានសម្រេចការសិក្សា

ពេលសិស្សកំពុងសរសេរ លោកគ្រូបង្រៀនឱ្យអានបណ្ដើរ ឱ្យអានបទនមស្ការជាភាសាសំស្ក្រឹតនេះ ជាភាសាខ្មែរ គឺឱ្យអានថា :

**ន មោ ពុ ទ្ធា យ សិ ទ្ធំ** ឱ្យចេញជាបទ ដូចតទៅ :

**ន** អីយ **ន ន ន**

**មោ** អីយ **មោ មោ មោ**

**ពុ** អីយ **ពុ ពុ ពុ** ( អានថា ពុត )

**ទ្ធា** អីយ **ទ្ធា ទ្ធា ទ្ធា** ( អានថា ធា )

**យ** អីយ **យ យ យ**

**សិ** អីយ **សិ សិ សិ** ( អានថា សិត )

**ទ្ធំ** អីយ **ទ្ធំ ទ្ធំ ទ្ធំ** ( អានថា ធំ ) ។

(១) អក្សរគំរូ

បើសិស្សសរសេរបទនមស្ការនេះបានហើយ លោកគ្រូបង្រៀនឱ្យសរសេរស្រះពេញតួ គឺ **អ អា ឥ ឦ** ។ល។ ហើយបង្គាប់អោយអានថា **អ អីយ អ អ អ** ។ល។ តទៅទៀត លោកគ្រូបង្រៀនឱ្យសរសេរព្យញ្ជនៈ **ក ខ គ ឃ ង** ។ ល ។ ហើយឱ្យអានតាមទំនងដូចគ្នា ។ បន្ទាប់ពីនោះ លោកដាក់ឱ្យរៀនសរសេរស្រះនិស្ស័យ គឺស្រះ ា ិ ី ... រហូតដល់ចប់ ។

រៀនចេះស្រះពេញតួ ស្រះនិស្ស័យ និងព្យញ្ជនៈអស់ហើយ លោកគ្រូបង្រៀនឱ្យបំបែកព្យញ្ជនៈផ្សំនឹងស្រះនិស្ស័យ ប្រកបព្យញ្ជនៈ ផ្ញើជើងជាលំដាប់ ឱ្យសិស្សចេះសរសេរ និងអានរត់មាត់ ។ ការរៀនបែបនេះហៅថា"រៀនផ្ទាល់មាត់" ។ កាលបើសិស្សបានរៀនចប់ផ្នែកបំបែក ផ្ញើជើង ប្រកបចប់សព្វគ្រប់ហើយ លោកគ្រូប្រដៅ[(១)]គឺសរសេរអក្សរមួយតួៗ ហើយឱ្យសិស្សអានឱ្យត្រូវ ។ បើពិនិត្យឃើញថា សិស្សអានរហ័ស ស្ទាត់ជំនាញហើយ ទើបលោកអនុញ្ញាតឱ្យឡើងទៅមើលសាស្ត្រាច្បាប់ ។

## ជាន់ទី ២ : រៀនមើលសាស្ត្រាច្បាប់

ការរៀនមើលសាស្ត្រាច្បាប់នេះគឺ ដំបូងឱ្យរៀនមើល (អាន) ជាពាក្យរាយ មិនទាន់ឱ្យមើល (អាន) ជាបទតាមច្បាប់ទេ ព្រោះសាស្ត្រាច្បាប់ទាំងអស់សុទ្ធតែជាពាក្យកាព្យ ដូចសាស្ត្រាច្បាប់ក្រម កេរកាល ច្បាប់ប្រុស ច្បាប់ស្រី ច្បាប់រាជនេតិ (ច្បាប់ព្រះរាជសម្ភារ) ។ ល ។ លោកគ្រូនាំឱ្យរៀនអាន ឱ្យចេះអានត្រឹមត្រូវច្បាស់លាស់តាមក្បួនអក្សររួច ទើបឱ្យសិស្សអានដោយខ្លួនឯងតទៅ ។ គេអានហើយអានទៀត អានច្រើនលើកច្រើនសា ទាល់តែចាំស្ទាត់រត់មាត់ អាចសូត្រមាត់ទទេបាន ដោយមិនបាច់មើលអក្សរ ។ ការអាននេះ លោកគ្រូអង្គុយជិត ផ្ទៀងមើល

---

(១) ប្រដៅ = សាកល្បង ( test ), ត្រួតពិនិត្យមើល ( controle )

ហើយបង្គាប់ឱ្យសិស្សចាប់សាស្ត្រាអាន តាំងពីដើមដល់ចប់ បើលោកឃើញថា សិស្សនេះចេះអានស្ទាត់ជំនាញហើយ លោកគ្រូពន្យល់សេចក្ដីក្នុងសាស្ត្រាច្បាប់នេះបន្ថែមទៀត ។ ធម្មតាច្បាប់ មានអត្ថន័យជ្រាលជ្រៅណាស់ រួចទើបលោកគ្រូឱ្យឡើងមួយថ្នាក់ទៀត គឺមើលសាស្ត្រាល្បែង តទៅ ។

## ជាន់ទី ៣ ៖ រៀនមើលសាស្ត្រាល្បែង(២)

ការរៀនមើលសាស្ត្រាល្បែង មានទំនងដូចគ្នានឹងរៀនមើលសាស្ត្រាច្បាប់ដែរ ។ តែម្ដងនេះ លោកគ្រូឱ្យរៀនអានចេញជាបទ ព្រោះសាស្ត្រាល្បែងទាំងអស់ សុទ្ធតែបានតែងនិពន្ធឡើងជាបទ មានបទកាកគតិ ព្រហ្មគីត ភុជង្គលីលា ពំនោល បន្ទោលកាក ។ ល ។ សាស្ត្រាល្បែង មានច្រើនច្បាប់ ដូចសាស្ត្រាច្បាប់ដែរ គឺ សាស្ត្រាជុច សុបិន ហង្សយន្ត វិមានច័ន្ទ ស័ង្ខសិល្បជ័យ ជ័យទត្ត សព្វសិទ្ធិ ។ល។

លោកគ្រូបង្រៀនឱ្យមើលតាមបទ សិស្សថាតាមទាល់តែត្រូវបទ ទើបឱ្យសិស្សអានខ្លួនឯងតទៅ ។ គេមើល (អាន) ដដែលៗ អានចុះអានឡើង ទាល់តែចាំស្ទាត់ ទើបផ្លាស់ទៅអានសាស្ត្រាមួយផ្សេងទៀត រហូតទាល់តែអស់សាស្ត្រាដែលមាននៅក្នុងវត្ត ។ លោកគ្រូផ្ទៀងមើលទៀត បើឃើញថាសិស្សចេះអានបទត្រឹមត្រូវហើយ លោកឱ្យឡើងទៅមើលសាស្ត្រាទេសន៍ ។

## ជាន់ទី ៤ ៖ ការរៀនមើលសាស្ត្រាទេសន៍

ការរៀនមើលសាស្ត្រាទេសន៍ មានទំនងអានផ្សេងពីសាស្ត្រាល្បែង ជាបទ ឬ ពាក្យរាយធម្មតា ។ សាស្ត្រាទេសន៍ ជាសេចក្ដីមួយបែបនៅក្នុងពួករាយដែរ

---

(២) រឿងល្បើក រឿងប្រលោមលោកជាពាក្យកាព្យ ( សាស្ត្រាសម្រាប់មើលលេង ) ។

ប៉ុន្តែ មិនមែនជាពាក្យរាយធម្មតាសុទ្ធសាធនោះទេ ជាពាក្យរាយជួនគ្នា ឬកម្រងពាក្យ ជួនរណ្ដំគ្នារដឹកទៅ ដែលគេនិយមហៅថា*កម្រងកែវ* ។ ដូច្នេះ លោកគ្រូបង្រៀនសិស្សឱ្យសិស្សរៀនអានលើកដាក់សំឡេងតាមបែបទេសន៍ គេហៅថា *រៀនទេសន៍* ។ សាស្ត្រាទេសន៍ មានច្រើនច្បាប់ដែរ ដូចជា សាស្ត្រាអានិសង្ស អានិសង្សចម្លងបុណ្យ អានិសង្សខ្មោច ។ ល ។ រហូតដល់សាស្ត្រាទេសន៍ធំៗ ដូចជា ទសជាតក៍ ជាដើម ។ សិស្សរៀនដល់ថ្នាក់នេះ ចាត់ទុកជាសិស្សជាន់ខ្ពស់ហើយ ។ អ្នកនិពន្ធសាស្ត្រាទសជាតក៍ សុទ្ធតែជាអ្នកមានស្នាដៃដ៏ប្រសើរខ្ពង់ខ្ពស់ ។ ពាក្យពេចន៍ខ្ពស់ មានអាថ៌កម្បីរភាព ពាក្យរាយជួនរណ្ដំគ្នា មើលទៅមិនអាក់ ពិរោះស្ដាប់ គួរឱ្យចង់មើល ដូចពាក្យតទៅនេះ :

« .... ព្រហ្មេ ម្នាលព្រាហ្មណ៍អើយ ! វីព្រៃខេត្តហេមពាន្ត សឹងដ៏ជាសំណាក់នៃបក្សាបក្សី តែងអាស្រ័យនៅសព្វពេលវេលា ហើរនាវេហាស៍ យាសយំចុះមកទំដោយលង្វែកមែកសាខា ខ្សៀវខ្សាវដោយភាសា ឮសូរល្វេងល្វើយ ។ ឯបក្សីទាំងឡាយនោះគឺ គ្រួច ក្រៀល ចង្កៀលខ្យង ត្រយងយំថ្ងូរ តុកទ្រូ ហូហូ តាវៅស្វិតចៅ អាវអាត់ ក្ងាន ក្លូ ក្អែក ប៉ោលតោក ត្រុំ ថ្កូ ស្ទាំង ភ្លាំង លលក សារិកា សឹងដ៏ហើរឆ្វៀលឆ្វាត់ ឆ្វេឆ្វាទៅមក ឆ្មៀងរកចំណីអាហារ ។ សំឡេងកង្កួច ឮគ្រលួច បីដូចតូរ្យតន្ត្រី ព្រៃ ស័ង្ខ រគាំង ភេរី ពិណពាទ្យ រនាត ពីរោះរងំ ។ ល ។

វីអស់ព្រៃព្រឹក្សានោះ មានពណ៌ទីទៃៗពីគ្នា ពុំដឹងបើនឹងប្រាប់ទេ ។ មានព្រីង ព្រូស ជន្លួស ដៃខ្លា គគីរ ឆាំឆា ពុកឆ្មា មហាហង្ស មានទាំងព្នៃលញ្ចៅ បង្គាបង្គៅ ម័កប៉ែន គូលេន សិរមាន់ ច័ន្ទន៍ ម៉ាក់បាត លាំងសាត ទុរេន មៀន ប្រដាក់ ម័កប្រេង ម័កប្រាង ម័កសាង ម័កដោក ឳឡោក ស្រឡៅ តាត្រាវ អង្កោល អង្កាញ់ កណ្ដក់ ចំបក់ រាំងភ្នំ ស្រគំ ពង្រ ញ្ញ កកោះ លំពោះ ក្រវាន់ ចន្ទន៍ ក្រស្នា ។ ល ។ មួយសោត ឯស្រះស្រង់បោក្ខរណី មានទឹកថ្លាយង់យល់ដី មីរដេរដាសដោយផ្កា

ឧប្បល ចង្កុលណី លំចងស្បង្ក័ជ សឹងដ៏ដុះលាយលេចធ្លា មានផ្ការីករហង់ មានហ្វូង មច្ឆាហែបហែលរេរាទៅមក ក្រហោ ក្រហែ ទ្រនេល បបែល កំភរ កំភុក មាន ទាំងត្រីឆ្ពិន ត្រីស្លាត អណ្តាតឆ្កែ ឆ្តោក គជ្រា អណ្តែងងាំង គល់រាំង រាហូ ឆ្តោ ផ្ទក់ ក្អកក្អី ត្រីក្រាយ ក្លាំងហាយ ក្លាំងហាត ដងខ្ទែង ច្រកែង ទីពោ ។ល។ »

ថិរវេលាសិក្សានេះ មិនមានកំណត់ច្បាស់លាស់ទេ ។ តែបើសិក្សា ឱ្យគ្រប់គំរប់បីឆ្នាំ ទើបសន្មតថា អស់ការសិក្សាមួយលើក ។ ក្នុងការអាស្រ័យនៅ ក្នុងវត្តនេះ សិស្សបានទទួលការអប់រំគ្រប់បែបយ៉ាង ។ លោកគ្រូមិនមែនបង្រៀនតែ អក្សរ ធម៌អាថ៌ប៉ុណ្ណឹងទេ លោកអប់រំធម្មចរិយាទៀត បង្រៀនឱ្យចេះគោរពគ្រូ គោរពមាតាបិតា ញាតិកាទូទៅ រហូតដល់អ្នកតូចអ្នកធំ ចេះសំពះ ចេះឱនលំទោន ចេះដាក់ខ្លួនអោយសម ដឹងខ្ពស់ ដឹងទាប ស្គាល់ខុស ស្គាល់ត្រូវ ស្គាប់ល្អ ស្គាល់ អាក្រក់ ស្គាល់គុណទោស ស្គាល់រាក់ជ្រៅ គួរមិនគួរ ឱ្យបានជាសិស្សប្រសើរ ឱ្យចេះ ដើរខ្លួនឯងនៅក្នុងលោករបស់មនុស្សនេះ ។ ទៅត្រង់ណា ឱ្យគេស្គាល់ថាជាកូនអ្នក មានពូជត្រកូលខ្ពង់ខ្ពស់ ជាមនុស្សបានទទួលការសិក្សាដ៏ល្អប្រសើរ ជាមនុស្សស្មោះ ត្រង់ចំពោះជាតិ សាសនា ព្រះមហាក្សត្រ ផែនទឹក ផែនដី ។

អាស្រ័យដោយការអប់រំនៅវត្តនេះហើយ បានជាប្រជាជនខ្មែរស្លូតត្រង់ សុភាពរាបសា ។

កុមារអាយុ ១២ ឆ្នាំ ត្រូវបួសជាសាមណេរសងគុណមាតា ។ បួសហើយ ត្រូវបន្តការសិក្សាទៅមុខទៀត ៖ រៀនសាមណេរវិន័យ រៀនធម៌សូត្រមន្ត រៀន លេខនព្វន្ត រៀនវិជ្ជាផ្សេងៗ តាមត្រូវការ ។ បើសាមណេរនេះ សឹកមកជាគ្រហស្ថ មានឈ្មោះមួយគេហៅថា « ជី » ។ដល់អាយុ ២១ ឆ្នាំ ត្រូវបួសជាភិក្ខុ រួចហើយមាន ការសិក្សាបន្តទៅទៀត ៖ រៀនវិន័យ រៀនធម៌អាថ៌ រៀនចំណេះវិជ្ជាផ្សេងៗ ខាងផ្លូវ លោកតាមត្រូវការ ។ បើនៅក្នុងវត្តខ្លួន ពុំមានការសិក្សាវិជ្ជាបច្ចេកទេសទេ សាម-

ណោរ ឬភិក្ខុ អាចលាគ្រូឧបជ្ឈាយ៍ទៅសិក្សាវិជ្ជាដែលខ្លួនត្រូវការ នៅវត្តដទៃទៀត ។ ក្នុងវត្តនីមួយៗ តែងមានកិច្ចការវត្ត ភិក្ខុសាមណេរ ក៏ត្រូវធ្វើកិច្ចការនោះៗ ការធ្វើនេះ ទុកដូចជាបាត់ហ្វឹករៀនធ្វើការនោះដែរ ។ ដទៃពីនេះ មានការសិក្សាជាន់ខ្ពស់ គឺរៀនសំណាក់ព្រះកម្មដ្ឋានស្មឹងស្មាធិ៍ ធ្វើចិត្តខ្លួនឱ្យបរិសុទ្ធ ផុតកិលេសក្ដីសៅហ្មង។ ខ្លះមានសទ្ធាវិរិយៈមាំមួន នៅជាអ្នកបួសតទៅ បានជាគ្រូសូត្រឆ្វេង-ស្ដាំ ជាចៅអធិ-ការ ។ ខ្លះមានសទ្ធា និងវិរិយៈទន់ខ្សោយ ក៏សឹកមកជាគ្រហស្ថវិញ គេហៅថា «អ្នក» ហើយក៏មានភរិយាទៅតាមប្រពៃណីអ្នកស្រុកតទៅ ។

ការសិក្សាដូចបានពោលមកនេះ ជារបៀបការសិក្សានៅត្រឹមសតវត្សទី ១៩ ។ របៀបសិក្សានេះ តាមការពិចារណាមើលឃើញថា មានមកតាំងពីសម័យព្រេងនាយ គឺពីសម័យមុនអង្គរ ។ សម័យមហានគរ ការសិក្សាហ្មត់ចត់ គ្រូសុទ្ធតែមានចំណេះវិជ្ជាខ្ពង់ខ្ពស់ ឯអ្នកសិក្សាក៏បានទទួលការចេះដឹងប្រសើរ គួរជាទីពេញចិត្ត ។

រៀបរៀងឃ្លាឃ្លោងឡើងវិញដោយ

**មៀច ប៉ុណ្ណ**

---

លោកថា ...

" បើជនណាចេះភាសាជាតិខ្លួនពុំច្បាស់ទេ

ជននោះពុំអាចចេះភាសាបរទេសប្រាកដឡើយ " [ជ.ប.ស្ងរ៍ (G.B. Shaw)]

តែបើ ...

" ជនណាពុំចេះភាសាបរទេស

ជននោះពុំអាចស្គាល់ភាសាខ្លួនបានច្បាស់ឡើយ " [ គ្វិត (Gœthe) ]

ឯកសារ

## និមិត្តរូបនិយមនៃ

# ប្រាសាទហិណ្ឌូ និង ប្រាសាទខ្មែរ

សិល្បៈខ្មែរ គឺជាសិល្បៈមួយចម្រុះ ដែលនៅក្នុងសិល្បៈនេះ គេអាចមើលឃើញមានឥទ្ធិពលជាច្រើន មកពីទិសខាងលិចក៏មាន មកពីទិសខាងកើតនៃប្រទេសខ្មែរក៏មាន ។

គេគប្បីធ្វើការកត់សម្គាល់ថា អារ្យធម៌ហិណ្ឌូ ដែលមានឥទ្ធិពលមកលើតំបន់ផ្សេងៗនៃចុងបូព៌ា ច្រើនមានចរិតជាសាសនា អក្សរសាស្ត្រ និងភាសាសាស្ត្រ, ហើយនេះត្រូវបានគេឃើញជាពិសេសតែនៅក្នុងប្រទេសកម្ពុជា, ប៉ុន្តែ អារ្យធម៌នេះមានប្រតិឃាតតិចតួចណាស់ ទៅលើទ្រង់ទ្រាយស្ថាបត្យកម្មនៃប្រាសាទ ។

ឥទ្ធិពលហិណ្ឌូ ត្រូវបានគេឃើញមាន នាសម័យដើមនៃសិល្បៈខ្មែរ នៅក្នុងប្រាសាទទាំងឡាយជំនាន់ដើម, ដែលគេច្រើនហៅថាសិល្បៈមុនអង្គរ, ជាសម័យកាល ដែលចាប់ពីសតវត្សទី៦ ដល់សតវត្សទី៩ ហើយដែលមានមុនសម័យកាល នៃប្រាសាទអង្គរ ឬ, តាមការនិយមជាទូទៅ, មានមុនសម័យកាល ហៅថាក្លាស៊ិក (La période dite classique) ដែលចាប់ផ្តើមពីសតវត្សទី៩ ដល់សតវត្សទី១៣ ។ នៅសម័យក្រោយនេះ, សិល្បៈខ្មែរបានក្លាយទៅជាសិល្បៈរបស់ផងខ្លួន ហើយបានផាត់ចោល ឬយ៉ាងហោចណាស់ បានកែសម្រួលប្រធានក្បាច់ ( Les motifs ) ឬទ្រង់ទ្រាយដែលទទួលយកមកពីឥណ្ឌា ។

ព្រោះហេតុនេះហើយបានជា គេពិបាករកអោយឃើញនៅក្នុងស្ថាបត្យ-កម្មទាំងអស់របស់ឥណ្ឌា នូវប្រាសាទណាមួយដែលរំលឹកអោយនឹកឃើញប្រាសាទតាកែវ ឬ ប្រាសាទអង្គរវត្តជាតួយ៉ាង ។

ជនជាតិខ្មែរបានបញ្ចូលថ្មី នូវទ្រង់ទ្រាយទាំងឡាយ ដែលគេពុំដែលស្គាល់នៅក្នុងប្រទេសឥណ្ឌា, ឬប្រសិនបើគេមិនបានច្នៃប្រឌិតទ្រង់ទ្រាយទាំងនោះទេ, គេសុខចិត្តទទួលយកទ្រង់ទ្រាយទាំងឡាយរបស់ប្រទេសនានា ក្រៅពីប្រទេសឥណ្ឌាវិញ, ពីព្រោះ គេមិនត្រូវភ្លេចទេថា ប្រទេសកម្ពុជាគឺជាកន្លែងឆ្លងកាត់ជាញឹកញយណាស់ នាដើមគ្រឹស្តសករាជ, បង្កើតបានទៅជាទីជួបជុំសម្រាប់អ្នកដំណើរ, អ្នកជំនួញ, អ្នកធ្វើបូជនិយេសន៍ ដែលបានធ្វើដំណើរមកពីទិសបស្ចិម ឆ្ពោះទៅប្រទេសចិន ឬពីប្រទេសចិនឆ្ពោះទៅបស្ចិមប្រទេស ។ គេពុំងឿងឆ្ងល់អ្វីទេថា ការនាំចូលធាតុបរទេសក្រៅពីឥណ្ឌា ត្រូវបានគេមើលឃើញនៅក្នុងសិល្បៈខ្មែរ ។ យើងមានភស្តុតាងអំពីរឿងនេះ នៅក្នុងការរកឃើញដ៏គួរអោយចាប់អារម្មណ៍របស់លោកម៉ាល្លើរ៉េ ( Malleret ) ជាសមាជិកសាលាបារាំងសែសចុងបូព៌ាប្រទេស, នៅក្នុងតំបន់មាត់សមុទ្រអតីតកម្ពុជា ត្រង់កន្លែងអុក-កែវ ( Oc-Eo ) ( អូ កែវ ? ) គឺជាទីកន្លែងក្រុងចាស់, ប្រហែលជារបស់ព្រះរាជាណាចក្រហ្វូណន ហើយក្រោយមកជាព្រះរាជាណាចក្រកម្ពុជា នាសតវត្សទី ៦ ។

យុទ្ធនាការជីកកកាយធ្វើនៅកន្លែងនោះ ដោយលោកម៉ាល្លើរ៉េ ក្នុងឆ្នាំ ១៩៤៤ បានរកឃើញវត្ថុជាចំនួនច្រើន មានអាគតដ្ឋានផ្សេងៗពីគ្នាណាស់, មានខ្លះមានដើមកំណើតរ៉ូម៉ាំង ដែលនេះជាការបញ្ជាក់បន្ថែមនូវអ្វីដែលខ្ញុំបាននិយាយនៅខាងដើម ។

ត្រឡប់មកនិយាយពីស្ថាបត្យកម្មខ្មែរវិញ គេអាចអះអាងថា អ្នកកសាងប្រទេសកម្ពុជា, ទន្ទឹមនឹងកសាងប្រាសាទទាំងឡាយថ្វាយព្រះអាទិទេពហិណ្ឌូ, គេក៏បានកែសម្រួលសមាសភាព, បច្ចេកទេស និង ការបកស្រាយអត្ថបទពិសិដ្ឋ ឬសិល្ប-សាស្ត្រ ដែលនៅក្នុងប្រទេសឥណ្ឌា ចាប់បង្ខំអោយអនុវត្តតាមក្បួនច្បាប់ជាដាច់ខាត ដែលអ្នកទាំងឡាយណាក៏ដោយ សាងសង់ប្រាសាទសាសនា ត្រូវតែគោរពតាមក្បួន

ច្បាប់នោះ ។

ម្យ៉ាងទៀត, វាពុំមានអ្វីធ្វើជាភស្តុតាងបញ្ជាក់ទេ ហើយចំពោះខ្លួនខ្ញុំផ្ទាល់, ខ្ញុំក៏មានសេចក្ដីសង្ស័យយ៉ាងខ្លាំងដែរថា តើមានស្ថាបត្យករ ឬជាងមកពីឥណ្ឌា បានមកធ្វើការនៅលើទឹកដីកម្ពុជា ហើយចូលរួមកសាងប្រាសាទដែរឬទេ ។

ដោយវិភាគស្ថាបត្យកម្មខ្មែរយ៉ាងល្អិតល្អន់ទៅ, បើខ្ញុំហ៊ានប្រើពាក្យនេះ, គេបានរកឃើញប្រធានក្បាច់ រូបមន្តទាំងឡាយដូចខ្ញុំបាននិយាយ, ដែលគេពុំដែលស្គាល់នៅក្នុងប្រទេសឥណ្ឌា ហើយដែលមានភាពដូចគ្នាយ៉ាងសុទ្ធសាធនឹងប្រធានក្បាច់ រូបមន្តទាំងឡាយ ដែលគេឃើញមាននៅអាស៊ីមីន័រ, នៅប្រទេសម៉េសូប៉ូតាមី ហើយថែមទាំងមាននៅក្នុងសិល្បៈក្រិក - រ៉ូម៉ាំង ទៀតផង ។ ខ្ញុំគ្រាន់តែលើកយកឧទាហរណ៍ ដ៏ល្បីល្បាញនៃក្បាច់ក្បាលសរសរក្លាស៊ិកខ្មែរ ដែលមានគំនូសកាត់ ( Profil ) ដូចគ្នាសុទ្ធសាធ ទៅនឹងគំនូស និងសិល្បៈក្រិក ដូចដែលគេអាចមើលឃើញនៅកូលីហ្ស៊េ ( Colisée ) ទីក្រុងរ៉ូម ។

ប្រធានក្បាច់ ស្ដីពីសត្វចតុប្បាទដាក់ប្រជល់មុខគ្នាលើផ្ទាំងចម្លាក់ច្រកទ្វារបង្អួចប្រាសាទបាយ័ន ឬ ប្រាសាទអង្គរវត្ត រំលឹកអោយឃើញប្រធានក្បាច់ដូចគ្នានឹងសាស្សានីដ ( sassanide ), (១) ប្រហែលជាសាស្សានីដខ្លួនឯង ត្រូវបានចម្លងមកពីសិល្បៈអេហ្ស៊េ ( L'art égéen ) ។

ឆ្លងមកពីទិសមួយផ្សេងគ្នា, គេសង្កេតឃើញមាននៅក្នុងសិល្បៈខ្មែរផងដែរ នូវប្រធានក្បាច់អូសេយានី, ដូចជាមុខបិសាច ដែលគេហៅថា រាហូ ហើយប្រហែលជាមានប្រភពមកពីលលាដ៍ក្បាល ដែលពួកអ្នកប្រមាញ់យកតែក្បាល នៅ

(១) sassanides សន្តតិវង្សពែរ ដែលគ្រប់គ្រងអាណាចក្រមួយលាតសន្ធឹងពីម៉េសូប៉ូ-តាមី មកដល់ទន្លេឥណ្ឌា, ពីឆ្នាំ ២២៤ / ២២៦ មកដល់ចំបាំងដណ្ដើមទឹកដី របស់ អារ៉ាប់ ឆ្នាំ (៦៥១) ។ ឈ.អ.

លើកោះមួយចំនួន នាផ្នែកខាងត្បូង បានចងដាក់លើទ្វារផ្ទះរបស់គេ ។ ដោយមិនបាច់និយាយដល់ប្រាសាទសង់បន្តុបបន្តអោយខ្ពស់នៅលើភ្នំមានរាងសាជី ដែលមាននៅក្នុងសិល្បៈបាប៊ីឡូន ក៏ដូចនៅក្នុងសិល្បៈម៉ាយ៉ាផងនោះទេ, គេក៏ឃើញមានប្រធានក្បាច់ជើងទៀនរាងមូល ដាក់កៀកគ្នាបិទជាបង្អួច ដែលជាលក្ខណៈពិសេសបំផុតនៃស្ថាបត្យកម្មប្រាសាទអង្គរ ហើយដែលគេឃើញមាននៅក្នុងប្រាសាទ ទាំងឡាយ នៃទ្វីបអាមេរិកកណ្តាល ។

ម្យ៉ាងទៀត, វាជាការគួរអោយជឿបានណាស់ថា នៅក្នុងប្រទេសខ្មែរសម័យបុរាណ អក្សរសិលាចារឹកត្រូវបានសរសេរជាភាសាសំស្ក្រឹត ហើយប្រាសាទទាំងឡាយកសាងឡើងឧទ្ទិសចំពោះព្រះសិវៈ, ព្រះវិស្ណុ ឬ ចំពោះព្រះពុទ្ធ, គេបានជឿហើយអាចសន្និដ្ឋានភ្លាម តាមរបៀបនិយាយម៉ោថា សិល្បៈខ្មែរទាំងអស់ចេញមកទាំងដុលពីប្រទេសឥណ្ឌា ហើយចម្លងតាមហិណ្ឌូ ។ ការនិយាយបែបនេះ គឺជាការមើលស្រាល ទាំងចរិតខ្មែរ ទាំងតន្ត្រនិស្ស័យរបស់ខ្មែរ ( Atavismes ) ។

ជនជាតិខ្មែរ មិនជាប់ពូជពីជនជាតិហិណ្ឌូទេ : ជនជាតិខ្មែរ គឺជាលទ្ធផលនៃការកាត់ពូជដ៏ច្រើន ដោយមានពូជជាមូលដ្ឋានគឺ ម៉ាឡាយូ-ឥណ្ឌូណេស៊ី ។ គេអាចដឹងបានម្យ៉ាងទៀត, នៅក្នុងទំនៀមទម្លាប់ និងប្រពៃណីរបស់ខ្មែរ ក៏ដូចជានៅក្នុងគ្រឿងសស្ត្រាវុធ ឬ ឧបករណ៍ដែលជនជាតិខ្មែរប្រើប្រាស់ដែរ ។

ជាលទ្ធផល វាបញ្ជាក់អោយឃើញថា តាមចិត្តគំនិត និងចរិតរបស់គេ, ជនជាតិខ្មែរ ខុសគ្នាទាំងស្រុង ពីអ្នកស្រុកទាំងឡាយនៅប្រទេសឥណ្ឌា ។ ជនជាតិខ្មែរ ធុញទ្រាន់ចំពោះបរមត្ថវិជ្ជា, ចំពោះអរូបិយកម្ម និងចំពោះទ្រឹស្តី ឬវិជ្ជាដែលពិបាកយល់ ឬ ដែលជាប្រស្នា ( Esotérisme ) ដែលកម្ពុជាង់សំខាន់ជាជំនឿរបស់សាសនាហិណ្ឌូ ។ ជនជាតិខ្មែរ មិនមែនជាជនជាតិដែលនិយមកាន់សាសនាតឹងរ៉ឹងទេ ហើយរឹតតែមិនមែនជាអ្នកកាន់ ឬជឿសាសនាពេកផងដែរ, គេគឺជាសិល្បករ ។ ជន

ជាតិខ្មែរ ចូលចិត្តពិធីបុណ្យ ចូលចិត្តការសប្បាយ ចូលចិត្តរបាំ និងតន្ត្រី ។ ជនជាតិខ្មែរ ពុំអាចផ្តាច់ខ្លួនចេញពីពិភពខាងក្រៅ ដើម្បីមកជ្រកសំងំនៅក្នុងពិភពផ្ទៃក្នុង និងក្នុងសមាធិ ដូចជាជនជាតិហិណ្ឌូកើតទេ ។ ដោយសារអធ្យាស្រ័យរបស់គេ, ខ្មែរមានចរិតប្រហាក់ប្រហែលគ្នានឹងជនជាតិទាំងឡាយខ្លះរស់នៅលើពួកកោះ នៅក្នុងសមុទ្រអូសេយានី ។ ចំពោះជនជាតិទាំងនោះ ការសប្បាយ និងរស់នៅ គឺជាហេតុផលនៃជីវិតរបស់ពួកគេ ។ ខ្ញុំមិនធ្លាប់ទៅដល់កោះហាវ៉ៃទេ, ទាំងមិនធ្លាប់ទៅកោះតាហ៊ីទីដែរ, ប៉ុន្តែក្នុងពេលស្នាក់នៅក្នុងកោះបាលី, ខ្ញុំបានសង្កេតឃើញពួកអ្នករស់នៅលើកោះនោះ មានសេចក្តីសប្បាយរីករាយដុះចេញពីកំណើត, ចូលចិត្តសម្តែងសិល្បៈ និងចូលចិត្តសប្បាយ និយាយអោយខ្លីទៅ គឺគេយល់អំពីជីវិត ដែលធ្វើអោយខ្ញុំនឹកឃើញប្រទេសខ្មែរ ។

វាពុំមែនជាការណ៍គួរអោយងឿងឆ្ងល់ទេថា ខ្មែរមានសន្តានចិត្តសាមញ្ញជាសិល្បករចូលចិត្តរូបភាពស្អាតល្អ មានការយល់ដឹងពីស្ថាបត្យកម្មនៃប្រាសាទទាំងឡាយខុសពីជនហិណ្ឌូ ដែលនិយមកាន់សាសនាយ៉ាងតឹងរ៉ឹង ហើយសម្រាប់ជនហិណ្ឌូសិល្បៈ គឺគ្រាន់តែជាទិដ្ឋភាពមួយជួយបង្ហាញអោយឃើញច្បាស់នូវសាសនាមួយ ដ៏ក្រអឺតក្រអោង ហើយស្មុគ្រស្មាញ ។

ប្រសិនបើគោលការណ៍នេះមិនប្រែប្រួលទេ, នោះសមិទ្ធផល ប្រាកដជាផ្សេងពីគ្នាយ៉ាងស្រឡះ ។

*គឺនិមិត្តរូប* ដែលគ្រប់គ្រង និងគ្របដណ្តប់លើស្ថាបត្យកម្មទាំងអស់នៃប្រាសាទឧទ្ទិសចំពោះសាសនានៅក្នុងប្រទេសឥណ្ឌា ។ ប្រាសាទ ត្រូវបានគេកសាងឡើងពីគំនូរថ្មដ៏ធំសម្បើម ដែលមានមុខងារតាងលោកធាតុ (Cosmos), តាងចក្រវាឡ ជាមួយនឹងភូតគាម, ពពួកសត្វ, សត្វលោក, ទេវលោក, មនុស្សលោក ពួកអសុរ ។

គឺលក្ខណៈនេះហើយ ដែលបង្ហាញនូវភាពសម្បូរហូរហៀរ នៃចម្លាក់ដែលមាននៅលើជញ្ជាំងហោជាង ក៏ដូចជានៅក្នុងបន្ទប់ខាងក្នុងដែរ ។

ចូលទៅក្នុងវិហារហិណ្ឌូ គឺដូចជាចូលទៅក្នុងពិភពមួយដ៏ចម្លែកអស្ចារ្យ និងមមើមមាយ, ដែលគេអាចពន្យល់បានតែតាមឆន្ទៈបង្កើតអោយមានចក្រវាឡមួយដូចក្នុងរឿងនិទាន និង ជានិមិត្តរូបប៉ុណ្ណោះ, ហើយមានតែអ្នកធ្លាប់ត្រិះរិះទេ ទើបអាចយល់បាននូវប្រស្នាដ៏ពិបាកយល់ទាំងនោះ ។

ស្ថាបត្យកម្មឥណ្ឌា គឺជាស្ថាបត្យកម្មមួយដ៏អាថិកំបាំង ដែលបង្កប់ក្នុងថ្ម នូវអត្ថន័យលាក់បំពួននៃអត្ថបទពិសិដ្ឋ ហើយដែលគេខិតខំធ្វើអោយអ្នកកាន់សាសនាអាចយល់បាន ។

ផ្ទុយទៅវិញ ប្រាសាទខ្មែរបង្ហាញស្ថាបត្យកម្មមួយដ៏សាមញ្ញ មានទិដ្ឋភាពស្ទើរតែជាក្លាស៊ិក ( Classique ) ស្របទៅនឹងអធ្យាស្រ័យរបស់យើងជាជនជាតិឡាតាំង ដែលស្គាល់បញ្ញត្តិរបស់ពួកគេ, ស្គាល់ទស្សនវិស័យរបស់គេ, ស្គាល់ច្រកល្ហករបស់គេ នៅក្នុងស្ថាបត្យកម្មនោះ ។

ជនជាតិខ្មែរ ចេះយកប្រធានក្បាច់ទាំងឡាយដែលនាំចូលមកពីប្រទេសឥណ្ឌា ហើយប្រើប្រាស់ប្រធានក្បាច់ទាំងនោះ ពុំមែនទុកជាបព្វជិតត្រូវគោរពនោះទេ, ប៉ុន្តែ ទុកជាអ្នកតែងលំអដ៏គួរអោយចាប់អារម្មណ៍ សម្រាប់អោយមានសុខុមភាព ជាមួយខ្សែបន្ទាត់ល្អៗ ក៏ដូចជា ជាមួយនិមិត្តរូបដែលប្រធានក្បាច់ទាំងនោះបានបង្ហាញ ។ សត្វចតុប្បាទទាំងនោះ, សត្វចម្លែកៗទាំងនោះ, ដែលនៅក្នុងប្រទេសឥណ្ឌា ត្រូវបានគេធ្វើអោយមានចលនាជាសត្វមានមហិទ្ធិឫទ្ធិដ៏ខ្លាំងក្លា, ត្រូវបានជនជាតិខ្មែរ យកវាមកបង្ហាញអោយទៅជាវោហារសិល្បៈ ហើយគេត្រូវតែទទួលស្គាល់ថា ជនជាតិខ្មែរចេះទាញយកមកប្រើយ៉ាងប៉ិនប្រសប់នូវសមាសភាគខ្លះ អំពីសោភណភាពស្ថាបត្យកម្ម ឬ សោភណភាពតែងលំអ ដែលជនជាតិហិណ្ឌូរវល់តែ

លង់លក់ក្នុងសុបិន ពុំដែលចេះធ្វើអោយសម្រេចបាននោះឡើយ ។

ខ្ញុំនឹងលើកយកឧទាហរណ៍ដែលគេស្គាល់គ្រប់គ្នា ហើយដែលគេបានកសាងឡើងជាញឹកញាប់នៅក្នុងស្ថាបត្យកម្មនៃប្រទេសខ្មែរនោះ គឺនាគ ។ សត្វនាគមានក្បាលច្រើននេះ ដែលជារចនាបថមួយបង្ហាញរូបពស់វែក, បង្កើតបានជាទិដ្ឋភាព ដែលបន្សីគ្នាទៅនឹងការតែងលំអស្ថាបត្យកម្មនៃប្រាសាទទាំងឡាយ នៅប្រទេសកម្ពុជា, ធ្វើជាបង្កាន់ដៃអមផ្លូវថ្នល់លើកចូលទៅកាន់ប្រាសាទ, សត្វនាគក្បាលច្រើននេះ ប្រកួតប្រជែញជាមួយនឹងទស្សនាទានតុបតែងលំអ ដែលប្រទេសអេហ្ស៊ីប និងប្រទេសអាស្ស៊ីរី (Assyrie) បានបន្សល់ទុកឱ្យយើង (ជនជាតិបារាំង) ។

ដូចគ្នាដែរ, ប្រធានក្បាច់ទាំងនោះ ដែលមានចរិតសាសនាជាពិសេស និងប្រើជានិមិត្តរូបនៅក្នុងប្រទេសឥណ្ឌា គឺគ្រុឌ, ដំរី, សឹង្ហ - ល - ។ នៅប្រទេសខ្មែរវិញ សត្វទាំងនេះបានក្លាយទៅជាហេតុផលយ៉ាងធម្មតា សម្រាប់ការតែងលំអប្រាសាទ វិហារ ប៉ុណ្ណោះ ។ រូបសត្វទាំងនោះ ត្រូវបានហ៊ុមព័ទ្ធដោយភ្ញីផ្កាតែងលំអដ៏សម្បូរ ហើយបង្កើតបានជាខ្សែប្រទាក់ឆ្វាក់គ្នា ឬក៏ផ្តាច់ទៅជាចម្លាក់ក្រឡោតជួយធ្វើអោយផ្នែកខាងមុខប្រាសាទមានទិដ្ឋភាពស៊ើមស្មៃ ។

នៅក្នុងប្រទេសឥណ្ឌា, ផ្នែកខាងក្នុង ក៏ដូចផ្នែកខាងក្រៅប្រាសាទដែរ គឺជានិមិត្តរូបតាងលោកធាតុ (Cosmos) ហើយបន្ទប់កណ្តាល (La cella) ដែលមានទេវរូបនៅខាងក្នុង គឺប្រដូចទៅនឹងអង្គទេវៈ ដែលផ្ទុកពន្លកពូជពិសិដ្ឋ ។ ប្រាសាទទាំងមូល មានជីវិត, ញាប់ញ័រ ហើយកម្រើក, ហើយចម្លាក់ទាំងអស់ ដែលពង្រាយយ៉ាងច្រើននៅលើជញ្ជាំង មានចលនាប្រកបដោយពលានុភាពដ៏រឹបឹង ។ សត្វចតុប្បាទ ឬ សត្វចម្លែកទាំងឡាយ ចំអើតឈរលើជើងក្រោយ, ជញ្ជ្រំជើងលើសាកសព, ទេវតា, ទេពអប្សរ ឱបប្រទាក់គ្នាជាគូៗ ជួនកាលប្រកបដោយភាពបរិសុទ្ធដ៏ត្រកាល ប៉ុន្តែ ជាញឹកញយដែរ ឋិតក្នុងសភាពមិនអាចពណ៌នាបាន ។ ចម្លាក់ទាំង

ឡាយនៅលើជញ្ជាំងប្រាសាទខ្មែរវិញ ច្រើនតែជាចម្លាក់ថិតវន្ត (Statique) ហើយធុញទ្រាន់ចំពោះកាយវិការកញ្ឆក់កញ្ឆែង និងឃោរឃៅ ។ ចំណែកភាពបរិសុទ្ធ នៃចម្លាក់ក្រឡោត (bas reliefs) ខ្មែរវិញ, គឺវាជាហេតុការណ៍មួយ ដែលគេស្គាល់ពេកទៅហើយ មិនចាំបាច់ពណ៌នាអំពីរឿងនេះទៀតទេ ។

នេះមិនមែនមានន័យថា និមិត្តរូបនេះ មិនមានប្រើនៅក្នុងស្ថាបត្យកម្មខ្មែរនោះទេ, អ្នកប្រាជ្ញទាំងឡាយ ដូចជាលោកហ្គោលូបេវ ( Goloubew ) លោកសឺដេស ឬ លោកមុស បានបោះពុម្ពផ្សាយការសិក្សាពិសេស ហើយយ៉ាងក្បោះក្បាយណាស់ ស្តីពីប្រធានបទនេះ, ប៉ុន្តែ និមិត្តរូបនេះឆ្លើយតបទៅនឹងលំដាប់នៃគំនិតទាំងឡាយផ្សេងក្រៅពីលំដាប់នៃគំនិត ដែលប្រាសាទទាំងឡាយនៃប្រទេសឥណ្ឌាបានបង្ហាញ ។

ប្រសិនបើអង្កែធំ (Le sanctuaire) ដែលជាលំនៅរបស់ព្រះអាទិទេពនៅប្រទេសឥណ្ឌា, នៅក្នុងទម្រង់ទាំងមូលរបស់ខ្លួនតាំងពីក្រោម រហូតដល់កំពូលជាតំណាងភ្នំព្រះសុមេរុ ដោយមានប្រធានក្បាច់និមិត្តរូបយ៉ាងច្រើន មានសត្វលោកគ្រប់ប្រភេទថ្លក់ទៅនឹងគ្រប់ក្បាច់ខ្សែ (Les moulures), នៅកម្ពុជាវិញ គឺពុំមែនតួប្រាសាទទេ ទាំងពុំមែនអង្កែធំដែរ ដែលតាងភ្នំព្រះសុមេរុនោះ ។ ភ្នំព្រះសុមេរុ ត្រូវបានគេបំប្រួញមកមានត្រឹមតែជាតួនាទីជាបាទដ្ឋាន (Piédestal=ជើងទ្រ), ជាគំនររាងសាជីមានថ្នាក់ៗ (Pyramide à gradins), គ្មានការតែងលំអអ្វីក្រៅពីមានសត្វរាជសីហ៍ ឬ សិង្ហ ប្រចាំនៅជ្រុងខឿនជណ្តើរ ឬ ជួនកាលមានរូបសត្វដំរី នៅលើជ្រុងនៃថ្នាក់ទាំងឡាយ ។

និយាយដោយខ្លីមក, នៅប្រទេសឥណ្ឌា អង្កែធំ (Le sanctuaire) គឺឋិតនៅជាន់ក្រោមផ្ទាល់ដី ឬឋិតនៅលើលានតូចមួយ (Une petite terrasse) មិនសូវខ្ពស់ពេកទេ : នៅស្រុកខ្មែរវិញ អង្កែធំ ឋិតនៅលើកំពស់មួយ ជួនកាលខ្ពស់

ជាងទីដីជុំវិញ ហើយមានខឿនថ្នាក់បន្តុបបន្តបន្ទាប់ៗ ( des séries de soubassements étagés) ពន្លេចចេញទៅក្នុងលំហរអាកាស នូវកំពូលស្រួច ដែលមានទេវរូបនៅខាងក្នុង ។ នេះហើយ ដែលលោកហ្វីលីពស្ទើន អោយឈ្មោះថា " ប្រាសាទភ្នំ " ( le temple montagne ) ។

ទីបំផុតទៅ, ប្រាសាទនៅក្នុងប្រទេសឥណ្ឌា ត្រូវបានគេសាងឧទ្ទិសចំពោះទេវៈ ដែលគេរួមបញ្ចូលទិដ្ឋភាពមួយរបស់ព្រហ្មណ៍, ជាព្រះដ៏កំពូល ឧប្បត្តិកឯងហើយគ្មានរូបរាងទេ : យើងឋិតនៅក្នុងបរិយាកាសឋានសួគ៌ និងជាឋានដែលមានតែក្នុងរឿងនិទាន ។ នៅប្រទេសខ្មែរវិញ, យើងចុះមកនៅលើផែនដី, អាទិទេពដែលនៅក្នុងអង្គរធំ គឺជារូបតាងព្រះមហាក្សត្រនៃព្រះរាជាណាចក្រ និងតាងព្រះរាជអាជ្ញា ។

ព្រះរាជា គឺជាអាទិទេពនៅលើផែនដី, ប្រដូចទៅនឹងទេវៈមួយអង្គ ក្នុងចំណោមទេវៈទាំងឡាយរបស់ទេវដ្ឋានព្រាហ្មណ៍ (un panthéon brahmanique) ។ ទេវៈទាំងឡាយនោះ ស្នាក់អាស្រ័យនៅលើបពិតដ៏ពិសិដ្ឋនៃភ្នំសុមេរុ, និវេសនដ្ឋាន ដែលនៅក្នុងនេះ មានតម្កល់កំពូលព្រះរូបទេវរាជ ក៏ត្រូវបានគេសាងឡើង នៅលើដីខ្ពស់ជារាងសាជី មានថ្នាក់៧ដែរ ។

ប៉ុន្តែ ជាការណ៍គួរអោយចង់ដឹងណាស់ថា, និមិត្តរូបនិយមហិណ្ឌូ ស្ដីពីប្រាសាទលោកធាតុនេះ ( Temple cosmos ), ជាតំណាងចក្រវាឡ, លុះដល់មកនៅប្រទេសខ្មែរ, និមិត្តរូបនិយមនេះ គេមិនយកទៅអនុវត្តចំពោះការកសាងប្រាសាទដោយផ្ទាល់ទេ, ប៉ុន្តែ គេបែរជាយកមកអនុវត្តចំពោះទីប្រជុំជន ( des ensembles ), ចំពោះផែនទីនៃក្រុង (អង្គរធំ), ចំពោះអាងទឹក (នាគព័ន្ធ) ទៅវិញ, គេអាចនិយាយថា គឺជាទេវកថារបស់ហិណ្ឌូ ដែលគេធ្វើអោយបានសម្រេចទៅជានគរោបនីយវិទ្យា ( វិជ្ជា ឬ វិធីតុបតែងទីក្រុង ) ។

តួយ៉ាងប្រាសាទបាយ័ន ដែលឋិតនៅកណ្ដាលក្រុងអង្គរធំ គឺជានិមិត្តតំណាងភ្នំព្រះសុមេរុ ដែលជានិវេសនដ្ឋាននៃព្រះបាទជ័យវរ្ម័នទី៧, ព្រះអង្គទ្រង់បានគិតគូរ ហើយកសាងប្រាសាទនេះ, កសាងកំពែងទីក្រុង, កសាងគូ (ឬស្នាមភ្លោះ) ដែលហ៊ុំព័ទ្ធកំពែង គឺជានិមិត្តរូបតំណាងមហាសាគរ និងបពិត (ភ្នំ) ដែលព័ទ្ធជុំវិញផែនដី ។ ដើម្បីបញ្ជាក់លើភាពផ្សេងគ្នា នៃការបកស្រាយនិមិត្តរូបនិយមនៅប្រទេសខ្មែរ និងនៅប្រទេសឥណ្ឌា, ខ្ញុំសូមធ្វើការកត់សម្គាល់ថា នៅក្នុងប្រទេសឥណ្ឌា ខ្ញុំមិនដែលបានស្គាល់ប្រាសាទ ឬ សារព័នសំណង់ (ensemble de constructions) ណាដែលមានគូ (ស្នាមភ្លោះ) ជាប់គ្នា មានជាថ្នាក់ៗព័ទ្ធជុំវិញ ដូចដែលគេឃើញមានយ៉ាងច្រើននៅក្នុងស្ថាបត្យកម្មខ្មែរទេ ។

នៅមានសល់សមិទ្ធកម្ម ជានិមិត្តរូបក្រោយមួយទៀត ដែលធ្វើអោយលេចច្បាស់ថែមទៀត នូវចរិតរាជះ ជាមួយនឹងចរិតទេវៈនៃប្រាសាទចុងសម័យក្លាស៊ិក នៅប្រទេសខ្មែរ ។ នោះគឺប្រាសាទដ៏ធំស្កឹមស្កៃ ច្របូកច្របល់ ហើយច្រងេងច្រងាង, ប្រសិនបើគេឈរលើទស្សនៈស្ថាបត្យកម្ម ។ ប្រាសាទនោះ គឺប្រាសាទបាយ័ន ។ រអ្នកផងទាំងពួងរបែងស្គាល់, ទោះបីជារូបគូរ ឬ ថតក៏ដោយ, នូវប៉មលំររដោយមុខធំគ្រមាំង មានមាត់ញញឹមដ៏អាថិកំបាំង ដែលលេចខ្ពស់ឡើងនៅគ្រប់ជ្រុង, គ្រប់ជាន់ថ្នាក់តែដដែលៗ ស្ទើរក្លាយទៅជាការមមើមមាយ ។ ដំបូង គេបានបកស្រាយមុខទាំងនោះថា ជាមុខរបស់ព្រះព្រហ្ម ពីព្រោះ អាទិទេពនេះ មានព្រះភក្ត្របួន ៖ ប៉ុន្តែ លុះដល់អ្នកបន្តការងារក្រោយខ្ញុំ គឺលោកទ្រូវេ ( Trouvé ) បានជីកកកាយនៅខាងក្រោមរូបនៅកណ្ដាលគេ, ហើយបានរកឃើញព្រះពុទ្ធរូបដ៏ល្អ មួយគ្រឿង ដែលមានកម្ពស់ជិតបួនម៉ែត្រនោះ, ការបកស្រាយថ្មីមួយ ក៏ត្រូវបានកើតឡើង ។ រូបបដិមានោះ, តាមលោកសឺដេស, គឺអាចជាការលើកព្រះឋានះព្រះបាទ

ជយវរ្ម័នទី ៧ ជាអ្នកកសាងប្រាសាទនេះអោយទៅជាអាទិទេព ដែលចរិតលក្ខណៈរបស់ព្រះអង្គ ត្រូវបានគេមើលឃើញដោយច្បាស់នៅលើកំពូលប៉ម ក្រោមទិដ្ឋភាពព្រះពោធិសត្វលោកេស្វរៈ ។ ព្រះភក្ត្រដ៏ច្រើន បែរឆ្ពោះទៅទិសទាំងបួន ឆ្លើយតបទៅនឹងអរូបិយកម្មមួយ ៖ គឺព្រះរាជានុភាពប្រសិទ្ធិពរជ័យអោយដល់ទឹកដី ក្នុងទិសទាំងបួននៃប្រទេស ។ ចំពោះព្រះភក្ត្រទាំងបួនដដែលៗ នៅលើ ប៉មនិមួយៗវិញ, លោកប៉ូល មុស (M. Paul Mus) ពន្យល់រឿងនេះ យ៉ាងក្បោះក្បាយ ទៅតាមចរិតនៃរូបបដិមាជាទីសក្ការៈ ដាក់នៅក្នុងប្រាង្គតូចៗ ( chapelles ) ជាប់នឹងប៉មទាំងនោះ ៖ គោររូបទាំងនោះ ( idoles ) តំណាងចរិតលក្ខណៈនៃព្រះអង្គម្ចាស់ (Princes) និងអ្នកមានបណ្ដាសក្តិ ដែលទុកដូចជាទេវៈ ឬក៏តំណាងទេវៈក្នុងស្រុក ។ « ប៉មនិមួយៗ គឺជាតំណាងខេត្តនិមួយៗនៃព្រះរាជាណាចក្រ ដោយឥតសង្ស័យឡើយ, ឬក៏ប្រសើរជាងនេះ, តំណាងមជ្ឈមណ្ឌលសាសនា និង រដ្ឋបាលរបស់ខេត្ត ។ ដូច្នេះ ប្រសិនបើមុខទាំងបួន ជានិមិត្តរូបតំណាងព្រះរាជានុភាព ដែលថែងចាំងទៅលើដែនដី, ការតម្កល់ទុកមុខទាំងបួននោះអោយឋិតនៅពីលើការគោរពបូជា, និងនៅពីលើទីកន្លែងផ្ទាល់របស់ខេត្តនិមួយៗ, នោះប្រហែលជាមានន័យយ៉ាងងាយថា ព្រះបាទជ័យវរ្ម័នទី៧ គឺជាព្រះរាជានៅក្នុងខេត្តនោះៗ ក៏ដូចជា នៅអង្គរដែរ ។ ដោយប្រការនេះហើយ ទើបមានការចាំបាច់ធ្វើអោយប៉មមានមុខច្រើនអោយប៉មនិមួយៗ ស្របជាមួយនឹងដែនដីមួយផ្នែករបស់ព្រះរាជាណាចក្រ (១) ។ »

ចាកចេញអំពីនិមិត្តរូបនិយមដ៏អាថ៌កំបាំង និងផុតដើងពីដី ដែលយើងបាន

(១) ចូរអាន " pour mieux comprendre Angkor ", par Georges Coedes pp 142 et 143 "

ដាក់ស្លាបព្យាកម្មហិណ្ឌូ នៅក្នុងប្រភេទនេះ, ឥឡូវ យើងចុះមកដល់និមិត្តរូបនិយម រដ្ឋបាល និងសុរិយោដីវិញម្ដង - បើខ្ញុំអាចនិយាយយ៉ាងនេះបាន - ដោយបង្វែរការ បកស្រាយរបស់លោកប៉ូល មុស បន្តិច ។

ពេលនេះ យើងជួបគ្នានៅអង្គរ នៅកណ្ដាលអាងទឹកមួយ ដ៏ជានិមិត្តរូប និយមលោកធាតុនៅក្នុងកូនប្រាសាទតូចមួយ ដែលគេបានឧទ្ទិសចំពោះព្រះពោធិសត្វ ជាគ្រូព្យាបាលជំងឺ ហើយដែលពីដើមជាកន្លែងសម្រាប់បួជនិយេសន៍ ។ កូនកោះនេះ ត្រូវបានព័ទ្ធជុំវិញដោយនាគពីរ ដែលបានផ្ដល់ឈ្មោះអោយកោះនោះថា : នាគព័ន្ធ ។ ពស់ឆ្វាយរង្វេល បង្កើតបានទៅជាបឹងធំដ៏ពិសិដ្ឋពុទ្ធសាសនា, អនវតប្ត ។ បឹងនោះ ផ្ដល់កំណើតដល់ទន្លេទាំងបួន ហូរចេញមកតាមក្បាលពោ, ដំរី, សេះ និងគោ; នៅ អង្គរ គេឃើញក្បាលទាំងនោះធ្វើជាមាត់ទបង្ហូរទឹកនៅក្នុងសំណង់តូចៗ ជាឧប-សម្ព័ន្ធ ដែលស្របទៅនឹងអាងទឹកបួននៅពីខាង, ប៉ុន្តែ ក្បាលមនុស្ស ត្រូវបានជំនួស ក្បាលគោទៅវិញ ។

ដើម្បីបញ្ចប់ ចូរយើងកត់ចំណាំថា ឥឡូវនេះ គេបានយកជាការណ៏ពិត ថា ប្រាសាទធំៗ របស់ខ្មែរ គឺជាប្រាសាទសម្រាប់ធ្វើបុណ្យខ្មោច ហើយពុំមែនជាផ្នូរ ទេ, ពីព្រោះ វាពុំមែនជាការណ៍ពិតទេ ដែលថាអដ្ឋិធាតុរបស់ព្រះរាជាទាំងឡាយ ត្រូវ បានគេតម្កល់ទុកនៅទីនោះ ក្រោយពេលបូជាសពរួច ។

ប្រាសាទទាំងឡាយនោះ ត្រូវបានគេសាងសង់ឡើង ដើម្បីជាកិត្តិយស ថ្វាយចំពោះព្រះរាជាសោយទីវង្គត, ហើយជួនកាលគេឧទ្ទិសថ្វាយនៅពេលព្រះរាជា គង់ព្រះជន្មនៅឡើយ ។ ព្រះអង្គនឹងត្រូវទទួលបច្ឆាមរណនាម និងទិដ្ឋភាពជាអាទិ ទេពណាមួយ ក្នុងបណ្ដាអាទិទេពរបស់ទេវដ្ឋានហិណ្ឌូ ។ ព្រោះហេតុនេះហើយ, បើតាមលោកសឺដេស ថា រូបបដិមា ដ៏មានចំនួនច្រើនរបស់ព្រះវិស្ណុ សិវៈ និង អាទិទេព ដទៃទៀតរបស់ឥណ្ឌា ដែលត្រូវបានគេរកឃើញ នៅពេលត្រួសត្រាយព្រៃ

ចេញពីប្រាសាទទាំងឡាយរបស់ខ្មែរ, បង្ហាញអោយឃើញដោយរបៀបមិនចំពោះមួយ នូវមហាបុរសរបស់ទេវដ្ឋានហិណ្ឌូ ។

« រូបភាពទាំងនោះ គឺភាគច្រើនជារូបភាពនៃព្រះរាជា, ព្រះអង្គម្ចាស់ ឬ អ្នកមានបណ្ដាស័ក្តិធំៗ ដែលគេធ្វើជារូបរាងមុខនៃអាទិទេព ។ ព្រះអង្គ ឬ អស់លោកទាំងនោះ បានភ្ជាប់ខ្លួនទៅនឹងអាទិទេពរួចហើយ ឬ នឹងភ្ជាប់ខ្លួនក្រោយពេលបញ្ចប់ជីវិតនៅលើផែនដីនេះ ។ ព្រះនាមរបស់រូបបដិមាជាទូទៅ គឺជានាមផ្សំដោយព្រះនាមរបស់ព្រះរាជា ឬ ផ្សំឈ្មោះរបស់អស់លោកទាំងនោះភ្ជាប់ជាមួយនឹងនាមរបស់អាទិទេព ។ ប្រការនេះ ចង្អុលយ៉ាងច្បាស់ថា គឺជាការគោរពបុគ្គល ( Culte personnel ) » (១) ។

ការគោរពនេះ និងការផ្ដល់កិត្តិយសដ៏ឧត្តុង្គឧត្តមថ្វាយចំពោះព្រះរាជា ដែលត្រូវបានលើកឋានៈជាអាទិទេព មិនសូវឃើញមាននៅក្នុងប្រទេសឥណ្ឌាទេ, ប៉ុន្តែ គេឃើញមាននៅជ្វា ( Java ) និងបាលី ( Bali ) ។

វាហាក់ដូចជាសេចក្ដីថ្លៃថ្នូរ ( l'orgueil ) របស់ស្ដេចប្រទេសខ្មែរ បញ្ចប់នៅត្រឹមឈោងចាប់យកទីបំផុត ( atteindre le paroxysme ) ដែលមិនគួរចាប់យកទៅវិញ ដោយមិនរវល់ដល់ការស្រុតចុះដុនដាបរបស់ខ្លួន ; អ្នកជិតខាងដ៏គួរអោយខ្លាច, ស្រេកឃ្លានទ្រព្យសម្បត្តិ ដែលគរទុកក្នុងព្រះរាជវាំងរបស់ស្ដេចខ្មែរ ហើយនៅពេលជាមួយគ្នានេះ គេចង់សងសឹកចំពោះការលុកលុយ និងបរាជ័យដែលគេបានទទួលនៅក្នុងដែនដីរបស់គេផ្ទាល់ផង, ដូចដែលចម្លាក់ក្រឡោត ( les bas reliefs ) នៅបាយ័ន និងសិលាចារឹកបានបន្សល់ទុកអោយយើង នូវអនុស្សាវរីយ៍អំពីរឿងនេះស្រាប់, គេក៏ធ្វើការវាយលុកចូលទៅក្នុងព្រះរាជធានី ។ ការស្រុតចុះដុនដាប ក៏ចាប់ផ្ដើមតាំងពីពេលនោះមក ហើយអរិយធម៌ ដ៏ត្រចះត្រចង់

Pour mieux comprendre Angkor, par Georges Coedes p 43

របស់ខ្មែរ ចាប់រលំរលាយបន្តិចម្តងៗ ក្រោមការចូលលុកលុយផ្ទួនៗ របស់សត្រូវមកពីខាងក្រៅ ។

Henri Marchal ( ហង់រី ម៉ារសាល )
in France Asie No. spécial 37 - 38 - 1949

បកប្រែ **ឈន រមៀម**

*ឈ្មួញទឹកពិតពឹងទូក* *រីឈ្មួញគោកពឹងរទេះ*
*សំណាងពឹងចំណេះ* *ប្រាជ្ញប្រាយចេះពឹងគម្ពីរ ។*
*ព្រះសង្ឃពឹងវិន័យ* *សត្វភពត្រៃពឹងធរណី*
*សេនាពឹងឫទ្ធី* *ឯអ្នកជីពិតពឹងវត្ថុ ។*
*រីមូលពឹងក្រឡឹង* *រីឯត្រង់ពឹងបន្ទាត់*
*កិរិយាពឹងសំពត់* *រីបរិសុទ្ធពិតពឹងសីល ។*
*សត្វឃ្មាតពិតពឹងរុយ* *សាច់សត្វស្អុយពឹងអំបិល*
*មង្គលពឹងពពិល* *រក្សាសីលពិតពឹងទាន ។*

" **ច្បាប់ហែមហាជន** "

# របៀបទស្សន៍ទាយទឹកភ្លៀង

ដោយផ្សារភ្ជាប់ជីវិតទៅនឹងការងារកសិកម្ម ដាំដុះ ប្រជាកសិករខ្មែរ ត្រូវការទឹកភ្លៀងជាចាំបាច់បំផុត ។ ដូច្នេះ ដើម្បីតម្រូវកិច្ចការភ្ជួររាស់ សាប ព្រោះ ដក ស្ទូង អោយស៊ីសង្វាក់គ្នានឹងរបបទឹកភ្លៀង កសិករខ្មែរបុរាណ មាន ចំណេះដឹង នឹងមានបទពិសោធន៍ខ្លះៗ ក្នុងការទស្សន៍ទាយ ឬក៏អាចដឹងទុកជា មុនអំពីរបបទឹកភ្លៀងក្នុងរដូវនេះ ក៏ដូចជារដូវក្រោយ ។ វាពិតណាស់ហើយថា ការទស្សន៍ទាយតាមបែបពិសោធនិយម (empirique) នេះ មិនអាចត្រឹមត្រូវ បាន ១០០ % ទេ ទោះបីផ្នែកឧតុនិយម ដែលមានរបៀបព្យាករណ៍ តាមបែប វិទ្យាសាស្ត្រ ក៏ទស្សន៍ទាយធាតុអាកាសនៅខុសឆ្គងខ្លះៗដែរ ។ ដូច្នេះ ទោះជា ត្រឹមត្រូវត្រឹមកំរិតណា ឬ មិនត្រឹមត្រូវក៏ដោយ ក៏យើងសូមលើកយករបៀប ទស្សន៍ទាយទឹកភ្លៀងនេះ មកជំរាបជូនជនានុជនជំនាន់ក្រោយ ដើម្បីបានជា ពន្លឺក្នុងការសិក្សាស្រាវជ្រាវអំពីជំនឿ ប្រពៃណី ទំនៀមទម្លាប់ខ្មែរយើងពី បុរាណផង ។

## I. ទស្សន៍ទាយភ្លៀងតិច - ច្រើន

### ១/. របៀបទស្សន៍ទាយដោយមើលជើងមេឃ :

នៅពេលព្រលឹមស្រាងៗ នាទិសខាងកើតជាប់នឹងជើងមេឃ បើកាល ណា គេឃើញមានពពកខ្មៅ(១) ជាជួរ លាតសន្ធឹងយ៉ាងវែង ស្របនឹងបន្ទាត់ជើង

(១) គេហៅថា ភ្នំទឹក ឬ ភ្នំយោង ក៏បាន

មេឃ ឬឃើញដុំពពកខ្មៅជាផ្ទាំងធំ នោះជាសញ្ញាថា ថ្ងៃនេះនឹងមានភ្លៀងធំ ពិសេសពេលរសៀល ។

*២/. របៀបទស្សន៍ទាយតាមកំដៅធាតុអាកាស :*

ចាប់ពីពេលថ្ងៃពេញពន្លឺ រហូតដល់ថ្ងៃជ្រៀលជ្រេ ប្រសិនបើធាតុអាកាសក្តៅខ្លាំង ហើយស្អុះស្អាប់ ស្ងប់ ឈប់ខ្យល់, នោះគេទាយថា ថ្ងៃនេះនឹងមានភ្លៀងធ្លាក់ច្រើន ជាមិនខាន ។

*៣/. របៀបទស្សន៍ទាយដោយពិនិត្យសកម្មភាពសត្វ :*

ចាស់ព្រឹទ្ធាចារ្យខ្មែរយើង ចេះវិធីសង្កេតសត្វស្រមោចដែលធ្វើសកម្មភាពពាំពង . ពាំចំណីរបស់វា តម្រៀបគ្នាវារដង្ហែរជាជួរវែងចេញពីសំបុក ឬពីរន្ធក្នុងដីឡើងតាមសសរផ្ទះ ។ សកម្មភាពបែបនេះ ធ្វើអោយគាត់ដឹងថា យ៉ាងយូរណាស់ ពីរបីថ្ងៃទៀតនឹងមានភ្លៀងធំ ជាប្រាកដ ។ ម្យ៉ាងទៀត នៅពេលថ្ងៃត្រង់ បើព្រះអាទិត្យបញ្ចេញចំហាយក្តៅយ៉ាងខ្លាំង ហើយគេឮគីង្គក់យំ «ក្រត១»[(១)] នោះគេដឹងថានឹងមានភ្លៀងធ្លាក់ហើយ ។

*៤/. របៀបទស្សន៍ទាយដោយពិនិត្យក្រយៅឈ្លូក[(២)] :*

---

(១) ជួនកាលកូនក្អាត់យំនៅក្នុងស្រែ ពេលថ្ងៃត្រង់កំពុងក្តៅខ្លាំង ក៏គេទាយថានឹងមាន ភ្លៀងដែរ ។ (២) គេហៅថា អំបោះខ្មោច ក៏បាន ។ អ្នកស្រុកខ្លះ(កោះធំ)ហៅថា អំបោះព្រះ ។

* មានមតិចាស់ៗខ្លះ បានពោលមកតៗគ្នាថា នៅនាស្ថានកៃលាស ស្តេចនាគរាជដែលមានភារៈផ្តល់ទឹកភ្លៀងប្រចាំឆ្នាំមកអោយមនុស្សលោក បានលេងទឹកយ៉ាងសប្បាយនៅក្នុងស្រះបោក្ខរណី ។ ពេលហែលមុជ បត់បែន ប្រែប្រួលខ្លួនចុះឡើងនោះ ស្តេចនាគរាជវាសរវ័ធកន្ទុយទៅលើដើមឈ្លូក ធ្វើអោយដាច់ពាសពេញស្រះ ។ ដូច្នេះហើយបានជាជ័រ ដែលហៀរចេញពីដើមឈ្លូកនេះ បានរសាត់រណ្តែកហោះហើរតាមខ្យល់ ធ្លាក់មកស្ថានកណ្តាលយើងយ៉ាងច្រើន នាំអោយយើងរាល់គ្នាបកស្រាយទៅតាមការយល់ប្លែកៗគ្នា ក្នុងការទស្សន៍ទាយទឹកភ្លៀង ។

បើភ្លៀងកំពុងធ្លាក់ជាប់ពីរ-បីថ្ងៃ ហើយគេឃើញក្រយៅឈ្លូកធ្លាក់ពីលើមេឃ នោះគេកំណត់ថានឹងរាំងភ្លៀង ។ តែបើកំពុងរាំង ហើយឃើញក្រយៅឈ្លូកធ្លាក់ នោះគេទាយថានឹងមានភ្លៀងវិញ ។

*៥/ . របៀបទស្សន៍ទាយដោយពិនិត្យខ្យល់ជំនោរ*[១] :

នៅពេលកំពុងរាំង បើកាលណាគេសង្កេតឃើញមានខ្យល់ជំនោរបក់មករឹង១ជាប់ចំនួនប៉ុន្មានថ្ងៃនោះ គេដឹងថា នៅរវាងប៉ុន្មានថ្ងៃខាងមុខ នឹងមាន « ភ្លៀងរលឹម » ចំនួនប៉ុណ្ណោះថ្ងៃដែរ ។

*៦/ របៀបទស្សន៍ទាយទឹកភ្លៀងប្រយោលពេល*[២] :

*(ក) ដោយពិនិត្យផ្កាឈើ*

ក្នុងចំណោមរុក្ខជាតិទាំងប៉ុន្មាន ចាស់បុរាណលោកកំណត់យកតែផ្កាអំពិល ឬ ផ្កាស្វាយប៉ុណ្ណោះ ធ្វើជាគោលនៃការនិនិត្យ ។ ធម្មតា អំពិលតែងចេញផ្កានៅរដូវដើមឆ្នាំ ។ កាលណាគេឃើញអំពិលចេញផ្កាច្រើនស្គុសស្គាយពេញទាំងដើម, ហើយ ចេញផ្កាស្រុះគ្នា ពុំមានរកេតរកូត ខ្លះមុន ខ្លះក្រោយ នោះគេសន្មតថា ឆ្នាំនេះ (រដូវខាងមុខ) នឹងមានភ្លៀងធ្លាក់យ៉ាងបរិបូណ៌, របរកសិកម្មនឹងផ្តល់ផលច្រើន ។ ផ្ទុយទៅវិញ បើអំពិលចេញផ្កាបន្តិចបន្តួចដោយមែកខ្លះ១ ជួនកាលមែកមុនចេញក្តិបទៅ ហើយមែកក្រោយទើបតែចេញផ្ការដាច់រដោចបន្តបន្ទាប់ បាតុភូតបែបនេះ គេដឹងថា ឆ្នាំនេះភ្លៀងធ្លាក់តិច ហើយមិនទៀងទាត់ ។ ដំណាំគ្រប់ប្រភេទ ច្បាស់ជាមិនហុចផលល្អឡើយ ។

*ខ/ តាមការពិនិត្យសត្វព្រៃ*

ជាធម្មតា ជនបទភាគច្រើននៅស្រុកស្រែយើង តែងតែផ្សារភ្ជាប់ជីវិត

(១) ខ្យល់ជំនោររដូវវស្សា ច្រើនបក់មកពីទិសខាងត្បូង ឬពីនីរតី ។

(២) ទាយក្នុងរដូវនេះ ឬ រដូវក្រោយ ។

ទៅនឹងចម្ងជាតិព្រៃភ្នំនានា ។ បណ្ដាកសិករចូលចិត្តទៅដេញសត្វ បណ្ដើរឆ្ពោះតាមទ្រូងព្រៃ លើភ្នំ រកអណ្ដើក ដេញត្រកួត សំពោច ជ្រូកព្រៃ ឈ្លូស ប្រើស ក្ដាន់ រមាំង ជាដើម ។ ជួនកាល ពួកផ្ញើរព្រៃទាំងនេះ ដេកសម្រាក ដាំបាយបរិភោគនៅក្នុងព្រៃ[១] នោះទៀតផង ។ នៅពេលដេញសត្វ គេច្រើនតែចាប់បានកូនត្រកួតតូចៗ[២] ដែលមេរត់ចោល ឬក៏រអិលជើងធ្លាក់ពីលើមែកឈើ ។ គេយកកូនត្រកួតមកប្រជុំគ្នាពិនិត្យមើលតាំងពីគល់កន្ទុយ (ដើមឆ្នាំ) ពាក់កណ្ដាលកន្ទុយ (ពាក់កណ្ដាលឆ្នាំ) ចុងកន្ទុយ (ចុងឆ្នាំ)[៣] ។ ធម្មតា កន្ទុយត្រកួតមានពីរពណ៌គឺ ខ្មៅ និង ស ឆ្លាស់គ្នាដូចជាចង្កាំកាំបិត ។ ពណ៌ខ្មៅ ជាសញ្ញាទឹកភ្លៀង ឯពណ៌ស ជាសញ្ញារាំងភ្លៀង ។ កាលបើពិនិត្យឃើញថា នៅគល់កន្ទុយមានពណ៌ខ្មៅវែងជាងពណ៌ស នោះគេទាយថា នៅដើមឆ្នាំមានភ្លៀងច្រើន ។ រួចគេពិនិត្យនៅពាក់កណ្ដាលកន្ទុយ និងចុងកន្ទុយ មើលអោយដឹងថា តើមានពណ៌អ្វីធំជាងពណ៌អ្វី រួចទើបគេទាយតាមនោះទៅ ។ ឧទាហរណ៍ បើនៅពាក់កណ្ដាលកន្ទុយ មានចន្លោះពណ៌សច្រើនជាងពណ៌ខ្មៅ គេទាយថា នៅពាក់កណ្ដាលឆ្នាំមានភ្លៀងតិច ឬ រាំងភ្លៀង ។ បើនៅចុងកន្ទុយ មានពណ៌ខ្មៅវែងជាងពណ៌ស ឬ មានសុទ្ធតែខ្មៅរហូតដល់ចុង គេទាយថា នៅចុងឆ្នាំនឹងមានភ្លៀងច្រើន ។

### *គ/ របៀបទស្សន៍ទាយទឹកភ្លៀងតាមការផ្សងទៀននៅក្នុងពិធីសំពះព្រះខែ*

អាចារ្យដែលមាននាទីចាត់ចែងកម្មវិធីបុណ្យសំពះព្រះខែ បានបង្គាប់អោយសរសេរដាក់ឈ្មោះខេត្ត នៅលើទៀននីមួយៗ ។ នៅពេលដែលទៀនកំពុង

---

(១) គេច្រើនសម្រាកនៅក្នុងគុហាចាស់សម័យបុរេប្រវត្តិសាស្ត្រ ឬ ដេកលើធ្នះដើម្បីបង្ការសត្វសាហាវ ។ (២) កាលវានៅតូច គេហៅថា «តម្រាព្រៃ» គឺទុកវាជាក្បួនសំរាប់ទាយទឹកភ្លៀង ។ (៣) ពណ៌នៅកន្ទុយសត្វព្រៃ មិនដូចគ្នារាល់ឆ្នាំនោះទេ គឺប្លែកពណ៌គ្នាជានិច្ច ។

ផេះ គេបង្ខិលឈើ(១) ដែលបិទទៀននោះអោយផ្អៀងទៅម្ខាង (ឆ្វេង ឬ ស្តាំ) ។ ពេលនោះ បើគេពិនិត្យទៅឃើញថា ទៀនតំណាងខេត្តណាស្រក់ញាប់ (ច្រើនជាងគេ) គេសន្មតថា ខេត្តនោះៗមានភ្លៀងច្រើន(២) ។

## II . ទស្សន៍ទាយអំពីការអស់ទឹកភ្លៀង

*១/. ដោយពិនិត្យផ្កាឈើ :*

គេច្រើនពិនិត្យផ្កាទន្ទ្រានខេត្ត និងផ្កាកន្ទ្រាំងបាយស (ស្មៅអំបោស) ក្នុងការកំណត់ទំនាយ ។ បើកាលណាគេឃើញដើមទន្ទ្រានខេត្ត និងដើមកន្ទ្រាំងបាយសចេញផ្កាហើយនោះ គេអាចនឹងដឹងបានថាលែងមានភ្លៀងទៀតហើយ ។ រុក្ខជាតិទាំងពីរប្រភេទនេះចេញផ្កាពុំមានពេលកំណត់ ទៀងទាត់ច្បាស់លាស់ទេ ។ ជួនកាលវាឆាប់ចេញផ្កា ជួនកាលវាក៏ចេញផ្កាយឺតពេល ។

*២/ ដោយស្តាប់សំគាល់សំឡេងសត្វ :*

ក្រោយពេលចេញវស្សា ចាស់ៗច្រើនសង្កេតសត្វពីរពួក ដើម្បីកំណត់សំគាល់ការអស់ទឹកភ្លៀងគឺ :

+ កាលណាគេឮសំឡេងកង្កែប ដែលខំស្រែកដោយត្រូវពស់លេប ឮស្នូរ « រីបៗ » នៅក្បែរ អណ្តូង - មុំភ្លឺស្រែ កៀនដំបូក នោះគេសំគាល់ថា អស់ភ្លៀងហើយ, ឯទឹកជំនន់ ក៏ស្រកទៅវិញផងដែរ ។

+ កាលណាគេឮស្នូរកុកក្រក ដែលចុះរកស៊ីក្នុងស្រែ និងថ្លុក ត្រពាំង បន្លឺសំឡេងឮស្នូរ « ក្រកៗ » នោះគេដឹងថា រដូវភ្លៀងនឹងចប់ហើយ ។ ហើយនេះ ក៏ជាសញ្ញានៃរដូវទឹកសម្រកផងដែរ ។

---

(១) ឈើបិទទៀនប្រវែងប្រមាណ ២,៥០ម ឬ ៣ម មានឆ្លាក់ក្បាលនាគនៅសង្ខាង ។

(២) ចំនួនទៀន ស្មើនឹងចំនួនខេត្ត ក្នុងព្រះរាជាណាចក្រកម្ពុជា ។

*គ/ ដោយចំណាំលើការប្រែប្រួលខ្យល់រដូវ និង ធាតុអាកាស*

+ កាលណាគេឃើញមេឃស្រឡះ ខៀវស្រងាត់ (១) ពុំមានពពកសោះ ហើយនៅពេលយប់ ផ្កាយទាំងឡាយរះយ៉ាងច្បាស់ក្រឡែតៗ មើលទៅឃើញធំៗ ជាងសព្វដង នោះគេដឹងថានឹងអស់ភ្លៀងហើយ ។

+ កាលណាខ្យល់រដូវ ( Mousson ) ផ្លាស់ប្តូរទិស គឺត្រឡប់ជាបក់មកពីទិសខាងជើង ឬពីឦសានវិញនោះ គេដឹងថារបបទឹកភ្លៀងត្រូវបានបញ្ចប់ហើយ ។

+ កាលណាមានភ្លៀងពេលអព្រាត ធ្លាក់ចុះមកជាមេធំៗ ភ្លៀងរបៀបនេះ គេហៅថាភ្លៀង « លាងស្នែ » ។ នេះមិនមែនជាភ្លៀងធម្មតាទេ ប៉ុន្តែ គឺជាភ្លៀង « ផ្តាំ » ភ្លៀងចុងក្រោយ ឧបមាដូចយើងខ្ញុំរមាត់ឈប់បរិភោគដូច្នេះដែរ ។

+ ជួនកាលភ្លៀងធំ នាពេលអព្រាតនេះ មានរន្ទះបាញ់ផ្ទងផាងផងដែរ ។ គេច្រើននិយមហៅថា « រន្ទះបាញ់ក្បាលត្រីក្រាញ់ » ព្រោះជាចៃដន្យនៅពេលស្រប ជាមួយនេះដែរ ក្បាលត្រីក្រាញ់ទាំងឡាយមានស្នាមរបកពពាល រលាត់ ទំពែក ។ នេះក៏ជាសញ្ញាថាអស់ទឹកភ្លៀងដែរ ។

*ឃ/ ដោយពិនិត្យភ្លៀងនៅថ្ងៃបុណ្យភ្ជុំបិណ្ឌ :*

ចាស់បុរាណ លោកអោយពិនិត្យថ្ងៃភ្ជុំបិណ្ឌ ដើម្បីកំណត់អោយដឹងថា តើឆ្នាំនេះ ភ្លៀងជួនចុងរដូវ ឬក៏រាំងរឹះ ។

ឆ្លងតាមរយៈការពិនិត្យនេះ លោកកំណត់ថា :

- ប្រសិនបើមានភ្លៀង នៅចំថ្ងៃបុណ្យភ្ជុំនោះ គេសន្មតថា ស្រូវនឹងស្កក ព្រោះភ្លៀងមិនជួនចុងឆ្នាំទេ ។

- ប្រសិនបើពុំមានភ្លៀងនៅថ្ងៃបុណ្យភ្ជុំបិណ្ឌទេ ចាស់ៗលោកសប្បាយ

---

(១) រាត្រីខែអស្សុជ ឬ កត្តិក

រីករាយ ហើយប្រកាសប្រាប់គ្នីគ្នាថា ឆ្នាំនេះភ្លៀងនឹងជួនចុងឆ្នាំ ។ ស្រូវធ្ងន់យើងនឹងបានផលពេញលេញជាមិនខាន ។

*ង/ ដោយឮសំឡេងផ្គរលា ឬ ផ្គរផ្ដាំក្ដាមខ្យង :*

នៅចុងខែអស្សុជ ឬ នៅដើមខែកត្តិក នាពេលអធ្រាត្រស្ងាត់ជ្រងំ គេតែងឮសូរផ្គរលាន់បន្លឺសំឡេងបង្អូសយ៉ាងវែង ឮពីជ្រុងទិសនិរតី ឬទក្សិណ ។ មុនដំបូងផ្គរនោះឮសូរដូចជានៅជិត ។ ប៉ុន្តែសំឡេងផ្គរឮកាន់តែឆ្ងាយទៅៗ តិចទៅៗ រហូតបាត់សូរសំឡេងតែម្ដង ។ អ្នកទាំងឡាយណាដែលធ្លាប់ព្រាត់គូស្នេហា ព្រាត់ប្រាសគ្រួសារ ឬ រស់នៅឃ្លាតឆ្ងាយពីស្រុកកំណើត កាលបើបានឮផ្គរនេះហើយ គេច្បាស់ជាស្រងេះស្រងោច ហៀរទឹកភ្នែកដោយពុំដឹងខ្លួន ។ ចាស់ៗអោយឈ្មោះផ្គរប្រភេទនេះថា « **ផ្គរលា** » ឬ « **ផ្គរផ្ដាំក្ដាម-ខ្យង** » ។ ព្រះបាទរាជសម្ភារ (១) ជាកវីដ៏ឆ្នើម នាសតវត្សទី ១៧ ទ្រង់ព្រះរាជនិពន្ធកំណាព្យមួយឈ្មោះ « សរសើរហេមន្តមាស (២) » ក្នុងនោះ កំណាព្យក៏បាននិយាយដល់ផ្គរលាន់ផ្ដាំក្ដាម-ខ្យង ដែលចាស់ៗពីដើម តែងសូត្រធ្វើបទយ៉ាងពីរោះ នៅពេលដែលឮផ្គរនេះ ។ ឧទាហរណ៍ « ... *ផ្គរផ្ដាំក្ដាមខ្យងកង្កែបត្រី អោយខំកាយរន្ធពួនអាត្មា តែទឹករីងខះអស់កាលណាប្រយ័ត្នមនុស្សាប្រហារឆី .... »* ។

ផ្គរលាន់ផ្ដាំក្ដាមខ្យង ឬ ផ្គរលានេះ ជាសំឡេងធម្មជាតិអោយដំណឹងដល់កសិករថាអស់ទឹកភ្លៀងហើយ គួរស្រវាស្រទេញតម្កល់ទឹកទុកក្នុងស្រែ ការពារក្រៀងស្រូវស្កក ។

ដោយ **មៀច ប៉ុណ្ណ**

(១) ព្រះរាជសម្ភារ ឬ ស្រីធម្មរាជា ឬ ពញា តូ ( ១៦២៩ - ១៦៣៤ ) ។

(២) កំណាព្យនេះ ទ្រង់បានព្រះរាជនិពន្ធពីឆ្នាំ ១៦២៩ ។

# ប្រវត្តិឃុំដូនសរ

ឃុំដូនសរ ស្ថិតនៅក្នុងស្រុកស្វាយរៀង ប៉ែកខាងជើងជាប់នឹងផ្លូវខេត្ត លេខ១០ ។ ចម្ងាយរបស់ឃុំពីទីរួមខេត្តស្វាយរៀងទៅទិសខាងជើងមាន១៧គ.ម ។

ឃុំនេះ មានព្រំប្រទល់ខាងជើងទល់នឹងឃុំចន្ទ្រី ស្រុករមាសហែក ។ ខាងត្បូងទល់នឹងឃុំធ្លក និងឃុំអង្គតាសូរ ស្រុកស្វាយរៀង ។ ខាងកើតទល់នឹងឃុំផ្លា និងឃុំម៉ឺនជ័យ ស្រុករំដួល ។ ខាងលិចទល់នឹងឃុំអង្គតាសូរ និងឃុំស្វាយយា ស្រុកស្វាយរៀង ។ វិសាលភាពរបស់ឃុំ មិនជាធំទូលាយប៉ុន្មានទេ ចម្ងាយពីជើងទៅត្បូង មានប្រមាណជាង៥ គ.ម និងពីកើតទៅលិច ជាង៤គ.ម ។

ផ្ទៃដីផ្នែកខាងជើង ច្រើនជាដីខ្មៅស្អិត ជាប់ទៅនឹងបឹង និងព្រៃក ។ ឯខាងត្បូងវិញ ជាដីខ្សាច់សុទ្ធ ខ្សោះជីជាតិ ។ ប្រជារាស្ត្រក្នុងឃុំប្រកបរបរកសិកម្មទាំងអស់គ្នា និងមានធ្វើស្ករត្នោតបន្ថែម នារដូវប្រាំង ។

ឃុំនេះធ្លាប់មានប្រវត្តិពីយូរលង់មកហើយ មានដូចតទៅ :

តាមដំណាលរបស់ចាស់ៗ បាននិទានតៗគ្នាមក ពិសេស លោកគ្រូចៅអធិការវត្តល្វើន ព្រះនាម ព្រំ នៅឆ្នាំ១៩៤៧ និងលោកតា តាត ឃុន នៅឆ្នាំ១៩៦៣ បានផ្តល់ពតិមានថា មុនមានមនុស្សមកនៅជាប់រហូតដល់សព្វថ្ងៃ ទីតាំងខ្លះរបស់ឃុំ ជាកន្លែងដែលមានមនុស្សជាន់ដើមធ្លាប់មករស់នៅរួចទៅហើយ ព្រោះកន្លែងទាំងនោះនៅសល់ទួលខ្ពស់ៗ ដូចជាទួលពស់វែក ទួលអង្រ្គង ទួលក្រាំង ដែលនៅលើទួលខ្លះ មានកប់ផ្ទាំងថ្មធំៗ មានលឹង្គព្រះឥសូរ និងយោនីព្រះនាងឧមាភគវតី និងវត្ថុបុរាណដទៃច្រើនទៀត ។ ប៉ុន្តែក្រោយមក គេពុំដឹងថាមនុស្សទាំងនោះចាកចោលទីកន្លែងនោះពីពេលណា ដោយសារបញ្ហាអ្វីឡើយ ។ ក្រោយ

មក ទីតាំងអស់នោះក្លាយជាព្រៃក្រាស់ មានឈើតូច . ធំ ដុះពាសពេញ ។ ផ្នែកខាងត្បូងជិតទន្លេ មានព្រៃរនាម ព្រៃរបោះ និងវាលស្មៅខ្លះ ដូចជាវាលដូនតើ(១) ជាដើម ។ នៅផ្នែកខាងជើង មានព្រៃក្រាស់ និងបឹងធំៗបីជាប់គ្នាគឺ បឹងកែក បឹងពោធិ បឹងចំរ៉េះ និងមានព្រៃក ដែលជាជម្រកពពួកសត្វព្រឹក និងសត្វស្លាបរស់នៅច្រើន ។ សព្វថ្ងៃ បឹងទាំងនោះរាក់អស់ ស្ទើរតែបាត់សភាពដើមទៅហើយ ។

លុះចំណេរតមក ប្រមាណជាង២០០ឆ្នាំមុននេះ មានមនុស្សចំណូលថ្មីៗ មករស់នៅជាបន្តបន្ទាប់នៅលើទីតាំងដីចាស់បុរាណនោះ ។ មនុស្សទាំងនោះ ចុះពីឃុំអង្គតាសួរ មករានព្រៃនៅផ្នែកខាងត្បូងនៃឃុំ ។ ឯមនុស្សមួយក្រុមទៀត ចុះពីឃុំស្វាយអង្គ មករានដីនៅប៉ែកខាងលិច ។ គ្រាដំបូង ទោះជាមានមនុស្សមករស់នៅ កជាក្រុម ជាភូមិហើយក៏ដោយ ក៏ទីតាំងថ្មីពុំទាន់មានឈ្មោះនៅឡើយ ។ ក្នុងពេលនោះ ដោយភូមិសាស្ត្រកន្លែងនោះមានព្រៃ មានបឹងបួរ ប្រជារាស្ត្រច្រើនប្រកបមុខរបរបាញ់សត្វ និងនេសាទត្រី ជាសំខាន់ ។

នាសម័យថ្ងៃមួយ មានពួកព្រានមួយក្រុមនៅឃុំស្វាយអង្គ បានទៅបរបាញ់សត្វនៅព្រៃមួយ ក្បែរភូមិស្វាយផ្អែម ។ ព្រានបាននាំគ្នាព័ទ្ធបាញ់នឹងស្នាត្រូវប្រើសមួយក្បាល តែគ្រាន់តែរបួស ពុំទាន់ងាប់ទេ ។ ប្រើសក៏បោលតម្រង់ទៅរកព្រៃធំនៅទិសខាងកើតវិញ ។ ពួកព្រានដេញតាមប្រើសចូលទៅក្នុងព្រៃធំនោះដែរ ។ ដោយមានបាយសំណុំទឹកបំពង់ ការដេញតាមប្រើសចេះតែបន្តទៅច្រើនថ្ងៃ ព្រោះយល់ថា ប្រើសពិតជាងាប់ដោយសារមុខរបួសពុំខានឡើយ ។ លុះចូលដល់ព្រៃធំ ព្រានជួបហ្វូងជ្រូកព្រៃ ក៏នាំគ្នាហ៊ុំព័ទ្ធបាញ់ជ្រូកទៀត(២) ។ បន្ទាប់មក ព្រាន

(១) វាលដូនតើ សព្វថ្ងៃក្លាយជាស្រែ ។ (២) កន្លែងដែលព្រានព័ទ្ធបាញ់ជ្រូក ក្រោយមកក្លាយជាភូមិមួយ ហៅថា ភូមិហ៊ុំព័ទ្ធជ្រូក សព្វថ្ងៃហៅថា ភូមិរំពាត់ជ្រូក ។

ក៏បន្តរុកចូលព្រៃជ្រៅតាមប្រើសទៅទៀត តែរកប្រើសរបូសមិនឃើញ ។ មិនតែប៉ុណ្ណោះ ពួកព្រានបែរជាវង្វេង ល្វីល្វើទាំងអស់គ្នា នៅក្នុងព្រៃនោះទៅ ។ ការវិលវល់ក្នុងព្រៃ អត់បាយ អត់ទឹកច្រើនថ្ងៃ ធ្វើឱ្យគ្រួសារញាតិមិត្តនៅឯផ្ទះ ចេញតាមរកសព្វកន្លែង ក៏ពុំឃើញដែរ ។ ដោយភិតភ័យនឹងបាត់មនុស្សច្រើនយ៉ាងនេះ អ្នកស្រុក ក៏នាំគ្នាធ្វើការបន់ស្រន់ ដោយគេយល់ថា ក្នុងព្រៃធំៗទាំងនោះ ប្រាកដជាមានទេព្រក្ស អារក្ស អ្នកតា បង់បត់ លាក់បំបាំងមនុស្សពុំខាន ។ គេនាំគ្នារៀបចំសំណែន លេងភ្លេង បញ្ជាន់អារក្សនៅក្នុងព្រៃ បួងសួងចំពោះវត្ថុសក្តិសិទ្ធិ ដែលរក្សាព្រៃ សុំអោយលោះលាត្រាប្រណីដល់គេ និងប្រគល់មនុស្សមកវិញ ។

ភ្លាមនោះដែរ គេប្រទះឃើញពួកព្រានដែលវង្វេងបាត់ទៅនោះ ស្ថិតនៅបង្ហើយនឹងកន្លែងបន់ស្រន់ ។ មនុស្សទាំងអស់មិនទាន់ស្លាប់ទេ ប៉ុន្តែមានភាពស្គមស្គាំង ល្ហិតល្ហៃជាខ្លាំង ព្រោះអត់អាហារ ។ ចាប់ពីពេលនោះមក គេនាំគ្នាសន្មតឈ្មោះព្រៃនោះជា " ព្រៃងងើ " ។ ឯអ្នកស្រុក ក៏នាំគ្នាខ្លាចព្រៃទាំងនោះតាំងពីពេលនោះមកដែរ ។ ក្រោយមក អ្នកស្រុកនៅតំបន់នោះ នាំគ្នាទម្លាប់ហៅបំព្រួញពីពីរម៉ាត់ មកមួយម៉ាត់វិញគឺ គេដូរឈ្មោះពី " ព្រៃងងើ " មកជា "ព្រៃល្វើ" វិញ ។ គេបានរៀបចំឱ្យមានអ្នកតាធំមួយ មានឈ្មោះថា " អ្នកតាសម្តេច " ( រាល់ថ្ងៃនៅភូមិរំពាត់ជ្រូក ) ។

ដោយសារកំណើនមនុស្សកាន់តែច្រើន ផ្ទៃដីនៅភូមិរការ ឃុំអង្គតាសូរកាន់តែចង្អៀតទៅ ម្ល៉ោះហើយប្រជារាស្ត្រ ក៏នាំគ្នាចុះទៅរានព្រៃយកដីបង្កបង្កើនផល និងរស់នៅបណ្តើរៗ រហូតដល់ទីតាំងខាងកើតព្រៃល្វើ រួចបង្កើតជាភូមិមួយ ហៅថាភូមិជ្រុងពពេល(១) ។ គេបានកសាងវត្តថ្មីមួយ នៅលើទីទួលខាងលិចភូមិ ចម្ងាយ២០០ម៉ែត្រ និងខាងជើងមាត់ទន្លេ ចម្ងាយ២០០ ម៉ែត្រ

(១) ភូមិជ្រុងពពេល សព្វថ្ងៃបាត់ហើយ ។

ដែរ ។ គេបាននិមន្តព្រះសង្ឃពីវត្តរការ មកគង់នៅចាំព្រះវស្សានៅវត្តនោះ ។ វត្តថ្មីនេះ ក៏មានឈ្មោះថា វត្តល្វើរ៍ ដែរ ។

នៅពេលនោះ មានប្រជារាស្ត្រមួយក្រុមទៀត មកពីទិសខាងលិច បានពង្រីកផ្ទៃដី ទៅរស់នៅពីខាងលិចព្រៃល្វើរ៍ ។ ដោយដីថ្មីមានជីជាតិល្អ ពលរដ្ឋទាំងពីរភូមិ និងអ្នកមកថែមក្រោយៗ ក៏ចេះតែនាំគ្នាបន្តកាប់ឆ្ការព្រៃ តំរង់ទៅទិសខាងជើង និងទៅទិសខាងកើតទៀត ។ ការកកើតជាភូមិថ្មីៗ មានជាបន្តបន្ទាប់ ។

ពេលអាណានិគមនិយមបារាំងចូលកាន់កាប់ប្រទេសកម្ពុជា គេចូលមកដល់ទីនេះតាមជើងទឹក ដោយចេញពីកំពង់ចំណតនៅពោធិតាហោរ (១) តាមដងទន្លេវាយគោ ខាងលិច ( Vaïco occidental ) ។ ពេលនោះ បារាំងបានដាក់ទ័ពប្រចាំការលើដីទួលមួយ ឱ្យឈ្មោះថា" ទួលពីកេរ (២)" ( Piquet ) ដើម្បីរក្សាសន្តិសុខ ។ ឯតាមផ្លូវគោក បារាំងបានឆ្លងកាត់ខេត្តរោងដំរី ( Tay Ninh ) កាត់តាមបណ្តាឃុំនៅស្រុករំដួល មកទាក់ទងគ្នានៅទីនោះតាមផ្លូវរទេះគោពីបូរាណ ។

បារាំងបានចងក្រងរបបត្រួតត្រារៀបចំជាឃុំមួយ ហៅថាឃុំល្វើរ៍ដដែល ( យកឈ្មោះព្រៃមកដាក់ជានាម ) ។ គេរៀបចំរដ្ឋអំណាចឃុំ និងរៀបចំភូមិសំរាប់គ្រប់គ្រង មានដល់១១ភូមិគឺ ភូមិល្វើរ៍ ភូមិព្រៃពោធិ ភូមិរំពាត់ជ្រូក ភូមិដូងព្រះ ភូមិចាម ភូមិដងទង់ ភូមិគួយ ភូមិព្រាច ភូមិចិនសា(៣)ភូមិអូរស្រងាំ និងភូមិបឹងកែក ។ ដោយការរៀបចំរដ្ឋអំណាច ប្រជារាស្ត្របានសុខសាន្ត និងមាន

---

(១)ពោធិតាហោរ សព្វថ្ងៃនៅឡើរូមខេត្តស្វាយរៀង ផ្នែកខាងកើតស្ពាន តាមផ្លូវជាតិលេខ១

(២) ឥឡូវជាផ្ទះប្រជារាស្ត្រ ខាងលិចផ្សារដូនសរ ។

(៣) ទំនងជាហៅតាមឈ្មោះចិន ដែលទៅតាំងលំនៅ នៅទីនោះមុនគេ

ជីវភាពធូរធារ ។ នៅក្បែរមាត់ទន្លេ មានជនជាតិចិន យួនមួយចំនួន មកតាំងទីលំ-នៅ ត្រង់មាត់កំពង់ពីរកន្លែងគឺ មួយកន្លែងនៅត្រង់ទួលយាយសរ ហៅថា កំពង់ដួនសរ និងមួយទៀត នៅត្រង់ទួលខាងត្បូងវត្ត ហៅថា កំពង់ក្តី ( ចិនកើតក្តីនឹងព្រះសង្ឃ បន្លំយកដីវត្ត ) ។ រីឯឈ្មោះកំពង់ដួនសរ ជាឈ្មោះយកតាមនាមដូនម្នាក់ក្នុងសម័យមុន ដែលបានមករស់នៅទីនេះ ។ នៅជាប់មាត់កំពង់ខាងជើងមាត់ទន្លេ មានទួលមួយធំ ។ ទួលនេះ ពុំលិចទឹកនៅរដូវវស្សាទេ ។ ទួលនេះហើយដែលលោកយាយសរបានរស់នៅ ។ គាត់ត្រូវបានអ្នកជិតខាងគោរពរាប់អានគ្រប់ៗគ្នា ។

នៅឆ្នាំ ១៩១០ រដ្ឋអំណាចអាណានិគមបារាំង បានកែនប្រជារាស្ត្រ ឱ្យលើកផ្លូវមួយពីទីរួមខេត្តស្វាយរៀង ដល់ឃុំចន្ទ្រី កាត់ដីឃុំល្វើរ៍ ផ្នែកខាងកើត ហើយឱ្យឈ្មោះថាផ្លូវលេខ ១០ ។ នៅឆ្នាំ ១៩២៤ គេបានកសាងសាលារៀនមួយជាសាលាបឋមសិក្សាជាន់ដំបូងល្វើរ៍ ។

ដោយប្រជារាស្ត្របានពិចារណាទៅឃើញថា ឈ្មោះឃុំល្វើរ៍ ជាឈ្មោះអាក្រក់ នាំឱ្យខ្មាសអៀន ពុំសមរម្យជាឈ្មោះឃុំមួយដែលមានមនុស្សរស់នៅមានជីវភាពបង្គួរដែរ ក៏នាំគ្នាសំណូមពរទៅរដ្ឋអំណាចបារាំងកែឈ្មោះថ្មី ។ គេក៏បានកែដោយដាក់ថា "ឃុំល្វើន" លុបអក្សរ រ៍ ចេញហើយដាក់អក្សរ ន មកជំនួសវិញ ។ ឯឈ្មោះភូមិ ឈ្មោះវត្ត និងឈ្មោះសាលារៀន ក៏បានកែដែរគឺ ភូមិល្វើន វត្តល្វើនសាលាបឋមសិក្សាជាន់ដំបូងល្វើន ។

នៅសម័យបារាំងត្រួតត្រា ទួលយាយសរត្រូវទុកចោល មានព្រៃដុះទ្រុបទ្រុល ។ ឆ្នាំ១៩៤០ គេបានសាងសំណង់ឈើមួយ សំរាប់ជាប៉ុស្តរបស់មេព្រៃចាំចាប់ឈើខុសច្បាប់ និងត្រួតពិនិត្យការនាំឈើចេញ ។ ឆ្នាំ១៩៤៨ បារាំងបានប្រមូលផ្ទះប្រជារាស្ត្រធ្វើជាភូមិយុទ្ធសាស្ត្រ ដោយពេលនោះមានអសន្តិសុខ ពេល

នោះបារាំងបានសង់ប៉ុមមួយ សំរាប់ការពារសន្តិសុខក្នុងឃុំនៅលើទួលដូនសរ ។ ដល់ឆ្នាំ១៩៥៤ ប្រជារាស្ត្រវិលទៅរស់នៅតាមភូមិវិញ ប៉ុន្តែ ប៉ុមនៅទុកសំរាប់រាជ-តម្រួត ( Police ) ការពារស្ពាន និងសន្តិសុខដដែល ។

គេនៅតែរក្សាឈ្មោះឃុំល្វើនដដែល រហូតមកដល់សម័យសង្គមរាស្ត្រនិយម ។

រីឯកំពង់ដូនសរ ក៏មានការវិវឌ្ឍន៍រីកចំរើនយ៉ាងខ្លាំង ក្លាយជាទីប្រជុំជនមានមនុស្សអ៊ូអរ មានផ្ទះថ្ម ផ្សារ ប្រកបដោយទំនិញគ្រប់មុខ អាស្រ័យដោយមានផ្លូវគោក ផ្លូវទឹក ចេញចូលបានគ្រប់រដូវ ។

ក្រោយរដ្ឋប្រហារឆ្នាំ១៩៧០ ឃុំល្វើនត្រូវស្ថិតនៅក្រោការគ្រប់គ្រងរបស់រដ្ឋអំណាចនៃសាធារណរដ្ឋខ្មែរ របស់លោកលន់ នល់ ។ ពេលនោះរដ្ឋអំណាចនៅតំបន់រំដោះ បានអនុវត្តតាមសំណូមពររបស់ប្រជារាស្ត្រភាគច្រើននិងដោយពិនិត្យឃើញថាឈ្មោះរបស់ឃុំ ពុំសមរម្យតាមប្រវត្តិនៃការតស៊ូរបស់ប្រជារាស្ត្រ ក៏បានឯកភាពប្តូរឈ្មោះឃុំល្វើន មកជាឃុំដូនសរវិញ ។ គេបានកាត់យកភូមិពីរពីឃុំស្វាយយា គឺ ភូមិព្រៃរការ និងភូមិស្វរ មកបញ្ចូលក្នុងឃុំដូនសរទៀត ។ គេលុបឈ្មោះភូមិល្វើន រួចបញ្ចូលក្នុងភូមិព្រៃពោធិ ។ ភូមិចាមភូមិដងទង់ត្រូវលុបចោល បញ្ចូលមកជាភូមិដូនសររហូតសព្វថ្ងៃ ។ នៅក្នុងសម័យសង្គ្រាម ពីឆ្នាំ ១៩៧០ - ១៩៧៥ សំណង់សាធារណៈក្នុងឃុំដូនសរ ត្រូវទទួលរងគ្រោះមហន្តរាយយ៉ាងធ្ងន់ធ្ងរ ។ ស្ពាន ផ្ទះថ្មនៅផ្សារដូនសរ ត្រូវបែកបាក់ខ្ទេចខ្ទីដោយសារការទម្លាក់គ្រាប់បែក ។ លុះមកដល់ក្នុងរបបប្រល័យពូជសាសន៍ ពីឆ្នាំ១៩៧៥ - ១៩៧៩ ទៀត គេបានកែនប្រជារាស្ត្រឱ្យទប់ទន្លេវាយគោជាកង់ៗ ធ្វើឱ្យដីហូរចុះ បណ្តាលឱ្យបាតទន្លេកាន់តែរាក់ទៅៗ រហូតដល់គោក នៅរដូវប្រាំងនៅរដូវវស្សា ពេលមានភ្លៀងធ្លាក់ច្រើន ទឹកឡើងលិច បណ្តាលឱ្យរលួយងាប់ព្រៃ-

អស់គ្មានសល់ ហើយទួលដូនសរ ក៏ត្រូវគេកាប់រំលាយ នាពេលនោះដែរ ។

ក្រោយថ្ងៃ ៧ មករា ១៩៧៩ ប្រជារាស្ត្របានវិលទៅរស់នៅជាធម្មតា តាមភូមិស្ថានរៀងៗខ្លួនដូចពីដើមវិញ ។ គេនាំគ្នាបង្កើតផ្សារដូនសរ សំរាប់លក់ដូរដល់សព្វថ្ងៃ ។ គេបានបង្កើតអនុវិទ្យាល័យមួយ ហៅថាអនុវិទ្យាល័យដូនសរ ។ ឯឈ្មោះឃុំ ក៏នៅប្រើឈ្មោះដូនសរ ជាប់រហូតមក ។ ដោយឡែក វត្តនៅតែដាក់ឈ្មោះថាវត្តល្វើន ដដែល ។

*ថ្ងៃសៅរ៍ទី ២៣ កក្កដា ឆ្នាំ ១៩៩៤*

**មោក ស៊ុម**

ប្រធានមន្ទីរធម្មការ និងសាសនា ខេត្តស្វាយរៀង

កូនអើយអ្នកចាំ កុំជឿខែឆ្នាំ កុំជឿតម្រា
ពាក្យក្បួនតម្រាយ កើតពីមនុស្សចារ ពីដូនពីតា
ចារតាមសម្គាល់ ។
អ្នកជឿតាមពូជ អម្បូរធ្លាប់ខូច វាខូចរៀងរាល់
ពូជមានវាមាន ពូជទាល់វាទាល់ កុសលអកុសល
យើងមើលមិនដាក់ ។

**" ច្បាប់ល្បើកថ្មី "**

អ្នកព្រះភិរម្យភាសា " អ៊ូ " ហៅ ង៉ុយ

# ស្វាមីប្រាំប្រការ
# ភរិយាប្រាំពីរប្រភេទ

**ភភន :**_ យើងនឹកស្ដាយ ដោយយល់ថាពុំគួរខាន ក៏បានស្រង់យកពាក្យកាព្យជាព្រះរាជនិពន្ធ នៃព្រះបាទសម្ដេចព្រះហរិរក្សរាមា ឥស្សរាធិបតី ព្រះបរមកោដ្ឋ (ព្រះអង្គដួង) ដែលទ្រង់និពន្ធចប់ក្នុងឆ្នាំរកា នព្វស័ក ព.ស ២៣៨០ កាលព្រះអង្គមានព្រះជន្មគម្រប់ ៤១ វស្សា មកចុះផ្សាយទុកជាព្រះកេរ្តិ៍ក្នុងទស្សនាវដ្ដីនេះ ។ កំណាព្យនេះ ថ្លែងពីគតិ៥យ៉ាង ដែលបុរសជាប្ដីត្រូវប្រតិបត្តិចំពោះស្ត្រីជាប្រពន្ធ និងថ្លែងពីភរិយា៧ប្រភេទ "ល្អប្លូន អាក្រក់បី" ។

អ្នកមានព្យាយាម, បើពេញចិត្តចំពោះព្រះរាជនិពន្ធនេះ, គួរទន្ទេញអោយចាំមាត់ ឬបង្គាប់អោយកូនចៅតូចៗ អោយទន្ទេញចាំមាត់ស្ទាត់ ហើយអោយនាំគ្នាសូត្ររឿយៗ ដើម្បីរំលឹកគ្នាក្នុងគ្រួសារ ក៏ជាការប្រពៃណាស់, មិនវែងណាស់ណាទេ, ដូចតទៅនេះ ÷

## គតិប្រាំយ៉ាងរបស់បុរសជាប្ដី ចំពោះភរិយា

*កតមេហិ*

*បញ្ចតី-* *ហិ សាមិកា* *ភរិយាស-*

*ង្គហាធម្មា* *ប្រែតាមអត្ថា-* *ធិប្បាយបាលី ។*

ថាប្រុសឯណា

នឹងមានភរិយា លោកឱ្យចេះស្ដី ទាំងប្រាំចំពោះ

សង្គ្រោះចិត្តស្រី ប្រពន្ធប្រក្រតី ដូចធមិសម្ដែង ។

បើប្ដីឯណា

ពុំកាន់កិរិយា ទាំងប្រាំនេះឯង ហៅប្ដីទុជិន

បើប្ដីកាន់ច្បាប់
ទាំងប្រាំនេះខ្ជាប់ ហៅប្ដីសុចរិត បម្រុងភរិយា
ដោយនាក្រមក្រឹត្យ ប្រសើរពេកពិត ឥតអ្វីផ្ទឹមឡើយ ។

អស់ប្រុសទាំងឡាយ
ចូរចាំអធិប្បាយ ច្បាប់នេះជាត្រើយ ទុកគ្រប់ប្រុសប្រាណ
កុំមានកន្តើយ មានប្រពន្ធហើយ ជាសុខសម្រាន្ត ។

មួយគឺហៅប្ដី
ឱ្យប្រើស្រដី នឹងប្រពន្ធមាន ពាក្យទន់ពីរោះ
ស្មើស្មោះដោយក្សាន្ត សរសើររាប់អាន តាមស័ព្ទវាចា ។

មួយគឺប្រពន្ធ
ខុសឆ្គងស្រាលធ្ងន់ កុំជេរផ្ដាសា ទាត់ធាក់ដៀលដិ
ដូចខ្ញុំអាត្មា កុំស្ដីដើមថា ឱ្យឮសាយស័ព្ទ ។

មួយគឺបានធន
ប្រគល់ប្រពន្ធ ទុកដាក់រណ្ដាប់ ទាំងគ្រឿងអាហារ
ជាការស្រីផ្ដាប់ រៀបចំសម្រាប់ ថែទាំរក្សា ។

មួយគឺកុំផ្គង់
កុំខំតែប- ង្កើតកូនហើយថា ប្រពន្ធសុខចិត្ត
ឱ្យគិតប្រាថ្នា រួសរកទ្រព្យា សម្រាប់ឱ្យផង ។

មួយគឺឱ្យចាប់
ស្រឡាញ់ឱ្យខ្ជាប់ កុំជិនណាយហោង បើមានប្រពន្ធ-
ទៀតកុំប៉ុនប៉ង ស្រឡាញ់ស្នេហ៍ស្នង ឱ្យស្មើមុខឡើយ ។

សម្ដែងសេចក្ដី
គ្រប់ប្រាំវិធី ថែងចប់ស្រេចហើយ ឱ្យអស់ប្រុសផង
ចាំចងជាត្រើយ ផ្ដង់កុំកន្តើយ ចោលច្បាប់បុរាណ ។

បើប្រុសឯណា
ពុំផ្ដង់ចិន្ដា ដូចធម៌ទូន្មាន នៅនឹងភរិយា
គ្មានជាសុខសាន្ដ ហិនហោចធនធាន ទាស់ទែងលែងគ្នា ។

ឯវិស័យចិត្ដ
អស់ស្រីផងពិត មានប្ដីប្រាថ្នា អំពើទាំងប្រាំ
នេះចាំចិន្ដា គ្រប់ចិត្ដភរិយា នៅនាលោកិយ ។

បើខ្វះអំពើ-
ណាមួយហើយតើ ប្រពន្ធថាប្ដី ចិត្ដពុំត្រូវត្រង់
ពុំគង់មេត្រី តូចចិត្ដស្វាមី អាក់អន់ពុំស្មោះ ។

លោកឱ្យប្រុសផង
គន់គិតសួនគ្រង ផ្ដង់ចិត្ដសង្គ្រោះ ប្រពន្ធឱ្យពិត
ដោយក្រឹត្យប្រាំនោះ ប្រពន្ធក៏ស្មោះ ចិត្ដចូលមូលឯង ។

កុំគិតតែយក
ប្រពន្ធបានមក គ្រាន់ឱបប្រលែង បង្កើតតែកូន
សោះសូន្យធនធេង លោកឱ្យគិតក្រែង ដំណៀលនិន្ទា ។

ធម្មតាជាប្ដី
បានទ្រព្យធនអ្វី ឬយសសក្ដា តែងនៅសុខសឹង
ទីពឹងផងគ្នា ព្រោះដៀតភរិយា កាន់ក្ដីសុចរិត ។

អំពើថ្មេះហោង
ឱ្យអស់ប្រុសផង ចងចាំក្នុងចិត្ត តាមធម៌ទ្ធន្ទាន
គ្រប់ប្រាណប្រុសពិត ទុកជាក្រមក្រឹត្យ ច្បាប់ច្បាស់តទៅ ។
អង្គអញ្ជរចនា
សេចក្ដីកាព្យា តាមច្បាប់ទុកនៅ ក្នុងព្រះបាលី
សេចក្ដីជ្រាលជ្រៅ ពុំហ៊ានសៅដៅ លើកលេងងាយដាយ ។
ឧស្សាហ៍ខំប្រុង
ប្រែរកវើសក្នុង គម្ពីរនិកាយ អដ្ឋកថា
ដីកាបរិយាយ និបាតទាំងឡាយ មកផ្សំស្រដី ។
ជាច្បាប់ទុកត
ដំណឹងតំណ ដំណើរស្ត្រី ឱ្យជាក់ប្រាកដ
ដោយបទបាលី គ្រាន់អស់ប្រុសស្រី រើសរៀនរកផ្លូវ ។
ច្បាប់នេះប្រសើរ
ដំណឹងដំណើរ ទំនងនេះក្លូវ ជាច្បាប់ប្រាកដ
ដោយបទត្រឹមត្រូវ គួរយើងឥឡូវ ប្រតិបត្តិរក្សា ។
គួររៀនឱ្យស្ទាត់
ឱ្យចាំរត់មាត់ ដាក់ក្នុងចិន្ដា គ្រាន់នឹងប្រឹតប្រៀន
បង្រៀនអាត្មា តាមដោយគាថា នេះឯងតទៅ ។
ថែងចប់អភិប្រាយ
ដោយអត្ថបរិយាយ សូរេចថ្ងៃសៅរ៍ ប្រាំបីរោចឯង
នាខែមាឃនៅ ឆ្នាំរកាត្រូវ នព្វស័កស្រេចហោង ។
***

# ភរិយា ៧ ប្រភេទ « ល្អប្អូន អាក្រក់ប្ដី »

*មួយសោតព្រះពុទ្ធ*
*ទេស្នាចំហុត ថារីភរិយា មានប្រាំពីរឈ្មោះ*
*ប្អូននោះចិត្តជា ប្ដីនោះមោហា ចិត្តខូចងាយដាយ*

ឯប្រពន្ធជា
ឯកឈ្មោះ*មាតា*- *ភរិយា* ដូចម្ដាយ ឃើផ្ទាលកូនខ្លួន
រវែងស្ងួនមិនណាយ មិននឹករសាយ ចិត្តចាំអាណិត ។

កូនទុក្ខទោសម្ដេច
ខ្សត់ក្រច្រើនតិច ខឹងខុសខូចចិត្ត ព្រាត់ប្រាសយូរលង់
ពុំបង់បែកចិត្ត គង់ចាំចិត្តគិត ឃើផ្ទាលកូនស្មោះ ។

ប្រពន្ធណាគាប់
ឃើផ្ទាលប្ដីខ្ជាប់ ចិត្តចាំកាន់កោះ ដូចម្ដាយស្រឡាញ់
កូនពេញពីពោះ ហៅប្រពន្ធនោះ ថ្លៃឥតផ្ទឹមដល់ ។

ប្រពន្ធជាទ្វី
ឈ្មោះហៅ*ទាសី*- *ភរិយា* ដូចកល់ ខ្ញុំនិងអម្ចាស់
ប្រើណាស់ខ្វាយខ្វល់ អាចអត់ទប់ទល់ ទម្ងន់បម្រើ ។

មិនមានទំនេរ
ទោះម្ចាស់វាយជេរ អត់ឱនស័រពើ តាមតែបង្គាប់
ប្រញាប់ចង់ធ្វើ ចិត្តពុំសើរើ ចៀសវាងក្រោធា ។

ប្រពន្ធណាអត់
ឱនអង្គអំណត់ ខ្លាចប្ដីអាត្មា ដូចខ្ញុំនិងម្ចាស់
ខ្លាចណាស់ធានា ប្រពន្ធនោះជា ប្រសើរសុខស្ងួន ។

ប្រពន្ធជាត្រី

ឈ្មោះ *ភគិនី*- *ភរិយា* ដូចប្អូន ស្រឡាញ់បងពិត
លំអិតលំអួន ទទួលដំបូ- ន្មានមាត់ពាក្យបង ។

ផ្ចាច់ផ្ដលតែមួយ

នឹងចងជាត្រួយ ចិត្តចាំបំណង ពំនាក់ពំនឹង
ពាក់ពឹងប៉ុនប៉ង តែនឹងអង្គបង ឥតម៉ៃទីទៃ ។

ប្រពន្ធណាចូល

នឹងប្ដីមួយមូល- ចិត្តជាប់អាល័យ ដូចប្អូននឹងបង
ចាំចងអាស្រ័យ ប្រពន្ធនោះថ្លៃ មធ្យមពេកពិត ។

ប្រពន្ធចត្វា

ឈ្មោះហៅ*សខា* - *ភរិយា* ដូចមិត្រ សំឡាញ់ស្រឡាញ់
អស់អញ្ជពេកពិត ស្មើខ្លួនស្មើចិត្ត ស្ម័គ្រស្មោះចិន្តា ។

បើមិត្រទៅបាត់

ស្ងប់ស្ងួតមុខមាត់ ទុក្ខទន់ទយា ឃើញមុខមកបាន
ចិត្តក្សាន្តសោះសា ស្រស់ស្រួលភក្ត្រា និរទុក្ខសោកសៅ ។

ប្រពន្ធណាចិត្ត

ស្រឡាញ់ប្ដីពិត គ្មានក្នុងគ្មានក្រៅ ដូចមិត្រនឹងមិត្រ
ចងចិត្តជាប់នៅ ប្រពន្ធនោះហៅ ឧត្តមក្រមាន ។

សម្ដែងភរិយា

ទាំងបួនសឹងជា ក្រស្រីធ្វើបាន បើស្រីណាគិត
ផ្គង់ចិត្តសន្ដាន ស្រឡាញ់ប្ដីប្រាណ ដូចធមិទេស្នា ។

លោកថាស្រីនោះ
ពុកេរ្តិ៍ពីរោះ ខ្ចួទៅនានា បើរស់ជីវិត
ទៅឋិតសួគ៌ា ចៀសចាកចតុរា- បាយបាបទុក្ខភ័យ ។

ប្រពន្ធពុំជា
ឈ្មោះ*វធកា-* *ភរិយា* ដូចនែ សត្រូវចាំចង
ទោសផងសព្វថ្ងៃ ប្រពន្ធចង្រៃ ប្ដីមានតែទុក្ខ ។

បើប្ដីខុសចិត្ត
វាគ្មានអាណិត ខេរខឹងច្រអុក ចាំចងទោសប្ដី
ស្រដីកិកកុក ឱ្យមាត់ឱ្យមុខ វាសវាងថ្លោះថ្លើយ ។

សុខទុក្ខសាំទាំ
វាមើលបំណាំ នៅស្ងៀមព្រងើយ ពុំជួយទុក្ខភ័យ
ដោះដៃកន្តើយ ស្លាប់ដោយរស់ដោយ គ្មានចិត្តមេត្រី ។

*ចោរីភរិយា*
ប្រពន្ធពុំជា លបលួចទ្រព្យប្ដី គ្មានចិត្តករុណា
មេត្តាប្រណី របស់ទ្រព្យអ្វី លក់ចាយអស់ធួន ។

*អយ្យាភរិយា*
ប្រពន្ធពុំជា តម្កើងតែខ្លួន ចេះតែប្រើប្ដី
ឥតបីមានសួន ធ្វើឫកណាំនួន ទុកប្ដីដូចខ្ញុំ ។

ប្រពន្ធទាំងបី
ធ្លាក់ទៅអវិចី រងទុក្ខដំណំ ក្នុងខ្ទះភ្លើងក្ដៅ
យូរនៅក្រៀមក្រំ ព្រោះចិត្តខ្លួនធំ ជាងប្ដីអាត្មា ។

ឯប្រពន្ធប្អូន-

មុខនោះគួរស្ងួន យកជាភរិយា នឹងកើតរបស់
គ្រឿយសសក្កា ផ្តើងពូជពង្សា សោយសុខថេរឋិត ។
សម្តែងបរិយាយ
ភរិយាទាំងឡាយ ប្រាំពីរចរិត ទាំងជូទាំងជា
ពណ៌នាពោលពិត ថែងចប់ពិនិត្យ តាមអត្ថគាថា ។

**ឱម ខែម**

ស្រង់ពីវចនានុក្រមខ្មែរ ភាគ១
ត្រង់មេពាក្យ ៖ ប្តី, ប្រពន្ធ

ក្រឡាប់នគរ វីងវីតកើតចោរ ច្រើនឡើងច្រើនឡើង
ពាលរីងក្រអើត ចើតម៉ើតចើតម៉ឹង ក្រដាសយ៉ាងស្តើង
ចាយហែកនៅដៃ ។
ប្រាក់ចាស់អស់ទៅ ព្រោះមនុស្សឥឡូវ ឧត្បាតចង្រៃ
ជាតិខ្មែរប្រែភេទ ក្រឡែតក្រឡៃ ក្រឡាស់សាសនីសៃយ
សព្វសព្វនានា ។
ជាតិខ្មែរប្រែខុស ស្រីក្លែងធ្វើប្រុស ប្រុសក្លែងធ្វើជា
យកប្តីប្រពន្ធ មិនស្គាល់មីងមា បុណ្យទានការងារ
កាប់គ្នាផតព្រៃង ។

" ច្បាប់ល្បើកថ្មី "

អ្នកព្រះភិរម្យភាសា " អ៊ូ " ហៅ ង៉ុយ

# សេចក្ដីជូនដំណឹង

គណៈកម្មការនិពន្ធ មានកិត្តិយសសូមជំរាបជូនដំណឹងចំពោះអស់លោកអ្នកអានជាទីគោរពថា នៅក្នុងលេខ ៤ នេះ គណៈកម្មការនិពន្ធ ពុំទាន់ចុះផ្សាយលទ្ធផលចម្លើយប្រស្នារបស់ទស្សនាវដ្ដីលេខ ៣ ទេ ពីព្រោះគណៈកម្មការបានទទួលចម្លើយតិចពេក ។ ហេតុនេះ គណៈកម្មការសំរេចលើកយកចម្លើយប្រស្នាកំណាព្យរបស់ទស្សនាវដ្ដីលេខ ៣ នេះ ទៅចុះផ្សាយក្នុងទស្សនាវដ្ដីលេខ ៥ វិញ ។ រីឯប្រស្នាថ្មី ក៏មិនបានចុះផ្សាយក្នុងលេខ ៤ នេះដែរ ។ សូមមេត្តារង់ចាំអាននៅក្នុងទស្សនាវដ្ដីលេខ ៥ ដែលនឹងចេញផ្សាយក្នុងពេលខាងមុខ ។ ឆ្លៀតក្នុងឱកាសនេះដែរ គណៈកម្មការ សូមលើកយកកំណាព្យចម្លើយរបស់ព្រះបទុមវង្សាសេង សុមុនី ដែលបានឆ្លើយកំណាព្យប្រស្នាចុះក្នុងទស្សនាវដ្ដីលេខ ២ មកចុះផ្សាយ ដើម្បីជាការលើកទឹកចិត្តចំពោះការយកព្រះទ័យទុកដាក់របស់ព្រះអង្គចំពោះទស្សនាវដ្ដី កម្ពុជសុរិយា ។

តាមពិត កំណាព្យចម្លើយរបស់ព្រះអង្គ មិនត្រូវនឹងបំណងប្រាថ្នារបស់សំណួរទេ ប៉ុន្តែ កំណាព្យនេះមានខ្លឹមសារគួរឱ្យពិចារណា និងមានសម្ផស្សល្អបង្គួរ ។

អត្ថបទកំណាព្យ មានដូចខាងក្រោមនេះ :

## « បទស្រាយប្រស្នា »

| | | |
|---|---|---|
| សូមស្រាយប្រស្នា | តាមដោយបញ្ញា | ការចាំចេះដឹង |
| បញ្ជាក់សេចក្ដី | ជូនជាដំណឹង | តាមដែលខ្ញុំដឹង |

ពីនគរកាយ ។

នគរកាយតូច   តែប្រសើរដូច   នគរជិតឆ្ងាយ
មានស្តេចមន្ត្រី   សែនសុខសប្បាយ   ក្នុងនគរកាយ
គ្រប់សព្វមិនខ្វះ ។

ស្តេចនាមចិត្តរាជ   មានឫទ្ធិអំណាច   ប្រសើរខ្លាំងណាស់
គ្រប់គ្រងផែនដី   នាទីជាម្ចាស់   សម្បត្តិឥតខ្វះ
សម្បូរគ្រប់មុខ ។

តាមការបកស្រាយ   ហាសិបពីរថ្នាយ   ជនជាប្រមុខ
ញាតិនឹងវេហ៍ពល   ស្តេចបានដាក់ទុក   តំណែងសព្វមុខ
ពីតូចដល់ធំ ។

មហាតលិកអាមាត្យ   ឧកញ៉ាព្រេងព្រាត   ពួកក្រុមជំនុំ
សព្វមុខតំណែង   តែងមកជួបជុំ   កិច្ចការតូចធំ
ប្រជុំដោះស្រាយ ។

តែគួរស្រណោះ   រាជាអង្គនោះ   គិតតែសប្បាយ
ឈ្លក់នឹងមហេសី   រូបស្រស់នោមឆាយ   រីករវគ្មានណាយ
គ្រប់ពេលវេលា ។

មហេសីប្រាកដ   មាននាមសន្មត់   ឈ្មោះអវិជ្ជា
ដំណើរល្វតល្វន់   ទន់ភ្លន់សោភា   ព្រះនាងអវិជ្ជា
ជាអគ្គមហេសី ។

នៅមិនឆ្ងាយពេក   សត្រូវជើងឯក   គ្មានត្រាប្រណី
លើកទ័ពមកច្បាំង   សម្លាប់មន្ត្រី   រាស្ត្រផងទីទៃ
ក្ស័យគ្មានសេសសល់ ។

ច្បាំងកាប់សម្លាប់ នាហ្មឺនរាស្ត្រស្លាប់ កើតទុក្ខរំពល់
សម្លាប់ទាំងអស់ គ្មានអ្វីសេសសល់ ធ្វើអោយមណ្ឌល
នគរទ្រុឌទ្រោម ។

នេះសូមបញ្ជាក់ វេលាពេលគ្រប់នាក់ កាប់ចាក់ព័ទ្ធរោម
កាប់ទៅកាប់មក រាល់ថ្ងៃមិនល្ហែ សឹងប្រយុទ្ធព្រម
គ្មានរាថយឡើយ ។

ឯព្រះរាជា មិនគិតធម្មា ព្រងើយកន្តើយ
រាស្ត្រស្លាប់បន្ត ឥតមានស្រោន្តស្បើយ នេះខ្ញុំសូមឆ្លើយ
ថារាងកាយមនុស្ស ។

*បទុមវង្សា* **សេង សុមុនី**

នគរថ្កើងថ្កើន សប្បាយពេញភ្នែក ក្នុងចិត្តឯកឯម
កូនប្រុសបណ្តាច់ កុំភ្លេចបណ្តាំ កប្បាសស្រូវព្រម
ត្រៀមទុំបែងចោក ។

---

" ច្បាប់ល្បើកថ្មី "

អ្នកព្រះតិរច្ឆានភាសា " អ៊ូ " ពោធិ ឆ៊ុយ

# សិក្ខាសាលាជាតិ
## ស្តីពី
## ព្រះពុទ្ធសាសនា និង ការអភិវឌ្ឍន៍សង្គមខ្មែរ

NATIONAL SEMINAR ON " BUDDHISM AND THE DEVELOPMENT OF KHMER SOCIETY "

ដោយបានទទួលការឧបត្ថម្ភពីលោក ពីធ័រ សៀវ អ្នកតំណាងអចិន្ត្រៃយ៍នៃមូលនិធិ ខុនរ៉ាដ អាឌីណូអ៊ែរ (Konrad Adenauer Foundation) ក្រសួងធម្មការនិងសាសនា សហការជាមួយសមាគមពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍នៅខេត្តបាត់ដំបង បានរៀបចំបើកសិក្ខាសាលាជាតិមួយ ស្តីពី «ព្រះពុទ្ធសាសនានិងការអភិវឌ្ឍន៍សង្គមខ្មែរ» នៅទីស្តីការរដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា ពីថ្ងៃ ២១ ដល់ថ្ងៃ ២៣ វិច្ឆិកា ១៩៩៤ ។

សិក្ខាសាលាបានប្រព្រឹត្តទៅក្រោមព្រះអធិបតី និងអធិបតីភាព សម្តេចព្រះសង្ឃរាជទាំងពីរគណៈ, ឯកឧត្តមរដ្ឋលេខាធិការ-អនុរដ្ឋលេខាធិការ ក្រសួងធម្មការ និងសាសនា, លោក ពីធ័រ សៀវ ។

ចូលរួមក្នុងសិក្ខាសាលានោះដែរ មាន ៖ ព្រះគ្រូ ហេង មុនីចិន្តា ប្រធានសមាគមពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍, មន្ត្រីសង្ឃជាន់ខ្ពស់ទាំងពីរគណៈជាច្រើនអង្គព្រមទាំងព្រះសង្ឃ និមន្តមកពីបណ្តាខេត្ត-ក្រុងទូទាំងប្រទេស និងមន្ត្រីជាអ្នកទទួលបន្ទុកការងារសាសនា ពីគ្រប់មន្ទីរធម្មការខេត្ត-ក្រុង សរុបចំនួនទាំងអស់ មាន ២៤០ រូប ។

គោលបំណងនៃសិក្ខាសាលា គឺ ៖

១- ដើម្បីអោយព្រះសង្ឃ ពិសេស ព្រះចៅអធិការវត្តនីមួយៗ បានស្គាល់ និងយល់កាន់តែច្បាស់នូវតួនាទីរបស់លោក ក្នុងការរួមចំណែកលើកស្ទួយ

ព្រះពុទ្ធសាសនា និងសង្គមជាតិ ។

២. ដើម្បីអោយព្រះសង្ឃយកព្រះទ័យទុកដាក់ខ្ពស់ថែមទៀត ក្នុងការរួមចំណែកជួយអប់រំប្រជាពលរដ្ឋពុទ្ធសាសនិក អោយភ្ញាក់រលឹកចេះជួយខ្លួនដោយខ្លួនឯង ដោយយកព្រះពុទ្ធសាសនា និងវត្តអារាម ធ្វើជាចំណុចផ្ដើមនៅក្នុងស្រុកភូមិ ជុំវិញវត្ត និងសាលារៀន ។

៣. ដើម្បអោយក្រសួង និងមន្ទីរធម្មការខេត្ត-ក្រុងយកចិត្តទុកដាក់ និងជួយជំរុញអោយមានការអភិវឌ្ឍន៍តាមវត្តនីមួយៗ ។

ប្រធានបទសំខាន់ៗ ក្នុងសិក្ខាសាលានេះ មាន :

១. « ព្រះពុទ្ធសាសនា និង ការអភិវឌ្ឍន៍អភិវឌ្ឍន៍សង្គមខ្មែរ » របស់ឯកឧត្តម ឈន អៀម អនុរដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា ដែលឆ្លុះបញ្ចាំងអោយឃើញអំពីកម្លាំងរបស់ព្រះពុទ្ធសាសនា ព្រះសង្ឃ វត្តអារាម ដែលជាកម្លាំងរស់ដ៏សំខាន់របស់សង្គម ហើយក៏ជាកម្លាំងចលករមិនអាចខ្វះបានក្នុងការរួមចំណែកអភិវឌ្ឍន៍សង្គមជាតិ ។

២. « ឥទ្ធិពលនៃវត្តអារាមក្នុងសង្គមខ្មែរ » របស់ឯកឧត្តម ហៀន វណ្ណារត្ន រដ្ឋលេខាធិការក្រសួងធម្មការនិងសាសនា ដែលឆ្លុះបញ្ចាំងអោយឃើញពីតួនាទីរបស់វត្ត តួនាទីរបស់ព្រះសង្ឃ និងតួនាទីនៃការអប់រំសីលធម៌ក្នុងសង្គម ។

៣. « វប្បធម៌ សិល្បៈ និងវឌ្ឍនភាពក្នុងសង្គមខ្មែរ » របស់លោកសាស្ត្រាចារ្យ ឆេង ផុន ។

៤. « ព្រះពុទ្ធសាសនា និងការផ្សះផ្សាជាតិ » របស់ភិក្ខុញៀម គឹមតេង (ខេត្តស្វាយរៀង) ។

៥. « ព្រះពុទ្ធសាសនា សន្តិភាព និងការអភិវឌ្ឍន៍ » របស់សម្ដេចព្រះមហាឃោសនន្ទ ។

៦. «ព្រះពុទ្ធសាសនាសំរាប់ថ្ងៃស្អែកនៅកម្ពុជា» របស់ព្រះតេជព្រះគុណ

ហេង មុនីចិន្តា (ខេត្តបាត់ដំបង) ។

ក្រៅពីនេះ មានបទអន្តរាគមន៍របស់តំណាងក្រសួងនានាជាច្រើនទៀត ដែលពាក់ព័ន្ធនឹងបញ្ហាចំបងរបស់សិក្ខាសាលា គឺ :

- ក្រសួងអប់រំ យុវជន និងកីឡា ធ្វើអន្តរាគមន៍ ស្តីពី «វត្តអារាមនិងការអប់រំ» ។
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ, ស្តីពី «តួនាទីរបស់ព្រះសង្ឃ ក្នុងការថែរក្សាបេតិកភ័ណ្ឌជាតិ» ។
- ក្រសួងទេសចរណ៍, ស្តីពី «វត្តអារាម និងទេសចរណ៍» ។
- ក្រសួងអភិវឌ្ឍន៍ជនបទ, ស្តីពី «វត្តអារាម និងការអភិវឌ្ឍន៍សង្គមគ្រួសារ» ។
- ក្រសួងបរិស្ថាន, ស្តីពី «បរិស្ថាន និងវត្តអារាម» ។
- ក្រសួងសុខាភិបាល, ស្តីពី «តួនាទីព្រះសង្ឃ ក្នុងការអប់រំសុខភាព» ។
- ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន, ស្តីពី «តួនាទីរបស់វត្តអារាម ក្នុងការជួយប្រជាជនខ្មែរ» ។

ខ្លឹមសារនៃប្រធានបទ និងបទអន្តរាគមន៍ខាងលើនេះ ត្រូវបានដាក់អោយពិភាក្សាតាមក្រុម ដើម្បីផ្លាស់ប្តូរយោបល់គ្នា ។ ក្នុងការពិភាក្សា សមាជិកដែលជាតួអង្គពាក់ព័ន្ធដោយចំពោះ បានផ្តល់យោបល់និងបំភ្លឺវែកញែកលើការងារសង្គម ដែលព្រះសង្ឃអាចចូលរួមចំណែកក្នុងការងារនេះបាន ដោយពុំមានទាស់ខុសនឹងធម៌វិន័យជាពុទ្ធប្បញ្ញត្តិ ។

អង្គសិក្ខាសាលា បានចាត់ទុកការរួមយោបល់របស់លោក ពិធីរ សៀវ ក្នុងសិក្ខាសាលានេះ ថាជាប្រធានបទនាំមុខមួយយ៉ាងសំខាន់ ។

**ឱម ខែម**

# ពិធីទទួលគម្ពីរព្រះត្រៃបិដក

នៅថ្ងៃទី ១២ ធ្នូ ១៩៩៤ វេលាម៉ោង ៩ ព្រឹក ក្រសួងធម្មការ និងសាសនា បានប្រារព្ធធ្វើពិធីទទួលគម្ពីរព្រះត្រៃបិដក ចំនួន ៥១ ក្បាល ពីឯកឧត្តម ហ្សាល កេរិន ជាឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃប្រទេសអូស្ត្រាលីប្រចាំព្រះរាជាណាចក្រកម្ពុជា ក្រោមអធិបតីភាព សម្តេច ជា ស៊ីម ប្រមុខរដ្ឋស្តីទីជាព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់ នៃព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ។

គម្ពីរព្រះត្រៃបិដក ទាំង ៥១ ក្បាលនេះ ជាសម្បត្តិរបស់ភិក្ខុឥន្ទមុនី ទិត សាគុន គង់នៅវត្តវិចិត្តារាម ស្រុកកៀនស្វាយ ខេត្តកណ្តាល ។ នៅពេលដែលរបបសាធារណរដ្ឋខ្មែររបស់សេនាប្រមុខលន់ ណុល រៀបនឹងដួលរលំ ព្រះភិក្ខុ ទិត សាគុន មានព្រះទ័យព្រួយបារម្ភ ចំពោះការបាត់បង់មតិកពុទ្ធសាសនាដ៏វិសេសនេះ ។ ភិក្ខុអង្គនេះបានយកគម្ពីរព្រះត្រៃបិដក ចំនួន ៥១ ក្បាល ទៅផ្ញើទុកនឹងស្ថានទូតអូស្ត្រាលី, ភ្នំពេញ ដើម្បីអោយស្ថានទូតនេះជួយថែរក្សាទុក ។ ស្ថានទូតអូស្ត្រាលីក៏បានបញ្ជូនគម្ពីរនេះទៅរក្សាទុកនៅឯបណ្ណាល័យ *កង់បេរ៉ា* ប្រទេសអូស្ត្រាលី ។

នៅឆ្នាំ ១៩៩២ ប្រទេសអូស្ត្រាលី យល់ថាជាពេលវេលាមួយ ដ៏សមរម្យហើយ ដើម្បីប្រគល់គម្ពីរព្រះត្រៃបិដកទាំង៥១ក្បាលនេះ ដល់ម្ចាស់ដើមវិញ ។ ប៉ុន្តែជាការគួរអោយសង្វេគណាស់ ព្រះភិក្ខុ ទិត សាគុន ដ៏អភ័ព្វ ត្រូវបានពួកខ្មែរក្រហមធ្វើគត់ នៅគុកទួលស្លែង ។ ដូច្នេះ ស្ថានទូត ក៏ប្រគល់គម្ពីរព្រះត្រៃបិដកនេះ ជូនចំពោះរាជរដ្ឋាភិបាលកម្ពុជា ដើម្បីជាគុណប្រយោជន៍ដល់ព្រះពុទ្ធសាសនាតទៅ ។

ការដែលប្រទេសអូស្ត្រាលី បានជួយរក្សាទុកនូវគម្ពីរព្រះត្រៃបិដក ដែលជាមូលដ្ឋានគ្រឹះនៃពុទ្ធសាសនា គឺជាកាយវិការប្រកបដោយមិត្តភាពរបស់ប្រជារាស្ត្រអូស្ត្រាលី ចំពោះប្រជារាស្ត្រកម្ពុជា មិនអាចបំភ្លេចបានឡើយ ។

ក្នុងនាមរាជរដ្ឋាភិបាល ពុទ្ធសាសនិក និងប្រជារាស្ត្រទាំងមូល សម្តេច ជា ស៊ីម បានសំដែងនូវអំណរគុណដ៏ស្មោះស្មគ្រជូនរដ្ឋាភិបាល និងប្រជារាស្ត្រអូស្ត្រាលី និងប្រសិទ្ធិពរសូមអោយចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការដ៏ល្អប្រពៃរវាងរដ្ឋាភិបាល និង ប្រជារាស្ត្រទាំងពីរ កម្ពុជា-អូស្ត្រាលី កាន់តែត្រចះត្រចង់ និងស្ថិតស្ថេរចិរកាល ។

ពិធីនេះ បានបញ្ចប់ក្រោមសូរស័ព្ទព្រះធមិ ។

***

នៅថ្ងៃទី១៨ ឆ្នាំ ១៩៩៤ វេលាម៉ោង២ និង៣០ នាទី នៅក្រសួងធម្មការ និងសាសនាដដែល ព្រះតេជព្រះគុណ Seikyo Muchaku ប្រធានគណៈកម្មាធិការជំនួយដល់ការបោះពុម្ពព្រះត្រៃបិដកឡើងវិញ នៅប្រទេសជប៉ុន ក៏បានប្រគល់គម្ពីរព្រះត្រៃបិដក ចំនួន ៦០ ក្បាល ជានិមិត្តរូបចំពោះក្រសួងធម្មការនិងសាសនាដែរ ។

ពិធីនេះ បានប្រព្រឹត្តទៅក្រោមអធិបតីភាព ឯកឧត្តម ហៀន វណ្ណារុទ្ធ រដ្ឋលេខាធិការក្រសួងធម្មការនិងសាសនា ព្រមទាំងមានមន្ត្រីសង្ឃ និងមន្ត្រីរាជការរបស់ក្រសួងធម្មការជាច្រើនរូបទៀតចូលរួម ។

គម្ពីរព្រះត្រៃបិដក ទាំង១១០ ភាគ រួមមាន ៖ វិន័យបិដក (១៣ភាគ), សុត្តន្តបិដក (៦៤ភាគ) និងអភិធម្មបិដក (៣៣ភាគ) កំពុងដំណើរការបោះពុម្ពជាថ្មី

ឡើងវិញ នៅប្រទេសជប៉ុន ចំនួន ១.០០០ ច្បាប់ ក្នុងមួយភាគ សរុបទាំងអស់ ១១០.០០០ ច្បាប់ ។

គណៈកម្មាធិការជំនួយដល់ការបោះពុម្ពព្រះត្រៃបិដកឡើងវិញ ដែលមាន ព្រះតេជព្រះគុណ សីក្យូ មូចាគូ (Seikyo Muchaku) ជាប្រធាន និង ព្រះតេជ ព្រះគុណ អីអ៊ីជី ស៊ីណូហារ៉ា (Eiichi Sinohara) ជាអគ្គលេខាធិការ កំពុងធ្វើ ការងារនេះយ៉ាងមមាញឹក ដើម្បីអោយគម្ពីរព្រះត្រៃបិដកទាំង១១០ ភាគ បានបោះ ចប់នៅខែមីនា ឆ្នាំ ១៩៩៥ ។

នៅក្នុងឱកាសប្រគល់គម្ពីរព្រះត្រៃបិដកនោះ ព្រះតេជព្រះគុណ សីក្យូ មូចាគូ បានមានពុទ្ធដីកាប្រាប់ថា គម្ពីរព្រះត្រៃបិដក ពីភាគទី៩១ ដល់ភាគទី១១០ ចំនួន ២០ ភាគ បានបោះរួចហើយ សរុបទាំងអស់ ២០.០០០ ក្បាល ។ លោកបាន នាំមកជាមួយលោក ៦០ ក្បាល គឺក្នុងមួយភាគ ៣ ក្បាល ដើម្បីប្រគល់ជូនជា និមិត្តរូប នាពេលនេះ ។

ថ្លែងស្វាគមន៍ក្នុងឱកាសនោះ ឯកឧត្តម ហៀន វណ្ណារត្ន រដ្ឋលេខាធិការ ក្រសួងធម្មការ និងសាសនា បានសំដែងអំណរគុណចំពោះសន្តានចិត្តសប្បុរស របស់ «គណៈកម្មាធិការជំនួយដល់ការបោះពុម្ពព្រះត្រៃបិដកឡើងវិញ» ព្រមទាំង សប្បុរសជនជប៉ុន ក្នុងការរួមវិភាគទានធ្វើអោយពុទ្ធសាសនានៅកម្ពុជា មានពន្លឺ រុងរឿងជាថ្មីឡើងវិញ ។

ពិធីនេះ បានបញ្ចប់ក្រោមស្ទូរស័ព្ទព្រះធម៌ !

**ឱម ខែម**